**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**មហាវិទ្យាល័យអប់រំ**

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន កម្រិតបរិញ្ញាបត្រ

# ចិត្តវិទ្យាអប់រំ



**កញ្ចប់សមត្ថភាពទី១**

**ចំណេះដឹងឯកទេសបរិញ្ញាបត្រ**

# មុខវិជ្ជា៖
# ចិត្តវិទ្យាអប់រំ

## កញ្ចប់សមត្ថភាពទី ១
## ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ

## ការពណ៌នាអំពីមុខវិជ្ជា

មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីឲ្យនិស្សិតស្វែងយល់អំពី សញ្ញាណទូទៅចិត្តវិទ្យា មូលដ្ឋានសរីរៈនៃបាតុភូតចិត្ត ញាណ ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ ការគិត រូបារម្មណ៍ សមាសធាតុនៃសុខភាព សមត្ថភាពចិត្តសង្គម ជំនាញសតវត្សទី២១ របៀបរៀនជំនាញសតវត្សទី២១ជាមួយគម្រោងវិនិយោគ ។

**លទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

លទ្ធផលសិក្សារំពឹងទុកទី ១៖ បរិយាយអំពីបាតុភូតចិត្ត

លទ្ធផលសិក្សារំពឹងទុកទី ២៖ បរិយាយអំពីសមាសភាពសុខភាពចិត្ត

លទ្ធផលសិក្សារំពឹងទុកទី ៣៖ យល់អំពីបំណិនសតវត្សទី២១

លទ្ធផលសិក្សារំពឹងទុកទី ៤៖ ផ្សារភ្ជាប់បំណិនសតវត្សទី២១ទៅនឹងគម្រោងវិនិយោគ

**របាយតម្លៃសិក្សា**

*ដើម្បីបំពេញគ្រប់លក្ខខណ្ឌបញ្ចប់ការសិក្សាមុខវិជ្ជានេះ អ្នកសិក្សាត្រូវ*

១. វត្តមានចូលសិក្សា ១០%

២. ការចូលរួមសកម្មភាពសិក្សា ២០%

៣. ការវាយតម្លៃកំឡុងពេលសិក្សា ៣០%

៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ៤០%

# **អារម្ភកថា**

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងចំណុចចតុកោណទី១ បានកំណត់យក "ការអភិវឌ្ឍធនធានមនុស្ស" មុំទី១ជាវិស័យអាទិភាព។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញដើរតួនាទីយ៉ាងសំខាន់ជាចំណែកមួយនៃការកែទម្រង់វិស័យអប់រំក្នុងការស្តារប្រព័ន្ធអប់រំជាតិឡើងវិញ តាមរយៈការផលិតអ្នកអប់រំដែលមានគុណភាពខ្ពស់។

នៅដើមអាណត្តិទី៦នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ ២០១៨-២០២៣ ដែលមានចក្ខុវិស័យ "កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន"។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងពីតួនាទីយ៉ាងសំខាន់របស់គ្រូបង្រៀនក្នុងវិស័យអប់រំ និងសង្គមជាតិ ដោយបញ្ជាក់ថា "គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ ការអភិវឌ្ឍប្រកបដោយចីរភាព" ដែលប្រែក្លាយប្រទេសមានប្រាក់ចំណូល មធ្យមកម្រិតខ្ពស់ ក្នុងឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍ក្នុងឆ្នាំ២០៥០។

ដើម្បីឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រ និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយនឹងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទទួលភារកិច្ចបន្ថែមទៀត តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំនៅកម្រិតមធ្យមសិក្សា និងបន្តអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅរយៈពេលបួនឆ្នាំបន្តទៀត ចាប់ពីឆ្នាំ២០២២-២០២៦។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាបានដឹកនាំ និងផ្តល់អនុសាសន៍យ៉ាងច្រើន ដែលធ្វើឱ្យគម្រោងប្រព្រឹត្តទៅដោយរលូន និង ជោគជ័យ។

គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សារៀបចំឡើង ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូឯកទេសលើមុខវិជ្ជាគោល៦ តាមគ្រឹះស្ថានមធ្យមសិក្សាគោលដៅ។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបណ្តុះបណ្តាលក្របខណ្ឌកម្មវិធីកម្រិតបរិញ្ញាបត្រអប់រំដល់នាយកសាលារៀន និងគ្រូឯកទេសដែលពុំទាន់មានសញ្ញាបត្របរិញ្ញាបត្រ ឬមានសញ្ញាបត្រខុសឯកទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំនួន១០០ នៅក្នុងគោលដៅគម្រោងនៅប្រទេសកម្ពុជា។ ដើម្បីពង្រីកវិសាលភាពនៃកំណែទម្រង់អប់រំ គម្រោងកែលម្អការអប់រំចំណេះទូទៅ ដែលប្រើប្រាស់យុទ្ធសាស្ត្រសហគមន៍សាលារៀនជាយុទ្ធសាស្ត្រស្នូលក្នុងការអនុវត្ត បានលេចរូបរាងឡើងក្នុងគោលបំណងបណ្តុះបណ្តាលនាយកសាលា និងគ្រូបង្រៀនចំនួនប្រមាណ ១៧០០០ នាក់ ដែលមកពី ១៧០០សាលា ក្នុងអនុវិស័យបី រួមមាន កុមារតូច បឋមសិក្សា និងមធ្យមសិក្សា។ មហាវិទ្យាល័យអប់រំក៏ត្រូវសហការផងដែរ ជាមួយស្ថាប័ន បណ្តុះបណ្តាលគ្រូទាំងអស់ ដើម្បីឈានទៅបង្កើតស្តង់ដាគុណភាពរួមមួយក្នុងការអប់រំគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលាឱ្យបានទូលំទូលាយ។ ដើម្បីឈានទៅសម្រេចបានការអនុវត្តគម្រោងថ្មីនេះ មហាវិទ្យាល័យត្រូវមានយុទ្ធសាស្ត្ររយៈពេលវែងមួយ សម្រាប់ឆ្នាំ ២០២១-២០៣០ ដើម្បីជាមគ្គុទេសបង្ហាញផ្លូវ។

សៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀននេះ បានរៀបចំឡើងជាការឆ្លើយតបជាមួយតម្រូវការដែលអ្នកសិក្សាជានាយក និងគ្រូបង្រៀនក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅដើម្បីធ្វើការស្វ័យសិក្សាលើខ្លឹមសារសំខាន់ៗ នៃយុទ្ធសាស្ត្រសហគមន៍សាលារៀន ដែលការស្វ័យសិក្សានេះបានភ្ជាប់មកជាមួយសំណួរស្វ័យសិក្សា ដែល

បញ្ជាក់ពីកម្រិតយល់ដឹងពីខ្លឹមសារគោលនីមួយៗនៃយុទ្ធសាស្ត្រសហគមន៍សាលារៀន។ តាមរយៈសៀវភៅសិក្សាគោលនេះ អ្នកសិក្សាក្នុងគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) និងគ្រឹះស្ថានបណ្តុះបណ្តាលឯទៀតអាចយកជាប្រយោជន៍ក្នុងការអនុវត្តកំណែទម្រង់សាលារៀន ដែលយកសហគមន៍ជាធនធានគោល ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យឈានទៅរកសាលារៀនជាប់ស្តង់ដាសហគមន៍សាលារៀន។

ទន្ទឹមនឹងនេះ វាជាឯកសារដែលឆ្លុះបញ្ចាំងពីមេរៀន បទពិសោធន៍នៃការអនុវត្ត និងផលសម្រេចជាក់ស្តែង និងជាឯកសាររស់ដែលមានលក្ខណៈបើកទូលាយឱ្យមានការកែលម្អបន្តផ្អែកលើការរៀនពីការអនុវត្ត ដែលនាំមកនូវលទ្ធផលវិជ្ជមាន។ ឯកសារនេះមានខ្លឹមសារ ដែលជាអត្ថប្រយោជន៍សម្រាប់ប្រើប្រាស់ក្នុងពេល ដែលបានអនុវត្តន៍កន្លងមក និងបន្តប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ហើយអាចនឹងប្រើប្រាស់សម្រាប់អនាគត ឬអាចនឹងកែសម្រួលបន្ថែមឱ្យសមស្របតាមកាលៈទេសៈ និងល្បឿននៃការអភិវឌ្ឍក្នុងសង្គមជាតិ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានជំនឿយ៉ាងមុតមាំ ក្នុងការរៀបចំក្របខណ្ឌកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្រោមគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាពិតជាដើរតួនាទីយ៉ាងសំខាន់ និងឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការសាងធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងក្រមសីលធម៌។ យើងនឹងបន្តការខិតខំប្រឹងប្រែងក្នុងការអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) ឱ្យបានកាន់តែប្រសើរជាមួយនឹងសៀវភៅសិក្សាគោលយុទ្ធសាស្ត្រសហគមន៍សាលារៀន និងឧត្តមានុវត្តន៍ផ្សេងៗដែលបានចងក្រង។

ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរចំពោះក្រុមការងារដែលបានខិតខំកសាងក្របខណ្ឌកម្មវិធីឱ្យទទួលបានលទ្ធផលល្អ។

ថ្ងៃ ពុធ ១៤ រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ កក្កដា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

## រចនាសម្ព័ន្ធកម្មវិធីសិក្សា

កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រអប់រំមានចំនួន ៦៣ ក្រេឌីត ដោយបញ្ចូលការសិក្សាលើមុខវិជ្ជាសិក្សា ការចូលរួមវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ការអនុវត្តផ្ទាល់ និងការចងក្រងរបាយការណ៍ស្រាវជ្រាវ។ ដោយសារអ្នកសិក្សាក្នុង កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនបានបំពេញគុណវុឌ្ឍិចំនួន ៦៣ ក្រេឌីត។ (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៣៦ ក្រេឌីត) (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (១២ (+៣) ក្រេឌីត) (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង (១២ ក្រេឌីត)។

ការចូលរួមសិក្ខាសាលាតម្រូវឱ្យនិស្សិត/អ្នកសិក្សារៀនបន្ថែម និងចែករំលែកបទពិសោធអំពីការអនុវត្តការងារនៅសាលារៀន។ ការអនុវត្តផ្ទាល់ គឺភ្ជាប់និស្សិត/អ្នកសិក្សាទៅនឹងការបំពេញកិច្ចការអនុវត្ត ដើម្បីចងក្រងបទពិសោធនៃការបំពេញការងារផ្អែកលើលទ្ធផល។ របាយការណ៍ស្រាវជ្រាវតម្រូវឱ្យនិស្សិត/អ្នកសិក្សាចងក្រងនូវបទពិសោធដែលអនុវត្តការងារប្រកបដោយផលសម្រេច។

| កញ្ចប់សមត្ថភាព | ចំនួនមុខវិជ្ជា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេសកម្រិតបរិញ្ញាបត្រ (៦០%) | ១២ មុខវិជ្ជា | ៣៦ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន (២០%) | ៤(+១) មុខវិជ្ជា | ១២ (+៣) |
| (៣)ហ្វឹកហាត់កម្មសិក្សានិងការអនុវត្តជាក់ស្តែង (២០%) | ៣ មុខវិជ្ជា | ១២ |
| សរុប | ២០ | ៦៣ |

## ក្របខណ្ឌកម្មវិធីសិក្សាបរិញ្ញាបត្រអប់រំ

មុខវិជ្ជាសិក្សាសម្រាប់កម្រិតបរិញ្ញាបត្រអប់រំនេះនឹងជួយឱ្យនិស្សិត/អ្នកសិក្សាបំពេញកញ្ចប់សមត្ថភាពដូចខាងក្រោមដើម្បីឆ្លើយតបនឹងលទ្ធផលសិក្សាកម្មវិធីអប់រំហើយឱ្យនិស្សិត/អ្នកសិក្សាមានសមត្ថភាពសម្រាប់បំពេញការងារប្រកបដោយវិជ្ជាជីវៈ។

| កញ្ចប់សមត្ថភាព | មុខវិជ្ជាសិក្សា | ចំនួនក្រេឌីត |
|---|---|---|
| (១)ចំណេះដឹងឯកទេស កម្រិតបរិញ្ញាបត្រ ៣៦ ក្រេឌីត(៦០%) | ចិត្តវិទ្យាអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះអប់រំ | ៣ |
| | ការប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការអប់រំ | ៣ |
| | ភាសាអង់គ្លេសសម្រាប់ការអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះនៃវង្វាយតម្លៃអប់រំ | ៣ |
| | មូលដ្ឋានគ្រឹះការស្រាវជ្រាវប្រតិបត្តិ | ៣ |
| | វិធីសាស្ត្រស្រាវជ្រាវ | ៣ |
| | ការគ្រប់គ្រងការរៀន និងបង្រៀន | ៣ |

| | | |
|---|---|---|
| | ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសាលារៀននិងរដ្ឋបាលសាលារៀន | ៣ |
| | ការសិក្សាពហុវិន័យនៅមធ្យមសិក្សា | ៣ |
| | ការអប់រំអំពីបម្រែបម្រួលអាកាសធាតុនៅមធ្យមសិក្សា | ៣ |
| | បញ្ញត្តិ និងគោលការណ៍ការអនុវត្តការគ្រប់គ្រងតាមសាលារៀន | ៣ |
| (២)ចំណេះដឹងវិធីសាស្ត្រដឹកនាំ និងការគ្រប់គ្រងតាមសាលារៀន ១២ (+៣) ក្រេឌីត (២០%) | ការគ្រប់គ្រង និងការវិភាគទិន្នន័យអប់រំ | ៣ |
| | ការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអប់រំ | ៣ |
| | ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ | ៣ |
| | ដំណើរការ ការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សា | ៣ |
| | ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀនសម្រាប់មធ្យមសិក្សា | ៣ |
| (៣)ហ្វឹកហាត់កម្មសិក្សា និងការអនុវត្តជាក់ស្តែង ១២ ក្រឌីត (២០%) | ការពិនិត្យតាមដាន និងការវាយតម្លៃគ្រឹះស្ថានសិក្សា | ៣ |
| | ការធ្វើអធិការផ្ទៃក្នុងតាមសាលារៀន | ៣ |
| | ការសរសេររបាយការណ៍ស្រាវជ្រាវ | ៦ |
| សរុប | | ៦៣ |

## លំហូរបង្រៀន និងរៀន

**លំហូរបង្រៀននិងរៀន ១មេរៀន ឬកិច្ចការមួយ រួមជាមួយបំណិនមួយ និងចរិយាមួយ**



## ស្តង់ដាស្តង់ដាគណៈគ្រប់គ្រងសាលារៀននៃយុទ្ធសាស្ត្រសហគមន៍សាលារៀន

**ស្តង់ដាទី១ និង ៤** សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស និង ដំណើរការរដ្ឋបាល និងប្រតិបត្តិការសហគមន៍សាលារៀន។ក្នុងការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀនទាំងអស់ត្រូវបានណែនាំឱ្យអនុវត្តកិច្ចការដូចតទៅ៖

| | |
|---|---|
| ១ | កែលម្អការសិក្សារៀនសូត្ររបស់សិស្សពីថ្នាក់ទី៧ ដល់ទី១២ នាំឱ្យសិស្សអាចទទួលបានកម្រិតល្អ និងល្អប្រសើរលើមុខវិជ្ជាគោល។ |
| ២ | ផ្តោតការសិក្សារបស់សិស្សលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាអទិភាព ពិសេសនៅមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ |
| ៣ | អនុវត្តអនុសាសន៍របាយការណ៍ការគ្រប់គ្រងហរិញ្ញវត្ថុ និងសវនកម្ម។ |
| ៤ | ធ្វើឱ្យការសិក្សាមានភាពបន្ស៊ីគ្នារវាងសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាដើម្បីឈានឆ្ពោះទៅឧត្តមសិក្សា។ |
| ៥ | បង្កើនប្រសិទ្ធផល និងកំណត់មុខសញ្ញាប្រើប្រាស់ធនធាន ដោយផ្តោតលើអទិភាពរបស់សាលារៀនដែលមានមូលដ្ឋានលើយុទ្ធសាស្ត្រ វប្បធម៌ និងគុណតម្លៃ។ |

## ការវាយតម្លៃលើការសិក្សា

ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាគឺផ្តោតលើលទ្ធផលសិក្សាជាគោល។ ការវាយតម្លៃលើការសិក្សាមានបីដំណាក់កាលធំៗ គឺ (១) ការវាយតម្លៃលើការសិក្សាមុខវិជ្ជា (២) ការវាយតម្លៃលើការសរសេររបាយការណ៍ស្រាវជ្រាវ និង (៣) ការវាយតម្លៃសរុបដោយពិនិត្យលើការបំពេញគ្រប់លក្ខខណ្ឌសម្រាប់បញ្ចប់ការសិក្សា។

## គោលការណ៍វាយតម្លៃ

គោលការណ៍រួមសម្រាប់ការវាយតម្លៃលើការសិក្សារបស់និស្សិត/អ្នកសិក្សាមានដូចតទៅ៖

១) និស្សិត/អ្នកសិក្សាតម្រូវឱ្យមានវត្តមានក្នុងការសិក្សាតាមមុខវិជ្ជានីមួយៗ មិនតិចជាង៧០%។ ក្នុងករណីអ្នកសិក្សាមានវត្តមានតិចជាង៧០% នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងបញ្ចប់មុខវិជ្ជានោះទេ។

២) ក្នុងករណីដែលនិស្សិត/អ្នកសិក្សាធ្លាក់មុខវិជ្ជាណាមួយក្នុងឆមាស នឹងមិនអនុញ្ញាតឱ្យបន្តការសិក្សាទៅឆ្នាំបន្ទាប់ និងប្រឡងបញ្ចប់ឡើយ។

៣) និស្សិត/អ្នកសិក្សាទាំងអស់ត្រូវធ្វើកិច្ចការស្រាវជ្រាវសំខាន់ៗតាមមុខវិជ្ជានីមួយៗ និងប្រគល់ជូនគ្រូឧទ្ទេសតាមមុខវិជ្ជាដែលបានកំណត់។

៤) និស្សិត/អ្នកសិក្សាត្រូវប្រឡងបញ្ចប់ការសិក្សាដែលធ្វើឡើងបន្ទាប់ពីចប់ឆមាសនីមួយៗ តាមការកំណត់ក្នុងកម្មវិធីសិក្សា។

៥) និស្សិត/អ្នកសិក្សាត្រូវចងក្រងឯកសារវឌ្ឍនភាពនៃកិច្ចការស្នូលរួមមានការហាត់ការ និងកម្មសិក្សាដែលផ្តោតលើ (ក) សកម្មភាពប្រតិបត្តិ (ខ) លទ្ធផលដែលសម្រេចបាន និង (គ) ការឆ្លុះបញ្ចាំង និងមេរៀនបទពិសោធន៍។

៦) និស្សិត/អ្នកសិក្សាត្រូវតែជាប់មធ្យមភាគនៃការសិក្សាមុខវិជ្ជានិងការធ្វើកម្មសិក្សា ដើម្បីទទួលការអនុញ្ញាតឱ្យការពាររបាយការណ៍ស្រាវជ្រាវ។

## ការផ្តល់ពិន្ទុ និងប្រព័ន្ធចំណាត់ថ្នាក់

និស្សិត/អ្នកសិក្សាអាចទទួលពិន្ទុចាប់ពី 00 ដល់ 100 ទៅតាមការវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងការសិក្សាមុខវិជ្ជា ការបំពេញកម្មសិក្សា និងការសរសេរនិងការការពាររបាយការណ៍។ ពិន្ទុដែលជាប់ត្រូវចាប់ផ្តើមពីមធ្យមភាគពិន្ទុ 50% ឬពិន្ទុនិទ្ទេស 2.00 ឡើងទៅ។

ពិន្ទុគឺកំណត់ពី 00.00 ដល់ 100 (មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប ឬ Grade Point Average – GPA)។ រូបមន្តគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point – P) និងតម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ (Attempted Credit Value – C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

ប្រព័ន្ធចំណាត់ថ្នាក់កម្មវិធី គឺផ្អែកទៅលើតម្លៃនៃពិន្ទុអតិបរមា 100% និង 50% នៃពិន្ទុអប្បបរមា។ ប្រព័ន្ធដាក់ពិន្ទុនេះ ត្រូវបានបកប្រែទៅជា "ពិន្ទុជានិទ្ទេស" និង "ពិន្ទុជាតម្លៃលេខ" ដូចដែលពិពណ៌នាដូចខាងក្រោម៖

| ពិន្ទុជាភាគរយ% | និទ្ទេស | ពិន្ទុនិទ្ទេស | មូលវិចារណ៍ |
|---|---|---|---|
| 85%-100% | A | 4.00 | ល្អប្រសើរ |
| 80%-84% | B+ | 3.50 | ល្អណាស់ |
| 70%-79% | B | 3.00 | ល្អ |
| 65%-69% | C+ | 2.50 | ល្អបង្គួរ |
| 50%-64% | C | 2.00 | មធ្យម |
| <49% | F | 1.50 | ធ្លាក់ |

## គោលការណ៍ប្រតិបត្តិ

ដើម្បីធានានូវការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងភាពស័ក្តិសិទ្ធ មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញអនុវត្តតាមគោលការណ៍ បទបញ្ញត្តិ និងបទដ្ឋានគតិយុត្តិរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយគ្នានេះដែរ និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងឈរលើស្មារតីស្មោះត្រង់ ទទួលខុសត្រូវខ្ពស់ និងភាពម្ចាស់ការ និងគោលការណ៍សុចរិតភាពនៃការសិក្សា។ សម្រាប់គោលការណ៍សុចរិតភាពនៃការសិក្សា និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានវាយតម្លៃលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា**

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិត/អ្នកសិក្សាម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យចាត់តាំង ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្ត ភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងសាលារៀន និងក្រៅសាលារៀន។ ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់និស្សិតម្នាក់ៗ ត្រូវបានធ្វើឡើងតាមរយៈយោបល់ឯកភាពពីមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណសម្បត្តិជាក់ស្តែងរបស់និស្សិត/អ្នកសិក្សាម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ការក្លែងបន្លំឯកសារ**

និស្សិត/អ្នកសិក្សាដែលក្លែងបន្លំឯកសារ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិតដោយស្វ័យប្រវត្តិ ព្រមទាំងទទួលទោសតាមច្បាប់ជាធរមាន។ និស្សិតត្រូវចាំថា ការលួចចម្លងស្នាដៃ ការលួចកម្មសិទ្ធិបញ្ញា និងគំនិតរបស់អ្នកដទៃគឺជាបទល្មើសសិក្សាធ្ងន់ធ្ងរដែលអាចឈានដល់ការបញ្ឈប់និស្សិតដែលប្រព្រឹត្តបទល្មើសពីកម្មវិធី។ និស្សិត/អ្នកសិក្សានឹងត្រូវធ្លាក់ជាស្ថាពរ បើនិស្សិត/អ្នកសិក្សារូបណាចម្លងដោយផ្ទាល់ពីនិស្សិតដទៃទៀត ឬប្រភពផ្សេងៗ ឬការប្រើសម្ភារៈ ឬឯកសារផ្សេងទៀត ដែលមិនត្រូវបានអនុញ្ញាតក្នុងការប្រឡង។

**របាយការណ៍/កិច្ចការស្រាវជ្រាវ**

និស្សិត/អ្នកសិក្សាត្រូវបង្ហាញនូវសុចរិតភាពនៃការស្រាវជ្រាវរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួនចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល។ រាល់សំណេរការងារសិក្សាទាំងអស់ មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗរបស់អ្នកដទៃមកធ្វើជាគំនិតជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឯកសារពិគ្រោះ ឬការអនុញ្ញាតពីម្ចាស់ប្រភព។

ក្នុងករណីរកឃើញមានការលួចចម្លងស្នាដៃអ្នកដទៃ និស្សិត/អ្នកសិក្សានឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សា បច្ចេកទេស និងក្រុមប្រឹក្សាវិន័យរបស់មហាវិទ្យាល័យអប់រំ ឬសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយត្រូវទទួលពិន័យឱ្យរៀនត្រួតថ្នាក់ ឬអាចត្រូវបញ្ឈប់ពីកម្មវិធីដោយគ្មានសំណងប្រាក់សិក្សាដែលបានបង់រួចហើយទេ និងមិនមានការចេញលិខិតស្នាមបញ្ជាក់ការសិក្សាអ្វីដែរ។

**សំគាល់៖** កម្មវិធីបណ្តុះបណ្តាលសូមរក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តជាក់ស្តែងដើម្បីឆ្លើយតបវឌ្ឍនភាពការរៀននិងបង្រៀន សមត្ថភាពរៀន និងអនុវត្តជាក់ស្តែង ស្ថានភាពរៀននិងបង្រៀនជាក់ស្តែង ដើម្បីសម្រេចបានលទ្ធផលសិក្សាល្អបំផុត និងសម្រេចស្តង់ដាសហគមន៍សាលារៀននៃគម្រោង GEIP។

# 0. យល់ដឹងពីសមាសធាតុនៃសុខភាព

3




4

## ១ ការភ្ញាក់ដឹង Awareness

- **ប្រុងប្រយ័ត្ន Attention ឬមួយ មិនរវល់តែម្តង៖** ធ្វើកិច្ចការនីមួយៗប្រកបដោយវិជ្ជាជីវៈ ធ្វើកិច្ចការអោយបានចប់ចុងចប់ដើម និងផ្តោតសម្រេចវត្ថុបំណងនៃកិច្ចការ។ ធ្វើកិច្ចការដោយផ្អែកតែលើទ្រឹស្តី និងឃ្លាតចាកពីការពិតគឺ មានន័យថាធ្វើកិច្ចការសើៗគ្មានការប្រុងប្រយ័ត្ន។
- **ភ្ញាក់ដឹង self-awareness ឬមួយ អញត្រូវរហូត៖** សិក្សាពីអ្វីកើតឡើងនៅក្នុងសាកលលោកទាក់ទងនឹងតួនាទីរបស់ខ្លួន ហើយយកចំណេះដឹងនេះមកឆ្លុះបញ្ចាំងថាខ្លួនកំពុងស្ថិតនៅទីណា ហើយរាល់ពេលនិយាយឬធ្វើកិច្ចការគប្បីផ្តោតលើអ្វីដែលខ្លួនត្រូវធ្វើដើម្បីបំពេញតួនាទីដែលខ្លួនកំពុងទទួល ជាជាងចំណាយពេលគិតនិងត្អូញត្អែរពីអ្នកដ៏ទៃ។

5

## ១ ការភ្ញាក់ដឹង Awareness

- **ចិត្តមេត្តា Meta-awareness ឬមួយ ពេលណាក៏ហឹង្សា៖** បណ្តុះចិត្តអនុគ្រោះនិងអាណិតអាសូរដល់គ្រប់មនុស្ស ដោយការជឿជាក់ថាមនុស្សមិនមែនជាបញ្ហាទេ តែចរិយារបស់គេទេដែលម្តងម្កាលជាបញ្ហា និងស្វែងយល់ថារាល់ពេលបង្កើតកំហឹងនៅក្នុងខ្លួនជានិច្ចកាលជាការធ្វើបាបខ្លួនឯង។ ការយល់ដឹងពីមូលហេតុដែលនាំអោយមនុស្សមានចរិយាជាបញ្ហានឹងនាំអោយអ្នកអាចបណ្តុះចិត្តអនុគ្រោះនិងអាណិតអាសូរ ហើយឈានដល់ការជួយមនុស្សជាជាងការបន្ទោសមនុស្ស។
- **ផ្តោត Focus ឬមួយ អញចេះជាងគេនិយាយតែទ្រឹស្តី៖** ជានិច្ចកាលសួរខ្លួនអ្នកថា "ខ្ញុំអាចធ្វើអ្វីបាននៅថ្ងៃនេះ ដែលនាំអោយមានប្រយោជន៍ដល់សិស្សនិងមន្ត្រីខ្ញុំ? " គប្បីជៀសវាងការត្អូញត្អែរពីអតីតកាល តែជំនួសវិញដោយការគិតពីការរស់នៅថ្ងៃនេះជាមួយអនាគតកាល។ ប្រើពេលដែលអ្នកមានធ្វើកិច្ចការថ្ងៃនេះជាមួយតួនាទីរបស់អ្នកក្នុងបរិបទសាកលលោក។

6

## ២ ផ្សារភ្ជាប់សង្គម Connection

- **ចិត្តល្អ Kindness ឬមួយ ក្រឡិចក្រឡុច៖** បង្ហាញដោយអំពើល្អជួយមនុស្ស អំពើអាចជាសំដី ឬសកម្មភាព។ បើអ្នកជួយមនុស្សបានកាន់តែច្រើន នោះអ្នកនឹងមានមនុស្សច្រើននិយាយជាមួយ ហើយអ្នកនឹងទទួលបាននូវព័ត៌មានពិតជាច្រើនពីមនុស្សទាំងនេះ។ ភាពឯកោនឹងបាត់បង់ អ្នកនឹងរីករាយហើយមានអាយុវែង។
- **អត់អោន Empathy ឬមួយ ជេរប្រមាថ៖** អ្នកមិនគប្បីគិតថានិយាយមួយដង មនុស្សគ្រប់គ្នាយល់ហើយធ្វើកិច្ចការបានត្រឹមត្រូវនោះទេ។ អ្នកគប្បីជួយមនុស្សអោយគេត្រៀមរួចស្រេចមុនពេលធ្វើកិច្ចការមួយ។ បើមានចន្លោះខ្វះខាត ផ្តល់ការអត់អោន ហើយបន្តជួយគេរហូតគេធ្វើកិច្ចការបានប្រសើរ។ អ្នកគប្បីជឿថា ការមិនអត់អោនដល់មនុស្សនឹងបានមកវិញតែការឈឺចាប់តែប៉ុណ្ណោះ។

7

## ២ ផ្សារភ្ជាប់សង្គម Connection

- **រក្សាសភាពវិជ្ជមាន Maintaining a positive outlook ឬមួយ ប្រើអំណាចខុសបែបបទ៖** នេះជាការគ្រប់គ្រងចិត្តរបស់អ្នក ហើយអ្នកអាចរក្សាបាននូវសភាពវិជ្ជមានបាន លុះណាអ្នកហាត់អនុវត្តនូវរបៀបដែលអ្នកទទួលព័ត៌មាន។ បើការទទួលព័ត៌មានក្នុងបរិបទអតីតកាលនោះជាការទទួលព័ត៌មានបែបអវិជ្ជមាន។ តែបើការទទួលព័ត៌មានក្នុងបរិបទអនាគតកាលនោះជាការទទួលព័ត៌មានបែបវិជ្ជមាន។ ឧទាហរណ៍៖ ១ មន្ត្រីម្នាក់នេះមិនទទួលខុសត្រូវធ្វើកិច្ចការមិនបានលទ្ធផល (អតីតកាល) ឬ ២ មន្ត្រីម្នាក់នេះត្រូវការការជួយបំប៉ននិងការដឹកដៃធ្វើកិច្ចការមួយនេះ សង្ឃឹមថាគាត់នឹងមានទឹកចិត្តធ្វើការនៅពេលគាត់ឃើញថាគាត់អាចសម្រេចបាននូវលទ្ធផលពីកិច្ចការមួយនេះ (អនាគត)។ ជាការល្អដែលអ្នកត្រូវរក្សាភាពវិជ្ជមាននេះរហូត ហើយមិនគប្បីបង្ហាញនូវចរិយាអវិជ្ជមានបើទោះបីជាម្តងក៏ដោយ។ បើមានចរិយាអវិជ្ជមានម្តង អាននាំអោយមន្ត្រីមានការងឿងឆ្ងល់ថា តើអ្នកប្រាកដជាមនុស្សបែបណា។

8

# ៣ យល់ពីខ្លួនឯង Insight

- យល់ពីខ្លួន **Self-knowledge** ឬមួយ **រស់តែក្នុងអតីតកាល៖** ជាការកសាងចំណេះដឹងស្វែងយល់ពីខ្លួនឯងរហូត។ ចំណេះដឹងនេះវាទាក់ទងនឹងគ្រប់ចរិយាដែលបានធ្វើនិងបំរុងនឹងធ្វើ។ បើចរិយាបានធ្វើនាំអោយមានអារម្មណ៍មិនស្រួល ត្រូវឆ្លុះបញ្ចាំងឡើងវិញថាត្រូវប្តូរយ៉ាងណាវិញនៅពេលធ្វើលើកក្រោយ។ សម្រាប់ចរិយាបំរុងនឹងធ្វើ ត្រូវគិតច្បាស់ថាវាច្បាស់ជានឹងទទួលបានមកវិញនូវអ្វីដែលអ្នកចង់បានឬទេ តែបើចរិយាបំរុងនឹងធ្វើនោះវានាំមកនូវអ្វីដែលអវិជ្ជមាន នោះអ្នកពុំគប្បីធ្វើវាឡើយ។
- ថយចុះភាពរឹងកំព្រឹស **Decreased stickiness** ឬមួយ **ជាប់សោរខួរក្បាលរហូត៖** អ្នកគប្បីជឿថា អ្នកមិនមែនជាម៉ាស៊ីនដោះស្រាយបញ្ហាទេ បើអ្នកគិតថាអ្នកគិតត្រូវរហូត នោះវានាំអោយទំនាក់ទំនងរបស់អ្នកស្ថិតនៅលើតែចំឡើយតែមួយរបស់អ្នកដែលត្រូវ។ របៀបនេះអ្នកនឹងក្លាយទៅជាមនុស្សរឹងកំព្រឹះ ហើយអ្នកនឹងជួបការលំបាកសម្រាប់ការដឹកនាំសម្រាប់ការផ្លាស់ប្តូរហើយ។ អ្នកអាចបន្ថយភាពរឹងកំព្រឹស បើអ្នកអនុវត្តតួនាទីជាអ្នកដឹកនាំដែលជាមនុស្សពូកែស្តាប់ សម្របសម្រួលអោយមនុស្សពិភាក្សា និងធ្វើការជាមួយគ្នាបាន។

9

# ៣ យល់ពីខ្លួនឯង Insight

- **វិញ្ញាណនាំសុខដល់ខ្លួន Healthy sense of self ឬមួយ អត្មានិយម៖** អ្នកគប្បីភ្ញាក់ដឹងថា ចិត្តខ្មៅ (darkness) អាចងាយជ្រាបចូលក្នុងខ្លួនអ្នកបន្ថែមលើចិត្តខ្មៅដែលអ្នកបានរស់នៅជាមួយវាក្នុងរយៈកាលពាទស្សវត្សនៃសង្គ្រាម តែការស្វែងរកចិត្តភ្លឺថ្លា (light) ជាការលំបាក។ បើអ្នកចំនាយពេលមួយគ្រប់គ្រាន់ព្យាយាមលប់ចិត្តខ្មៅ ហើយជំនួសអោយវិញនូវចិត្តភ្លឺថ្លា នោះអ្នកនឹងមានភាពងាយស្រួលក្នុងការរក្សាចិត្តភ្លឺថ្លា ហើយវានឹងនាំអោយអ្នកបណ្តុះបាននូវវិញ្ញាណនាំសុខដល់ខ្លួន។

10

## ៤ វត្ថុបំណង Purpose

- មានទិសច្បាស់លាស់ Clear direction ឬមួយ រស់តាមទម្លាប់៖ ធ្វើកិច្ចការមួយត្រូវសម្រេចលទ្ធផលមួយ មិនមែនធ្វើកិច្ចការមួយបានចប់ទៅវិញដោយបានធ្វើកិច្ចការមួយនោះទេ។ សន្សំលទ្ធផលប្រាកដចំនួនមួយឬពីរក្នុងមួយឆ្នាំដែលនាំដល់ការសម្រេចផលសិក្សារបស់សិស្សនោះជាការប្រពៃ។ អ្នកគប្បីជឿថាបើធ្វើកិច្ចការច្រើនពេកដដែលៗនឹងនាំអោយបង្កើតឡើងនូវបញ្ហារាប់មិនអស់ហើយរវល់តែដោះស្រាយវា។ តម្រូវការក្នុងសង្គមមិននៅដដែលទេ ការកំណត់ទិសច្បាស់លាស់ហើយធ្វើកិច្ចការចាំបាច់ដើម្បីសម្រេចបានដល់ទិសដៅ នោះអ្នកនឹងអាចឆ្លើយតបបាននូវតម្រូវការសង្គមហើយ។

11

## ៤ វត្ថុបំណង Purpose

- វិញ្ញាណយល់ថាជីវិតហ្នឹងមានន័យ Sense that life has meaning ឬមួយ លង់លក់ជាមួយភាពឯកោ៖ អ្នកជាមនុស្សតែម្នាក់គត់ដែលធ្វើអោយជីវិតអ្នកមានន័យ។ ជីវិតមានន័យលុះណាអ្នកអាចជួយខ្លួនឯងបាននិងជួយមនុស្សជុំវិញអ្នកបាន។ អ្នកជាមនុស្សដូចនេះពេលជួបបរាជ័យក្នុងការងារត្រូវចាត់ទុកថាជារឿងធម្មតា រៀនពីវាហើយជៀសវាងភាពបរាជ័យលើកទី២លើកិច្ចការដដែល។

12

## ៤ វត្ថុបំណង Purpose

- គ្រប់ចរិយាប្រចាំថ្ងៃមានវត្ថុបំណងច្បាស់លាស់ **Every day tasks aligned with purpose** ឬមួយ គ្រប់គ្រាន់ជាមួយចរិយាដែលប្រើហឹង្សាជាមូលដ្ឋាន៖ នៅពេលជួយចំណោទឬបញ្ហា សំនួរគន្លឹះអ្នកត្រូវសួរខ្លួនឯងគឺ ទី១ តើអ្នកប្រាកដចង់បានអ្វីពីចំណោទឬបញ្ហាមួយនេះ និងទី២ សួរខ្លួនអ្នកថា តើត្រូវធ្វើអ្វីដើម្បីទទួលនូវអ្វីដែលអ្នកចង់បាន។ ឧទាហរណ៍ពីចំណោទទី១ មនុស្សម្នាក់ជេរមនុស្សម្នាក់ទៀតមិនឈប់រយៈពេលពីរថ្ងៃកន្លះ  មនុស្សដែលត្រូវគេជេរសួរចំនួរទី១ដល់ខ្លួនឯងថា តើចង់បានអ្វីពីចំណោទមួយនេះ ចំឡើយគឺ មិនចង់បានអ្វីទាំងអស់ពីអ្នកជេរនោះដោយសារគាត់នោះមិនមានអ្វីជាផ្លូវការទាក់ទងនិងអ្វីដែលគាត់ជេរ រួចបន្តសួរសំនួរទី២ តើត្រូវធ្វើអ្វីចំពោះការជេរនោះ ចំឡើយគឺ មិនចាំបាច់ត្រូវធ្វើអ្វីទាំងអស់ ព្រោះអ្នកមិនចង់បានអ្វីពីចំណោទនេះផង។ ប្រាំមួយខែក្រោយអ្នកជេរចង់មកនិយាយជាមួយអ្នកត្រូវគេជេរ តែមិនហ៊ានមកជួបដោយសារខ្លាចអ្នកត្រូវគេជេរខឹង គាត់ស៊ើបសួរគេឯង ហើយទីបំផុតគាត់ដឹងថាអ្នកត្រូវគេជេរមិនបានខឹងជាមួយកាត់ទេ ដូចនេះគាត់ក៏សុំមកជួបអ្នកត្រូវកាត់ជេរ។ ទំនាក់ទំនងរវាងមនុស្សទាំងពីរបានចាប់ផ្តើមជាធម្មតា។

13

# សមត្ថភាពសិស្សត្រូវទទួលបាន

14

## កសាងសិស្សម្នាក់ដែលអាចរស់ក្នុងសតវត្សទី២១




### ចរិយាថៃកូនរបស់មាតាបិតានិងគ្រូបង្រៀន

កូនដែលបានទទួលការស្រឡាញ់និងក្លាយជាមនុស្សដែលស្រឡាញ់មនុស្សផង ទាំងពួង

កូនដែលបានទទួលការគោរពនិងក្លាយជាមនុស្សគោរពអ្នកដទៃ

កូនដែលបានទទួលការថៃទាំមានសមភាពនិងក្លាយទៅជាមនុស្សមានយុត្តិធម៌

កូនដែលត្រូវបានមាតាបិតាស្តាប់និងក្លាយជាអ្នកពូកែស្តាប់

កូនដែលបានទទួលនូវជម្រើសនិងធ្វើការសម្រេចចិត្តដោយខ្លួនឯងនិងក្លាយទៅជាមនុស្សទទួលខុសត្រូវនិងមានឯករាជ្យភាព

កូនដែលបានទទួលនូវសេចក្តីសណ្តោសនិងក្លាយទៅជាមិត្តដ៏ល្អ

កូនដែលមានឱកាសអនុវត្តបំណិនសង្គមនិងការងារនិងមានពិសោធន៏រស់នៅ

កូនដែលបានទទួលនូវចរិយាទាំងអស់ខាងលើនិងក្លាយទៅជាអ្នកដឹកនាំ

15

ចរិយាមួយណាអ្នកចង់ធ្វើ និងមានន័យដូចម្តេច

- ការស្រឡាញ់ ជាការផ្តល់អោយដោយមិនទាមទារ
- ការគោរព ជាការរក្សាតម្លៃបុគ្គលខ្លួនជាមនុស្ស
- ការថៃទាំមានសមភាព ជាការផ្តល់អោយស្មើគ្នានូវតម្រូវការមូលដ្ឋានសម្រាប់មនុស្ស
- បានមាតាបិតាស្តាប់ ជាការទទួលយកនូវការពិតរបស់កូន
- បានទទួលនូវជម្រើស ជាការផ្តល់ឱកាសអោយកូនគិតនិងពិចារណា
- ធ្វើការសម្រេចចិត្តដោយខ្លួនឯង ជាសិទ្ធិអំណាចកូនឈានឆ្ពោះទៅរកឯករាជភាព និងម្ចាស់ការ ក្នុងការជួយខ្លួនឯងនិងជួយអ្នកដទៃ
- បានទទួលនូវសេចក្តីសណ្តោស ជាការបង្ហាញនូវមេត្តានិងករុណា
- មានឱកាសអនុវត្តបំណិនសង្គមនិងការងារ ជាការបង្ហាញនូវការទុកចិត្តរបស់អ្នកអោយកូនរស់នៅជាមួយការពិតនៃសង្គម
- ចរិយារបស់អ្នកខាងលើនឹងជួយកូនអោយរស់ជាមួយនឹងជីវិតរីករាយហើយ

16




17

# សមត្ថភាពចិត្តសង្គម OECD

18

| តារាងក្របខ័ណ្ឌសមត្ថភាពចិត្តសង្គមរបស់OECD ចែកចេញជាប្រាំសំណុំ ប្ចូក មួយ៖ | | *សញ្ញាប៉ះទង្គិចអារម្មណ៍* |
|---|---|---|
| ១. សមត្ថភាពអនុវត្តការងារ | ការផ្តោតលើការសម្រេចលទ្ធផល *កំណត់ស្តង់ដាខ្ពស់សម្រាប់ខ្លួនគេ និងប្រឹងប្រែងធ្វើកិច្ចការដើម្បីសម្រេចស្តង់ដា*<br>ការទទួលខុសត្រូវ *ផ្តល់កិត្តិយសលើការប្តេជ្ញាចិត្ត និង ជាមនុស្សទៀងទាត់ពេលវេលា និងជឿជាក់បាន*<br>ការត្រួតពិនិត្យខ្លួនឯង *ជៀសវាងអ្វីដែលនាំរំខាន និងផ្តោតលើកិច្ចការបច្ចុប្បន្ន ដើម្បីសម្រេចគោលបំណងជីវិត*<br>ការតស៊ូ *តស៊ូធ្វើកិច្ចការ និងសកម្មភាពទាំងអស់រហូតធ្វើបានសម្រេច* | *សញ្ញាប៉ះទង្គិចអារម្មណ៍៖*<br>▪ *ទុក្ខព្រួយ*<br>▪ *ខឹង*<br>▪ *មិនខ្វីធ្វើដឹង* |

19

| តារាងក្របខ័ណ្ឌសមត្ថភាពចិត្តសង្គមរបស់OECD ចែកចេញជាប្រាំសំណុំ ប្ចូក មួយ៖ | | ការប៉ះទង្គិចអារម្មណ៍ |
|---|---|---|
| ២. ការធ្វើឱ្យមានលំនឹងផ្លូវចិត្ត | ការប្រឆាំងទប់ការតានតឹងអារម្មណ៍ *ប្រកាន់ចរិយាស្រទន់ចំពោះភាពអន្ទះសារ និងដោះស្រាយបញ្ហាដោយស្ងប់ស្ងាត់ (មានភាពធូរស្រាល និងទប់ទល់ជាមួយការតានតឹងអារម្មណ៍បានប្រសើរ)*<br>សុទិដ្ឋិនិយម(មានជំនឿតែលើអ្វីដែលល្អនិងភាពរីករាយ) *ប្រកាន់ចរិយាវិជ្ជមាន និងមានសង្ឃឹមលើអ្វីដែលល្អ និងភាពរីករាយសម្រាប់ខ្លួន និងជីវិតជាទូទៅ*<br>ការគ្រប់គ្រងចិត្តអារម្មណ៍ *បានរៀបចំយុទ្ធសាស្ត្រផ្លូវចិត្តប្រកបដោយប្រសិទ្ធិភាព ទប់ទល់ជាមួយ កំហឹង ភាពក្រោធខឹង និងសេចក្តីក្តៅក្រហាយនិងមួម៉ៅ* | *សញ្ញាប៉ះទង្គិចអារម្មណ៍៖*<br>▪ *ភ័យខ្លាច*<br>▪ *ខ្មាស់* |

20

| | | |
|---|---|---|
| ៣. កិច្ចសហប្រតិបត្តិការ | **ការយល់ចិត្ត** *មានចិត្តល្អនិងយកចិត្តទុកដាក់នឹងអ្នកដទៃ និងសុខមាលភាពរបស់គេ ដែលនាំឱ្យគេ ផ្តល់តម្លៃ និងវិនិយោគលើទំនាក់ទំនងមិត្តភាពជិតស្និត*<br>**ការទុកចិត្ត** *គិតថាអ្នកដទៃមានបំណងល្អ និងអនុគ្រោះដល់អ្នកដែលមានចរិយាបង្ករគ្រោះថ្នាក់*<br>**ការសហការណ៍** *រស់ដោយភាពចុះសម្រុងគ្នា និងផ្តល់តម្លៃដល់ភាពទំនាក់ទំនងផ្លូវចិត្តក្នុងចំណោមមនុស្សទាំងអស់* | ***មានផ្ទុំពាគសញ្ញាផ្លូវចិត្ត៖***<br>▪ ***ពិបាកនិយាយគ្នា***<br>▪ ***ចរិយាច្រឡោតគោតក្លូង*** |

21

| | | |
|---|---|---|
| ៤. មានសតិអារម្មណ៍បើកទូលាយ | **អត់ធ្មត់** ***មានចិត្តបើកទូលាយចំពោះទស្សនៈផ្សេងៗខុសៗគ្នា ផ្តល់តម្លៃដល់ភាពផ្សេងៗទីទៃពីគ្នា មានភាពពេញចិត្តជាមួយមនុស្ស និងវប្បធម៌ដែលខុសៗគ្នា***<br>**ប្រឌិតញាណ** ***បង្កើតវិធីថ្មីៗសម្រាប់ ធ្វើការងារ និង ការគិត ពីស្ថានភាពមួយ តាមរយៈ ការរិះរក រៀនសូត្រពីបរាជ័យ ការយល់ឃើញ និងទស្សនៈវិស័យ***<br>**ភាពចង់យល់ចង់ដឹង** ***មានចំណាប់អារម្មណ៍ចំពោះគំនិតច្រើន និងស្រឡាញ់ការរៀនសូត្រ ការស្វែងយល់ដឹង ការរិះរកបន្ថែមសមត្ថភាពបញ្ញា ជាអ្នកសួរច្រើននិងចង់ដឹងចង់ឮ*** | ***មានផ្ទុំពាគសញ្ញាផ្លូវចិត្ត៖***<br>▪ ***យល់សប្តិអាក្រក់***<br>▪ ***ស្ទើរដេកស្ទើរភ្ញាក់*** |

22

| | | |
|---|---|---|
| ៥. ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ | ចងមិត្តភាពក្នុងសង្គម *ស្វែងជួបមនុស្សច្រើន ទាំងមិត្តភក្តិ និងមនុស្សចម្លែក បង្កើត និងរក្សាបាននូវទំណាក់ទំនងសង្គម*<br>ការការពារអះអាង *បញ្ជាក់នូវយោបល់ តម្រូវការ និងអារម្មណ៍ជាមួយភាពជឿជាក់ខ្លួនឯង ប្រើប្រាស់ចំណេះដឹងដែលមានឥទ្ធិពលសង្គម*<br>មានហ៊ាមពល *ប្រើប្រាស់ជីវិតប្រចាំថ្ងៃប្រកបដោយហ៊ាមពល សេចក្តីរំភើប និងប្រព្រឹត្តដោយឯកឯង* | *សញ្ញាប៉ះទង្គិចដល់ដំណើរសរីរសាស្ត្រ*<br>▪ *ចង្អោ*<br>▪ *វិលមុខ*<br>▪ *លំនាំនៃការដេកមានការប៉ះទង្គិច*<br>▪ *ផ្លាស់ប្តូរការឃ្លានអាហារ*<br>▪ *ឈឺក្បាល*<br>▪ *បញ្ហាដំណើរការក្រពះពោះវៀន* |



| | | |
|---|---|---|
| ៦. បំណិនលាយសមត្ថភាពបញ្ចូលគ្នា | ជឿជាក់ថាខ្លួនមានប្រសិទ្ធិភាព *ជឿជាក់លើសមត្ថភាពរបស់ខ្លួនថា អាចធ្វើកិច្ចការ និងសម្រេចគោលបំណងបាន*<br>ការគិតជាក់លាក់ *វាយតម្លៃ និងបកស្រាយព័ត៌មាន ដោយឯករាជ្យ និងមិនាការរាំងស្កាត់*<br>ការយល់ដឹងឬញាណមានមេត្តា *ដឹងថាសតិរបស់ខ្លួនមានដំណើរយ៉ាងណា ជាមួយនឹងពិសោធន៍គ្រប់គ្រងសតិរបស់ខ្លួន ដូចជា ការរិះគិត ការមានអារម្មណ៍ថាត្រូវគេបំពាន ការជឿជាក់ខ្លាំងពេកលើការសម្រេចចិត្តរបស់ខ្លួន ហើយ ឆ្លុះបញ្ចាំងសតិនេះថាខ្លួនមានការប៉ះទង្គិចយ៉ាងណា និងប្រើវាតាមពិសោធន៍របស់ខ្លួន ដើម្បីជៀសវាងបាននូវសតិឈឺរបស់ខ្លួន* | *ឈានទៅដល់មានសញ្ញាវិបត្តិចិត្តវិទ្យាៈ*<br>▪ *វិបត្តិតានតឹងអារម្មណ៍ក្រោយការប៉ះទង្គិចអារម្មណ៍*<br>▪ *ទុក្ខព្រួយគ្រាំគ្រាក្នុងចិត្ត*<br>▪ *ភាពអន្ទះអន្ទែង*<br>▪ *វិបត្តិបំបែកបំបាក់ដកខ្លួនចេញពីគេ*<br>▪ *បញ្ហាទទួលរងនូវថ្នាំញៀណ* |

| ភាពទាក់ទងគ្នានៃសមត្ថភាពចិត្តសង្គមរបស់ប្រទេស OECD | | |
|---|---|---|
| *អនុវត្តជាប់ជាប្រចាំ៖*<br>• ការត្រួតពិនិត្យខ្លួនឯង<br>• ការទទួលខុសត្រូវ<br>• ការសហការណ៍គ្នា | *ផ្តល់ចំឡើយតប៖*<br>• មានសង្ឃឹមភាពរហូត<br>• ផ្តោតលើការសម្រេចការងារ<br>• *ផ្តោតលើប្រសិទ្ធិភាពរបស់ខ្លួន* | *ចាប់យកឱ្យបាននូវការចាប់អារម្មណ៍៖*<br>• ចង់ដឹងចង់យល់<br>• រក្សាឋាមពល |
| *សេចក្តីសង្ឃឹមកំណត់ទុកជាមុន៖*<br>• ត្រួតពិនិត្យខ្លួនឯង<br>• ទទួលខុសត្រូវ<br>• សហការណ៍គ្នា<br>• *ផ្តោតលើប្រសិទ្ធិភាពរបស់ខ្លួន* | *សម្របចរិយាឬការបង្រៀន៖*<br>• មានសង្ឃឹមភាពរហូត<br>• ផ្តោតលើការសម្រេចការងារ<br>• *ផ្តោតលើប្រសិទ្ធិភាពរបស់ខ្លួន* | *ប្រឈមរវាងភាពខុសគ្នា និងភាពរឹងកំព្រឹស៖*<br>• *អត់ធ្មត់*<br>• *សុទ្ធិដ្ឋិនិយម(មានជំនឿតែលើអ្វីដែលល្អនិងភាពរីករាយ)* |

25

| ភាពទាក់ទងគ្នានៃសមត្ថភាពចិត្តសង្គមរបស់ប្រទេស OECD | | |
|---|---|---|
| *ជំរុញអនុវត្តបន្តរជាប់ជាប្រចាំជាមួយសេចក្តីសង្ឃឹមកំណត់ទុកជាមុន៖*<br>• ត្រួតពិនិត្យខ្លួនឯង<br>• ប្រឆាំងទប់នឹងការតាមតឹងអារម្មណ៍ | *ហាត់កម្មសិក្សា និងអនុវត្ត៖*<br>• ផ្តោតលើប្រសិទ្ធិភាពរបស់ខ្លួន | *សាងសង់ទំនាក់ទំនង មិត្តភាព៖*<br>• *យល់ចិត្ត*<br>• *សុទ្ធិដ្ឋិនិយម(មានជំនឿតែលើអ្វីដែលល្អនិងភាពរីករាយ)*<br>• *សហការណ៍គ្នា*<br>• *ទុកចិត្តគ្នា* |
| *ពិនិត្យថាខ្លួនយល់ឬនៅ៖*<br>• ផ្តោតលើប្រសិទ្ធិភាពរបស់ខ្លួន<br>• សហការណ៍គ្នា<br>• *សង់សមត្ថភាពចុះសម្រុងជាមួយសង្គម*<br>• *ការការពារអះអាង* | *ការបង្កើនសមត្ថភាពការគិតកាន់តែស៊ីជម្រៅ៖*<br>• គិតជាកលោក<br>• ការការពារអះអាង<br>• *បើកចំហរផ្លូវចិត្តនិងសតិ*<br>• *ប្រឌិតញាណ បង្កើតគំនិតថ្មី* | |

26


ភាពក្រីក្រទាំង៣
ក្រីក្ររៀនសូត្រ
ក្រីក្រលុយ
ក្រីក្រសង្គម

27


មិនចេះអាន
រៀនអាន
អានដើម្បីរៀន
រៀនពីរបៀបរៀន
លំហូរនៃការរៀនសូត្រ និងការសិក្សាតាមកម្រិតសមត្ថភាព

28

បើមិនស្គាល់ តួអក្សរនិងស្រះ អានពាក្យមេចកើត

អានពាក្យមិនកើត តើអានឃ្លាខ្លីមេចបាន

អានឃ្លាខ្លីមិនបាន តើអានឃ្លាវែងមេចបាន

អានឃ្លាវែងមិនបាន តើអានកថាខ័ណ្ឌមេចបាន

អានកថាខ័ណ្ឌបាន តែអានយឺត អានរំលងពាក្យ នាំភ្លេចពាក្យខាងដើមកថាខ័ណ្ឌ
តើអាចយល់អត្ថបទមេចបាន

អានមានល្បឿនតាមស្តង់ដាកំណត់ជាចំនួនពាក្យក្នុង១នាទី ទើបអាចយល់អត្ថបទបាន
យល់អត្ថបទបាន ទើបអាចអានដើម្បីរៀនបាន

ហើយឈានដល់កសាងសមត្ថភាពវិភាគ ដោយការប្រមូលនិងប្រើប្រាស់ព័ត៌មានច្រើនប្រភេទបញ្ចូលគ្នា

*នៅទីបញ្ចប់ទើបសិស្សអាចរៀនពីរបៀបរៀនបាន*

29

បើមិនចេះលេខ តើអាចធ្វើវិធីបូកបានទេ

បើមិនចេះបូកលេខ តើអាចធ្វើវិធីដកលេខមេចទៅ

បើមិនចេះមេលេខ តើធ្វើវិធីគុណលេខមេចទៅ

បើមិនចេះមេលេខ និងមិនចេះគុណលេខ តើធ្វើវិធីចែកលេខមេចបាន

បើមិនចេះគិតលេខ តើអាចរៀនមុខវិជ្ជា វិទ្យាសាស្ត្រ (រូបវិទ្យា ជីវៈវិទ្យា គីមីវិទ្យា) មេចកើតទៅ

បើមិនចេះមុខវិជ្ជាវិទ្យសាស្ត្រ តើរៀនជាវិស្វករមេចបាន

*ហើយបើចេះ អក្សរសាស្ត្រ ដែលជាការប្រើ ភាសា បូកផ្សំជាមួយការវិភាគទិន្នន័យ សិស្សអាចក្លាយជាមនុស្សវិទ្យាសាស្ត្រសង្គម ឬជាអ្នកដឹកនាំនិងគ្រប់គ្រងបាន*

*បើមានសមត្ថភាពសង្គម និងវិទ្យាសាស្ត្រ សិស្សអាចក្លាយជាអ្នកវិទ្យាសាស្ត្រពិតបាន*

30


អានមុនមកថ្នាក់
អាន ជាលក្ខ័ណ្ឌ
អានជាការប្រកួត
អានលឿន និងយល់
របៀប និងល្បិចបង្រៀន

31


ជំនាញសតវត្សទី២១
បញ្ញា ចេះគិត ដោះស្រាយ បញ្ហា សម្រេច ចិត្ត
ជំនាញ យល់ និងប្រើទ្រឹស្តី ក្នុងការងារនិង ជីវិត
ចរិយា ផ្តោត លើការងារ និង សីលធម៌
មេត្តា គុណធម៌ រៀនរហូត ជា មនុស្សពេញ លេញ រីករាយ

32

## របៀបរៀនជំនាញសតវត្សទី២១ ជាគម្រោងវិនិយោគ




33

*វិធីសាស្ត្របង្រៀននិងរៀន តាមម៉ូដែលប្រទេសហ្វាំងឡង់ បែបប្រទេសខ្មែរ*

យោងតាមពិសោធន៍ប្រទេសហ្វាំងឡង់ សមត្ថភាពគោលរបស់សិស្សប្រទេសកម្ពុជាអាចមានដូចខាងក្រោម ហើយមហាវិទ្យាអប់រំបានយកជាគោលក្នុងកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន៖

១) ការគិត និងការរៀនសូត្រពីរបៀបរៀនសូត្រ
២) អក្ខរកម្មវប្បធម៌ និងសុជីវធម៌ ទំនាក់ទំនង និងការថែទាំកុមារ
៣) ការគ្រប់គ្រងជីវិតប្រចាំថ្ងៃ ការថែទាំខ្លួន និងការរស់មានសុខមាលភាព
៤) អក្ខរកម្មមុខវិជ្ជាចម្រុះ
៥) ភាសាបរទេស និងបំណិនព័ត៌មានវិទ្យា
៦) បំណិនមុខរបរ និងការងារ
៧) ការចូលរួម និងកសាងការទទួលខុសត្រូវសង្គមសម្រាប់អនាគតមាននិរន្តរភាព

34

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុកៈ**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹងៈ*

កិច្ចការទី ១ៈធ្វើផែនការគម្រោងវិនិយោគស្បៀងដោយប្រើប្រាស់ទ្រឹស្តីចិត្តវិទ្យា។

កិច្ចការទី ២ៈ របាយការណ៍ភាពរីកចម្រើននៃការអនុវត្តជាក់ស្តែងនូវគម្រោងវិនិយោគ ដោយប្រើប្រាស់ទ្រឹស្តីចិត្តវិទ្យា។

កិច្ចការទី ៣ៈ របាយការណ៍វិភាគផលផលិត ចំណូល ចំណាយនិងការសន្សំ កំហុសកើតមាននិងហេតុផល សកម្មភាពជាដំណោះស្រាយនិងការកសាងផែនការវិនិយោគបន្ទាប់ទៀត។

កិច្ចការទី ៤ៈរបាយការណ៍ពិនិត្យតាមដាន វាយតម្លៃគម្រោងស្បៀងដោយមានការដាក់បញ្ចូលបំណិនសតវត្សទី២១។

កិច្ចការទី ៥ៈ របាការណ៍ផ្សព្វផ្សាយនៃការអនុវត្តគម្រោងវិនិយោគស្បៀងដោយបញ្ចូលបំនិនសតវត្សទី២១ និងបាតុភូតចិត្ត

# ផ្នែកទី១

# ចិត្តវិទ្យាទូទៅ

# មេរៀនទី១ សញ្ញាណទូទៅចិត្តវិទ្យា

## I- ទស្សនៈ

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីបញ្ញត្តិចិត្តវិទ្យា បាតុភូតចិត្ត និងធម្មជាតិនៃបាតុភូតចិត្តរបស់មនុស្ស
- កំណត់បានពីសារសំខាន់នៃសញ្ញាណទូទៅចិត្តវិទ្យា
- មានស្មារតីយកចិត្តទុកដាក់ក្នុងការសិក្សាពីចិត្តវិទ្យា ដោយមានជំនឿជាក់លើការអប់រំ ជាកត្តាកំណត់វាសនាមនុស្ស ។

## II- សេចក្តីផ្តើម

ចិត្តវិទ្យា ជាមាតាលើគ្រប់វិស័យ ជាមុខវិជ្ជាដែលមានសារៈប្រយោជន៍ដែលមនុស្សគ្រប់រូបចាំបាច់ត្រូវយល់ដឹងអំពីមុខវិជ្ជានេះឱ្យបានច្បាស់លាស់។

## III- ខ្លឹមសារ

### ក. និយមន័យ៖

ចិត្តវិទ្យាជាវិទ្យាសាស្ត្រ ដែលសិក្សាពីបាតុភូតចិត្ត និងក្រឹត្យក្រមនៃការកកើតចិត្ត ។

មុខវិជ្ជានេះសិក្សាពីឥរិយាបថរបស់មនុស្ស ដើម្បីពណ៌នា សាកល្បងពន្យល់ ព្យាករណ៍ទុកពីរបៀបនៃការគិត លំនាំកាយវប្បកម្ម ការអភិវឌ្ឍផ្នែកបញ្ញា ចំណេះដឹងសង្គម សីលធម៌ ចិត្តរំភើប បុគ្គលិក លក្ខណៈ និងការរស់នៅរបស់មនុស្ស ហើយស្ថិតនៅលើព្រំដែនទំនាក់ទំនងជាមួយវិទ្យាសាស្ត្រធម្មជាតិ និងវិទ្យាសាស្ត្រសង្គម ។

ចិត្តវិទ្យា ជាវិទ្យាសាស្ត្រព្រោះ ៖

- មានកម្មវត្ថុសិក្សាច្បាស់លាស់
- មានវិធីសិក្សាជាក់លាក់
- នាំមកនូវផលប្រយោជន៍ដល់សង្គមមនុស្ស ។

១- កម្មវត្ថុសិក្សាចិត្តវិទ្យា៖ គឺសិក្សាពីបាតុភូតចិត្តរបស់មនុស្ស ។

ឧទាហរណ៍ ៖

- ពេលឃើញផ្កាម្លិះ យើងដឹងថាមានក្លិនក្រអូប
- ពេលឮសំឡេងនៅលើផ្ទៃអាកាស យើងអាចដឹងថាមានយន្តហោះ
- ការខិតខំរៀនសូត្រ អាចឱ្យគេដឹងថាទៅថ្ងៃអនាគតនឹងមានសុភមង្គលក្នុងជីវិត
- ការឱ្យតម្លៃបេតិកភណ្ឌជាតិ គឺបញ្ជាក់ចរិតមនសិការជាតិ... ។

ដឹងក្លិនក្រអូប ដឹងថាមានយន្តហោះ ដឹងថាមានសុភមង្គល ចរិតមនសិការជាតិ ទាំងនេះគឺជាបាតុភូតចិត្ត។

### ១.១. បាតុភូតចិត្ត

បាតុភូតចិត្ត ជាបាតុភូតទាំងឡាយដែលប្រព្រឹត្តទៅនៅក្នុងខួរក្បាលរបស់មនុស្ស និងសម្តែងចេញមកខាងក្រៅវិញតាមរយៈទឹកមុខ ពាក្យសម្តី អាកប្បកិរិយា អំពើ និងសកម្មភាព ។

ឧទាហរណ៍៖ សិស្សដែលយល់ខ្លឹមសារមេរៀនច្បាស់លាស់ នោះគេសម្តែងចេញនូវភាពអង់អាចមានទឹកមុខញញឹមញញែម ។ ផ្ទុយទៅវិញ សិស្សដែលមិនសូវយល់ខ្លឹមសារមេរៀនច្រើនមានទឹកមុខ ស្លេកស្លាំង និងមានការលាក់លៀមខ្លួនឯង ។

### ១.២. លក្ខណៈ ពិសេសនៃបាតុភូតចិត្ត

#### ១.២.១. លក្ខណៈ ពិសេសទី១ (បាតុភូតសតិអារម្មណ៍)

ជាបាតុភូតមួយដែលកើតឡើងដោយការទទួលអារម្មណ៍ សន្សំ ត្រិះរិះ និងពិចារណានូវអារម្មណ៍ដែលធ្លាប់បានទទួលតាមរយៈឥន្ទ្រីយ៍ទាំង ៥ (ចក្ខុ សោត ឃាន ជីវ្ហា កាយវិញ្ញាណ) ព្រោះយើងមិនអាចស្ទាប ប៉ះពាល់ វាស់វែង រាប់ចំនួននៃបាតុភូតនោះបានទេ ។

យើងអាចសិក្សាបាតុភូតចិត្តបានដោយប្រយោលពីខាងក្រៅខ្លួនដូចជា តាមរយៈការសង្កេតទៅលើកាយវិការ ទឹកមុខ ពាក្យសម្ដី សកម្មភាព ។

ឧទាហរណ៍៖ ភាពមានវិបត្តិធ្វើឱ្យមនុស្សមានទឹកមុខក្រៀមក្រំ ។

#### ១.២.២. លក្ខណៈ ពិសេសទី២ (ឥទ្ធិពលរបស់បាតុភូតចិត្ត)

បាតុភូតចិត្តជាបាតុភូតទទួលអារម្មណ៍ សន្សំអារម្មណ៍ ត្រិះរិះនូវអារម្មណ៍ ឬពិចារណានូវអារម្មណ៍ទាំងឡាយដែលធ្លាប់បានទទួលពីមជ្ឈដ្ឋានជុំវិញខ្លួនរាល់ថ្ងៃក្នុងជីវិតរស់នៅ ។ ដូច្នេះអារម្មណ៍ដែលទទួលបានតាមរយៈឥន្ទ្រីយ៍ទាំង៥ គឺជាប្រភពនៃ«សញ្ញា» ដែលធ្វើឱ្យយើងដឹងទទួលនូវសព្វេតនាសប្បាយរីករាយពេញចិត្ត ហើយអារម្មណ៍ខ្លះទៀតធ្វើឱ្យយើងទុក្ខសោក ឬមិនពេញចិត្ត ជួនកាលទទួលអារម្មណ៍ឈឺចាប់ (សព្វេតនាទុក្ខព្រួយ)រហូតមានការធ្វើអត្តឃាតខ្លួនឯងក៏មាន (ដូចជាសិស្សខ្លះប្រឡងធ្លាក់មិនព្រមបរិភោគអាហារ) ។ ប៉ុន្តែជីវិតមនុស្សខ្លះមិនសូវជួបការលំបាកប៉ុន្មានទេ ។ ដូច្នេះឥន្ទ្រីយ៍ទាំង៥របស់គេជួបតែអារម្មណ៍សុខ ធ្វើឱ្យសព្វេតនា ចិត្ត របស់គេរីករាយមានសុភមង្គលដែលយើងហៅថាមនុស្សមានសុខភាពផ្លូវចិត្តល្អ នាំឱ្យសុខភាពផ្លូវកាយក៏ល្អផងដែរ ។ ដោយហេតុថាមុខងាររបស់ចិត្តតម្រង់ទិសដឹកនាំ និងជំរុញទៅលើអំពើ និងសកម្មភាពរបស់មនុស្ស ។

ដោយមានបាតុភូតចិត្តនេះហើយ បានជាពេលគ្រូពន្យល់មេរៀនធ្វើឱ្យសិស្សមានការប្រុងប្រយ័ត្នស្ដាប់ ដោយយកចិត្តទុកដាក់ និងធ្វើការត្រិះរិះពិចារណារាល់បញ្ហាសំខាន់ៗនៃមេរៀននីមួយៗ ។

រួមសេចក្ដីមក ឥទ្ធិពលរបស់បាតុភូតចិត្តមានសារៈសំខាន់ក្នុងជីវភាពរស់នៅ ក្នុងការសិក្សា ក្នុងការលេងល្បែងកំសាន្ត និងក្នុងទំនាក់ទំនងរវាងមនុស្ស និងមនុស្សក្នុងសង្គម។

### ២. វិធីសិក្សាបាតុភូតចិត្ត

ដើម្បីសិក្សាពីបាតុភូតចិត្ត គេអាចប្រើវិធីជាច្រើនដូចជា វិធីសង្កេត វិធីពិសោធ វិធីសន្ទនា វិធីធ្វើតេស្ត វិធីសិក្សាពីលទ្ធផលនៃសកម្មភាព វិធីវិភាគប្រវត្តិរូប វិធីសង្កេតដោយសរសេរ។ល។

ក្នុងចំណោមវិធីទាំងអស់នេះ យើងលើកយកមកបង្ហាញនូវវិធីខ្លះៗដូចជា៖

- **វិធីសង្កេត ៖** វិធីដែលគេប្រើច្រើនជាងគេក្នុងចិត្តវិទ្យា។ វិធីនេះសិក្សាពីសកម្មភាពនានា តាមរយៈការសង្កេតលើកាយវិការ ទឹកមុខ ពាក្យសម្ដី។ល។ របស់មនុស្សម្នាក់ៗ ដើម្បីកត់សម្គាល់ ពីគុណសម្បត្តិ និងគុណវិបត្តិរបស់មនុស្សនោះ។

**ឧទាហរណ៍៖** ការសង្កេតលើបម្រុងប្រយ័ត្នរបស់សិស្សក្នុងថ្នាក់ សង្កេតលើសកម្មភាពធ្វើការងាររបស់សិស្ស (ភាពឧស្សាហ៍ ភាពខ្ជិល និងសកម្មភាពការងាររបស់គេ)។

- **វិធីអង្កេតដោយសរសេរ ៖** គឺជាការសិក្សាទៅលើស្នាដៃ ទៅលើសមិទ្ធិផល របាយការណ៍ ប្រវត្តិរូប ឯកសារប្រព័ន្ធកម្រងសំណួរ ស្លាកស្នាម (ផូស៊ីល) ... ។

**ឧទាហរណ៍ទី១ ៖** ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ទទួលព័ត៌មានបានតាមរយៈរបាយការណ៍ ដោយមិនចាំបាច់ទ្រង់ចុះទៅផ្ទាល់ឡើយ ។

**ឧទាហរណ៍ទី២ ៖** តាមរយៈប្រវត្តិរូប យើងអាចទទួលបានព័ត៌មានពីបុគ្គលណាមួយជាក់លាក់ ។

- **វិធីសន្ទនា៖** វិធីដែលប្រើការសន្ទនារវាងមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬទៅមនុស្ស មួយក្រុម តាមរយៈសំណួរដែលគេបានចោទសួរឡើងសំដៅស្វែងយល់ពីចិត្តគំនិត និងភាពអាថ៌កំបាំងរបស់មនុស្សនោះ ឬក្រុមមនុស្សនោះ ដោយផ្អែកលើការវិភាគប្រតិកម្មពាក្យសម្តី ឬសកម្មភាពកាយវិការដែលតបតមកវិញ។

**ឧទាហរណ៍៖** ការសន្ទនារវាងគ្រូ និងសិស្សពីបញ្ហាដែលបណ្តាលឱ្យពួកគេធ្វើកិច្ចការមិនបានលទ្ធផលល្អ។

- **វិធីពិសោធន៍៖** វិធីនេះមានបំណងបង្កបាតុភូតចិត្តសម្រាប់យកមកសិក្សា ដើម្បីអាចសង្កេតពីការប្រែប្រួលធាតុផ្សេងៗរបស់បាតុភូតនោះ។ វិធីពិសោធអាចប្រព្រឹត្តទៅតាមរបៀបពីរយ៉ាងគឺ តាមការពិសោធធម្មតា និងតាមការពិសោធនៅក្នុងបន្ទប់ពិសោធ។

  - ពិសោធងាយៗ៖ ជាការពិសោធដែលគេរៀបចំឡើងក្នុងជីវភាព ឬក្នុងសកម្មភាពធម្មតារបស់មនុស្សដែលគេចង់ពិសោធដូចជា នៅក្នុងថ្នាក់រៀន ការលេងល្បែងនានា សកម្មភាពសង្គម ។ល។
    **ឧទាហរណ៍៖** យកសម្ភារៈលេងជាច្រើនឱ្យកុមារលេងដូចជា កូនឡាន យន្តហោះ កប៉ាល់ទឹក រថភ្លើង...ដើម្បីសង្កេតពីទំនោរ ឬចំណង់ចំណូលចិត្តរបស់កុមារ។
  - ពិសោធក្នុងបន្ទប់ពិសោធន៍ ៖ វិធីនេះប្រព្រឹត្តទៅក្នុងលក្ខខណ្ឌដែលធ្វើឱ្យលេចឡើង នូវបាតុភូតចិត្តដែលអ្នកពិសោធន៍ចង់បាន ។ បច្ចុប្បន្នវិធីនេះ ត្រូវបានគេអនុវត្តយ៉ាងទូលំទូលាយលើសកលលោក ហើយបន្ទប់ពិសោធន៍ខ្លះក៏បំពាក់ទៅដោយឧបករណ៍ទំនើបៗ និងសុក្រឹតថែមទៀតផង ដែលអាចផ្តល់បាននូវលទ្ធផលច្បាស់លាស់ ជាក់លាក់ ពិសេសគេប្រើវិធីនេះញឹកញាប់នៅក្នុងមន្ទីរពេទ្យ និងបន្ទប់សួរចម្លើយជនសង្ស័យ។
    **ឧទាហរណ៍៖** ម៉ាស៊ីនបង្ហាញពីចង្វាក់បេះដូងតាមរយៈក្រាភិច។

### ខ. ធម្មជាតិ នៃបាតុភូតចិត្ត

### ១. ធម្មជាតិ នៃបាតុភូតចិត្ត

ធម្មជាតិនៃបាតុភូតចិត្ត បានមកពីចំណាំងរបស់តថភាពសត្យានុម័ត ដែលខួរក្បាលមនុស្សទទួលបានហើយចំណាំងនេះមានលក្ខណៈអត្តនោម័ត និងក្លាយទៅជាសម្បត្តិផ្ទាល់ខ្លួន ដែលជាសមិទ្ធផលនៃលំនាំអភិវឌ្ឍរបស់មនុស្ស។

ឧទាហរណ៍៖ មានរបស់មួយនៅលើតុ យើងដឹងថាជាសៀវភៅ ហើយសៀវភៅនោះជាសៀវភៅប្រវត្តិសាស្ត្រ។

### ២. ចរិតអត្តនោម័ តនៃតថភាពសត្យានុម័ត

#### ២.១. តថភាពសត្យានុម័ត

តថភាពសត្យានុម័ត គឺអ្វីដែលកើតមានក្រៅញាណរបស់មនុស្ស និងជាប្រភពចិត្ត។ តថភាព សត្យានុម័តត្រូវចាំងចូលក្នុងខួរក្បាលរបស់មនុស្ស ហើយបង្កើតបានជារូបភាពចិត្ត។ បើគ្មាន តថភាពសត្យានុម័ត ក៏គ្មានរូបភាពចិត្តដែរ។ រូបភាពចិត្តផ្សារភ្ជាប់តថភាពសត្យានុម័តយ៉ាងជិតស្និទ្ធ ទៅនឹងខួរក្បាល បានន័យថារូបភាពចិត្តផ្សារភ្ជាប់ទៅនឹងអ្វីៗដូចជា មនុស្ស សត្វ វត្ថុ បាតុភូតផ្សេងៗ...ដែលមនុស្សមានទំនាក់ទំនងជាមួយបរិស្ថានជុំវិញបណ្តាលឱ្យរូបភាពចិត្តកើតមានឡើងគ្រប់ពេលវេលា ហើយកើតមានរាល់មនុស្សគ្រប់រូប។

ឧទាហរណ៍ ៖ មានមនុស្សម្នាក់ពាក់អាវពណ៌ក្រហមដើរកាត់មុខយើង ពេលនោះយើងដឹងថា ជានារី ។

#### ២.២. ចរិតអត្តនោម័ តរបស់ចិត្ត

រូបភាពចិត្តដែលកើតមកពីវត្ថុមួយ ឬបាតុភូតមួយដែលស្ថិតនៅក្នុងខួរក្បាលរបស់មនុស្ស តែងតែមានភាពខុសប្លែកគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ពីព្រោះចំណាំងចូលទៅក្នុងខួរក្បាលនេះ វាផ្លាស់ប្តូរទៅតាមបទពិសោធការយល់ដឹង និងវិសេសភាពរបស់បុគ្គលតាមរយៈការពិនិត្យសង្កេត និងវាយតម្លៃ ហើយអាស្រ័យផងដែរតាមចំណង់

ចំណូលចិត្ត ។

ឧទាហរណ៍៖ នារីពាក់អាវពណ៌ក្រហមដើរកាត់អម្បាញ់មិញនេះ មានរូបសម្ផស្សស្រស់ស្អាត។ ផ្ទុយទៅវិញ មិត្តយើងម្នាក់ទៀតបានឃើញដែរ តែនិយាយថា នារីនោះមិនមានរូបសម្ផស្សស្រស់ស្អាតទេ។

ដូចនេះ វត្ថុ ឬបាតុភូតមួយ ត្រូវបានគេពិនិត្យសង្កេត និងវាយតម្លៃប្លែកៗពីគ្នាទៅតាមទស្សនៈ បញ្ញាញាណរបស់បុគ្គលម្នាក់ៗ។ ទាំងនេះបញ្ជាក់ឱ្យដឹងថា បាតុភូតចិត្តជារូបភាពអត្តនោម័តនៃចិត្ត ព្រោះវត្ថុតែមួយផ្តល់រូបភាពចិត្តផ្សេងៗគ្នាចំពោះបុគ្គលផ្សេងៗគ្នា ។

### ២.៣. បាតុភូតចិត្តជាមុខងាររបស់ខួរក្បាល

មូលដ្ឋានរូបធាតុនៃបាតុភូតចិត្តគឺ **ខួរក្បាល** និង**ក៏តិចខួរក្បាល**។ គ្មានខួរក្បាលគឺ គ្មានបាតុភូតចិត្ត។ ខួរក្បាលមិនធម្មតានាំឱ្យខួរក្បាលមិនធម្មតា (ឧទាហរណ៍៖ មនុស្សវិកលចរិត អ្នកមាន ជំងឺសរសៃប្រសាទ អ្នកវង្វេងស្មារតី)។

ប៉ុន្តែ បាតុភូតចិត្តមិនមែនជាខួរក្បាលទេ ពីព្រោះបាតុភូតចិត្តមិនមែនជារូបធាតុ ដែលបញ្ចេញដោយខួរក្បាល ដូចជាថ្លើមបញ្ចេញទឹកប្រម៉ាត់នោះទេ។ ពេលណាខួរក្បាលទទួលបានរំញោច ខួរក្បាលបញ្ជាទៅសរីរាង្គណាមួយ ពេលនោះមនុស្សនឹងសម្តែងចេញជាសកម្មភាព។ ដូចនេះបាតុភូតចិត្តជា មុខងាររបស់ខួរក្បាល។

ឧទាហរណ៍៖ ពេលគ្រូហៅសិស្សម្នាក់ឱ្យឡើងមកលើក្តារខៀន(រំញោច) សិស្សស្តាប់ឮ(បាតុភូតចិត្ត) រួចសិស្សដើរទៅរកក្តារខៀន(សកម្មភាព)។

### គ. ចំណែកថ្នាក់នៃបាតុភូតចិត្ត

បាតុភូតចិត្តត្រូវបានអ្នកចិត្តវិទូ ចែកចេញជាបីប្រភេទគឺ លំនាំចិត្ត សភាពចិត្ត និងលក្ខណៈចិត្ត ។

**គ.១. លំនាំចិត្ត៖** លំនាំចិត្ត ជាបាតុភូតចិត្តមួយដែលកើតឡើងដោយសារឥន្ទ្រីយ៍ទាំង៥ ប៉ះជាមួយវត្ថុ ឬបាតុភូតជុំវិញ ហើយទទួលបាននូវរូបភាពចិត្ត (ទទួលបាននូវអារម្មណ៍) ឬលំនាំចិត្ត គឺជាបាតុភូតនៃសកម្មភាពដែលប្រព្រឹត្ត និងកើតឡើងដើម្បីប្រែក្លាយរាល់អំពើពីពិភពខាងក្រៅខ្លួនឱ្យទៅជារូបភាពចិត្ត។ លំនាំចិត្តជានិយ័តករទី១ ដែលដឹកនាំសកម្មភាពនៃសភាពចិត្ត និងលក្ខណៈចិត្តរបស់មនុស្ស។ លំនាំចិត្តចែកចេញជា លំនាំពុទ្ធិ(ចំណេះដឹង) លំនាំសញ្ចេតនា និងលំនាំឆន្ទៈ ដែលលំនាំទាំងបីនេះមានឥទ្ធិពលទៅវិញទៅមកបង្កើតបានជាជីវិតចិត្តរបស់បុគ្គល។

**គ.២. សភាពចិត្ត៖** សភាពចិត្តជាបាតុភូតចិត្តមួយដែលកើតឡើងដោយយកលំនាំចិត្តជាមធ្យោបាយ ដើម្បីឆ្លុះបញ្ចាំងលំនាំចិត្តនោះឱ្យកាន់តែប្រសើរឡើង ។

ឧទាហរណ៍ ៖ ចិន្តាអានសៀវភៅដោយយកចិត្តទុកដាក់ (អានជាលំនាំចិត្ត យកចិត្តទុកដាក់ជាសភាពចិត្ត) ។

**គ.៣. លក្ខណៈចិត្ត៖** លក្ខណៈចិត្តជាបាតុភូតចិត្តរបស់មនុស្សដែលកើតឡើងដោយសារមានលំនាំចិត្ត សភាពចិត្ត ជាគ្រឹះ ហើយក្លាយទៅ ជាលក្ខណៈចិត្តដែលជាបាតុភូតចិត្តមួយជាប់លាប់ ស្ថិតស្ថេរយូរអង្វែង ជួនកាលមិនប្រែប្រួលអស់មួយជីវិត ។

ឧទាហរណ៍ ៖ ចិន្តាអានសៀវភៅដោយយកចិត្តទុកដាក់យូរៗក្លាយទៅជាទម្លាប់ក្នុងការអាន ក្លាយទៅជាឥរិយាបថ គឺឧស្សាហ៍អាន ។

**ទំនោរ អត្តចរិត ឬកពា សម្បទា សញ្ចេតនា សុទ្ធតែជាលក្ខណៈចិត្តរបស់មនុស្ស ។**

**ចំណាំ** ៖ លក្ខណៈចិត្តកើតឡើងដោយសារតែការប្រកាន់យក ត្រាប់តាម ហើយក្លាយទៅជាទម្លាប់ ទម្លាប់យូរៗក្លាយទៅជាឥរិយាបថរបស់មនុស្ស ដែលយើងហៅថាលក្ខណៈចិត្តនោះឯង ។

សរុបមកបាតុភូតចិត្តរួមមាន លំនាំចិត្ត សភាពចិត្ត និងលក្ខណៈចិត្តដែលមានភាពជាប់ជំពាក់គ្នាមានអន្តរកម្មនឹងគ្នា ដែលសម្តែងចេញឱ្យឃើញពីជីវិតចិត្តទាំងមូលរបស់មនុស្ស។




## ៣. អត្ថប្រយោជន៍របស់ចិត្តវិទ្យា

ចិត្តវិទ្យាមានសារៈសំខាន់ចំពោះជីវភាពរស់នៅក្នុងសង្គម ជាពិសេសផ្តល់សមត្ថភាពគ្រប់គ្រង និងដឹកនាំការងារ សមត្ថភាពក្នុងការតាមដានសង្កេតដូចជា ការបង្រៀន ការរៀនរបស់សិស្ស ការព្យាបាល ការតាមដានអ្នកជំងឺ វិស័យយោធា ប៉ូលីស តុលាការ សិល្បៈ ពាណិជ្ជកម្ម ។ល។

ឧទាហរណ៍៖ គ្រូពេទ្យត្រូវស្គាល់ចិត្តរបស់អ្នកជំងឺ។ សិល្បករត្រូវស្គាល់ចំណង់ចំណូលចិត្តទស្សនិកជន។ អ្នកបច្ចេកទេសផលិតឧបករណ៍តម្រូវនឹងសេចក្តីត្រូវការ និងចំណង់ចំណូលចិត្តអ្នកប្រើប្រាស់។

ចិត្តវិទ្យាជាមុខវិជ្ជាសំខាន់ក្នុងវិស័យអប់រំ និងជាមូលដ្ឋានគ្រឹះរបស់គរុកោសល្យវិទ្យា ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតសិក្សា។ ការយល់ដឹងខ្ពស់នូវចំណេះដឹងផ្នែកចិត្តវិទ្យា អាចឱ្យយើងឈោងចាប់យកគំរូវិធីបង្រៀនថ្មីៗបានល្អដូចជា គោលវិធីបង្រៀនសិស្សមជ្ឈមណ្ឌល វិធីសិក្សាបែបសហការ វិធីស្រាវជ្រាវជាដើម ដែលជាវិធីបង្រៀនកំពុងមានសកម្មភាព និងចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការលើកកម្ពស់ប្រសិទ្ធភាពអប់រំ។

### ចិត្តវិទ្យាសម្រាប់គ្រូបង្រៀន គឺមានន័យថា ៖

- មានភាពងាយស្រួលក្នុងការស្គាល់សិស្សរបស់ខ្លួនបានច្បាស់។
- មានភាពប្រសើរក្នុងការធ្វើទំនាក់ទំនងជាមួយសិស្ស និងមានឥទ្ធិពលទៅលើសិស្ស ដោយជួយសិស្សឱ្យគេ

ទទួលបានលទ្ធផលសិក្សាល្អ និងឱ្យក្លាយជាបុគ្គលដែលមានលក្ខណៈពេញលេញ។

- យល់លក្ខណៈក្នុងការវាយតម្លៃការសិក្សារបស់សិស្ស និងជីវិតរបស់គេ (ក្នុងសាលារៀន ឬក្រៅសាលារៀន ឬគ្រប់ពេលឈប់សម្រាក) យល់លក្ខខណ្ឌសមស្រប និងមិនសមស្របផ្តល់ជាគំនិត ដើម្បីឱ្យគេមានការផ្លាស់ប្តូរ។
- ទទួលការកត់សម្គាល់ និងវិធីស្គាល់ខ្លួនឯងបានប្រសើរ ហើយស្វ័យកែតម្រូវដែលយើងអាចនិយាយបានថាមានបំណិនគ្រប់គ្រងខ្លួនឯង មានភាពច្នៃប្រឌិតខ្ពស់ និងមានជីវិតប្រកបដោយសុភមង្គល ព្រមទាំងជាគ្រូដែលមានគុណភាព។

ការយល់ដឹងបានច្បាស់លាស់នូវចិត្តវិទ្យា ផ្តល់ឱ្យអ្នកអប់រំនូវព័ត៌មានបានច្រើនដែលបង្ហាញពីលក្ខណៈនៃការលូតលាស់ និងអភិវឌ្ឍខាងបញ្ញាញាណ ព្រមទាំងអាកប្បកិរិយា និងផ្លូវចិត្តរបស់អ្នកទទួលការអប់រំផងដែរ។

## IV- សន្និដ្ឋាន

ការបង្រៀន និងរៀន គ្រូចាំបាច់ត្រូវស្គាល់បុគ្គលិកលក្ខណៈដោយឡែកៗរបស់សិស្សម្នាក់ៗ ។ ចិត្តវិទ្យា ពិតជាមានសារប្រយោជន៍យ៉ាងខ្លាំងក្នុងការបង្រៀន និងអប់រំសិស្សឱ្យមានបុគ្គលិកលក្ខណៈល្អ ដើម្បីចូលរួមសកម្មភាពសង្គមបានត្រឹមត្រូវ។

### សំណួរ

១. តើបាតុភូតចិត្តជាអ្វី? ចូរលើកឧទាហរណ៍មកបញ្ជាក់។

២. ចូរបញ្ជាក់ថា ចិត្តជារូបភាពអត្តនោម័តនៃតថសត្យានុម័តក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗ?

៣. ចូរពន្យល់ពីចំណែកថ្នាក់នៃបាតុភូតចិត្ត ។

៤. តើចិត្តវិទ្យាមានអត្ថប្រយោជន៍យ៉ាងដូចម្តេចសម្រាប់អ្នកអប់រំ?

# មេរៀនទី២ មូលដ្ឋានសរីរៈនៃបាតុភូតចិត្ត

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- បកស្រាយបញ្ញត្តិចិត្តវិទ្យា សរីរៈវិទ្យា និងមុខងារប្រព័ន្ធសរសៃប្រសាទ
- ប្រៀបធៀបចំណុចសំខាន់ៗរបស់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស
- មានស្មារតីស្រឡាញ់ចូលចិត្តសិក្សាចិត្តវិទ្យា ដើម្បីចូលរួមអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្សឱ្យទទួលបានលទ្ធផលល្អ ។

## II- សេចក្តីផ្តើម

ក្នុងការសិក្សា ក៏ដូចជានៅក្នុងជីវភាពប្រចាំថ្ងៃ យើងត្រូវស្គាល់ពីទំនាក់ទំនងរវាងចិត្តវិទ្យា និងមូលដ្ឋានសរីរៈ ដែលជាមូលដ្ឋានក្នុងការបង្កើតបាតុភូតចិត្តរបស់មនុស្ស ។ លើសពីនេះទៅទៀត យើងអាចស្គាល់បាតុភូតផ្សេងៗ ដូចជា បាតុភូតរូប មេកានិច គីមី ... ។

## III- ខ្លឹមសារ

### ក- ទំនាក់ទំនងរវាងចិត្តវិទ្យា និងសរីរៈវិទ្យា

#### ១- ចិត្តវិទ្យា និងសរីរៈវិទ្យាមានទំនាក់ទំនងឯកភាពគ្នា

ចិត្តវិទ្យា និងសរីរៈវិទ្យា ជាវិទ្យាសាស្ត្រដែលមានកម្មវត្ថុសិក្សាជាប់ពាក់ព័ន្ធនឹងគ្នា។ ចិត្តវិទ្យាជាវិទ្យាសាស្ត្រដែលសិក្សាអំពីអាកប្បកិរិយា និងការលូតលាស់ផ្លូវចិត្តគំនិត។ សរីរៈវិទ្យាជាវិទ្យាសាស្ត្រដែលសិក្សា អំពីលំនាំប្រព្រឹត្តទៅនឹងការលូតលាស់នៃសរីរាង្គខាងក្នុង និងខាងក្រៅខ្លួនមនុស្សដូចជា ចលនា និងដំណើរប្រព្រឹត្តទៅនៃបេះដូង សួត ប្រព័ន្ធសរសៃប្រសាទ និងមុខងាររបស់វា។

បាតុភូតចិត្ត និងសរីរៈវិទ្យាមានទំនាក់ទំនងឯកភាពគ្នា។ បើគ្មានសកម្មភាពសរសៃប្រសាទ នោះបាតុភូតចិត្តក៏មិនអាចមានដែរ។ សកម្មភាពសរសៃប្រសាទ និងបាតុភូតសរីរៈជាមូលដ្ឋានរូបរបស់បាតុភូតចិត្ត។ បាតុភូតចិត្តត្រូវការមូលដ្ឋានរូបមួយ គឺប្រព័ន្ធសរសៃប្រសាទ។

#### ២- ចំណាំងរបស់តថភាពសត្យានុម័ត

គឺជាចំណាំង ដែលប្រព្រឹត្តមកលើសរីរាង្គវិញ្ញាណរបស់យើង តាមរយៈសកម្មភាពរបស់យើង ធ្វើឱ្យបាតុភូតចិត្តកើតមានឡើង។

**ឧទាហរណ៍** ៖ ពន្លឺព្រះអាទិត្យក្តៅខ្លាំង នាំឱ្យយើងរត់ទៅជ្រកក្រោមម្លប់។

ដើម្បីយល់ស៊ីជម្រៅទៅលើបាតុភូតចិត្ត និងសកម្មភាពផ្លូវចិត្តរបស់មនុស្សតាមលក្ខណៈវិទ្យាសាស្ត្រ យើងត្រូវមានចំណេះដឹងជាមូលដ្ឋានស្តីអំពីមូលដ្ឋានរូបរបស់បាតុភូតចិត្ត ពោលគឺសំណុំប្រព័ន្ធសរសៃប្រសាទ និងសកម្មភាពសរសៃប្រសាទ ។

### ខ- សញ្ញាណសង្ខេបលើទ្រង់ទ្រាយ និងមុខងាររបស់ប្រព័ន្ធសរសៃប្រសាទ

#### ១- ចំណុចសំខាន់ៗស្តីពីប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស

ប្រព័ន្ធសរសៃប្រសាទទទួលបន្ទុកផ្នែកទំនាក់ទំនងរវាងសព៌ាង្គកាយទាំងមូល និងមជ្ឈដ្ឋានជុំវិញខ្លួនយើង ព្រមទាំងតម្រូវការ និងជួយយើងក្នុងការសម្រួលរបស់សរីរាង្គកាយក្នុងការចិញ្ចឹមជីវិត ក្នុងជីវភាពរស់នៅទៅតាមមជ្ឈដ្ឋានប្លែកៗ ឬស្ថានភាពផ្សេងៗគ្នាក្នុងសង្គម។ ប្រព័ន្ធសរសៃប្រសាទចែកចេញជាពីរផ្នែកគឺ ផ្នែកកណ្តាល និងផ្នែក

បរិមណ្ឌល ។

### ក- ប្រព័ន្ធសរសៃប្រសាទផ្នែកកណ្ដាល

ប្រព័ន្ធសរសៃប្រសាទផ្នែកកណ្ដាលមាន សំណុំខួរក្បាល និងសំណុំខួរឆ្អឹងខ្នង។

សំណុំខួរក្បាល ចែកចេញជាពីរចំហៀងហៅថា អឌ្ឍគោលខួរឆ្វេង និងអឌ្ឍគោលខួរស្ដាំ។ នៅក្នុងអឌ្ឍគោលខួរនីមួយៗ ផ្នែកខាងក្នុងរួមផ្សំឡើងដោយសារធាតុពណ៌ស ដែលគ្របដណ្ដប់ដោយសារធាតុពណ៌ប្រផេះ ស្រទាប់ស្ដើងមានកម្រាស់ ២ ម.ម ជាមធ្យម ហៅថាសំបកខួរ ឬកំរិតចខួរ។ ប្រសិនបើ គេអាចលាតត្រដាងសំបកខួរនោះបាន គេនឹងបានក្រឡាផ្ទៃទាំងអស់ប្រហែល២០ ដ.ម² ដែលមានទំហំធំជាងផ្ទៃអឌ្ឍគោលខួរ ។

**ខ្ទាត់បណ្ដោយខួរក្បាល**




ដងខួរក្បាលមាន ខួរក្បាលកណ្ដាលដែលស្ថិតនៅចន្លោះខួរតូច និងអឌ្ឍគោលខួរដែលមានដុំភ្លោះពីរ ហៅថា ទុយប៉ែគុលក្វាឌ្រីស៊ីមម៉ូ។

ខួរតូច ជាសារធាតុក៏មាននៅក្នុងនោះដែរ ខួរកញ្ចឹងក ។

ខួរឆ្អឹងខ្នង ស្ថិតនៅក្នុងរន្ធឆ្អឹងខ្នង ចាប់តាំងពីកញ្ចឹងក រហូតដល់ឆ្អឹងកន្ទុយ។ បើគេកាត់ខួរឆ្អឹងខ្នង គេនឹងឃើញសារធាតុពណ៌ប្រផេះស្រោបជុំវិញទៅដោយសារធាតុពណ៌ស។

ប្រព័ន្ធសរសៃប្រសាទកណ្ដាលមានតួនាទីសម្រាប់បញ្ជា និងត្រួតពិនិត្យលើទំនាក់ទំនងគឺ សំដៅធានាបាននូវឯកភាពគ្នារវាងសរីរាង្គ ឬអាការៈខាងក្នុង និងសព៌ាង្គកាយទាំងមូលរវាងសព៌ាង្គកាយ និងមជ្ឈដ្ឋានជុំវិញខ្លួន។ ឯផ្នែកផ្សេងៗទៀតនៃប្រព័ន្ធសរសៃប្រសាទកណ្ដាលដូចជា ខួរឆ្អឹងខ្នងសម្រាប់ដឹកនាំអំពើងាយៗ ។

**ឧទាហរណ៍** ៖ ដៃប៉ះភ្លើង គឺ ខួរឆ្អឹងខ្នងជាអ្នកបញ្ជាទៅសាច់ដុំដៃឱ្យដកដៃចេញ ។

### ខ- ប្រព័ន្ធសរសៃប្រសាទបរិមណ្ឌល ឬប្រព័ន្ធណឺរ៉ូន-វេសេតាទីប

ប្រព័ន្ធណឺរ៉ូន-វេសេតាទីប មានពីរចំណែកដែលចាក់ចូលទៅក្នុងសរីរាង្គរបស់យើងគឺ ប្រព័ន្ធអរតូសាំប៉ាទិច និងប្រព័ន្ធប៉ារ៉ាសាំប៉ាទិច។

ប្រព័ន្ធអរតូសាំប៉ាទិច បង្កើតឡើងដោយមានមជ្ឈមណ្ឌលស្ថិតនៅត្រង់ផ្នែក ក ខ្នង ឆ្អឹងកន្ទុយ នៃសារធាតុពណ៌ប្រផេះរបស់ខួរឆ្អឹងខ្នង។ វាភ្ជាប់ទៅនឹងសរីរាង្គខាងក្នុងដូចជា បេះដូង ហើយវាតម្រង់ទៅរកសរសៃឈាមក្រោម

ស្បែកដោយសារសរសៃប្រសាទអរតូសាំប៉ាទិច។

ប្រព័ន្ធប៉ារ៉ាសាំប៉ាទិចមានមជ្ឈមណ្ឌលប្រសាទស្ថិតនៅក្នុងខួរកញ្ចឹងក និងនៅក្នុងផ្នែកកញ្ចុញគូទនៃឆ្អឹងខ្នង។ សរសៃប្រសាទផ្លឺម៉ូកាស្រ្ទិច ជាសរសៃប្រសាទប៉ារ៉ាសាំប៉ាទិចដែលសំខាន់ជាងគេបង្អស់។ វាចេញពីខួរកញ្ចឹងក ហើយចាក់ចូលទៅសរីរាង្គខាងក្នុងនៃទ្រូងរបស់យើង។

ប្រព័ន្ធសរសៃប្រសាទបរិមណ្ឌលត្រូវទទួលបន្ទុកជាច្រើនផ្នែកនៅក្នុងសកម្មភាពចិញ្ចឹមសព៌ាង្គកាយរបស់យើង។

**ខ្នាត់បណ្ដោយនៃខួរក្បាល**




**រូបផ្គុំប្រព័ន្ធណឺរ៉ូន**




### គ- សញ្ញាណ សង្ខេប លើទម្រង់ណឺរ៉ូន និងមុខងាររបស់វា

ណឺរ៉ូនជាកោសិកាប្រសាទដែលមានតួមួយស្ថិតនៅក្នុងសារធាតុពណ៌ប្រផេះ ឬក្នុងកង់គ្លីយ៉ុង និងភីបដែលបន្តពីតួកោសិកាទៅក្នុងសារធាតុពណ៌ស ឬក្នុងសរសៃប្រសាទ។ សំណុំណឺរ៉ូនបង្កើតបានជាសរសៃប្រព័ន្ធប្រសាទ។ ណឺរ៉ូននីមួយៗមានតួ និងសាខាជាច្រើន។ តួរបស់វាមានស៊ីតូប្លាស និងណ្វៃយ៉ូមួយ។ បណ្ដាសាខារបស់ណឺរ៉ូននីមួយៗមានផ្នែកខ្លី ហៅថាដង់ឌ្រីត និងផ្នែកវែង ហៅថាអាក់សូន ឬស៊ីឡាំងដ្រាក់។ ណឺរ៉ូននីមួយៗមានអាក់សូនមួយ និងដង់ឌ្រីតជាច្រើន។ ដង់ឌ្រីតគឺជាទ្វារចូល ឯអាក់សូនគឺជាទ្វារចេញរបស់ណឺរ៉ូន។ គ្រង់កន្លែងដែលណឺរ៉ូនជាប់ទាក់ទងគ្នាពីមួយទៅមួយហៅថា ស៊ីណាប់។ ដោយសារស៊ីណាប់នេះហើយ ដែលណឺរ៉ូននីមួយៗអាចសម្រេចបាននូវទំនាក់ទំនងរវាងខ្លួនវាជាមួយនឹងណឺរ៉ូនដទៃទៀតជាមួយកោសិកាវិញ្ញាណ ជាមួយកោសិកាសាច់ដុំ ឬកោសិកាក្រពេញ។

ណឺរ៉ូនមានមុខងារពីរយ៉ាងគឺ បង្កើតឱ្យមានអាំងភ្លុចប្រសាទ កាលណាមានរំញោចពីខាងក្រៅ ហើយផ្ទេរអាំងភ្លុចនោះទៅឱ្យណឺរ៉ូនបន្ទាប់ទៀត។ ស៊ីឡាំងដ្រាក់ប្រជុំគ្នាបង្កើតបានជាបាច់សរសៃប្រសាទ។ សរសៃប្រសាទ មានពីរយ៉ាងគឺ សរសៃប្រសាទប្រទាញចូលដែលសម្រាប់បញ្ជូនអាំងភ្លុចប្រសាទពីសរីរាង្គឥន្ទ្រីយ៍ ទៅឱ្យមជ្ឈមណ្ឌលប្រសាទ និងមួយទៀតគឺសរសៃប្រសាទប្រទាញចេញ ដែលនាំអាំងភ្លុចប្រសាទចេញពីមជ្ឈមណ្ឌលប្រសាទទៅកាន់

សរីរាង្គចលករ ។

**ឧទាហរណ៍** ៖ សាច់ដុំដៃ សាច់ដុំជើង ។

ផ្នែកខ្ពស់បំផុតនៃខួរក្បាលដែលប្រកដោយអឌ្ឍគោលខួរពីរ មានសារៈសំខាន់ជាងគេបំផុត ហើយដែលគេចាត់ទុកថា ជាមូលដ្ឋានរូបនៃសកម្មភាពផ្លូវចិត្តរបស់មនុស្ស។

ប្រព័ន្ធសរសៃប្រសាទធានាសកម្មភាពរូប និងរក្សាដំណើរការប្រព្រឹត្តទៅយ៉ាងសុខដុមនៃសព៌ាង្គកាយទាំងមូល ព្រមទាំងសម្របសម្រួលសព៌ាង្គកាយទៅតាមលក្ខខណ្ឌនៃស្ថានភាព ឬមជ្ឈដ្ឋានជុំវិញខ្លួនដោយសារវ៉េផ្លិចផ្សេងៗ។

**ណឺរ៉ូន**




**លំនាំក្នុងការប្រាស្រ័យទាក់ទងរបស់ណឺរ៉ូន**




## ២- សញ្ញាណ រ៉េផ្លិច-រ៉េផ្លិចឥតលក្ខខណ្ឌ-រ៉េផ្លិចមានលក្ខខណ្ឌ

### ក- សញ្ញាណរ៉េផ្លិច

មជ្ឈដ្ឋាន ឬស្ថានភាពជុំវិញខ្លួនយើងធ្វើអំពើ ឬប្រព្រឹត្តជានិច្ចមកលើប្រព័ន្ធសរសៃប្រសាទ តាមរយៈសរីរាង្គឥន្ទ្រិយ៍របស់យើង។ ដើម្បីមានអត្ថិភាព និងលូតលាស់បានសព៌ាង្គកាយត្រូវធ្វើប្រតិកម្មតបវិញនៅពេលណាដែលវាទទួលរំញោច។ លំនាំបែបនេះ គេហៅថា រ៉េផ្លិច។

**ឧទាហរណ៍** ៖ - ក្មេងឃ្លានបាយ រសក្រពះធ្វើប្រតិកម្មមកលើផ្ទៃពោះវៀន នាំឱ្យពោះវៀនក្រហាយ ហើយបណ្ដាលឱ្យក្មេងយំ ។ រំញោចក្រពះ(សរីរាង្គក្នុង) នាំឱ្យមានប្រតិកម្ម ក្មេងយំ(រំញោចក្នុង)។

- គ្រូអានអត្ថបទសរសេរតាមអាន សិស្សកត់ត្រាតាម ។ រំញោច(សំដីគ្រូ) នាំឱ្យមានប្រតិកម្មសិស្សស្តាប់ និងសរសេរតាម ។

ចាប់តាំងពីសកម្មភាពងាយៗដូចជា សម្រែកក្មេង ពេលវាឃ្លានបាយរហូតដល់សកម្មភាពស្មុគស្មាញដូចជាការសិក្សារបស់សិស្សសរសេរតាម និងរាល់សកម្មភាពផ្សេងៗទៀតរបស់មនុស្សសុទ្ធសឹងជាសកម្មភាពរ៉េផ្លិចទាំងអស់។

**និយមន័យ ៖** រ៉េផ្លិច គឺជាប្រតិកម្មនៃសព៌ាង្គកាយដែលឆ្លើយតបទៅនឹងរំញោច ដែលកើតមានពីខាងក្នុង ឬពីខាងក្រៅខ្លួន ដែលកើតឡើងដោយផ្នែកណាមួយដ៏ពិតប្រាកដនៃប្រព័ន្ធសរសៃប្រសាទក្នុងខ្លួនមនុស្សយើង។

### ខ- រ៉េផ្លិចឥតលក្ខខណ្ឌ

រ៉េផ្លិចឥតលក្ខខណ្ឌ ជារ៉េផ្លិចមានពីកំណើត ឬជួនកាលជារ៉េផ្លិចតំណពូជ ។

តាំងពីវ័យទារក មនុស្សក៏ដូចជាសត្វ ធ្វើប្រតិកម្មឆ្លើយតបទៅនឹងចំណាំងនៃតថភាពសត្យានុម័តនៃមជ្ឈដ្ឋាន ឬស្ថានភាពជុំវិញខ្លួន ដើម្បីមានអត្ថិភាពក្នុងសង្គមដោយសាររ៉េផ្លិចឥតលក្ខខណ្ឌ។ រាល់ប្រតិកម្មនៃខួរឆ្អឹងខ្នងសុទ្ធសឹងជារ៉េផ្លិចឥតលក្ខខណ្ឌ ឬជារ៉េផ្លិចពី កំណើត ។ រ៉េផ្លិចរបស់ដងខួរក្បាល ខួរតូច ខួរកញ្ចឹងក ក៏សុទ្ធសឹងជារ៉េផ្លិចឥតលក្ខខណ្ឌដែរ។

**ឧទាហរណ៍ ៖** ដៃប៉ះភ្លើងក្តៅនាំឱ្យដកដៃចេញភ្លាម ។ មូសខាំយកដៃទះ។ កើតមក ចេះយំ ចេះសើច ចេះស្រែក ចេះ...។

រ៉េផ្លិចឥតលក្ខខណ្ឌ មានបន្លាស់ប្តូរប្រែប្រួលតិចតួចណាស់ ហើយតម្រូវឱ្យមានរំញោចយ៉ាងសមស្របផង ទើបមានអត្ថិភាពបានយ៉ាងប្រសើរក្នុងមជ្ឈដ្ឋានរស់នៅដូចជា សំឡេងអាចទទួលបានដោយត្រចៀក (សំឡេងខ្លាំងពេកធ្វើឱ្យមនុស្សពិបាកទ្រាំ) ពន្លឺអាចទទួលបានដោយសារភ្នែក(ភ្លឺចាំងខ្លាំងពេក ភ្នែកមិនអាចទ្រាំទ្របាន)។ល។

### គ- រ៉េផ្លិចមានលក្ខខណ្ឌ

ផ្សេងពីរ៉េផ្លិចឥតលក្ខខណ្ឌ រ៉េផ្លិចមានលក្ខខណ្ឌ កើតមានឡើងក្នុងលក្ខខណ្ឌជាកំណត់។ សរីរៈវិទូជាតិរុស្ស៊ីឈ្មោះលោក ប៉ាវឡូវ បានរកឃើញ និងហៅ រ៉េផ្លិចនេះថា ជារ៉េផ្លិចមានលក្ខខណ្ឌ ដែលអាចកើតមានឡើង និងបាត់បង់សាបរលាបទៅវិញក្នុងរយៈពេលមួយមិនកំណត់បាន។ លោក ប៉ាវ ឡូវ ១៨៤៦-១៩៣៦ ជាអ្នកប្រាជ្ញសរីរៈវិទ្យានៅវិទ្យាស្ថានលេនីនក្រាដ បានស្រាវជ្រាវរកឃើញរ៉េផ្លិចមានលក្ខខណ្ឌមុនគេ ហើយទទួលបានរង្វាន់ណូបែលក្នុងឆ្នាំ ១៩០៤ ។ ដើម្បីសិក្សាពីរ៉េផ្លិចនេះ លោក ប៉ាវ ឡូវ បានធ្វើពិសោធទៅលើសត្វឆ្កែ ដោយសង្កេតមើលរ៉េផ្លិចក្រពេញទឹកមាត់របស់វា ។

រូបទី១៖ ក្នុងលក្ខខណ្ឌធម្មតា ពន្លឺចង្កៀង ជារំញោចណឺត គ្មានប្រយោជន៍អ្វីទៅលើក្រពេញទឹកមាត់ឆ្កែទេ។

រូបទី២៖ វត្ថុភ្លោច(សាច់) ដែលប៉ះនឹងអណ្តាតរបស់ឆ្កែ បង្កើតបានជារ៉េផ្លិចទឹកមាត់ ហើយនេះជារ៉េផ្លិចឥតលក្ខខណ្ឌធម្មតា ។

រូបទី៣៖ ក្នុងពេលតែមួយ គេផ្តល់វត្ថុភ្លោចលើអណ្តាតវាផង និងលើចក្ខុវាផង ។ នៅពេលនេះគេដឹងថា នៅចន្លោះមណ្ឌលទាំងពីរនៃកំរតិច និងនៅចន្លោះសរីរាង្គវិភាគគឺ ជីវ្ហាវិញ្ញាណ និងចក្ខុវិញ្ញាណ មានខ្សែបន្ទាត់មួយតភ្ជាប់គ្នារវាងមណ្ឌលទាំងពីរនោះជាបណ្តោះអាសន្ន ។

រូបទី៤៖ ក្រោយពីបានផ្តល់រំញោចទាំងពីរនោះជាច្រើនដងក្នុងពេលជាមួយគ្នា គេសង្កេតឃើញខ្សែភ្ជាប់បណ្តោះអាសន្ននោះស្ថិតនៅនឹងកំរតិចខួរក្នុងរយៈពេលមួយ ។ លទ្ធផលដែលគេទទួលបានគឺ រំញោចដែលណឺត (ពន្លឺចង្កៀង) ចាប់ផ្តើមធ្វើឱ្យឆ្កែចេញទឹកមាត់ ។ នេះជារ៉េផ្លិចមានលក្ខខណ្ឌរបស់ឆ្កែ ។



គំនូសបំព្រួញ ទី១

**ការពិសោធរបស់លោក ប៉ាវ ឡូវ**



គំនូសបំព្រួញ ទី២



គំនូសបំព្រួញ ទី៣



គំនូសបំព្រួញ ទី៤

ដូចនេះ យើងឃើញថាសកម្មភាពនៃរ៉ឺផ្លិចមានលក្ខខណ្ឌគឺការបន្សាំសពាង្គកាយទៅនឹងស្ថានភាព ឬមជ្ឍដ្ឋានជុំវិញ ហើយវាមានកម្រិតខ្ពស់ជាងរ៉ឺផ្លិចឥតលក្ខខណ្ឌ ។ រ៉ឺផ្លិចមានលក្ខខណ្ឌបង្កើតឡើងដោយ កំរតិចខួរ ពោលគឺសកម្មភាពនៃសរសៃប្រសាទខាងលើ។ ដើម្បីបង្កើតរ៉ឺផ្លិចមានលក្ខខណ្ឌ គេត្រូវមានលក្ខខណ្ឌដូចតទៅ ៖

ចំពោះសត្វ៖ ត្រូវពឹងផ្អែកលើ រ៉ឺផ្លិចឥតលក្ខខណ្ឌមួយ ឬរ៉ឺផ្លិចមានលក្ខខណ្ឌដែលមានពីមុន ទើបសម្រេចបានរ៉ឺផ្លិចមានលក្ខខណ្ឌ

ចំពោះមនុស្ស ៖ ត្រូវពឹងផ្អែកលើបទពិសោធន៍ដែលគេធ្លាប់មានពីមុនមក ។

ឧទាហរណ៍ ៖ ពេលឮគេនិយាយពីស្វាយខ្ចី ធ្វើឱ្យអ្នកស្តាប់ចេញទឹកមាត់ ។ នេះជារ៉ឺផ្លិចមានលក្ខខណ្ឌ ព្រោះមនុស្សអ្នកស្តាប់នេះធ្លាប់បានហូបស្វាយពីមុនបានជាធ្វើឱ្យគេចេញទឹកមាត់ ។ ហើយម្តងនេះទៀត រសជាតិជូរមិនបានប៉ះនឹងអណ្តាតរបស់គេទេ គេគ្រាន់តែស្តាប់ឮនឹងត្រចៀក ក៏ធ្វើឱ្យគេចេញទឹកមាត់ដែរ ។

ឧទាហរណ៍ ៖ សិស្សស្តាប់គ្រូធ្វើអត្ថាធិប្បាយពីខ្លឹមសារមេរៀនមួយ សិស្សអាចកត់ត្រាបាននូវចំណុចសំខាន់ៗនៃមេរៀន មកពីសិស្សមានចំណេះដឹង និងសមត្ថភាពពីមុនរួចមកហើយ។

### ៣- ច្បាប់ ផ្សេង ៗនៃសកម្មភាព ប្រព័ន្ធសរសៃប្រសាទ

គ្រប់សកម្មភាពទាំងអស់របស់ខួរក្បាល និងកំរតិចខួរស្តែងចេញតាមរយៈលំនាំពីរយ៉ាងគឺ រំញោច និងការទប់រំញោច។ លំនាំទាំងពីរនេះមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នាជានិច្ច ហើយផ្សារភ្ជាប់នឹងប្រព្រឹត្តទៅតាមច្បាប់ដ៏ជាក់លាក់ដូចតទៅ៖

#### ក- ច្បាប់ បម្លែង ឱ្យទៅជាការ ទប់រំញោច

រំញោច គឺជាលំនាំចិត្តដែលធ្វើឱ្យមជ្ឈមណ្ឌលសរសៃប្រសាទ និងផ្នែកដែលទាក់ទងនឹងវាមានសកម្មភាពខ្លាំង ។ សភាពកើតឡើងនៃរំញោចដែលបណ្តាលឱ្យមានប្រតិកម្មមួយចំនួននៃសពាង្គកាយដូចជា ចលនាសាច់ដុំ ការបញ្ចេញក្រពេញ ការបញ្ចេញសំឡេង ការបញ្ចេញកាយវិការ ការធ្វើអំពើ ឬចលនាទប់ទល់...។

ឧទាហរណ៍ ៖ ធុំក្លិនសម្លឈ្ងុយឆ្ងាញ់ នាំឱ្យស្រក់ទឹកមាត់ ឃ្លានបាយ ។ នេះគឺការបញ្ចេញក្រពេញទឹកមាត់ ។
អ្នកបរបាញ់ឮសូរសត្វឃុំ ដើរសំដៅទៅទីកន្លែងនោះ។ ពេលមូសខាំយកដៃទះមូស។ ពេលឮនរណាម្នាក់ហៅចំឈ្មោះ ងាកមុខទៅរកអ្នកនោះ ។

កាលណាមានរំញោច ចំណុចណាមួយនៅត្រង់ក័រតិចខួរ ត្រូវរំញោចខ្លាំង ឬតិចទៅតាមកម្លាំងនៃរំញោចដែលមនុស្សទទួល ។ កាលណារំញោចមានអាំងតង់ស៊ីតេខ្លាំងពេក ធ្វើឱ្យមនុស្សភ្ញាក់ព្រើត ។

ឧទាហរណ៍ ៖ សំឡេងខ្លាំងពេកធ្វើឱ្យយើងភ្ញាក់ ចាក់ក្រឡេក ស្រែកសន្ធាប់...។

កាលណារំញោចមានកម្លាំងមិនសូវជាខ្លាំង ហើយដដែលៗច្រើនដងដូចគ្នា នាំឱ្យរំញោចនោះ ត្រូវបានបម្លែងឱ្យទៅជា ការទប់រំញោចទៅវិញ។

ឧទាហរណ៍ ៖ សំឡេងដដែលៗរបស់រថភ្លើង ធ្វើឱ្យអ្នកដំណើរដេកលក់។
ចម្រៀងបំពេរបស់ម្តាយ នាំឱ្យកូនដេកលក់។
ស្នូររថភ្លើង(ជាវត្ថុភ្ញោច) ដដែលៗបម្លែងឱ្យទៅជាការទប់រំញោច(កូនដេកលក់)។

រំញោច និងការទប់រំញោច ជាលំនាំពីរផ្ទុយគ្នា តែវាធ្វើសកម្មភាពប្រព័ន្ធសរសៃប្រសាទរួមបញ្ចូលគ្នា ។ លំនាំទាំងពីរនេះជាប់ពាក់ព័ន្ធគ្នាជានិច្ច ។ លំនាំរបស់រំញោចក្តី លំនាំរបស់ការទប់រំញោចក្តី មិនអាចប្រព្រឹត្តទៅ ឬកើតឡើងតែឯកឯងបាននោះទេ ។ លំនាំទាំងពីរនេះកើតមានឡើងដោយសាររំញោចពីខាងក្រៅ ឬខាងក្នុងខ្លួន នៅលើក័រតិចខួរ។

ឧទាហរណ៍៖ - រំញោចខាងក្រៅខ្លួន៖ ធុំក្លិនក្រអូបទឹកអប់ ឬក្លិនផ្កា ក្រឡេករកមើលអ្នកលាបទឹកអប់ ឬក្រឡេករកមើលផ្កា ។ ការឮសូរចម្រៀង សំឡេងស្រែកហៅ...។
- រំញោចខាងក្នុងខ្លួន ៖ ចុកពោះ ក្ដៅពោះ ឈឺក្រពះ ត្រូវរកគ្រូពេទ្យព្យាបាល...។

## ខ- សំណាយ និងការផ្តុំ

កាលណាមានរំញោចនៅនឹង ក័រតិចខួរ ត្រង់ចំណុចណាមួយ គេនឹងមានការទប់រំញោចនៅត្រង់ម្តុំនោះ។ តែបើរំញោច ឬការទប់រំញោចនេះមិនស្ថិតនៅនឹងនរមួយកន្លែងទេ វាអាចរាលដាលទៅដល់ចំណុចដទៃទៀតពាសពេញក័រតិចខួរ ។ នេះគឺជាបាតុភូតនៃសំណាយ ។

ឧទាហរណ៍ ៖ ឪម៉ាល់ទិច ការឈឺចាប់មិនមែនកើតឡើងតែត្រង់កន្លែងដែលវាទិចទេ វាអាចរាលដាលធ្វើឱ្យយើងឈឺចាប់ដល់ចំណុចផ្សេងៗទៀតក្នុងខ្លួនយើង ។

បើសិនណាជាអាំងតង់ស៊ីតេ ឬកម្លាំងនៃរំញោចមានកម្រិតមធ្យមពោលគឺមិនខ្លាំងពេក មិនខ្សោយពេក លំនាំនៃរំញោចនេះមិនឈប់នៅត្រង់ចំណុចតែមួយទេ តែវាអាចរាលដាលជុំវិញក័រតិចខួរ ។ សំណាយនេះកើតមានឡើងយូរឬឆាប់ វាអាស្រ័យទៅតាមកម្លាំងដំបូងនៃរំញោចនោះឯង ។ ក្រោយពីលាតសន្ធឹងសាយភាយដល់ត្រង់ចំណុចព្រំដែនណាមួយដ៏ជាក់លាក់ លំនាំនៃរំញោចទាំងនេះ ក៏ផ្តុំគ្នាត្រង់ចំណុចណាមួយពិតប្រាកដ ។ នេះជាបាតុភូតនៃការផ្តុំរំញោច ឬការទប់រំញោច ។

ឧទាហរណ៍ ៖ កុមារដែលរៀនសរសេរអក្សរផ្ចង់នៅថ្នាក់ដំបូង យើងសង្កេតឃើញថា ដងប៉ាកា ឬខ្មៅដៃ របស់វាហាក់ដូចជាបញ្ចាទៅខ្ទងវាផង ទៅបបូរមាត់វាផង ។ កាលណាវាគូសបន្ទាត់ឡើងលើ បបូរមាត់វាខើចឡើងលើ ។ កាលណាវាគូសងាកមកខាងឆ្វេង ឬទៅខាងស្តាំ វាខំផ្ងៀង ក ទៅតាម ហើយមាត់វាក៏វៀចតាមនោះដែរ ។

ទាំងនេះបង្ហាញឱ្យឃើញថា នៅពេលកុមារផ្តើមរៀនសរសេរអក្សរផ្ចង់ រំញោចលាតសន្ធឹងហួសព្រំដែនរបស់វាគឺរំញោចមិនគ្រាន់តែស្ថិតនៅត្រង់មណ្ឌលចក្ខុ និងចលនាដៃរបស់កុមារប៉ុណ្ណោះទេ គឺរំញោចនោះវារាលដាលរហូតដល់ចលនាដងខ្លួន និងបបូរមាត់ទៀតផង ។ លុះដល់កុមារទម្លាប់សរសេររាល់ថ្ងៃទៅ វ៉ផ្លិចទាំងនោះអាចផ្តាច់ពីគ្នាបានដោយសារតែកាផ្តុំនៃរំញោចត្រង់ចំណុចមួយដ៏សមស្រប ។ លក្ខណៈបែបនេះ ក៏បង្ហាញឱ្យឃើញដូចគ្នាដែរចំពោះ

មនុស្សធំដែលរៀនជិះកង់ ។

### គ- ច្បាប់ ប្រតិឃាត

វិញ្ញោចមិនគ្រាន់តែមានសមត្ថភាពបង្កើតបានសំណាយ និងប្រមូលផ្តុំ ដើម្បីទប់វិញ្ញោចប៉ុណ្ណោះទេ តែវាមានសមត្ថភាពផ្លាស់ប្តូរគ្នាបាន និងជួយគ្នាទៅវិញទៅមកបានផង ។ ករណីបែបនេះ ហៅថា ប្រតិឃាត ឬអាំងឌុចស្យុងប្រាស ។ បាតុភូតប្រតិឃាតនេះ កើតមានឡើងនៅពេលណាដែលមានវិញ្ញោចត្រង់ចំណុចណាមួយនៃអឌ្ឍគោលខួរ ឬក័រតិចខួរ ហើយវិញ្ញោចនោះឯងបង្កើតឱ្យមានការទប់ក្នុងតំបន់ជិតខាងនៃចំណុចនេះ ប្រាសមកលើវិញ្ញោចដែលរាលដាលនេះ ។

ឧទាហរណ៍ ៖ កាលណាគេផ្តោតអារម្មណ៍សម្លឹងមើលផ្ទាំងគំនូរមួយ គេហាក់ដូចជាស្តាប់មិនឮសំឡេងដែលកើតឡើងជុំវិញខ្លួនគេទេ ។ នេះបណ្តាលមកពីតំបន់ដែលទាក់ទងនឹងចក្ខុន្ទ្រីយារម្មណ៍ មានវិញ្ញោចខ្លាំងទៅលើផ្ទាំងរូបភាព ហើយវិញ្ញោចនេះស្រូបយកវិញ្ញោចអស់ពីសោតិន្ទ្រីយារម្មណ៍ នាំឱ្យតំបន់សោតិន្ទ្រីយារម្មណ៍ដែលទាក់ទងការស្តាប់ក្លាយទៅជាតំបន់ទប់ស្កាត់វិញ្ញោចទៅវិញ ។

ឧទាហរណ៍ផ្សេងទៀត ៖ ជក់អានសៀវភៅប្រលោមលោកទាល់តែភ្លេចហូបបាយ ។ ជក់អារម្មណ៍ស្តាប់គ្រូពន្យល់ទាល់តែភ្លេចកត់ត្រា ឬក៏ផ្តោតស្មារតីកត់ត្រាខ្លាំងពេក ភ្លេចស្តាប់គ្រូ ។ កុមារកំពុងហូបបាយយ៉ាងឆ្ងាញ់ ពេលឃើញម្តាយដែលបែកយូរ ក៏ទុកចានស្លាបព្រាចោល ហើយរត់ទៅឱបម្តាយ ។

### ឃ- ច្បាប់ នៃប្រព័ន្ធសកម្មភាព របស់ក័រតិចខួរ

ក្នុងលក្ខខណ្ឌនៃជីវភាពរស់នៅធម្មតា វិញ្ញោចមិនមែនតែកើតឡើងដោយឯកឯងនោះទេ ។ មានវិញ្ញោចមួយចំនួនអាចកើតឡើងក្នុងពេលជំណាលគ្នាមកលើសរីរាង្គឥន្ទ្រីយ៍របស់យើង ។ មជ្ឈមណ្ឌលសរសៃប្រសាទមិនអាចបំពេញមុខងារដាច់តែឯងបានទេក្នុងការទទួល និងធ្វើវិភាគទៅលើវិញ្ញោចទាំងនោះ ។ ដូចនេះ មជ្ឈមណ្ឌលសរសៃប្រសាទត្រូវមានទំនាក់ទំនងជាមួយនឹងមណ្ឌលទាំងឡាយផ្សេងទៀតនៅលើក័រតិចខួរ ដើម្បីផ្តុំវិញ្ញោចនឹងទប់វិញ្ញោចនោះ ។ សំយោគនៅលើក័រតិចខួរអាចប្រមូលផ្តុំវិញ្ញោច និងប្រតិកម្មដែលនៅដាច់តែឯងឱ្យទៅជាលំនាំមួយពេញលេញដែលគេហៅថាប្រព័ន្ធសកម្មភាពរបស់ក័រតិចខួរ ។ ការវិភាគ និងការធ្វើសំយោគនេះនាំឱ្យមានប្រតិកម្មនៃសព៌ាង្គកាយដែលឆ្លើយតបទៅនឹងវិញ្ញោច ។

កាលណាយើងជំរុញសកម្មភាពនៃវិញ្ញោចមួយសេរីពីសព៌ាង្គកាយរបស់យើង ហើយយើងធ្វើអំពើដដែលនេះឱ្យបានច្រើនដង យើងនឹងបានផ៉ង្លិចមួយសេរី ដែលកើតឡើងជាបន្តបន្ទាប់គ្នា ។ ផ៉ង្លិចដែលចេះតែប្រព្រឹត្តទៅបែបនេះ បើយើងចេះហ្វឹកហ្វឺនពង្រឹងវា នោះវានឹងបង្កើតបានជាស្តេរ៉េអូទីបឌីណាមិច ដែលជាមូលដ្ឋានសរីរៈនៃចំណេះធ្វើ អំពើស្វ័យប្រវត្តិ និងទម្លាប់ ។

ច្បាប់នេះមានអត្ថន័យសំខាន់ណាស់ ចំពោះប្រព័ន្ធសកម្មភាពរបស់ក័រតិចខួរដែលគេចាត់ទុកថាជាមូលដ្ឋានសកម្មភាពរបស់បាតុភូតចិត្ត ។

ដោយសារច្បាប់ទាំងនេះ អ្នកប្រាជ្ញសរីរៈវិទ្យាបានស្រាវជ្រាវឃើញថា ក័រតិចខួរ គួបផ្សំគ្នាជាមួយណឺរ៉ូនរាប់ពាន់ដើម្បីក្តាប់បាន និងត្រួតពិនិត្យព័ត៌មានបានយ៉ាងទៀងទាត់ទៅលើតំបន់ដែលមានវិញ្ញោច និងតំបន់ដែលទប់វិញ្ញោច ។ តំបន់នីមួយៗមានសមត្ថភាពបម្លែងផ្សេងៗពីគ្នា ។ វាអាចជាសំណាយ ជាការផ្តុំ ឬជាប្រតិឃាត ។

ឧទាហរណ៍ ៖ សិស្សម្នាក់កំពុងធ្វើលំហាត់ធរណីមាត្រ ។ មានមិត្តម្នាក់មកបបួលគេឱ្យទៅដើរលេង ។ គេមិនទៅទេ គេសុខចិត្តនៅធ្វើលំហាត់តទៅទៀត លុះត្រាតែ ក័រតិចខួរអាចធ្វើវិភាគ និងធ្វើសំយោគបានរហូតទាល់តែគេអាចយល់ច្បាស់ទៅលើទ្រឹស្តីបទ ឬបមន្តណាមួយនោះបានច្បាស់លាស់ ។

ស្នូរជួងធ្វើឱ្យសិស្សកើតមានប្រតិកម្ម ផ៉ង្លិចមួយសេរីដូចជា រៀបចំខ្លួនចូលថ្នាក់ ឬចេញលេង ធ្វើពលកម្ម ហាត់

ប្រាណ...។

### ៤- ប្រភេទផ្សេង ៗនៃសកម្មភាព របស់ប្រព័ន្ធសរសៃប្រសាទ (ប្រព័ន្ធសញ្ញាកម្មទាំងពីរ )

ច្បាប់ទាំងអស់នៃសកម្មភាពរបស់ប្រព័ន្ធសរសៃប្រសាទដូចបានរៀបរាប់មកនេះ ត្រូវបានរកឃើញដោយលោក ប៉ាវឡូវ ដែលធ្វើពិសោធទៅលើសត្វ ។ តាមទ្រឹស្តីរបស់គាត់ សកម្មភាពរបស់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស ក៏ប្រព្រឹត្តទៅតាមច្បាប់នោះដែរ ដោយគ្រាន់តែមនុស្សមានកម្រិតខ្ពស់ជាងសត្វប៉ុណ្ណោះ ។

សព៌ាង្គកាយរបស់យើងទទួលរំញោចដែលមានរូបភាពប្លែកៗទៅតាមស្ថានភាព ឬមជ្ឈដ្ឋានជុំវិញខ្លួនយើង ។ រូបភាពរបស់វត្ថុ ឬបាតុភូត ដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍របស់យើង បានរក្សារូបភាពរបស់វាឱ្យស្ថិតជាប់លើអឌ្ឍគោលខួរ ។ រូបភាពវត្ថុ ឬបាតុភូតដែលយើងចាប់ផ្តើមស្គាល់ដំបូងបង្អស់ក្នុងជីវភាពរស់នៅ ហៅថា ប្រព័ន្ធ សញ្ញាកម្មទី១ ។ ប្រព័ន្ធសញ្ញាកម្មទី១នេះ កើតមានទាំងមនុស្សទាំងសត្វ ។ បើសត្វគ្មានប្រព័ន្ធសញ្ញាកម្មទី១នេះទេ បានន័យថា មនុស្សមិនអាចផ្សាំង ឬបង្ហាត់សត្វបានទេ ។

ឧទាហរណ៍ ៖ តុ ទូ កៅអី ឈ្មោះមនុស្ស ឈ្មោះទីកន្លែង ម៉ាករថយន្ត ម៉ាកម៉ូតូ ដែលយើងឃើញជាដំបូង ត្រូវបានរក្សារូបភាពរបស់វានៅនឹងអឌ្ឍគោលខួរ ។

សត្វគោ ក្របី សេះ ដំរី ដែលមនុស្សពង្រាប ឬផ្សាំងវាសម្រាប់ប្រើប្រាស់ និងសត្វស្វា ខ្លា តោ... ដែលគេបង្ហាត់វាឱ្យលេងសៀក។

ប៉ុន្តែចំពោះមនុស្ស មានប្រព័ន្ធវាក្យស័ព្ទមួយចំនួនទៀតដូចជា ពាក្យ កន្សោមពាក្យ សំនួនវោហារស័ព្ទ បណ្តុំពាក្យ ដែលអាចឆ្លុះបញ្ចាំងបានជាប្រយោលទៅលើទំនាក់ទំនងគ្នារវាងវត្ថុ និងបាតុភូត ទៅតាមលក្ខណៈធម្មជាតិរបស់វា ។ ពាក្យសំដី ពាក្យសរសេរ កន្សោមពាក្យ ដែលគេប្រើប្រាស់ដោយឆ្លុះបញ្ចាំងជាប្រយោលទៅលើវត្ថុ ឬបាតុភូតដែលគេធ្លាប់បាននិយាយ ឬបានស្គាល់រួចមកហើយនោះគឺជាប្រព័ន្ធសញ្ញាកម្មទី២ ។

ឧទាហរណ៍ ៖ គ្រូបង្រៀនសិស្សឱ្យស្គាល់ពីឈ្មោះបន្លែ ស្ពៃក្តោប ខាត់ណា ត្រប់ ប៉េងប៉ោះ ដោយបង្ហាញបន្លែទាំងនេះចំពោះមុខសិស្ស។ សិស្សស្គាល់ឈ្មោះបន្លែទាំងនោះ ជាលើកដំបូងបង្អស់ ។ នេះជាប្រព័ន្ធសញ្ញាកម្មទី១ ។ រូបភាពបន្លែមទាំងនេះ ស្ថិតជាប់អឌ្ឍគោលខួរ ។ ពេលមួយដែលគ្រូរំឭកឡើងវិញពីឈ្មោះបន្លែទាំងនេះ សិស្ស មានសមត្ថភាពស្គាល់ឡើងវិញបានតាមរយៈពាក្យ កន្សោមពាក្យ ឬមានសមត្ថភាពចងចាំរហូតដល់អាចគូររូបបានឡើងវិញដោយមិនបាច់មើលឈ្មោះបន្លែជាក់ស្តែង ។ នេះជាប្រព័ន្ធសញ្ញាកម្មទី២ ។

**ឧទាហរណ៍** ៖ ពេលភ្នែកមើលឃើញផ្លែស្វាយ រូបភាពផ្លែស្វាយជិតជាប់នៅក្នុងខួរក្បាល យើងឱ្យឈ្មោះហៅថា សញ្ញាកម្មទី១ ។ សញ្ញាកម្មទី១នេះ ត្រូវជំនួសដោយសញ្ញា « ព » ដែលយើងឱ្យឈ្មោះហៅថាអក្សរ នោះគឺជា សញ្ញាកម្មទី២ (ផ្លែស្វាយ) ។

ប្រព័ន្ធសញ្ញាកម្មទាំងពីរនេះកើតមាន និងអភិវឌ្ឍឡើងនៅក្នុង ៖

- ការបង្រៀនសិស្សដោយប្រើសម្ភារឧបទេស
- លំនាំកាយពលកម្ម និងបញ្ញាពលកម្ម
- ការហ្វឹកហ្វឺនទៅលើវិស័យណាមួយ
- លំនាំអភិវឌ្ឍន៍នៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ
- លក្ខខណ្ឌចាំបាច់នៃជីវភាពរស់នៅក្នុងសង្គម
- លំនាំនៃការស្វែងយល់ ឬការស្គាល់មជ្ឈដ្ឋានជាច្រើន
- ទំនាក់ទំនងរវាងបុគ្គល និងបុគ្គលក្នុងសង្គម ។

## IV- សន្និដ្ឋាន

ការសិក្សាពីទំនាក់ទំនងរវាងចិត្តវិទ្យា និងសរីរៈវិទ្យាអាចឱ្យយើងទទួលបានចំណេះដឹងជាច្រើន ស្តីពីមុខងាររបស់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស រ៉េផ្លិចលក្ខខណ្ឌ រ៉េផ្លិចឥតលក្ខខណ្ឌ និងប្រភេទផ្សេងៗនៃសកម្មភាពរបស់ប្រព័ន្ធសរសៃប្រសាទ ពិសេសគឺយកមកអនុវត្តក្នុងការបង្រៀន និងរៀនប្រកបដោយជោគជ័យ ។

### សំណួរ

១. តើចិត្តវិទ្យា និងសរីរៈវិទ្យាមានទំនាក់ទំនងគ្នាដូចម្តេចខ្លះ ?
២. តើប្រព័ន្ធសរសៃប្រសាទផ្នែកកណ្តាលមានមុខងារដូចម្តេចខ្លះ ?
៣. ចូរបកស្រាយប្រព័ន្ធសរសៃប្រសាទបរិមណ្ឌល ។
៤. តើណឺរ៉ូនមានមុខងារយ៉ាងដូចម្តេចខ្លះ ?
៥. តើគ្រូបង្រៀនត្រូវធ្វើដូចម្តេច ដើម្បីឱ្យសិស្សមានរ៉េផ្លិចលក្ខខណ្ឌ ?
៦. ចូរបកស្រាយពីច្បាប់បម្លែងរំញោច ឱ្យទៅជាការទប់រំញោច។
៧. តើច្បាប់នៃសកម្មភាពប្រព័ន្ធសរសៃប្រសាទមានសារៈប្រយោជន៍យ៉ាងណាចំពោះមនុស្ស? ចូរលើកឧទាហរណ៍បញ្ជាក់ ។

# មេរៀនទី៣ ញាណ

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីញាណ អនុញាណ អញាណ
- បកស្រាយបានច្បាស់លាស់អំពីកម្រិតផ្សេងៗនៃញាណរបស់មនុស្ស
- មានទំនុកចិត្តលើខ្លឹមសារនៃសកម្មភាពបង្រៀនទៅនឹងកម្រិតញាណរបស់សិស្សម្នាក់ៗ ។

## II- សេចក្តីផ្តើម

ដើម្បីយល់ដឹងពីអ្វីៗដែលនៅជុំវិញខ្លួន មនុស្សម្នាក់ៗត្រូវកំណត់ច្បាស់ពីអ្វីៗទាំងនោះតាមរយៈញាណ ។

## III- ខ្លឹមសារ

### ១- និយមន័យ

ញាណ គឺជាសតិ(សមត្ថភាព)យល់ដឹងនូវបាតុភូតចិត្ត គឺមានន័យថា ជាសមត្ថភាពស្គាល់នូវអ្វីដែលកើតមានឡើងនៅខាងក្រៅ និងខាងក្នុងខ្លួនយើង ។

នៅក្នុងខ្លួនយើងមានញាណ ដែលធ្វើឱ្យយើងដឹងថា យើងកើតទុក្ខ យើងសប្បាយ ...។

មានមនសិការមានន័យថាយើងមានការភ្ញាក់រឭក យើងដឹង ឬក៏មានន័យថា យើងគិត យើងមានសញ្ចេតនា និងមានឥន្ទ្រីយារម្មណ៍ ។ យើងមិនត្រូវមានការភ័ន្តច្រឡំពាក្យ ចិត្តញាណ និងសីលញាណឡើយ។ ចិត្តញាណធ្វើឱ្យយើងយល់ដឹងអំពើដែលយើងប្រព្រឹត្ត។ សីលញាណប្រាប់យើងថាអំពើដែលយើងធ្វើនោះល្អ ឬអាក្រក់ វាទូន្មានយើង លួងលោមយើង។ ល ។

### ២- កម្រិតញាណ

ញាណមិនមែនបំភ្លឺបាតុភូតចិត្តទាំងអស់ក្នុងកម្រិតស្មើគ្នាទេ ។ ក្នុងដែនញាណរបស់យើងតែងមានកន្លែងខ្លះទទួលពន្លឺខ្លាំង កន្លែងខ្លះទទួលពន្លឺតិច កន្លែងខ្លះទៀតស្ទើរតែគ្មានទទួលពន្លឺបន្តិចសោះ ។ កន្លែងទទួលពន្លឺខ្លាំង (ដឹងច្បាស់)ហៅថា ញាណការណ៍(ញាណ) កន្លែងភ្លឺព្រាលៗ(ដឹងតិចៗ) ហៅថាអនុញាណ កន្លែងងងឹតហៅថាអញាណ។ ដូចនេះ ញាណមានបីកម្រិត។

ឧទាហរណ៍៖

ក. កាលណាយើងយកចិត្តទុកដាក់លើហេតុការណ៍មួយយើងយល់ច្បាស់ពីហេតុការណ៍នោះគឺ ញាណការណ៍ (fait de conscience)។

ខ. ពេលដែលយើងដើរលេងបណ្តើរជជែកជាមួយមិត្តភក្តិបណ្តើរ យើងឃើញអ្នកដទៃផង ហើយអាចចៀសមិន ឱ្យប៉ះអ្នកទាំងនោះផង ប្រត្យក្សារម្មណ៍ពីអ្នកដទៃ នៅពេលនោះមានលក្ខណៈទូលំទូលាយមិនច្បាស់លាស់ ។ នេះគឺ កម្រិតញាណបន្ទាប់បន្សំ។ ពេលខ្ញុំធ្វើការងារ ខ្ញុំហាក់មិនចាប់អារម្មណ៍ពីសំឡេងទិចតាក់របស់នាឡិកា ឬក៏ចាប់ អារម្មណ៍តែបន្តិចបន្តួច នេះគឺបាតុភូតអនុញាណ។

គ. នៅពេលយើងចូលសំងំដេក ញាណរបស់យើងបន្ថយថាមពល បន្ទាប់មកយើងបាត់ញាណទាំងស្រុង ។ ប៉ុន្តែពេលនោះ អនុស្សាវរីយ៍ គំនិត សញ្ចេតនាបន្តអត្ថិភាពក្នុងគំនិតយើង តែយើងមិនដឹងខ្លួនឡើយ ទោះបីយើងខំរំឭក យ៉ាងណាក្តីនេះគឺបាតុភូតអញាណ ។

ពេលខ្លះយើងកំពុងដេកលក់ មានគេចាក់ចម្រៀង ឬមានបាតុភូតអ្វីមួយកើតឡើង យើងហាក់ដូចយល់សប្តិឃើញ យើងស្តាប់ចម្រៀងនោះ ឬជួនកាលយើងហាក់ឮចម្រៀងល្វើយៗ ដោយមិនដឹងខ្លួន ។

ដើម្បីងាយយល់យើងធ្វើការប្រៀបធៀប៖ ក្នុងខួរក្បាលយើង នៅពេលដែលយើងស្ថិតក្នុង " ញាណ " ប្រៀបបាន ទៅនឹងបន្ទប់មួយបំភ្លឺដោយពន្លឺខ្លាំងក្លា។ យើងឃើញវត្ថុ ទាំងឡាយដែលនៅក្នុងនោះបានច្បាស់លាស់។ នៅពេល យើងដេកលក់ខួរក្បាលរបស់យើងប្រៀបបានទៅនឹងបន្ទប់ដែលបំភ្លឺដោយពន្លឺខ្សោយបំផុត។ ពេលនោះយើងមើលវត្ថុ ទាំងឡាយក្នុងនោះដោយលំបាកបំផុតជួនកាលមើលមិនឃើញផង។ ហេតុនេះបាតុភូតចិត្តទាំងអស់ស្ទើរតែមិនអាច ដឹងបានដោយញាណ។ ញាណដឹងបានតែមួយផ្នែកតូចនៃសញ្ចេតនា អនុស្សាវរីយ៍ គំនិត ដែលមាននៅក្នុងខ្លួនយើង ចំណែកអ្វីផ្សេងទៀតត្រូវភ្លេចអស់។

តាមការពិតញាណរបស់យើងដែលរក្សាទុកអនុស្សាវរីយ៍យ៉ាងសន្ធឹកសន្ធាប់បានផ្តល់ទៅឱ្យលំនឹកបន្តិចម្តងៗ ដោយសារភាពចាំបាច់នៃសកម្មភាពរបស់យើងប៉ុណ្ណោះ ។ បើសិនជាយើងមានគំនិតមានអនុស្សាវរីយ៍ទាំងអស់តែម្តង ព្រមៗគ្នាយើងមិនអាចធ្វើសកម្មភាពបៀបណាមួយបានឡើយព្រោះគំនិត និងសញ្ចេតនាទាំងនោះនឹងរំខានយើង។

ដូចនេះញាណរំឭកឱ្យយើងដឹងតែអនុស្សាវរីយ៍ណាដែលយើងត្រូវការរាល់ពេលនៅក្នុងជីវភាព ហើយរក្សាទុក ហេតុការណ៍ផ្សេងៗទៀតនៅក្នុងទីងងឹត ជាធម្មតាអញ្ញាណមានសារៈសំខាន់ជាងញាណ ព្រោះអញ្ញាណរក្សាទុកគំនិត យ៉ាងសំបូរបែបនៅក្នុងខួរក្បាលរបស់យើងទៅតាមបទពិសោធនៃគថភាព។ ដើម្បីយល់ពីអ្វីៗដែលកើតមានឡើងនៅ ក្នុងខួរក្បាល យើងធ្វើការឧបមាខួរក្បាលរបស់យើងទៅនឹងបន្ទប់ក្រោមទីងងឹតដែលមានប្រហោងតូចចង្អៀតមួយហើយ មានពន្លឺអាចឆ្លងកាត់។ បាច់ពន្លឺនេះអាចបំភ្លឺបាន តែវត្ថុមួយចំនួនដែលនៅជុំវិញប៉ុណ្ណោះ ក្រៅពីនេះគឺទីងងឹត។

ខួរក្បាលយើងក៏ដូចនេះដែរ អាចដឹងបានតែលើអ្វីៗដែលញាណបានបំភ្លឺប៉ុណ្ណោះ ។ ញាណក៏ដូចជាកាំពន្លឺដែល អាចប្តូរទីកន្លែងនៅទីងងឹត ។ ញាណរបស់យើងអាចដឹងបានអ្វីៗដែលនៅជុំវិញខ្លួន។

ដូចនេះសកម្មភាពរបស់ខួរក្បាលយើងមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ។ បាតុភូតចិត្តនឹងអាចស្ថិតស្ថេរបានតែ មួយរយៈពេលប៉ុណ្ណោះក្នុងញាណរបស់យើង។

តាមទម្លាប់ញាណអាចថយចុះ ឬបាត់បង់ទៅវិញ។ ហេតុនេះ ដើម្បីដើរ សរសេរ អាន ធ្វើពលកម្ម ជាបឋមយើង ត្រូវចាប់អារម្មណ៍លើរាល់ឥន្ទ្រីយារម្មណ៍ទាំងអស់។

ពីដំបូងយើងមានការចាប់អារម្មណ៍ខ្លាំងលើការងារដែលយើងគិតថាលំបាកចំពោះយើង។ បន្ទាប់មក និងនៅទី បញ្ចប់ឥន្ទ្រីយារម្មណ៍ និងកាយវិការរបស់យើងក្លាយជាធម្មតាគឺ យើងមិនចាប់អារម្មណ៍ឡើយ ។ យើងធ្វើហាក់មិនដឹង ខ្លួន។ ភាគច្រើនពលកម្មបញ្ញា គឺជាការងារអញ្ញាណនៃខួរក្បាល។

ឧទាហរណ៍៖ មេរៀនមួយដែលសិស្សរៀនមិនទាន់ចេះពីល្ងាច ជួនកាលដល់ព្រឹកឡើងវាហាក់ដូចបានចេះជាង ពីល្ងាច ដោយហេតុថាពេលយប់អញ្ញាណបន្តធ្វើការរហូត។

### IV- សន្និដ្ឋាន

គំនិតយើង ទង្វើយើង អាស្រ័យមួយផ្នែកធំដោយជីវិតអញ្ញាណរបស់យើង ។ ដូចនេះយើងមិនត្រូវធ្វើសកម្មភាព តែទៅលើជីវិតញាណរបស់កុមារតែប៉ុណ្ណោះទេ ។ ត្រូវចូលឱ្យដល់អញ្ញាណរបស់កុមារតាមរយៈការទន្ទេញការខំប្រឹង។

តាមរយៈលំហាត់ដដែលៗ និងយូរអង្វែងទម្លាប់របៀបគិតនិងអំពើអាចចូលជ្រៅដល់សតិអារម្មណ៍ សិស្សកាល ណាគេរៀន។ ជួនកាលគេហាក់ដូចជាមានអារម្មណ៍ថាគេភ្លេចទាំងអស់ ។ ប៉ុន្តែតាមពិតចំណេះដឹងដែលមានទាំងនោះ ស្ថិតក្នុងអញ្ញាណរបស់គេ ហើយអាចបង្កើតបញ្ញារបស់គេផង។ លទ្ធផលជាក់ស្តែងផ្ទាល់នឹងភ្នែកនៃការអប់រំរបស់យើង មានតម្លៃតិចជាងលទ្ធផលដែលគេមើលមិនឃើញ ។

ការអភិវឌ្ឍខាងក្នុងផ្នែកបញ្ញា និងឆន្ទៈ គឺជាលក្ខខណ្ឌចាំបាច់នៃលទ្ធផលទៅអនាគត ។ ជួនកាលគេអាច បង្រៀនមនុស្សដេកលក់បាន តាមរយៈចាក់ខ្សែអាត់ ឬកាសែត CD VCD DVD USB ឱ្យមនុស្សដេកស្តាប់ ។

## សំណួរ

១- ពេលយើងដក់ចិត្តមើលរឿងក្នុងវីដេអូ ជួនកាលយើងមិនដឹងថាមានអ្វីៗកើតឡើងជុំវិញខ្លួនយើងទេ តើព្រោះអ្វី?

២- ពេលយើងដេកលក់ តើយើងបាត់បង់ញាណទាំងស្រុងឬទេ?

៣- តើបាតុភូតនៃការយល់សប្តិមានពាក់ព័ន្ធនឹងញាណរបស់យើងឬទេ? ចូរពន្យល់បាតុភូតនេះ ។

៤- តើចិត្តញាណ និងសីលញាណខុសគ្នាដូចម្តេច?

# មេរៀនទី៤ ឥន្ទ្រីយារម្មណ៍

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីបញ្ញត្តិ ចំណែកថ្នាក់ និងច្បាប់ឥន្ទ្រីយារម្មណ៍
- កំណត់បានពីមុខងារនៃឥន្ទ្រីយារម្មណ៍ ដោយបញ្ជាក់ឧទាហរណ៍នៃមុខងារនីមួយៗ
- មានទម្លាប់ប្រើប្រាស់ទ្រឹស្តីឥន្ទ្រីយារម្មណ៍ទៅនឹងការបង្រៀន និងរៀន ។

## II- សេចក្តីផ្តើម

លំនាំពុទ្ធិ សំដៅដល់តថភាពសត្យានុម័តមានទម្រង់ច្រើនយ៉ាងប្លែកៗ ហើយស្មុគស្មាញទៀតផង។ ចំណាំងពីតថភាពសត្យានុម័តនេះប្រព្រឹត្តមកលើមនុស្សគ្រប់ពេលវេលា។ មនុស្សរស់នៅនិងអភិវឌ្ឍដោយមានសមត្ថភាពឆ្លុះបញ្ចាំងរាល់អំពើ និងលក្ខណៈនៃវត្ថុ ឬបាតុភូតដែលស្ថិតនៅក្នុងតថភាពសត្យានុម័តនេះ ។ សមត្ថភាពឆ្លុះបញ្ចាំងនេះបានធ្វើឱ្យមនុស្សមានពុទ្ធិចំពោះបរិស្ថានជុំវិញ និងអាចបន្សាំខ្លួនទៅនឹងបរិស្ថាននោះបានទេ ។ តាមធម្មតាក្នុងសកម្មភាពពុទ្ធិនេះ មានលំនាំពីរគឺ ពុទ្ធិឥន្ទ្រីយ៍ និងពុទ្ធិវិចារ។

ពុទ្ធិឥន្ទ្រីយ៍ ជាលំនាំពុទ្ធិដែលឆ្លុះបញ្ចាំងតថភាពសត្យានុម័តដោយប្រើឥន្ទ្រីយ៍។ ពុទ្ធិឥន្ទ្រីយ៍មានឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ ។

ដូចនេះ ក្នុងការរស់នៅរបស់មនុស្សម្នាក់ៗត្រូវការប្រើប្រាស់សរីរាង្គឥន្ទ្រីយ៍ទាំង៥ ដើម្បីទទួលយកចំណេះដឹងពីតថភាពដែលនៅជុំវិញខ្លួនយើង។

## III- ខ្លឹមសារ

### ១. និយមន័យ

ឥន្ទ្រីយារម្មណ៍ គឺលំនាំចិត្តសាមញ្ញបំផុតដែលឆ្លុះបញ្ចាំងលក្ខណៈតែម្យ៉ាង ឬទោលនៃវត្ថុ ឬបាតុភូតទាំងឡាយដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍។ ឥន្ទ្រីយារម្មណ៍ឆ្លុះបញ្ចាំងផងដែរនូវសភាពខាងក្នុងនៃសារពាង្គកាយយើង។

ឥន្ទ្រីយារម្មណ៍ គឺជាអារម្មណ៍ដំបូងដែលត្រូវបានបញ្ជូនទៅញាណរបស់យើង តាមរយៈសរីរាង្គឥន្ទ្រីយ៍ និងសរសៃប្រសាទ។

| | | |
|---|---|---|
| ឧទាហរណ៍ទី១៖ | មើលក្តារខៀន | ឃើញពណ៌ស |
| | មើលផ្កាកុលាប | ឃើញពណ៌ក្រហម |
| | ហិតក្លិនផ្កាចំប៉ា | ដឹងថាមានក្លិនក្រអូប |
| | លូកដៃប៉ះភ្លើង | ដឹងថាក្តៅ។ |
| ឧទាហរណ៍ទី២៖ | ពេលឃ្លានបាយ ក្ររពោះ...។ | |

ដោយសារឥន្ទ្រីយារម្មណ៍ ធ្វើឱ្យយើងអាចដឹងពី៖ ពណ៌ ក្លិន សីតុណ្ហភាព ទម្រង់ រសជាតិ ភាពទន់ ជ្រាយនៃវត្ថុ ។ ឥន្ទ្រីយារម្មណ៍មិនអាចឆ្លុះបញ្ចាំងលក្ខណៈទាំងស្រុងនៃវត្ថុបានទេ ឥន្ទ្រីយារម្មណ៍អាចឆ្លុះបញ្ចាំងបានតែលក្ខណៈដាច់មួយៗរបស់វត្ថុ ឬបាតុភូតប៉ុណ្ណោះ។

### ២. តួនាទី

ឥន្ទ្រីយារម្មណ៍មានតួនាទីសំខាន់ណាស់សម្រាប់ការរស់នៅរបស់មនុស្សម្នាក់ៗ ។ វាជាមូលដ្ឋានគ្រឹះក្នុងការបង្កើតរាល់ពុទ្ធិ និងបាតុភូតចិត្តរបស់មនុស្ស ។ បើសិនជាគ្មានឥន្ទ្រីយារម្មណ៍ក៏គ្មានបាតុភូតចិត្ត និងពុទ្ធិបានដែរ ។

ឧទាហរណ៍ ៖ បុគ្គលម្នាក់បាត់បង់សរីរាង្គឥន្ទ្រីយ៍(សោត) នោះបុគ្គលនោះគ្មានសោតិន្ទ្រីយារម្មណ៍បាត់បង់

បាតុភូតចិត្ត និងពុទ្ធិដែលទាក់ទងសោតវិញ្ញាណ ។

ឥន្ទ្រីយារម្មណ៍ ឆ្លុះបញ្ចាំងលក្ខណៈនីមួយៗ ដាច់ដោយឡែកពីគ្នារបស់វត្ថុ ឬបាតុភូតហើយមិនអាចឆ្លុះបញ្ចាំងលក្ខណៈទូទៅនោះទេ។ ឥន្ទ្រីយារម្មណ៍ឆ្លុះបញ្ចាំងដោយផ្ទាល់លើវត្ថុ ឬបាតុភូតទាំងឡាយដែលកំពុងប្រព្រឹត្តមកលើសរីរាង្គឥន្ទ្រីយ៍របស់យើង។

ដូច្នេះ ឥន្ទ្រីយារម្មណ៍ជាលំនាំចិត្តដ៏សាមញ្ញបំផុត ដែលមិនអាចឱ្យយើងស្គាល់បានទេ ឬញែកឱ្យដាច់ពីគ្នាបានចំពោះវត្ថុណាមួយបានឡើយ។ ប៉ុន្តែឥន្ទ្រីយារម្មណ៍មាននាទីសំខាន់ណាស់ក្នុងជីវភាពរស់នៅរបស់មនុស្សម្នាក់ៗដោយហេតុថា បើគ្មានឥន្ទ្រីយារម្មណ៍ នោះមនុស្សនឹងពុំអាចស្គាល់ទម្រង់ណាមួយនៃរូបធាតុ ឬទម្រង់នៃចលនាបានឡើយ។

### ៣. មូលដ្ឋាន សរីរៈវិទ្យារ បស់ឥន្ទ្រីយារម្មណ៍

ឥន្ទ្រីយារម្មណ៍អាចកើតមានប្រសិនបើមានវត្ថុ ឬបាតុភូតណាមួយធ្វើអំពើមកលើសរីរាង្គឥន្ទ្រីយ៍ ឬសរីរាង្គវិភាគរបស់យើង។

**សរីរាង្គទទួល**

- **សរីរាង្គសម្រាប់ទទួលរំញោច** គឺជាចុងនៃសរសៃប្រសាទដែលទទួលវេទនារម្មណ៍។

**ឧទាហរណ៍៖** ចក្ខុវិញ្ញាណទទួលរំញោចដោយសាររ៉េទីន នូវពណ៌ និងទម្រង់នៃវត្ថុ។

- **សរសៃប្រសាទប្រទាញចូល** សម្រាប់បញ្ជូនរំញោចទៅមណ្ឌលប្រសាទ ឬទៅកាន់ខួរក្បាល។

**ឧទាហរណ៍ ៖** សរសៃប្រសាទអុបទិច(ចក្ខុវិញ្ញាណ)

- **ផ្នែកមួយដែលទាក់ទងនឹងអឌ្ឍគោលខួរ** (ជាផ្នែកកណ្ដាលនៃសរីរាង្គវិភាគជាកោសិកានៃសរសៃប្រសាទដែលជាប់ទាក់ទងនឹងអឌ្ឍគោលខួរក្បាល)៖ គឺកន្លែងនេះហើយដែលបង្កើតបានជាឥន្ទ្រីយារម្មណ៍ ។

**ឧទាហរណ៍ ៖** សរីរាង្គចក្ខុវិញ្ញាណ គឺកំពកពយនៃសំបកខួរក្បាល(គឺខួរកញ្ចឹងកដែលនាំព័ត៌មានទៅកាន់សំបកខួរក្បាល)។

**ឧទាហរណ៍ ៖** ផ្កាពណ៌ក្រហមនាំឱ្យរ៉េទីនមានរំញោច"ឃើញពណ៌ក្រហម" ។ សរសៃប្រសាទប្រទាញចូលបានបញ្ជូនរំញោច"ពណ៌ក្រហម" ទៅកាន់ខួរក្បាល ។ផ្នែកមួយនៃអឌ្ឍគោលខួរវិភាគរំញោច និងផ្តល់ឱ្យជាឥន្ទ្រីយារម្មណ៍ "ពណ៌ក្រហម"។

ឥន្ទ្រីយារម្មណ៍ កើតមាននៅក្នុងមជ្ឈមណ្ឌលនៃសរសៃប្រសាទ ដែលពាក់ព័ន្ធទៅនឹងសំបកខួរក្បាល។ ប្រសិនបើសកម្មភាពទាំងបី (រ៉េទីន សរសៃប្រសាទអុបទិច និងកំពកពយនៃសំបកខួរក្បាល) កើតមានឡើង ព្រមគ្នានោះឥន្ទ្រីយារម្មណ៍នឹងកើតមានឡើង។

### ៤. ចំណែកថ្នាក់ របស់ឥន្ទ្រី យារម្មណ៍

គេចែកឥន្ទ្រីយារម្មណ៍ជាពីរក្រុម៖ **ឥន្ទ្រី យារម្មណ៍ក្រៅ និងឥន្ទ្រី យារម្មណ៍ក្នុង** ។

៤.១. ឥន្ទ្រី យារម្មណ៍ក្រៅ គឺជាឥន្ទ្រីយារម្មណ៍ ដែលបង្កើតឡើងដោយរំញោចស្ថិតនៅខាងក្រៅសរីរាង្គកាយរបស់មនុស្សយើង។ ឥន្ទ្រីយារម្មណ៍ក្រៅមាន៖

- ចក្ខិន្ទ្រី យារម្មណ៍ ឬ ឥន្ទ្រី យារម្មណ៍នៃចក្ខុវិញ្ញាណ ផ្តល់ឱ្យយើងពីទម្រង់នៃរូបភាព ពន្លឺពណ៌សម្បុរ វិមាត្រ ចម្ងាយ និងទិសនៃវត្ថុ។ ឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណបំពេញតួនាទីមួយយ៉ាងសំខាន់នៅក្នុងការស្គាល់បានចំពោះពិភពខាងក្រៅខ្លួនរបស់មនុស្ស តាមរយៈពន្លឺដែលចាំងមកពីវត្ថុដែលនៅជុំវិញខ្លួនយើង។

- សោតិន្ទ្រី យារម្មណ៍ ឬឥន្ទ្រី យារម្មណ៍នៃសោតវិញ្ញាណ ផ្តល់ឱ្យយើងដឹងពីសូរសំឡេងដែលបង្កដោយរលកសំឡេងពោលតាមរយៈរំញ័រនៃខ្យល់ ។ ដោយសារឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណនេះហើយ ដែលមនុស្សអាចមានទំនាក់ទំនងនឹងគ្នា តាមរយៈភាសាដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ហេតុការណ៍ដែលបានកើតមានឡើង។

- **ឃានិន្ទ្រី យារម្មណ៍ ឬឥន្ទ្រី យារម្មណ៍ នៃឃានវិញ្ញាណ** ផ្តល់ឱ្យយើងស្គាល់ ដឹងក្លិនផ្សេងៗ។ ឃានវិញ្ញាណមានអត្ថប្រយោជន៍ នៅពេលដែលឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណ និងសោតវិញ្ញាណមានការខូចបង់ទៅនោះ ឥន្ទ្រីយារម្មណ៍នៃឃានវិញ្ញាណ និងឥន្ទ្រីយ៍ដទៃទៀតដែលនៅមានសេសសល់មានតួនាទីសំខាន់ៗ ដោយឡែកពីគ្នាមកជាជំនួយ។

- **ជីវ្ហិន្ទ្រី យារម្មណ៍ ឬឥន្ទ្រី យារម្មណ៍ នៃជីវ្ហាវិញ្ញាណ** ផ្តល់ឱ្យយើងស្គាល់រសជាតិផ្សេងៗ អាស្រ័យដោយការគួបផ្សំគ្នានៃឃានវិញ្ញាណផងដែរ។ ឥន្ទ្រីយារម្មណ៍ដែលទទួលបានពីជីវ្ហាវិញ្ញាណមានរស់ជាតិជូរ ល្វីង ប្រៃ។ល។ ហើយក៏មានការគួបផ្សំពីសំណាក់ឥន្ទ្រីយារម្មណ៍នៃឃានវិញ្ញាណផងដែរ។

- **កាយិន្ទ្រី យារម្មណ៍ ឥន្ទ្រី យារម្មណ៍ នៃកាយវិញ្ញាណ** គឺជាឥន្ទ្រីយារម្មណ៍កើតឡើងដោយការរំញោចនៃចលនា និងកម្តៅ។ ឥន្ទ្រីយារម្មណ៍នៃកាយវិញ្ញាណទទួលបានមកពីការប៉ះពាល់ សម្ពាធ កម្តៅ ភាពត្រជាក់ និងការឈឺចាប់នៅលើផ្ទៃស្បែកទូទៅនៃសព៌ាង្គកាយយើង ដោយអង្គល្អិតឆ្មារនៃកាយវិញ្ញាណ ដែលស្ថិតនៅចុងសរសៃប្រសាទនៃកាយឥន្ទ្រីយ៍ ។

### ៤.២. ឥន្ទ្រី យារម្មណ៍ក្នុង

ឥន្ទ្រីយារម្មណ៍ក្នុង គឺជាឥន្ទ្រីយារម្មណ៍ដែលបង្កឡើង ដោយសាររំញោចនៅខាងក្នុងខ្លួនមនុស្ស ។

#### ៤.២.១. ឥន្ទ្រី យារម្មណ៍ចលករ

ឥន្ទ្រីយារម្មណ៍ចលករ គឺជាឥន្ទ្រីយារម្មណ៍ដែលឆ្លុះបញ្ចាំងការផ្លាស់ប្តូរនៅក្នុងសរីរាង្គ នៃចលនាសាច់ដុំរបស់យើង។ ឥន្ទ្រីយារម្មណ៍នេះ ប្រាប់យើងឱ្យដឹងនូវការកន្ត្រាក់ទាញចុះឡើងនៃសរសៃពួររបស់សាច់ដុំ និងឥរិយាបថនៃដងខ្លួនរបស់យើង។

ឧទាហរណ៍៖ ពេលកំពុងរត់ ពេលកំពុងលោត ពេលកំពុងហែលទឹក ។

#### ៤.២.២. ឥន្ទ្រី យារម្មណ៍ លំនឹង

ឥន្ទ្រីយារម្មណ៍លំនឹង ដែលឆ្លុះបញ្ចាំងពីឥរិយាបថ និងចលនានៃក្បាលមនុស្ស ។ សរីរាង្គឥន្ទ្រីយ៍នៃលំនឹងស្ថិតនៅត្រង់ផ្នែកក្នុងនៃត្រចៀក ។ ឥន្ទ្រីយារម្មណ៍លំនឹងនេះ មានទំនាក់ទំនងនឹងសរីរាង្គក្នុងខ្លួនដូចជា កាលណាមានការរំញោចខ្លាំងពេក វាអាចបង្កឱ្យមានការវិលមុខ។

ឧទាហរណ៍៖ ការវិលមុខនៅពេលជិះរថយន្ត ឬយន្តហោះ បណ្តាលមកពីខ្វះលំនឹង។

#### ៤.២.៣. ឥន្ទ្រី យារម្មណ៍ សរីរាង្គ

ឥន្ទ្រីយារម្មណ៍សរីរាង្គ គឺជាសភាពនៃអាការខាងក្នុងខ្លួនមនុស្សយើងរួមមាន ការឃ្លាន ការឆ្អែតឆ្អល់ ឈឺក្បាល ឈឺពោះ ការខ្ពើម ឬ រកកលក្អួត ។ល។

ឧទាហរណ៍៖ ការឃ្លាន ការស្រេក ការចង់ក្អួត ការឈឺចាប់ក្នុងក្រពះ ដោយជំងឺរលាកក្រពះ ។

## ៥. ច្បាប់ផ្សេងៗនៃឥន្ទ្រីយារម្មណ៍

### ៥.១. ច្បាប់ ព្រំ កំណត់នៃឥន្ទ្រី យារម្មណ៍

ឥន្ទ្រីយារម្មណ៍ក៏ដូចជាប្រភេទផ្លូវចិត្តដទៃទៀត ដែលគ្រប់លំនាំចិត្តតែងតែប្រព្រឹត្តទៅតាមច្បាប់ទាំងអស់ ។ ដូច្នេះ ឥន្ទ្រីយារម្មណ៍ក៏ប្រព្រឹត្តទៅតាមក្រឹត្យក្រមរបស់ខ្លួនដែរ ។

រំ... ...ដលមានមកលើសរីរាង្គឥន្ទ្រីយ៍ បង្កើតបានជាឥន្ទ្រីយារម្មណ៍។ ដូច្នេះដើម្បីបង្កឱ្យមានឥន្ទ្រីយារម្មណ៍ ...មានព្រំដែនច្បាស់លាស់ហៅថា"ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍" ដែលមានពីរកម្រិតគឺ **ព្រំកំណត់** ...**ណត់កម្រិតខ្ពស់** ហើយការឃ្លាតពីគ្នារវាងកម្រិតព្រំទាំងពីរហៅថា **ព្រំកំណត់ខុសគ្នា** ។

...**ក់នៃឥន្ទ្រី យារម្មណ៍ កម្រិតទាប** គឺជាកម្លាំងអប្បបរមានៃរំញោចដែលគ្រប់គ្រាន់ល្មមក្នុងការ

បង្កើតបានជាឥន្ទ្រីយារម្មណ៍ ។

ឧទាហរណ៍៖ កម្រិតសំឡេងរបស់គ្រូហៅសិស្សឈ្មោះ "ក" នៅអង្គុយខាងក្រោយ ហើយអាចឱ្យសិស្សឈ្មោះ "ក" នោះអាចឮបាន។ បើតិចជាងនេះ សិស្សឈ្មោះ "ក" ស្តាប់មិនឮ ព្រោះកម្លាំងរំញោចនោះស្ថិតនៅក្រោមព្រំទាប។ ពន្លឺតិចពេកធ្វើឱ្យចក្ខុវិញ្ញាណរបស់យើងមិនអាចផ្តិតយករូបភាពពិតប្រាកដបាន។

**៥.១.២. ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍កម្រិតខ្ពស់** គឺជាកម្លាំងអតិបរិមានៃរំញោច ហួសពីនេះគឺមិនអាចមានឥន្ទ្រីយារម្មណ៍ឡើយ។

ឧទាហរណ៍៖ កាលណាយើងឮរន្ទះ យើងពុំអាចឮអ្វីទៀតក្រៅពីនេះឡើយ ។ ដូចគ្នា កាលណាពន្លឺខ្លាំងពេកនាំឱ្យភ្នែករបស់យើងមិនអាចមើលចំបានដែរ ។ សំឡេងមីក្រូខ្លាំងពេកធ្វើឱ្យយើងស្តាប់មិនបាន (ញែកសូរមិនបាន) ។

ដូច្នេះ សាស្ត្រាចារ្យមិនត្រូវនិយាយដោយសំឡេងតិចពេកទេ ព្រោះនាំឱ្យសិស្សស្តាប់ពុំបាន ព្រោះសំឡេងរបស់គាត់ស្ថិតនៅក្រោមព្រំទាបនៃសោតវិញ្ញាណ ហើយក៏មិនត្រូវប្រើសំឡេងខ្ពស់ពេក នាំឱ្យមានការរំខានផងដែរ ។ ដូចគ្នានេះដែរ ថ្នាក់រៀនត្រូវរៀបចំឱ្យមានពន្លឺគ្រប់គ្រាន់ទៀតផង ។

**៥.១.៣. ព្រំកំណត់ខុសគ្នានៃ ឥន្ទ្រីយារម្មណ៍**

គឺកម្រិតបន្ថែម ឬបន្ថយនៃកម្លាំងរំញោចដែលអាចឱ្យមនុស្សញែករំញោចពីរដាច់ពីគ្នា ។

ឧទាហរណ៍៖ យើងមានអង្ករមួយគីឡូក្រាមយួរក្នុងដៃ។ បើគេដាក់បន្ថែមអង្ករ ៣ ឬ៤គ្រាប់ទៀត នោះយើងពុំអាចដឹងថាមានទម្ងន់បន្ថែមទេ។ លុះត្រាតែគេថែមអង្ករ១ក្តាប់ថែមទៀតទើបយើងដឹងថា មានទម្ងន់ខុសគ្នា។ កំណើននៃទម្ងន់នេះ នឹងកើតមានបានលុះត្រាតែទម្ងន់បន្ថែមនោះស្មើនឹង១ភាគ២០នៃទម្ងន់ដើមដំបូង។ ទម្ងន់អង្ករបន្ថែមបង្កើតបានជាព្រំកំណត់ខុសគ្នានៃឥន្ទ្រីយារម្មណ៍។

## ៥.២. ច្បាប់សម្របសម្រួល(បន្សាំ)នៃឥន្ទ្រីយារម្មណ៍

ដើម្បីឆ្លុះបញ្ចាំងឱ្យបានល្អប្រសើរ និងដើម្បីការពារប្រព័ន្ធប្រសាទផងនោះ ឥន្ទ្រីយារម្មណ៍ត្រូវមានសមត្ថភាពបន្សាំតាមរំញោចទាំងឡាយ។ ភាពបន្សាំ គឺជាសតិមួយដែលធ្វើឱ្យផទនារម្មណ៍របស់ឥន្ទ្រីយារម្មណ៍ផ្លាស់ប្តូរបានគឺសំដៅធ្វើឱ្យការផ្លាស់ប្តូរនៃកម្លាំងរំញោចមានភាពសមស្រប។ បើកាលណាកម្លាំងរំញោចកើនឡើង ឥន្ទ្រីយារម្មណ៍ត្រូវថយចុះ ផ្ទុយទៅវិញកាលណាកម្លាំងរំញោចថយចុះ ឥន្ទ្រីយ៍ភាពកើនឡើង។ ដោយសារសមត្ថភាពបន្សាំនេះនាំឱ្យច្បាប់បន្សាំនៃឥន្ទ្រីយារម្មណ៍មានផលសំខាន់ខ្លាំង។

ឧទាហរណ៍៖ ពេលយើងចូលក្នុងរោងភាពយន្តកំពុងបញ្ចាំង ដំបូងយើងមើលមិនឃើញអ្វីទាំងអស់ តែបន្ទាប់មកបន្តិច យើងអាចមើលឃើញអ្វីៗជាបន្តបន្ទាប់។

## ៥.៣. ច្បាប់ផ្ទុយគ្នានៃ ឥន្ទ្រីយារម្មណ៍

ភាពផ្ទុយគ្នានៃឥន្ទ្រីយារម្មណ៍នេះ កើតឡើងពីបាតុភូតនៃទង្វើបញ្ច្រាស់គ្នារវាងឥន្ទ្រីយារម្មណ៍ដែលមានប្រភេទដូចគ្នា។

ឧទាហរណ៍៖ បើយើងយកកំណាត់សំពត់ពណ៌ប្រផេះពីរផ្ទាំង មួយដាក់លើផ្ទៃពណ៌ស និងមួយផ្ទាំងទៀតដាក់លើផ្ទៃពណ៌ខ្មៅ ។ នោះកំណាត់សំពត់ដែលដាក់លើផ្ទៃពណ៌សមានភាពស្រអាប់ជាង។

## ៥.៤. ច្បាប់នៃអំពើបញ្ច្រាសគ្នារវាងឥន្ទ្រីយារម្មណ៍ (ច្បាប់ប្រតិឃាដ)

ឥន្ទ្រីយារម្មណ៍ទាំងឡាយ ត្រូវបានទទួលរងនូវអំពើបញ្ច្រាសរវាងគ្នានិងគ្នា ហើយមិនអាចកើតឡើងដាច់ដោយឡែកពីគ្នាបានឡើយ ។ កាលណារំញោចដែលមានកម្លាំងខ្សោយប្រព្រឹត្តទៅលើសរីរាង្គវិភាគណាមួយនោះធ្វើឱ្យឥន្ទ្រីយារម្មណ៍នៃសរីរាង្គវិភាគដទៃទៀតកើនឡើង ។ ផ្ទុយទៅវិញ បើសរីរាង្គវិភាគមួយណារំញោចខ្លាំង នោះបណ្តាលឱ្យឥន្ទ្រីយារម្មណ៍នៃសរីរាង្គវិភាគដទៃទៀតថយចុះវិញ ។

ឧទាហរណ៍៖ ទឹកស្ករដូសដាក់ក្នុងកែវពីរផ្សេងគ្នា ដោយមួយកែវទុកឱ្យត្រជាក់ និងមួយកែវទៀតនៅក្តៅនៅឡើយ ។ ពេលគេបរិភោគទឹកស្ករទាំងពីរកែវនោះ គេមានអារម្មណ៍ថា ទឹកស្ករដែលត្រជាក់ផ្អែមជាង ។ បាតុភូតនេះបណ្តាលមកពីកម្តៅនោះជះឥទ្ធិពលទៅលើកាយិន្ទ្រីយារម្មណ៍ បណ្តាលឱ្យជីវ្ហិន្ទ្រីយារម្មណ៍ថយចុះ ។

## ៥.៥. ច្បាប់វិបល្លាស ដែលកើតមានក្នុងវេទនារម្មណ៍

យើងគប្បីធ្វើពិសោធ ដោយយកចង្កឹះឬស្លឹកពីរ ឬយកអំបែងកែវពីរមកត្រដុសលើគ្នា យើងនឹងដឹងថា មានអ្វីមួយដែលកើតឡើងនៅលើសរសៃប្រសាទរបស់យើង។ ដូច្នេះ យើងឃើញថា រំញោចដែលកើតមានមកលើ សោតវិញ្ញាណបង្កឱ្យមានឥន្ទ្រីយារម្មណ៍នៅក្នុងសរីរាង្គរបស់យើង។

នៅក្នុងភាសាណាក៏ដោយ គេតែងតែជួបប្រទះការសម្តែងចេញនូវវាចារដែលឆ្លុះបញ្ចាំងឱ្យឃើញបាតុភូតនៃវិបល្លាស ដែលកើតមានក្នុងវេទនារម្មណ៍របស់មនុស្សដូចជា ការប្រើល្បិចបោកបញ្ឆោត(Faire patte de veloure) ការប្រើសំដីផ្អែមល្ហែម(Voix mielleuse)។

ដោយសារច្បាប់នៃវិបល្លាសដែលកើតមានក្នុងវេទនារម្មណ៍របស់មនុស្ស គេអាចឈានដល់ការផលិតបាននូវឧបករណ៍ដែលមានលទ្ធភាពផ្លាស់ប្តូរសញ្ញានៃសំឡេង(Sinnaux sonores) ឱ្យទៅជាសញ្ញាភ្លើងពណ៌(Signaux en couleurs)។ ឧបករណ៍នេះបង្កើតបានជាសម្បទានៃសរីរាង្គដែលទទួលបាននូវអារម្មណ៍តាមសង្វាក់តូរ្យតន្ត្រី និងជម្រៅរបស់វា សម្រាប់អ្នកស្តាប់នៅក្នុងបន្ទប់ប្រគុំតូរ្យតន្ត្រីគេហៅថាតូរ្យតន្ត្រីដែលលម្អដោយពន្លឺភ្លើងពណ៌ (Musique chromatique)។ ដោយឈរលើមូលដ្ឋាននៃគោលការណ៍នេះ គេបានបង្កើតរួចមកហើយនូវឧបករណ៍សម្រាប់ផ្លាស់ប្តូរសញ្ញានៃពន្លឺ(Sinnaux lumineux) ឱ្យទៅជាសញ្ញានៃសំឡេង(Sinnaux sonores) សម្រាប់មនុស្សខ្វាក់ ហើយដោយសារតែឧបករណ៍នេះមនុស្សខ្វាក់អាចអានសៀវភៅបែបណាក៏បាន។

## IV- សន្និដ្ឋាន

ច្បាប់ឥន្ទ្រីយារម្មណ៍ដែលយើងបានសិក្សាខាងលើ មានអត្ថន័យធំធេងក្នុងការបង្រៀនសិស្សនៅគ្រប់កម្រិតសិក្សា ។ គ្រូបង្រៀនគ្រប់រូប ត្រូវចាប់យកចំណេះដឹងពីឥន្ទ្រីយារម្មណ៍នេះទៅអនុវត្តក្នុងការងារបង្ហាត់បង្រៀនសិស្សគ្រប់មុខវិជ្ជាឯកទេសទាំងអស់នៅក្នុងថ្នាក់រៀនដូចជា រៀបចំបន្ទប់រៀនឱ្យមានពន្លឺគ្រប់គ្រាន់ល្មម និងមានខ្យល់អាកាសចេញចូលល្អ ហើយហ្វឹកហ្វឺនសិស្សឱ្យចេះប្រើច្បាប់បន្សាំឥន្ទ្រីយារម្មណ៍ ។ គ្រូបង្រៀនត្រូវនិយាយដោយប្រើសំឡេងសមល្មម និងប្រើប្រាស់សម្ភារៈឱ្យបានសមស្រប និងត្រឹមត្រូវ ។

### សំណួរ

១- ដូចម្តេចដែលហៅថាឥន្ទ្រីយារម្មណ៍?

២- តើឥន្ទ្រីយារម្មណ៍មានតួនាទីអ្វីខ្លះ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ។

៣- ចូរបង្ហាញពីលក្ខណៈសំខាន់ៗរបស់ឥន្ទ្រីយារម្មណ៍ ។

៤- តើឥន្ទ្រីយារម្មណ៍មានប្រយោជន៍យ៉ាងដូចម្តេចខ្លះក្នុងការសិក្សា?

# មេរៀនទី៥ ប្រត្យក្សារម្មណ៍

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- បកស្រាយបានពីបញ្ញត្តិ កម្រិត និងច្បាប់ប្រត្យក្សារម្មណ៍
- ប្រៀបធៀបឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍
- ទម្លាប់យកច្បាប់ប្រត្យក្សារម្មណ៍ទៅប្រើប្រាស់ក្នុងការបង្រៀន និងរៀន។

## II- សេចក្តីផ្តើម

យើងបានដឹងរួចមកហើយពីមុខងារនៃឥន្ទ្រីយារម្មណ៍ ចំពោះការឆ្លុះបញ្ចាំងលើរាល់វត្ថុឬបាតុភូតទាំងឡាយ ក៏ប៉ុន្តែរាល់ការឆ្លុះបញ្ចាំងទាំងនោះមានភាពស្មុគស្មាញចំពោះការខុសប្លែកគ្នាខាងផ្នែកគុណភាពនិងលក្ខណៈ ។ ដូចនេះដើម្បីធ្វើឱ្យបានប្រាកដប្រជាលើរាល់វត្ថុ ឬបាតុភូតនោះតួនាទីឥន្ទ្រីយារម្មណ៍ ត្រូវធ្វើសំយោគនៅលើសំបកខួរក្បាលដោយបង្កើតជារូបភាពទាំងមូលត្រឹមត្រូវឥតខ្ចោះ ដែលជាប់ពាក់ព័ន្ធនឹងវត្ថុ ឬបាតុភូតទាំងនោះ ។ ចំណាំងពេញលេញគ្រប់គ្រាន់នៃតថភាពនេះ គឺប្រត្យក្សារម្មណ៍ ។ ហេតុដូចនេះ យើងគួរតែញែកឱ្យដាច់ពីគ្នារវាងឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ ដើម្បីឱ្យការសិក្សារបស់យើងមានភាពច្បាស់លាស់ ។ ប៉ុន្តែតាមការពិត លំនាំទាំងពីរនេះផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ។ កាលណាគេទទួលឥន្ទ្រីយារម្មណ៍ ភ្លាមនោះគេក៏បានទទួលប្រត្យក្សារម្មណ៍ផងដែរ។ គេប្រាកដជាគ្មានប្រត្យក្សារម្មណ៍ បើគេគ្មានឥន្ទ្រីយារម្មណ៍នោះទេ ។

## III- ខ្លឹមសារ

### ១. និយមន័យ

ប្រត្យក្សារម្មណ៍ គឺជាលំនាំចិត្តដែលឆ្លុះបញ្ចាំងលក្ខណៈទាំងស្រុងរបស់វត្ថុ ឬបាតុភូត ដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រិយ៍របស់យើង។

ឧទាហរណ៍៖ យើងទទួលប្រត្យក្សារម្មណ៍ពីនាឡិកាដៃ ពេលនោះយើងឃើញនាឡិកាដៃ ដោយប្រើភ្នែកដើម្បីមើល(មូលឬជ្រុង) និងចលនាទ្រនិច(កំពុងដើរ) និងពណ៌។ ប្រសិនបើយើងប្រើម្រាមដៃរបស់យើង ដើម្បីស្ទាប់លើផ្ទៃកញ្ចក់ ពេលនោះយើងដឹងថា ផ្ទៃកញ្ចក់នាឡិកានោះរលោង។

ប្រត្យក្សារម្មណ៍ផ្តល់ឱ្យយើងដឹងនូវរូបភាពទាំងស្រុងទៅលើវត្ថុ ទោះបីរូបភាពនោះមានលក្ខណៈមិនពេញលេញក៏ដោយ ឱ្យតែយើងធ្លាប់បានដឹង ឬបានស្គាល់ម្តងរួចមកហើយ។

ឧទាហរណ៍៖ បើមានរូបភាពមួយ ជាវត្ថុដែលយើងឃើញត្រឹមតែផ្នែកខ្លះដូចជា ស្លាប និងកន្ទុយ នោះយើងអាចដឹង និងអាចធ្វើសេចក្តីសន្និដ្ឋានបានថា រូបភាពនៃវត្ថុនោះ គឺជារូបយន្តហោះ។

### ២. ប្រៀបធៀបឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍

ប្រៀបធៀបឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍៖

| *លក្ខណៈដូចគ្នា* | |
|---|---|
| ឥន្ទ្រីយារម្មណ៍ | ប្រត្យក្សារម្មណ៍ |
| - លំនាំចិត្ត | |
| - ឆ្លុះបញ្ចាំងពីវត្ថុ បាតុភូត ដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រិយ៍ ។ | |
| *លក្ខណៈខុសគ្នា* | |
| - ផ្តល់លក្ខណៈទោលនៃវត្ថុ ឬបាតុភូត | - ផ្តល់លក្ខណៈទាំងស្រុងនៃវត្ថុ ឬបាតុភូត |
| - លទ្ធផល៖ ឥន្ទ្រីយារម្មណ៍ផ្សេងៗ ឧទាហរណ៍៖ ចក្ខុឥន្ទ្រីយារម្មណ៍ សោតិន្ទ្រីយារម្មណ៍ | - លទ្ធផល៖ រូបភាព ឧទាហរណ៍៖ ឃើញសៀវភៅ(បានជារូបភាពសៀវភៅ) |

### ៣. មូលដ្ឋាន សរីរៈរបស់ប្រត្យក្សារម្មណ៍

លោក ប៉ាវឡូវ (Pavlov) សរីរវិទូជនជាតិរុស្ស៊ី បានស្រាយបំភ្លឺមូលដ្ឋានសរីរៈរបស់ប្រត្យក្សារម្មណ៍ថា ជាផលិតផលមានលក្ខខណ្ឌ ។ ទំនាក់ទំនងនៃសរសៃប្រសាទក្នុងមួយរយៈពេលកើតមានឡើងនៅក្នុងសំបកខួរក្បាល កាលណាវត្ថុ ឬបាតុភូតនៃពិភពខាងក្រៅប្រព្រឹត្តមកលើសរីរាង្គឥន្ទ្រីយ៍ដែលនាំឱ្យមានរំញោចដ៏ស្មុគស្មាញ ។ នៅលើសំបកខួរក្បាល សរីរាង្គវិភាគបានធ្វើការវិភាគរាល់លក្ខណៈនៃវត្ថុទាំងឡាយដែលយើងមើលឃើញ ឬយល់ដឹង និងត្រូវបានធ្វើសំយោគឱ្យបានគ្រប់គ្រាន់ទៅលើវត្ថុទាំងឡាយនោះ ទើបយើងអាចបង្កើតបានជារូបភាពនៃវត្ថុនោះទាំងស្រុង និងពេញលេញគ្រប់គ្រាន់ក្នុងខួរក្បាលរបស់យើង ។

រួមសេចក្តីមក មូលដ្ឋានសរីរៈរបស់ប្រត្យក្សារម្មណ៍ គឺជាសកម្មភាពចម្រុះគ្នាពីសំណាក់សរីរាង្គវិភាគជាច្រើនក្នុងខ្លួនយើង ដែលជាហេតុធ្វើឱ្យប្រត្យក្សារម្មណ៍ជួយយើងឱ្យស្គាល់ពិភពខាងក្រៅខ្លួនបានប្រសើរជាងឥន្ទ្រីយារម្មណ៍ ។

### ៤. ចំណែកថ្នាក់ នៃប្រត្យក្សារម្មណ៍

តាមធម្មតាមានបែបបទពីរយ៉ាង ដែលនាំឱ្យគេអាចធ្វើចំណែកថ្នាក់បានទៅលើប្រត្យក្សារម្មណ៍ ។ គេអាចធ្វើចំណែកថ្នាក់ទៅលើប្រត្យក្សារម្មណ៍ ដោយយោលទៅតាមរូបភាពផ្សេងៗគ្នា នៃអត្ថិភាពរបស់វត្ថុ និងបាតុភូត ។

- យោលទៅតាមលក្ខណៈវិនិច្ឆ័យទី១ យើងមានប្រត្យក្សារម្មណ៍ដូចតទៅនេះ ៖ ប្រត្យក្សារម្មណ៍នៃចក្ខុវិញ្ញាណ ប្រត្យក្សារម្មណ៍សោតវិញ្ញាណ ប្រត្យក្សារម្មណ៍នៃកាយវិញ្ញាណ ។ល។
- យោលទៅតាមលក្ខណៈវិនិច្ឆ័យទី២ យើងមានប្រត្យក្សារម្មណ៍ដូចតទៅ ៖ ប្រត្យក្សារម្មណ៍នៃលំហ ប្រត្យក្សារម្មណ៍នៃពេលវេលា និងប្រត្យក្សារម្មណ៍នៃចលនា ។

#### ៤.១. ប្រត្យក្សារ ម្មណ៍ពីលំហ

ប្រត្យក្សារម្មណ៍ពីលំហ គឺជាចំណាំងនៃលំហ ដែលកើតឡើងតាមរបៀបសត្យានុម័ត ។ ប្រត្យក្សារម្មណ៍រួមមានទម្រង់នៃវត្ថុ វិមាត្រ ទីតាំង ធៀបទៅនឹងវត្ថុមួយផ្សេងទៀតដូចជា សណ្ឋាន ចម្ងាយ និងទិសដៅដែលមានតួនាទីសម្រាប់តម្រង់ទិសរបស់មនុស្សជុំវិញខ្លួន ។

##### ៤.១.១. ប្រត្យក្សារ ម្មណ៍ ពីរូបភាព

ប្រត្យក្សារម្មណ៍នេះ កើតមានតាមរយៈសរីរាង្គវិភាគរបស់ចក្ខុវិញ្ញាណ សរីរាង្គវិភាគរបស់កាយវិញ្ញាណ និងសរីរាង្គវិភាគរបស់ឥន្ទ្រីយារម្មណ៍ដែលកើតពីចលនានៃផ្នែកផ្សេងៗរបស់ខ្លួនយើង។

ឧទាហរណ៍៖ ភ្នែកមើលឃើញ អាចកំណត់បានរូបភាពរបស់វត្ថុដោយផ្ទាល់។ ដៃទៅប៉ះពាល់លើវត្ថុដោយការស្ទាប ក៏អាចកំណត់បានរូបភាពរបស់វត្ថុ។

##### ៤.១.២. ប្រត្យក្សារ ម្មណ៍ ពីវិមាត្រ

ប្រការនេះ អាស្រ័យលើវត្ថុដែលយើងមើលឃើញ ហើយត្រូវបានកំណត់ច្បាស់ទៅលើវិមាត្រនៃរូបភាពរបស់វត្ថុនោះ នៅលើស្រទាប់ស្បែកស្តើងនៃកែវភ្នែករបស់យើង និងតាមរយៈចម្ងាយនៃវត្ថុនោះមកភ្នែករបស់យើង។

##### ៤.១.៣. ប្រត្យក្សារ ម្មណ៍ ពីជម្រៅ និងចម្ងាយ

ប្រត្យក្សារម្មណ៍នេះ កើតមានដោយ ៖

- ការមើលឃើញច្បាស់ដោយភ្នែកទាំងសងខាង ដែលបំពេញតួនាទីយ៉ាងសំខាន់។
- ពន្លឺ និងភាពងងឹត ដែលកំណត់ជម្រៅ និងចម្ងាយរបស់វត្ថុ។
- ឃានវិញ្ញាណ និងសោតវិញ្ញាណ។

ឧទាហរណ៍៖ នៅពេលយប់ងងឹត យើងឮស្នូរជើងមនុស្សដើរ (តាមសោតវិញ្ញាណ) ហើយស្នូរជើងនោះបានខិតមកជិតយើង បន្តិចក្រោយមកយើងអាចឃើញរូបភាពមនុស្សថាជានរណាម្នាក់ (តាមចក្ខុវិញ្ញាណ) ។

### ៤.១.៤. ប្រត្យក្សារ ម្មណ៍ ពីការតម្រង់ទិស

គឺត្រូវបានកំណត់ដោយទីតាំងនៃរូបភាពរបស់មនុស្សរបស់វត្ថុមួយនៅលើកែវភ្នែករបស់យើង ដោយធៀបទៅនឹងវត្ថុឯទៀត និងការពិនិត្យសង្កេតដែលនៅជុំវិញខ្លួនយើង។

ដូចនេះ លំនាំប្រត្យក្សារម្មណ៍នៃការតម្រង់ទិស ស្ថិតនៅលើឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណ កាយវិញ្ញាណ ឃានវិញ្ញាណ និងសោតវិញ្ញាណ។

ឧទាហរណ៍៖ តាមរយៈក្រសែភ្នែក តាមរយៈការចង្អុល តាមក្លិន តាមរយៈសំឡេង យើងអាចដឹងទីតាំងនៃវត្ថុ ឬបាតុភូតនៅក្នុងលំហ។

### ៤.២. ប្រត្យក្សារ ម្មណ៍ ពីពេលវេលា

ប្រត្យក្សារម្មណ៍ពីពេលវេលា គឺជាចំណាំងរយៈពេលនៃល្បឿនដែលឆ្លុះបញ្ចាំងការផ្លាស់ប្តូរ ដែលកើតមានឡើងក្នុងតថភាពពិតពជុំវិញខ្លួនយើង។

ប្រត្យក្សារម្មណ៍ពីពេលវេលាកើតឡើងអាស្រ័យដោយកត្តាជាច្រើនផ្សំគ្នាដូចជា ៖

- ខ្លឹមសារនៃសកម្មភាព និង ទំនួលផ្លូវចិត្តរបស់មនុស្ស។

ឧទាហរណ៍ ៖ ពេលសិស្សកំពុងប្រឡងមានអារម្មណ៍ថា ពេលវេលាហាក់ដូចជាខ្លីជាងធម្មតា។ តែផ្ទុយទៅវិញពេលទន្ទឹងរង់ចាំអ្វីមួយ នោះហាក់បីដូចជាពេលវេលាមានរយៈពេលយូរខុសពីធម្មតា។

- ទៅតាមវ័យរបស់មនុស្ស ។

ឧទាហរណ៍៖ កុមារមានអារម្មណ៍ថា ពេលវេលាកន្លងទៅយឺតណាស់ រីឯមនុស្សចាស់វិញហាក់ដូចជាចេះតែព្រួយបារម្មណ៍ថា ពេលវេលាកន្លងទៅរហ័សពេក ។

### ៤.៣. ប្រត្យក្សារ ម្មណ៍ពីចលនា

ប្រត្យក្សារម្មណ៍ពីចលនា គឺជាចំណាំងនៃការផ្លាស់ប្តូរទីតាំងរបស់វត្ថុទាំងឡាយ ដែល ស្ថិតនៅក្នុងលំហ ហើយពេលនោះឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណ និងចលករ ដើរតួនាទីយ៉ាងសំខាន់ ។

ឧទាហរណ៍៖ ភ្នែកមើលឃើញរថយន្ត ដែលកំពុងមានចលនាក្នុងលំហ ហើយក្នុងរយៈពេលមួយ រថយន្តបានប្តូរទីតាំងថ្មី(ខណៈនេះល្បឿននៃចលនាមានព្រំដែនកំណត់ សម្រាប់ឥន្ទ្រីយ៍នៃចក្ខុវិញ្ញាណចាប់បាន)។

ប្រត្យក្សារម្មណ៍នៃចលនា អាចកើតមានឡើងដោយសារសរីរាង្គវិភាគរបស់សោតវិញ្ញាណ

ឧទាហរណ៍៖ សំឡេងមួយបានខិតមកជិតយើងម្តងបន្តិចៗ ឬក៏ឃ្លាតចេញពីយើងបន្តិចម្តងៗ។

## ៥. ច្បាប់ នៃប្រត្យក្សារម្មណ៍

លំនាំនៃប្រត្យក្សារម្មណ៍ ត្រូវបានបែងចែកទៅតាមច្បាប់ដូចជា ៖

### ៥.១. ច្បាប់ ជម្រើ ស(ច្បាប់ ប្រមូលផ្តុំ )

គឺជាការផ្តាច់វត្ថុមួយពីផ្ទៃពន្លិចរបស់វា ដើម្បីឆ្លុះបញ្ចាំងវត្ថុនោះឱ្យបានល្អប្រសើរ ។ ជម្រើសនៃប្រត្យក្សារម្មណ៍ពឹងផ្អែកផងដែរ លើចំណង់ចំណូលចិត្តទំនួលផ្លូវចិត្ត និងតម្រូវការរបស់បុគ្គល ។

ឧទាហរណ៍៖ ពេលអង្គុយរៀន សិស្សមើលទៅក្តារខៀន តុគ្រូ និងគ្រូបង្រៀន។ល។ ពេលនោះ សិស្សពិនិត្យមើលតែលោកគ្រូ ដែលជាកម្មវត្ថុសមស្របតាមតម្រូវការ។

ឧទាហរណ៍៖ នៅលើផ្ទាំងផែនទីនៃប្រទេសកម្ពុជា មានគំនូសជាច្រើនស្តីពីផ្លូវទឹក ផ្លូវអាកាស ផ្លូវដែក ។ល។ និងពណ៌ផ្សេងៗទៀត ស្តីពីសម្បត្តិធម្មជាតិ ។ ពេលបង្រៀន គ្រូបានណែនាំសិស្សឱ្យសង្កេតពីផ្លូវជាតិ ដែលតាងដោយគំនូសពណ៌ក្រហម ដែលគេត្រូវសិក្សា(ជាតម្រូវការរបស់សិស្ស) ឯគំនូសដទៃទៀតក្លាយជាផ្ទៃពន្លិចទៅវិញ ។

នៅក្នុងជីវភាពប្រចាំថ្ងៃ មនុស្សតែងជួបប្រទះនឹងវត្ថុ ឬបាតុភូតជាច្រើន ដែលប្រព្រឹត្តមកលើសរីរាង្គឥន្ទ្រីយ៍ក្នុង

ពេលជាមួយគ្នា។ ដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់លាស់នូវវត្ថុ ឬ បាតុភូតនោះ មនុស្សមានសមត្ថភាព និងជ្រើសរើស ឬ ផ្ដាច់ចេញយកវត្ថុតែមួយ ឬពីរ ដើម្បីឆ្លុះបញ្ចាំង។ នេះជាលំនាំនៃការជ្រើសរើសរបស់ប្រត្យក្សារម្មណ៍។

ច្បាប់ជម្រើសនៃប្រត្យក្សារម្មណ៍នេះ ត្រូវបានគេយកទៅអនុវត្តក្នុងជីវភាពរស់នៅ និងក្នុងការបង្រៀន។ ដើម្បីបន្លិចវត្ថុមួយ គេត្រូវរិះរកលក្ខណៈប្លែកគ្នារបស់វត្ថុនឹងផ្ទៃពន្លិច។

ឧទាហរណ៍៖ ប្រើដីសពណ៌សលើផ្ទៃក្ដារខៀនពណ៌បៃតង ឬខ្មៅ ។ សម្ភារៈបង្រៀនត្រូវរំលេចពណ៌ឱ្យបានច្បាស់នូវគំនូសណាដែលត្រូវបង្រៀន។ ផ្ទុយមកវិញ ដើម្បីធ្វើឱ្យពិបាកចំណាំត្រូវធ្វើឱ្យវត្ថុប្រទ្បាំនឹងផ្ទៃបន្លិច។

ឧទាហរណ៍៖ ទាហានប្រើសម្លៀកបំពាក់ និងមានពណ៌ដូចធម្មជាតិក្នុងទីប្រយុទ្ធ ដើម្បីបន្លំកុំឱ្យសត្រូវមើលឃើញ ដោយគេត្រូវប្រើស្លឹកឈើ ឬមែកឈើបន្ថែមទៀត ។

### ៥.២. ច្បាប់ ស្ថេរ ភាពនៃប្រ ត្យក្សារម្មណ៍

ស្ថេរភាពនៃប្រត្យក្សារម្មណ៍ គឺជាសមត្ថភាពក្នុងការស្គាល់វត្ថុ ដោយឥតប្រែប្រួលទោះបីលក្ខខណ្ឌនៃវត្ថុបាតុភូត ទម្រង់ ត្រូវបានផ្លាស់ប្ដូរក៏ដោយ បានន័យថា វត្ថុតែមួយមើលក្នុងលក្ខខណ្ឌចម្ងាយខុសគ្នា ក្រោមពន្លឺខុសៗគ្នា ក្នុងស្ថានភាពផ្សេងគ្នានៃលំហ(ផ្ដល់រូបភាពមានទម្រង់ច្រើន) យើងនៅតែស្គាល់វត្ថុនោះដដែល។

ឧទាហរណ៍៖ កុមារម្នាក់ឈរនៅជិតយើង ហើយក៏មានមនុស្សចាស់ម្នាក់ទៀតឈរនៅខាងក្រោយកុមារក្នុងចម្ងាយមួយ។ នៅលើរ៉ែទីនកែវភ្នែក យើងផ្ដិតរូបភាពរបស់កុមារធំជាងរូបភាពរបស់មនុស្សចាស់។ តែតាមពិតមនុស្សនោះមានកម្ពស់ខ្ពស់ជាងកុមារ។

ឧទាហរណ៍៖ ក្មេងនៅតែស្គាល់មុខម្ដាយច្បាស់ ទោះបីម្ដាយនោះស្លៀកសម្លៀកបំពាក់បែបណាក៏ដោយ ។

### ៥.៣. ច្បាប់ យល់ដឹងនៃប្រ ត្យក្សារម្មណ៍

ប្រត្យក្សារម្មណ៍ ទទួលរងឥទ្ធិពលពីកត្តាខាងក្រៅ និងកត្តាខាងក្នុង។ ដោយឡែកឥទ្ធិពលពីកត្តាខាងក្នុងលើប្រត្យក្សារម្មណ៍ កើតមានឡើងរាល់មនុស្សគ្រប់រូបអាស្រ័យលើចរិតនិងបុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗដែលឱ្យកំណើតដល់ប្រត្យក្សារម្មណ៍ខាងតម្រូវការចំណង់ចំណូលចិត្ត រសជាតិ និងសព្ទេតនាដែលជាកម្រិតនៅក្នុងប្រត្យក្សារម្មណ៍។

ឧទាហរណ៍៖ កាលណាគេមានទុក្ខក្រៀមក្រំ នោះគេមើលទៅទេសភាពដែលនៅជុំវិញខ្លួនគេហាក់ដូចជាអាប់អួរ។ ដូច្នេះ ប្រត្យក្សារម្មណ៍អាចកើតឡើងយ៉ាងពេញទំហឹងបាន លុះត្រាតែមានការយល់ដឹងដ៏សមស្របផងដែរ។ ក្នុងការបង្រៀន និងអប់រំសិស្ស គ្រូត្រូវមានការយល់ដឹងពីបទពិសោធចំណេះដឹង ទំនោរ ចំណង់ចំណូលចិត្ត និងទំនួលផ្លូវចិត្តរបស់សិស្ស ទើបលទ្ធផលសម្រេចបានជោគជ័យ។

### ៥.៤. ច្បាប់ អត្ថន័ យនៃប្រ ត្យក្សារម្មណ៍

ប្រត្យក្សារម្មណ៍កើតមានឡើង ដោយសារទង្វើផ្ទាល់របស់រំញោចមកលើសរីរាង្គឥន្ទ្រីយ៍របស់យើង ក៏ប៉ុន្តែរូបភាពនៃប្រត្យក្សារម្មណ៍តែងតែនាំមកជានិច្ចនូវអត្ថន័យមួយជាកំណត់ ពោលគឺអត្ថន័យនៃការក្រឡេកឃើញវត្ថុដែលជាហេតុឱ្យគេអាចកំណត់ឈ្មោះវត្ថុនោះបាននៅក្នុងខួរក្បាលរបស់គេ។ គេអាចធ្វើចំណាត់ថ្នាក់វត្ថុនោះបានទៅតាមក្រុមរបស់វា ឬនៅក្នុងចំណាត់ថ្នាក់ណាមួយជាកំណត់នៃវត្ថុនោះ ហើយមនុស្សយើងអាចធ្វើទូទៅកម្មបានទៅលើវត្ថុនោះដោយប្រើពាក្យ ឬសំដីជាក់ស្ដែង។ សូម្បីតែកាលណាគេត្រូវក្រឡេកឃើញវត្ថុចម្លែកមួយ គេតែងតែរិះរកផងដែរក្នុងការធ្វើចំណាត់ថ្នាក់វត្ថុនោះទៅក្នុងប្រភេទនៃវត្ថុដែលមានលក្ខណៈដូចគ្នា ។ អត្ថន័យរបស់ប្រត្យក្សារម្មណ៍ធ្វើឱ្យយល់ដឹងបានថា ប្រត្យក្សារម្មណ៍ គឺជាលំនាំមួយដ៏សកម្មដែលមនុស្សយើងចាប់ផ្ដើមធ្វើសកម្មភាពញាណសក្ដិ ដើម្បីបង្កើតបានជារូបភាពដែលជាប់ពាក់ព័ន្ធនឹងវត្ថុនោះនៅក្នុងខួរក្បាលរបស់មនុស្សយើង។

ដោយយកច្បាប់នេះទៅអនុវត្តក្នុងការប្រតិបត្តិ នៅក្នុងការបង្ហាញអំពីវត្ថុថ្មី បាតុភូត ឬសញ្ញាណណាមួយដល់

សិស្ស យើងជាគ្រូបង្រៀនគប្បីផ្តត់ផ្តង់ឱ្យសិស្សដឹងច្បាស់ពីឈ្មោះនៃចំណែកផ្សេងៗ ព្រមទាំងពាក្យច្បាស់លាស់របស់វត្ថុនោះផង។

### ៥.៥. ច្បាប់ មាយាការ នៃប្រត្យក្សារម្មណ៍

មាយាការនៃប្រត្យក្សារម្មណ៍ គឺជាចំណាំងភាន់ច្រឡំជាសត្យានុម័តពីវត្ថុ ឬបាតុភូតទាំងឡាយ។ មាយាការ នៃប្រត្យក្សារម្មណ៍កើតមាននៅគ្រប់ប្រភេទប្រត្យក្សារម្មណ៍ទាំងអស់ដូចជាប្រត្យក្សារម្មណ៍ពីលំហ ប្រត្យក្សារម្មណ៍ពីពេលវេលា ប្រត្យក្សារម្មណ៍ពីចលនាជាដើម។

ឧទាហរណ៍៖ ពេលយើងជិះរថយន្តមួយដែលកំពុងបើក ពេលយើងបិទភ្នែក យើងហាក់ដូចជាទទួលអារម្មណ៍ថា រថយន្តបើកថយក្រោយវិញ។ ពេលយើងបើកភ្នែក ឃើញដើមឈើរត់ថយក្រោយ។ នេះជាការភាន់ច្រឡំ នៅក្នុងប្រត្យក្សារម្មណ៍នៃចលនា។

ឧទាហរណ៍៖ យើងដាក់ចង្កឹះមួយចូលទៅក្នុងទឹក ចង្កឹះនោះហាក់បីដូចជាបាក់ តែតាមពិតចង្កឹះនោះមិនបាក់ទេ ។ ទាំងអស់នេះជាការភាន់ច្រឡំធម្មតាសម្រាប់មនុស្សទូទៅ លើកលែងតែក្នុងករណីខ្លះ ដែលមនុស្សមានជំងឺដាល់តូនី (មើលឃើញពណ៌ក្រហមជាពណ៌ផ្ទៃមេឃ)។

មាយាការនៃប្រត្យក្សារម្មណ៍បង្កឡើងដោយមូលហេតុបីប្រភេទ ៖

- មូលហេតុផ្លូវកាយ
- មូលហេតុសរីរវិទ្យា
- មូលហេតុផ្លូវចិត្ត

នៅក្នុងការបង្រៀនសិស្ស យើងជាគ្រូបង្រៀនគួរចៀសវាងមាយាការអតិបរមា នៅក្នុងប្រត្យក្សារម្មណ៍របស់សិស្ស ដោយរៀបចំឱ្យបានត្រឹមត្រូវនូវសម្ភារឧបទេសដូចជា រូបថតផ្ទាំងគំនូរ រូបភាព គំនូសវាស រូបចាក់ពុម្ព ...។ល។ ហើយត្រូវបង្ហាញវត្ថុទាំងនោះ ឱ្យសិស្សឃើញទៅតាមលក្ខណៈវិទ្យាសាស្ត្រដ៏ច្បាស់លាស់ ព្រមទាំងដឹកនាំសិស្សឱ្យយកចិត្តទុកដាក់ពិនិត្យសង្កេតសម្ភារៈ ដែលយកមកបង្រៀនឱ្យបានហ្មត់ចត់។ ផ្ទុយទៅវិញ មាយាការត្រូវបានប្រើនៅក្នុងការលាបពណ៌ ផ្ទាំងគំនូរ ការតុបតែងបន្ទប់ជាដើម។

រួមសេចក្តីមក មនុស្សស្គាល់តថភាពបរានុម័ត ដែលប្រព្រឹត្តមកលើសរពាង្គកាយ ដោយសារ ឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ (ប្រត្យក្សារម្មណ៍ជាលំនាំពុទ្ធិសកម្មមួយរបស់មនុស្ស) ។ លំនាំចិត្តទាំងពីរនេះ មានអត្ថន័យធំធេងសម្រាប់ជីវិតមនុស្ស ព្រោះបើគ្មានលំនាំទាំងពីរនេះទេនោះ គេពុំអាចមានលំនាំពុទ្ធិណាមួយឡើយ ហើយលំនាំចិត្តដទៃទៀតដូចជា ការគិត និង រូបារម្មណ៍ក៏ពុំអាចកើតមានដែរ។

## ៦. ការសង្កេត និងស្មារតីសង្កេត

ការសង្កេត ជាប្រត្យក្សារម្មណ៍គិតទុកជាមុន ដោយតម្រង់ទៅរកគោលបំណងមួយជាក់លាក់ និងធ្វើឡើងទៅតាមផែនការដែលរៀបចំជាមុនទៅលើវត្ថុ ឬបាតុភូតណាមួយនៃតថភាពបរានុម័ត។

ឧទាហរណ៍៖ ឱ្យសិស្សសង្កេតផ្កាមួយ ដើម្បីឱ្យស្គាល់ច្បាស់ពីផ្នែកផ្សេងៗនៃផ្កានេះ។ ឱ្យសិស្សសង្កេតពីផែនទីមួយ ដើម្បីឱ្យច្បាស់ពីស្នាមគំនូសដែលសម្គាល់ ភ្នំ ទន្លេ បឹង ព្រៃ ផ្លូវគមនាគមន៍ (ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស) ។ល។

ដូចនេះ ក្នុងការសង្កេត ប្រត្យក្សារម្មណ៍មានគោលដៅឆ្លុះបញ្ចាំងឱ្យបានពេញលេញ ច្បាស់លាស់ និងល្អិតល្អន់ពីលក្ខណៈផ្សេងៗ ពីការប្រែប្រួល និងទិដ្ឋភាពផ្សេងៗនៃវត្ថុដែលគេត្រូវសង្កេតនោះ។

មនុស្សគ្រប់រូបអាចមានលទ្ធភាពសង្កេតបានដូចគ្នា តែលទ្ធផលនៃការសង្កេតនោះប្រែប្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត អាស្រ័យតាមស្មារតី និងសមត្ថភាពសង្កេតរបស់គេម្នាក់ៗ ទៅលើរាល់ចំណុចសំខាន់ៗ និងដោយឡែករបស់វត្ថុ និងបាតុភូត។ ដូចនេះមនុស្សដែលមានស្មារតីសង្កេតខ្លាំង គឺអ្នកដែលទទួលអារម្មណ៍បានភ្លាមៗ និង

ជាក់ច្បាស់ពីលក្ខណៈពិសេស និងសំខាន់ៗនៃវត្ថុដែលគេបានសង្កេត ទោះបីលក្ខណៈនោះ ពិបាកកត់សម្គាល់ ឬក៏មានលក្ខណៈបន្ទាប់បន្សំក៏ដោយ។

ក្នុងសាលារៀន ការសង្កេតមាននាទីសំខាន់បំផុតក្នុងការបង្រៀន និងអប់រំ ។ ដូចនេះ ដើម្បីពង្រឹងស្មារតីសង្កេតរបស់សិស្ស និងបង្កលក្ខណៈសមស្របឱ្យសិស្សមានការសង្កេតល្អ គ្រូត្រូវ ៖

- យកចិត្តទុកដាក់ជាចម្បង ចំពោះសភាពនៃសរីរាង្គឥន្ទ្រីយ៍ទាំងឡាយរបស់សិស្ស។
- កំណត់ឱ្យច្បាស់គោលបំណង អត្ថន័យ និងតម្រូវការនៃការសង្កេត។
- ដឹកនាំវិធីសង្កេតតាមគម្រោង និងតាមលក្ខណៈជាប្រព័ន្ធ។
- បង្កលក្ខណៈងាយស្រួលដល់កុមារតូចៗ ដើម្បីឱ្យគេប្រមូលផ្តុំសរីរាង្គឥន្ទ្រីយ៍ជាច្រើនក្នុងការសង្កេត។
- កត់ត្រា និងប្រើប្រាស់លទ្ធផលនៃការសង្កេត ដោយទាញសេចក្តីសន្និដ្ឋាន។
- ទាញយកលទ្ធផលនៃការសង្កេតមកប្រើប្រាស់ឱ្យបានយ៉ាងសកម្ម។

## IV- សន្និដ្ឋាន

ប្រត្យក្សារម្មណ៍គឺជាដំណាក់កាលនៃការទទួលព័ត៌មានជាក់លាក់។ ក្នុងការសង្កេតប្រត្យក្សារម្មណ៍មានគោលដៅឆ្លុះបញ្ចាំងពេញលេញច្បាស់លាស់ ល្អិតល្អន់ពីលក្ខណៈផ្សេងៗពីបម្រែបម្រួលនិងទិដ្ឋភាពនៃវត្ថុដែលត្រូវសង្កេត ។

ការប្រើប្រាស់ការសង្កេតល្អសំដៅលើការប្រើប្រាស់សរីរាង្គឥន្ទ្រីយ៍ប្រកបដោយប្រសិទ្ធភាព ។

### សំណួរ

១. ដូចម្តេចដែលហៅថា ប្រត្យក្សារម្មណ៍ ?
២. ចូរប្រៀបធៀបឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ ។
៣. តើគ្រូបង្រៀនយកច្បាប់ប្រត្យក្សារម្មណ៍ទៅអនុវត្តយ៉ាងដូចម្តេចនៅក្នុងលំនាំនៃការបង្រៀន?
៤. ការសង្កេតជាអ្វី ? តើគ្រូបង្រៀនត្រូវធ្វើដូចម្តេច ដើម្បីពង្រឹងស្មារតីសង្កេតរបស់សិស្ស ?

# មេរៀនទី៦ លំនឹក

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីសញ្ញាណនៃលំនឹក ប្រភេទ តួនាទី និងការប្រយុទ្ធទប់ទល់នឹងការភ្លេច
- ប្រើប្រាស់បំណិននៃការធ្វើលំនឹកកម្មក្នុងដំណើរការបង្រៀន និងរៀន
- មានទម្លាប់ប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀន ដើម្បីងាយស្រួលក្នុងការបង្កើត និងពង្រឹងលំនឹកសិស្ស។

## II- សេចក្តីផ្តើម

គ្រប់សកម្មភាព និងអំពើរបស់មនុស្សកើតឡើងដោយសារចិត្តជាអ្នកតម្រង់ទិសដៅ ហើយចិត្តបានប្រមូលផ្តុំនូវបទពិសោធរបស់បុគ្គលនីមួយៗ។ បទពិសោធនេះបានដិតជាប់នៅក្នុងខួរក្បាល ឬមិនដិតជាប់អាស្រ័យ ដោយរបៀបនៃការបណ្តុះបណ្តាលនៅក្នុងខ្លួនយើងម្នាក់ៗ ហើយអាចរលុបបាត់ទាំងស្រុង ឬអាចរក្សាទុកនូវរូបភាពទាំងនោះដោយបង្កើតឡើងសារជាថ្មីកាលណាយើងត្រូវការ ។ លំនាំនៃការរក្សាទុកបទពិសោធ និងការបញ្ចេញនូវបទពិសោធមកក្រៅវិញហៅថា លំនឹក ។

លំនឹកមាននាទីយ៉ាងសំខាន់ ក្នុងជីវភាពរស់នៅក្នុងសង្គម ។ លំនឹកជាលក្ខខណ្ឌគ្រឹះនៃការរីកចម្រើនរបស់មនុស្សជាតិ ពិសេសសម្រាប់ជីវិតចិត្តរបស់មនុស្ស ។ ដោយសារលំនឹកនេះហើយ ទើបសកម្មភាពញាណរបស់មនុស្សយើងឈានដល់កម្រិតថ្មីមួយ គឺអាចឆ្លុះបញ្ចាំងដោយប្រយោលទៅលើវត្ថុ និងបាតុភូត ។

## III- ខ្លឹមសារ

### ក- និយមន័យ

លំនឹក គឺជាលំនាំចិត្តដែលថតយក ផ្តិតយក រក្សាទុក ស្គាល់ឡើងវិញ និងបង្កើតឡើងវិញនូវរូបភាពនៃវត្ថុ ឬបាតុភូតដែលគេបានជួបប្រទះពីពេលមុននិងបទពិសោធទាំងឡាយដែលបុគ្គលម្នាក់ៗបា នជួបប្រទះក្នុងអតីតកាល ។

លំនឹក ឬការចងចាំ ជាផ្នែកមួយយ៉ាងសំខាន់នៃជីវិតរបស់មនុស្ស។ ចំពោះសត្វវាបានទទួលតែត្រឹមការចំណាំប៉ុណ្ណោះ (ទីកន្លែងដែលមានអាហារ ទីដែលវាមានសុវត្ថិភាព ទីដែលវាអាចរស់បាន និងអាចធំធាត់បាន)។ ជាងនេះទៅទៀត មនុស្សត្រូវការ ការចងចាំ ឬលំនឹកដើម្បីបង្កើតឡើងនូវមជ្ឈដ្ឋានសង្គមសព្វគ្រប់ក្នុងកម្រិតខ្ពស់។ ម៉ាស៊ីនកុំព្យូទ័របង្កើតឡើងដោយសារមនុស្ស ដែលមានមុខងារយ៉ាងច្រើនក្នុងសកម្មភាពរបស់មនុស្ស។ នេះក៏មកពីសេចក្តីត្រូវការនៃការចងចាំដែរ។ តែបើគ្មានឧបករណ៍នេះ ក៏មិនអាចដោះស្រាយនូវបញ្ហាធំៗហើយស្មុគស្មាញ និងពោរពេញទៅដោយភាពសុក្រឹតបានដែរ។

និយាយរួម លំនឹករបស់មនុស្ស គឺជាបែបបទនៃសំណុំចិត្តសាស្ត្រ និងលក្ខណៈរបស់បុគ្គលដែលវិវត្តទៅដោយបទពិសោធសមត្ថភាពនៃការចងចាំ ការរក្សាទុក និងការបង្កើតឡើងវិញ ។

គេអាចនិយាយបានថា លំនឹកជាលំនាំចិត្តដែលឆ្លុះបញ្ចាំងបទពិសោធ ដែលមនុស្សបានឆ្លងកាត់មកហើយក្រោមរូបភាពនៃរូបភាពតំណាង ឬ លំនឹកគិត ។

រូបតំណាងជារូបនៃវត្ថុ ឬបាតុភូតដែលលេចឡើងក្នុងខួរក្បាល កាលណាគ្មានវត្ថុ ឬបាតុភូតប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍ ។

ការចងចាំអនុស្សាវរីយ៍ល្អៗ ដែលគេធ្លាប់មានកន្លងមក ឬការចងចាំចិត្តរំភើបនៅពេលដែលយើងប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ។

### ខ. ចរិតលក្ខណៈ នៃលំនឹក

លំនឹកឆ្លុះបញ្ចាំងពីពិភពបានុម័ត (គេមិនអាចរំឭកឃើញនូវអ្វីដែលគ្មាននោះទេ)។ លំនឹកឆ្លុះបញ្ចាំងវត្ថុ ឬបាតុភូត ឬបទពិសោធដែលគេបានជួបប្រទះពីមុន បទពិសោធនេះហើយ ដែលមនុស្សយើងម្នាក់ៗត្រូវបញ្ចេញឱ្យឃើញតាមរយៈលំនឹក។ នេះជាចរិតលក្ខណៈខាងផ្លូវចិត្តនៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗដែលត្រូវបានបណ្តុះបណ្តាលឡើង ដោយឈរលើមូលដ្ឋាននៃបទពិសោធលើគ្រប់ទិដ្ឋភាពទាំងអស់របស់បុគ្គល ។

### គ. លំនាំគ្រឹះ នៃលំនឹក

លំនឹក គឺជាសកម្មភាពមួយដែលមានលក្ខណៈសកម្មស្មុគស្មាញ ហើយត្រូវបានចែកចេញជាលំនាំផ្សេងៗ ដូចជា លំនឹកកម្ម ការរក្សាទុកព័ត៌មាន ការនឹកឃើញព័ត៌មានឡើងវិញ និងការបង្កើតព័ត៌មានឡើងវិញ។

#### ១. លំនឹកកម្ម

លំនឹកកម្ម ជាអំពើនៃការកត់ត្រារូបភាព ការឆ្លាក់ ការផ្តិត នូវស្នាមគំនូសទាំងឡាយដែលបានកត់ត្រាទុកនៅក្នុងខួរក្បាល ។ ម្យ៉ាងទៀតគេអាចនិយាយថា លំនឹកកម្ម ជាលំនាំនៃការបណ្តុះបណ្តាលព័ត៌មានក្នុងស្មារតីដែលជាផលនៃចំណាប់អារម្មណ៍ទៅលើវត្ថុ ឬបាតុភូត ដែលយើងអាចទទួលដឹងបាននៅលើសំបកខួរក្បាល។ ដើម្បីរំឭក នូវការចងចាំរូបភាពអ្វីមួយ គេត្រូវតែបានឃើញ ឮ ស្ទាបប៉ះផ្ទាល់វត្ថុនោះសិន បានន័យថា មនុស្សអាចកសាងរូបភាពដែលជាតំណាងរបស់លំនឹក លុះត្រាតែគេបានទទួលឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍ពីលក្ខណៈរបស់រូបភាពនោះជាមុនសិន ។

ឧទាហរណ៍៖ យើងអាចចងចាំអាស័យដ្ឋានរបស់មិត្តយើងម្នាក់ ប្រសិនបើយើងធ្លាប់មានអាស័យដ្ឋាននោះ ឬធ្លាប់បានឮ ឬបានទៅដល់កន្លែងនោះ។

ឧទាហរណ៍៖ យើងអាចចងចាំទ្រឹស្តីបទណាមួយ បើយើងបានសិក្សាទ្រឹស្តីនោះយ៉ាងល្អិតល្អន់ ឬបានប្រើប្រាស់វានៅក្នុងដំណោះស្រាយបញ្ហាណាមួយ។

គេចែកលំនឹកកម្មជាពីរគឺ៖ **លំនឹកកម្មគិតទុកមុន** និង**លំនឹកកម្មមិនគិតទុកមុន** ឬអាចនិយាយថា **លំនឹកកម្ម ឆន្ទៈ** និង**លំនឹកកម្មអឆន្ទៈ** ។

**១.១. លំនឹកកម្មមិនគិតទុកមុន ឬលំនឹកកម្មអឆន្ទៈ** គឺជាប្រភេទនៃលំនឹកដែលធ្វើឱ្យលំនឹកកម្ម ឬការចងចាំកើត ឡើងដោយគ្មានបំណង និងមិនតម្រង់មុខសញ្ញាទៅរកទិសដៅដែលបានកំណត់មុនឡើយ ។

ឧទាហរណ៍៖ ពេលយើងធ្វើដំណើរឆ្លងកាត់កន្លែងកើតហេតុ ទើបយើងនឹកឃើញពីគ្រោះថ្នាក់ចរាចរ ដែលយើងបានជួបប្រទះពីថ្ងៃមុន ។

**១.២. លំនឹកកម្មគិតទុកមុន ឬលំនឹកកម្មឆន្ទៈ** គឺជាលំនឹកកម្មដែលប្រព្រឹត្តទៅ ដោយយោងទៅតាមគោលដៅ និងបំណងធ្វើឱ្យមានលំនឹក ហើយតម្រូវឱ្យមានការខំប្រឹងប្រែងពីឆន្ទៈដែលបានកំណត់ទុកជាមុន។

ឧទាហរណ៍៖ យើងអាចចងចាំអាស័យដ្ឋានមិត្តយើង ព្រោះយើងមានបំណងទៅរកគេនៅពេលខាងមុខ ។

**លំនឹកកម្មគិតទុកមុនប្រព្រឹត្តទៅតាម របៀបដូចជា ៖**

- **លំនឹកកម្មចលនាការ ឬលំនឹកកម្មមេកានិច៖** លំនឹកកម្មនេះផ្អែកលើការធ្វើសកម្មភាពដដែលៗ ឬថាឡើងវិញដដែលៗច្រើនដងដ៏សាមញ្ញ តាមរយៈប្រត្យក្សារម្មណ៍នៃឯកសារសិក្សា។ ការសម្តែងឡើងជាគំរូរបស់លំនឹកកម្មនេះ គឺជាទង្វើយ៉ាងស្វាហាប់ក្នុងការសិក្សា។

ឧទាហរណ៍៖ ក្មេងរៀនច្រៀងចម្រៀង រៀនមេរៀន ដោយការទន្ទេញចាំមាត់ដើម្បីបានលទ្ធផលល្អ ។

- **លំនឹកកម្មមានអត្ថន័យ៖** ស្ថិតនៅលើការយល់ដឹងពីខ្លឹមសារឯកសារ និងចំណេះដឹង ហើយផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលំនាំនៃការគិតរបស់មនុស្ស។ លំនឹកកម្មនេះផ្តល់នូវការយល់ជ្រួតជ្រាបស៊ីជម្រៅ និងពង្រីកបន្ថែម

លើចំណេះដឹង។

ឧទាហរណ៍៖ យើងចាំផលគុណ $(a + b)^2 = a^2 + 2ab + b^2$ ។

លំនឹកកម្មនេះទាមទារការប្រឹងប្រែងខ្លាំង តែវាមានលក្ខណៈប្រាកដប្រជាហើយចាំបានយូរ ។

- **លំនឹកកម្មដោយ ប្រើ ល្បិចចងចាំ៖** គឺជារបៀបធ្វើការចងចាំឱ្យបានល្អនូវអ្វីមួយ ដោយបង្កើតទំនាក់ទំនងនៃខ្លឹមសារ ដើម្បីឱ្យមានអត្ថន័យមួយសមរម្យទៅលើអ្វីដែលគ្មានអត្ថន័យ ដើម្បីងាយស្រួលចងចាំ ។

ឧទាហរណ៍៖ យើងចងចាំការប្រើប្រាស់ពាក្យ "ប្ដ" ដោយពាក្យបួនម៉ាត់បានច្បាស់(ប្ដេជ្ញា ប្ដឹង ប្ដូរ ប្ដី) ។

## ២. ការរក្សាព័ ត៌មានទុក

ការរក្សាព័ត៌មានទុក គឺជាលំនាំនៃការរក្សាទុកនូវព័ត៌មានដែលគេបានបណ្ដុះបណ្ដាលរួចមកហើយនៅលើសំបកខួរក្បាលក្រោយពេលធ្វើលំនឹកកម្ម។ ក្នុងការសិក្សា ការរក្សាទុកព័ត៌មានមានសារៈសំខាន់ណាស់សម្រាប់ឱ្យយើងរំឭកឡើងវិញនៅពេលយើងត្រូវការ។ ការរក្សាព័ត៌មានទុកមានពីរប្រភេទគឺ តាមបែបសកម្ម គឺជាការរំឭកឡើងវិញនៅលើឯកសារដែលគេបានចងចាំរួចមកហើយ។ មួយវិញទៀត គឺការរក្សាទុកបែបអកម្មដែលផ្អែកលើមូលដ្ឋាននៃការថាឡើងវិញដោយផ្ទួនៗ ។

## ៣. ការ នឹកឃើញឡើងវិញ

លទ្ធផលរបស់លំនាំនៃលំនឹកកម្មនិងការរក្សាទុកព័ត៌មានត្រូវបានស្ដែងចេញឱ្យឃើញនៅក្នុងលំនាំនៃការនឹកឃើញព័ត៌មានឡើងវិញ និងការបង្កើតព័ត៌មានឡើងវិញ។

ការនឹកឃើញព័ត៌មានឡើងវិញ គឺជាការរំឭកឡើងវិញទៅលើវត្ថុណាមួយ កាលណាគេមានអារម្មណ៍មួយទទួលដឹងទៅលើវត្ថុនោះសារជាថ្មី។ ការនឹកឃើញព័ត៌មានឡើងវិញប្រព្រឹត្តទៅបានលុះណាតែវត្ថុដែលគេធ្លាប់ឃើញវាពីមុននោះផុសចេញយ៉ាងទាន់ហន់នូវឥន្ទ្រិយារម្មណ៍មួយដោយឡែកហើយយ៉ាងស្ទិទ្ធស្នាលផង។ នេះគឺជាឥន្ទ្រិយារម្មណ៍ដែលជាមូលដ្ឋាននៃការនឹកឃើញព័ត៌មានឡើងវិញ។

## ៤. ការបង្កើ តឡើងវិញ

ការបង្កើតព័ត៌មានឡើងវិញខុសប្លែកគ្នាពីការនឹកឃើញព័ត៌មានឡើងវិញនៅត្រង់ចំណុចដែលថា រូបភាពដែលត្រូវបានរក្សាទុកពីមុនរួចមកហើយនៅក្នុងលំនឹកនោះមានជីវិតរស់ឡើងវិញ ដោយម្ចាស់ខ្លួនមិនបាច់ទទួលដឹងអារម្មណ៍សារជាថ្មីទៅលើវត្ថុដែលផ្ដល់រូបភាពនេះទៅក្នុងខួរក្បាលឡើយ។ ការនឹកឃើញព័ត៌មានឡើងវិញ និងការបង្កើតព័ត៌មានឡើងវិញអាចមានលក្ខណៈជាឆន្ទៈ ឬអឆន្ទៈ។

ការបង្កើតព័ត៌មានឡើងវិញដោយឆន្ទៈ ទាមទារនូវការខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈ ហើយដែលទាមទារនូវភាពជំនះបានទៅលើការលំបាកហៅថា ការរំឭកព័ត៌មានឡើងវិញ។ ការបង្កើតរូបភាព ឬព័ត៌មានចាស់ៗឡើងវិញដែលត្រូវស្ថិតក្នុងនៅក្នុងលំហមួយ និងរយៈពេលមួយកំណត់នោះ គេហៅថាការនឹកឃើញព័ត៌មាន ឬរូបភាពឡើងវិញក្រោយពេលដែលភ្លេចវានោះ មិនគ្រាន់តែធ្វើឱ្យយើងរំលឹកបានដោយខ្លួនយើងទៅលើព័ត៌មាន ឬរូបភាពពីអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជួយយើងឱ្យកំណត់បានថែមទៀតទៅលើរូបភាពរបស់វានៅក្នុងរយៈពេលមួយជាក់កំណត់ ឬទីកន្លែងណាមួយជាក់ស្ដែង។

បើសិនជាយើងធ្វើលំនឹកកម្មបានល្អ រក្សាទុកបានល្អ យើងក៏អាចស្គាល់ឡើងវិញ និង បង្កើតឡើងវិញបានដោយងាយដែរ។ ការធ្វើឱ្យលំនឹករីកចម្រើន គឺធ្វើយ៉ាងណាឱ្យការបង្កើតឡើងវិញបានល្អប្រសើរ។

ហេតុនេះគេត្រូវធ្វើការប្រុងប្រយ័ត្នលើលំនឹកកម្មដែលមានអត្ថន័យបានសេចក្ដីថាដើម្បីចងចាំបានល្អនូវពុទ្ធិមួយគេត្រូវយល់ឱ្យបានច្បាស់ពីអត្ថន័យរបស់ពុទ្ធិនោះសិន។

ឧទាហរណ៍៖ ដើម្បីដោះស្រាយលំហាត់ធរណីមាត្រ គេត្រូវយល់ឱ្យបានច្បាស់ពីអត្ថន័យរបស់លំហាត់នោះ

សិន ទើបអាចដោះស្រាយបាន និងចងចាំបានយូរអង្វែង។

### ឃ. ប្រភេទលំនឹក

ប្រភេទលំនឹក គឺផ្អែកលើសរីរាង្គឥន្ទ្រីយ៍ ដែលមាននាទីសំខាន់ក្នុងការទទួលព័ត៌មានដូចជា៖

- កម្រិតនៃការចូលរួមរបស់ការគិតក្នុងគំនិត
- បម្រុងប្រយ័ត្នដែលចូលរួមក្នុងលំនឹក
- ពេលវេលានៃការរក្សាទុកលំនឹក ។

គេចែកលំនឹកជាប្រភេទផ្សេងៗដូចតទៅ ៖

### ១. លំនឹកចក្ខុ លំនឹកសោតៈ លំនឹកចលករ

ក្នុងវិជ្ជាជីវៈគ្រូបង្រៀនយើងនឹងជួបប្រទះសិស្សខ្លះដែលអាចរំឭកឃើញ(ចងចាំ)បានល្អនូវអ្វីៗដែលវាបានឃើញ និងបានអាន។ គេថាសិស្សនេះមានលំនឹកចក្ខុល្អ ព្រោះលំនឹកចក្ខុវិញ្ញាណដែលមានភ្នែករបស់យើងសម្រាប់ទទួលបន្ទុកមានតួនាទីយ៉ាងសំខាន់ ។

ឧទាហរណ៍៖ ព្រឹត្តិការណ៍មួយបានកើតនៅក្នុងទីក្រុង ក្រុមប៉ូលីសបានចុះស្រាវជ្រាវ។ ក្នុងខណៈមួយភ្នាក់ងារប៉ូលីសបានសាកសួររកអ្នកដែលបានឃើញហេតុការណ៍នេះ ឬភិនភាគសង្ស័យដែលបង្កឱ្យមានកើតហេតុការណ៍នេះឡើង តាមរយៈការបង្ហាញនូវរូបថត ឬរូបគូរតាមរយៈការពណ៌នារបស់សាក្សី ។

មនុស្សខ្លះទៀតអាចមានលំនឹកល្អនូវអ្វីដែលវាបានឮ។ គេថាអ្នកនោះមានលំនឹកសោតៈល្អ។

មនុស្សខ្លះទៀតនោះ អាចចងចាំបានយ៉ាងល្អនូវអ្វីៗដែលគេបានចាប់កាន់ ស្ទាប ប៉ះផ្ទាល់ ។ គេថា អ្នកនោះមានលំនឹកចលករល្អ។ លំនឹកចលករ ជាលំនឹកដែលឆ្លុះបញ្ចាំងពីចលនាទាំងឡាយ។

ឧទាហរណ៍៖ យើងចេះហែលទឹក។ នៅពេលយើងរស់នៅតំបន់ភ្នំមួយរយៈពេលយូរ យើងពុំដែលបានហែលទឹកទេ តែយើងអាចរំឭកការចងចាំបានយ៉ាងប៉ិនប្រសប់ ។

### ២. លំនឹកផ្ទាល់ និងលំនឹកប្រយោល

**២.១. លំនឹកផ្ទាល់ ៖** ជាលំនឹកដែលឆ្លុះបញ្ចាំងដោយផ្អែកលើវត្ថុ ឬបាតុភូតជាក់ស្ដែង ។

ឧទាហរណ៍៖ មេរៀនភូមិវិទ្យាដោយផ្អែកលើវត្ថុ ឬបាតុភូតជាក់ស្ដែង។ ក្នុងសម័យកុម្មុយនីស្តបុព្វកាល ភាគច្រើនគេប្រើលំនឹកផ្ទាល់ ព្រោះខួរក្បាលគេពុំទាន់បានហ្វឹកហ្វឺនរីកចម្រើនដូចជា ដើម្បីចំណាំឆ្នាំទី ១ ទី២ គេយកខ្សែមកក្ដួច១ ២... ឬតាងថ្ងៃ១ ២... ឬរាប់ចំនួនគោបញ្ចូលក្រោល...។ គេមិនអាចស្គាល់អ្វីក្រៅពីសង្គមដែលគេបានរស់នៅឡើយ ។

**២.២. លំនឹកប្រយោល៖** គឺជាលំនឹកដែលឆ្លុះបញ្ចាំងដោយប្រយោលនូវវត្ថុ ឬបាតុភូត ។ មនុស្សអាចនឹកឃើញដល់វត្ថុមួយផ្សេងទៀត ដោយសារលំនឹកប្រយោលនៅចំពោះមុខវត្ថុជាក់ស្ដែងណាមួយ។ លំនឹកនោះជួយមនុស្សឱ្យចេះចំណាំ។

ឧទាហរណ៍៖ រៀនមេរៀនភូមិវិទ្យាដោយប្រើផែនទី រួចយើងអាចចងក្រងមេរៀនបាន។ សិស្សអាចយល់ផែនទីបានអាស្រ័យដោយសិស្សស្គាល់ និងចំណាំពីសញ្ញាសម្គាល់ទាំងឡាយនៅលើផែនទី។ ចំពោះភូគោលដែលគ្រូលើកបង្ហាញ សិស្សអាចនឹកឃើញដល់ទម្រង់ផែនដី។

បច្ចុប្បន្នវិទ្យាសាស្ត្រជឿនលឿន គេអាចឱ្យមនុស្សមានលំនឹកប្រយោល។

ឧទាហរណ៍៖ តាមរយៈប្រព័ន្ធទូរទស្សន៍ តាមរូបភាព ឬទស្សនាវដ្ដី តាមរយៈខ្សែភាពយន្ត ឬវីដេអូ... មនុស្សអាចស្គាល់ទ្វីបទាំង៥លើពិភពលោក ទោះបីជាគេមិនបានជួបផ្ទាល់ក៏ដោយ ។

### ៣. លំនឹកមេកានិច និងលំនឹកសមហេតុផល

**៣.១.លំនឹកមេកានិចៈ**គឺជាលំនឹកដែលមិនគិតពីអត្ថន័យ និងខ្លឹមសារនៃវត្ថុ ឬបាតុភូតដែលគេត្រូវរំឭកដល់។

ឧទាហរណ៍៖ ក្មេង៣-៤ឆ្នាំ ដែលចេះច្រៀងចាំស្ទាត់ តែមិនយល់ពីអត្ថន័យនៃចម្រៀងនោះឡើយ ។

**៣.២. លំនឹកសមហេតុផលៈ** គឺជាលំនឹកដែលផ្អែកលើការត្រិះរិះពិចារណា ឱ្យយល់ដឹងពីខ្លឹមសារ ។

ឧទាហរណ៍៖ សិស្សដែលរៀនមេរៀន ដោយចេះធ្វើគម្រោង ឬចេះសង្ខេបមេរៀន ដើម្បីអាចចងចាំន័យនៃវត្ថុ ឬបាតុភូតបានល្អ ។

### ៤. លំនឹកមិនគិតទុកមុន និងលំនឹកគិតទុកមុន

**៤.១. លំនឹកមិនគិតទុកមុន៖** គឺជាលំនឹកដែលមិនបាញ់ឆ្ពោះទៅរកគោលបំណងណាមួយ ព្រោះវាជាវត្ថុ ឬបាតុភូតដែលយើងមិនចង់រំឭក តែវាស្ថិតនៅក្នុងខួរក្បាលរបស់យើង។

ឧទាហរណ៍៖ យើងធ្លាប់បានឃើញជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរមួយ យើងតែងតែនឹកឃើញជននោះជានិច្ច ឬជារៀងរាល់ពេលដែលយើងធ្វើដំណើរឆ្លងកាត់ទីនោះ។

**៤.២. លំនឹកគិតទុកមុន៖** គឺជាលំនឹកដែលបាញ់ឆ្ពោះទៅរកគោលបំណងមួយ ហើយដែលបានកំណត់ទុកមុនហើយជាស្រេច។

ឧទាហរណ៍៖ យើងរៀនធរណីមាត្រត្រូវចងចាំទ្រឹស្តីបទ ។ យើងរៀនរូបវិទ្យាចាំបាច់ត្រូវចងចាំច្បាប់ និងរូបមន្ត។

នេះជាលំនឹកគិតទុកមុន ព្រោះយើងត្រូវការចងចាំពុទ្ធិដើម្បីអាចយកទៅប្រើប្រាស់បាននៅក្នុងជីវភាពប្រចាំថ្ងៃ។

លំនឹកគ្រប់ប្រភេទ សុទ្ធតែមានសារៈសំខាន់ដល់ជីវិតមនុស្ស។ ប៉ុន្តែក្នុងសកម្មភាពបង្រៀន និងរៀន គឺតម្រូវឱ្យគ្រូ សិស្សចេះហ្វឹកហ្វឺន និងពង្រីកលំនឹកសមហេតុផល និងលំនឹកគិតទុកមុន។

### ៥. លំនឹករយៈពេលខ្លី និងលំនឹករយៈពេលវែង

**៥.១. លំនឹករយៈពេលខ្លី៖** គឺជាលំនឹកដែលគេប្រើសម្រាប់ពេលខ្លីគឺមានន័យថា គេត្រូវប្រើប្រាស់ដើម្បីសម្រេចនូវអំពើទាំងឡាយក្នុងរយៈពេលមួយខ្លី បន្ទាប់មកលំនឹកនេះនឹងក្លាយទៅជាលំនឹកមិនចាំបាច់ទៅវិញ ។

ឧទាហរណ៍៖ អ្នកបកប្រែភាសា ត្រូវប្រើលំនឹកតិចពីមួយឃ្លាទៅមួយឃ្លា រួចគេបំភ្លេចឃ្លាទាំងនោះចោល ដើម្បីទៅចាប់យកឃ្លាថ្មីទៀត ។

**៥.២. លំនឹករយៈពេលវែង៖** គឺជាលំនឹកដែលគេរក្សាទុកឱ្យបានយូរអង្វែងចាប់ពីមួយថ្ងៃទៅមួយខែ...រហូតមួយជីវិត។

ឧទាហរណ៍៖ រៀនមេរៀនដើម្បីប្រឡង...។ សិស្សអាចចងចាំរូបមន្តបានយូរអង្វែង...។

រួមសេចក្តីមក លំនឹកទាំងពីរប្រភេទនេះ មានតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅ និងក្នុងសកម្មភាពរបស់មនុស្សយើងម្នាក់ៗ អាស្រ័យដោយការងារត្រូវបំពេញតម្រូវការជាក់ស្តែង និងសកម្មភាពនីមួយៗរបស់មនុស្សយើងម្នាក់ៗ ។

## ង. តួនាទី លំនឹក

លំនឹកមានតួនាទីមួយយ៉ាងសំខាន់ណាស់ នៅក្នុងជីវភាពរស់នៅរបស់មនុស្ស។ បើគ្មានលំនឹកនោះមនុស្សយើងក៏គ្មានបទពិសោធន៍ដែរ។ ហើយបើគ្មានបទពិសោធន៍សោះ នោះក៏មិនអាចធ្វើសកម្មភាពបានដែរ។

លោក I.M Setchénov បានមានប្រសាសន៍តាមរបៀបកំប្លែង ប៉ុន្តែជាសម្តីដែលនិយាយយ៉ាងត្រឹមត្រូវថា បើមនុស្សយើងគ្មានលំនឹកទេនោះ ជានិច្ចជាកាលគេនឹងរស់នៅរបៀបដូចទារក។

យើងនឹងជួបប្រទះនូវភាពកង្វល់ខុសពីប្រក្រតីចំពោះជីវភាពរស់នៅរបស់អ្នកណាដែលបាត់បង់ ឬខូចនូវលំនឹករបស់ខ្លួនដូចជា គេភ្លេចឈ្មោះ និងអាយុរបស់គេ។ នោះគេលែងដឹងបានថា តើខ្លួនគេស្ថិតនៅទីណា។ ទាំងនេះសឱ្យ

ឃើញថា បើគ្មានបទពិសោធដែលគេអាចប្រមូលផ្ដុំបាននោះទេ ជីវិតរបស់មនុស្សនឹងជួបសេចក្ដីកង្វល់ជាមិនខានហើយ មនុស្សនោះនឹងលែងមានបុគ្គលិកលក្ខណៈជាមនុស្សទៀតឡើយ។

លំនឹកជាលក្ខខណ្ឌមួយក្នុងការប្រែក្លាយចំណេះដឹងឥន្ទ្រីយ៍ឱ្យទៅជាចំណេះដឹងវិចារ ហើយជាផ្នែកមួយដែលស្ថិតនៅក្នុងសមាសភាពរបស់បុគ្គលិកលក្ខណៈលំនឹកបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតផ្លូវចិត្តរបស់មនុស្សយើងម្នាក់ៗ។ ការបណ្ដុះបណ្ដាលលំនឹកឱ្យដល់សិស្ស នឹងហ្វឹកហ្វឺនសិស្សឱ្យមានលំនឹកដ៏ល្អ គឺជាភារកិច្ចមួយដ៏សំខាន់របស់គ្រូបង្រៀន។ ការហ្វឹកហ្វឺន និងការអភិវឌ្ឍគំនិតច្នៃប្រឌិតចំពោះសិស្សមិនអាចកាត់ផ្ដាច់បានពីការហ្វឹកហ្វឺននិងការអភិវឌ្ឍលំនឹកបានឡើយ។ ដោយហេតុថា គ្មានសកម្មភាពស្មារតីណាមួយដែលពឹងផ្អែកលើចំណេះដឹងជាក់ស្ដែងបានឡើយ ។

### ច. ការសិក្សា និងការហ្វឹកហ្វឺនលំនឹកសិស្ស

#### ១. ការសិក្សាលំនឹកសិស្ស

យើងជាគ្រូបង្រៀន ត្រូវប្រើចំណេះដឹងចិត្តវិទ្យា ដើម្បីពិនិត្យសង្កេតការសិក្សា និងវិភាគលំនាំចិត្តរបស់សិស្សក្នុងបំណងធ្វើឱ្យការបង្រៀនទទួលបានលទ្ធផលល្អ។

បើប្រៀបធៀបទៅនឹងលំនឹកគិតរបស់កុមារ លំនឹករបស់ជំទង់មានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ព្រោះ លំនឹកកម្មរបស់គេរីកចម្រើនយ៉ាងខ្លាំង។ ជំទង់ចាប់ផ្ដើមចេះបែងចែកជាផ្នែកផ្សេងៗ វិះរកអត្ថន័យ និងទំនាក់ទំនងរបស់ផ្នែកទាំងនោះ ពិសេសជំទង់មានសមត្ថភាពក្ដាប់បាននូវទំនាក់ទំនងសមហេតុផលនៃពុទ្ធិវិទ្យាសាស្ត្រ។

#### ២. ការហ្វឹកហ្វឺនលំនឹកសិស្ស

**២.១. ការភ្លេច ៖** ការភ្លេចបានន័យថា ស្នាមគំនូសទាំងឡាយដែលត្រូវបានរក្សាទុកក្នុងខួរក្បាលត្រូវលុបបាត់មិនលេចឡើងវិញទៀតឡើយ។ ការភ្លេចមានដូចជា ការភ្លេចទាំងស្រុង ការភ្លេចផ្នែកខ្លះ និងការភ្លេចជាបណ្ដោះអាសន្ន។

**២.១.១. ការភ្លេច ទាំងស្រុង ៖** គឺមានន័យថា មិនអាចនឹកឃើញឡើងវិញ ហើយក៏មិនអាចបង្កើតឡើងវិញបាននូវព័ត៌មានពីអតីតកាល ។

**២.១.២. កាភ្លេច ផ្នែកខ្លះ ៖** គឺជាការមិនអាចបង្កើតនូវព័ត៌មានវិញបាន តែមានសមត្ថភាពអាចនឹកឃើញព័ត៌មានបានខ្លះ។

**២.១.៣. ការភ្លេចបណ្ដោះអាសន្ន៖** គឺក្នុងរយៈពេលដ៏យូរអង្វែង យើងពុំអាចបង្កើតព័ត៌មាននោះវិញបានទេ ក៏ប៉ុន្តែ ក្នុងរយៈពេលណាមួយនោះ ស្រាប់តែយើងនឹកឃើញព័ត៌មាន ឬរូបភាពនោះឡើងវិញ។

**២.២.លក្ខណៈនៃការភ្លេច**

- ការភ្លេចកើតមានចំពោះអ្វីដែលគ្មានទំនាក់ទំនង ឬក៏មានទំនាក់ទំនងតិចតួចស្ដួចស្ដើងពេក ជាមួយនឹងជីវភាពរស់នៅ ឬក៏អ្វីដែលមិនសមស្របទៅនឹងចំណង់ចំណូលចិត្ត និងតម្រូវការរបស់បុគ្គលនីមួយៗ។
- ការភ្លេចកើតមានចំពោះអ្វីៗដែលគេមិនប្រើប្រាស់វា ឱ្យបានញឹកញយក្នុងសកម្មភាពជាប្រចាំ។
- ការភ្លេចកើតមានមកលើខ្លួនយើង នៅពេលមានរំញោចដ៏ចម្លែក ឬក៏រំញោចដែលមានឥទ្ធិពលខ្លាំងពេក ។
- ការភ្លេចកើតមាននៅពេលដែលយើងទទួលនូវការប្រព្រឹត្តសកម្មភាពមួយផ្សេងទៀត។ ផ្នែកខ្លះនៃព័ត៌មានត្រូវភ្លេចបន្តិចម្ដងៗហួតបាត់ទាំងស្រុង។

**ការហ្វឹកហ្វឺនលំនឹក**

- យល់ច្បាស់ពីពុទ្ធិ
- បង្កើនចំណូលចិត្ត និងតម្រូវការរបស់សិស្ស
- ជំរុញសិស្សឱ្យប្រើសរីរាង្គឥន្ទ្រីយ៍ច្រើន ដើម្បីចូលរួម
- ទាក់ទាញសិស្សធ្វើសកម្មភាពប្រតិបត្តិជាក់ស្ដែងឱ្យបានច្រើន

- ឱ្យសិស្សរៀនឆ្លាស់មុខវិជ្ជា និងសិក្សាទៀងទាត់ពេលវេលា

### ឆ. លំនឹក និងបុគ្គលិកលក្ខណៈ

លំនឹកមានភាពខុសគ្នា អាស្រ័យទៅតាមបុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ ៖

១. អាស្រ័យដោយចរិតបុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ ។ លំនឹកមានលក្ខណៈប្រមូលផ្តុំ និងអាស្រ័យដោយចំណង់ចំណូលចិត្តរបស់មនុស្ស រួមទាំងតម្រូវការដែលគេចង់រំឭកឡើងវិញ។

២. ភាពខុសគ្នារបស់បុគ្គលនីមួយៗ ដោយសារគុណសម្បត្តិរបស់លំនឹក។ ភាពខុសគ្នានេះ គឺមកពីភាពហ័សរហួននៃលំនឹកកម្ម ពេលវេលា ការរក្សាទុកព័ត៌មាន និងរបៀបបង្កើតឡើងវិញនៃព័ត៌មាន។

៣. លំនឹករបស់បុគ្គលនីមួយៗ អាស្រ័យទៅតាមអាយុ ភេទ និងអាជីពការងារ ។

- **លំនឹកអាស្រ័យតាមអាយុ ៖** តាមការសិក្សាស្រាវជ្រាវរបស់អ្នកចិត្តវិទ្យា បានឱ្យដឹងថាមនុស្សចាប់ពី អាយុ ១ឆ្នាំ ដល់ ២៥ឆ្នាំ មានលំនឹកល្អ និងរហ័សរហួន ។ ចាប់ពី ២៥ឆ្នាំ ដល់ ៤៥ឆ្នាំ លំនឹកមានភាពនឹងនរ ហើយចាប់ពី៤៥ឆ្នាំឡើងទៅលំនឹកមានភាពថយចុះ ។
- **លំនឹកអាស្រ័យតាមភេទ៖** លំនឹករបស់ស្ត្រីមានភាពល្អប្រសើរជាងលំនឹករបស់បុរសតែមិនច្រើនពេកទេ។
- **លំនឹកអាស្រ័យតាមមុខរបរ៖** ជាងគំនូរមានលំនឹកចក្ខុវិញ្ញាណល្អ តន្ត្រីករមានលំនឹកខាងសោតវិញ្ញាណ...។

ដូចនេះដើម្បីបង្ហាត់បង្រៀនសិស្សឱ្យបានល្អប្រសើរ គ្រូបង្រៀនគប្បីត្រូវយកចិត្តទុកដាក់ពិនិត្យសង្កេត ចរិតលក្ខណៈលំនឹកឱ្យបានដិតដល់ អំពីការខុសប្លែកគ្នានៃលំនឹករវាងសិស្សនីមួយៗ។

## IV- សន្និដ្ឋាន

ដើម្បីឱ្យគរុសិស្សមានលំនឹកល្អក្នុងការបង្រៀនជានិច្ចកាលត្រូវ ប្រើប្រាស់សម្ភារឧបទេសឱ្យបានសមស្របតាមមេរៀន និងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ខ្លឹមសារមេរៀនត្រូវផ្សារភ្ជាប់នឹងជីវភាពរស់នៅ រៀនសារឡើងវិញឱ្យបានញឹកញាប់(មុនបង្រៀនត្រូវរំឭកមេរៀនចាស់) និងយកចិត្តទុកដាក់លើប្រភេទនៃលំនឹក។

## សំណួរ

១. ដូចម្តេចដែលហៅថាលំនឹក? ប្រភេទលំនឹកមានអ្វីខ្លះ?

២. ហេតុអ្វីបានជាគេនិយាយថាលំនឹកគឺជាកម្រិតមួយនៃចំណេះដឹងរបស់មនុស្ស បើប្រៀបធៀបទៅនឹងឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍?

៣. ចូររកភាពប្លែកគ្នា និងភាពស្រដៀងគ្នារវាងរូបភាពប្រត្យក្សារម្មណ៍ និងរូបតំណាងរបស់លំនឹក ។

៤. តើត្រូវធ្វើដូចម្តេច ដើម្បីប្រយុទ្ធទប់ទល់នឹងការភ្លេច?

៥. តើលំនឹកមានសារប្រយោជន៍យ៉ាងណាខ្លះចំពោះការសិក្សា និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ?

## មេរៀនទី៧ ការគិត

### I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់បានពីសញ្ញាណទូទៅនៃការគិត
- កំណត់បាននូវលក្ខណៈពិសេសដែលបង្ហាញពីចរិតក្នុងគម្រោងនៃការគិត
- យកចិត្តទុកដាក់ដល់ការគិតរបស់សិស្សសមស្របតាមវ័យ ។

### II- សេចក្តីផ្តើម

ឥន្រ្ទីយារម្មណ៍ និងប្រត្យក្សារម្មណ៍ផ្តល់ឱ្យយើងនូវពុទ្ធិចំពោះវត្ថុរូបី និងចំពោះលក្ខណៈវត្ថុនោះបានភ្លាមៗ ។ ពុទ្ធិទាំងនេះមានសារៈសំខាន់ចំពោះសកម្មភាពទាំងឡាយរបស់មនុស្សតែមិនទាន់គ្រប់គ្រាន់ទេ ព្រោះពុទ្ធិរបស់មនុស្សពុំទាន់កំណត់ចប់ត្រឹមឥន្រ្ទីយារម្មណ៍ និងប្រត្យក្សារម្មណ៍ប៉ុណ្ណោះទេ ។ សកម្មភាពសិក្សា សកម្មភាពពលកម្មមិនតម្រូវឱ្យមនុស្សមានត្រឹមតែពុទ្ធិរូបី និងពុទ្ធិចំពោះលក្ខណៈខាងក្រៅនៃវត្ថុតែប៉ុណ្ណោះទេ តែមនុស្សត្រូវភ្ជាប់ឱ្យបាននូវទំនាក់ទំនងថ្មីរវាងវត្ថុ និងបាតុភូត ឬរឿងរ៉ាវ ដែលស្ថិតនៅក្នុងមជ្ឈដ្ឋានជុំវិញខ្លួនយើង ។ ជាមួយនេះដែរ មនុស្សត្រូវរៀបចំជាមុននូវវិធីដែលខ្លួនត្រូវយកទៅអនុវត្ត ដើម្បីធ្វើឱ្យសម្រេចសកម្មភាពទាំងនោះ ។

តម្រូវការក្នុងមជ្ឈដ្ឋានបានធ្វើឱ្យមនុស្សឆ្លុះបញ្ចាំងតាមទម្រង់ផ្សេងៗ ដូចជាតំណាងទូទៅលើវត្ថុ ឬបាតុភូតដែលគេមើលឃើញ ។ ចំណាំងទូទៅនេះ តម្រូវឱ្យមនុស្សមានពុទ្ធិឥន្រ្ទីយ៍ជាមូលដ្ឋានបង្អែកសម្រាប់ឈោងចាប់សញ្ញាណអរូបី និងទូទៅគឺជាដំណាក់ពុទ្ធិវិចារ ។

ពុទ្ធិវិចារ ជាលំនាំពុទ្ធិដែលឆ្លុះបញ្ចាំងដោយប្រយោលពីលក្ខណៈខាងក្នុងនៃវត្ថុ ឬបាតុភូតដែលកន្លងហួសមកហើយ ឬដែលស្ថិតនៅចំពោះមុខឬទៅអនាគត ហើយបង្កើតបានជាសញ្ញាណអរូបីកម្ម និងទូទៅកម្ម។

ក្នុងជីវិតរស់នៅរបស់មនុស្ស យើងតែងតែជួបប្រទះបញ្ហាជាច្រើន ដែលស្ថិតនៅជុំវិញខ្លួនយើងមានវត្ថុបាតុភូត និងហេតុការណ៍ជាច្រើនទៀតដែលយើងមិនស្គាល់ មិនយល់ និងមិនដឹងជាមុន ដែលត្រូវប្រឈមមុខនឹងការដោះស្រាយ។ លំនាំនៃដំណោះស្រាយដ៏មានប្រសិទ្ធភាពកើតចេញមកពីចំណេះដឹង ដែលមានលំនាំខ្ពស់ជាងលំនាំនៃចំណេះដឹងឥន្រ្ទីយ៍ហៅថា **ការគិត** ។

### III- ខ្លឹមសារ

#### ១- និយមន័យ

ការគិតជាលំនាំចិត្តដែលឆ្លុះបញ្ចាំងលក្ខណៈនៃធម្មជាតិ និងទំនាក់ទំនងខាងក្នុងមានចរិតជាក្រឹត្យក្រមនៃវត្ថុ ឬបាតុភូតដែលកើតមាននៅក្នុងតថភាពសត្យានុម័ត ហើយដែលពីមុនយើងមិនទាន់បានស្គាល់នៅឡើយ (មានន័យថាចំណេះដឹងឥន្រ្ទីយ៍មិនអាចឆ្លុះបញ្ចាំងទៅលើវាបាន ) ។

ការគិតគឺជាកម្រិតថ្មីនៃចំណេះដឹង បើប្រៀបធៀបទៅនឹងឥន្រ្ទីយារម្មណ៍ និងប្រត្យក្សារម្មណ៍ ព្រោះដោយសារតែពុទ្ធិឥន្រ្ទីយ៍ទាំងពីរនេះ គ្រាន់តែឆ្លុះបញ្ចាំងបានពីលក្ខណៈ និងទំនាក់ទំនងខាងក្រៅរបស់វត្ថុ ឬបាតុភូតប៉ុណ្ណោះ ។ ការគិត អាចឆ្លុះបញ្ចាំងបានលក្ខណៈខាងក្នុងរបស់វត្ថុ ឬបាតុភូត ដោយមានចរិតលក្ខណៈតាមក្រឹត្យក្រមជាក់លាក់ផង ។ ការគិតអាចឆ្លុះបញ្ចាំងវត្ថុ ឬបាតុភូតអ្វីដែលថ្មីស្រឡាង ពោលគឺយើងមិនទាន់ធ្លាប់ជួបប្រទះពីមុនទាល់តែសោះ។

ឧទាហរណ៍៖ គ្រូកែកិច្ចការសិស្សអាចដឹងពី៖

- កំហុស និងចំណុចខ្វះខាតរបស់សិស្ស
- លទ្ធផលនៃការសិក្សារបស់សិស្ស

- របៀបសិក្សារបស់សិស្ស
- កម្រិតចំណេះដឹងរបស់សិស្ស
- អាចឆ្លុះបញ្ចាំងពីលទ្ធផលនៃការបង្រៀនរបស់ខ្លួនគាត់ចំពោះសិស្ស ។

ទាំងនេះជាបាតុភូតដែលឆ្លុះបញ្ចាំងដោយសារ ការគិតរបស់គ្រូបង្រៀន ។

ឧទាហរណ៍៖ អ្នកជំងឺម្នាក់ទៅរកគ្រូពេទ្យ ដើម្បីរកឱ្យឃើញពីប្រភេទជំងឺ គ្រូពេទ្យសួរពីអាការៈជំងឺ ។ តាមចម្លើយរបស់អ្នកជំងឺ គ្រូពេទ្យអាចដឹងពីរោគសញ្ញានៃជំងឺ ។ ការត្រិះរិះទាំងឡាយរបស់គ្រូពេទ្យដែលវិភាគលើរោគសញ្ញា និងការព្យាបាល គឺជាបាតុភូតនៃការគិត ។

កម្រិតយល់ដឹងរបស់សិស្សដែលគ្រូពិនិត្យឃើញ ប្រភេទជំងឺដែលគ្រូពេទ្យរកឃើញ ជាខ្លឹមសារត្រូវបានឆ្លុះបញ្ចាំងដោយសារការគិត រីឯឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍មិនអាចឆ្លុះបញ្ចាំងបាននូវបាតុភូត ឬវត្ថុអរូបីដូចនេះបានទេ ។ ប្រត្យក្សារម្មណ៍គ្រាន់តែធ្វើឱ្យយើងឃើញពីលក្ខណៈខាងក្រៅរបស់ជំងឺ ពុំអាចដឹងបានពីប្រភេទជំងឺទេ ។ ឯកំហុស និងកង្វះខាត ឬកម្រិតចំណេះដឹងរបស់សិស្ស ក៏មិនអាចឆ្លុះបញ្ចាំងបានដោយសារប្រត្យក្សារម្មណ៍ដែរ ។

## ២- ធម្មជាតិ នៃការគិត

ការគិត ជាលំនាំពុទ្ធិដែលមានកម្រិតខ្ពស់ ហើយប្រព្រឹត្តទៅនៅក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗ ។ លទ្ធផលនៃការគិតត្រូវបានស្តែងចេញមកខាងក្រៅតាមរយៈភាសា និងសកម្មភាព ។ ភាសាជាមធ្យោបាយនៃការគិត ដែលផ្សារភ្ជាប់ទៅនឹងភាសាក្នុងរបស់មនុស្ស ។ សកម្មភាពដែលស្តែងចេញពីការគិតគឺ ភាពប៉ិនប្រសប់នៃការគិតទៅលើដំណើរអភិវឌ្ឍន៍ប្រវត្តិសាស្ត្រ ទំនាក់ទំនងរវាងមនុស្សក្នុងសង្គម និងសមិទ្ធផលនៃឧបករណ៍ផលិតនៅក្នុងវិស័យវិទ្យាសាស្ត្របច្ចេកទេស វិស័យឧស្សាហកម្ម វិស័យកសិកម្ម វិស័យទូរគមនាគមន៍...ដែលមនុស្សរួមគ្នាគិត ដោយប្រើពេលយ៉ាងយូរ និងច្រើនជំនាន់ ។

ការគិតនៃខួរក្បាលរបស់មនុស្ស អាចបង្កើតបានជាម៉ាស៊ីនស្វ័យប្រវត្តិសម្រាប់បម្រើសេចក្តីត្រូវការរបស់មនុស្ស និងជួយដោះស្រាយបញ្ហាផ្សេងៗដែលមនុស្សមិនអាចដោះស្រាយបានដូចជា ម៉ាស៊ីនវិនិច្ឆ័យរោគសញ្ញា ម៉ាស៊ីនសម្រាប់គណនា កុំព្យូទ័រដែលអាចកត់ត្រាបាននូវទិន្នន័យយ៉ាងច្រើន...។

ដូចនេះការគិត គឺជាសតិដ៏មានតម្លៃរបស់មនុស្ស ពីព្រោះមានតែមនុស្សទេ ដែលមានការគិតហើយអាចកំណត់នូវទិសដៅនៃការគិតរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាសម្រាប់សង្គម ។ ការគិតអាស្រ័យទៅតាមសមត្ថភាពចំណេះដឹង និងភាពប៉ិនប្រសប់របស់បុគ្គលនីមួយៗ ។ ការគិតអាចឱ្យមនុស្សស្គាល់ និងដណ្តើមត្រួតត្រា ឬសម្រេចការងារធំៗក្នុងជីវិតរស់នៅដូចជា ការស្វែងរកភាពសម្រុះសម្រួល ការចុះសម្រុងគ្នា និងសន្តិភាពទៀតផង ។ ការគិតធ្វើឱ្យមនុស្សមិនត្រឹមតែដណ្តើមឈ្នះលើភពផែនដីប៉ុណ្ណោះទេ តែគេអាចដណ្តើមត្រួតត្រាក្នុងលំហអាកាសទៀតផង ។

## ៣. ចំណែកថ្នាក់ នៃការគិត

ផ្អែកលើមូលដ្ឋាននៃកំណកំណើត និងកម្រិតអភិវឌ្ឍន៍នៃការគិត គេចែកការគិតជាបីប្រភេទគឺ ៖

### ៣.១. ការគិតរូបីតាមដៃ

ការគិតរូបីតាមដៃ គឺការគិតដោយដៃ ។ ការគិតប្រភេទនេះ មានចំពោះក្មេងអាយុ៣ឆ្នាំ ចំពោះសត្វស្វា និងមនុស្សជំនាន់ដើម ។

ឧទាហរណ៍៖ ស្វា និងស្និតចេក ។ ស្វាអាចឈោងបេះផ្លែចេកបាន ដោយសារវាយកកំណាល់ជាច្រើន ដែលនៅក្រោមស្និតចេកមកគរលើគ្នា ឱ្យបានកម្ពស់ដល់ផ្លែចេក ។

### ៣.២. ការគិតរូបីតាមរូបភាព

ការគិតបែបនេះ កើតមានចំពោះក្មេងអាយុ៤-៦ដល់៧ឆ្នាំ។ ក្មេងដល់ដំណាក់កាលអាយុនេះ គេអាចគិត

ជាមួយរូបភាពតំណាងនៃវត្ថុ ហើយនាទីរបស់ដៃថយចុះ ពេលនេះការគិតអរូបីទើបនឹងចាប់ផ្តើម ។

ឧទាហរណ៍៖ បទពិសោធរបស់ព្យាហ្សេ (Piaget) ជាមួយដុំប៊ូលពីរ មួយមូល មួយទៀតគាត់សង្កត់ឱ្យសំប៉ែតនៅមុខក្មេង ។ ក្មេងសង្កេតឃើញថា ប៊ូលសំប៉ែតធំជាងប៊ូលមូល ។

ឧទាហរណ៍៖ ធនញ្ជ័យ ក្នុងរឿងធនញ្ជ័យគិតថា អំបុកដាក់ចង្អេរច្រើនជាងអំបុកដាក់ល្អី ។

### ៣.៣. ការគិតអរូបី

ការគិតអរូបី ជាការគិតរបស់មនុស្សដែលមានកម្រិតខ្ពស់ ។ ការគិតអរូបីអាចឆ្លុះបញ្ចាំងក្រឹត្យក្រម និងទំនាក់ទំនងនៃហេតុការណ៍ផ្សេងៗ ដែលពុទ្ធិឥន្ទ្រីយ៍ និងការគិតដទៃទៀតមិនអាចឆ្លុះបញ្ចាំងបាន ។ ការគិតអរូបីក៏បង្កើតបានជាបញ្ញត្តិដែរ ។

សាលារៀនមានតួនាទី ធ្វើឱ្យការគិតគ្រប់ប្រភេទរបស់សិស្សរីកចម្រើន ពិសេសគឺការគិតអរូបី ។ មធ្យោបាយដ៏មានប្រសិទ្ធភាពនៃការគិតនៅក្នុងថ្នាក់រៀនគឺ ការផ្តល់ឱកាសច្រើន ជាពិសេសពេលវេលា និងគំនិតប្រៀបធៀបដែលរួមទាំងឱកាសធ្វើសកម្មភាព និងការសហការប្តូរយោបល់គ្នារវាងសិស្ស និងសិស្ស ។ ដូចនេះ គ្រូត្រូវរិះរកគ្រប់មធ្យោបាយដើម្បីពង្រីកការគិតរបស់សិស្សនៅក្នុងការអប់រំ ការបង្រៀន និងការរៀន ។

ដោយការគិតអរូបី សិស្សអាចយល់បានពីប្រវត្តិសាស្ត្រសម័យបុរាណ សំណុំនៃចំណុចមួយ វាលលំហសមុទ្រទឹកកក... ។

ការគិតអរូបីអាចឱ្យសិស្សចេះវិភាគ និងឱ្យតម្លៃលើសកម្មភាពតួអង្គនីមួយៗ តាមរយៈអំណាន ឬការស្តាប់រឿងនិទានផ្សេងៗ ។ ពិសេសជាងនេះទៅទៀត ការគិតអរូបីអាចឱ្យមនុស្សរកឃើញភពផ្សេងៗដូចជា ភពព្រះច័ន្ទ និងភពតារាប្លែកៗទៀត ។

## ៤. ចរិតលក្ខណៈ នៃការគិត

ដោយសារការគិតជាកម្រិតខ្ពស់បំផុត នៃសកម្មភាពញាណរបស់មនុស្ស ដូចនេះ ការគិតត្រូវមានចរិតលក្ខណៈដូចតទៅ៖

### ៤.១. ចរិតលក្ខណៈ ចោទជាបញ្ហានៃការគិត

ការគិតជាលំនាំផ្លូវចិត្តដែលកើតមានឡើងក្នុងជីវភាពរស់នៅ ឬក្នុងការប្រតិបត្តិការងារដោយតម្រង់ទៅរកគោលដៅមួយ ។ ការគិតកើតមកពីសកម្មភាពមានបញ្ហា ដែលធ្វើឱ្យមនុស្សផុសចេញនូវគំនិតថ្មី គោលបំណងថ្មី ។ ការជួបប្រទះបញ្ហាថ្មី ស្ថានភាពថ្មី និងលក្ខខណ្ឌនៃសកម្មភាពថ្មី ធ្វើឱ្យមនុស្សតម្រង់ទិសទៅរកគោលបំណងមួយជាក់លាក់ ។

ឧទាហរណ៍៖ សិស្សម្នាក់ជាសិស្សព្យាយាមរៀនសូត្រ មានស្មារតីទទួលខុសត្រូវក្នុងការងារ ហើយឥឡូវគេបែរជាមិនយកចិត្តទុកដាក់ក្នុងការសិក្សា ។ នេះជាបាតុភូតមួយ ដែលទាមទារឱ្យសាស្ត្រាចារ្យ ត្រូវគិតពិចារណាអំពីចរិតលក្ខណៈរបស់សិស្សនោះ ។

ការគិត គឺជាការសិក្សាស្រាវជ្រាវ ដែលនាំឱ្យយើងទៅរកគំហើញថ្មីៗ ។ ប្រសិនបើគេ ធ្លាប់ជួបប្រទះបញ្ហាណាមួយម្តងរួចមកហើយ ។ និងដោយសារចំណេះដឹង ព្រមទាំងគេធ្លាប់មានបទពិសោធផងនោះ នោះគេនឹងមិនត្រូវការការគិតប៉ុន្មានឡើយ ។

ឧទាហរណ៍៖ សិស្សអនុវិទ្យាល័យមិនត្រូវការគិតទេ បើយើងសួរគេថា ពីរគុណនឹងពីរត្រូវជាប៉ុន្មាននោះ ។

ការគិតជារំញោចនៃស្ថានភាពបញ្ហា ដែលបង្កឱ្យមានរំញោចនៃការគិតទាំងអស់ ។ ដើម្បីឱ្យមនុស្សកើតមានការគិត លុះត្រាតែមនុស្សស្គាល់ស្ថានភាពបញ្ហាសិន ទើបមនុស្សអាចកំណត់ទិសដៅនៃការគិតបាន ។ សមត្ថភាពនៃការគិតក៏អាស្រ័យផងដែរ ទៅនឹងអ្វីដែលមនុស្សធ្លាប់ជួបប្រទះ និងបទពិសោធ ក៏ប៉ុន្តែជួនកាលស្ថានភាពបញ្ហា វាហួស

ពីព្រំដែនចំណេះដឹងនោះបង្កឱ្យមានអសមត្ថភាពនៃការគិត ។

ឧទាហរណ៍៖ ល្បែងល្បងបញ្ញាខ្លះ ធ្វើឱ្យបេក្ខជនមិនអាចឆ្លើយបាន ។

### ៤.២. ការគិតជាចំណាំងប្រយោល

ការគិតពុំមែនជាចំណាំងផ្ទាល់ដូចឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍នោះទេ ។ ការគិត ជាចំណាំងប្រយោល ព្រោះការគិតអាចឆ្លុះបញ្ចាំងវត្ថុ ឬបាតុភូតដែលប្រព្រឹត្តដោយប្រយោលមកលើសរីរាង្គឥន្ទ្រីយ៍ ។ ការគិតជួយយើងឱ្យមានសមត្ថភាពយល់ដឹងពីចរិតលក្ខណៈខាងក្នុងដែលពុទ្ធិឥន្ទ្រីយ៍មិនអាចឆ្លុះបញ្ចាំងបាន ។

ឧទាហរណ៍៖ ភ្លៀងធ្លាក់នៅពេលយប់ពេលយើងកំពុងគេងលក់ ។ លុះព្រឹកពីដំណេកយើងដឹងថាមានភ្លៀងធ្លាក់ ព្រោះសំអាងលើសញ្ញាខាងក្រៅដូចជា ដំណក់ទឹកភ្លៀងមានជាប់នឹងស្លឹកឈើ និងដីសើម... ។

### ៤.៣. ការគិតសម្ដែងចេញឡើងតាមរយៈភាសា

ដោយសារភាសា យើងអាចស្គាល់ និងដឹងបានពីអ្វីៗ ដែលយើងមិនដែលឃើញ មិនដែលឮ ។

ឧទាហរណ៍៖ សិស្សខ្មែរយើងមួយចំនួនធំមិនធ្លាប់បានឃើញវាលសមុទ្រខ្សាច់ ឬសមុទ្រទឹកកកនោះទេ ។ ដោយសារតែការបកស្រាយ ការពន្យល់ និងការអធិប្បាយរបស់សាស្ត្រាចារ្យ ពេលនោះ សិស្សអាចដឹង ស្គាល់ពីវាលសមុទ្រខ្សាច់ ឬសមុទ្រទឹកកកបាន ។

ឧទាហរណ៍៖ គ្រូពេទ្យមិនអាចដឹងពីកម្រិតប្រភេទជំងឺបានច្បាស់លាស់នោះទេ នៅពេលដែលគាត់ទើបតែបានឃើញអ្នកជំងឺភ្លាម ។ តែក្រោយពីគាត់សាកសួរអ្នកជំងឺពីមូលហេតុខ្លះ ទើបគាត់ធ្វើការសរុបគ្រប់រោគវិនិច្ឆ័យទាំងអស់ដែលគាត់ដឹងដោយធ្វើការវិភាគ ប្រៀបធៀប និងសំយោគទៅលើរោគវិនិច្ឆ័យតាមចំណេះដឹងផ្នែកទ្រឹស្ដី និងបទពិសោធក្នុងការអនុវត្ត ។ ទីបំផុតគ្រូពេទ្យ អាចធ្វើសេចក្ដីសន្និដ្ឋានបានលើរោគវិនិច្ឆ័យនោះ ។

នៅមានវត្ថុ ឬបាតុភូតខ្លះទៀត ដែលយើងមិនអាចពិនិត្យឃើញដោយផ្ទាល់បាន ។ អ្នកវិទ្យាសាស្ត្របានផលិតវត្ថុ ឬឧបករណ៍ដូចជា ទែម៉ូម៉ែត ប្រដាប់វាស់ស្ទង់សម្រាប់ប្ដូរសម្ពាធបរិយាកាស កុងទ័រ ប្រដាប់វាស់ឈាម... ដែលជាតម្រូវការចាំបាច់របស់មនុស្ស ហើយសព្វថ្ងៃនេះ គេអាចវាស់ចលនានៃបេះដូង និងខួរក្បាលបានទៀតផង តាមរយៈកុំព្យូទ័រ ដែលទាំងអស់នេះជាលក្ខណៈចំណាំងប្រយោលនៃការគិត។

### ៤.៤. ចរិតលក្ខណៈ អរូបីកម្ម និងទូទៅកម្មនៃ ការគិត

ការគិតជាចំណាំងបែបអរូបីទៅលើវត្ថុ និងបាតុភូតទាំងឡាយ ។

ឧទាហរណ៍៖ ប្រភេទជំងឺ កម្រិតវប្បធម៌សិស្សម្នាក់ៗ ទាំងនេះជាចរិតលក្ខណៈអរូបី បានន័យថា បើយើងមិនអាចមើលឃើញ មិនអាចឮ មិនអាចប៉ះពាល់បាន នេះជាចំណាំងអរូបី។

ដោយសារការគិត មនុស្សអាចយល់បានស៊ីជម្រៅ ល្អិតល្អន់នូវខ្លឹមសារ និងគុណភាពនៃវត្ថុ ឬបាតុភូតជាច្រើន ហើយបង្កើតបានជាសញ្ញាណទូទៅមួយ ។

ឧទាហរណ៍៖ ឆ្កែ ឆ្មា ជ្រូក គោ ក្របី សេះ មានលក្ខណៈរួមមួយ គឺការចិញ្ចឹមកូនដោយទឹកដោះ ។ ដោយសារមានលក្ខណៈរួមទូទៅ គេអាចចងក្រងសត្វទាំងនោះនៅក្នុងពពួកតែមួយគឺ ថនិកសត្វ។ ដូច្នេះ ការកំណត់ថា "**ថនិក សត្វ**" ជាសញ្ញាណទូទៅកម្ម ។

ការគិតតាមបែបអរូបី និងទូទៅមិនត្រឹមតែមានដំណោះស្រាយចំពោះមុខក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ តែថែមទាំងជួយយើងឱ្យគ្រោងទុកបាននូវបញ្ហាទាំងឡាយទៅអនាគតផង ។

ឧទាហរណ៍៖ ដោយលោហធាតុមានការប្រែប្រួលក្រោមឥទ្ធិពលនៃសីតុណ្ហភាព ដូច្នេះហើយបានជានៅពេលគេសាងសង់ផ្លូវរថភ្លើង នៅមុខតំណគេត្រូវតែទុកចន្លោះតូចមួយ ។

### ៤.៥. ការគិតប្រើភាសាជាឧបករណ៍

ការគិត ជាលំនាំពុទ្ធិដែលមានមុខងារដ៏សំខាន់ ដែលធ្វើឱ្យគេស្គាល់ពិភពបរានុម័ត ។ ក្នុងលំនាំនៃការគិតជាតុសំខាន់គឺ"បញ្ញត្តិភាសា"។ ដូចនេះភាសាជាលំនាំមួយ ដែលមានមុខងារបង្ហាញលទ្ធផលនៃការគិត ។ បញ្ញត្តិភាសាត្រូវបានស្តែងចេញពីពាក្យមួយម៉ាត់ ឬជាភាសាដែលមានលក្ខណៈជាច្បាប់ ឬជានិយមន័យ។ បញ្ញត្តិភាសាក៏ជារូបភាពនៃពិភពបរានុម័តដែរ តែខុសពីរូបភាពនៃឥន្ទ្រីយារម្មណ៍ ឬប្រត្យក្សារម្មណ៍ ដែលយើងមានបញ្ញត្តិបង្កប់គ្រប់លក្ខណៈសំខាន់ៗ នៃក្រឹត្យក្រមទាំងឡាយរបស់វត្ថុ ឬបាតុភូត ។

ឧទាហរណ៍៖ បញ្ញត្តិ"កាផ" គឺជារូបភាពមួយនៃរូបធរណីមាត្រដែលមានមុំកែងបួន និងជ្រុងបួនស្មើគ្នា។ គេមិនចាំបាច់យកសញ្ញាសម្គាល់រូបផ្សេងៗទៀតដូចជា ពណ៌ ប្រវែង ឬកម្រាស់នៃរូបភាពនោះមកបង្ហាញទេ។

បញ្ញត្តិ"តុ" សម្គាល់ពីគ្រឿងសង្ហារឹមដែលមានផ្ទៃរាបស្មើ ទ្រដោយជើងបួន សម្រាប់តម្កល់វត្ថុផ្សេងៗ។ ចំពោះបញ្ញត្តិ"តុ" នេះគេអាចស្គាល់បាន ដោយមិនគិតពីទម្រង់របស់តុ (មូល ជ្រុង កាផ) ឬទំហំ (តូច ធំ ទាប ខ្ពស់) ឡើយ ។

ការគិតត្រូវបានសម្តែងចេញតាមរយៈភាសា ។ តែផ្ទុយទៅវិញ ភាសាមិនអាចមានអត្ថិភាពឡើយ ប្រសិនណាវាមិនឈរលើមូលដ្ឋាននៃការគិតទេ វាគ្រាន់តែជាសំឡេងនិយាយជាប់ៗគ្នាដោយឥតន័យ និងគ្មានអត្ថរស។ ភាសាជាលំនាំផ្លូវចិត្តដែលមានមុខងារសម្រាប់បង្ហាញពីការគិត ។

ឧទាហរណ៍៖ ការគិតទៅដល់ការងារ គ្រួសារ ផ្ទះសំបែង... ត្រូវបានសម្តែងចេញជាពាក្យ ការងារគ្រួសារ ផ្ទះសំបែង... តែពាក្យទាំងនេះមិនបានសម្តែងចេញក្រៅនោះទេ តែវាបានស្ថិតនៅក្នុងខួរក្បាលរបស់យើង ។

ដូចនេះ ដើម្បីបណ្តុះដល់សិស្សនូវបញ្ញត្តិត្រឹមត្រូវ គ្រូបង្រៀនគ្រប់រូបត្រូវពឹងផ្អែកលើរូបភាព ដែលស្ថិតនៅក្នុងបទពិសោធ និងបង្ហាញដល់សិស្សនូវភាពខុសគ្នា ជាគោលការណ៍រវាងវត្ថុទាំងឡាយ ។ ម្យ៉ាងទៀតគ្រូបង្រៀនត្រូវប្រើការសង្កេត ប្រើរូបភាព ដើម្បីពន្យល់សិស្សពីលក្ខណៈខុសគ្នា និងលក្ខណៈដូចគ្នានៃវត្ថុនោះ ។ ដោយសារវិធីនេះ សិស្សអាចយល់ជ្រួតជ្រាបបានពីបញ្ញត្តិវិទ្យាសាស្ត្រទាំងឡាយ។

### ៤.៦. ការគិតអាចជួយឱ្យមនុស្សឆ្លុះបញ្ចាំងបានដ៏ជាក់លាក់ទៀងទាត់ ហើយស៊ីជម្រៅទៅលើធម្មជាតិនៃវត្ថុ និងបាតុភូត ដែលស្ថិតនៅក្នុងតថភាពសត្យានុម័ត

គឺមានតែការគិតទេ ដែលជួយមនុស្សឱ្យមានលទ្ធភាពឆ្លុះបញ្ចាំងបាននូវធម្មជាតិរបស់វត្ថុ និងបាតុភូត ព្រមទាំងទំនាក់ទំនងដែលមានលក្ខណៈជាក្រឹត្យក្រម ហើយដែលអាចឆ្លងកាត់កម្រិតដែលមើលឃើញជាក់ស្តែងរបស់ពុទ្ធិឥន្ទ្រីយ៍ ។ ពិសេសណាស់ទៅទៀត ការគិតគឺជាកម្រិតខ្ពស់បំផុតរបស់សកម្មភាពញាណសក្តិ ពោលគឺ កម្រិតនៃពុទ្ធិវិចារ ។ ប៉ុន្តែនេះក៏មិនមែនមានន័យថា ការគិតចេះតែឆ្លុះបញ្ចាំងបានត្រឹមត្រូវឥតខ្ចោះជានិច្ចទៅលើវត្ថុ ឬបាតុភូតនោះទេ ។ ការគិតឆ្លុះបញ្ចាំងបានត្រឹមត្រូវឥតខ្ចោះ ឬមិនត្រឹមត្រូវ អាស្រ័យដោយល្បិច និងវិធីដែលមនុស្សគិតទេ ។

### ៤.៧. ការគិតមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងពុទ្ធិឥន្ទ្រីយ៍

ថ្វីត្បិតតែការគិតមានកម្រិតខ្ពស់ជាងពុទ្ធិឥន្ទ្រីយ៍ក៏ដោយ ( ឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ) ក៏ការគិតមិនអាចកាត់ផ្តាច់ពីពុទ្ធិឥន្ទ្រីយ៍នេះបានឡើយ ។ ទំនាក់ទំនងបញ្ច្រាសគ្នា និងទំនាក់ទំនងឯកភាពគ្នារវាងការគិត និងពុទ្ធិឥន្ទ្រីយ៍ស្តែងឡើងឱ្យឃើញនូវចំណុចទាំងឡាយដូចតទៅ ៖

- ពុទ្ធិឥន្ទ្រីយ៍គឺជាមូលដ្ឋាននៃការគិត ។ ការគិតត្រូវពឹងផ្អែកលើពុទ្ធិឥន្ទ្រីយ៍ ។ ពុទ្ធិឥន្ទ្រីយ៍ គឺជាប្រភពដែលផ្គត់ផ្គង់សម្ភារៈឱ្យដល់សកម្មភាពនៃការគិត ។ លើរាល់ចំណេះដឹងទាំងអស់ចាប់ប្រភពចេញមកពីបទពិសោធន៍ ឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍នេះឯង ។ ប្រត្យក្សារម្មណ៍ គឺជាដំណាក់កាលមួយ និងជា សមាសធាតុមួយនៅក្នុងសកម្មភាពនៃការគិត ( គេត្រូវមើលឃើញស្ថានភាពមានបញ្ហាសិន មុននឹងកំណត់បាននូវភារកិច្ចនៃការគិត ) ។ ពុទ្ធិឥន្ទ្រីយ៍បង្កើតបានជាមធ្យោបាយមួយថែមទៀត ដែលជួយឱ្យមនុស្សត្រួតពិនិត្យបានទៅលើភាពត្រឹមត្រូវឥតស្មៀង

របស់ការគិត ។

- ផ្ទុយទៅវិញ ការគិត និងផលិតផលរបស់វាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើលំនាំនៃពុទ្ធិឥន្ទ្រីយ៍ដូចជា ភាពជម្រើស អត្ថន័យ និងស្ថេរភាព របស់ប្រត្យក្សារម្មណ៍ ។ វត្ថុ និងបាតុភូត ដែលចាំងចូលមកក្នុងចក្ខុវិញ្ញាណរបស់យើង មិនគ្រាន់តែនាំមកនូវឥន្ទ្រីយារម្មណ៍ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងនាំមកនូវសកម្មភាពនៃការគិតទៀតផង ។

ដោយយោលទៅតាមចរិតរបស់លំនាំនៃការគិត ដូចដែលយើងបានពិសោធរួចមកហើយនោះ យើងអាចទាញសេចក្តីសន្និដ្ឋានគរុកោសល្យដ៏ចាំបាច់នៅក្នុងការបង្រៀន និងការអប់រំដូចតទៅ ៖

ក. គប្បីយកចិត្តទុកដាក់ឱ្យបានដិតដល់ ចំពោះការអភិវឌ្ឍនៃការគិតរបស់សិស្ស ដោយហេតុថា សិស្សមិនមានសតិនៃការគិតទេ ហើយសិស្សក៏មិនអាចយកជោគជ័យបានលើធម្មជាតិ និងធ្វើម្ចាស់ការលើសង្គមដោយខ្លួនឯងបានឡើយ ។

ខ. ការអភិវឌ្ឍនៃការគិត មិនអាចកាត់ផ្តាច់ពីវប្បធម៌នៃភាសាបានឡើយ ។ នៅពេលណាដែលសិស្សក្តាប់បានភាសាវិទ្យាសាស្ត្រនៃមុខវិជ្ជាសិក្សានីមួយៗ ហើយសិស្សពិតជាមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធ្វើឱ្យការគិតនៅក្នុងវិស័យផ្សេងទៀតនៃវិទ្យាសាស្ត្រអភិវឌ្ឍឡើង ។

គ. ការអភិវឌ្ឍនៃការគិតមិនអាចជំនួសឱ្យការហ្វឹកហ្វឺនរបស់ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ សតិនៃការសង្កេត និងលំនឹករបស់សិស្សបានឡើយ ។

ឃ. ការអភិវឌ្ឍការគិត ត្រូវឱ្យមានដំណើរការប្រព្រឹត្តទៅស្របគ្នា និងការផ្តត់ផ្តង់ចំណេះដឹង និងឆ្លងកាត់វិធីបង្រៀន និងរៀននេះទៀតផង ។

ង. បើគេចង់ឱ្យខួរក្បាលរបស់សិស្សមានលក្ខណៈសកម្មពិតប្រាកដ ដោយជំរុញសិស្សឱ្យចេះគិត គេត្រូវចេះបង្កើតឱ្យមានស្ថានភាពបញ្ហានៅចំពោះមុខសិស្ស ។ បែបបទដ៏ងាយស្រួលបំផុតក្នុងការអនុវត្តឱ្យបានសម្រេចតាមប្រការនេះ គ្រូបង្រៀនត្រូវចេះចោទជាសំណួរឱ្យសមស្របទៅតាមសមត្ថភាពសិស្ស តាមកម្រិតសិក្សា នៅពេលដែលគេពន្យល់មេរៀន ។

### ៥. ចលនានៃការគិត

ទង្វើរបស់ការគិតដែលសម្រេចបានរយៈអំពើនៃបញ្ញា ជាការកំណត់នោះហៅថា ចលនានៃការគិត ។ តាមទស្សនៈធម្មជាតិ ការគិតគឺជាលំនាំផ្លូវចិត្តមួយដែលបុគ្គលបានប្រកាន់ភ្ជាប់តាមរយៈចលនានៃបញ្ញាជាកំណត់ ដើម្បីដោះស្រាយបញ្ហា ឬភារកិច្ចដែលចោទឡើងចំពោះខ្លួនគេ ។ បុគ្គលធ្វើការគិត ឬមិនធ្វើ នោះវាអាស្រ័យដោយហេតុការណ៍ដែលមនុស្សនោះធ្វើ ឬមិនធ្វើចលនានៃការគិតនៅក្នុងខួរក្បាលទេ ។ ហេតុនេះ បានជាក្រុមចិត្តវិទូហៅចលនានៃការគិត ម្យ៉ាងទៀតថា ច្បាប់ផ្ទៃក្នុងរបស់ការគិត ។ យើងសិក្សាពីចលនានៃការគិតជាក់ស្តែងដូច តទៅ ៖

#### ក. ការវិភាគ

ការវិភាគ គឺជាលំនាំដែលប្រើចលនានៃខួរក្បាលរបស់មនុស្ស ហើយដែលត្រូវកាត់ផ្តាច់ពីវត្ថុ និងបាតុភូតចំពោះ៖

- ទិដ្ឋភាពណាមួយ
- លក្ខណៈណាមួយ
- ផ្នែកផ្សេងៗដែលជាសមាសភាគ
- ទំនាក់ទំនង

នេះគឺជាបំណែងចែកវត្ថុពីចំណេះដឹង ដែលមានរួចមកហើយនៅក្នុងខួរក្បាលមនុស្សឱ្យទៅជាធាតុ និងផ្នែកផ្សេងៗគ្នា ។ មូលដ្ឋានសរីរៈរបស់ចលនានៃការគិត គឺការរួមបញ្ចូលគ្នាជាកំណត់រវាងការកើតមានរំញោច និងការថយ

ចុះនៃរំញោចនៅលើសំបកខួរក្បាលមនុស្ស ។

### ខ. ការប្រៀបធៀប

ការប្រៀបធៀបគឺជាលំនាំដែលប្រើចលនានៃខួរក្បាលរបស់មនុស្សដែរ ហើយសំដៅកំណត់បាននូវភាពដូចគ្នា ឬ ភាពខុសគ្នា ក្រុមមានអត្ថសញ្ញាណ និងក្រុមឥតមានអត្ថសញ្ញាណ ឬវិសមភាពរវាងវត្ថុ និងបាតុភូតទាំងឡាយ ។ ចលនានៃការប្រៀបធៀបមានទំនាក់តំនងយ៉ាងជិតស្និទ្ធជាមួយនឹងចលនានៃការវិភាគ និងការធ្វើសំយោគ ។ នៅក្នុងដំណាក់កាលទីមួយនៃការសិក្សាស្រាវជ្រាវពិភពជុំវិញខ្លួន គេអាចស្គាល់ពីវត្ថុដែលខុសប្លែកពីគ្នាតាមរយៈការប្រៀបធៀបនេះឯង ។

ការប្រៀបធៀបជាមូលដ្ឋាននៃការគិត និងចំណេះដឹងទាំងឡាយ ។

**គ. ការធ្វើសំយោគ** គឺជាលំនាំដែលប្រើចលនានៃខួរក្បាលមនុស្សដែរ ដោយប្រមូលផ្តុំឡើងវិញនូវសមាសភាគទាំងឡាយ (ដែលកាត់ពីគ្នាដោយសារការវិភាគ) ឱ្យបានគ្រប់គ្រាន់ត្រឹមត្រូវឡើងវិញ ។ មូលដ្ឋានសរីរៈរបស់លំនាំនៃសំយោគគឺការបិទមិនឱ្យមានទំនាក់ទំនងសរសៃប្រសាទជាបណ្ដោះអាសន្ននៅលើសំបកខួរក្បាល ។ ការវិភាគ និងការធ្វើសំយោគមានចំណងទាក់ទងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ហើយបង្កើតបានជាឯកតាមួយដែលមិនអាចផ្ដាច់ពីគ្នាបានឡើយ ។ ការវិភាគត្រូវបានគេធ្វើឡើងដោយយោលទៅតាមទំនោរនៃការធ្វើសំយោគ ហើយការធ្វើសំយោគនេះប្រព្រឹត្តទៅដោយឈរលើមូលដ្ឋាននៃលទ្ធផលរបស់ការវិភាគ ។

### ឃ. អរូបីកម្ម និងទូទៅកម្ម

អរូបីកម្មគឺជាលំនាំផ្លូវចិត្ត ដែលប្រើខួរក្បាលដើម្បីបញ្ជាក់ពីទិដ្ឋភាពលក្ខណៈចំណងទាក់ទងភាពបន្ទាប់បន្សំភាពឥតបានការដោយរក្សាទុកតែភាពចាំបាច់ក្នុងការគិតតែប៉ុណ្ណោះ ។

ទូទៅកម្មគឺជាលំនាំផ្លូវចិត្តដែលប្រើខួរក្បាលដើម្បីប្រមូលផ្តុំនូវវត្ថុ ឬបាតុភូតជាច្រើនប្រភេទខុសប្លែកគ្នា ហើយដែលមានលក្ខណៈ និងចំណងទាក់ទងដូចគ្នា ហើយដែលកំណត់ទៅតាមក្រុម ឬថ្នាក់របស់វា ។ ទូទៅកម្មនាំមកនូវអ្វីដែលគេហៅថាលក្ខណៈរួម ។

## ៦. ផលនៃការគិត

ការសិក្សាពីផលនៃការគិត គឺជាភារកិច្ចរបស់តក្កវិជ្ជា ។ ហេតុដូច្នេះហើយបានជាយើងសិក្សាដោយសង្ខេបពីផលទាំងនេះ ក្នុងឋានៈជាការបណ្ដុះបណ្ដាលផ្លូវចិត្ត ដែលបង្កើតឡើងដោយឈរលើមូលដ្ឋានរបស់លំនាំនៃការគិត ។

### ក. អំពីបញ្ញត្តិ

បញ្ញត្តិ គឺជាចំណេះដឹងដែលត្រូវធ្វើទូទៅកម្មរួចមកហើយទៅលើវត្ថុ ឬបាតុភូតមួយក្រុម ដែលមានសញ្ញាប្រភេទដូចគ្នា ។ បញ្ញត្តិ (ជាផលនៃការគិត) និងរូបតំណាង (ជាផលនៃលំនឹក) តែងតែមានការខុសប្លែកគ្នាពីមួយទៅមួយទៀត ។ ក៏ប៉ុន្តែវាមានទំនាក់ទំនងរវាងគ្នានឹងគ្នាជានិច្ច តួយ៉ាងដូចជា ៖

- បញ្ញត្តិមិនអាចកើតមានឡើយនៅក្រោមទម្រង់រូបីឥន្ទ្រីយ៍ ។ បញ្ញត្តិមានលក្ខណៈទូលំទូលាយ និងទូទៅជាងរូបតំណាង ។
- បញ្ញត្តិស្ដែងឡើងឱ្យឃើញតាមរយៈពាក្យ (Mot) ។ ក៏ប៉ុន្តែពាក្យមួយម៉ាត់អាចសម្ដែងឡើងនូវបញ្ញត្តិជាច្រើនផ្សេងគ្នា ហើយជួនកាលបញ្ញត្តិអាចស្ដែងចេញតាមរយៈពាក្យជាច្រើន ។
- បញ្ញត្តិបែបណាក៏ដោយក៏ជាផលនៃការអភិវឌ្ឍរបស់ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃប្រជាជាតិមួយ ឬមនុស្សជាតិទាំងមូល ។ បញ្ញត្តិត្រូវបានបណ្ដុះឡើងក្នុងខួររបស់មនុស្ស ដែលឈរលើមូលដ្ឋាននៃរបកគំហើញថ្មីរបស់វិទ្យាសាស្ត្រ បច្ចេកទេស និងផលិតកម្ម ។ ហេតុដូច្នេះហើយបានជាបញ្ញត្តិប្រកាន់យកនូវខ្លឹមសារដ៏កាន់តែសំបូរបែប ហើយពេញលេញផង ។

- បញ្ញត្តិនីមួយៗ ត្រូវបានបណ្តុះឡើងក្នុងខួរក្បាលរបស់មនុស្ស ដោយឈរលើមូលដ្ឋាននៃឥន្រ្ទីយារម្មណ៍ ក៏ប៉ុន្តែបញ្ញត្តិមិនមានរូបភាពឥន្រ្ទីយារម្មណ៍ទេ ។

- គ្មានព្រំដែនកំណត់ដាច់ខាតទេ រវាងរូបតំណាង និងបញ្ញត្តិ ។ ដោយប្រែក្លាយខ្លួនទៅជាមានលក្ខណៈទូទៅ រូបតំណាងចាប់ផ្តើមប្រកាន់យកនូវសញ្ញាសម្គាល់របស់បញ្ញត្តិជាស្រេចទៅហើយ ។ ហើយបន្ទាប់ពីបានក្លាយខ្លួនទៅជាបញ្ញត្តិហើយ វាក៏ប្រែក្លាយខ្លួនឯងទៅជារូបតំណាងវិញ ។

នៅពេលនោះចំណងទាក់ទងបញ្ច្រាសគ្នាទៅវិញទៅមករវាងរូបតំណាង និងបញ្ញត្តិកាន់តែស្មុគស្មាញឡើង ។ ការប្រៀបធៀប ការទូរគ្នា(Confrontation) រវាងរូបតំណាង និងបញ្ញត្តិកាន់តែធ្វើឱ្យយើងយល់បានថា ព្រឹត្តិការណ៍តែមួយតែងតែមិនមានភាពដូចគ្នាបេះបិទទៅនឹងទស្សនៈទូទៅឡើយ ។

ឧទាហរណ៍៖ សញ្ញាណនៃពាក្យថា «មនុស្ស» ជានិច្ចកាលវាតែងតែមានលក្ខណៈទូលំទូលាយជាងរូបតំណាងរបស់ស្ត្រីម្នាក់ ឬបុរសម្នាក់ណាដែលមានលក្ខណៈជាក់ស្តែង ។ នេះគឺជាបញ្ហាមួយដែលយើងត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបណ្តុះបាននូវបញ្ញត្តិក្នុងខួរក្បាលរបស់សិស្ស ជាពិសេសគឺសិស្សនៅកម្រិតបឋមសិក្សា ។

**ខ. ការវិនិច្ឆ័យ៖** ការវិនិច្ឆ័យគឺជាលំនាំដែលទាញចេញពីការផ្គុំនៃបញ្ញត្តិពីរ ឬច្រើនក្នុងការបញ្ជាក់ពីគុណភាព ឬតម្លៃវត្ថុ ឬបាតុភូតអ្វីមួយ ។

ឧទាហរណ៍ ៖ - ក្តារខៀននេះល្អ ស្រួលសរសេរ ។
- ចិត្តវិទ្យា ជាវិទ្យាសាស្ត្រមួយ ។

**គ. វិចារ ៖** វិចារគឺជាការវិនិច្ឆ័យមួយទាញចេញពីការវិនិច្ឆ័យផ្សេងៗទៀត ។ វាជាដំណាក់កាលនៃការកកើតមាននូវទស្សនវិជ្ជា។

ឧទាហរណ៍ ៖ ជរា ព្យាធិ មរណៈ
- មនុស្សទាំងអស់សុទ្ធតែស្លាប់
- សុក្រាតជាមនុស្ស
- សុក្រាតត្រូវតែស្លាប់ ។

## ៧. ចរិតបុគ្គលក្នុងគម្រោងនៃការគិត

ចរិតបុគ្គលរបស់មនុស្សម្នាក់ៗក្នុងគម្រោងនៃការគិតស្តែងឡើងឱ្យឃើញតាមរយៈភាពខុសប្លែកគ្នា ការផ្គួបផ្សំគ្នារវាងប្រភេទនៃការគិតក្នុងខ្លួនគេ ។ ចរិតបុគ្គលនៃការគិតនេះ ស្តែងចេញឱ្យឃើញនៅក្នុងគុណសម្បត្តិនៃសកម្មភាពញាណសក្តិ(Qualités des activités cognitives = គុណភាពសកម្មភាពនៃការគិត) របស់មនុស្សម្នាក់ៗ ឧទាហរណ៍៖ គ្រូដាក់បង្ហាញឱ្យសិស្សកម្រិតខ្ពស់ ឱ្យសិស្សចេះ អភិវឌ្ឍជំនាញគិតកម្រិតខ្ពស់ យល់ហេតុផល មានដំណោះស្រាយត្រឹមត្រូវ។ សកម្មភាពនៃចំណេះដឹងរបស់មនុស្សម្នាក់ៗ មានគុណសម្បត្តិដូចតទៅ៖

### ៧.១. ស្មារតីម្ចាស់ការក្នុងការគិត

ភាពប៉ិនប្រសប់ក្នុងការដោះស្រាយបញ្ហាដោយខ្លួនផ្ទាល់ ការរកឃើញ និងការកំណត់បាននូវបញ្ហាថ្មីគឺជាស្មារតីច្នៃប្រឌិតនៃការសម្តែងចេញ ឱ្យឃើញយ៉ាងច្បាស់លាស់នៅក្នុងស្មារតីម្ចាស់ការក្នុងការគិត។

### ៧.២. ភាពទន់ភ្លន់នៃការគិត

ប្រការនេះ អាស្រ័យនៅនឹងការប្រតិបត្តិ ដែលចេះសម្របសម្រួលទៅតាមសភាពជាក់ស្តែង ហើយការគិតត្រូវសមស្របតាមកិច្ចការនោះ ។

### ៧.៣. ភាពរហ័សរហួននៃការគិត

គឺជាភាពប៉ិនប្រសប់ និងស្ទាត់ជំនាញក្នុងការដោះស្រាយបញ្ហាដែលទទួលបានសម្រេចក្នុងរយៈពេលសមរម្យ ។

### ៧.៤. ភាពទូលំទូលាយនៃការគិត

គឺអាស្រ័យទៅនឹងចំណេះដឹងទូទៅដែលបុគ្គលម្នាក់ៗមាន ហើយភាពទូលំទូលាយនេះសម្តែងចេញឱ្យឃើញចំពោះចរិតដ៏ពេញលេញ និងការច្នៃប្រឌិតនៅក្នុងវិធីសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងការអនុវត្ត។

### ៧.៥. ជម្រៅនៃ ការគិត

ប្រការនេះ អាស្រ័យនៅនឹងសមត្ថភាពរបស់បុគ្គលម្នាក់ៗ ដែលស៊ីជម្រៅលើធម្មជាតិនៃបញ្ហា ។

### ៧.៦. ស្មារតីទិតៀននៃការគិត

គឺជាការវាយតម្លៃ ដោយសត្យានុម័តទៅលើការគិតរបស់បុគ្គលម្នាក់ៗ និងការគិតរបស់អ្នកដទៃដោយបកស្រាយបំភ្លឺឱ្យបានជាក់ច្បាស់ និងមានអំណះអំណាងត្រឹមត្រូវ ហើយទាញសេចក្តីសន្និដ្ឋានទៅតាមគំនិតជឿនលឿន ។

## IV- សន្និដ្ឋាន

គុណសម្បត្តិនៃការគិត អាស្រ័យដោយផ្ទាល់ទៅនឹងដំណើរអភិវឌ្ឍន៍ជាទូទៅនៃ បុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់ៗ បទពិសោធផ្ទាល់ខ្លួន ចរិតអប់រំ និងការអភិវឌ្ឍនៃឆន្ទៈរបស់មនុស្សម្នាក់ៗ។ ហេតុដូច្នេះ ការអប់រំបញ្ញាជាផ្នែកមួយដ៏សំខាន់នៅក្នុងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់សិស្ស ។

ដូច្នេះ គ្រូបង្រៀនត្រូវប្រើវិធីសាស្ត្រយ៉ាងណា ដើម្បីពង្រឹងសមត្ថភាពនៃការគិតរបស់សិស្សនៅក្នុងការអប់រំ ការបង្រៀន និងរៀន ដូចជាបង្ហាត់សិស្សឱ្យធ្វើសកម្មភាពនៃការគិតបង្កើតបញ្ញត្តិដោយខ្លួនឯង បណ្តុះគំនិតលើការ វិនិច្ឆ័យ និងប្រើប្រាស់ការត្រិះរិះរបស់សិស្ស ដោយត្រូវពង្រីកគ្រប់គុណភាពនៃការគិត ។

### សំណួរ

១. តើការគិតជាអ្វី?

២. ចូរបង្ហាញឱ្យឃើញថា ការគិតជាចំណាំងប្រយោលដោយលើកឧទាហរណ៍មកបញ្ជាក់។

៣. ចូរនិយាយពីការគិតរូបីតាមដៃ ដោយលើកឧទាហរណ៍មកបញ្ជាក់។

៤. តើការគិតអរូបីជួយយើងឱ្យមានសមត្ថភាពអ្វីខ្លះ?

៥. តើគ្រូបង្រៀនត្រូវធ្វើដូចម្តេចដើម្បីបណ្តុះបំណិនគិតដល់សិស្ស?

# មេរៀនទី៨ រូបារម្មណ៍

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់បានពីសញ្ញាណនៃរូបារម្មណ៍
- ពន្យល់ពីមូលដ្ឋានសរីរៈ និងតួនាទីរបស់រូបារម្មណ៍
- មានទម្លាប់កសាងរូបភាពថ្មីដោយប្រើរូបារម្មណ៍ ។

## II- សេចក្ដីផ្ដើម

គ្រប់សកម្មភាព មនុស្សតែងតែនឹកគិតជាមុន ពីគោលដៅ របៀបដោះស្រាយ និងអាចធ្វើការប្រមើលមើលពីលទ្ធផលដែលនឹងអាចឱ្យគេទទួលបានផងដែរ ។ ក៏ប៉ុន្តែក្នុងករណីជាច្រើនទៀតនៅចំពោះមុខស្ថានភាពបញ្ហា មនុស្សមិនចេះតែអាចមានសមត្ថភាពដោះស្រាយបានទាំងអស់នោះទេ មនុស្សត្រូវពឹងផ្អែកលើលំនាំថ្មីមួយទៀតនៃចំណេះដឹងដែលមានកម្រិតខ្ពស់គឺ **រូបារម្មណ៍** ។

## III- ខ្លឹមសារ

### ១. និយមន័យ

រូបារម្មណ៍ ជាលំនាំចិត្តដែលឆ្លុះបញ្ចាំងវត្ថុទាំងឡាយដែលពុំទាន់កើតមាននៅឡើយ នៅក្នុងបទពិសោធរបស់បុគ្គល និងមិនទាន់កើតមាននៅក្នុងតថភាព។ លំនាំនេះប្រព្រឹត្តទៅដោយបង្កើតរូបភាពថ្មី ហើយចាប់ផ្ដើមពីរូបតំណាងចាស់ៗ ដែលបានមកពីឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍។

ឧទាហរណ៍៖ អាទិទេព "ព្រះគណេស" ដែលមានក្បាលជាដំរី ដងខ្លួនជាមនុស្ស ។ រូបសំណាកនេះកើតមានពីរូបារម្មណ៍របស់មនុស្ស។

រូបតំណាងទាំងនោះ ក៏មានមូលដ្ឋានបង្អែកដែលបានពីការគិតដែរ បានន័យថា រូបារម្មណ៍ត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ និងការគិត ។ រូបារម្មណ៍ជាលំនាំចិត្ត ដែលផ្សារភ្ជាប់ពុទ្ធិឥន្ទ្រីយ៍ទៅពុទ្ធិវិចារ ។

ប្រត្យក្សារម្មណ៍ផ្ដល់ឱ្យយើងនូវរូបភាពនាពេលបច្ចុប្បន្ន ។ លំនឹកនាំមកនូវរូបភាព ដែលកើតមានកន្លងរួចមកហើយក្នុងអតីតកាល ឯរូបារម្មណ៍វិញផ្ដល់ឱ្យយើងនូវរូបភាពសម្រាប់អនាគត ។ ដូច្នេះ រូបារម្មណ៍ក៏ដូចជាការគិតដែរ ព្រោះវាកើតឡើងតែក្នុងពេលណា ដែលមនុស្សបានជួបប្រទះនូវស្ថានភាពបញ្ហាក្នុងជីវភាពរស់នៅ ។

គេអាចនិយាយម្យ៉ាងទៀតថា រូបារម្មណ៍ជាលក្ខខណ្ឌនៃការច្នៃប្រឌិតរបស់មនុស្ស ។ ប៉ុន្តែគ្រប់រូបភាពរបស់រូបារម្មណ៍មានប្រភពមកពីតថភាព។ ចំពោះក្មេងក៏សម្បូររូបារម្មណ៍ និងរូបតំណាងច្នៃប្រឌិតដែរ ។ នៅក្នុងដំណាក់កាលអាយុបុរេសិក្សា ក្មេងចាប់ផ្ដើមមានរូបារម្មណ៍សំខាន់ៗ ។

### ២. ចំណែកថ្នាក់ នៃរូបារម្មណ៍

គេអាចធ្វើចំណែកថ្នាក់រូបារម្មណ៍ជា២ប្រភេទដូចតទៅ ៖

#### ២.១. រូបារម្មណ៍ គិតទុកជាមុន

រូបារម្មណ៍នេះសំដៅទៅរកគោលដៅមួយជាក់លាក់ប្រកបដោយផែនការ និងវិធីសាស្ត្រច្បាស់លាស់ ។ គេតែងតែប្រើរូបារម្មណ៍នេះក្នុងការបង្រៀន ការអប់រំសិស្ស និងក្នុងការងារពលកម្ម ។

ឧទាហរណ៍៖ ពេលបង្រៀនអក្សរសាស្ត្ររឿងទុំទាវ គ្រូត្រូវធ្វើឱ្យសិស្សចេះនឹកគិតដល់របបសង្គម សេដ្ឋកិច្ច និងជីវភាពរបស់មនុស្សជំនាន់សម័យលង្វែក ។

ឧទាហរណ៍ ៖ មុននឹងចេញដំណើរពីទ្វីបអឺរ៉ុបទៅប្រទេសឥណ្ឌា តាមទិសខាងលិច លោកគ្រីស្តូបកូឡុម (Christophe Colomb) គាត់នឹកគិតថា បើផែនដីមានរាងមូល ការធ្វើដំណើរតាមទិសខាងលិចនេះ គាត់បានវិលចូលទៅទ្វីបអឺរ៉ុបវិញ។

### ក. រូបារម្មណ៍បង្កើតឡើងវិញ

គឺជាលំនាំបង្កើតរូបភាពថ្មី ដោយផ្អែកលើបទពិសោធ និងផ្អែកលើកត្តាដែលបានមកពីប្រត្យក្សារម្មណ៍។ ការកសាងរូបភាពថ្មីមានគោលដៅ និងបណ្តុះពុទ្ធិចំពោះវត្ថុ ឬបាតុភូតតាមរយៈការរ៉ាយរ៉ាប់របស់អ្នកដទៃ ។

ឧទាហរណ៍៖ ស្តាប់គ្រូរ៉ាយរ៉ាប់ពីវាលលំហខ្សាច់ ភ្នំភ្លើង សមុទ្រទឹកកក... សិស្សអាចនឹកគិតដល់វាលលំហ ភ្នំភ្លើង សមុទ្រទឹកកកនោះ ។

ឧទាហរណ៍៖ ស្តាប់ការនិទានរឿងរបស់សិស្សម្នាក់ យើងអាចនឹកគិតដល់សកម្មភាពរបស់តួអង្គ ជួនកាលអាចធ្វើឱ្យយើងស្រក់ទឹកភ្នែក។

### ខ. រូបារម្មណ៍ច្នៃប្រឌិត

រូបារម្មណ៍នេះបង្កើតដោយរូបភាពតំណាងថ្មីៗ សម្រាប់វត្ថុដែលមិនទាន់មាននៅឡើយ ។ រូបភាពនៃរូបារម្មណ៍ច្នៃប្រឌិតជារូបភាពដែលមិនទាន់មានក្នុងតថភាព ។

ឧទាហរណ៍៖ តាំងពីយូរមកហើយ មនុស្សបាននឹកស្រមៃទៅដល់ការហោះហើរក្នុងលំហអាកាស ។

ឧទាហរណ៍៖ នៅសតវត្សទី១៨ មិនទាន់មាននាវាមុជទឹកនៅឡើយទេ ។ ប៉ុន្តែលោកស៊ុលវ៉ែន បាននឹកស្រមៃទៅដល់នាវាមុជទឹកនេះ។

## ២.២. រូបារម្មណ៍មិនគិតទុកមុន

រូបារម្មណ៍នេះកើតដោយចៃដន្យ ដោយឈរលើមូលដ្ឋានប្រត្យក្សារម្មណ៍ណាមួយ។ ក្នុងជីវភាពរស់នៅមនុស្សតែងតែជួបប្រទះនឹងរូបារម្មណ៍មិនគិតទុកមុនជានិច្ច ។

ឧទាហរណ៍៖ ពេលមើលឃើញដុំពពកនៅលើមេឃ យើងអាចគិតនឹកគិតទៅដល់រូបភាពរបស់មនុស្សម្នាក់ ឬរូបភាពនៃវិមានមួយ ឬរូបសត្វសេះ ឬរូបដំរី ។

ឧទាហរណ៍៖ ក្នុងរង្វង់ព្រះច័ន្ទពេញបូណ៌មី ជួនកាលអ្នកខ្លះមើលឃើញរូបដើមពោធិ៍ អ្នកខ្លះមើលឃើញសត្វទន្សាយ។

ឧទាហរណ៍៖ ពេលយប់ស្ងាត់យើងស្តាប់ឮសំឡេងចម្លែកមួយដូចជា ស្នូរកាំភ្លើង យើងនឹកគិតថា ប្រហែលជាគេបាញ់ចាប់ចោរ ឬក៏មានឧក្រិដ្ឋជនណាម្នាក់ប្លន់អ្នកដំណើរ ។

ឧទាហរណ៍៖ ក្លិនឈ្ងុយដែលភាយចេញពីផ្ទះបាយ នាំឱ្យយើងនឹកគិតដល់ឈ្មោះសម្លដែលធ្លាប់បរិភោគ ។

## ៣. តួនាទីរបស់រូបារម្មណ៍

រូបារម្មណ៍មាននាទីសំខាន់ណាស់ក្នុងសកម្មភាពប្រតិបត្តិ និងទ្រឹស្តីរបស់មនុស្សដោយសាររូបារម្មណ៍មនុស្សអាចបង្កើតឧបករណ៍ថ្មីៗ និងទម្រង់ចាត់តាំងការងារថ្មីៗ ។ រូបារម្មណ៍មានសារៈសំខាន់ណាស់ក្នុងវិទ្យាសាស្ត្របច្ចេក-ទេស និងសិល្បៈ ។ មនុស្សដែលគ្មានរូបារម្មណ៍ មានសមត្ថភាពត្រឹមតែប្រមូលហេតុការណ៍ផ្សេងៗ ដែលកើតមានរួចមកហើយ តែគេមិនអាចរាវរក និងបង្កើតអ្វីដែលថ្មីបានទេ ។

រូបារម្មណ៍មាននាទីសំខាន់ណាស់ក្នុងទ្រឹស្តី និងក្នុងគ្រប់សកម្មភាពប្រតិបត្តិរបស់មនុស្ស ដូចជា សារៈសំខាន់ចាំបាច់ក្នុងការបង្កើតឧបករណ៍ពលកម្មថ្មីៗ ចាំបាច់ក្នុងវិស័យវិទ្យាសាស្ត្របច្ចេកទេស និងសិល្បៈ(តែងនិពន្ធ)។

ឧទាហរណ៍៖ មធ្យោបាយដឹកជញ្ជូនមនុស្សត្រូវការធ្វើដំណើរឱ្យបានឆាប់រហ័ស។ ការបង្កើតចាប់ពីទោចក្រយាន្ត រថយន្ត កប៉ាល់ទឹក រហូតដល់មានយន្តហោះ ដែលគេអាចធ្វើដំណើរក្នុងចម្ងាយរាប់ពាន់គីឡូម៉ែតក្នុងមួយថ្ងៃ ។

នៅមានឧបករណ៍វិទ្យាសាស្ត្រជាច្រើនទៀត ដែលកើតចេញមកពីរូបារម្មណ៍របស់មនុស្ស និងកំពុងតែមាននាទីយ៉ាងសំខាន់ក្នុងការបម្រើសេវារបស់មនុស្ស ។

### ៤. វិធីកសាងរូបភាពថ្មី នៅក្នុងរូបារម្មណ៍ (Méthodes d'édifier l'image nouvelle dans l'imagination)

រូបភាពថ្មីរបស់រូបារម្មណ៍ ត្រូវបានបង្កើតឡើងទៅតាមបែបបទជាច្រើនផ្សេងគ្នា ដូចជា៖

#### ៤.១-វិធីផ្លាស់ ប្តូរវិមាត្រ និងចំនួននៃផ្នែក ជាសមាសធាតុរបស់វត្ថុ (Méthode de changer les dimentions et le nombre parties composantes de l'objet )

ក្នុងករណីនេះ គេឃើញមានដូចជា៖ រូបភាពរបស់យក្ស (L'image des géant ) រូបសំណាករបស់ព្រះពុទ្ធដែលមានដៃច្រើន...។ ញញួរសម្រាប់វាយសំពង ជាញញួរធំហើយវាមិនមានរូបភាពដូចញញួរធម្មតាទេព្រោះវិមាត្ររបស់វាខុសប្លែកគ្នាពីញញួរធម្មតាច្រើនណាស់។

#### ៤.២-វិធីធ្វើ ឱ្យមាន តម្លៃជាក់ស្តែង (Méthode de mettre en relief )

គឺជាបែបបទបង្កើតឱ្យមានរូបភាពថ្មី ដោយកំណត់យកតែផ្នែកដោយឡែកនៃគុណភាព ទំនាក់ទំនងណាមួយរបស់វត្ថុ ឬបាតុភូតជាមួយនឹងវត្ថុ ឬបាតុភូតផ្សេងទៀតដោយយករូបភាពថ្មីរបស់វត្ថុ ឬបាតុភូតដែលទើបបង្កើតបាននោះ មកដាក់ក្នុងចំណាត់ថ្នាក់ទី១ វិញ។ វិធីមួយផ្សេងទៀតដែលគេប្រើប្រាស់ក្នុងករណីនេះ គឺវិធីបំផ្លើស។

#### ៤.៣-វិធីផ្គុំ ផ្នែក ផ្សេង ៗបញ្ចូលគ្នា (Méthode d'agglutination )

គឺជាវិធីបណ្តុះផ្នែកសមាសភាគជាច្រើនរបស់វត្ថុផ្សេងគ្នា ដោយបង្កើតបានតែរូបភាពថ្មីតែមួយ ។

ឧទាហរណ៍៖ រូបភាពម៉ុងសាយចិន។ រូបភាពរបស់ព្រះសិវៈ មានក្បាលជាដំរី និងខ្លួនជាមនុស្ស ។

រូបភាពសត្វស្ទាំង មានក្បាលជាមនុស្ស ខ្លួនជាសត្វតោ ។

រូបភាពថ្មីនៃរូបារម្មណ៍នេះមានផ្នែកផ្សេងៗដែលជាសមាសធាតុផ្គុំបញ្ចូលគ្នានេះឥតមានបាត់ ឬផ្លាស់ឡើយ។

#### ៤.៤-វិធីលាយ ចម្រុះ គ្នា (Méthode de combinaison )

គ្រាន់តែក្រឡេកឃើញភ្លាមយើងដឹងថា វិធីនេះមានភាពស្រដៀងគ្នាបន្តិចបន្តួច ទៅនឹងវិធីផ្គុំផ្នែកផ្សេងៗបញ្ចូលគ្នា។ ក៏ប៉ុន្តែរូបភាពនេះមិនមែនជាបណ្តុំដ៏សាមញ្ញ ឬការចាប់ផ្គុំយកទៅតាមធាតុដើមរបស់វាឡើយ។ ដោយដាក់បញ្ចូលគ្នាឱ្យបានរូបភាពថ្មីមួយនោះ ធាតុដើមត្រូវផ្លាស់ប្តូរទ្រង់ទ្រាយទាំងអស់។ កាលណាផ្លាស់ប្តូររួច ធាតុទាំងនោះមានទំនាក់ទំនងថ្មីមួយ ។ ការលាយចម្រុះគ្នាគឺជាការធ្វើសំយោគតាមរបៀបច្នៃប្រឌិត ( Synthèse créatrice ) ហើយនេះក៏មិនមែនជាការដាក់បន្ថែមយ៉ាងសាមញ្ញទៅលើធាតុដែលគេស្គាល់មកហើយនោះទេ ។

វិធីនេះត្រូវបានគេយកទៅប្រើប្រាស់យ៉ាង ទូលំទូលាយនៅក្នុងវិស័យបច្ចេកទេស វិទ្យាសាស្ត្រ អក្សរសិល្ប៍ និងសិល្បៈ ។

#### ៤.៥-វិធីគំរូកម្ម (Méthode de typisation )

នេះគឺជាវិធីបណ្តុះបណ្តាលរូបភាពថ្មី ដែលមានលក្ខណៈស្មុគស្មាញបំផុត ដែលក្នុងរូបភាពនេះមានលក្ខណៈគំរូ(Propriétés typiques ) ចរិតលក្ខណៈរបស់បុគ្គលិកលក្ខណៈដែលជាតំណាងរបស់ស្រទាប់សង្គមមួយជាក់លាក់។

វិធីនេះត្រូវបានគេយកមកប្រើប្រាស់នៅក្នុងសកម្មភាពបង្កើតស្នាដៃអក្សរសិល្ប៍ (Création des oeuvres littéraires ) ស្នាដៃ សិល្បៈ(Oeuvre artisques ) និងក្នុងសិល្បៈចម្លាក់ (Sculpture )។

ធាតុនៃចម្លាក់ដែលគេប្រើសម្រាប់ដាក់លើក្លោងទ្វារ (Chef de voûte ) តាមបែបគំរូកម្មនោះ

គឺជាសំយោគច្នៃប្រឌិត(Création créatrice ) និងទូទៅកម្មទៅលើលក្ខណៈ ផ្សេងៗដូចជាលក្ខណៈដោយឡែក និងគំរូរបស់បុគ្គលិកលក្ខណៈ។

#### ៤.៦-វិធីសទិសភាព (Méthode d'analogie)

កាលពីសម័យសង្គមបុព្វកាលរបស់មនុស្សជាតិ បុព្វបុរសយើងចេះបង្កើតឧបករណ៍ដ៏សាមញ្ញបំផុតរួចមក

ហើយទៅតាមសទិសនៃការធ្វើដោយដៃ ។ ឧបករណ៍ទាំងនេះ ជាឧបករណ៍ការងារដែលគេផលិតសម្រាប់ប្រើប្រាស់ ។ មុននឹងផលិតបាននូវឧបករណ៍ការងារទាំងនោះមនុស្សបានរកឃើញសទិសភាពនៅក្នុងខួរក្បាលរបស់គេ។ ដោយសារតែសទិសភាពនេះហើយទើបឧបករណ៍នៃការងារត្រូវបានគេធ្វើឡើងដោយគ្រាប់តាមទំនងនៃចលនាដៃរបស់មនុស្សដែលកាន់ឧបករណ៍នោះ ។ សព្វថ្ងៃនេះការយល់ដឹងពីទំនាក់ទំនងរវាងជីវសាស្ត្រ និងអេឡិចត្រូនិក( Bionique = Qui concer-ne la biologie et l'électronique ) គឺជាការអភិវឌ្ឍក្នុងកម្រិតខ្ពស់បំផុតរបស់វិធីសទិសនៅក្នុងលំនាំនៃរបកគំហើញរបស់អ្នកវិទ្យាសាស្ត្រ ។

## ៥. ទំនាក់ទំនងរូបារម្មណ៍ និង ការគិត

៥.១. រូបារម្មណ៍ដូចគ្នានឹងការគិតដែរ គឺជួយយើងឱ្យគ្រោងទុកមុនសម្រាប់ពេលអនាគត ។ ការគិត និងរូបារម្មណ៍ បានជួយយើងឱ្យប្រមើលទុកមុន នូវលទ្ធផលនៃសកម្មភាពរបស់យើង និងជួយកែតម្រូវសកម្មភាពដែលយើងបម្រុងនឹងធ្វើ ដើម្បីឆ្លើយតបនឹងមជ្ឈដ្ឋានដែលផ្លាស់ប្តូរឥតឈប់ឈរ ។

ឧទាហរណ៍ ៖ ការប្រៀបប្រដូច ការធ្វើសំបុករបស់ឃ្មុំទៅនឹងស្ថាបត្យករ ឬសត្វពីងពាងទៅនឹងជាងតម្បាញ ។

៥.២. កាលណាយើងស្ថិតក្នុងស្ថានភាពបញ្ហា ដែលឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ និងការគិត គ្មានសមត្ថភាពដោះស្រាយបញ្ហានោះ រូបារម្មណ៍ក៏បានចូលមកជំនួស ។

ឧទាហរណ៍៖ ពេលភ្លៀងកំពុងធ្លាក់ មានរន្ទះខ្លាំង( បាតុភូតរន្ទះ ) នៅពេលដែលវិទ្យាសាស្ត្រមិនទាន់រីកចម្រើន ការគិតក៏ពុំអាចដោះស្រាយបាន ពីបាតុភូតនេះ រូបារម្មណ៍ក៏បានចូលមកជំនួស ដោយដោះស្រាយថារន្ទះកើតឡើងដោយសារ**រាមាសូរ** ចោលពូថៅទៅលើនាង**មេខលា** ដែលកាន់កែវមុនីនៅដៃ ។

៥.៣. កាលណាមជ្ឈដ្ឋានសង្គមមានបម្រាប់គ្រប់គ្រាន់ គេប្រើការគិតដើម្បីដោះស្រាយ។ ប៉ុន្តែ បើកាលណាក្នុងមជ្ឈដ្ឋាននោះមិនទាន់មានបម្រាប់ច្បាស់លាស់ គេប្រើរូបារម្មណ៍ដើម្បីដោះស្រាយ ។

ឧទាហរណ៍៖ ក្នុងរឿងព្រេង មានតួអង្គយក្ស ។

## ៦. ការស្រមៃ

ការស្រមៃ គឺជាលំនាំចិត្តដែលមានភាពស្រដៀងគ្នានឹងរូបារម្មណ៍ច្នៃប្រឌិត គ្រាន់តែការស្រមៃស្ថិតនៅលើបំណងប្រាថ្នា ចំណង់របស់មនុស្សនៅពេលអនាគត ។ ការស្រមៃអាចក្លាយជាការពិត ក្នុងករណីខ្លះដែលស្មារតី ឆន្ទៈ និងគំនិតធ្វើសកម្មភាពព្រមគ្នា។ ការស្រមៃ បានផ្តល់ឱ្យយើងនូវគុណសម្បត្តិ និងគុណវិបត្តិ។ ការស្រមៃផ្តល់នូវគុណសម្បត្តិ គឺការស្រមៃដែលចេះប៉ាន់ប្រមាណបានសមរម្យតាមសភាពការណ៍ និងសកម្មភាព ។

## ៧. ឧត្តមគតិ

ឧត្តមគតិជារូបភាពដ៏ខ្ពស់បំផុត ដែលជាទម្រង់របស់ការស្រមៃដែរ តែវាបានសណ្ឋិតនៅជាប់យូរណាស់ក្នុងខួរក្បាលរបស់មនុស្ស ។ ដូចនេះយើងអាចនិយាយបានថា ឧត្តមគតិជាកម្រិតខ្ពស់បំផុតរបស់រូបារម្មណ៍ ។

ឧទាហរណ៍៖ ឧត្តមគតិរបស់ប្រជាជនកម្ពុជា គឺចង់កសាងប្រព័ន្ធលទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅក្នុងសង្គមកម្ពុជា។

# IV- សន្និដ្ឋាន

រូបារម្មណ៍មានសារៈសំខាន់ក្នុងការបង្រៀន និងអប់រំ ។ គ្រូបង្រៀនត្រូវប្រើពាក្យសម្តីដែលសំបូរទៅដោយរូបារម្មណ៍ ដើម្បីទាក់ទាញបម្រុងប្រយ័ត្នសិស្ស និងទំនោរចិត្តក្នុងម៉ោងសិក្សា ។ ម្យ៉ាងទៀត គ្រូបង្រៀនត្រូវបណ្តុះរូបារម្មណ៍ អភិវឌ្ឍដល់សិស្ស ដើម្បីពង្រីក និងបង្កើតរូបារម្មណ៍ព្រមទាំងគំនិតច្នៃប្រឌិតដល់សិស្សឱ្យបានច្រើន ។

## សំណួរ

១. ចូរឱ្យនិយមន័យរូបារម្មណ៍ ។
២. ចូរប្រៀបធៀបរូបារម្មណ៍គិតទុកមុន និងរូបារម្មណ៍មិនគិតទុកមុន ។
៣. តើរូបារម្មណ៍ និងការគិតមានទំនាក់ទំនងនឹងគ្នាយ៉ាងណាដែរ ?
៤. តើរូបារម្មណ៍មានសារៈប្រយោជន៍យ៉ាងណាខ្លះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ?

## មេរៀនទី៩ ភាសា

### I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីភាសាជាតិ ភាសាបុគ្គល ភាសាក្នុង និងភាសាក្រៅ
- កំណត់បានច្បាស់ពីតួនាទីនៃភាសា និងពង្រីកភាសាបានល្អ ពិសេសភាសាក្នុង
- យកចិត្តទុកដាក់ដល់ការប្រើភាសារបស់សិស្សទាំងក្នុង និងក្រៅម៉ោងសិក្សា ។

### II- សេចក្តីផ្តើម

ដោយសារការងារពលកម្ម ភាសាជាលក្ខណៈពិសេសជាមូលដ្ឋានគ្រឹះមួយ ដែលញែកមនុស្សឱ្យដាច់ស្រឡះអំពីសត្វ ក្នុងការធ្វើទំនាក់ទំនងរវាងមនុស្សក្នុងសង្គម ។

ភាសាជាប្រព័ន្ធកម្ម(ការបូកផ្សំរវាងប្រព័ន្ធសញ្ញាច្រើនទើបកើតជាភាសា) និងជាការរៀបចំតាមគោលបំណងនៃសញ្ញា។

### III- ខ្លឹមសារ

#### ១. និយមន័យ

**ភាសាជាតិ** គឺជាប្រព័ន្ធនៃសញ្ញា ដែលសម្តែងចេញជាពាក្យ ។ ក្នុងនោះរួមមាន ៖

- សូរវិទ្យា(កុមារ គុហារ... កុ ខ្យល់អឃោសៈ គុ ខ្យល់ឃោសៈ)
- វេយ្យាករណ៍(គោមួយ នាមនៅពីមុខគុណនាម ONE COW គុណនាមនៅពីមុខនាម)
- គ្រឹះសទ្ទានុក្រម (ពាក្យបច្ចេកទេស ដោយផ្អែកលើវេយ្យាករណ៍ )
- ល្បិចតែងនិពន្ធ (បទកាកគតិ ពំនោល...)

ភាសាវិវត្តទៅតាមពេលវេលា ទៅតាមព្រឹត្តិការណ៍សង្គម និងតាមលក្ខណៈចិត្តនៃជាតិសាសន៍នីមួយៗ ។

ឧទាហរណ៍៖ ជនជាតិខ្មែរមានភាសាជាតិរបស់ខ្លួនគឺភាសាខ្មែរ ជនជាតិអង់គ្លេសមានភាសាជាតិរបស់ខ្លួន គឺភាសាអង់គ្លេស ជនជាតិទំពួន ដែលរស់នៅតំបន់ភាគឦសាននៃប្រទេសកម្ពុជាមានភាសាក្រុមជនជាតិរបស់ខ្លួនគឺភាសាទំពួន។

**ភាសាបុគ្គល** គឺជាភាសាដែលបុគ្គលម្នាក់ៗប្រើសម្រាប់ធ្វើទំនាក់ទំនង នៅក្នុងជីវភាពរស់នៅ និងធ្វើសកម្មភាពទំនាក់ទំនងក្នុងសង្គមជាមួយអ្នកដទៃ ។ ភាសាបុគ្គល គឺជាភាសាប្រើប្រាស់ផ្ទាល់នៃបុគ្គលម្នាក់ៗ ដោយយកភាសាជាតិជាមធ្យោបាយ ។

ឧទាហរណ៍ ៖ ភាសានិយាយរបស់អ្នកសៀមរាប ខុសពីភាសានិយាយរបស់អ្នកបាត់ដំបង ហើយក៏ខុសពីអ្នកភ្នំពេញ ឬអ្នកតាកែវដែរ ។

រួមសេចក្តីមក ភាសាគឺជាមធ្យោបាយសម្រាប់ទាក់ទងរបស់មនុស្សក្នុងសង្គម ជាឧបករណ៍នៃសកម្មភាពបញ្ញារបស់មនុស្ស ។ តាមរយៈភាសាគេអាចបង្ហាញសកម្មភាពផ្លូវចិត្ត និងជាលំនាំមួយដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលំនាំនៃចំណេះដឹង ពិសេសទៅនឹង**ការគិត** ។

ជាទូទៅ ជនជាតិនីមួយៗទោះបីជាជនជាតិភាគតិចក៏ដោយ សុទ្ធតែមានភាសារបស់ខ្លួន ដែលក្នុងនោះរួមមានប្រព័ន្ធសូរវិទ្យា គ្រឹះសទ្ទានុក្រម វេយ្យាករណ៍ និងបែបបទផ្សេងៗទៀតដូចជា ខាងវោហា សាស្ត្រជាដើម ។ ភាសាមានការវិវត្តទៅតាមពេលវេលា ព្រឹត្តិការណ៍សង្គម ទស្សនៈរបស់ជនជាតិនីមួយៗនិងជាបេតិកភណ្ឌផ្នែកស្មារតី សម្រាប់ជនជាតិនីមួយៗ ។ លក្ខណៈពិសេសមួយទៀតដែលគួរឱ្យយើងចាប់អារម្មណ៍ផងដែរនោះ គឺវិវត្តនៃភាសា និងការខ្ចីភាសា

គេយកមកប្រើច្រើនហួសប្រមាណ ដោយគ្មានមូលដ្ឋានច្បាស់លាស់ គឺជាលទ្ធផលអាក្រក់នៃការបាត់បង់អត្តសញ្ញាណរបស់ជាតិមួយ ។

### ២. ភាពខុសគ្នារវាងភាសាជាតិ និង ភាសាបុគ្គល

ភាសាជាតិ និងភាសាបុគ្គល ជាបាតុភូតប្រវត្តិសាស្ត្រដែលកើតមានឡើងក្នុងការងារពលកម្ម ក្នុងសកម្មភាពផ្សេងៗរបស់មនុស្ស និងក្នុងទំនាក់ទំនងផ្នែកស្មារតី។ តែភាសាជាតិ និងភាសាបុគ្គលមានលក្ខណៈខុសគ្នាខ្លះដូចជា៖

- ភាសាជាតិនីមួយៗមានភាសាផ្ទាល់របស់ខ្លួន ដែលមានប្រព័ន្ធសូរវិទ្យាមួយ គ្រឹះសន្ទានុក្រម វេយ្យាករណ៍ និងល្បិចផ្សេងៗនៃវោហាសាស្ត្រ។
- ភាសាជាតិមួយជាបេតិកភណ្ឌខាងស្មារតីរបស់ប្រជាជាតិនោះ។
- មនុស្សម្នាក់ប្រើភាសាជាតិរបស់ខ្លួន សម្រាប់សម្តែងការគិត និងសញ្ចេតនារបស់ខ្លួន និងប្រើសម្រាប់ការយល់ ដឹង ពីការគិត និងសញ្ចេតនាអ្នកដទៃទៀតផង។
- ចូលដល់វ័យសិក្សានៅមធ្យមសិក្សា សិស្សមានចំណេះដឹងខាងវិទ្យាសាស្ត្រ គេចេះពាក្យថ្មីច្រើន ចេះរបៀបតែងឃ្លា ចេះភាសានិយាយធម្មតា និងភាសាអក្សរសិល្ប៍ទៀតផង ។
- ចិត្តវិទ្យាសិក្សាពីភាសាបុគ្គលម្នាក់ៗ មិនមែនសិក្សាពីភាសាជាតិមួយនោះទេ។

### ៣. មុខងារមូលដ្ឋានរបស់ភាសា

#### ៣.១. ភាសាជាមធ្យោបាយ មួយសម្រាប់រ៉ាយរ៉ាប់ ពីបទពិសោធសង្គមប្រវត្តិ

ភាសាមានមុខងារសំខាន់បំផុត ក្នុងការរក្សាទុកបទពិសោធសង្គមប្រវត្តិដែលមានទំនាក់ទំនងពីជំនាន់មួយទៅជំនាន់មួយ។ ក្នុងទំនាក់ទំនងគ្នាទៅវិញទៅមក បុគ្គលម្នាក់ៗតែងទទួលព័ត៌មានយ៉ាងច្រើនពីអ្នកដទៃ ហើយគេអាចផ្ទេរព័ត៌មានរបស់គេទៅអ្នកទាំងនោះវិញជានិច្ច។ ហេតុនេះ ភាសាជាឧបករណ៍សម្រាប់ទំនាក់ទំនងរវាងបុគ្គលនឹងសង្គម។

#### ៣.២. ភាសាជាមធ្យោបាយ សំខាន់ជួយមនុស្សឱ្យធ្វើ មធ្វើ សកម្មភាព បញ្ញាពិសេសគឺដើម្បីគិត

សត្វឆ្លើយតបនឹងរំញោចក្នុងមជ្ឈដ្ឋានជុំវិញ ដោយសារបទពិសោធ ដោយផ្អែកលើប្រព័ន្ធរ៉ឺផ្លិចឥតលក្ខខណ្ឌ និងមានរ៉ឺផ្លិចលក្ខខណ្ឌ។ មនុស្សខុសពីសត្វត្រង់មនុស្សមានភាសា និងមានមនសិការ។ ភាសាជាឧបករណ៍សំខាន់សម្រាប់ឱ្យមនុស្សគិតទុកជាមុនពីផែនការការងារ ការធ្វើឱ្យសម្រេចសកម្មភាពណាមួយ និងចេះប្រៀបធៀបលទ្ធផលដែលទទួលបានទៅនឹងសេចក្តីប៉ងប្រាថ្នាដែលគេបានគ្រោងទុកពីមុន។

### ៤. សកម្មភាព ភាសាបុគ្គល

#### ៤.១. បញ្ញត្តិ សកម្មភាព ភាសាបុគ្គល

សកម្មភាពភាសាបុគ្គល ជាលំនាំនៃការប្រើប្រាស់ភាសាដើម្បីទាក់ទងគ្នាទៅវិញទៅមក និងដើម្បី ប្រមូលបទពិសោធ និងទិន្នន័យព័ត៌មាននៃសង្គមប្រវត្តិ ឬដើម្បីគ្រោងពីសកម្មភាពផ្សេងៗ ។

ភាសាបុគ្គលជាមធ្យោបាយទាក់ទង រីឯសកម្មភាពភាសាបុគ្គលជាលំនាំទាក់ទងគ្នាទៅវិញ ទៅមក ។ ក្នុងសកម្មភាពភាសាបុគ្គលមានទិដ្ឋភាពពីរគឺ **ការបន្លឺសំឡេង** និង**ការយល់អត្ថន័យនៃការបន្លឺសំឡេង**។

- **ការបន្លឺសំឡេង** គឺជាលំនាំដែលចាប់ផ្តើមចេញពីការគិតទៅជាភាសានិយាយ។ លំនាំនេះចាប់ផ្តើមនៅពេលដែលប្រធានត្រូវការនិយាយពីបញ្ហាអ្វីមួយទៅកាន់មនុស្សម្នាក់ទៀត ។

ឧទាហរណ៍៖ សិស្ស"ក" សួរទៅកាន់សិស្ស"ខ" ថា"តើសម្លាញ់បានសិក្សាមេរៀនប្រឡងច្បាស់ហើយ ឬនៅ? បើមានចម្ងល់អ្វី គ្នានឹងជួយឯង ប្រសិនបើគ្នាអាចជួយបាន " ។

- **ការយល់អត្ថន័យនៃការបន្លឺសំឡេង** គឺជាលំនាំមួយដែលផ្ទុយពីលំនាំការបន្លឺសំឡេង។ ការយល់អត្ថន័យនៃការបន្លឺសំឡេង ជាលំនាំចិត្តមួយដែលឆ្លុះបញ្ចាំងពីបរិមាណព័ត៌មាននៃការផ្សព្វផ្សាយផ្ទាល់មាត់ គឺមានន័យថា

យល់អត្ថន័យនៃការបន្លឺសំឡេង ដែលចេញមកពីមាត់បុគ្គលម្នាក់ៗ។

លំនាំនេះប្រព្រឹត្តទៅជាវិជ្ជមានក្រោមរូបភាពពីរ ៖

- ប្រត្យក្សារ ម្មណ៍ ច្បាស់ លាស់ ពីការបន្លឺសំឡេង

ឧទាហរណ៍ ៖ ឮសំឡេងមិត្តរួមថ្នាក់ហៅ ឬសួរ  គឺជាភាសាបុគ្គល ដូចជាសិស្សឈ្មោះ "សុខ" បានសួរទៅសម្លាញ់គេឈ្មោះ "ឧត្តម" ថា ពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តើឯងមានបំណងទៅលេងស្រុកកំណើតដែរឬទេ? មិត្តគេឈ្មោះឧត្តមបានឆ្លើយថា "គ្នាមិនបានទៅលេងស្រុកកំណើតទេ ព្រោះបងប្រុសគ្នា បានបបួលគ្នាទៅកំសាន្តនៅឯក្រុងព្រះសីហនុ" (បានន័យថា ប្រត្យក្សារម្មណ៍ពីភាសា បុគ្គល) ។

- ការយល់ខ្លឹមសារ (យល់ពីភាសាបុគ្គល) បានន័យថា នាំខ្លឹមសារដែលគេផ្សព្វផ្សាយនោះ ទៅភ្ជាប់នឹងបទពិសោធផ្ទាល់ខ្លួន។

ឧទាហរណ៍៖ សិស្សវីរៈនិយាយថា "ខ្ញុំបានជិះដំរីលេងកាលពីថ្ងៃអាទិត្យសប្តាហ៍មុន" ។ សិស្ស "វាសនា"ស្តាប់ឮ ក៏យល់ និងមានការនឹកគិតទៅដល់ហេតុការណ៍នេះ ព្រោះគេធ្លាប់បានស្គាល់ដំរី និងក៏ធ្លាប់បានជិះវាផងដែរ ។

កាលណាគេទទួលប្រត្យក្សារម្មណ៍ច្បាស់លាស់ពីភាសាបុគ្គលណាមួយ  នោះគេអាចធ្វើវិភាគ ឬទូទៅកម្ម លើការផ្សាយទៅបុគ្គលម្នាក់ទៀត  ហើយគេក៏អាចយល់ពីភាសាបុគ្គលនោះ  និងម្យ៉ាងទៀត គេក៏អាចយល់ពីភាសា ជាតិរបស់បុគ្គលនោះផងដែរ ។

ឧទាហរណ៍៖ ជនជាតិអង់គ្លេសបង្រៀនភាសាអង់គ្លេស ដោយនិយាយភាសាអង់គ្លេសពន្យល់ទៅសិស្សកម្ពុជាថ្នាក់កម្រិតមធ្យម សិស្សនោះមិនអាចយល់ទាំងស្រុងនោះទេ ដោយហេតុថា ពួកគេមិនទាន់យល់ភាសាបានច្បាស់ ពុំទាន់មានទម្លាប់ស្តាប់បានល្អ រួមទាំងអំបូរភាសាផ្សេងពីភាសាខ្មែរ ។

រួមសេចក្តីមក ក្នុងសកម្មភាពភាសាបុគ្គលមានលំនាំពីរបដិបក្ខនឹងគ្នា គឺ ៖

ការគិតមកជាភាសាក្រៅហៅថា ការបន្លឺសំឡេង និង លំនាំកែប្រែភាសាក្រៅទៅជាភាសាក្នុង ឬទៅជាការគិតដោយផ្សារភ្ជាប់ជាមួយនឹងបទពិសោធន៍របស់បុគ្គលហៅថា ការយល់អត្ថន័យនៃការបន្លឺសំឡេង។

### ៤.២. ទម្រង់សកម្មភាព ភាសាបុគ្គល

ក្នុងចិត្តវិទ្យាគេសង្កេតឃើញភាសាមានទម្រង់ពីរ **ភាសាក្រៅ** និង **ភាសាក្នុង**

ក. ភាសាក្រៅ   ចែកចេញជាភាសានិយាយ និងភាសាសរសេរ ៖

+ភាសានិយាយ  ភាសានិយាយ  និងភាសាសន្ទនាជាទម្រង់មូលដ្ឋានដែលកើតឡើងមុនគេបង្អស់  និងមានលក្ខណៈពិសេសដូចតទៅ៖

- ភាសានិយាយច្រើនតែបង្កើតបានជាប្រតិកម្ម ដូចជាសម្តីរបស់បុគ្គលម្នាក់ដែលនិយាយណែនាំបុគ្គលម្នាក់ទៀត ដែលជាគូសន្ទនា។
- ភាសានិយាយប្រែប្រួលទៅតាមកាលៈទេសៈហើយផ្សារភ្ជាប់ទៅនឹងកម្មវត្ថុដែលគេលើកមកនិយាយ ឬសន្ទនា ។
- ភាសានិយាយអាចត្រូវបំពេញឱ្យខ្លី ដោយសារតែមធ្យោបាយផ្សេងទៀតនៃការសម្តែងចេញរបស់មនុស្ស ដូចជាការសម្តែងចេញកាយវិការ  ទឹកមុខ  ការមិចភ្នែក  សំណើច ចលនានៃគ្រាប់ភ្នែក...។ ហៅថាទំនាក់ទំនងដោយគ្មានភាសានិយាយ ។
- ភាសាសន្ទនា(សំវាទវិធី)ជាទម្រង់មូលដ្ឋាន ដែលកើតឡើងមុនគេបង្អស់ ។ ភាសាសន្ទនាជាទម្រង់មួយងាយស្រួលប្រកប ដោយលក្ខណៈពិសេសដូចតទៅ ៖
    - វិវត្តទៅតាមកាលៈទេសៈ បានន័យថា ការសន្ទនាត្រូវផ្សារភ្ជាប់ទៅនឹងមជ្ឈដ្ឋានដែលគេកំពុង

- របៀបសិក្សារបស់សិស្ស
- កម្រិតចំណេះដឹងរបស់សិស្ស
- អាចឆ្លុះបញ្ចាំងពីលទ្ធផលនៃការបង្រៀនរបស់ខ្លួនគាត់ចំពោះសិស្ស ។

ទាំងនេះជាបាតុភូតដែលឆ្លុះបញ្ចាំងដោយសារ ការគិតរបស់គ្រូបង្រៀន ។

ឧទាហរណ៍៖ អ្នកជំងឺម្នាក់ទៅរកគ្រូពេទ្យ ដើម្បីរកឱ្យឃើញពីប្រភេទជំងឺ គ្រូពេទ្យសួរពីអាការៈជំងឺ ។ តាមចម្លើយរបស់អ្នកជំងឺ គ្រូពេទ្យអាចដឹងពីរោគសញ្ញានៃជំងឺ ។ ការត្រិះរិះទាំងឡាយរបស់គ្រូពេទ្យដែលវិភាគលើរោគសញ្ញា និងការព្យាបាល គឺជាបាតុភូតនៃការគិត ។

កម្រិតយល់ដឹងរបស់សិស្សដែលគ្រូពិនិត្យឃើញ ប្រភេទជំងឺដែលគ្រូពេទ្យរកឃើញ ជាខ្លឹមសារត្រូវបានឆ្លុះបញ្ចាំងដោយសារការគិត រីឯឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍មិនអាចឆ្លុះបញ្ចាំងបាននូវបាតុភូត ឬវត្ថុអរូបីដូចនេះបានទេ ។ ប្រត្យក្សារម្មណ៍គ្រាន់តែធ្វើឱ្យយើងឃើញពីលក្ខណៈខាងក្រៅរបស់ជំងឺ ពុំអាចដឹងបានពីប្រភេទជំងឺទេ ។ ឯកំហុស និងកង្វះខាត ឬកម្រិតចំណេះដឹងរបស់សិស្ស ក៏មិនអាចឆ្លុះបញ្ចាំងបានដោយសារប្រត្យក្សារម្មណ៍ដែរ ។

## ២- ធម្មជាតិ នៃការគិត

ការគិត ជាលំនាំពុទ្ធិដែលមានកម្រិតខ្ពស់ ហើយប្រព្រឹត្តទៅនៅក្នុងខួរក្បាលរបស់មនុស្សម្នាក់ៗ ។ លទ្ធផលនៃការគិតត្រូវបានស្តែងចេញមកខាងក្រៅតាមរយៈភាសា និងសកម្មភាព ។ ភាសាជាមធ្យោបាយនៃការគិត ដែលផ្សារភ្ជាប់ទៅនឹងភាសាក្នុងរបស់មនុស្ស ។ សកម្មភាពដែលស្តែងចេញពីការគិតគឺ ភាពប៉ិនប្រសប់នៃការគិតទៅលើដំណើរអភិវឌ្ឍន៍ប្រវត្តិសាស្ត្រ ទំនាក់ទំនងរវាងមនុស្សក្នុងសង្គម និងសមិទ្ធផលនៃឧបករណ៍ផលិតនៅក្នុងវិស័យវិទ្យាសាស្ត្របច្ចេកទេស វិស័យឧស្សាហកម្ម វិស័យកសិកម្ម វិស័យទូរគមនាគមន៍...ដែលមនុស្សរួមគ្នាគិត ដោយប្រើពេលយ៉ាងយូរ និងច្រើនជំនាន់ ។

ការគិតនៃខួរក្បាលរបស់មនុស្ស អាចបង្កើតបានជាម៉ាស៊ីនស្វ័យប្រវត្តិសម្រាប់បម្រើសេចក្តីត្រូវការរបស់មនុស្ស និងជួយដោះស្រាយបញ្ហាផ្សេងៗដែលមនុស្សមិនអាចដោះស្រាយបានដូចជា ម៉ាស៊ីនវិនិច្ឆ័យរោគសញ្ញា ម៉ាស៊ីនសម្រាប់គណនា កុំព្យូទ័រដែលអាចកត់ត្រាបាននូវទិន្នន័យយ៉ាងច្រើន...។

ដូចនេះការគិត គឺជាសតិដ៏មានតម្លៃរបស់មនុស្ស ពីព្រោះមានតែមនុស្សទេ ដែលមានការគិតហើយអាចកំណត់នូវទិសដៅនៃការគិតរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាសម្រាប់សង្គម ។ ការគិតអាស្រ័យទៅតាមសមត្ថភាពចំណេះដឹង និងភាពប៉ិនប្រសប់របស់បុគ្គលនីមួយៗ ។ ការគិតអាចឱ្យមនុស្សស្គាល់ និងដណ្តើមត្រួតត្រា ឬសម្រេចការងារធំៗក្នុងជីវិតរស់នៅដូចជា ការស្វែងរកភាពសម្រុះសម្រួល ការចុះសម្រុងគ្នា និងសន្តិភាពទៀតផង ។ ការគិតធ្វើឱ្យមនុស្សមិនត្រឹមតែដណ្តើមឈ្នះលើភពផែនដីប៉ុណ្ណោះទេ តែគេអាចដណ្តើមត្រួតត្រាក្នុងលំហអាកាសទៀតផង ។

## ៣. ចំណែកថ្នាក់ នៃការគិត

ផ្អែកលើមូលដ្ឋាននៃកំណាកំណើត និងកម្រិតអភិវឌ្ឍន៍នៃការគិត គេចែកការគិតជាបីប្រភេទគឺ ៖

### ៣.១. ការគិតរូបីតាមដៃ

ការគិតរូបីតាមដៃ គឺការគិតដោយដៃ ។ ការគិតប្រភេទនេះ មានចំពោះក្មេងអាយុ៣ឆ្នាំ ចំពោះសត្វស្វា និងមនុស្សជំនាន់ដើម ។

ឧទាហរណ៍៖ ស្វា និងស្និតចេក ។ ស្វាអាចឈោងបេះផ្លែចេកបាន ដោយសារវាយកកំណល់ជាច្រើន ដែលនៅក្រោមស្និតចេកមកគរលើគ្នា ឱ្យបានកម្ពស់ដល់ផ្លែចេក ។

### ៣.២. ការគិតរូបីតាមរូបភាព

ការគិតបែបនេះ កើតមានចំពោះក្មេងអាយុ៤-៦ដល់៧ឆ្នាំ។ ក្មេងដល់ដំណាក់កាលអាយុនេះ គេអាចគិត

ជាមួយរូបភាពតំណាងនៃវត្ថុ ហើយនាទីរបស់ដៃថយចុះ ពេលនេះការគិតអរូបីទើបនឹងចាប់ផ្តើម ។

ឧទាហរណ៍៖ បទពិសោធរបស់ព្យាហ្សេ (Piaget) ជាមួយដុំប៊ូលពីរ មួយមូល មួយទៀតគាត់សង្កត់ឱ្យសំប៉ែតនៅមុខក្មេង ។ ក្មេងសង្កេតឃើញថា ប៊ូលសំប៉ែតធំជាងប៊ូលមូល ។

ឧទាហរណ៍៖ ធនញ្ជ័យ ក្នុងរឿងធនញ្ជ័យគិតថា អំបុកដាក់ចង្កេះច្រើនជាងអំបុកដាក់ល្អី ។

### ៣.៣. ការគិតអរូបី

ការគិតអរូបី ជាការគិតរបស់មនុស្សដែលមានកម្រិតខ្ពស់ ។ ការគិតអរូបីអាចឆ្លុះបញ្ចាំងក្រឹត្យក្រម និងទំនាក់ទំនងនៃហេតុការណ៍ផ្សេងៗ ដែលពុទ្ធិឥន្ទ្រីយ៍ និងការគិតដទៃទៀតមិនអាចឆ្លុះបញ្ចាំងបាន ។ ការគិតអរូបីក៏បង្កើតបានជាបញ្ញត្តិដែរ ។

សាលារៀនមានតួនាទី ធ្វើឱ្យការគិតគ្រប់ប្រភេទរបស់សិស្សរីកចម្រើន ពិសេសគឺការគិតអរូបី ។ មធ្យោបាយដ៏មានប្រសិទ្ធភាពនៃការគិតនៅក្នុងថ្នាក់រៀនគឺ ការផ្តល់ឱកាសច្រើន ជាពិសេសពេលវេលា និងគំនិតប្រៀបធៀបដែលរួមទាំងឱកាសធ្វើសកម្មភាព និងការសហការប្តូរយោបល់គ្នារវាងសិស្ស និងសិស្ស ។ ដូចនេះ គ្រូត្រូវរិះរកគ្រប់មធ្យោបាយដើម្បីពង្រីកការគិតរបស់សិស្សនៅក្នុងការអប់រំ ការបង្រៀន និងការរៀន ។

ដោយការគិតអរូបី សិស្សអាចយល់បានពីប្រវត្តិសាស្ត្រសម័យបុរាណ សំណុំនៃចំណុចមួយ វាលលំហសមុទ្រទឹកកក... ។

ការគិតអរូបីអាចឱ្យសិស្សចេះវិភាគ និងឱ្យតម្លៃលើសកម្មភាពតួអង្គនីមួយៗ តាមរយៈអំណាន ឬការស្តាប់រឿងនិទានផ្សេងៗ ។ ពិសេសជាងនេះទៅទៀត ការគិតអរូបីអាចឱ្យមនុស្សរកឃើញភពផ្សេងៗដូចជា ភពព្រះច័ន្ទ និងភពតារាប្លែកៗទៀត ។

## ៤. ចរិតលក្ខណៈនៃការគិត

ដោយសារការគិតជាកម្រិតខ្ពស់បំផុត នៃសកម្មភាពញាណរបស់មនុស្ស ដូចនេះ ការគិតត្រូវមានចរិតលក្ខណៈដូចតទៅ៖

### ៤.១. ចរិតលក្ខណៈចោទជាបញ្ហានៃការគិត

ការគិតជាលំនាំផ្លូវចិត្តដែលកើតមានឡើងក្នុងជីវភាពរស់នៅ ឬក្នុងការប្រតិបត្តិការងារដោយតម្រង់ទៅរកគោលដៅមួយ ។ ការគិតកើតមកពីសកម្មភាពមានបញ្ហា ដែលធ្វើឱ្យមនុស្សផុសចេញនូវគំនិតថ្មី គោលបំណងថ្មី ។ ការជួបប្រទះបញ្ហាថ្មី ស្ថានភាពថ្មី និងលក្ខខណ្ឌនៃសកម្មភាពថ្មី ធ្វើឱ្យមនុស្សតម្រង់ទិសទៅរកគោលបំណងមួយជាក់លាក់ ។

ឧទាហរណ៍៖ សិស្សម្នាក់ជាសិស្សព្យាយាមរៀនសូត្រ មានស្មារតីទទួលខុសត្រូវក្នុងការងារ ហើយឥឡូវគេបែរជាមិនយកចិត្តទុកដាក់ក្នុងការសិក្សា ។ នេះជាបាតុភូតមួយ ដែលទាមទារឱ្យសាស្ត្រាចារ្យ ត្រូវគិតពិចារណាអំពីចរិតលក្ខណៈរបស់សិស្សនោះ ។

ការគិត គឺជាការសិក្សាស្រាវជ្រាវ ដែលនាំឱ្យយើងទៅរកគំហើញថ្មីៗ ។ ប្រសិនបើគេ ធ្លាប់ជួបប្រទះបញ្ហាណាមួយម្តងរួចមកហើយ ។ និងដោយសារចំណេះដឹង ព្រមទាំងគេធ្លាប់មានបទពិសោធផងនោះ នោះគេនឹងមិនត្រូវការការគិតប៉ុន្មានឡើយ ។

ឧទាហរណ៍៖ សិស្សអនុវិទ្យាល័យមិនត្រូវការគិតទេ បើយើងសួរគេថា ពីរគុណនឹងពីរត្រូវជាប៉ុន្មាននោះ ។

ការគិតជាវំញោចនៃស្ថានភាពបញ្ហា ដែលបង្កឱ្យមានវំញោចនៃការគិតទាំងអស់ ។ ដើម្បីឱ្យមនុស្សកើតមានការគិត លុះត្រាតែមនុស្សស្គាល់ស្ថានភាពបញ្ហាសិន ទើបមនុស្សអាចកំណត់ទិសដៅនៃការគិតបាន ។ សមត្ថភាពនៃការគិតក៏អាស្រ័យផងដែរ ទៅនឹងអ្វីដែលមនុស្សធ្លាប់ជួបប្រទះ និងបទពិសោធ ក៏ប៉ុន្តែជួនកាលស្ថានភាពបញ្ហា វាហួស

ពីព្រំដែនចំណេះដឹងនោះបង្កឱ្យមានអសមត្ថភាពនៃការគិត ។

ឧទាហរណ៍៖ ល្បែងល្បងបញ្ញាខ្លះ ធ្វើឱ្យបេក្ខជនមិនអាចឆ្លើយបាន ។

### ៤.២. ការគិតជាចំណាំងប្រយោល

ការគិតពុំមែនជាចំណាំងផ្ទាល់ដូចឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍នោះទេ ។ ការគិត ជាចំណាំងប្រយោល ព្រោះការគិតអាចឆ្លុះបញ្ចាំងវត្ថុ ឬបាតុភូតដែលប្រព្រឹត្តដោយប្រយោលមកលើសរីរាង្គឥន្ទ្រីយ៍ ។ ការគិតជួយយើងឱ្យមានសមត្ថភាពយល់ដឹងពីចរិតលក្ខណៈខាងក្នុងដែលពុទ្ធិឥន្ទ្រីយ៍មិនអាចឆ្លុះបញ្ចាំងបាន ។

ឧទាហរណ៍៖ ភ្លៀងធ្លាក់នៅពេលយប់ពេលយើងកំពុងគេងលក់ ។ លុះព្រោកពីដំណេកយើងដឹងថាមានភ្លៀងធ្លាក់ ព្រោះសំអាងលើសញ្ញាខាងក្រៅដូចជា ដំណក់ទឹកភ្លៀងមានជាប់នឹងស្លឹកឈើ និងដីសើម... ។

### ៤.៣. ការគិតសម្ដែងចេញឡើងតាមរយៈភាសា

ដោយសារភាសា យើងអាចស្គាល់ និងដឹងបានពីអ្វីៗ ដែលយើងមិនដែលឃើញ មិនដែលឮ ។

ឧទាហរណ៍៖ សិស្សខ្មែរយើងមួយចំនួនធំមិនធ្លាប់បានឃើញវាលសមុទ្រខ្សាច់ ឬសមុទ្រទឹកកកនោះទេ ។ ដោយសារតែការបកស្រាយ ការពន្យល់ និងការអធិប្បាយរបស់សាស្ត្រាចារ្យ ពេលនោះ សិស្សអាចដឹង ស្គាល់ពីវាលសមុទ្រខ្សាច់ ឬសមុទ្រទឹកកកបាន ។

ឧទាហរណ៍៖ គ្រូពេទ្យមិនអាចដឹងពីកម្រិតប្រភេទជំងឺបានច្បាស់លាស់នោះទេ នៅពេលដែលគាត់ទើបតែបានឃើញអ្នកជំងឺភ្លាម ។ តែក្រោយពីគាត់សាកសួរអ្នកជំងឺពីមូលហេតុខ្លះ ទើបគាត់ធ្វើការសរុបគ្រប់រោគវិនិច្ឆ័យទាំងអស់ដែលគាត់ដឹងដោយធ្វើការវិភាគ ប្រៀបធៀប និងសំយោគទៅលើរោគវិនិច្ឆ័យតាមចំណេះដឹងផ្នែកទ្រឹស្ដី និងបទពិសោធក្នុងការអនុវត្ត ។ ទីបំផុតគ្រូពេទ្យ អាចធ្វើសេចក្ដីសន្និដ្ឋានបានលើរោគវិនិច្ឆ័យនោះ ។

នៅមានវត្ថុ ឬបាតុភូតខ្លះទៀត ដែលយើងមិនអាចពិនិត្យឃើញដោយផ្ទាល់បាន ។ អ្នកវិទ្យាសាស្ត្របានផលិតវត្ថុ ឬឧបករណ៍ដូចជា ទែម៉ូម៉ែត ប្រដាប់វាស់ស្ទង់សម្រាប់ប្តូរសម្ពាធបរិយាកាស កុងទ័រ ប្រដាប់វាស់ឈាម... ដែលជាតម្រូវការចាំបាច់របស់មនុស្ស ហើយសព្វថ្ងៃនេះ គេអាចវាស់ចលនានៃបេះដូង និងខួរក្បាលបានទៀតផង តាមរយៈកុំព្យូទ័រ ដែលទាំងអស់នេះជាលក្ខណៈចំណាំងប្រយោលនៃការគិត។

### ៤.៤. ចរិតលក្ខណៈ អរូបីកម្ម និងទូទៅកម្មនៃ ការគិត

ការគិតជាចំណាំងបែបអរូបីទៅលើវត្ថុ និងបាតុភូតទាំងឡាយ ។

ឧទាហរណ៍៖ ប្រភេទជំងឺ កម្រិតវប្បធម៌សិស្សម្នាក់ៗ ទាំងនេះជាចរិតលក្ខណៈអរូបី បានន័យថា បើយើងមិនអាចមើលឃើញ មិនអាចឮ មិនអាចប៉ះពាល់បាន នេះជាចំណាំងអរូបី។

ដោយសារការគិត មនុស្សអាចយល់បានស៊ីជម្រៅ ល្អិតល្អន់នូវខ្លឹមសារ និងគុណភាពនៃវត្ថុ ឬបាតុភូតជាច្រើន ហើយបង្កើតបានជាសញ្ញាណទូទៅមួយ ។

ឧទាហរណ៍៖ ឆ្កែ ឆ្មា ជ្រូក គោ ក្របី សេះ មានលក្ខណៈរួមមួយ គឺការចិញ្ចឹមកូនដោយទឹកដោះ ។ ដោយសារមានលក្ខណៈរួមទូទៅ គេអាចចងក្រងសត្វទាំងនោះនៅក្នុងពពួកតែមួយគឺ ថនិកសត្វ។ ដូច្នេះ ការកំណត់ថា **"ថនិក សត្វ"** ជាសញ្ញាណទូទៅកម្ម ។

ការគិតតាមបែបអរូបី និងទូទៅមិនត្រឹមតែមានដំណោះស្រាយចំពោះមុខក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ តែថែមទាំងជួយយើងឱ្យគ្រោងទុកបាននូវបញ្ហាទាំងឡាយទៅអនាគតផង ។

ឧទាហរណ៍៖ ដោយលោហធាតុមានការប្រែប្រួលក្រោមឥទ្ធិពលនៃសីតុណ្ហភាព ដូច្នេះហើយបានជានៅពេលគេសាងសង់ផ្លូវរថភ្លើង នៅមុខតំណគេត្រូវតែទុកចន្លោះតូចមួយ ។

### ៤.៥. ការគិតប្រើភាសាជាឧបករណ៍

ការគិត ជាលំនាំពុទ្ធិដែលមានមុខងារដ៏សំខាន់ ដែលធ្វើឱ្យគេស្គាល់ពិភពបរានុម័ត ។ ក្នុងលំនាំនៃការគិតធាតុសំខាន់គឺ"បញ្ញត្តិភាសា"។ ដូចនេះភាសាជាលំនាំមួយ ដែលមានមុខងារបង្ហាញលទ្ធផលនៃការគិត ។ បញ្ញត្តិភាសាត្រូវបានស្តែងចេញពីពាក្យមួយម៉ាត់ ឬជាភាសាដែលមានលក្ខណៈជាច្បាប់ ឬជានិយមន័យ។ បញ្ញត្តិភាសាក៏ជារូបភាពនៃពិភពបរានុម័តដែរ តែខុសពីរូបភាពនៃឥន្ទ្រីយារម្មណ៍ ឬប្រត្យក្សារម្មណ៍ ដែលយើងមានបញ្ញត្តិបង្កប់គ្រប់លក្ខណៈសំខាន់ៗ នៃក្រឹត្យក្រមទាំងឡាយរបស់វត្ថុ ឬបាតុភូត ។

ឧទាហរណ៍៖ បញ្ញត្តិ"ការេ" គឺជារូបភាពមួយនៃរូបធរណីមាត្រដែលមានមុំកែងបួន និងជ្រុងបួនស្មើគ្នា។ គេមិនចាំបាច់យកសញ្ញាសម្គាល់រូបផ្សេងៗទៀតដូចជា ពណ៌ ប្រវែង ឬកម្រាស់នៃរូបភាពនោះមកបង្ហាញទេ។

បញ្ញត្តិ"តុ" សម្គាល់ពីគ្រឿងសង្ហារឹមដែលមានផ្ទៃរាបស្មើ ទ្រដោយជើងបួន សម្រាប់តម្កល់វត្ថុផ្សេងៗ។ ចំពោះបញ្ញត្តិ"តុ" នេះគេអាចស្គាល់បាន ដោយមិនគិតពីទម្រង់របស់តុ (មូល ជ្រុង ការេ) ឬទំហំ (តូច ធំ ទាប ខ្ពស់) ឡើយ ។

ការគិតត្រូវបានសម្តែងចេញតាមរយៈភាសា ។ តែផ្ទុយទៅវិញ ភាសាមិនអាចមានអត្ថិភាពឡើយ ប្រសិនណាវាមិនឈរលើមូលដ្ឋាននៃការគិតទេ វាគ្រាន់តែជាសំឡេងនិយាយជាប់ៗគ្នាដោយឥតន័យ និងគ្មានអត្ថរស។ ភាសាជាលំនាំផ្លូវចិត្តដែលមានមុខងារសម្រាប់បង្ហាញពីការគិត ។

ឧទាហរណ៍៖ ការគិតទៅដល់ការងារ គ្រួសារ ផ្ទះសំបែង... ត្រូវបានសម្តែងចេញជាពាក្យ ការងារគ្រួសារ ផ្ទះសំបែង... តែពាក្យទាំងនេះមិនបានសម្តែងចេញក្រៅនោះទេ តែវាបានស្ថិតនៅក្នុងខួរក្បាលរបស់យើង ។

ដូចនេះ ដើម្បីបណ្តុះដល់សិស្សនូវបញ្ញត្តិត្រឹមត្រូវ គ្រូបង្រៀនគ្រប់រូបត្រូវពឹងផ្អែកលើរូបភាព ដែលស្ថិតនៅក្នុងបទពិសោធ និងបង្ហាញដល់សិស្សនូវភាពខុសគ្នា ជាគោលការណ៍រវាងវត្ថុទាំងឡាយ ។ ម្យ៉ាងទៀតគ្រូបង្រៀនត្រូវប្រើការសង្កេត ប្រើរូបភាព ដើម្បីពន្យល់សិស្សពីលក្ខណៈខុសគ្នា និងលក្ខណៈដូចគ្នានៃវត្ថុនោះ ។ ដោយសារវិធីនេះ សិស្សអាចយល់ជ្រួតជ្រាបបានពីបញ្ញត្តិវិទ្យាសាស្ត្រទាំងឡាយ។

### ៤.៦. ការគិតអាចជួយឱ្យមនុស្សឆ្លុះបញ្ចាំងបានដ៏ជាក់លាក់ទៀងទាត់ ហើយស៊ីជម្រៅទៅលើធម្មជាតិនៃវត្ថុ និងបាតុភូត ដែលស្ថិតនៅក្នុងតថភាពសត្យានុម័ត

គឺមានតែការគិតទេ ដែលជួយមនុស្សឱ្យមានលទ្ធភាពឆ្លុះបញ្ចាំងបាននូវធម្មជាតិរបស់វត្ថុ និងបាតុភូត ព្រមទាំងទំនាក់ទំនងដែលមានលក្ខណៈជាក្រឹត្យក្រម ហើយដែលអាចឆ្លងកាត់កម្រិតដែលមើលឃើញជាក់ស្តែងរបស់ពុទ្ធិឥន្ទ្រីយ៍ ។ ពិសេសណាស់ទៅទៀត ការគិតគឺជាកម្រិតខ្ពស់បំផុតរបស់សកម្មភាពញាណសត្តិ ពោលគឺ កម្រិតនៃពុទ្ធិវិចារ ។ ប៉ុន្តែនេះក៏មិនមែនមានន័យថា ការគិតចេះតែឆ្លុះបញ្ចាំងបានត្រឹមត្រូវឥតខ្ចោះជានិច្ចទៅលើវត្ថុ ឬបាតុភូតនោះទេ ។ ការគិតឆ្លុះបញ្ចាំងបានត្រឹមត្រូវឥតខ្ចោះ ឬមិនត្រឹមត្រូវ អាស្រ័យដោយល្បិច និងវិធីដែលមនុស្សគិតទេ ។

### ៤.៧. ការគិតមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងពុទ្ធិឥន្ទ្រីយ៍

ថ្វីត្បិតតែការគិតមានកម្រិតខ្ពស់ជាងពុទ្ធិឥន្ទ្រីយ៍ក៏ដោយ ( ឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ) ក៏ការគិតមិនអាចកាត់ផ្តាច់ពីពុទ្ធិឥន្ទ្រីយ៍នេះបានឡើយ ។ ទំនាក់ទំនងបញ្ច្រាសគ្នា និងទំនាក់ទំនងឯកភាពគ្នារវាងការគិត និងពុទ្ធិឥន្ទ្រីយ៍ស្តែងឡើងឱ្យឃើញនូវចំណុចទាំងឡាយដូចតទៅ ៖

- ពុទ្ធិឥន្ទ្រីយ៍គឺជាមូលដ្ឋាននៃការគិត ។ ការគិតត្រូវពឹងផ្អែកលើពុទ្ធិឥន្ទ្រីយ៍ ។ ពុទ្ធិឥន្ទ្រីយ៍ គឺជាប្រភពដែលផ្គត់ផ្គង់សម្ភារៈឱ្យដល់សកម្មភាពនៃការគិត ។ លើរាល់ចំណេះដឹងទាំងអស់ចាប់ប្រភពចេញមកពីបទពិសោធន៍ ឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍នេះឯង ។ ប្រត្យក្សារម្មណ៍ គឺជាដំណាក់កាលមួយ និងជា សមាសធាតុមួយនៅក្នុងសកម្មភាពនៃការគិត ( គេត្រូវមើលឃើញស្ថានភាពមានបញ្ហាសិន មុននឹងកំណត់បាននូវភារកិច្ចនៃការគិត ) ។ ពុទ្ធិឥន្ទ្រីយ៍បង្កើតបានជាមធ្យោបាយមួយថែមទៀត ដែលជួយឱ្យមនុស្សត្រួតពិនិត្យបានទៅលើភាពត្រឹមត្រូវឥតល្អៀង

របស់ការគិត ។

- ផ្ទុយទៅវិញ ការគិត និងផលិតផលរបស់វាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើលំនាំនៃពុទ្ធិឥន្ទ្រីយ៍ដូចជា ភាពជម្រើស អត្ថន័យ និងស្ថេរភាព របស់ប្រត្យក្សារម្មណ៍ ។ វត្ថុ និងបាតុភូត ដែលចាំងចូលមកក្នុងចក្ខុវិញ្ញាណរបស់យើង មិនគ្រាន់តែនាំមកនូវឥន្ទ្រីយារម្មណ៍ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងនាំមកនូវសកម្មភាពនៃការគិតទៀតផង ។

ដោយយោលទៅតាមចរិតរបស់លំនាំនៃការគិត ដូចដែលយើងបានពិសោធរួចមកហើយនោះ យើងអាចទាញសេចក្តីសន្និដ្ឋានគរុកោសល្យដ៏ចាំបាច់នៅក្នុងការបង្រៀន និងការអប់រំដូចតទៅ ៖

ក. គប្បីយកចិត្តទុកដាក់ឱ្យបានដិតដល់ ចំពោះការអភិវឌ្ឍនៃការគិតរបស់សិស្ស ដោយហេតុថា សិស្សមិនមានសតិនៃការគិតទេ ហើយសិស្សក៏មិនអាចយកជោគជ័យបានលើធម្មជាតិ និងធ្វើម្ចាស់ការលើសង្គមដោយខ្លួនឯងបានឡើយ ។

ខ. ការអភិវឌ្ឍនៃការគិត មិនអាចកាត់ផ្តាច់ពីវប្បធម៌នៃភាសាបានឡើយ ។ នៅពេលណាដែលសិស្សក្តាប់បានភាសាវិទ្យាសាស្ត្រនៃមុខវិជ្ជាសិក្សានីមួយៗ ហើយសិស្សពិតជាមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធ្វើឱ្យការគិតនៅក្នុងវិស័យផ្សេងទៀតនៃវិទ្យាសាស្ត្រអភិវឌ្ឍឡើង ។

គ. ការអភិវឌ្ឍនៃការគិតមិនអាចជំនួសឱ្យការហ្វឹកហ្វឺនរបស់ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ សតិនៃការសង្កេត និងលំនឹករបស់សិស្សបានឡើយ ។

ឃ. ការអភិវឌ្ឍការគិត ត្រូវឱ្យមានដំណើរការប្រព្រឹត្តទៅស្របគ្នា និងការផ្តត់ផ្តង់ចំណេះដឹង និងឆ្លងកាត់វិធីបង្រៀន និងរៀននេះទៀតផង ។

ង. បើគេចង់ឱ្យខួរក្បាលរបស់សិស្សមានលក្ខណៈសកម្មពិតប្រាកដ ដោយជំរុញសិស្សឱ្យចេះគិត គេត្រូវចេះបង្កើតឱ្យមានស្ថានភាពបញ្ហានៅចំពោះមុខសិស្ស ។ បែបបទដ៏ងាយស្រួលបំផុតក្នុងការអនុវត្តឱ្យបានសម្រេចតាមប្រការនេះ គ្រូបង្រៀនត្រូវចេះចោទជាសំណួរឱ្យសមស្របទៅតាមសមត្ថភាពសិស្ស តាមកម្រិតសិក្សា នៅពេលដែលគេពន្យល់មេរៀន ។

### ៥. ចលនានៃការគិត

ទង្វើរបស់ការគិតដែលសម្រេចបានរយៈអំពើនៃបញ្ហា ជាការកំណត់នោះហៅថា ចលនានៃការគិត ។ តាមទស្សនៈធម្មជាតិ ការគិតគឺជាលំនាំផ្លូវចិត្តមួយដែលបុគ្គលបានប្រកាន់ភ្ជាប់តាមរយៈចលនានៃបញ្ហាជាកំណត់ ដើម្បីដោះស្រាយបញ្ហា ឬភារកិច្ចដែលចោទឡើងចំពោះខ្លួនគេ ។ បុគ្គលធ្វើការគិត ឬមិនធ្វើ នោះវាអាស្រ័យដោយហេតុការណ៍ដែលមនុស្សនោះធ្វើ ឬមិនធ្វើចលនានៃការគិតនៅក្នុងខួរក្បាលទេ ។ ហេតុនេះ បានជាក្រុមចិត្តវិទូហៅចលនានៃការគិត ម្យ៉ាងទៀតថា ច្បាប់ផ្ទៃក្នុងរបស់ការគិត ។ យើងសិក្សាពីចលនានៃការគិតជាក់ស្តែងដូច តទៅ ៖

#### ក. ការវិភាគ

ការវិភាគ គឺជាលំនាំដែលប្រើចលនានៃខួរក្បាលរបស់មនុស្ស ហើយដែលត្រូវកាត់ផ្តាច់ពីវត្ថុ និងបាតុភូតចំពោះ៖

- ទិដ្ឋភាពណាមួយ
- លក្ខណៈណាមួយ
- ផ្នែកផ្សេងៗដែលជាសមាសភាគ
- ទំនាក់ទំនង

នេះគឺជាបំណែងចែកវត្ថុពីចំណេះដឹង ដែលមានរួចមកហើយនៅក្នុងខួរក្បាលមនុស្សឱ្យទៅជាធាតុ និងផ្នែកផ្សេងៗគ្នា ។ មូលដ្ឋានសរីរៈរបស់ចលនានៃការគិត គឺការរួមបញ្ចូលគ្នាជាកំណត់រវាងការកើតមានរំញោច និងការថយ

ចុះនៃរំញោចនៅលើសំបកខួរក្បាលមនុស្ស ។

### ខ. ការប្រៀបធៀប

ការប្រៀបធៀបគឺជាលំនាំដែលប្រើចលនានៃខួរក្បាលរបស់មនុស្សដែរ ហើយសំដៅកំណត់បាននូវភាពដូចគ្នា ឬ ភាពខុសគ្នា ក្រុមមានអត្តសញ្ញាណ និងក្រុមឥតមានអត្តសញ្ញាណ ឬវិសមភាពរវាងវត្ថុ និងបាតុភូតទាំងឡាយ ។ ចលនានៃការប្រៀបធៀបមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចលនានៃការវិភាគ និងការធ្វើសំយោគ ។ នៅក្នុងដំណាក់កាលទីមួយនៃការសិក្សាស្រាវជ្រាវពិភពជុំវិញខ្លួន គេអាចស្គាល់ពីវត្ថុដែលខុសប្លែកពីគ្នាតាមរយៈការប្រៀបធៀបនេះឯង ។

ការប្រៀបធៀបជាមូលដ្ឋាននៃការគិត និងចំណេះដឹងទាំងឡាយ ។

**គ. ការធ្វើសំយោគ** គឺជាលំនាំដែលប្រើចលនានៃខួរក្បាលមនុស្សដែរ ដោយប្រមូលផ្តុំឡើងវិញនូវសមាសភាគទាំងឡាយ (ដែលកាត់ពីគ្នាដោយសារការវិភាគ) ឱ្យបានគ្រប់គ្រាន់ត្រឹមត្រូវឡើងវិញ ។ មូលដ្ឋានសរីរៈរបស់លំនាំនៃសំយោគគឺការបិទមិនឱ្យមានទំនាក់ទំនងសរសៃប្រសាទជាបណ្តោះអាសន្ននៅលើសំបកខួរក្បាល ។ ការវិភាគ និងការធ្វើសំយោគមានចំណងទាក់ទងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ហើយបង្កើតបានជាឯកតាមួយដែលមិនអាចផ្តាច់ពីគ្នាបានឡើយ ។ ការវិភាគត្រូវបានគេធ្វើឡើងដោយយោលទៅតាមទំនោរនៃការធ្វើសំយោគ ហើយការធ្វើសំយោគនេះប្រព្រឹត្តទៅដោយឈរលើមូលដ្ឋាននៃលទ្ធផលរបស់ការវិភាគ ។

### ឃ. អរូបីកម្ម និងទូទៅកម្ម

អរូបីកម្មគឺជាលំនាំផ្លូវចិត្ត ដែលប្រើខួរក្បាលដើម្បីបញ្ជាក់ពីទិដ្ឋភាពលក្ខណៈចំណងទាក់ទងភាពបន្ទាប់បន្សំភាពឥតបានការដោយរក្សាទុកតែភាពចាំបាច់ក្នុងការគិតតែប៉ុណ្ណោះ ។

ទូទៅកម្មគឺជាលំនាំផ្លូវចិត្តដែលប្រើខួរក្បាលដើម្បីប្រមូលផ្តុំនូវវត្ថុ ឬបាតុភូតជាច្រើនប្រភេទខុសប្លែកគ្នា ហើយដែលមានលក្ខណៈ និងចំណងទាក់ទងដូចគ្នា ហើយដែលកំណត់ទៅតាមក្រុម ឬថ្នាក់របស់វា ។ ទូទៅកម្មនាំមកនូវអ្វីដែលគេហៅថាលក្ខណៈរួម ។

## ៦. ផលនៃការគិត

ការសិក្សាពីផលនៃការគិត គឺជាភារកិច្ចរបស់តក្កវិជ្ជា ។ ហេតុដូច្នេះហើយបានជាយើងសិក្សាដោយសង្ខេបពីផលទាំងនេះ ក្នុងឋានៈជាការបណ្តុះបណ្តាលផ្លូវចិត្ត ដែលបង្កើតឡើងដោយឈរលើមូលដ្ឋានរបស់លំនាំនៃការគិត ។

### ក. អំពីបញ្ញត្តិ

បញ្ញត្តិ គឺជាចំណេះដឹងដែលត្រូវធ្វើទូទៅកម្មរួចមកហើយទៅលើវត្ថុ ឬបាតុភូតមួយក្រុម ដែលមានសញ្ញាប្រភេទដូចគ្នា ។ បញ្ញត្តិ (ជាផលនៃការគិត) និងរូបតំណាង (ជាផលនៃលំនឹក) តែងតែមានការខុសប្លែកគ្នាពីមួយទៅមួយទៀត ។ ក៏ប៉ុន្តែវាមានទំនាក់ទំនងរវាងគ្នានឹងគ្នាជានិច្ច តួយ៉ាងដូចជា ៖

- បញ្ញត្តិមិនអាចកើតមានឡើយនៅក្រោមទម្រង់រូបីឥន្រ្ទីយ៍ ។ បញ្ញត្តិមានលក្ខណៈទូលំទូលាយ និងទូទៅជាងរូបតំណាង ។
- បញ្ញត្តិស្តែងឡើងឱ្យឃើញតាមរយៈពាក្យ (Mot) ។ ក៏ប៉ុន្តែពាក្យមួយម៉ាត់អាចសម្តែងឡើងនូវបញ្ញត្តិជាច្រើនផ្សេងគ្នា ហើយជួនកាលបញ្ញត្តិអាចស្តែងចេញតាមរយៈពាក្យជាច្រើន ។
- បញ្ញត្តិបែបណាក៏ដោយក៏ជាផលនៃការអភិវឌ្ឍរបស់ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃប្រជាជាតិមួយ ឬមនុស្សជាតិទាំងមូល ។ បញ្ញត្តិត្រូវបានបណ្តុះឡើងក្នុងខួររបស់មនុស្ស ដែលឈរលើមូលដ្ឋាននៃរបកគំហើញថ្មីរបស់វិទ្យាសាស្ត្រ បច្ចេកទេស និងផលិតកម្ម ។ ហេតុដូច្នេះហើយបានជាបញ្ញត្តិប្រកាន់យកនូវខ្លឹមសារដ៏កាន់តែសំបូរបែប ហើយពេញលេញផង ។

- បញ្ញត្តិនីមួយៗ ត្រូវបានបណ្ដុះឡើងក្នុងខួរក្បាលរបស់មនុស្ស ដោយឈរលើមូលដ្ឋាននៃឥន្ទ្រីយារម្មណ៍ ក៏ប៉ុន្តែបញ្ញត្តិមិនមានរូបភាពឥន្ទ្រីយារម្មណ៍ទេ ។
- គ្មានព្រំដែនកំណត់ដាច់ខាតទេ រវាងរូបតំណាង និងបញ្ញត្តិ ។ ដោយប្រែក្លាយខ្លួនទៅជាមានលក្ខណៈទូទៅ រូបតំណាងចាប់ផ្ដើមប្រកាន់យកនូវសញ្ញាសម្គាល់របស់បញ្ញត្តិជាស្រេចទៅហើយ ។ ហើយបន្ទាប់ពីបានក្លាយខ្លួនទៅជាបញ្ញត្តិហើយ វាក៏ប្រែក្លាយខ្លួនឯងទៅជារូបតំណាងវិញ ។

នៅពេលនោះចំណងទាក់ទងបញ្ច្រាសគ្នាទៅវិញទៅមករវាងរូបតំណាង និងបញ្ញត្តិកាន់តែស្មុគស្មាញឡើង ។ ការប្រៀបធៀប ការទូរគ្នា(Confrontation) រវាងរូបតំណាង និងបញ្ញត្តិកាន់តែធ្វើឱ្យយើងយល់បានថា ព្រឹត្តិការណ៍តែមួយតែងតែមិនមានភាពដូចគ្នាបេះបិតទៅនឹងទស្សនៈទូទៅឡើយ ។

ឧទាហរណ៍៖ សញ្ញាណនៃពាក្យថា «មនុស្ស» ជានិច្ចកាលវាតែងតែមានលក្ខណៈទូលំទូលាយជាងរូបតំណាងរបស់ស្ត្រីម្នាក់ ឬបុរសម្នាក់ណាដែលមានលក្ខណៈជាក់ស្ដែង ។ នេះគឺជាបញ្ហាមួយដែលយើងត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបណ្ដុះបាននូវបញ្ញត្តិក្នុងខួរក្បាលរបស់សិស្ស ជាពិសេសគឺសិស្សនៅកម្រិតបឋមសិក្សា ។

**ខ. ការវិនិច្ឆ័យ៖** ការវិនិច្ឆ័យគឺជាលំនាំដែលទាញចេញពីការផ្គុំនៃបញ្ញត្តិពីរ ឬច្រើនក្នុងការបញ្ជាក់ពីគុណភាព ឬតម្លៃវត្ថុ ឬបាតុភូតអ្វីមួយ ។

ឧទាហរណ៍ ៖ - ក្ដារខៀននេះល្អ ស្រួលសរសេរ ។
- ចិត្តវិទ្យា ជាវិទ្យាសាស្ត្រមួយ ។

**គ. វិចារ ៖** វិចារគឺជាការវិនិច្ឆ័យមួយទាញចេញពីការវិនិច្ឆ័យផ្សេងៗទៀត ។ វាជាដំណាក់កាលនៃការកកើតមាននូវទស្សនវិជ្ជា។

ឧទាហរណ៍ ៖ ជរា ព្យាធិ មរណៈ
- មនុស្សទាំងអស់សុទ្ធតែស្លាប់
- សូក្រាតជាមនុស្ស
- សូក្រាតត្រូវតែស្លាប់ ។

## ៧. ចរិតបុគ្គលក្នុងគម្រោងនៃការគិត

ចរិតបុគ្គលរបស់មនុស្សម្នាក់ៗក្នុងគម្រោងនៃការគិតស្ដែងឡើងឱ្យឃើញតាមរយៈភាពខុសប្លែកគ្នា ការផ្គួបផ្សំគ្នារវាងប្រភេទនៃការគិតក្នុងខ្លួនគេ ។ ចរិតបុគ្គលនៃការគិតនេះ ស្ដែងចេញឱ្យឃើញនៅក្នុងគុណសម្បត្តិនៃសកម្មភាពញាណសក្តិ(Qualités des activités cognitives = គុណភាពសកម្មភាពនៃការគិត) របស់មនុស្សម្នាក់ៗ ឧទាហរណ៍៖ គ្រូដាក់បង្ហាញឱ្យសិស្សកម្រិតខ្ពស់ ឱ្យសិស្សចេះ អភិវឌ្ឍជំនាញគិតកម្រិតខ្ពស់ យល់ហេតុផល មានដំណោះស្រាយត្រឹមត្រូវ។ សកម្មភាពនៃចំណេះដឹងរបស់មនុស្សម្នាក់ៗ មានគុណសម្បត្តិដូចតទៅ៖

### ៧.១. ស្មារតីម្ចាស់ការក្នុងការគិត

ភាពប៉ិនប្រសប់ក្នុងការដោះស្រាយបញ្ហាដោយខ្លួនផ្ទាល់ ការរកឃើញ និងការកំណត់បាននូវបញ្ហាថ្មីគឺជាស្មារតីច្នៃប្រឌិតនៃការសម្ដែងចេញ ឱ្យឃើញយ៉ាងច្បាស់លាស់នៅក្នុងស្មារតីម្ចាស់ការក្នុងការគិត។

### ៧.២. ភាពទន់ភ្លន់នៃការគិត

ប្រការនេះ អាស្រ័យនៅនឹងការប្រតិបត្តិ ដែលចេះសម្របសម្រួលទៅតាមសភាពជាក់ស្ដែង ហើយការគិតត្រូវសមស្របតាមកិច្ចការនោះ ។

### ៧.៣. ភាពរហ័សរហួននៃការគិត

គឺជាភាពប៉ិនប្រសប់ និងស្ទាត់ជំនាញក្នុងការដោះស្រាយបញ្ហាដែលទទួលបានសម្រេចក្នុងរយៈពេលសមរម្យ ។

### ៧.៤. ភាពទូលំទូលាយនៃការគិត

គឺអាស្រ័យទៅនឹងចំណេះដឹងទូទៅដែលបុគ្គលម្នាក់ៗមាន ហើយភាពទូលំទូលាយនេះសម្តែងចេញឱ្យឃើញចំពោះចរិតដ៏ពេញលេញ និងការច្នៃប្រឌិតនៅក្នុងវិធីសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងការអនុវត្ត។

### ៧.៥. ជម្រៅនៃ ការគិត

ប្រការនេះ អាស្រ័យនៅនឹងសមត្ថភាពរបស់បុគ្គលម្នាក់ៗ ដែលស៊ីជម្រៅលើធម្មជាតិនៃបញ្ហា ។

### ៧.៦. ស្មារតីទិតៀននៃការគិត

គឺជាការវាយតម្លៃ ដោយសត្យានុម័តទៅលើការគិតរបស់បុគ្គលម្នាក់ៗ និងការគិតរបស់អ្នកដទៃដោយបកស្រាយបំភ្លឺឱ្យបានជាក់ច្បាស់ និងមានអំណះអំណាងត្រឹមត្រូវ ហើយទាញសេចក្តីសន្និដ្ឋានទៅតាមគំនិតជឿនលឿន ។

## IV- សន្និដ្ឋាន

គុណសម្បត្តិនៃការគិត អាស្រ័យដោយផ្ទាល់ទៅនឹងដំណើរអភិវឌ្ឍន៍ជាទូទៅនៃ បុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់ៗ បទពិសោធផ្ទាល់ខ្លួន ចរិតអប់រំ និងការអភិវឌ្ឍនៃឆន្ទៈរបស់មនុស្សម្នាក់ៗ។ ហេតុដូច្នេះ ការអប់រំបញ្ញាជាផ្នែកមួយដ៏សំខាន់នៅក្នុងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់សិស្ស ។

ដូច្នេះ គ្រូបង្រៀនត្រូវប្រើវិធីសាស្ត្រយ៉ាងណា ដើម្បីពង្រឹងសមត្ថភាពនៃការគិតរបស់សិស្សនៅក្នុងការអប់រំ ការបង្រៀន និងរៀន ដូចជាបង្ហាត់សិស្សឱ្យធ្វើសកម្មភាពនៃការគិតបង្កើតបញ្ញត្តិដោយខ្លួនឯង បណ្តុះគំនិតលើការ វិនិច្ឆ័យ និងប្រើប្រាស់ការត្រិះរិះរបស់សិស្ស ដោយត្រូវពង្រីកគ្រប់គុណភាពនៃការគិត ។

### សំណួរ

១. តើការគិតជាអ្វី?

២. ចូរបង្ហាញឱ្យឃើញថា ការគិតជាចំណាំងប្រយោលដោយលើកឧទាហរណ៍មកបញ្ជាក់។

៣. ចូរនិយាយពីការគិតរូបីតាមដៃ ដោយលើកឧទាហរណ៍មកបញ្ជាក់។

៤. តើការគិតអរូបីជួយយើងឱ្យមានសមត្ថភាពអ្វីខ្លះ?

៥. តើគ្រូបង្រៀនត្រូវធ្វើដូចម្តេចដើម្បីបណ្តុះបំណិនគិតដល់សិស្ស?

# មេរៀនទី៨ រូបារម្មណ៍

## I- ទស្សនទាន

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់បានពីសញ្ញាណនៃរូបារម្មណ៍
- ពន្យល់ពីមូលដ្ឋានសរីរៈ និងតួនាទីរបស់រូបារម្មណ៍
- មានទម្លាប់កសាងរូបភាពថ្មីដោយប្រើរូបារម្មណ៍ ។

## II- សេចក្តីផ្តើម

គ្រប់សកម្មភាព មនុស្សតែងតែនឹកគិតជាមុន ពីគោលដៅ របៀបដោះស្រាយ និងអាចធ្វើការប្រមើលមើលពីលទ្ធផលដែលនឹងអាចឱ្យគេទទួលបានផងដែរ ។ ក៏ប៉ុន្តែក្នុងករណីជាច្រើនទៀតនៅចំពោះមុខស្ថានភាពបញ្ហា មនុស្សមិនចេះតែអាចមានសមត្ថភាពដោះស្រាយបានទាំងអស់នោះទេ មនុស្សត្រូវពឹងផ្អែកលើលំនាំថ្មីមួយទៀតនៃចំណេះដឹងដែលមានកម្រិតខ្ពស់គឺ **រូបារម្មណ៍** ។

## III- ខ្លឹមសារ

### ១. និយមន័យ

រូបារម្មណ៍ ជាលំនាំចិត្តដែលឆ្លុះបញ្ចាំងវត្ថុទាំងឡាយដែលពុំទាន់កើតមាននៅឡើយ នៅក្នុងបទពិសោធរបស់បុគ្គល និងមិនទាន់កើតមាននៅក្នុងតថភាព។ លំនាំនេះប្រព្រឹត្តទៅដោយបង្កើតរូបភាពថ្មី ហើយចាប់ផ្តើមពីរូបតំណាងចាស់ៗ ដែលបានមកពីឥន្ទ្រីយារម្មណ៍ និងប្រត្យក្សារម្មណ៍។

ឧទាហរណ៍៖ អាទិទេព "ព្រះគណេស" ដែលមានក្បាលជាដំរី ដងខ្លួនជាមនុស្ស ។ រូបសំណាកនេះកើតមានពីរូបារម្មណ៍របស់មនុស្ស។

រូបតំណាងទាំងនោះ ក៏មានមូលដ្ឋានបង្អែកដែលបានពីការគិតដែរ បាននន័យថា រូបារម្មណ៍ត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ និងការគិត ។ រូបារម្មណ៍ជាលំនាំចិត្ត ដែលផ្សារភ្ជាប់ពុទ្ធិឥន្ទ្រីយ៍ទៅពុទ្ធិវិចារ ។

ប្រត្យក្សារម្មណ៍ផ្តល់ឱ្យយើងនូវរូបភាពនាពេលបច្ចុប្បន្ន ។ លំនឹកនាំមកនូវរូបភាព ដែលកើតមានកន្លងរួចមកហើយក្នុងអតីតកាល ឯរូបារម្មណ៍វិញផ្តល់ឱ្យយើងនូវរូបភាពសម្រាប់អនាគត ។ ដូច្នេះ រូបារម្មណ៍ក៏ដូចជាការគិតដែរ ព្រោះវាកើតឡើងតែក្នុងពេលណា ដែលមនុស្សបានជួបប្រទះនូវស្ថានភាពបញ្ហាក្នុងជីវភាពរស់នៅ ។

គេអាចនិយាយម្យ៉ាងទៀតថា រូបារម្មណ៍ជាលក្ខខណ្ឌនៃការច្នៃប្រឌិតរបស់មនុស្ស ។ ប៉ុន្តែគ្រប់រូបភាពរបស់រូបារម្មណ៍មានប្រភពមកពីតថភាព។ ចំពោះក្មេងក៏សម្បូររូបារម្មណ៍ និងរូបតំណាងច្នៃប្រឌិតដែរ ។ នៅក្នុងដំណាក់កាលអាយុបុរេសិក្សា ក្មេងចាប់ផ្តើមមានរូបារម្មណ៍សំខាន់ៗ ។

### ២. ចំណែកថ្នាក់ នៃរូបារម្មណ៍

គេអាចធ្វើចំណែកថ្នាក់រូបារម្មណ៍ជា២ប្រភេទដូចតទៅ ៖

#### ២.១. រូបារម្មណ៍ គិតទុកជាមុន

រូបារម្មណ៍នេះសំដៅទៅរកគោលដៅមួយជាក់លាក់ប្រកបដោយផែនការ និងវិធីសាស្ត្រច្បាស់លាស់ ។ គេតែងតែប្រើរូបារម្មណ៍នេះក្នុងការបង្រៀន ការអប់រំសិស្ស និងក្នុងការងារពលកម្ម ។

ឧទាហរណ៍៖ ពេលបង្រៀនអក្សរសាស្ត្ររឿងទុំទាវ គ្រូត្រូវធ្វើឱ្យសិស្សចេះនឹកគិតដល់របបសង្គម សេដ្ឋកិច្ច និងជីវភាពរបស់មនុស្សជំនាន់សម័យលង្វែក ។

ឧទាហរណ៍ ៖ មុននឹងចេញដំណើរពីទ្វីបអឺរ៉ុបទៅប្រទេសឥណ្ឌា តាមទិសខាងលិច លោកគ្រីស្តូបកូឡុម (Christophe Colomb) គាត់នឹកគិតថា បើផែនដីមានរាងមូល ការធ្វើដំណើរតាមទិសខាងលិចនេះ គាត់បានវិលចូលទៅទ្វីបអឺរ៉ុបវិញ។

### ក. រូបារម្មណ៍បង្កើតឡើងវិញ

គឺជាលំនាំបង្កើតរូបភាពថ្មី ដោយផ្អែកលើបទពិសោធ និងផ្អែកលើកត្តាដែលបានមកពីប្រត្យក្សារម្មណ៍។ ការកសាងរូបភាពថ្មីមានគោលដៅ និងបណ្ដុះពុទ្ធិចំពោះវត្ថុ ឬបាតុភូតតាមរយៈការរ៉ាយរ៉ាប់របស់អ្នកដទៃ ។

ឧទាហរណ៍៖ ស្ដាប់គ្រូរ៉ាយរ៉ាប់ពីវាលលំហខ្សាច់ ភ្នំភ្លើង សមុទ្រទឹកកក... សិស្សអាចនឹកគិតដល់វាលលំហ ភ្នំភ្លើង សមុទ្រទឹកកកនោះ ។

ឧទាហរណ៍៖ ស្ដាប់ការនិទានរឿងរបស់សិស្សម្នាក់ យើងអាចនឹកគិតដល់សកម្មភាពរបស់តួអង្គ ជួនកាលអាចធ្វើឱ្យយើងស្រក់ទឹកភ្នែក។

### ខ. រូបារម្មណ៍ច្នៃប្រឌិត

រូបារម្មណ៍នេះបង្កើតដោយរូបភាពតំណាងថ្មីៗ សម្រាប់វត្ថុដែលមិនទាន់មាននៅឡើយ ។ រូបភាពនៃរូបារម្មណ៍ច្នៃប្រឌិតជារូបភាពដែលមិនទាន់មានក្នុងតថភាព ។

ឧទាហរណ៍៖ តាំងពីយូរមកហើយ មនុស្សបាននឹកស្រមៃទៅដល់ការហោះហើរក្នុងលំហអាកាស ។

ឧទាហរណ៍៖ នៅសតវត្សទី១៨ មិនទាន់មាននាវាមុជទឹកនៅឡើយទេ ។ ប៉ុន្តែលោកស៊ុលវែន បាននឹកស្រមៃទៅដល់នាវាមុជទឹកនេះ។

## ២.២. រូបារម្មណ៍មិនគិតទុកមុន

រូបារម្មណ៍នេះកើតដោយចៃដន្យ ដោយឈរលើមូលដ្ឋានប្រត្យក្សារម្មណ៍ណាមួយ។ ក្នុងជីវភាពរស់នៅមនុស្សតែងតែជួបប្រទះនឹងរូបារម្មណ៍មិនគិតទុកមុនជានិច្ច ។

ឧទាហរណ៍៖ ពេលមើលឃើញដុំពពកនៅលើមេឃ យើងអាចគិតនឹកគិតទៅដល់រូបភាពរបស់មនុស្សម្នាក់ ឬរូបភាពនៃវិមានមួយ ឬរូបសត្វសេះ ឬរូបដំរី ។

ឧទាហរណ៍៖ ក្នុងរង្វង់ព្រះច័ន្ទពេញបូណ៌មី ជួនកាលអ្នកខ្លះមើលឃើញរូបដើមពោធិ៍ អ្នកខ្លះមើលឃើញសត្វទន្សាយ។

ឧទាហរណ៍៖ ពេលយប់ស្ងាត់យើងស្ដាប់ឮសំឡេងចម្លែកមួយដូចជា ស្នូរកាំភ្លើង យើងនឹកគិតថា ប្រហែលជាគេបាញ់ចាប់ចោរ ឬក៏មានឧក្រិដ្ឋជនណាម្នាក់ប្លន់អ្នកដំណើរ ។

ឧទាហរណ៍៖ ក្លិនឈ្ងុយដែលភាយចេញពីផ្ទះបាយ នាំឱ្យយើងនឹកគិតដល់ឈ្មោះសម្លដែលធ្លាប់បរិភោគ ។

## ៣. តួនាទីរបស់រូបារម្មណ៍

រូបារម្មណ៍មាននាទីសំខាន់ណាស់ក្នុងសកម្មភាពប្រតិបត្តិ និងទ្រឹស្ដីរបស់មនុស្សដោយសាររូបារម្មណ៍មនុស្សអាចបង្កើតឧបករណ៍ថ្មីៗ និងទម្រង់ចាត់តាំងការងារថ្មីៗ ។ រូបារម្មណ៍មានសារៈសំខាន់ណាស់ក្នុងវិទ្យាសាស្ត្របច្ចេកទេស និងសិល្បៈ ។ មនុស្សដែលគ្មានរូបារម្មណ៍ មានសមត្ថភាពត្រឹមតែប្រមូលហេតុការណ៍ផ្សេងៗ ដែលកើតមានរួចមកហើយ តែគេមិនអាចរាវរក និងបង្កើតអ្វីដែលថ្មីបានទេ ។

រូបារម្មណ៍មាននាទីសំខាន់ណាស់ក្នុងទ្រឹស្ដី និងក្នុងគ្រប់សកម្មភាពប្រតិបត្តិរបស់មនុស្ស ដូចជា សារៈសំខាន់ចាំបាច់ក្នុងការបង្កើតឧបករណ៍ពលកម្មថ្មីៗ ចាំបាច់ក្នុងវិស័យវិទ្យាសាស្ត្របច្ចេកទេស និងសិល្បៈ(តែងនិពន្ធ)។

ឧទាហរណ៍៖ មធ្យោបាយដឹកជញ្ជូនមនុស្សត្រូវការធ្វើដំណើរឱ្យបានឆាប់រហ័ស។ ការបង្កើតចាប់ពីទោចក្រយាន្ត រថយន្ត កប៉ាល់ទឹក រហូតដល់មានយន្តហោះ ដែលគេអាចធ្វើដំណើរក្នុងចម្ងាយរាប់ពាន់គីឡូម៉ែតក្នុងមួយថ្ងៃ ។

នៅមានឧបករណ៍វិទ្យាសាស្ត្រជាច្រើនទៀត ដែលកើតចេញមកពីរូបារម្មណ៍របស់មនុស្ស និងកំពុងតែមាននាទីយ៉ាងសំខាន់ក្នុងការបម្រើសេវារបស់មនុស្ស ។

### ៤. វិធីកសាងរូបភាពថ្មី នៅក្នុងរូបារម្មណ៍ (Méthodes dédifier limage nouvelle dans limagination)

រូបភាពថ្មីរបស់រូបារម្មណ៍ ត្រូវបានបង្កើតឡើងទៅតាមបែបបទជាច្រើនផ្សេងគ្នា ដូចជា៖

#### ៤.១- វិធីផ្លាស់ប្តូរវិមាត្រ និងចំនួននៃផ្នែក ជាសមាសធាតុរបស់វត្ថុ (Méthode de changer les dimentions et le nombre parties composantes de lobjet )

ក្នុងករណីនេះ គេឃើញមានដូចជា៖ រូបភាពរបស់យក្ស (Limage des géant ) រូបស័ណាករបស់ព្រះពុទ្ធដែលមានដៃច្រើន...។ ញញួរសម្រាប់វាយសំពង ជាញញួរធំហើយវាមិនមានរូបភាពដូចញញួរធម្មតាទេព្រោះវិមាត្ររបស់វាខុសប្លែកគ្នាពីញញួរធម្មតាច្រើនណាស់។

#### ៤.២- វិធីធ្វើឱ្យមាន តម្លៃជាក់ស្តែង (Méthode de mettre en relief )

គឺជាបែបបទបង្កើតឱ្យមានរូបភាពថ្មី ដោយកំណត់យកតែផ្នែកដោយឡែកនៃគុណភាព ទំនាក់ទំនងណាមួយរបស់វត្ថុ ឬបាតុភូតជាមួយនឹងវត្ថុ ឬបាតុភូតផ្សេងទៀតដោយយករូបភាពថ្មីរបស់វត្ថុ ឬបាតុភូតដែលទើបបង្កើតបាននោះ មកដាក់ក្នុងចំណាត់ថ្នាក់ទី១ វិញ។ វិធីមួយផ្សេងទៀតដែលគេប្រើប្រាស់ក្នុងករណីនេះ គឺវិធីបំផ្លើស។

#### ៤.៣- វិធីផ្គុំ ផ្នែក ផ្សេង ៗបញ្ចូលគ្នា (Méthode dagglutination )

គឺជាវិធីបណ្តុះផ្នែកសមាសភាគជាច្រើនរបស់វត្ថុផ្សេងគ្នា ដោយបង្កើតបានតែរូបភាពថ្មីតែមួយ ។

ឧទាហរណ៍៖ រូបភាពម៉ុងសាយចិន។ រូបភាពរបស់ព្រះសិវៈ មានក្បាលជាដំរី និងខ្លួនជាមនុស្ស ។

រូបភាពសត្វស្ទាំង មានក្បាលជាមនុស្ស ខ្លួនជាសត្វគោ ។

រូបភាពថ្មីនៃរូបារម្មណ៍នេះមានផ្នែកផ្សេងៗដែលជាសមាសធាតុផ្គុំបញ្ចូលគ្នានេះគតមានបាត់ ឬផ្លាស់ឡើយ។

#### ៤.៤- វិធីលាយចម្រុះ គ្នា (Méthode de combinaison )

គ្រាន់តែក្រឡេកឃើញភ្លាមយើងដឹងថា វិធីនេះមានភាពស្រដៀងគ្នាបន្តិចបន្តួច ទៅនឹងវិធីផ្គុំផ្នែកផ្សេង ៗបញ្ចូលគ្នា។ ក៏ប៉ុន្តែរូបភាពនេះមិនមែនជាបណ្តុំដ៏សាមញ្ញ ឬការចាប់ផ្គុំយកទៅតាមធាតុដើមរបស់វាឡើយ។ ដោយដាក់បញ្ចូលគ្នាឱ្យបានរូបភាពថ្មីមួយនោះ ធាតុដើមត្រូវផ្លាស់ប្តូរទ្រង់ទ្រាយទាំងអស់។ កាលណាផ្លាស់ប្តូររួច ធាតុទាំងនោះមានទំនាក់ទំនងថ្មីមួយ ។ ការលាយចម្រុះគ្នាគឺជាការធ្វើសំយោគតាមរបៀបច្នៃប្រឌិត ( Synthèse créatrice ) ហើយនេះក៏មិនមែនជាការដាក់បន្ថែមយ៉ាងសាមញ្ញទៅលើធាតុដែលគេស្គាល់មកហើយនោះទេ ។

វិធីនេះត្រូវបានគេយកទៅប្រើប្រាស់យ៉ាង ទូលំទូលាយនៅក្នុងវិស័យបច្ចេកទេស វិទ្យាសាស្ត្រ អក្សរសិល្ប៍ និងសិល្បៈ ។

#### ៤.៥- វិធីគំរូកម្ម (Méthode de typisation )

នេះគឺជាវិធីបណ្តុះបណ្តាលរូបភាពថ្មី ដែលមានលក្ខណៈស្មុគស្មាញបំផុត ដែលក្នុងរូបភាពនេះមានលក្ខណៈគំរូ(Propriétés typiques ) ចរិតលក្ខណៈរបស់បុគ្គលិកលក្ខណៈដែលជាតំណាងរបស់ស្រទាប់សង្គមមួយជាក់ណាត់។

វិធីនេះត្រូវបានគេយកមកប្រើប្រាស់នៅក្នុងសកម្មភាពបង្កើតស្នាដៃអក្សរសិល្ប៍ (Création des oeuvres littéraires ) ស្នាដៃ សិល្បៈ(Oeuvre artisques ) និងក្នុងសិល្បៈចម្លាក់ (Sculpture )។

ធាតុនៃចម្លាក់ដែលគេប្រើសម្រាប់ដាក់លើក្លោងទ្វារ (Chef de voûte ) តាមបែបគំរូកម្មនោះ

គឺជាសំយោគច្នៃប្រឌិត(Création créatrice ) និងទូទៅកម្មទៅលើលក្ខណៈ ផ្សេងៗដូចជាលក្ខណៈដោយឡែក និងគំរូរបស់បុគ្គលិកលក្ខណៈ។

#### ៤.៦- វិធីសទិសភាព (Méthode danalogie)

កាលពីសម័យសង្គមបុព្វកាលរបស់មនុស្សជាតិ បុព្វបុរសយើងចេះបង្កើតឧបករណ៍ដ៏សាមញ្ញបំផុតរួចមក

ហើយទៅតាមសទិសនៃការធ្វើដោយដៃ ។ ឧបករណ៍ទាំងនេះ ជាឧបករណ៍ការងារដែលគេផលិតសម្រាប់ប្រើប្រាស់ ។ មុននឹងផលិតបាននូវឧបករណ៍ការងារទាំងនោះមនុស្សបានរកឃើញសទិសភាពនៅក្នុងខួរក្បាលរបស់គេ។ ដោយសារតែសទិសភាពនេះហើយទើបឧបករណ៍នៃការងារត្រូវបានគេធ្វើឡើងដោយគ្រាប់តាមទំនងនៃចលនាដៃរបស់មនុស្សដែលកាន់ឧបករណ៍នោះ ។ សព្វថ្ងៃនេះការយល់ដឹងពីទំនាក់ទំនងរវាងជីវសាស្ត្រ និងអេឡិចត្រូនិច( Bionique = Qui concer-ne la biologie et l'électronique ) គឺជាការអភិវឌ្ឍក្នុងកម្រិតខ្ពស់បំផុតរបស់វិធីសទិសនៅក្នុងលំនាំនៃរបកគំហើញរបស់អ្នកវិទ្យាសាស្ត្រ ។

### ៥. ទំនាក់ទំនងរូបារម្មណ៍ និង ការគិត

**៥.១.** រូបារម្មណ៍ដូចគ្នានឹងការគិតដែរ គឺជួយយើងឱ្យគ្រោងទុកមុនសម្រាប់ពេលអនាគត ។ ការគិត និងរូបារម្មណ៍បានជួយយើងឱ្យប្រមើលទុកមុន នូវលទ្ធផលនៃសកម្មភាពរបស់យើង និងជួយកែតម្រូវសកម្មភាពដែលយើងបម្រុងនឹងធ្វើ ដើម្បីឆ្លើយតបនឹងមជ្ឈដ្ឋានដែលផ្លាស់ប្តូរឥតឈប់ឈរ ។

ឧទាហរណ៍ ៖ ការប្រៀបប្រដូច ការធ្វើសំបុករបស់ឃ្មុំទៅនឹងស្ថាបត្យករ ឬសត្វពីងពាងទៅនឹងជាងតម្បាញ ។

**៥.២.** កាលណាយើងស្ថិតក្នុងស្ថានភាពបញ្ហា ដែលឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ និងការគិត គ្មានសមត្ថភាពដោះស្រាយបញ្ហានោះ រូបារម្មណ៍ក៏បានចូលមកជំនួស ។

ឧទាហរណ៍៖ ពេលភ្លៀងកំពុងធ្លាក់ មានរន្ទះខ្លាំង( បាតុភូតរន្ទះ ) នៅពេលដែលវិទ្យាសាស្ត្រមិនទាន់រីកចម្រើន ការគិតក៏ពុំអាចដោះស្រាយបាន ពីបាតុភូតនេះ រូបារម្មណ៍ក៏បានចូលមកជំនួស ដោយដោះស្រាយថារន្ទះកើតឡើងដោយសាររាមាសូ ចោលពូថៅទៅលើនាងមេខលា ដែលកាន់កែវមុនីនៅដៃ ។

**៥.៣.** កាលណាមជ្ឈដ្ឋានសង្គមមានបម្រាប់គ្រប់គ្រាន់ គេប្រើការគិតដើម្បីដោះស្រាយ។ ប៉ុន្តែ បើកាលណាក្នុងមជ្ឈដ្ឋាននោះមិនទាន់មានបម្រាប់ច្បាស់លាស់ គេប្រើរូបារម្មណ៍ដើម្បីដោះស្រាយ ។

ឧទាហរណ៍៖ ក្នុងរឿងព្រេង មានតួអង្គយក្ស ។

### ៦. ការស្រមៃ

ការស្រមៃ គឺជាលំនាំចិត្តដែលមានភាពស្រដៀងគ្នានឹងរូបារម្មណ៍ច្នៃប្រឌិត គ្រាន់តែការស្រមៃស្ថិតនៅលើបំណងប្រាថ្នា ចំណង់របស់មនុស្សនៅពេលអនាគត ។ ការស្រមៃអាចក្លាយជាការពិត ក្នុងករណីខ្លះដែលស្មារតី ឆន្ទៈ និងគំនិតធ្វើសកម្មភាពព្រមគ្នា។ ការស្រមៃ បានផ្តល់ឱ្យយើងនូវគុណសម្បត្តិ និងគុណវិបត្តិ។ ការស្រមៃផ្តល់នូវគុណសម្បត្តិ គឺការស្រមៃដែលចេះប៉ាន់ប្រមាណបានសមរម្យតាមសភាពការណ៍ និងសកម្មភាព ។

### ៧. ឧត្តមគតិ

ឧត្តមគតិជារូបភាពដ៏ខ្ពស់បំផុត ដែលជាទម្រង់របស់ការស្រមៃដែរ តែវាបានសណ្ឋិតនៅជាប់យូរណាស់ក្នុងខួរក្បាលរបស់មនុស្ស ។ ដូចនេះយើងអាចនិយាយបានថា ឧត្តមគតិជាកម្រិតខ្ពស់បំផុតរបស់រូបារម្មណ៍ ។

ឧទាហរណ៍៖ ឧត្តមគតិរបស់ប្រជាជនកម្ពុជា គឺចង់កសាងប្រព័ន្ធលទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅក្នុងសង្គមកម្ពុជា។

## IV- សន្និដ្ឋាន

រូបារម្មណ៍មានសារៈសំខាន់ក្នុងការបង្រៀន និងអប់រំ ។ គ្រូបង្រៀនត្រូវប្រើពាក្យសម្តីដែលសំបូរទៅដោយរូបារម្មណ៍ ដើម្បីទាក់ទាញបម្រុងប្រយ័ត្នសិស្ស និងទំនោរចិត្តក្នុងម៉ោងសិក្សា ។ ម្យ៉ាងទៀត គ្រូបង្រៀនត្រូវបណ្តុះរូបារម្មណ៍ អភិវឌ្ឍដល់សិស្ស ដើម្បីពង្រីក និងបង្កើតរូបារម្មណ៍ព្រមទាំងគំនិតច្នៃប្រឌិតដល់សិស្សឱ្យបានច្រើន ។

## សំណួរ

១. ចូរឱ្យនិយមន័យរូបារម្មណ៍ ។

២. ចូរប្រៀបធៀបរូបារម្មណ៍គិតទុកមុន និងរូបារម្មណ៍មិនគិតទុកមុន ។

៣. តើរូបារម្មណ៍ និងការគិតមានទំនាក់ទំនងនឹងគ្នាយ៉ាងណាដែរ ?

៤. តើរូបារម្មណ៍មានសារៈប្រយោជន៍យ៉ាងណាខ្លះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ?

# មេរៀនទី៩ ភាសា

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីភាសាជាតិ ភាសាបុគ្គល ភាសាក្នុង និងភាសាក្រៅ
- កំណត់បានច្បាស់ពីតួនាទីនៃភាសា និងពង្រីកភាសាបានល្អ ពិសេសភាសាក្នុង
- យកចិត្តទុកដាក់ដល់ការប្រើភាសារបស់សិស្សទាំងក្នុង និងក្រៅម៉ោងសិក្សា ។

## II- សេចក្តីផ្តើម

ដោយសារការងារពលកម្ម ភាសាជាលក្ខណៈពិសេសជាមូលដ្ឋានគ្រឹះមួយ ដែលញែកមនុស្ស ឱ្យដាច់ស្រឡះអំពីសត្វ ក្នុងការធ្វើទំនាក់ទំនងរវាងមនុស្សក្នុងសង្គម ។

ភាសាជាប្រព័ន្ធកម្ម(ការបូកផ្សំរវាងប្រព័ន្ធសញ្ញាច្រើនទើបកើតជាភាសា) និងជាការរៀបចំតាមគោលបំណងនៃសញ្ញា។

## III- ខ្លឹមសារ

### ១. និយមន័យ

ភាសាជាតិ គឺជាប្រព័ន្ធនៃសញ្ញា ដែលសម្តែងចេញជាពាក្យ ។ ក្នុងនោះរួមមាន ៖

- សូរវិទ្យា(កុមារ គុហារ... កុ ខ្យល់អឃោសៈ គុ ខ្យល់ឃោសៈ)
- វេយ្យាករណ៍(គោមួយ នាមនៅពីមុខគុណនាម ONE COW គុណនាមនៅពីមុខនាម)
- គ្រឹះសទ្ទានុក្រម (ពាក្យបច្ចេកទេស ដោយផ្អែកលើវេយ្យាករណ៍ )
- ល្បិចតែងនិពន្ធ (បទកាកគតិ ពំនោល...)

ភាសាវិវត្តទៅតាមពេលវេលា ទៅតាមព្រឹត្តិការណ៍សង្គម និងតាមលក្ខណៈចិត្តនៃជាតិសាសន៍នីមួយៗ ។

ឧទាហរណ៍៖ ជនជាតិខ្មែរមានភាសាជាតិរបស់ខ្លួនគឺភាសាខ្មែរ ជនជាតិអង់គ្លេសមានភាសាជាតិរបស់ខ្លួន គឺភាសាអង់គ្លេស ជនជាតិទំពួន ដែលរស់នៅតំបន់ភាគឦសាននៃប្រទេសកម្ពុជាមានភាសាក្រុមជនជាតិរបស់ខ្លួនគឺភាសាទំពួន។

ភាសាបុគ្គល គឺជាភាសាដែលបុគ្គលម្នាក់ៗប្រើសម្រាប់ធ្វើទំនាក់ទំនង នៅក្នុងជីវភាពរស់នៅ និងធ្វើសកម្មភាពទំនាក់ទំនងក្នុងសង្គមជាមួយអ្នកដទៃ ។ ភាសាបុគ្គល គឺជាភាសាប្រើប្រាស់ផ្ទាល់នៃបុគ្គលម្នាក់ៗ ដោយយកភាសាជាតិជាមធ្យោបាយ ។

ឧទាហរណ៍ ៖ ភាសានិយាយរបស់អ្នកសៀមរាប ខុសពីភាសានិយាយរបស់អ្នកបាត់ដំបង ហើយក៏ខុសពីអ្នកភ្នំពេញ ឬអ្នកតាកែវដែរ ។

រួមសេចក្តីមក ភាសាគឺជាមធ្យោបាយសម្រាប់ទាក់ទងរបស់មនុស្សក្នុងសង្គម ជាឧបករណ៍នៃសកម្មភាពបញ្ញារបស់មនុស្ស ។ តាមរយៈភាសាគេអាចបង្ហាញសកម្មភាពផ្លូវចិត្ត និងជាលំនាំមួយដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលំនាំនៃចំណេះដឹង ពិសេសទៅនឹង**ការគិត** ។

ជាទូទៅ ជនជាតិនីមួយៗទោះបីជាជនជាតិភាគតិចក៏ដោយ សុទ្ធតែមានភាសារបស់ខ្លួន ដែលក្នុងនោះរួមមានប្រព័ន្ធសូរវិទ្យា គ្រឹះសទ្ទានុក្រម វេយ្យាករណ៍ និងបែបបទផ្សេងៗទៀតដូចជា ខាងវោហា សាស្ត្រជាដើម ។ ភាសាមានការវិវត្តទៅតាមពេលវេលា ព្រឹត្តិការណ៍សង្គម ទស្សនៈរបស់ជនជាតិនីមួយៗនិងជាបេតិកភណ្ឌផ្នែកស្មារតី សម្រាប់ជនជាតិនីមួយៗ ។ លក្ខណៈពិសេសមួយទៀតដែលគួរឱ្យយើងចាប់អារម្មណ៍ផងដែរនោះ គឺវិវត្តនៃភាសា និងការខ្ចីភាសា

គេយកមកប្រើច្រើនហួសប្រមាណ ដោយគ្មានមូលដ្ឋានច្បាស់លាស់ គឺជាលទ្ធផលអាក្រក់នៃការបាត់បង់អត្តសញ្ញាណរបស់ជាតិមួយ ។

### ២. ភាពខុសគ្នារវាងភាសាជាតិ និង ភាសាបុគ្គល

ភាសាជាតិ និងភាសាបុគ្គល ជាបាតុភូតប្រវត្តិសាស្ត្រដែលកើតមានឡើងក្នុងការងារពលកម្ម ក្នុងសកម្មភាពផ្សេងៗរបស់មនុស្ស និងក្នុងទំនាក់ទំនងផ្នែកស្មារតី។ តែភាសាជាតិ និងភាសាបុគ្គលមានលក្ខណៈខុសគ្នាខ្លះដូចជា៖

- ភាសាជាតិនីមួយៗមានភាសាផ្ទាល់របស់ខ្លួន ដែលមានប្រព័ន្ធសូរវិទ្យាមួយ គ្រឹះសទ្ទានុក្រម វេយ្យាករណ៍ និងល្បិចផ្សេងៗនៃវោហាសាស្ត្រ។
- ភាសាជាតិមួយជាបេតិកភណ្ឌខាងស្មារតីរបស់ប្រជាជាតិនោះ។
- មនុស្សម្នាក់ប្រើភាសាជាតិរបស់ខ្លួន សម្រាប់សម្តែងការគិត និងសញ្ចេតនារបស់ខ្លួន និងប្រើសម្រាប់ការយល់ ដឹង ពីការគិត និងសញ្ចេតនាអ្នកដទៃទៀតផង។
- ចូលដល់វ័យសិក្សានៅមធ្យមសិក្សា សិស្សមានចំណេះដឹងខាងវិទ្យាសាស្ត្រ គេចេះពាក្យថ្មីច្រើន ចេះរបៀបតែងឃ្លា ចេះភាសានិយាយធម្មតា និងភាសាអក្សរសិល្ប៍ទៀតផង ។
- ចិត្តវិទ្យាសិក្សាពីភាសាបុគ្គលម្នាក់ៗ មិនមែនសិក្សាពីភាសាជាតិមួយនោះទេ។

### ៣. មុខងារមូលដ្ឋានរបស់ភាសា

#### ៣.១. ភាសាជាមធ្យោបាយ មួយសម្រាប់រ៉ាយរ៉ាប់ ពីបទពិសោធសង្គមប្រវត្តិ

ភាសាមានមុខងារសំខាន់បំផុត ក្នុងការរក្សាទុកបទពិសោធសង្គមប្រវត្តិដែលមានទំនាក់ទំនងពីជំនាន់មួយទៅជំនាន់មួយ។ ក្នុងទំនាក់ទំនងគ្នាទៅវិញទៅមក បុគ្គលម្នាក់ៗតែងទទួលព័ត៌មានយ៉ាងច្រើនពីអ្នកដទៃ ហើយគេអាចផ្ទេរព័ត៌មានរបស់គេទៅអ្នកទាំងនោះវិញជានិច្ច។ ហេតុនេះ ភាសាជាឧបករណ៍សម្រាប់ទំនាក់ទំនងរវាងបុគ្គលនឹងសង្គម។

#### ៣.២. ភាសាជាមធ្យោបាយ សំខាន់ជួយមនុស្សឱ្យធ្វើ មធ្វើសកម្មភាព បញ្ញាពិសេសគឺដើម្បីគិត

សត្វឆ្លើយតបនឹងរំញោចក្នុងមជ្ឈដ្ឋានជុំវិញ ដោយសារបទពិសោធ ដោយផ្អែកលើប្រព័ន្ធរ៉ផ្លិចឥតលក្ខខណ្ឌ និងមានរ៉េផ្លិចលក្ខខណ្ឌ។ មនុស្សខុសពីសត្វត្រង់មនុស្សមានភាសា និងមានមនសិការ។ ភាសាជាឧបករណ៍សំខាន់សម្រាប់ឱ្យមនុស្សគិតទុកជាមុនពីផែនការការងារ ការធ្វើឱ្យសម្រេចសកម្មភាពណាមួយ និងចេះប្រៀបធៀបលទ្ធផលដែលទទួលបានទៅនឹងសេចក្តីប៉ងប្រាថ្នាដែលគេបានគ្រោងទុកពីមុន។

### ៤. សកម្មភាព ភាសាបុគ្គល

#### ៤.១. បញ្ញត្តិ សកម្មភាព ភាសាបុគ្គល

សកម្មភាពភាសាបុគ្គល ជាលំនាំនៃការប្រើប្រាស់ភាសាដើម្បីទាក់ទងគ្នាទៅវិញទៅមក និងដើម្បី ប្រមូលបទពិសោធ និងទិន្នន័យព័ត៌មាននៃសង្គមប្រវត្តិ ឬដើម្បីគ្រោងពីសកម្មភាពផ្សេងៗ ។

ភាសាបុគ្គលជាមធ្យោបាយទាក់ទង រីឯសកម្មភាពភាសាបុគ្គលជាលំនាំទាក់ទងគ្នាទៅវិញ ទៅមក ។ ក្នុងសកម្មភាពភាសាបុគ្គលមានទិដ្ឋភាពពីរគឺ ការបន្លឺសំឡេង និងការយល់អត្ថន័យនៃការបន្លឺសំឡេង។

- ការបន្លឺសំឡេង គឺជាលំនាំដែលចាប់ផ្តើមចេញពីការគិតទៅជាភាសានិយាយ។ លំនាំនេះចាប់ផ្តើមនៅពេលដែលប្រធានត្រូវការនិយាយពីបញ្ហាអ្វីមួយទៅកាន់មនុស្សម្នាក់ទៀត ។

ឧទាហរណ៍៖ សិស្ស"ក" សួរទៅកាន់សិស្ស"ខ" ថា"តើសម្លាញ់បានសិក្សាមេរៀនប្រឡងច្បាស់ហើយ ឬនៅ? បើមានចម្ងល់អ្វី គ្នានឹងជួយឯង ប្រសិនបើគ្នាអាចជួយបាន " ។

- ការយល់អត្ថន័យនៃការបន្លឺសំឡេង គឺជាលំនាំមួយដែលផ្ទុយពីលំនាំការបន្លឺសំឡេង។ ការយល់អត្ថន័យនៃការបន្លឺសំឡេង ជាលំនាំចិត្តមួយដែលឆ្លុះបញ្ចាំងពីបរិមាណព័ត៌មាននៃការផ្សព្វផ្សាយផ្ទាល់មាត់ គឺមានន័យថា

យល់អត្ថន័យនៃការបន្លឺសំឡេង ដែលចេញមកពីមាត់បុគ្គលម្នាក់ៗ។

លំនាំនេះប្រព្រឹត្តទៅជាវិជ្ជមានក្រោមរូបភាពពីរ ៖

- ប្រត្យក្សារម្មណ៍ ច្បាស់លាស់ពីការបន្លឺសំឡេង

ឧទាហរណ៍ ៖ ឮសំឡេងមិត្តរួមថ្នាក់ហៅ ឬសួរ គឺជាភាសាបុគ្គល ដូចជាសិស្សឈ្មោះ "សុខ" បានសួរទៅសម្លាញ់គេឈ្មោះ "ឧត្តម" ថា ពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ តើឯងមានបំណងទៅលេងស្រុកកំណើតដែរឬទេ? មិត្តគេឈ្មោះឧត្តមបានឆ្លើយថា "គ្នាមិនបានទៅលេងស្រុកកំណើតទេ ព្រោះបងប្រុសគ្នា បានបបួលគ្នាទៅកំសាន្តនៅឯក្រុងព្រះសីហនុ" (បានន័យថា ប្រត្យក្សារម្មណ៍ពីភាសា បុគ្គល) ។

- ការយល់ខ្លឹមសារ (យល់ពីភាសាបុគ្គល) បានន័យថា នាំខ្លឹមសារដែលគេផ្សព្វផ្សាយនោះ ទៅភ្ជាប់នឹងបទពិសោធផ្ទាល់ខ្លួន។

ឧទាហរណ៍៖ សិស្សវីរៈនិយាយថា "ខ្ញុំបានជិះដំរីលេងកាលពីថ្ងៃអាទិត្យសប្តាហ៍មុន" ។ សិស្ស "វ៉ាសនា"ស្តាប់ឮ ក៏យល់ និងមានការនឹកគិតទៅដល់ហេតុការណ៍នេះ ព្រោះគេធ្លាប់បានស្គាល់ដំរី និងក៏ធ្លាប់បានជិះវាផងដែរ ។

កាលណាគេទទួលប្រត្យក្សារម្មណ៍ច្បាស់លាស់ពីភាសាបុគ្គលណាមួយ នោះគេអាចធ្វើវិភាគ ឬទូទៅកម្ម លើការផ្សាយទៅបុគ្គលម្នាក់ទៀត ហើយគេក៏អាចយល់ពីភាសាបុគ្គលនោះ និងម្យ៉ាងទៀត គេក៏អាចយល់ពីភាសា ជាតិរបស់បុគ្គលនោះផងដែរ ។

ឧទាហរណ៍៖ ជនជាតិអង់គ្លេសបង្រៀនភាសាអង់គ្លេស ដោយនិយាយភាសាអង់គ្លេសពន្យល់ទៅសិស្សកម្ពុជាថ្នាក់កម្រិតមធ្យម សិស្សនោះមិនអាចយល់ទាំងស្រុងនោះទេ ដោយហេតុថា ពួកគេមិនទាន់យល់ភាសាបានច្បាស់ ពុំទាន់មានទម្លាប់ស្តាប់បានល្អ រួមទាំងអំបូរភាសាផ្សេងពីភាសាខ្មែរ ។

រួមសេចក្តីមក ក្នុងសកម្មភាពភាសាបុគ្គលមានលំនាំពីរបដិបក្ខនឹងគ្នា គឺ ៖

ការគិតមកជាភាសាក្រៅហៅថា ការបន្លឺសំឡេង និង លំនាំកែប្រែភាសាក្រៅទៅជាភាសាក្នុង ឬទៅជាការគិតដោយផ្សារភ្ជាប់ជាមួយនឹងបទពិសោធន៍របស់បុគ្គលហៅថា ការយល់អត្ថន័យនៃការបន្លឺសំឡេង។

### ៤.២. ទម្រង់សកម្មភាព ភាសាបុគ្គល

ក្នុងចិត្តវិទ្យាគេសង្កេតឃើញភាសាមានទម្រង់ពីរ **ភាសាក្រៅ** និង **ភាសាក្នុង**

ក. ភាសាក្រៅ ចែកចេញជាភាសានិយាយ និងភាសាសរសេរ ៖

+ភាសានិយាយ ភាសានិយាយ និងភាសាសន្ទនាជាទម្រង់មូលដ្ឋានដែលកើតឡើងមុនគេបង្អស់ និងមានលក្ខណៈពិសេសដូចតទៅ៖

- ភាសានិយាយច្រើនតែបង្កើតបានជាប្រតិកម្ម ដូចជាសម្តីរបស់បុគ្គលម្នាក់ដែលនិយាយណែនាំបុគ្គលម្នាក់ទៀត ដែលជាគូសន្ទនា។
- ភាសានិយាយប្រែប្រួលទៅតាមកាលៈទេសៈហើយផ្សារភ្ជាប់ទៅនឹងកម្មវត្ថុដែលគេលើកមកនិយាយ ឬសន្ទនា ។
- ភាសានិយាយអាចត្រូវបំពេញឱ្យខ្លី ដោយសារតែមធ្យោបាយផ្សេងទៀតនៃការសម្តែងចេញរបស់មនុស្ស ដូចជាការសម្តែងចេញកាយវិការ ទឹកមុខ ការមិចភ្នែក សំណើច ចលនានៃគ្រាប់ភ្នែក...។ ហៅថាទំនាក់ទំនងដោយគ្មានភាសានិយាយ ។
- ភាសាសន្ទនា(សំវាទវិធី)ជាទម្រង់មូលដ្ឋាន ដែលកើតឡើងមុនគេបង្អស់ ។ ភាសាសន្ទនាជាទម្រង់មួយងាយស្រួលប្រកប ដោយលក្ខណៈពិសេសដូចតទៅ ៖
    - វិវត្តទៅតាមកាលៈទេសៈ បានន័យថា ការសន្ទនាត្រូវផ្សារភ្ជាប់ទៅនឹងមជ្ឈដ្ឋានដែលគេកំពុង

សន្ទនា ។

- ភាសាសន្ទនាជាភាសាដែលមិនគ្រោងទុកមុន ជាទូទៅភាសាសន្ទនាជារចនាសម្ព័ន្ធនៃភាសាមួយដែលគ្រាន់តែមានលក្ខណៈរៀបចំមិនបានត្រឹមត្រូវប៉ុណ្ណោះព្រោះគេប្រើឃ្លាប្រយោគងាយៗ។
- ភាសាឯកវាទ(ឯកវាទវិធី) បានរីកចម្រើនពីភាសាសន្ទនា ។ ភាសាឯកវាទកើតឡើងដោយ មានវេយ្យាករណ៍ត្រឹមត្រូវ និងតម្រូវការផ្សព្វផ្សាយដល់មនុស្សមួយចំនួននូវដំណឹងផ្សេងៗ ។

ឧទាហរណ៍៖ របាយការណ៍ ការនិទានរឿង សុន្ទរកថាក្នុងអង្គប្រជុំ បទឧទ្ទេស ឬ បទអន្តរាគមន៍ អនុសាសន៍ជាដើម ។

**ភាសាឯកវាទត្រូវប្រើវិធីដូចខាងក្រោម ៖**

- ប្រើពាក្យសម្ដីឱ្យច្បាស់លាស់ ។
- ខ្លឹមសារដែលយកមករ៉ាយរ៉ាប់ត្រូវឱ្យសមស្របនឹងតថភាពបានុម័តស្របទៅនឹងចំណូលចិត្តរបស់អ្នកស្ដាប់។
- ត្រូវចេះរ៉ាយរ៉ាប់យ៉ាងណាឱ្យអ្នកស្ដាប់ជក់ចិត្ត ពោលគឺទេពកោសល្យនៃការនិយាយ ។

**+ភាសាសរសេរ៖** ភាសាសរសេរកើតឡើងបន្ទាប់ពីភាសានិយាយ និងជាភាសាដែលគិតទុកមុន។ ក្រោយពេលមនុស្សមានតម្រូវការរក្សាទុកឱ្យបានយូរនូវសម្ដីរបស់ខ្លួន និងតម្រូវការបញ្ជូនសម្ដីទៅឆ្ងាយតាមរយៈសំបុត្រ ឬតាមរយៈអន្តរបណ្ដាញ...។ គេកំណត់សញ្ញាឮឱ្យទៅជាសញ្ញាសរសេររួចគេក៏បង្កើតអក្សរឡើង ។

តាមឯកសារស្រាវជ្រាវបានបញ្ជាក់ថា រូបរាងអក្សរបានធ្វើការវិវត្តមកពីទម្រង់សញ្ញាជាតំណាងឱ្យវត្ថុនានា ឬមានអត្ថន័យផ្សេងៗដោយប្រើជារូបភាពនិមិត្តសញ្ញាផ្សេងៗ។ បន្ទាប់មកគេប្រើអក្សរគំនិតដែលជាតំណាងដោយផ្ទាល់ទៅលើគំនិតតាមរយៈសញ្ញាដែលជាតំណាងឱ្យវត្ថុ។ លំនាំនេះមានមកទល់បច្ចុប្បន្ន ក្នុងករណីតួអក្សរក្នុងភាសាចិន ។

ឧទាហរណ៍ ៖ ដំបូងគេបង្កើតអក្សរតាមរយៈអក្សរគំនិត ដូចជា៖




## ខ. ភាសាក្នុង

ភាសាក្នុង គឺជាទម្រង់អត្ថិភាពនៃគំនិតរបស់មនុស្ស។ ភាសាក្នុង គឺជាភាសាដែលគេគិតក្នុងចិត្តដោយមិនទាន់បញ្ចេញមកខាងក្រៅ ។ ភាសាក្នុងជាទម្រង់មួយនៃការគិត និងមានរចនាសម្ព័ន្ធដូចគ្នានឹងភាសាក្រៅដែរគ្រាន់តែមានលក្ខណៈខ្លីជាងភាសាខាងក្រៅ ហើយប្រព្រឹត្តទៅយ៉ាងលឿន ដើម្បីអាចតាមដានចលនារបស់ការគិតបាន ។

ភាសាក្នុងជាលទ្ធផលនៃការនាំយកភាសាក្រៅទៅក្នុង ។ ភាសាក្នុងនេះសម្ដែងចេញមកខាងក្រៅជាភាសាសរសេរ ឬភាសានិយាយ ។

នៅទីបំផុតប្រព័ន្ធអក្ខរក្រមផ្សេងៗក៏ចាប់ផ្ដើមកើតឡើង នោះគឺជាប្រព័ន្ធនៃសំណេរដែលពឹងផ្អែកលើអក្ខរក្រម។ តាមប្រព័ន្ធអក្ខរក្រម អក្សរនីមួយៗតំណាងឱ្យគំនិត និងសំឡេងមួយទៀតផង (ស្រៈ និង ព្យញ្ជនៈ)។ ដោយសារលក្ខណៈអក្ខរក្រម ធ្វើឱ្យផ្នែកវប្បធម៌របស់មនុស្សជាតិ មានការអភិវឌ្ឍយ៉ាងខ្លាំង។

ភាសាសរសេរទាមទារនូវការប្រើគំនិត និងទស្សនៈយ៉ាងខ្លាំង និងមានទម្រង់ ព្រមទាំងភាសាសុក្រឹត្យក្នុងសំណេរ ទើបអត្ថន័យនៃការសរសេរមានភាពច្បាស់លាស់។

## ៥. ភាសា និង លំនាំពុទ្ធិ ( សកម្មភាព ពុទ្ធិ )

ភាសាជាតិ និងភាសាបុគ្គលមានមុខងារសំខាន់ក្នុងជីវិតចិត្តរបស់មនុស្ស។ គ្រប់លំនាំបាតុភូតចិត្តរបស់មនុស្សតាំងពីឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ លំនឹក រូបារម្មណ៍ ការគិត សុទ្ធតែយកភាសាមកប្រើជាឧបករណ៍ទាំងអស់ ។

ឧទាហរណ៍៖ ក្នុងពេលបង្រៀន ដោយសារភាសារបស់គ្រូធ្វើឱ្យសិស្សអាចយល់បានពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលកន្លងរួចមកហើយអាចយល់ពីតំបន់ភូមិសាស្ត្រឆ្ងាយៗ ដែលគ្រូលើកយកមកបង្រៀន ព្រោះពេលនោះសិស្សយល់ភាសារបស់គ្រូ ហើយអាចបំលែងទៅជារូបតំណាងផ្សេងៗ ។

ភាសាបុគ្គលមានមុខងារសំខាន់ក្នុងចលនានៃការគិតរបស់មនុស្ស រីឯភាសាក្នុងជាទម្រង់មួយរបស់ការគិត ។ ដូចនេះ ប្រសិនបើភាសាក្នុងខ្សោយ ចលនានៃការគិតក៏ប្រព្រឹត្តទៅមិនបានធម្មតាដែរ។

និយាយរួមភាសាបុគ្គលផ្សារភ្ជាប់ជានិច្ចទៅនឹងបាតុភូតចិត្ត និងលំនាំពុទ្ធិរបស់មនុស្ស ។

## ៦. តួនាទីរបស់ភាសាបុគ្គល

ភាសាបុគ្គលមានតួនាទី បង្កើតទំនាក់ទំនង និងបង្ហាញឱ្យឃើញនូវលក្ខណៈនៃចំណេះដឹង សញ្ចេតនា និងចិត្តរំភើប ព្រមទាំងឆន្ទៈ និងអំពើលើឆន្ទៈនោះផង។

### ក. លក្ខណៈ នៃចំណេះដឹង

ភាសាបុគ្គលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងមនសិការរបស់បុគ្គល និង បទពិសោធក្នុងជីវភាពរស់នៅក្នុងសង្គម ហើយបង្កើតឡើងនូវសកម្មភាពនៃចំណេះដឹង ។ ដូចនេះការអភិវឌ្ឍផ្លូវចិត្តរបស់មនុស្ស នាំឱ្យមានការអភិវឌ្ឍភាសា ។

ឧទាហរណ៍៖ បើយើងយកទារកខ្មែរមួយរូបឱ្យទៅរស់នៅក្នុងសង្គម ដែលនិយាយភាសាអង់គ្លេស នោះកុមារនឹងអាចនិយាយភាសាអង់គ្លេសបាន ហើយគេនឹងមិនអាចនិយាយភាសាខ្មែរបានវិញឡើយ ។

ភាសារបស់បុគ្គល អាចឆ្លុះបញ្ចាំងបាននូវតថភាពបានុម័តរបស់មនុស្ស ដោយផ្អែកទៅលើបញ្ញត្តិការពិចារណា ការវិនិច្ឆ័យ ការធ្វើសំយោគ និងប្រត្យក្សារម្មណ៍ ។

ដូចនេះគ្រូបង្រៀនគួរតែតាមដានឱ្យបានហ្មត់ចត់ នូវដំណើរអភិវឌ្ឍន៍នៃភាសារបស់សិស្សម្នាក់ៗ ដោយហេតុថា ភាសាគឺជាឧបករណ៍ដែលអាចបង្ហាញឱ្យយើងបានដឹង នូវកម្រិតចំណេះដឹងរបស់សិស្សបាន ។

### ខ. ចិត្តរំភើប និងសញ្ចេតនា

ចិត្តរំភើប និងសញ្ចេតនាសម្តែងចេញមកពីបាតុភូតនៃទំនាក់ទំនងផ្អែកភាសា រវាងមនុស្ស និងមនុស្សក្នុងសង្គម តាមរយៈភាសាបុគ្គលដែលជាពាក្យសម្តី និងកាយវិការ។ គ្រប់សកម្មភាពភាសារបស់បុគ្គលទាំងពាក្យសម្តី និងកាយវិការ ពិសេសអាស្រ័យលើការលើកដាក់សំឡេង និងរបៀបនិយាយ គឺអាចសម្តែងចេញឱ្យឃើញនូវចិត្តរំភើប និងសញ្ចេតនាដូចជា ភាពសប្បាយរីករាយ ភាពគួរឱ្យមានទំនុកចិត្ត ភាពក្រៀមក្រំក្នុងចិត្ត ទុក្ខលំបាក ភាពមានកំហឹង ឬភាពគំនុំគំគួនជាដើម ។

### គ. ឆន្ទៈ និងអំពើឆន្ទៈ

គ្រប់បញ្ហាកើតមានឡើង សមត្ថភាពនៃដំណោះស្រាយបង្ហាញពីឆន្ទៈរបស់បុគ្គលដែលសម្រេចបាននូវអំពើឆន្ទៈ ដោយអាស្រ័យទៅនឹងចំណេះដឹង បទពិសោធផ្ទាល់ខ្លួននៃទំនាក់ទំនងក្នុងសង្គម។ ប្រការនេះអាចឱ្យបុគ្គលធ្វើការសម្រេចចិត្ត ដោយសម្តែងចេញនូវសញ្ចេតនា និងឆន្ទៈ ហើយទាំងអស់នេះស្ថិតនៅក្រោមរូបភាពនៃភាសាប៉ុណ្ណោះ ។

## ៧. ភាសា និង បុគ្គលិកលក្ខណៈ

អាកប្បកិរិយារបស់មនុស្ស មិនមែនសម្តែងចេញតាមវត្ថុជាក់ស្តែងទេ តែវាត្រូវសម្តែងចេញតាមសកម្មភាពភាសាបុគ្គល និងទង្វើរបស់បុគ្គលនោះ។ ទន្ទឹមនឹងនោះ លក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈ ក៏លេចឡើងដែរ ។ អាកប្បកិរិយា និងបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗមិនដូចគ្នាទេ ។

### ក. ភាសាបុគ្គល និងទំនោរ

ទំនោរនៃបុគ្គលិកលក្ខណៈ ត្រូវបានសម្តែងចេញតាមការជឿជាក់ ឧត្តមគតិ និងចំណង់ចំណូលចិត្ត ។ ទំនោរនៃបុគ្គលិកលក្ខណៈដឹកនាំការជ្រើសរើសទិសដៅ និងខ្លឹមសាររបស់ការសន្ទនា ។

### ខ. ភាសាបុគ្គល និងអត្តចរិត

ទំនាក់ទំនងភាសា គឺជាតម្រូវការរបស់មនុស្ស ។ លំនាំទំនាក់ទំនងនេះបានឆ្លុះបញ្ចាំងពីចិត្តស្មោះត្រង់ មានសុជីវធម៌ អាកប្បកិរិយាសុភាពរាបសារ ចិត្តស្លូតបូត សមានចិត្តល្អ ដែលគេចាត់ទុកជាអត្តចរិតវិជ្ជមាន ។

ក្នុងជីវភាពប្រចាំថ្ងៃ ពេលទាក់ទងគ្នា មនុស្សមានបំណងនឹងប្រាប់ពីការគិត ចិត្តរំភើប សំណូមពរ អាកប្បកិរិយា និងចំណង់ចំណូលចិត្តរបស់ខ្លួនដល់អ្នកដទៃ ។

អត្តចរិតដែលយើងបានរៀបរាប់ខាងលើនេះ អាចផ្លាស់ប្តូរទៅតាមឬកពា និងឆន្ទៈរបស់បុគ្គលនីមួយៗ ។ សីលធម៌ គុណធម៌ ក៏សម្តែងចេញក្នុងសកម្មភាពភាសាបុគ្គលដែរ ។ កាលណាបុគ្គលម្នាក់សន្ទនាជាមួយបុគ្គលម្នាក់ទៀត គេអាចដឹងបានថា អ្នកនោះមានទំនុកចិត្តលើខ្លួនឯង ចេះប្រមាណខ្លួន ជាមនុស្សស្លូតបូត ជាមនុស្សមានអំនួត ជាមនុស្សព្យាបាទគេ ឬ ជាមនុស្សមិនសូវសេកម្ម ។

ចរិតលក្ខណៈនៃបុគ្គលបង្ហាញឱ្យឃើញនូវសកម្មភាពបញ្ញា និងសកម្មភាពវិជ្ជាជីវៈមួយជាក់លាក់ត្រូវបានឆ្លុះបញ្ចាំងក្នុងរចនាបថនៃភាសា។ ហេតុនេះគេអាចឆ្លុះបញ្ចាំងពីចរិតលក្ខណៈ កម្រិតវប្បធម៌ និងការភ្ញាក់រឭកវិជ្ជាជីវៈរបស់មនុស្សម្នាក់ៗ តាមរយៈរចនាបថនៃភាសារបស់មនុស្សនោះ ។

ក្នុងវិស័យអប់រំ ភាសាជាមធ្យោបាយមូលដ្ឋានគ្រឹះរបស់គ្រូ ហេតុនេះគ្រូម្នាក់ៗខិតខំបង្កើនអក្ខរាវិរុទ្ធ និងខិតខំកែលម្អរចនាបថភាសារបស់ខ្លួន ឱ្យបានច្បាស់លាស់ត្រឹមត្រូវ និងសម្តែងចេញនូវរូបារម្មណ៍ឱ្យបានច្រើន ។

### គ. ភាសាបុគ្គល និង ឫកពា

តាមរយៈភាសាបុគ្គល ធ្វើឱ្យយើងស្គាល់អំពីឫកពារបស់អ្នកដែលកំពុងនិយាយ ។
ឧទាហរណ៍ ៖ មនុស្សសម្តីផ្អែម សុភាព ទន់ភ្លន់ នេះ បង្ហាញពីឫកពាសុភាពរាបសាររបស់អ្នកនិយាយ ។

### ឃ. ភាសាបុគ្គល និងសម្បទា

តាមរយៈភាសាបុគ្គល អាចឱ្យយើងស្វែងយល់ពីសមត្ថភាពរបស់មនុស្សដែលកំពុងនិយាយ ។
ឧទាហរណ៍ ៖ ពេលយើងធ្វើសម្ភាសន៍ជ្រើសរើសបុគ្គលិកមុននឹងឱ្យចូលបម្រើការងារ ។

## ៨. ការរីកលូតលាស់ភាសាវ័យជំទង់

ជាទូទៅ ការរីកលូតលាស់ភាសារបស់ជំទង់ ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការអភិវឌ្ឍនៃការគិត គុណសម្បត្តិផ្នែកសីលធម៌ រូបារម្មណ៍ និងលំនាំនៃការសិក្សា។ ពេលចូលដល់វ័យជំទង់ ជំទង់ចាប់ផ្តើមចូលទៅសិក្សានៅមធ្យមសិក្សា។ សកម្មភាពសិក្សាបើកទូលាយនូវចំណេះដឹងគ្រប់វិស័យ។ ហេតុនេះពាក្យបច្ចេកទេស និងបញ្ញត្តិវិទ្យាសាស្ត្រក៏កើនឡើងយ៉ាងឆាប់រហ័ស។ ការក្តាប់បាននូវប្រព័ន្ធបញ្ញត្តិច្រើន ហើយសំបូរបែបធ្វើឱ្យចលនានៃការគិតរីកចម្រើន និងមានការស្មុគស្មាញ ការយល់ស៊ីជម្រៅទៅលើខ្លឹមសារ ឯកសារក៏កើតមានឡើងដូចជា សមត្ថភាពវិភាគ អរូបកម្ម ទូទៅកម្ម ប្រៀបធៀប និងធ្វើសំយោគ។

ភាសាជាតិដែលបង្រៀននៅសាលារៀនចំណេះទូទៅ ជួយឱ្យភាសាជំទង់កាន់តែសំបូរបែប មានបំណិនក្នុងការ

ប្រើប្រាស់បានច្បាស់លាស់ និងប្រកបដោយរូបភាពពិតផង ។

ជាគោលការណ៍ភាសាក្នុងរបស់មនុស្សម្នាក់ៗមានការរីកចម្រើនដូចភាសាក្រៅដែរ នៅដំណាក់វ័យជំទង់នេះ ។ ភាសាក្នុងសម្ដែងចេញតាមទម្រង់ឯកវាទវិធី។ ជំទង់យកចិត្តទុកដាក់នឹងការប្រែប្រួលជីវិតក្នុងរបស់គេ នេះគឺជាការលេចឡើងនូវសញ្ចេតនាថ្មី ការគិតថ្មី...។ ព្រោះជំទង់ចាប់ផ្ដើមចេះវិភាគសញ្ចេតនា ចេះប៉ាន់ប្រមាណនូវគំនិតបុគ្គលរបស់ខ្លួនបានខ្លះហើយ ។ ភាសាក្នុង និងភាសាក្រៅត្រូវបានជំទង់យកមកប្រើជាមធ្យោបាយសម្រាប់ការវាយតម្លៃ កែតម្រូវ និងអប់រំខ្លួនឯង។ ប៉ុន្តែនៅមានគុណវិបត្តិខ្លះក្នុងការរីកលូតលាស់ភាសារបស់ជំទង់ ដែលអ្នកអប់រំត្រូវយកចិត្តទុកដាក់ និងតាមដានព្រោះទន្ទឹមនឹងការក្ដាប់បាននូវបញ្ញត្តិវិទ្យាសាស្ត្រ និងអក្ខរាវិរុទ្ធ ជំទង់ក៏ចេះប្រើ និងយល់ពាក្យសម្ដីខ្លះដែលគេមិនលើកយកមកបង្រៀនទៀតផង។

## IV- សន្និដ្ឋាន

សកម្មភាពភាសាបុគ្គលមិនគ្រាន់តែជាឧបករណ៍នៃការគិត ឬគ្រាន់តែជាមធ្យោបាយសម្រាប់ទាក់ទងប៉ុណ្ណោះទេ តែថែមទាំងផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងបាតុភូតចិត្តរបស់បុគ្គលទៀតផង ។ ភាសាត្រូវឯកភាពជាមួយនឹងការរីកលូតលាស់នៃការគិត និងមនសិការ ។ ឯគុណសម្បត្តិនៃបុគ្គលិកលក្ខណៈ ក៏ត្រូវបានសម្ដែងចេញតាមរយៈសកម្មភាព ភាសាបុគ្គលផងដែរ ។

### សំណួរ

១. ភាសាជាតិ និងភាសាបុគ្គលខុសគ្នាដូចម្ដេច?

២. តើភាសាបុគ្គលមានតួនាទីយ៉ាងដូចម្ដេចក្នុងជីវិតពិតរបស់មនុស្ស?

៣. ហេតុអ្វីបានជាគេនិយាយថា ភាសាក្នុង ជាមធ្យោបាយសម្រាប់ការគិត?

៤. តើគ្រូបង្រៀនគប្បីធ្វើដូចម្ដេច ដើម្បីឱ្យភាសារបស់សិស្សមានការអភិវឌ្ឍ?

# មេរៀនទី១០ បម្រុងប្រយ័ត្ន

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់បានពីបញ្ញត្តិ ចំណែកថ្នាក់ និងមូលដ្ឋានគ្រឹះនៃបម្រុងប្រយ័ត្ន
- កំណត់បានពីសារៈសំខាន់នៃបម្រុងប្រយ័ត្ន
- ឈ្លាសវៃក្នុងការរកវិធានការទាក់ទាញបម្រុងប្រយ័ត្នសិស្សក្នុងម៉ោងសិក្សាបានល្អ ។

## II- សេចក្តីផ្តើម

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គេតែងតែជួបប្រទះជានិច្ចនឹងករណីដែលមនុស្សត្រូវការស្តាប់ សម្លឹងមើល ឬអនុវត្តការងារណាមួយយ៉ាងយកចិត្តទុកដាក់រហូតស្ទើរតែមិនដឹងអ្វីៗ ដែលប្រព្រឹត្តនៅជុំវិញគេផង ។ ការប្រមូលផ្តុំគំនិតបែបនេះគឺ បម្រុងប្រយ័ត្ន។

## III- ខ្លឹមសារ

### ១. និយមន័យ

បម្រុងប្រយ័ត្នជាសភាពចិត្តមួយ ដែលតាមជាប់នឹងលំនាំចិត្ត ហើយមាននាទីប្រមូលលំនាំចិត្តនោះបាញ់ឆ្ពោះទៅរកទិសដៅណាមួយជាក់លាក់ ដើម្បីឆ្លុះបញ្ចាំងវត្ថុនោះឱ្យបានច្បាស់លាស់ ។

បម្រុងប្រយ័ត្ន គឺជាសភាពចិត្ត ដែលបង្ហាញសកម្មភាពជុំវិញចិត្តរបស់មនុស្ស ក្នុងរយៈពេលមួយច្បាស់លាស់ចំពោះវត្ថុមួយ ឬបាតុភូតមួយ ឬសកម្មភាពមួយ ។ បម្រុងប្រយ័ត្នអាស្រ័យទៅតាមជម្រើស (អ្វីដែលមិនមែនជាគោលដៅបម្រុងប្រយ័ត្ន ចំណាប់អារម្មណ៍មានតិចតួច ឬក៏គ្មានចំណាប់អារម្មណ៍ទាល់តែសោះ) លក្ខណៈបុគ្គល (កកើតឡើងដោយភាពខុសគ្នាតាមបុគ្គលនីមួយៗ)ស្ថានភាព(បុគ្គលនីមួយៗមានបម្រុងប្រយ័ត្នក្នុងស្ថានភាពផ្សេងគ្នា) អាស្រ័យទៅនឹងឱកាសនៃការអប់រំ និងការហ្វឹកហ្វឺន ។

- បម្រុងប្រយ័ត្នក្នុងការស្តាប់ (ស្តាប់ដោយយកចិត្តទុកដាក់)

  ឧទាហរណ៍៖ បម្រុងប្រយ័ត្នរបស់សិស្សក្នុងពេលសិក្សា ស្តាប់ការពន្យល់មេរៀនរបស់គ្រូ ។

- បម្រុងប្រយ័ត្នក្នុងការមើល (មើលដោយយកចិត្តទុកដាក់)

  ឧទាហរណ៍ ៖ សិស្សទាំងអស់កំពុងស្តាប់គ្រូពន្យល់មេរៀនដោយយកចិត្តទុកដាក់ បានន័យថាសិស្សប្រើភ្នែកសម្លឹងមើលក្តារខៀន និងកាយវិការរបស់គ្រូ ត្រចៀកផ្ទៀងស្តាប់ការពន្យល់ ហើយដៃកត់ត្រាអត្ថន័យសំខាន់ៗ។ សកម្មភាពទាំងនេះកំពុងតាមជាប់នឹងសកម្មភាពចិត្តមួយគឺ បម្រុងប្រយ័ត្ន ។

គេអាចនិយាយបានថា បម្រុងប្រយ័ត្នជាសភាពចិត្ត ដែលតាមជាប់ជាមួយនឹងលំនាំពុទ្ធិប៉ុណ្ណោះ ។

នៅក្នុងពិភពយើងនេះ អ្វីៗមានច្រើនណាស់ហើយប្លែកៗទៀតផង យើងមិនអាចស្គាល់វត្ថុទាំងនោះក្នុងពេលជាមួយគ្នាតែម្តងបានទេ ។ បម្រុងប្រយ័ត្នអាចជួយឱ្យយើងផ្តោតអារម្មណ៍ទៅលើវត្ថុណាមួយតាមការជ្រើសរើស ដើម្បីឆ្លុះបញ្ចាំង ឬស្គាល់វត្ថុនោះឱ្យបានច្បាស់លាស់។

- **បម្រុងប្រយ័ត្នបានកើតក្នុងពលកម្មបញ្ញា និងពលកម្មកម្លាំងកាយ**

យើងជាគ្រូបង្រៀនត្រូវផ្តល់ទម្លាប់ និងអប់រំយុវសិស្សឱ្យមានបម្រុងប្រយ័ត្នលើការសិក្សាក្នុងថ្នាក់ ក្នុងបន្ទប់ពិសោធន៍ ចេះតាមដានការបកស្រាយពន្យល់មេរៀនរបស់គ្រូក្នុងពេលបង្រៀន និងក្នុងពេលធ្វើកិច្ចការដែលគ្រូដាក់ឱ្យធ្វើនៅក្នុងថ្នាក់ ឬនៅផ្ទះ ។

សរុបមក បម្រុងប្រយ័ត្នជាប្រភពនៃការផ្តោតស្មារតី និងការទទួលខុសត្រូវលើអ្វីដែលល្អ និងមានប្រយោជន៍

ដល់ជីវភាពរស់នៅ និងក្នុងការងារសង្គម ។

## ២. បំណកស្រាយ ពន្យល់ តាមបែបសរីរសាស្ត្រ

តាមសរីរវិទ្យា គេពន្យល់បម្រុងប្រយ័ត្នតាមសភាពចិត្តនេះដូចតទៅ ៖

ក. កាលណារំញោចមួយកើតមានឡើង ប្រព័ន្ធសរសៃប្រសាទទាំងមូលធ្វើប្រតិកម្មទៅរកទិសនៃរំញោចតាមទ្រឹស្តីរ៉េផ្លិចតម្រង់ទិសរបស់លោក ប៉ាវឡូវ ដែលមានលក្ខណៈដូចតទៅ ៖

- រ៉េផ្លិចកើតឡើងឯងៗ មិនថាមនុស្ស ឬសត្វ
- រ៉េផ្លិចនេះកើតមានជានិច្ច ឱ្យតែរំញោចនោះមានលក្ខណៈថ្មីប្លែកពីធម្មជាតិ ។
- រ៉េផ្លិចនេះបាត់បង់ទៅវិញ កាលណារំញោចមានលក្ខណៈច្រំដែល នេះជារ៉េផ្លិចគ្មានលក្ខខណ្ឌ ។
- រ៉េផ្លិចគ្មានលក្ខខណ្ឌនេះមានប្រភេទពិសេសមួយដែលរួមមាន ៖
  - ការតម្រង់ទិសសរីរាង្គឥន្ទ្រីយ៍ទៅរកវត្ថុភ្ញោចដែលស្ថិតនៅក្រោមការបញ្ជារបស់មជ្ឈមណ្ឌលសរសៃប្រសាទ ។
  - ការត្រៀមរបស់សព៌ាង្គកាយ ដើម្បីធ្វើប្រតិកម្មនឹងរំញោច ។

ខ. សភាពនៃបម្រុងប្រយ័ត្នសម្តែងចេញនូវកិរិយាបថមួយចំនួន ៖

- ការសម្លឹងអ្វីមួយដោយដក់ចិត្តសឹងតែមិនព្រិចភ្នែក ហៅថាបម្រុងប្រយ័ត្ននៃចក្ខុវិញ្ញាណ ។
- ការសម្លឹងទៅឆ្ងាយដោយជ្រួញចិញ្ចើម ហៅថាបម្រុងប្រយ័ត្នឆ្ពោះទៅរកពិភពខាងក្រៅ ។
- ការស្តាប់ដោយចំហមាត់ ហៅថាបម្រុងប្រយ័ត្ននៅក្នុងប្រត្យក្សារម្មណ៍នៃសោតវិញ្ញាណ ។

ជួនកាលបម្រុងប្រយ័ត្នប្រព្រឹត្តទៅរួមជាមួយនឹងកាយវិការ ដែលសម្របសម្រួលតាមចលនានៃ វត្ថុ ។

ឧទាហរណ៍៖ កុមារធ្វើចលនាមាត់ បបូរមាត់ និងដងខ្លួន កាលណាគេគូររូបភាពអ្វីមួយ។

## ៣. ចំណែកថ្នាក់ របស់បម្រុងប្រយ័ត្ន

គេចែកបម្រុងប្រយ័ត្នជាពីរប្រភេទគឺ **បម្រុងប្រយ័ត្នមិនគ្រោងទុកជាមុន** និង**បម្រុងប្រយ័ត្នគ្រោងទុក ជាមុន**។

### ៣.១. បម្រុងប្រយ័ត្នមិនគ្រោងទុកជាមុន(បម្រុងប្រយ័ត្នធម្មជាតិ ឬ បម្រុងប្រយ័ត្នអចន្ទៈ)

បម្រុងប្រយ័ត្នមិនគ្រោងទុកជាមុន លេចឡើងកាលណាមានវត្ថុភ្ញោចថ្មីកើតមានចំពោះបុគ្គល ។

ឧទាហរណ៍ ៖ ពេលកំពុងស្តាប់គ្រូពន្យល់ ស្រាប់តែមានយន្តហោះមួយហោះយ៉ាងទាបពីលើអគារសិក្សា វត្ថុភ្ញោចថ្មីនេះ ធ្វើឱ្យសិស្សទាំងអស់បែរបម្រុងប្រយ័ត្នទៅរកសំឡេងថ្មីនេះ (យន្តហោះ) ជាមិនខានគឺបម្រុងប្រយ័ត្នមិនគ្រោងទុកមុន ។

បម្រុងប្រយ័ត្ននេះ មិនបញ្ជាដោយមនសិការទេឡើយ ហើយក៏មិនផ្អែកទៅលើមធ្យោបាយពិសេសណាមួយដែរ ។ បម្រុងប្រយ័ត្នមិនគ្រោងទុកមុន កើតមានអាស្រ័យដោយចរិតលក្ខណៈនៃវត្ថុ ឬបាតុភូតដូចជា កម្លាំងនៃរំញោច ភាពផ្ទុយគ្នារវាងវត្ថុភ្ញោចនឹងមជ្ឈដ្ឋាន និងទំនាក់ទំនងរវាងវត្ថុ ឬបាតុភូតនឹងទំនោររបស់បុគ្គល(តម្រូវការ ចំណូលចិត្ត) ។

ឧទាហរណ៍៖ យើងកំពុងអង្គុយញុំាបាយក្នុងអាហារដ្ឋានមួយ ស្រាប់តែឮសូរកែវធ្លាក់ ។ ពេលនោះយើងបែរបម្រុងប្រយ័ត្នទៅរកសំឡេងថ្មីដោយរិះគិត(នេះគឺបម្រុងប្រយ័ត្នមិនគ្រោងទុកមុន ដែលកើតមានពីកម្លាំងរំញោចសំឡេងកែវធ្លាក់) រកប្រភពដែលនាំឱ្យធ្លាក់កែវបែក ។

ទំនាក់ទំនងរវាងវត្ថុភ្ញោចនឹងទំនោររបស់បុគ្គល(តម្រូវការ ចំណូលចិត្ត) ។

ឧទាហរណ៍ ៖ សិស្សដែលមានចំណូលចិត្តខាងគណិតវិទ្យា ពេលចូលទៅបណ្ណាគារភ្នែកគេរំពៃរកតែសៀវភៅគណិតវិទ្យា ។

ដូចនេះ បម្រុងប្រយ័ត្នមិនគ្រោងទុកមុន កើតមានដោយគ្មានបំណងគិតទុកមុន និងគ្មានការប្រឹងប្រែងពីផ្លូវ

កាយ ក៏ដូចជាផ្លូវចិត្តដែរ ។ ប៉ុន្តែបម្រុងប្រយ័ត្ននេះមានរយៈពេលខ្លី ។

### ៣.២. បម្រុងប្រយ័ត្នគ្រោង ទុកមុន(បម្រុងប្រយ័ត្នឆន្ទៈ)

បម្រុងប្រយ័ត្នគ្រោងទុកមុន គឺជាប្រភេទបម្រុងប្រយ័ត្នដែលបញ្ជាដោយមនសិការ និងប្រព្រឹត្តទៅ តាមផែនការមួយកំណត់ និងផ្អែកលើមធ្យោបាយជាក់លាក់ ។

បម្រុងប្រយ័ត្ននេះត្រូវបានកើតឡើងក្នុងការបង្រៀន ការរៀន ការធ្វើពលកម្ម និងល្បែង។ ចរិត លក្ខណៈផ្លូវចិត្តនៃបម្រុងប្រយ័ត្នគ្រោងទុកមុន តម្រូវឱ្យប្រធានមានការប្រឹងប្រែងប្រកបដោយឆន្ទៈ ។

ឧទាហរណ៍៖ ដើម្បីបង្រៀនសិស្ស គ្រូត្រូវប្រឹងយកចិត្តទុកដាក់រៀបចំមេរៀន និងពន្យល់សិស្ស (នេះគឺបម្រុងប្រយ័ត្នគ្រោងទុកមុន) ។

ឧទាហរណ៍៖ កីឡាករកំពុងបណ្ដើរបាល់សំដៅទៅបញ្ចូលទី ទស្សនិកជនរាប់ពាន់នាក់នាំគ្នាផ្ដោតបម្រុងប្រយ័ត្នទៅលើបាល់នោះយ៉ាងខ្លាំង(ល្បែង) ។

ឧទាហរណ៍៖ ថ្ងៃស្អែកត្រូវប្រឡង យប់នេះសិស្សខំទន្ទេញមេរៀនដោយយកចិត្តទុកដាក់(ការរៀន) ។

ក្នុងការបង្រៀន គ្រូមាននាទីនឹងប្ដូរបម្រុងប្រយ័ត្នមិនគ្រោងទុកមុន ឱ្យទៅជាបម្រុងប្រយ័ត្នគ្រោងទុកមុន ដើម្បីឱ្យការសិក្សារបស់សិស្សទទួលលទ្ធផលល្អ និងបន្ថយភាពហត់នឿយក្នុងការសិក្សាថែម ទៀត ។

ឧទាហរណ៍៖ ក្នុងមេរៀនជីវវិទ្យាមួយ គ្រូយកសត្វព្រាបចូលទៅក្នុងថ្នាក់។ លក្ខណៈទាំងមូលរបស់សត្វព្រាបអាចទាញបម្រុងប្រយ័ត្នសិស្ស(បម្រុងប្រយ័ត្នមិនគ្រោងទុកមុន)។ ប៉ុន្តែ បើគ្រូចេះចោទសួរជាសំណួរថា តើចំពុះវាដូចម្ដេច? ពេលនោះសិស្សចាប់ផ្ដោតបម្រុងប្រយ័ត្នទៅលើចំពុះព្រាបដោយយកចិត្តទុកដាក់ (បម្រុងប្រយ័ត្នគ្រោងទុកមុន) ។

### ៤. លក្ខណៈ ជាមូលដ្ឋាន គ្រឹះ នៃបម្រុងប្រយ័ត្ន (Propriétés fondamentales de l'attention )

បម្រុងប្រយ័ត្នឆន្ទៈ និងបម្រុងប្រយ័ត្នអឆន្ទៈ មានលក្ខណៈពិសេសមួយចំនួន ដែលអាចឱ្យគេញែកដាច់ពីគ្នាបានយ៉ាងងាយ។ វាជាការសំខាន់ណាស់ ដើម្បីស្គាល់ច្បាស់អំពីលក្ខណៈពិសេសទាំងនេះពីព្រោះសកម្មភាពនីមួយៗរបស់មនុស្សយើងទាមទារនូវប្រភេទនៃបម្រុងប្រយ័ត្នដ៏សមស្រប ហើយបុគ្គលម្នាក់ៗមានលក្ខណៈពិសេសផ្សេងៗគ្នាខាងបម្រុងប្រយ័ត្ននេះ ។

#### ៤.១- ការផ្ដោត ស្មារ តីប្រុងប្រយ័ត្ន (La concentration de l'attention )

ការផ្ដោតស្មារតីប្រុងប្រយ័ត្ននេះ គឺជាការប្រើប្រាស់ចំណាំងទៅលើមជ្ឈដ្ឋាន ឬបញ្ហាអ្វីមួយដែលមានព្រំដែនកំណត់ច្បាស់លាស់ ។ ដរាបណាដែលមានការផ្ដោតស្មារតីប្រុងប្រយ័ត្នកាន់តែខ្លាំង ដរាបនោះការឆ្លុះបញ្ចាំងបានទៅលើ បញ្ហាអ្វីមួយក៏កាន់តែច្បាស់លាស់ឡើងដែរ។ ការផ្ចង់ស្មារតីប្រុងប្រយ័ត្ននេះ ត្រូវបានបកស្រាយពន្យល់តាមរយៈការកើតឡើងនូវរំញោចយ៉ាងខ្លាំងត្រង់តំបន់ណាមួយនៃស្រោមខួរក្បាល រីឯមជ្ឈដ្ឋានដែលស្ថិតនៅក្បែរតំបន់នេះជាមជ្ឈដ្ឋានដែលកាត់បន្ថយរំញោចនោះ។

ឧទាហរណ៍៖ វិចិត្រករ រ៉ូ ដាំង ភ្លេចគិតដល់មិត្តភក្តិរបស់គាត់ ដែលនាំគ្នាទៅមើលរូបចម្លាក់ដែលគាត់កំពុងឆ្លាក់ ពីព្រោះគាត់កំពុងតែផ្ចង់ស្មារតីរបស់គាត់ ដើម្បីនឹងឆ្លាក់រូបសំណាកមួយដែលមិនទាន់បានល្អ ។

#### ៤.២- បំណែងចែកនៃបម្រុងប្រយ័ត្ន (La répartition de l'attention )

ការបែងចែកនៃស្មារតីប្រុងប្រយ័ត្ន កើតមានឡើងនៅពេលណាដែលមនុស្សប្រើសតិផ្ចង់បម្រុងប្រយ័ត្នទៅលើវត្ថុ ឬ សកម្មភាពជាច្រើនក្នុងពេលជាមួយគ្នា។

ឧទាហរណ៍៖ នៅពេលបកស្រាយពន្យល់មេរៀន គ្រូបង្រៀនត្រូវផ្ដោតស្មារតីប្រុងប្រយ័ត្នទៅលើខ្លឹមសារនៃមេរៀនផង ទៅលើអាកប្បកិរិយារបស់សមូហភាពសិស្សក្នុងថ្នាក់ផង និងប្រើប្រាស់សម្ភារ

ឧបទេសផង ។

បទពិសោធន៍បានបង្ហាញឱ្យដឹងថា បម្រុងប្រយ័ត្នមិនបែងចែកផងទេនៅក្នុងអំពើដែលកើតឡើងបញ្ច្រាសគ្នា។ អំពើណាមួយនៅក្នុងចំណោមអំពើទាំងនោះ តែងតែមានឥទ្ធិពលខ្លាំងក្នុងការទាក់ទាញបម្រុងប្រយ័ត្ន រីឯអំពើផ្សេងទៀតមិនខ្លាំងក្លាត្រូវបានក្លាយទៅជាអំពើបន្ទាប់បន្សំ ។ ដើម្បីនឹងសម្រួលដល់ការបែងចែកនៃបម្រុងប្រយ័ត្ន ដែលកើតឡើងទៅលើអំពើដ៏ច្រើននេះ គេត្រូវឱ្យអំពើខ្លះនៃអំពើទាំងអស់នោះ ក្លាយទៅជាមានភាពស្និទ្ធស្នាល និងមានលក្ខណៈស្វ័យប្រវត្តិដើម្បីងាយស្រួលដល់ការផ្តោតស្មារតីប្រុងប្រយ័ត្នទៅលើអំពើទាំងឡាយ ដែលទើបនឹងកើតឡើងថ្មី ។

ឧទាហរណ៍៖ អ្នកវាយអង្គុលីលេខ ឬ វាយកុំព្យូទ័រដោយគ្រាន់តែប្រើភ្នែកសម្លឹងមើលអត្ថបទដែលត្រូវវាយ

ចម្លងប៉ុណ្ណោះ រីឯម្រាមដៃរបស់គេមានចលនារស់រវើកក្នុងការវាយតួអក្សរទៅតាមលក្ខណៈស្វ័យប្រវត្តិ។

សិស្សដែលតាមដានស្តាប់គ្រូពន្យល់ផង និងប្រើដៃកត់ត្រាខ្លឹមសារមេរៀនផង បានផ្តោតស្មារតីយ៉ាងខ្លាំងខាងការស្តាប់ចាប់បាន រីឯដៃសរសេរមានលក្ខណៈស្វ័យប្រវត្តិជាស្រេច ។

### ៤.៣- ទំហំនៃបម្រុងប្រយ័ត្ន (Volume de l'attention )

នេះគឺជាចំនួននៃវត្ថុបំណង ដែលបម្រុងប្រយ័ត្នក្រសោបយកបានក្នុងពេលជាមួយគ្នា ហើយនិងកម្រិតឆ្លុះបញ្ចាំងដែលមានភាពស្មើគ្នាផង។ ទំហំនៃបម្រុងប្រយ័ត្នជាអនុគមន៍នៃចំនួនវត្ថុបំណងនោះ ។

លក្ខណៈនៃបម្រុងប្រយ័ត្នបែបនេះមានភាពចាំបាច់ណាស់សម្រាប់គ្រូបង្រៀន ពីព្រោះគាត់ត្រូវផ្តោតស្មារតីប្រុងប្រយ័ត្នទៅលើហេតុផលជាច្រើនក្នុងពេលព្រមគ្នា កាលណាគាត់ត្រូវបកស្រាយពន្យល់ខ្លឹមសារនៃមេរៀនណាមួយ ។ គេអាចធ្វើទៅបានលុះត្រាតែគេមានបទពិសោធន៍ជាច្រើន ហើយគេធ្លាប់ស្គាល់វត្ថុបំណងទាំងនោះទៀតផង។

### ៤.៤- លំនឹងនៃបម្រុងប្រយ័ត្ន (Stabilité de l'attention )

នោះគឺជាសតិដែលផ្ចង់ស្មារតីប្រុងប្រយ័ត្នទៅលើវត្ថុណាមួយ ឬវត្ថុច្រើននៅក្នុងរយៈពេលមួយដ៏យូរបង្គួរដោយគ្មានគិតដល់ដំណើរប្រែប្រួលនៃវត្ថុបំណងផ្សេងទៀត ។

ឧទាហរណ៍៖ សិស្សបឋមសិក្សាអាចផ្ចង់ស្មារតីប្រុងប្រយ័ត្នស្តាប់គ្រូពន្យល់មេរៀនក្នុងរយៈពេលពី ១០ ទៅ ១៥ នាទី ។សិស្សអនុវិទ្យាល័យអាចផ្ចង់ស្មារតីបានពី ២០ទៅ២៥នាទី ។ សិស្សវិទ្យាល័យអាចផ្ចង់ស្មារតីបានពី ៤៥ ទៅ ៥០ នាទី ។

### ៤.៥- បន្លាស់ទីបម្រុងប្រយ័ត្ន (Le déplacement de l'attention)

បន្លាស់ទីបម្រុងប្រយ័ត្ន គឺជាសតិដែលផ្ចង់ស្មារតីប្រុងប្រយ័ត្នទៅលើវត្ថុបំណងមួយ ហើយផ្លាស់វត្ថុបំណងនោះឱ្យទៅជាករណីនៃតម្រូវការថ្មីតាមវត្ថុបំណងមួយផ្សេងទៀត ។ សតិនេះមិនអាចមានគ្រប់គ្នាទេ ។ មានសិស្សខ្លះក្នុងករណីផ្លាស់ប្តូរការសិក្សាពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ជួបការលំបាកយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរបម្រុងប្រយ័ត្ន។ រីឯសិស្សខ្លះទៀតផ្តោតស្មារតីប្រុងប្រយ័ត្នយ៉ាងងាយបំផុតទៅលើការសិក្សាមុខវិជ្ជា ថ្មីតាំងពីនាទីដំបូងម្ល៉េះ ។

សភាពបែបនេះ មិនមែនផ្ទុយនឹងស្ថេរភាពនៃបម្រុងប្រយ័ត្នទេ ហើយវាក៏ខុសប្លែកផងដែរពីការបែងចែកនៃបម្រុងប្រយ័ត្ន ។ បម្រុងប្រយ័ត្នចាកចោលយ៉ាងងាយបំផុតពីវត្ថុបំណងចាស់ ដើម្បីផ្តោតមកលើវត្ថុបំណងថ្មីតាមកម្លាំងដដែល ។ សតិនេះមានភាពចាំបាច់ណាស់សម្រាប់សិស្សនៅក្នុងមេរៀនសង្កេត និងការធ្វើពិសោធន៍ ។

## ៥. ការមិនធ្វេសប្រហែសជាលក្ខណៈមួយរបស់បុគ្គលិកលក្ខណៈ

ការមិនធ្វេសប្រហែសរបស់មនុស្សម្នាក់ចំពោះបញ្ហាមួយ គឺជាទិដ្ឋភាពមួយនៃបម្រុងប្រយ័ត្នដែលមានកម្រិតខ្ពស់ ហើយលក្ខណៈពិសេសនៃការមិនធ្វេសប្រហែសនេះ គឺជាទំនួលខុសត្រូវខ្ពស់ចំពោះមុខងារមួយជាក់លាក់ គឺជាជម្រៅសញ្ចេតនាចំពោះការងារទាំងឡាយ ។ មូលដ្ឋាននៃការមិនធ្វេសប្រហែស គឺជាបម្រុងប្រយ័ត្នគ្រោងទុកមុន ។ ភាពផ្ទុយនៃការមិនធ្វេសប្រហែស គឺជាភាពព្រងើយកន្តើយ ។ កាលណាគេព្រងើយកន្តើយ ចំពោះកិច្ចការនានា គឺមាន

ន័យថា គេបានបាត់បង់នូវភាពប្រុងប្រយ័ត្ន ដែលបណ្ដាលឱ្យគេមិនអាចធ្វើអ្វីបានជោគជ័យទាំងស្រុងនោះទេ ។

គេចាត់ទុកការមិនធ្វេសប្រហែស គឺជាលក្ខណៈមួយរបស់បុគ្គលិកលក្ខណៈ ពីព្រោះការបណ្ដុះទស្សនៈឧត្ដមគតិ ជំនឿជាក់របស់មនុស្សម្នាក់ៗ សុទ្ធតែផ្អែកលើបម្រុងប្រយ័ត្នរបស់គេ ចំពោះអ្វីៗទាំងអស់នៅក្នុងជីវភាពរស់នៅជានិច្ច ។

## IV- សន្និដ្ឋាន

ដើម្បីធ្វើឱ្យបម្រុងប្រយ័ត្នមានភាពប្រសើរចំពោះសិស្ស គ្រូត្រូវតែបង្ហាញនូវទិសដៅសកម្មភាពច្បាស់លាស់ ធ្វើការទាក់ទាញអារម្មណ៍ បង្កើនសកម្មភាពដល់សិស្សឱ្យបានច្រើន លៃលកឱ្យបានសមរម្យនូវពេលវេលាមិនត្រូវអូសបន្លាយការបង្រៀនហួសម៉ោងកំណត់ដែលនាំឱ្យសិស្សហត់នឿយធុញទ្រាន់ ហើយបាត់បម្រុងប្រយ័ត្ន ។ គ្រូត្រូវ ចេះប្រែប្រួលវិធី និងល្បិចបង្រៀន ដើម្បីចៀសវាងភាពច្រំដែលនាំឱ្យសិស្សមានភាពស៊ាំ ហើយបាត់បម្រុងប្រយ័ត្នត្រូវចេះប្រើពាក្យសម្ដី កុំប្រើសំឡេងដដែលៗ ដោយគ្មានការលើកដាក់ដែលនាំឱ្យសិស្សងងុយដេកត្រូវបង្រៀនដោយផ្ដើមចេញពីអ្វីដែលងាយទៅពិបាក ពីអ្វីដែលស្គាល់ទៅអ្វីដែលមិនស្គាល់ (ចំណេះដឹងដែលមានស្រាប់ទៅចំណេះដឹងថ្មី) ។

### សំណួរ

១. តើបម្រុងប្រយ័ត្នជាអ្វី ?

២. ចូរប្រៀបធៀបបម្រុងប្រយ័ត្នមិនគ្រោងទុកជាមុន និងបម្រុងប្រយ័ត្នគ្រោងទុកជាមុន ដោយលើកឧទាហរណ៍មកបញ្ជាក់។

៣. តើគ្រូបង្រៀនគប្បីធ្វើដូចម្ដេចដើម្បីឱ្យសិស្សមានបម្រុងប្រយ័ត្នល្អក្នុងម៉ោងសិក្សា ?

៤. តើគ្រូត្រូវធ្វើដូចម្ដេច ដើម្បីរក្សាបម្រុងប្រយ័ត្នសិស្សឱ្យបានយូរក្នុងពេលបង្រៀន ?

# មេរៀនទី១១ ឆន្ទៈ និង អំពើឆន្ទៈ

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់បានពីបញ្ញត្តិឆន្ទៈ អំពើឆន្ទៈ និងបំណងប្រាថ្នា
- ញែកបានអំពីបំណងប្រាថ្នា ឆន្ទៈ និងធ្វើការសម្រេចចិត្តបានត្រឹមត្រូវ
- មានទម្លាប់សម្រេចចិត្តយ៉ាងត្រឹមត្រូវ និងមានឆន្ទៈមោះមុតក្នុងការបង្រៀន ។

## II- សេចក្តីផ្តើម

ពេលមានទង្វើ មនុស្សមិនគ្រាន់តែស្គាល់ពិភពជុំវិញខ្លួន និងស្វែងចេញនូវសញ្ចេតនាប៉ុណ្ណោះទេ ប៉ុន្តែមនុស្សថែមទាំងធ្វើអំពើទៅលើតថភាពសត្យានុម័ត ដើម្បីប្រែក្លាយតថភាពសត្យានុម័តនោះ ឱ្យទៅជាតម្រូវការផ្ទាល់ខ្លួន និងតម្រូវការរបស់សង្គមទៀតផង ។ មនុស្សអាចធ្វើរបៀបនេះពីព្រោះ គេមានឆន្ទៈ ហើយគេស្តែងចេញនូវឆន្ទៈនេះនៅក្នុងទង្វើរបស់គេ ។

## III. ខ្លឹមសារ

### ១. និយមន័យ

#### ក. ឆន្ទៈ

ឆន្ទៈ ជាលំនាំចិត្តដែលតម្រង់ទិសសកម្មភាពរបស់មនុស្ស ឱ្យឆ្ពោះទៅរកគោលបំណងមួយជាក់លាក់ ហើយបំពេញសកម្មភាពទាំងនេះដោយភ្ញាក់រឭក និងជម្នះនូវឧបសគ្គ ឬការលំបាកទាំងឡាយ ដើម្បីឈោងចាប់គោលបំណងនេះ។

ឧទាហរណ៍ ៖ គោលបំណងចង់ក្លាយជាគ្រូមធ្យមសិក្សាបឋមភូមិត្រូវមាន ៖

- ការបំពេញលក្ខខណ្ឌ៖ ប្រឡងចូលមកសិក្សានៅតាមមជ្ឈមណ្ឌលគរុកោសល្យ ។
- សកម្មភាព៖ ខិតខំរៀនសូត្រស្វែងយល់មូលដ្ឋានចិត្ត-គរុកោសល្យ សិក្សាស្រាវជ្រាវនូវមុខវិជ្ជាឯកទេសឱ្យបានច្បាស់លាស់ យល់ដឹងពីវិធីសាស្ត្របង្រៀន និងហាត់ពត់អប់រំលើផ្នែកសីលធម៌ ដើម្បីធ្វើជាគំរូដល់សិស្ស ។
- ការលំបាក៖ ស្នាក់នៅក្នុងអន្តេវាសិកដ្ឋាន ឃ្លាតឆ្ងាយពីឪពុកម្តាយ ។

ប្រការនេះជាការតាំងចិត្តដោយឆន្ទៈផ្ទាល់ខ្លួន ដើម្បីសម្រេចតាមគោលបំណង ។

រួមសេចក្តីមក ឆន្ទៈរបស់មនុស្សសម្តែងចេញឱ្យឃើញក្នុងសកម្មភាពអំពើជានិច្ច ហើយអំពើទាំងនោះហៅថា អំពើឆន្ទៈ ។

#### ខ. អំពើឆន្ទៈ

អំពើឆន្ទៈ ជាអំពើប្រកបដោយញាណជានិច្ច ដែលដឹកនាំឆ្ពោះទៅរកគោលបំណងមួយជាក់លាក់ ហើយដែលទាក់ទងទៅនឹងការប្រឹងប្រែង ដើម្បីជម្នះគ្រប់ឧបសគ្គ និងការលំបាកដើម្បីសម្រេចគោលបំណងនោះ ។

ឧទាហរណ៍៖ មើលសិល្បៈ ដោះស្រាយចំណោទ អំពើរបស់កុមាររៀនសរសេរដំបូង។

ក្នុងអំពើឆន្ទៈ មនុស្សតែងតែធ្វើការជ្រើសរើស ដោយគិតទុកជាមុននូវមធ្យោបាយ និងរបៀបប្រតិបត្តិ ដើម្បីនឹងសម្រេចគោលបំណងនោះ ។ បុគ្គលនីមួយៗត្រូវខំប្រឹងប្រែងយ៉ាងស្វាហាប់ និងមានទស្សនៈត្រឹមត្រូវច្បាស់លាស់ និងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ដើម្បីឈានទៅសម្រេចរាល់ការលំបាក និងឧបសគ្គទាំងឡាយក្នុងសកម្មភាពឆ្ពោះទៅរកការបំពេញតាមគោលបំណង និងទិសដៅមួយពិតប្រាកដ ដោយស្មារតីទទួលខុសត្រូវខ្ពស់។

## ២. លក្ខណៈ ខុសគ្នារវាងអំពើឆន្ទៈ និងអំពើអឆន្ទៈ

ក្នុងជីវភាពរស់នៅ យើងតែងតែជួបប្រទះនូវអំពើឆន្ទៈ អំពើអឆន្ទៈ។

### ២.១. អំពើឆន្ទៈ

អំពើឆន្ទៈស្ថិតនៅជាអំពើប្រកបដោយការភ្ញាក់រឭកជានិច្ច ។ ឆន្ទៈស្តែងឱ្យឃើញក្នុងករណីនេះតាមរយៈការកំណត់នូវគោលបំណងនៃអំពើ តាមរយៈជម្រើសដែលគិតទុកជាមុននូវមធ្យោបាយ ល្បិចនៅក្នុងការប្រតិបត្តិ និងក្នុងកិច្ចខិតខំប្រឹងប្រែង សំដៅសម្រេចបាននូវភារកិច្ច ។

អំពើឆន្ទៈ ឬអំពើចេតនាមិនមែនជាអំពើដែលកើតឡើងឯកឯងហើយស្ថិតនៅដាច់ស្រឡះពីមូលហេតុនោះទេ។ នៅក្នុងករណីនេះ យើងត្រូវមានទស្សនៈមួយដ៏ត្រឹមត្រូវ និងប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។ យើងត្រូវប្រឆាំងយ៉ាងស្វាហាប់ទល់នឹងទស្សនៈផ្ទុយនឹងវិទ្យាសាស្ត្រ និងទស្សនៈប្រតិបត្តិ ដែលចាត់ទុកឆន្ទៈរបស់មនុស្សជាកម្លាំងស្មារតីម្យ៉ាងដោយឡែកដែលស្ថិតនៅដាច់ស្រឡះពីមូលហេតុជាសត្យានុម័ត ពីលំនាំសរីរៈវិទ្យានៃសព៌ាង្គកាយហើយដឹកនាំអំពើរបស់មនុស្សទាំងអស់។

តាមទស្សនៈវិទ្យាសាស្ត្រដ៏ត្រឹមត្រូវគេបានកំណត់ថា អំពើឆន្ទៈរបស់មនុស្សទទួលរងជានិច្ច នូវលក្ខខណ្ឌសង្គមប្រវត្តិដែលមនុស្សរស់នៅ និងប្រព្រឹត្តអំពើ។

### ២.២. អំពើអឆន្ទៈ

អំពើអឆន្ទៈ គឺកើតឡើងដោយរ៉េផ្លិចឥតលក្ខខណ្ឌដូចជា ការប៉ប្រិចភ្នែក ការក្អក ការរលាស់ដៃ ពេលប៉ះកម្ដៅ ការក្ដាប់ដៃ។ល។ រួមទាំងលក្ខណៈធម្មជាតិរបស់មនុស្សពីកំណើតខ្លះទៀត ក៏បង្ហាញពីអំពើអឆន្ទៈផងដែរដូចជា មុខឡើងក្រហម ឬស្លេកស្រពោកក្រហមពេលមានភាពរំភើបអ្វីមួយកើតឡើង។ល។ ដែលគេអាចនិយាយបានថាជាអំពើអឆន្ទៈ ពោលគឺលំនាំនៃអំពើដែលប្រព្រឹត្តទៅដោយអចេតនា ឬជាអំពើសភាវគតិ ។

ជាទូទៅអំពើអឆន្ទៈកើតឡើងតាមបែបអចេតនា ហើយពេលខ្លះអំពើទាំងនោះត្រូវបានគេស្គាល់ នៅពេលដែលមនុស្សធ្វើអំពើ ហើយសកម្មភាពនៃអំពើនោះ បានសម្ដែងចេញមកក្រៅតាមរយៈឥរិយាបថរបស់បុគ្គលនីមួយៗ ។

## ៣. ដំណាក់កាលសំខាន់ៗនៃអំពើឆន្ទៈ

អំពើឆន្ទៈមានដំណាក់កាលសំខាន់ៗដូចតទៅ ៖

### ក. កំណើតនៃសេចក្តីប្រាថ្នា

សេចក្តីប្រាថ្នា កើតឡើងពីតម្រូវការរបស់មនុស្ស។ សេចក្តីប្រាថ្នារបស់មនុស្សមានទំហំធំណាស់ហើយមានភាពប្លែកៗ និងស្មុគស្មាញផង។ គេចែកសេចក្តីប្រាថ្នារបស់មនុស្សជាពីរប្រភេទ ៖

**ក.១. បំណង៖** គឺជាសេចក្តីប្រាថ្នាមិនជាក់លាក់ដែលមានកម្រិតទាបមិនទាន់ប្រាកដប្រជា ហើយគ្រាន់តែកើតមាននៅក្នុងអារម្មណ៍។ បំណងជាសភាពចិត្តដែលមិនទាន់មានសញ្ញាណច្បាស់លាស់នៅក្នុងគំនិត ។

ឧទាហរណ៍៖ បំណងទៅមើលភាពយន្ត បំណងទិញកង់ ។ល។

**ក.២. ចំណង់៖** គឺជាសេចក្តីប្រាថ្នា ដែលគេចាប់អារម្មណ៍បានច្បាស់ជាបង្គួរ ។ មនុស្សដែលមានចំណង់គឺជាអ្នកដែលស្គាល់គោលបំណងច្បាស់លាស់នៃសេចក្តីប្រាថ្នារបស់ខ្លួន ។

ឧទាហរណ៍៖ ចង់ធ្វើជាគ្រូមធ្យមសិក្សាបឋមភូមិ គឺត្រូវខិតខំរៀនសូត្រដើម្បីនឹងប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រៀបចំសំណុំលិខិតសុំចូលប្រឡង និងទទួលបានជោគជ័យចូលរៀនវគ្គបណ្តុះបណ្តាលនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ។

### ខ. ការប្រយុទ្ធក្នុងចិត្ត និងការសម្រេចចិត្ត

លំនាំនៃការជ្រើសរើសសេចក្តីប្រាថ្នា គោលបំណង មធ្យោបាយ និងល្បិចផ្សេងៗដែលសមស្របនឹងចិត្តរបស់

គេតែងតែមានលក្ខណៈប្រយុទ្ធក្នុងចិត្តជានិច្ច។ ការប្រយុទ្ធក្នុងចិត្ត គឺពិតជាការប្រយុទ្ធរវាងហេតុផលនៃអំពើរបស់មនុស្ស ដើម្បីថ្លឹងថ្លែងរកផលល្អ ឬអាក្រក់មុននឹងសម្រេចចិត្តអនុវត្ត។ គេហៅការប្រយុទ្ធក្នុងចិត្តនេះថា ការប្រយុទ្ធរវាងហេតុផល ។

ឧទាហរណ៍៖ ចង់ធ្វើជាគ្រូបង្រៀន ចង់ធ្វើជាអ្នកបច្ចេកទេសជំនាញខាងអេឡិចត្រូនិច ចង់ធ្វើជាអ្នកជំនួញឯកខាងអគ្គិពលកម្ម ... ។

ការប្រយុទ្ធក្នុងចិត្ត ត្រូវតែបញ្ចប់ដោយការសម្រេចចិត្តមួយ។ ការសម្រេចចិត្តឈប់នៅត្រឹមគោលបំណងមួយដែលគេបានកំណត់នៅត្រឹមល្បិច និងមធ្យោបាយចាំបាច់ក្នុងការឈោងចាប់នូវគោលបំណងនោះ។

ដូចនេះអំពើឆន្ទៈខុសប្លែកគ្នាពីអំពើអឆន្ទៈ ដោយអំពើឆន្ទៈជំរុញមនុស្សតាមរយៈការផុសចេញនូវមូលហេតុមួយដ៏ជាក់លាក់ ហើយផ្ដើមចេញនូវការតស៊ូរវាងការផុសចេញនូវមូលហេតុ និងគំនិតជាច្រើនប្រកបដោយវិចារណញ្ញាណ ធ្វើឱ្យមនុស្សកើតមាននូវសេចក្ដីប្រាថ្នា គោលបំណង និងមធ្យោបាយ។ ករណីនេះអាចទទួលផលជាវិជ្ជមាន និងអវិជ្ជមាន ពោលគឺភាពពេញចិត្ត និងមិនពេញចិត្តនូវអំពើដែលខ្លួនបានប្រព្រឹត្ត ។

រួមសេចក្ដីមក ការសម្រេចចិត្ត អាស្រ័យដោយមូលហេតុជាច្រើនគួបផ្សំគ្នា ជាពិសេសគឺតម្រូវការ កម្លាំងនៃការផុសចេញនូវមូលហេតុ ស្ថានភាពជាក់ស្ដែង សភាពចិត្តផ្នែកសញ្ចេតនា កម្រិតវប្បធម៌ បទពិសោធ ចំណេះដឹង មតិយោបល់ពីមជ្ឈដ្ឋានជុំវិញការផ្ដល់ការទូន្មានពីអ្នកជិតខាង ឬអ្នកអប់រំផ្ទាល់ ។ល។

### គ. ការអនុវត្តការ សម្រេចចិត្ត

គឺជាដំណាក់សំខាន់នៃអំពើឆន្ទៈ ។ ការអនុវត្តក្នុងការសម្រេចចិត្ត ជាដំណាក់ចុងក្រោយនៃអំពើឆន្ទៈ ។ បើគ្មានដំណាក់នេះទេ ឆន្ទៈពុំអាចលេចរូបរាងបានឡើយ ហើយមនុស្សយើងក៏ពុំអាចមានឆន្ទៈដែរ ។ ដើម្បីអនុវត្តការសម្រេចចិត្តនេះ គេត្រូវជ្រើសរើស និងប្រើគ្រប់មធ្យោបាយ ។

ឧទាហរណ៍៖ បន្ទាប់ពីសម្រេចចិត្តចូលធ្វើជាគ្រូមធ្យមសិក្សាបឋមភូមិ យើងត្រូវមានការរៀបចំសំណុំលិខិតផ្ទាល់ខ្លួន និងឯកសារផ្សេងៗទៀត ដែលមជ្ឈមណ្ឌលតម្រូវឱ្យបំពេញ មុននឹងបានចូលមកទទួលការបណ្ដុះបណ្ដាល ។

### ឃ. ការធ្វើ ឱ្យសេ ចក្ដី ប្រាថ្នាទ ទូលបានជោគជ័យ

ការធ្វើឱ្យសេចក្ដីប្រាថ្នាបានសម្រេចទទួលបាននូវជោគជ័យ គឺមានន័យដូចគ្នានឹងការសម្រេចបំណង ដែលជាដំណាក់មួយដ៏សំខាន់នៃលំនាំឆន្ទៈ។ ការធ្វើឱ្យសេចក្ដីសម្រេចទទួលបានជោគជ័យ គឺអាស្រ័យទៅនឹងអំពើឆន្ទៈ ឬអំពើសញ្ចេតនារបស់មនុស្ស ដែលសម្ដែងចេញតាមរយៈកាយវិការ និងអំពើដែលតម្រូវឱ្យមានភាពត្រឹមត្រូវ និងទៀងទាត់ផង ។ ដូច្នេះការសម្ដែងចេញនូវឆន្ទៈរបស់មនុស្ស ដើម្បីសម្រេចចិត្តទទួលបានជោគជ័យ លុះត្រាតែមនុស្សត្រូវពុះពាររាល់ការលំបាក ដែលបាតុភូតនៃការលំបាកនេះមានលក្ខណៈជាអត្តនោម័ត និងសត្យានុម័ត ។

- ការលំបាកដែលមានលក្ខណៈជាអត្តនោម័ត គឺជាការលំបាកនៅក្នុងខ្លួនម្នាក់ៗ ។ យើងឃើញអំពើពីរកើតឡើងសភាពអកម្ម និងសភាពសកម្ម ។

ឧទាហរណ៍៖ ពេលនឿយហត់ ពេលងងុយគេង ពេលមានជំងឺ ភាពខ្ជិលច្រអូស... ធ្វើឱ្យកើតមានឡើងនូវសភាពផ្លូវចិត្តអវិជ្ជមាន។ ក្នុងករណីនេះ ដោយស្មារតីឆន្ទៈរបស់មនុស្ស អំពើបែបអវិជ្ជមាន និងអសកម្មនឹងត្រូវបានកែលម្អឡើងវិញ ។ នេះដោយសារការខិតខំប្រឹងប្រែងផ្នែកឆន្ទៈ ដែលធ្វើឱ្យខួរក្បាលរបស់យើងចាប់ផ្ដើមការ។

- ការលំបាកដែលមានលក្ខណៈសត្យានុម័ត គឺជាការលំបាកខាងក្រៅខ្លួនមនុស្ស ឧបសគ្គនៅក្នុងមជ្ឈដ្ឋានរស់នៅ ដែលយើងត្រូវតែប្រឹងប្រែងជម្នះឱ្យបាន ។ ការលំបាកនៅក្នុងតថភាពសត្យានុម័ត កើតមានឡើងចំពោះមនុស្សគ្រប់រូប ដែលមិនអាចគេចផុតបានទេដូចជា ការប៉ះទង្គិចខាងពាក្យសម្ដី ការបន្តុចបង្អាក់ ការប្រើប្រាស់ល្បិចភូតកុហកជាដើម ហើយច្រើនកើតមានចំពេលដែលមនុស្សជួបក្នុងស្ថានភាពទ័លច្រក គ្មានមធ្យោបាយដោះស្រាយដែលជា

ដំណាក់កាលជួបការលំបាក ។ ក្នុងករណីនេះលំនាំនៃទង្វើរបស់មនុស្សទៅលើធម្មជាតិ និងការប្រែក្លាយធម្មជាតិទៅតាមតម្រូវការរបស់ខ្លួន គឺជាលំនាំតស៊ូជាសាវន្ត ដើម្បីទទួលបានជោគជ័យ ។

### ៤. ចរិតលក្ខណៈ នៃឆន្ទៈរបស់ជំទង់

ជំទង់ចាប់ផ្ដើមមានឆន្ទៈ និងចេះអប់រំឆន្ទៈដោយខ្លួនឯង។ ជំទង់ចាត់ទុកខ្លួនគេដូចជាមនុស្សពេញវ័យជានិច្ច ហើយវាយតម្លៃខ្លួនឯងយ៉ាងខ្ពស់បំផុត ។

ម្យ៉ាងទៀតជំទង់ចង់បង្ហាញឱ្យឃើញពីគោលបំណង គំនិតម្ចាស់ការ សេចក្ដីក្លាហាន រហូតដល់ចិត្តអំណត់ និងវិន័យរបស់គេថែមទៀតផង ។

ឧទាហរណ៍៖ ជំទង់ចង់ក្លាយជាកីឡាករបាល់ទាត់ ពេលនោះគេមានឆន្ទៈក្នុងលំហាត់ប្រាណរៀងរាល់ព្រឹក ហើយចាប់ផ្ដើមលេងបាល់ទាត់ ដោយមិនចាំបាច់មានបញ្ជាពីមនុស្សធំ ។

ដោយសារជំទង់ជាវ័យដែលពុំទាន់ប៉ិនប្រសប់ក្នុងការប៉ាន់ប្រមាណចំណេះដឹងនៅឡើយ បានជាពេលខ្លះជំទង់តែងតែយល់ច្រឡំថា ទម្រង់ខាងក្រៅនៃវត្ថុ ឬបាតុភូតទាំងឡាយ គឺជាខ្លឹមសារនៃវត្ថុ ឬបាតុភូតនោះ ។ ហេតុនេះ ជំទង់នៅមានចំណុចខ្លះដូចជា ៖

- ចាត់ទុកអំពើខ្លះថាជាស្នាដៃប្រកបដោយវីរភាពដូចជា ជំទង់ដើរកាត់ភ្លៀងដោយខ្លួនឯង កាន់កំសៀវទឹកពុះដោយគ្មានទ្រាប់ដៃ ដើរកាត់ផ្លូវថ្នល់ពីមុខរថយន្ត។

- ឆាប់ចាប់អារម្មណ៍ ឆាប់ជាប់ចិត្ត ហើយនឹងយកតម្រាប់តាមអំពើផ្សងព្រេងខ្លះ ដែលគេយល់ថាជាអំពើប្រកបដោយវីរភាព ទោះបីអំពើនោះជាអំពើអាក្រក់ហើយគ្មានអត្ថន័យចំពោះសង្គមក៏ដោយ។

ឧទាហរណ៍៖ ជំទង់ហានបង្អត់បាយខ្លួនឯងមួយថ្ងៃ ឬពីរថ្ងៃ ដើម្បីបញ្ជាក់ពីសេចក្ដីក្លាហាន។ ជំទង់យកតម្រាប់តាមតួឯកក្នុងភាពយន្ត ហាត់ប្រដាល់ សាកល្បងសាច់ដុំដោយវាយបំបាក់ដុំឥដ្ឋ។

ជាទូទៅឆន្ទៈជំទង់មិនទាន់ស្ថិតស្ថេររឹងមាំទេ។

### ៥. ការអប់រំឆន្ទៈ ជំទង់

ដើម្បីអប់រំជំទង់ឱ្យមានឆន្ទៈល្អ អ្នកអប់រំត្រូវយកចិត្តទុកដាក់នឹងបញ្ហាដូចតទៅ ៖

- ផ្សារភ្ជាប់ការហ្វឹកហ្វឺនឆន្ទៈទៅនឹងសកម្មភាព ដែលមានអត្ថន័យសង្គមកម្រិតខ្ពស់ ។ ដំបូងគេ ត្រូវប្រើវិធីណាដែលទាក់ទាញអារម្មណ៍ជំទង់ និងបន្ទាប់មកទើបខិតចូលទៅក្នុងខ្លឹមសាររបស់ឆន្ទៈ។ ក្រៅពីសកម្មភាពសមូហភាព គេត្រូវហ្វឹកហ្វឺនសមត្ថភាពផ្ទាល់ខ្លួនរបស់ជំទង់ផងដែរ។

ឧទាហរណ៍៖ ប្រគល់ភារកិច្ចជាអ្នកដឹកនាំក្រុមកីឡាបាល់ទាត់ប្រចាំសាលា សម្រាប់ការចូលរួមប្រកួតអន្តរសាលា។

- ផ្សារភ្ជាប់ការហ្វឹកហ្វឺនឆន្ទៈទៅនឹងសកម្មភាពសង្គមដូចជា ចូលរួមថែរក្សាបរិស្ថាន ឃោសនា ការទប់ស្កាត់ជំងឺអេដស៍ ឬការប្រើប្រាស់គ្រឿងញៀនចូលរួមក្នុងចលនាដើម្បីសេរីភាព លទ្ធិប្រជាធិបតេយ្យ ភាពយុត្តិធម៌ក្នុងសង្គម ។ល។

- ជំរុញជាជំហានៗទៅរកការអប់រំឆន្ទៈ ក្នុងការងារប្រចាំថ្ងៃដែលងាយៗ ដោយប្រែក្លាយការហ្វឹកហ្វឺននេះ ឱ្យទៅជាទម្លាប់ប្រកបដោយគុណភាពខ្ពស់។

ហេតុនេះ គ្រូត្រូវអប់រំជំទង់ឱ្យបំពេញយ៉ាងត្លៀវក្លានូវភារកិច្ចប្រចាំថ្ងៃដូចជា ក្រោកពីដំណេកហើយត្រូវហាត់ប្រាណ ឬរំឭកមេរៀន និងធ្វើការសិក្សាស្វែងយល់បន្ថែម ធ្វើកិច្ចការដោយយកចិត្តទុកដាក់ ជួយធ្វើការឪពុកម្ដាយ... ដោយមិនចាំបាច់មានបញ្ជាពីមនុស្សធំ។ នេះគឺជារបៀបល្អប្រសើរក្នុងការអប់រំឆន្ទៈជំទង់។

## IV- សន្និដ្ឋាន

គ្រូគួរតែយល់ និងជួយរាល់ការលំបាករបស់សិស្សខាងក្នុង និងខាងក្រៅខ្លួន ក្នុងនាមជាអ្នកសម្របសម្រួល ព្រោះរាល់សកម្មភាពសិក្សារបស់សិស្ស គឺកើតឡើងដោយឆន្ទៈពិតប្រាកដរបស់ពួកគេ។ ឧបសគ្គទាំងឡាយដែលមករំខានដូចជា សំឡេងពីខាងក្រៅ ការជជែកគ្នានៅក្បែរខ្លួន...បណ្ដាលឱ្យមានផលប៉ះពាល់មកលើចំណង់ចំណូលចិត្តរបស់សិស្សក្នុងការសិក្សា។ សកម្មភាពអវិជ្ជមានធ្វើឱ្យឆន្ទៈថយចុះ។

### សំណួរ

១. តើអំពើឆន្ទៈ និងអំពើអឆន្ទៈខុសគ្នាយ៉ាងដូចម្ដេច?
២. តើអំពើឆន្ទៈមានតួនាទីអ្វីខ្លះក្នុងសកម្មភាពរបស់មនុស្ស?
៣. ចូររៀបរាប់ពីដំណាក់កាលសំខាន់ៗនៃលំនាំឆន្ទៈ។
៤. តើគ្រូបង្រៀនត្រូវធ្វើដូចម្ដេច ដើម្បីអប់រំឆន្ទៈ និងអំពើឆន្ទៈរបស់ជំទង់ឱ្យបានល្អ?

# មេរៀនទី១២ ចិត្តរំភើប និងសញ្ចេតនា

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់បានពីបញ្ញត្តិ ចិត្តរំភើប សញ្ចេតនា ប្រភេទសញ្ចេតនា និងកម្រិតសញ្ចេតនា
- រកឃើញភាពខុសគ្នារវាង ចិត្តរំភើប និងសញ្ចេតនា ព្រមទាំងកំណត់បានពីប្រភេទ និងកម្រិតសញ្ចេតនា
- អប់រំសិស្សឱ្យបង្កើត សញ្ចេតនាវិជ្ជមាន និងចៀសវាងបង្កើតសញ្ចេតនាអវិជ្ជមានក្នុងជីវភាពប្រចាំថ្ងៃ។

## II- សេចក្តីផ្តើម

នៅក្នុងជីវភាពរស់នៅ មនុស្សគ្រប់រូបតែងតែមានការប្រែប្រួលនូវបុគ្គលិកលក្ខណៈ និងសកម្មភាពរបស់ខ្លួនទៅតាមតថភាពសត្យានុម័ត។ ពេលនេះលំនាំចិត្តបានផុសចេញឡើងតាមរយៈលំនាំចំណេះដឹង និងការប្រែប្រួលនូវតថភាព ដែលធ្វើឱ្យមនុស្សមានឥរិយាបថថ្មីមួយ ពោលគឺមានទំនាក់ទំនងទៅនឹងតម្រូវការវត្ថុបំណង ឬបាតុភូតជាក់ស្តែង។ ឥរិយាបថវាកើតមានឡើងអាស្រ័យទៅតាមតម្រូវការសម្ភារៈ និងស្មារតីដែលធ្វើឱ្យមនុស្សពេញចិត្ត ឬមិនពេញចិត្ត។ ឥរិយាបថទាំងនេះរបស់មនុស្សចំពោះតថភាព គឺការសម្តែងឱ្យឃើញនូវចិត្តរំភើប និងសញ្ចេតនារបស់បុគ្គលនីមួយៗ ។

## III- ខ្លឹមសារ

### ១. និយមន័យ

#### ១.១ ចិត្តរំភើប

ចិត្តរំភើប ជាលំនាំចិត្ត ជាបាតុភូតចិត្តមួយ ដែលមានលក្ខណៈបណ្តោះអាសន្នប្រព្រឹត្តនៅក្នុងរយៈពេលខ្លី ។

ឧទាហរណ៍៖ យើងកំពុងឃ្លាន ពេលឃើញគេលើកបាយយកមកនាំឱ្យយើងត្រេកអរ ។

#### ១.២ សញ្ចេតនា

សញ្ចេតនា ជាលក្ខណៈចិត្ត ជាបាតុភូតចិត្តមួយ ដែលមានលក្ខណៈស្ថិតស្ថេរយូរអង្វែង។

ដូច្នេះចិត្តរំភើប និងសញ្ចេតនា ជាឥរិយាបថរបស់មនុស្ស ដែលសម្តែងឡើងចំពោះវត្ថុ ឬបាតុភូតនៃតថភាពបានុម័ត ដែលឆ្លើយតប ឬមិនឆ្លើយតបតាមចំណង់ចំណូលចិត្ត ហើយអាស្រ័យទៅតាមតម្រូវការផ្នែកសម្ភារៈ ឬផ្នែកស្មារតីរបស់មនុស្សម្នាក់ៗ។ សញ្ចេតនារបស់មនុស្សកើតឡើងដោយសារទូទៅកម្មនៃចិត្តរំភើបផ្ទួនៗគ្នាច្រើនដង។

ឧទាហរណ៍ ៖ - ទឹកចិត្តម្តាយស្រឡាញ់កូន។

- យុវជនម្នាក់ធ្លាប់បានជួយសង្គ្រោះយុវតីម្នាក់ ឱ្យរួចផុតពីគ្រោះថ្នាក់ចរាចរ ទំនាក់ទំនងអ្នកទាំងពីរកើតមានឡើងដោយសារការយកចិត្តទុកដាក់ជាបន្តទៅទៀត ដែលធ្វើឱ្យគេទាំងពីរមានសញ្ចេតនានឹងគ្នា។

### ២. ប្រភេទនៃសញ្ចេតនា

យោងទៅតាមសកម្មភាពរបស់មនុស្សម្នាក់ៗ គេចែកសញ្ចេតនាជាពីរប្រភេទគឺ សញ្ចេតនាកម្រិតទាប និងសញ្ចេតនាកម្រិតខ្ពស់។

**២.១ សញ្ចេតនាកម្រិតទាប៖** គឺជាសញ្ចេតនាផ្សារភ្ជាប់ទៅនឹងតម្រូវការផ្នែកសម្ភារៈរបស់មនុស្សដោយមិនអាស្រ័យទៅនឹងស្មារតីនោះទេ។

ឧទាហរណ៍៖ ពេលឃ្លានបាយ គេមានទឹកមុខហាក់មិនសូវសប្បាយចិត្ត គេតែងតែទៅរកទីដែលមានអាហារសម្រាប់ហូប ក្រោយពេលហូបបាយហើយ គេនឹងមានទឹកមុខរីករាយឡើងវិញ។

២.២ សញ្ចេតនាកម្រិតខ្ពស់៖ គឺជាប្រភេទនៃសញ្ចេតនា ដែលមានជាប់ទាក់ទិនទៅនឹងតម្រូវការផ្នែកស្មារតីរបស់មនុស្ស ។ គេចែកសញ្ចេតនាកម្រិតខ្ពស់ជា៖

- សីលសញ្ចេតនា (សញ្ចេតនាប្រកបដោយសីលធម៌)

សីលសញ្ចេតនា ជាលក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈ ដែលសម្តែងចេញតាមរយៈឥរិយាបថរបស់បុគ្គលក្នុងទំនាក់ទំនងជាមួយអ្នកដទៃក្នុងសង្គម សហគមន៍ និងក្នុងជីវភាពរស់នៅ។

ឥរិយាបថរបស់បុគ្គលចំពោះសញ្ចេតនាផ្ទាល់ខ្លួន គឺការស្គាល់ខ្លួនឯង(ការយល់ដឹងរបស់បុគ្គលនោះចំពោះខ្លួនឯង)។ នេះជាការឱ្យតម្លៃទៅលើសីលធម៌ផ្ទាល់ខ្លួន ដែលសម្តែងចេញពីមនសិការផ្នែកសីលធម៌។

ឧទាហរណ៍៖ អ្នកស្រឡាញ់អំពើល្អ បើកាលណាគេបានធ្វើអំពើល្អ គេតែងតែមានសេចក្តីត្រេកអរណាស់។ ដូចជា យើងបានជួយសង្គ្រោះក្មេងម្នាក់ឱ្យផុតពីគ្រោះថ្នាក់ យើងសប្បាយចិត្តនឹងខ្លួនឯង ព្រោះបានធ្វើអំពើល្អ។

ដូចនេះ ក្នុងជីវភាពរស់នៅរបស់មនុស្សក្នុងសង្គម សីលសញ្ចេតនាសម្តែងចេញឱ្យឃើញតាមរយៈសេចក្តីស្រឡាញ់យុត្តិធម៌ សមធម៌ តម្លាភាព មានស្មារតីទទួលខុសត្រូវ ស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ស្នេហាមាតុភូមិ ស្រឡាញ់ពលរដ្ឋខ្លួន ស្រឡាញ់និងថែរក្សាបរិស្ថានជាតិ មានមិត្តភាពល្អ ភាតរភាព ចំណងទាក់ទងល្អ ជាមួយអន្តរជាតិ គោរពសិទ្ធិសេរីភាព និងគ្មានអំពើហិង្សា...។ ដែលទាំងអស់នេះហើយ ជាតម្លៃសញ្ចេតនាកម្រិតខ្ពស់របស់មនុស្សគ្រប់រូបក្នុងសង្គម ។

- សិល្បៈសញ្ចេតនា (សញ្ចេតនាផ្នែកសិល្បវិជ្ជា)

សិល្បៈសញ្ចេតនា គឺជាសញ្ចេតនាដែលមានទំនាក់ទំនងទៅនឹងការពេញចិត្ត ឬមិនពេញចិត្តនឹងតម្រូវការផ្នែកសោភ័ណ។ សញ្ចេតនាប្រភេទនេះ ច្រើនតែឱ្យតម្លៃទៅលើស្នាដៃច្នៃប្រឌិតខាងសិល្បៈ និងសោភ័ណភាពដែលកើតមាននៅក្នុងតថភាពសត្យានុម័ត ។

ឧទាហរណ៍៖ រូបចម្លាក់នៅប្រាសាទអង្គរ បានបង្កប់ទៅដោយខ្លឹមសារ និងសោភ័ណភាពខាងផ្នែកបច្ចេកទេសដ៏អស្ចារ្យ ។ យើងចូលចិត្តគយគន់ទេសភាពល្អៗក្នុងធម្មជាតិ (ទេសភាពពេលព្រះអាទិត្យរះកាត់ប្រាសាទអង្គរវត្ត ឬទេសភាពពេលថ្ងៃជិតអស្តង្គតនៅលើកំពូលភ្នំបាក់ខែង ឬទេសភាពមាត់សមុទ្រពេលថ្ងៃជិតអស្តង្គត)។ យើងចង់ស្លៀកពាក់ថ្មី ស្អាតល្អបែបប្រពៃណី ឬទាន់សម័យ(សោភ័ណល្អ) ។

សិល្បៈសញ្ចេតនា អាស្រ័យទៅនឹងលក្ខខណ្ឌសង្គម និងប្រវត្តិសាស្ត្រ ដែលតែងតែកំណត់នូវលក្ខណៈ វិនិច្ឆ័យទៅលើសោភ័ណភាព ។

សោភ័ណភាពកំណត់នូវលក្ខណៈពិសេស និងលក្ខខណ្ឌខាងក្រៅរបស់វត្ថុ ដូចជា ទម្រង់ ពណ៌ សំឡេង... សុទ្ធតែត្រូវបានឆ្លុះបញ្ចាំងចូលទៅក្នុងខួរក្បាលរបស់យើង តាមរយៈសរីរាង្គឥន្ទ្រីយ៍ ហើយផ្សារភ្ជាប់ទៅនឹងការវិភាគលើខ្លឹមសារតាមបែបបទនៃសរីរាង្គវិភាគ ។ ទម្រង់ដែលកំណត់ឡើងដោយខ្លឹមសារនេះហើយ ដែលជាផ្នែកសិល្បវិជ្ជា ។ ដូចនេះការអប់រំសិល្បវិជ្ជាដល់មនុស្ស គឺត្រូវបណ្តុះទស្សនៈសោភ័ណភាពខាងក្រៅឱ្យបានហ្មត់ចត់ត្រឹមត្រូវ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ដែលត្រូវកំណត់ឱ្យបានច្បាស់លាស់នូវទម្រង់របស់វត្ថុ។

សិល្បៈសញ្ចេតនា មិនអាចផ្តាច់ចេញបានពីមនសិការ និងឥរិយាបថរបស់មនុស្ស នៅចំពោះមុខតថភាពសត្យានុម័តបានឡើយ។ ដូចនេះហើយបានជាសិល្បៈសញ្ចេតនាត្រូវផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសីលសញ្ចេតនា។ ឥរិយាបថរបស់មនុស្ស ចំពោះស្នាដៃសិល្បៈ ត្រូវបានកំណត់ច្បាស់មិនត្រឹមតែរូបភាពនៃការសម្តែងចេញនូវស្នាដៃទាំងនោះទេ ក៏ប៉ុន្តែសំខាន់បង្អស់នោះគឺ តម្លៃ និងអត្ថន័យរបស់ស្នាដៃសិល្បៈនោះទៀតផង។

- សញ្ចេតនាផ្នែកបញ្ញា៖ ទាក់ទងនឹងសកម្មភាពពុទ្ធិ ពោលគឺសកម្មភាពយល់ដឹងរបស់មនុស្ស។

សញ្ចេតនាផ្នែកបញ្ញា គឺជាប្រភេទនៃសញ្ចេតនាដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសកម្មភាពទទួលយក

ះដឹងរបស់មនុស្ស ដោយប្រើប្រាស់នូវរូបភាពដំណោះស្រាយតាមមធ្យោបាយផ្សេងៗរួមផ្សំនឹងមូលដ្ឋានទ្រឹស្តី និងបទពិសោធលើការរកឃើញ និងបង្កើតជាស្នាដៃច្នៃប្រឌិត ។

ឧទាហរណ៍៖ ជក់ចិត្តនឹងការសិក្សា ជក់ចិត្តក្នុងការអាន ការងឿងឆ្ងល់ ការចង់ដឹង ការទុកចិត្ត ការព្រួយបារម្ភ ការសង្ស័យ...ទាំងអស់នេះជាសញ្ចេតនាផ្នែកបញ្ញា ។

សញ្ចេតនាផ្នែកបញ្ញាសម្តែងចេញ ដោយការស្រឡាញ់ជក់ចិត្តទៅលើកម្មវត្ថុ ឬបាតុភូតថ្មីស្រឡាង ដោយសេចក្តីត្រេកអរ ដែលអំពើនេះជះឥទ្ធិពលទៅលើការពង្រឹងពង្រីកបានចំពោះសកម្មភាពនៃការសិក្សាស្រាវជ្រាវ និងការបង្កើតឡើងនូវស្នាដៃច្នៃប្រឌិត ។

### ៣. កម្រិតចិត្តរំភើប និងសញ្ចេតនា

សញ្ចេតនារបស់មនុស្សមានកម្រិតខុសៗគ្នាដូចលំនាំពុទ្ធិដែរ គឺពីទាបទៅខ្ពស់ ពីងាយស្រួលទៅ ស្មុគស្មាញ ពីបណ្តោះអាសន្នទៅស្ថិតស្ថេរ ពីជាក់ស្តែងទៅទូទៅ។ កម្រិតទាំងអស់នេះ ត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យដូចតទៅ ៖

**៣. ១. ចិត្តរំភើបខ្សោយ ៖** ជាកម្រិតទាបបំផុតនៃសញ្ចេតនាដែលកើតមានដោយលក្ខណៈពិសេសនៃវត្ថុ ឬបាតុភូតជាក់ស្តែង។

ឧទាហរណ៍៖ ពេលបានឃើញទេសភាពពណ៌បៃតងនាំឱ្យយើងចង់គយគន់ និងមានអារម្មណ៍គួរជាទីគាប់ចិត្ត។

**៣.២ ទឹកចិត្ត៖** ជាសញ្ចេតនាស្ថិតស្ថេរដែលមានកម្លាំងមធ្យម ឬខ្សោយ (ទឹកចិត្តអាចស្ថិតនៅក្នុងពេលមួយម៉ោង ឬមួយឆ្នាំ ឬយូរអង្វែង)។ ទឹកចិត្តជះឥទ្ធិពលទៅលើឥរិយាបថ និងសកម្មភាពរបស់មនុស្សក្នុងរយៈពេលយូរ ។

ឧទាហរណ៍៖ ពេលចូលមកដល់មជ្ឈមណ្ឌលគរុកោសល្យដំបូងគរុនិស្សិតខ្លះដូចជាត្រេកអរ។ សេចក្តីត្រេកអរនេះមិនមែនធំដុំទេ ប៉ុន្តែអាចស្ថិតស្ថេរបានយូរ។

**៣.៣. ចិត្តរំជួល៖** គឺជាសភាពចិត្តដែលបណ្តាលមកពីចិត្តរំភើបខ្លាំង ហើយដែលប្រព្រឹត្តទៅក្នុងរយៈពេលមួយខ្លី ។ ពេលនោះមនុស្សមិនអាចបញ្ជាខ្លួនឯងបានទេ ។

ឧទាហរណ៍៖ ពេលជួបឪពុកម្តាយ ឬអ្នកដែលយើងស្រឡាញ់ខ្លាំងជាងគេ ក្រោយពីមានការបែកគ្នារយៈពេលយូរកន្លងមក ឬក៏ការរួចផុតពីគ្រោះថ្នាក់អ្វីមួយ ក្នុងខណៈពេលដំបូងយើងមានចិត្តត្រេកអរសប្បាយយ៉ាងខ្លាំង រហូតអ្នកខ្លះបែរជាយំផងក៏មាន ។

**៣.៤ លំងប់៖** គឺជាសញ្ចេតនាដែលមានកម្លាំងខ្លាំងហើយជ្រាលជ្រៅ និងស្ថិតនៅអស់រយៈពេលយូរ ។

ឧទាហរណ៍៖ លំងប់នឹងការលេងបាល់ទាត់ នាំឱ្យយុវជនខ្លះភ្លេចបាយ ភ្លេចទឹក ភ្លេចការសិក្សាក៏មាន ។




គំនូសបំព្រួញកម្រិតសញ្ចេតនា

នៅមានសញ្ចេតនាផ្សេងទៀត ដែលជាការឆ្លុះបញ្ចាំងពីលោកទស្សនៈដូចជា សេចក្តីស្នេហាមាតុភូមិ ការស្រឡាញ់សម្បត្តិវប្បធម៌ និងបេតិកភណ្ឌជាតិ ការស្រឡាញ់ធម្មជាតិ ស្មារតីសមូហភាពជាដើម គឺជាសញ្ចេតនាមួយ

ប្រភេទទៀត ដែលមានកម្រិតខ្ពស់សម្រាប់មនុស្ស ។

### ៤. លក្ខណៈ សញ្ចេតនា ចិត្តរំភើប និងចំណងទាក់ទងគ្នា

លក្ខណៈចិត្តរំភើប និងសញ្ចេតនាមានការលំបាកក្នុងការញែកឱ្យដាច់ពីគ្នា។ សញ្ចេតនាជាបាតុភូតចិត្ត ដែលស្ថិតនៅក្នុងលក្ខណៈចិត្ត ដោយមានចរិតឋិតថេរ និងសណ្ឋិតនៅយូរក្នុងខ្លួនមនុស្ស។ ចំណែកឯចិត្តរំភើបវិញ គឺជាបាតុភូតចិត្តដែលជាលំនាំផ្លូវចិត្ត ពោលគឺចិត្តរំភើបកើតមានឡើងដោយបាតុភូត ដែលមានចរិតបណ្ដោះអាសន្ន ហើយវាសម្ដែងចេញក្នុងកាលៈទេសៈណាមួយដ៏ជាក់លាក់។

ឧទាហរណ៍៖ ឪពុក ម្ដាយមានការថ្នាក់ថ្នមស្រឡាញ់កូន(សញ្ចេតនា)។ កូនទទួលបានលទ្ធផលល្អក្នុងការសិក្សា(ចិត្តរំភើប) ។ ពេលកូនមានជំងឺ ម្ដាយឪពុកតែងតែពិបាកចិត្ត និងគិតទៅដល់កូនជានិច្ច (សញ្ចេតនា) ។

ដូចនេះ ចិត្តរំភើប និងសញ្ចេតនា មានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ។ គេអាចនិយាយបានថាចិត្តរំភើបជាមូលដ្ឋាន និងមធ្យោបាយនៃការសម្ដែងចេញនូវសញ្ចេតនា រីឯសញ្ចេតនាវិញ ជាលទ្ធផលនៃ ការធ្វើសំយោគ និងធ្វើទូទៅកម្មនៃចិត្តរំភើបច្រើនដងដដែលៗ ។

### ៥. លក្ខណៈ ពិសេសនៃចិត្តរំភើប និងសញ្ចេតនា

ចិត្តរំភើប និងសញ្ចេតនា មានលក្ខណៈពិសេសពីរយ៉ាងសំខាន់គឺ ៖

ក. ចិត្តរំភើប និងសញ្ចេតនា កើតឡើងពីបដិវាទកម្មរវាងទស្សនៈពីរ។ បើគេនិយាយពីការសប្បាយ បានន័យថា គេប្រៀបធៀបនៅក្នុងគំនិតទៅនឹងសេចក្ដីទុក្ខព្រួយ។ សេចក្ដីស្រឡាញ់ផ្ទុយនឹងការស្អប់ខ្ពើម។

ខ. ចិត្តរំភើប និងសញ្ចេតនា កើតឡើងពីចរិតទ្វេភាគី ដែលចរិតនេះសម្ដែងឡើងជាភាពវិជ្ជមាន និងអវិជ្ជមាន ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ។

ឧទាហរណ៍៖ ការសប្បាយក្នុងការសិក្សា គឺជាការសប្បាយបែបវិជ្ជមាន។

យើងដឹងហើយថា មនុស្សគ្រប់រូបតែងតែមានតណ្ហា ហើយតម្លៃរបស់ខ្លួនវាអាស្រ័យលើឥរិយាបថ ចរិតដែលគេឱ្យតម្លៃ។ ដូចនេះលក្ខណៈនៃចិត្តរំភើប និងសញ្ចេតនា ត្រូវស្ថិតនៅលើព្រំដែនមួយជាក់លាក់ ពោលគឺកម្រិតវិជ្ជមាន។

### ៦. មូលដ្ឋាន ប្រសាទ សរីរៈ និងការ សម្ដែង ចេញចិត្តរំភើប និងសញ្ចេតនា

#### ក. មូលដ្ឋាន ប្រសាទ សរីរៈនៃចិត្តរំភើប និងសញ្ចេតនា

ចិត្តរំភើប និងសញ្ចេតនា ជាលំនាំផ្លូវចិត្តស្ថិតនៅក្រោមការដឹកនាំរបស់សំបកខួរក្បាលតាមរយៈសរសៃប្រសាទនៃសំបកខួរក្បាល ដែលបំពេញនាទីយ៉ាងសំខាន់ នៅក្នុងការធ្វើឱ្យកើតមានចិត្តរំភើប និងសញ្ចេតនា ។

នៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ អំពើទាំងអស់ដែលសម្ដែងឱ្យឃើញសញ្ចេតនារបស់មនុស្សមានចរិតជាឆ្លុះមានលក្ខខណ្ឌ។ ចិត្តរំភើប និងសញ្ចេតនារបស់មនុស្សក៏មានទំនាក់ទំនងផងដែរ ជាមួយនឹងរូបភាពផ្លូវចិត្ត ដែលស្ថិតនៅក្នុងសំបកខួរក្បាលរបស់មនុស្ស។ កាលណាមានរូបភាពថ្មីចូល រូបភាពចាស់ត្រូវបាត់បន្តិចម្ដងៗ ហើយពេលនោះរូបភាពថ្មីបង្កើតជាសញ្ចេតនាដ៏ធ្ងន់ដូចជា ការផ្លាស់ប្ដូរទីកន្លែងរស់នៅ ការប្ដូរទម្លាប់ ការឃ្លាតឆ្ងាយពីមិត្តភក្តិ។

តាមការបកស្រាយពន្យល់បានឱ្យដឹងថា ផ្នែកខាងក្រោមនៃខួរក្បាលក៏បំពេញតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមានចិត្តរំភើប និងសញ្ចេតនា ។ ដូចនេះ ផ្នែកខាងក្រោមនៃខួរក្បាល និងសំបកខួរក្បាលធ្វើនិយតកម្ម មានន័យថាសំបកខួរក្បាលមានតួនាទីក្នុងការសម្ដែងចេញនូវចិត្តរំភើប និងសញ្ចេតនា ។ ដូចនេះផ្នែកខាងក្រោមសំបកខួរក្បាលក៏មានតួនាទីក្នុងការសម្ដែងចេញនូវចិត្តរំភើប និងសញ្ចេតនាផងដែរ។

#### ខ. ការ សម្ដែង ចេញនូវចិត្តរំភើប និងសញ្ចេត នា តាមបែបសរីរៈ

នៅផ្នែកខាងក្រោមនៃសំបកខួរក្បាល មានមជ្ឈមណ្ឌលសម្រាប់បញ្ជារបស់ប្រព័ន្ធសរសៃប្រសាទចិញ្ចឹម(ការចិញ្ចឹមរាងកាយដោយអាហារ) ដែលជាផ្នែកមួយនៃបណ្ដុំនៃចិត្តរបស់មនុស្ស។ ប្រព័ន្ធសរសៃប្រសាទចិញ្ចឹមនេះ មាន

តួនាទីធ្វើឱ្យសរីរាង្គខាងក្នុងខ្លួនមនុស្សមានភាពទៀងទាត់។ ហេតុដូចនេះហើយបានជាចិត្តរំភើប និងសញ្ចេតនាតែងតែពាក់ព័ន្ធទៅនឹងការចិញ្ចឹមក្នុងខ្លួនយើង។ ឧទាហរណ៍៖ ពេលរំភើបខ្លាំងធ្វើឱ្យយើងបាត់ឃ្លានបាយ ឬពេលព្រួយចិត្តយើងញ៉ាំបាយមិនបាន ។

តាមការសិក្សាស្រាវជ្រាវបានឱ្យឃើញថា ចិត្តរំភើបរបស់មនុស្ស ត្រូវបានផ្សារភ្ជាប់ជាធម្មតាទៅនឹងការផ្លាស់ប្តូររបស់មុខងារសរីរៈនៃប្រព័ន្ធឈាមរត់។ នៅពេលណាមនុស្សមានចិត្តរំភើប លក្ខណៈរបស់មនុស្សមានការប្រែប្រួល (ស្វាហាប់ ឬព្រងើយកន្តើយ)ដែលធ្វើឱ្យទឹកមុខមានការផ្លាស់ប្តូរ(ក្រហម ឬស្លេកស្លាំង)។ ការផ្លាស់ប្តូរទឹកមុខនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងចង្វាក់បេះដូង ។ ហេតុនេះ ត្រង់នេះហើយទើបគេចាត់ទុកបេះដូង ជានិមិត្តរូបនៃសញ្ចេតនារបស់មនុស្ស។ ដូចនេះបេះដូងជាកន្លែង ដែលសម្តែងចេញនូវចិត្តរំភើប មានទំនាក់ទំនងទៅនឹងការផ្លាស់ប្តូរមុខងារនៃការដកដង្ហើម ។

ឧទាហរណ៍៖ ពេលមានទុក្ខព្រួយ គេដកដង្ហើមវែងៗ។

ចិត្តរំភើបក៏ធ្វើឱ្យសរីរៈរបស់មនុស្សមានការប្រែប្រួលផងដែរ ពិសេសលើមុខងារនៃការរំលាយអាហារដូចជាសប្បាយពេក ឬមានទុក្ខព្រួយពេកធ្វើឱ្យគេមិនឃ្លានអាហារ។

### ៧. ច្បាប់ នៃសញ្ចេតនា

**ក. ច្បាប់ ចម្លង៖** សញ្ចេតនាអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។

ឧទាហរណ៍ ៖

- សំណើចអាចឆ្លងពីសិស្សម្នាក់ដល់សិស្សទាំងអស់ក្នុងថ្នាក់ ។
- មិត្តសំឡាញ់យើងម្នាក់កំពុងមានទុក្ខព្រួយខ្លាំង បណ្តាលឱ្យយើងក៏មានទុក្ខព្រួយជាមួយគេដែរ។

**ខ. ច្បាប់ ចល័ត៖** សញ្ចេតនាចល័ត ជាសញ្ចេតនាដែលអាចផ្ទេរពីវត្ថុមួយទៅមួយទៀត ។

ឧទាហរណ៍ ៖ ភាសិតខ្មែរចែងថា «ខឹងគោវាយរទេះ» ។ គ្រូដាក់ទណ្ឌកម្មសិស្សម្នាក់ដែលធ្វើខុស តែមិនត្រូវដាក់ទណ្ឌកម្មជាសមូហភាពនោះទេ ព្រោះវាជាអំពើអយុត្តិធម៌មួយ ។

**គ. ច្បាប់ ល្បាយ៖** សញ្ចេតនាមួយត្រូវបានលាយឡំគ្នានឹងសញ្ចេតនាផ្សេងៗទៀត ។

ឧទាហរណ៍៖

- ស្នេហារវាងបុរស និងនារី អាចលាយឡំនឹងការប្រច័ណ្ឌ ។
- ស្នេហាមាតុភូមិលាយនឹងកំហឹងឈឺចាប់ ព្រោះការឈ្លានពានពីបរទេសលើបូរណភាពទឹកដីយើង ។

### ៨. រូបភាពនៃសញ្ចេតនា

សញ្ចេតនារបស់មនុស្សមានភាពសំបូរបែប និងស្មុគស្មាញ ដោយអាស្រ័យលើមូលដ្ឋានជឿន កម្លាំងថេរពេលវេលា កម្រិតស៊ីជម្រៅលើខ្លឹមសារ។ គេចែកសញ្ចេតនាតាមសភាពលក្ខណៈដូចតទៅ៖

**ក. សភាពនៃស្មារតី**

សភាពនៃស្មារតី គឺជាសភាពនៃសញ្ចេតនា ដែលស្ថិតនៅបានយូរអង្វែង ហើយមានកម្លាំងមធ្យម ឬខ្សោយ ។ សភាពស្មារតីរបស់មនុស្ស អាចមានលក្ខណៈវិជ្ជមានដូចជា សេចក្តីត្រេកអរ គំនិតសុទិដ្ឋិនិយម ស្នេហាមាតុភូមិ ស្នេហាមាតាបិតា ភាពស្មោះត្រង់ប្តីប្រពន្ធ។ល។ ដែលសកម្មភាពច្រើនតែសម្តែងចេញនូវទឹកមុខស្រស់ស្រាយ។ ពេលខ្លះអាចមានលក្ខណៈអវិជ្ជមានដូចជា គំនិតទុទិដ្ឋិនិយម ទុក្ខក្រៀមក្រំ ភាពធុញទ្រាន់ ភាពគ្មានការតស៊ូ ។ល។ ដែលជាធម្មតា គេសង្កេតឃើញជីវិតរស់នៅមានសភាពបែបខ្មៅងងឹត ហើយជានិច្ចកាលច្រើនគិតថា គេនឹងជួបនូវឧបសគ្គបែបណាមួយនៅពេលអនាគតជាមិនខាន។ ព័ត៌មាន បាតុភូត និងហេតុការណ៍ផ្សេងៗធ្វើឱ្យមនុស្សមានស្មារតីផ្សេងៗគ្នា។ ម្យ៉ាងទៀតសភាពស្មារតីរបស់មនុស្សអាស្រ័យទៅនឹងសុខភាព រាងកាយ រួមទាំងលក្ខខណ្ឌជីវិតរស់នៅរបស់មនុស្ស

ផង។

ឧទាហរណ៍៖ បញ្ហាបរិស្ថានសព្វថ្ងៃ ជាកង្វល់របស់មនុស្សដែលរស់នៅលើផែនដីតាមរយៈការឡើងកម្តៅជាដើម។ ការលើកសសើររបស់គ្រូប្រចាំថ្នាក់ ធ្វើឱ្យការសិក្សារបស់សិស្សកាន់តែមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

### ខ. ចិត្តរំភើប

ចិត្តរំភើប គឺជាសភាពចិត្តដែលបង្កឡើងតាមរយៈការចាប់អារម្មណ៍យ៉ាងខ្លាំងក្លា ដែលកើតមានឡើងក្នុងរយៈពេលដ៏ខ្លី។ ដូចគ្នានឹងសភាពស្មារតីដែរ ចិត្តរំភើបអាចជាវិជ្ជមានដូចជា ការសប្បាយច្រើននៅពេលប្រឡងជាប់... ។ ហើយចិត្តរំភើបបែបអវិជ្ជមានដូចជា សេចក្តីអស់សង្ឃឹមពេលប្រឡងធ្លាក់...។

ជាទូទៅចិត្តរំភើប កើតមានឡើងនៅពេលណាដែលមានហេតុការណ៍ដ៏សំខាន់បែបណាមួយនោះផុសចេញភ្លាមៗនៅក្នុងជីវភាពរស់នៅរបស់យើង។ ជាការពិតចិត្តរំភើបខ្លះ ធ្វើឱ្យមនុស្សមិនអាចគ្រប់គ្រងលើសកម្មភាពរបស់ខ្លួនឯងបានផង រហូតហ៊ានប្រព្រឹត្តបទល្មើស។ ដូចនេះ មនុស្សត្រូវតែមានឆន្ទៈមួយប្រឆាំងលើសកម្មភាពបែបនេះ។

### គ. តណ្ហា

តណ្ហា គឺជាសភាពចិត្តដែលកើតឡើងដោយសារចិត្តរំភើប ដែលមានលក្ខណៈខ្លាំង ស៊ីជម្រៅ ហើយស្ថិតនៅបានយូរអង្វែង។ តណ្ហាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការតម្រង់ទិសនៃអំពើ និងការគិតរបស់មនុស្ស។ តណ្ហាក៏មានពីរបែបដូចចិត្តរំភើប និងសភាពស្មារតីផងដែរ គឺតណ្ហាវិជ្ជមាន និងតណ្ហាអវិជ្ជមាន។ តណ្ហាវិជ្ជមានដូចជា តណ្ហាក្នុងការសិក្សា តណ្ហាក្នុងសិល្បៈ តណ្ហាក្នុងវិជ្ជាជីវៈជាដើម។ រីឯតណ្ហាអវិជ្ជមានដូចជា តណ្ហាប្រព្រឹត្តលើអំពើអបាយមុខ តណ្ហាក្នុងការប្រើប្រាស់នូវគ្រឿងញៀន។ល។ តណ្ហាបែបវិជ្ជមានជាតណ្ហាប្រកបទៅដោយធម៌សប្បុរសដែលធ្វើឱ្យមនុស្សមានសកម្មភាពច្នៃប្រឌិតលើការងារនិងមានឥទ្ធិពលក្នុងការប្រមូលផ្តុំបាននូវកម្លាំងមនុស្សដើម្បីឈានទៅសម្រេចជោគជ័យយ៉ាងធំធេង។

## ៩. តួនាទី ចិត្តរំភើប និងសញ្ចេតនា

សញ្ចេតនាមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការរុញច្រានមនុស្សឱ្យមានសកម្មភាព។ សញ្ចេតនាដ៏សកម្មតែងតែដឹកនាំមនុស្សទៅរកទង្វើវិជ្ជមាន។ មនុស្សនឹងមានទង្វើវិជ្ជាមានប្រកបដោយលក្ខណៈច្នៃប្រឌិត ដរាបណាមនុស្សមានតណ្ហាងប់ទៅលើឧត្តមគតិ។ ការចូលរួម និងការពារសម្បត្តិវប្បធម៌ជាតិ ដរាបណាបុគ្គលនោះមានសេចក្តីស្នេហាជាតិមាតុភូមិយ៉ាងជ្រាលជ្រៅ ។

រីឯចិត្តរំភើបមានឥទ្ធិពលក្នុងការបង្កើននូវកម្លាំងកាយរបស់មនុស្ស ហើយរុញច្រានមនុស្សឱ្យធ្វើសកម្មភាពយ៉ាងខ្លាំងក្លាដូចជា ការសប្បាយ ការស្រែកអរជាពន់ពេកជាដើម ដែលមានលក្ខណៈចិត្តរំភើបដ៏សកម្ម។ ដោយឡែកចិត្តរំភើបអវិជ្ជមាន បានធ្វើឱ្យមនុស្សចុះខ្សោយកម្លាំង ដូចជាការព្រួយបារម្ភ ការអស់សង្ឃឹមជាដើម ។

## ១០. ចរិតសង្គមប្រវត្តិនៃសញ្ចេតនារបស់មនុស្ស

មនុស្សជាភាវៈសង្គម ដូចនេះ គ្រប់បាតុភូតចិត្តរបស់មនុស្សមានចរិតសង្គម ។ ក្នុងលំនាំរីកចម្រើននៃប្រវត្តិសាស្ត្រសង្គម សញ្ចេតនាថ្មីៗបានកើតឡើង។ សញ្ចេតនាខ្លះកាលពីមុនមាននាទីសំខាន់ក្នុងផ្លូវចិត្តរបស់មនុស្សតែឥឡូវត្រូវបាត់បង់ទៅវិញ ។

ឧទាហរណ៍៖ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មានមនុស្សមួយចំនួនជាជនគំរូឱ្យរបបនោះ ពោលគឺរបបប្រល័យពូជសាសន៍។ ជនមួយចំនួននោះ បានប្រព្រឹត្តនូវអំពើអមនុស្សធម៌ សាហាវយង់ឃ្នង កាប់សម្លាប់ ជនរួមជាតិឯង ដែលជាជនស្លូតត្រង់ ជាជនគ្មានទោសពៃរ៍ដោយឥតត្រាប្រណី។ បច្ចុប្បន្នក្នុងសង្គមថ្មី មនុស្សគ្រប់រូបបាន និងកំពុងកសាងខ្លួនឱ្យសមជាពលរដ្ឋថ្លៃថ្នូរ និងមានការគោរពសិទ្ធិសេរីភាពស្មើគ្នាក្រោមច្បាប់កំណត់។ យើងឃើញថា

មនុស្សម្នាក់អាចពេលមុននាំមក សញ្ចេតនាអវិជ្ជមាន តែក្រោយមកបែរជានាំមកនូវសញ្ចេតនាវិជ្ជមានវិញ។

និយាយរួម សញ្ចេតនាមានចរិតសង្គមច្បាស់លាស់ ព្រោះសញ្ចេតនាជាលទ្ធផលនៃសង្គម ដែលពោរពេញទៅដោយខ្លឹមសារ និងអត្ថន័យធំធេងសម្រាប់សង្គមនីមួយៗ ។

### ១១. ទំនាក់ទំនងរវាងសញ្ចេតនា ពុទ្ធិ និងអំពើ

ជីវិតចិត្តរបស់មនុស្ស កើតមានឡើងដោយកត្តាមូលដ្ឋានបីគឺ ពុទ្ធិ សញ្ចេតនា និង អំពើ ។ ក្នុងនោះ សញ្ចេតនាមាននាទីសំខាន់ជាងគេ ព្រមទាំងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងកត្តាផ្សេងទៀត។

ពុទ្ធិជាពន្លកនៃសញ្ចេតនា ផ្ទុយទៅវិញសញ្ចេតនាជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើពុទ្ធិ។ ទំនាក់ទំនងរវាងពុទ្ធិ និងសញ្ចេតនាមានភាពស្មុគស្មាញ ដូចនេះបើសញ្ចេតនាមិនផ្សារភ្ជាប់ទៅនឹងពុទ្ធិនោះទេ ខ្លឹមសារនៃពុទ្ធិនឹងគ្មានន័យហើយគ្រាន់តែជាការក្លែងបន្លំប៉ុណ្ណោះ។ ក្នុងករណីខ្លះដែលសញ្ចេតនាខ្លាំងអាចនាំឱ្យពុទ្ធិដើរឆ្ពោះទៅរកផ្លូវខុស ។

សញ្ចេតនារបស់មនុស្សត្រូវបានកើតឡើង និងរីកលូតលាស់ក្នុងសកម្មភាពរបស់មនុស្ស។ សញ្ចេតនា គឺជាកម្លាំងចលករនៃអំពើរបស់មនុស្ស ពិសេសសិល្បសញ្ចេតនាជាកម្លាំងខ្លាំងជាងគេ។

ឧទាហរណ៍៖ កាលណាគេស្រឡាញ់ការសិក្សា គេសប្បាយចិត្តទទួលយកចំណេះដឹងគ្រប់មុខវិជ្ជា មានអំណត់ព្យាយាមក្នុងការសិក្សា មានគំនិតស្វែងយល់គ្រប់បញ្ហា។

### ១២. ជីវិតសញ្ចេតនារបស់ជំទង់

នៅដំណាក់វ័យនេះ អំណះអំណាងបុគ្គលិកលក្ខណៈជាតម្រូវការចាំបាច់របស់ជំទង់។ ទិដ្ឋភាពផ្សេងៗនៃការវិវត្តរបស់ជំទង់ក៏តម្រង់ឆ្ពោះទៅរកទិសដៅសំខាន់តែមួយនេះដែរ។ ក្នុងនោះមានទំនាក់ទំនងជាមួយមិត្តភក្តិ សហគមន៍មនុស្សពេញវ័យ និងជាមួយភេទខុសគ្នា។

#### ក. មិត្តភាព និង ស្នេហានៅវ័យជំទង់

ជំទង់ប្រាថ្នាចង់បានមិត្តភាពស្ថិតស្ថេរយូរអង្វែង។ ពេលនេះជំទង់ចាប់ផ្តើមមានមិត្តសម្លាញ់ មិត្តស្និទ្ធស្នាល និងជាពិសេសគេចង់បានកល្យាណមិត្ត ដែលមិនអាចបែកពីគ្នាបានអស់មួយជីវិត ដើម្បីគេអាចប្រាប់រឿងអាថ៌កំបាំង សេចក្តីប៉ងប្រាថ្នា ឬគម្រោងការខ្លះដែលគេរក្សាទុកជាសម្ងាត់ពីមនុស្សចាស់ ។

ជាមួយនឹងភាពគ្រប់ការ សញ្ចេតនារវាងភេទទាំងពីរក៏ចាប់កើតមាន។ មិត្តភាពនេះបាត់បង់ធាតុដើមរបស់វាបន្តិច ព្រោះវាបង្កប់សេចក្តីស្នេហានៅក្នុងនោះ។ នេះជាទិដ្ឋភាពមួយថ្មីដែលអ្នកចិត្តវិទូហៅថា"មិត្តភាពស្នេហា"។ បញ្ហានេះគឺសំខាន់ណាស់ ដែលអ្នកអប់រំគ្រប់រូបគួរតែយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លា ។

#### ខ. ចិត្តរំភើប និងសញ្ចេតនាជំទង់

នៅដំណាក់កាលនេះ សញ្ចេតនារបស់ជំទង់មានភាពជ្រាលជ្រៅហើយស្មុគស្មាញ។ ការសម្តែងចេញនៃចិត្តរំភើប និងសញ្ចេតនាមានប្លែកៗដូចជា សប្បាយហួសហេតុ តវ៉ាយ៉ាងខ្លាំង ព្រួយបារម្ភខ្លាំង ក្លាហានហួស តប់ប្រមល់ខ្លាំងជាដើម។ ជាទូទៅប្រតិកម្មនៃចិត្តរំភើបនេះមានភាពខ្លាំងក្លា ហើយពិបាកទៀតផង។

ដូចនេះមនុស្សពេញវ័យត្រូវតែបង្ហាញនូវភាពស្ងប់ស្ងាត់ ភាពទន់ភ្លន់ និងភាពម៉ឺងម៉ាត់ចំពោះជំទង់ជានិច្ច ។ ជំទង់ផ្លាស់ប្តូរទឹកមុខជាញឹកញយ បណ្តាលមកពីភាពមិនជាប់លាប់នៃចិត្តរំភើប និងសញ្ចេតនា។ ជំទង់សប្បាយក៏ងាយ កើតទុក្ខក៏ងាយ នៅក្នុងល្បែងដំបូងគេឃើញវាស្រុះស្រួលនឹងគ្នា ប៉ុន្តែបន្តិចក្រោយមក ត្រឡប់ជាមានជម្លោះ និងមានការបែកបាក់គ្នាទៅវិញ ។

និយាយរួមចិត្តរំភើប និងសញ្ចេតនារបស់ជំទង់មានភាពហ៊ាស រស់រវើក ពុះកញ្ជ្រោល និងផ្លាស់ប្តូរយ៉ាងងាយ។

#### គ. ការអប់រំសញ្ចេតនាដល់សិស្ស

សញ្ចេតនាមានអត្ថន័យធំធេងចំពោះជីវិតរបស់មនុស្ស ព្រោះសញ្ចេតនាជាកម្លាំងចលករ ដែលជំរុញមនុស្សឱ្យ

កែប្រែឥតឈប់ឈរទៅតាមពិភពបរានុម័ត។ ដូចនេះការអប់រំសញ្ចេតនា គឺជាភារកិច្ចដ៏សំខាន់នៃការអប់រំទូទៅ ។

គ.១. ដើម្បីអប់រំសិស្សឱ្យក្លាយទៅជាពលរដ្ឋល្អក្នុងសង្គមប្រជាធិបតេយ្យ គេត្រូវបណ្តុះសិស្សនូវសញ្ចេតនាសកម្មខ្លាំងក្លា និងស្ថិតស្ថេរ ហើយប្រែក្លាយសញ្ចេតនាទាំងនេះឱ្យទៅជាតម្រូវការជាកម្លាំងជំរុញសកម្មភាពរបស់សិស្សក្នុងការសិក្សា ការស្រាវជ្រាវរកសច្ចធម៌ និងមានបំណិនក្នុងការដោះស្រាយបញ្ហាដោយខ្លួនឯង តាមលក្ខណៈវិទ្យាសាស្ត្រ។

គ.២. គេត្រូវអប់រំផងដែរ នូវសញ្ចេតនាវិជ្ជមាន និងលុបបំបាត់ចោលនូវសញ្ចេតនាអវិជ្ជមាន។ ដូចនេះ គ្រូបង្រៀនត្រូវអប់រំសិស្សឱ្យស្រឡាញ់ និងប្រព្រឹត្តអំពើល្អ ឱ្យស្អប់ហើយប្រឆាំងនឹងអំពើអាក្រក់។

គ.៣. តាមធម្មតាសញ្ចេតនារបស់ជំទង់ ត្រូវបានផ្សារភ្ជាប់ទៅនឹងរូបារម្មណ៍។ ដូចនេះគេត្រូវបណ្តុះជំទង់នូវរូបភាពដែលប្រកបដោយលក្ខណៈ សប្បាយរីករាយតាមគ្រប់មធ្យោបាយ។

ការអប់រំសញ្ចេតនារបស់ជំទង់ជាសិល្បៈមួយ ដូចនេះ គ្រូបង្រៀនមានតួនាទីនឹងបង្ហាញគំរូសីលធម៌រស់នៅល្អឥរិយាបថសមរម្យ និងធ្វើការអប់រំផ្នែកសីលធម៌ដល់ជំទង់ជារៀងរាល់ពេល ដោយហេតុថា គ្រូបង្រៀនជាកញ្ចក់ដ៏ភ្លឺស្វាងសម្រាប់ឱ្យ ជំទង់ឆ្លុះ និងយកតម្រាប់តាម ។

## IV- សន្និដ្ឋាន

យើងជាគ្រូបង្រៀន ត្រូវបង្ហាញឱ្យឃើញនូវគំរូល្អដ៏ប្រពៃដល់សិស្ស ដើម្បីឱ្យសិស្សទាំងឡាយត្រាប់តាម ហើយជាល្បិចដ៏ល្អប្រសើរក្នុងការអប់រំសញ្ចេតនា។

### សំណួរ

១. តើចិត្តរំភើបជាអ្វី? សញ្ចេតនាជាអ្វី?

២. តើសញ្ចេតនារបស់មនុស្ស មានចរិតសង្គមប្រវត្តិដូចម្តេច?

៣. តើការអប់រំសញ្ចេតនាដល់សិស្សនាំឱ្យមានអត្ថប្រយោជន៍យ៉ាងដូចម្តេចខ្លះ?

៤. តើយើងត្រូវធ្វើដូចម្តេច ដើម្បីអប់រំសញ្ចេតនាវិជ្ជមានដល់សិស្ស?

# មេរៀនទី១៣ រចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ

បុគ្គលិកលក្ខណៈ គឺជាសភាពនៃការសម្តែងចេញនូវសកម្មភាពរបស់បុគ្គលនីមួយៗចំពោះសង្គម ។ តម្លៃនៃបុគ្គលនីមួយៗនៅក្នុងសង្គមសង្កត់ធ្ងន់ជាពិសេសលើសីលធម៌ គុណធម៌ ចំណេះដឹង ឋានៈ និងតួនាទីរបស់បុគ្គលនោះនៅក្នុងសង្គម ។

ដោយសារបុគ្គលិកលក្ខណៈជាបាតុភូតសង្គមមួយដែលស្មុគស្មាញ ធ្វើឱ្យអ្នកស្រាវជ្រាវវិទ្យាសាស្ត្រមានការចាប់អារម្មណ៍យ៉ាងខ្លាំង និងធ្វើការសិក្សាលើបញ្ហាស្តីពីរចនាសម្ព័ន្ធនៃបុគ្គលិកលក្ខណៈនោះ ។

បុគ្គលិកលក្ខណៈចែកចេញជារចនាសម្ព័ន្ធបួនយ៉ាងគឺ ៖

- ទំនោរ
- អត្តចរិត
- ឫកពា
- សម្បទា

## ទំនោរ

### I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- រៀបរាប់បានពីបញ្ញត្តិ និងធាតុរបស់ទំនោរ
- បកស្រាយពីធាតុសំខាន់ៗរបស់ទំនោរ
- មានស្មារតីប្រើប្រាស់មេរៀនទំនោរក្នុងការបង្រៀនជាប្រចាំ ។

### II- សេចក្តីផ្តើម

នៅក្នុងជីវភាពរស់នៅ និងក្នុងសកម្មភាព(ជីវភាពផ្នែកសម្ភារៈ ការសិក្សា ការងារ...) មនុស្សខំប្រឹងយកចិត្តទុកដាក់ចំពោះវត្ថុបំណងមួយជាក់លាក់ដែលគេចាត់ទុកថា មានអត្ថន័យធំធេងសម្រាប់ខ្លួនគេ ។

ដើម្បីសិក្សាឱ្យបានច្បាស់លាស់យើងត្រូវមានសៀវភៅ ឯកសារគ្រប់គ្រាន់ និងមានសម្ភារៈផ្សេងៗទៀតដែលជាតម្រូវការចាំបាច់សម្រាប់ជីវភាពរបស់គរុសិស្សទៅតាមឧត្តមគតិដ៏ល្អថ្លៃថ្លា ។ វត្ថុបំណងដែលគេចង់បានគេមានតណ្ហា និងតម្រង់ទិសទៅរកគឺជាការស្តែងនៃទំនោរ។

### III- ខ្លឹមសារ

#### ១. និយមន័យ

ទំនោរ គឺជាលក្ខណៈចិត្តស្មុគស្មាញរបស់បុគ្គល និងជាប្រព័ន្ធនៃកម្លាំងចលករខាងក្នុង ដែលកំណត់នូវចរិតសកម្មរបស់បុគ្គល និងការជ្រើសរើសឥរិយាបថរបស់ខ្លួនចំពោះតថភាពសត្យានុម័ត។ ទំនោរជាកម្លាំងចលករដែលរុញច្រានមនុស្សឱ្យប្រព្រឹត្តទៅតាមទិសដៅណាមួយ។

ឧទាហរណ៍៖ អ្នកចូលចិត្តភ្លេង ពេលជួបនឹងឧបករណ៍ភ្លេងតែងតែចង់បាន ឬមួយស្តាត់ទៅរកកន្លែងណាដែលមានភ្លេង។ អ្នកខ្លះចូលចិត្តគំនូរ តែងតែចំណាយពេលវេលាជាច្រើនធ្វើការស្វែងយល់ និងចូលទៅទស្សនាការតាំងពិព័រណ៍គំនូររូបភាព។ ចំណែកអ្នកស្រឡាញ់មុខរបរគ្រូបង្រៀនជាអ្នកស្រឡាញ់កុមារ និងមានបំណងលើកកម្ពស់ធនធានមនុស្សបានស្ម័គ្រចិត្តប្រឡងចូលមកសិក្សានៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ឬសាលាគរុកោសល្យរាជធានី ខេត្ត។

ដូចនេះទំនោរ ជាប្រព័ន្ធកម្លាំងចលករនៃបុគ្គលិកលក្ខណៈ គឺមានន័យថា ទំនោរមាននាទីសម្រាប់រុញច្រានឱ្យ

មនុស្សប្រព្រឹត្ត និងកំណត់ទិសដៅសកម្មភាពធម្មតារបស់ខ្លួន។

ឧទាហរណ៍៖ សិស្ស"ក" មានទំនោរក្នុងការអានសៀវភៅ។ ទំនោរនេះរុញច្រានសិស្ស"ក" ឱ្យរកសៀវភៅដើម្បីអាន និងរុញច្រានសិស្ស"ក" ឱ្យទៅកាន់បណ្ណាល័យ។

### ២. ការស្តែងចេញដ៏ចាំបាច់នៃធាតុរបស់ទំនោរ

ទំនោរត្រូវបានសម្តែងចេញឱ្យឃើញតាមរយៈ៖

**ក. តម្រូវការ ៖** គឺជាសំណូមពរចាំបាច់មួយ ដែលអាចឱ្យមនុស្សរស់នៅ និងរីកលូតលាស់បានក្នុងមជ្ឈដ្ឋានរបស់ខ្លួន។

ឧទាហរណ៍៖ យើងត្រូវការបរិភោគ(មានតម្រូវការមួយកើតឡើង) គឺធ្វើឱ្យយើងទៅរករបស់អ្វីមួយដើម្បីហូប ហើយវាបង្ខំឱ្យយើងដើរទៅរកកន្លែងដែលមានរបស់ហូប។

ឧទាហរណ៍៖ យើងមានទំនោរអានសៀវភៅ ពេលនោះយើងមានតម្រូវការមួយគឺ រកសៀវភៅដើម្បីអាន។ តម្រូវការនេះជំរុញឱ្យយើងទៅរកបណ្ណាល័យ ដើម្បីរកខ្ចីសៀវភៅសម្រាប់អាន។

មនុស្សម្នាក់ៗមានតម្រូវការច្រើនប្រភេទដូចជា៖

- **តម្រូវការផ្នែក សម្ភារៈ ៖** មនុស្សត្រូវការហូបចុក ត្រូវការជីវជាតិផ្សេងៗ គ្រឿងសម្រាប់ផឹក សម្លៀកបំពាក់ កន្លែងស្នាក់នៅ សម្ភារៈប្រើប្រាស់...។
- **តម្រូវការផ្នែកស្មារតី៖** តម្រូវការចំណេះដឹង សុវត្ថិភាពផ្ទាល់ខ្លួន សេរីភាពដូចជាការនិយាយស្តី សោភណភាព សិទ្ធិអំណាចស្របច្បាប់ តម្រូវការយុត្តិធម៌ និងតម្លាភាពក្នុងសង្គម សុជីវធម៌ ជំនឿទុកចិត្ត ផ្នែកសិល្បៈ ។ល។

### ខ. ចំណូលចិត្ត

ចំណូលចិត្តជាឥរិយាបថនៃបុគ្គលចំពោះវត្ថុទាំងឡាយ ដែលមានអត្ថន័យសំខាន់សម្រាប់បម្រើជីវិតរស់នៅរបស់បុគ្គលនីមួយៗ និងដែលធ្វើឱ្យបុគ្គលមានទំនាក់ចិត្ត។

ឧទាហរណ៍៖ គ្រូបង្រៀនគណិតវិទ្យា ពេលចូលបណ្ណាល័យគាត់ទាក់ចិត្តនឹងសៀវភៅ គណិតវិទ្យា។

ចំណូលចិត្តជាកម្លាំងចលករជួយជំរុញឱ្យលំនាំចិត្តមានសកម្មភាព និងធ្វើឱ្យលំនាំចិត្តនោះប្រព្រឹត្តទៅកាន់តែល្អប្រសើរ ជាពិសេសចំណូលចិត្តបានបង្កើនសមត្ថភាពការងារ។ ដូចនេះរាល់ការបង្រៀនគ្រូគប្បីបង្កើនចំណូលចិត្តដល់សិស្សរាល់គ្រប់មុខវិជ្ជាក្នុងពេលបង្រៀន ដើម្បីឱ្យគេឈោងចាប់យកនូវចំណេះដឹងបានច្បាស់លាស់។

ចំណូលចិត្តរបស់មនុស្សមានទំនាក់ទំនងនឹងតម្រូវការ សញ្ចេតនា ចរិត សម្បទា កម្រិតវប្បធម៌ ការអប់រំ។ល។ ដែលជាបាតុភូតផ្លូវចិត្តសម្រាប់ការអភិវឌ្ឍបុគ្គលិកលក្ខណៈនៃបុគ្គលនីមួយៗ។

### គ. លោកទស្សនៈ

លោកទស្សនៈគឺជាប្រព័ន្ធទស្សនៈនៃបុគ្គលចំពោះធម្មជាតិ សង្គម និងមនុស្ស។ លោកទស្សនៈជាមនោគមវិជ្ជាចំពោះវណ្ណៈមួយ ឬសង្គមមួយ ។ លោកទស្សនៈជាត្រីវិស័យនៃសកម្មភាពរបស់មនុស្ស បានន័យថាលោកទស្សនៈកំណត់ឥរិយាបថនៃបុគ្គល ចំពោះតថភាពបានុម័ត ហើយជាគ្រឹះនៃសីលធម៌ ។

ឧទាហរណ៍ ៖

- ការគោរពសិទ្ធិមនុស្ស ការបណ្តុះទឹកចិត្ត ស្រឡាញ់ធម្មជាតិ ស្រឡាញ់បរិស្ថានជាលោកទស្សនៈ ។
- ការអប់រំជួយដល់ការកាត់បន្ថយភាពក្រីក្រ ។

### ឃ. ឧត្តមគតិ

ឧត្តមគតិ គឺជាវត្ថុបំណងដ៏ថ្លៃថ្លា ដែលឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងមនសិការរបស់មនុស្សក្រោមទម្រង់នៃរូបភាពដ៏ល្អឥតខ្ចោះនៃជនគំរូ ឬនៃសង្គមគំរូមួយ ដែលបុគ្គលនីមួយៗខំបញ្ចេញអស់កម្លាំងកាយចិត្តរបស់ខ្លួន ដើម្បីឈោង

ចាប់ឱ្យបាន ។

ឧទាហរណ៍៖ ឧត្តមគតិអ្នកស្នេហាជាតិ គឺមានការស្រាវជ្រាវ និងសិក្សាយ៉ាងច្បាស់លាស់នូវអត្តសញ្ញាណជាតិ មានមនោសញ្ចេតនាចំពោះជនជាតិខ្លួន មានឆន្ទៈមោះមុតក្នុងការការពារបូរណភាពដែនដី ស្រឡាញ់យុត្តិធម៌ និងផ្តល់សេរីភាពដល់ជនគ្រប់រូប។

នៅក្នុងដំណាក់អាយុកំណត់មួយ ឧត្តមគតិ គឺជាស្នូលរបស់បុគ្គលិកលក្ខណៈ ព្រោះឧត្តមគតិជាគោលបំណងនៃជីវិត។ ឧត្តមគតិមានតថនិយមផង និងមានអណ្តែតអណ្តូងនិយមផង ក្នុងនោះវាក៏មានឧត្តមគតិរួម និងឧត្តមគតិជាក់ស្តែងទៀតដែរ។

លក្ខណៈពិសេសនៃឧត្តមគតិ

- ឧត្តមគតិដែលមានភាពតថនិយម គឺជាឧត្តមគតិផ្សារភ្ជាប់នឹងការពិត។

ឧទាហរណ៍៖ យើងមានឧត្តមគតិកសាងជាតិឱ្យមានការអភិវឌ្ឍទាន់ប្រទេសជឿនលឿនក្នុងតំបន់ និងពិភពលោក។

- ឧត្តមគតិអណ្តែតអណ្តូង គឺជាឧត្តមគតិស្ថិតនៅក្នុងការស្រមៃនៃវត្ថុបំណងរបស់បុគ្គលនីមួយៗទៅអនាគត។ ប្រសិនបើឧត្តមគតិនេះស្ថិតនៅយូរអង្វែង ហើយមនុស្សកើតមានចិត្តសារ៉ាផងនោះ ឧត្តមគតិនេះ គ្រាន់តែជាការស្រមៃប៉ុណ្ណោះ ។

- ឧត្តមគតិរួម ជាឧត្តមគតិរបស់បុគ្គលម្នាក់ៗ ដែលជាផលិតផលរបស់សង្គមប្រវត្តិ ហើយដែលសម្តែងចេញរួមគ្នា បង្កើតបានជាឧត្តមគតិសម្រាប់សង្គមមួយ ។

ឧទាហរណ៍៖ យើងមានឧត្តមគតិមួយ គឺកសាងប្រទេសយើងឱ្យមានសោភណភាពល្អឆើតឆាយ ដូចបណ្តាលប្រទេសនៅក្នុងតំបន់អាស៊ីបូព៌ាដូចជា ប្រទេសសិង្ហបុរី កូរ៉េខាងត្បូង ជប៉ុន...។

- ឧត្តមគតិជាក់ស្តែង គឺឧត្តមគតិនៃបុគ្គលម្នាក់ៗ ដែលសម្តែងចេញតាមរយៈអំពើ និងសកម្មភាព ។

ឧទាហរណ៍៖ គរុនិស្សិតមានឧត្តមគតិជាក់ស្តែង គឺចង់ក្លាយខ្លួនជាគ្រូបង្រៀនមួយរូប ប្រកបដោយភាពទន់ភ្លន់ មានទេពកោសល្យខ្ពស់ក្នុងការបង្រៀន និងការអប់រំព្រមទាំងមានវិជ្ជាជីវៈខ្ពង់ខ្ពស់ផង។

## IV- សន្និដ្ឋាន

គ្រូមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាល ដោយធ្វើឱ្យមានការអភិវឌ្ឍនូវចក្ខុវិស័យដល់សិស្សានុសិស្ស ។ ទំនោររបស់បុគ្គលគឺជាមូលដ្ឋានគ្រឹះនៃចិត្តរបស់បុគ្គលនីមួយៗ ដែលជាកម្លាំងចលករកំណត់នូវចរិតសកម្ម និងកំណត់ការជ្រើសរើសឥរិយាបថរបស់បុគ្គលចំពោះតថភាព។ ទំនោរនេះបង្ហាញឱ្យឃើញតាមរយៈតម្រូវការ ចំណូលចិត្ត លោកទស្សនៈ និងឧត្តមគតិរបស់បុគ្គលនីមួយៗ។ ការពង្រីកទំនោរ ការបណ្តុះបណ្តាលទំនោរតាមគ្រប់រូបភាពផ្អែកលើលោកទស្សនៈ និងឧត្តមគតិ ក៏ដូចជាតម្រូវការ និងចំណូលចិត្ត គឺជាការបណ្តុះបណ្តាលធនធានមនុស្សទៅតាមតម្រូវការនៃសង្គមវិទ្យាសាស្ត្រជឿនលឿនបែបប្រជាធិបតេយ្យ។

### សំណួរ

១. ដូចម្តេចដែលហៅថាទំនោរ ? ចូរធ្វើការវិភាគលើរចនាសម្ព័ន្ធនៃទំនោរ។

២. អ្វីទៅហៅថាតម្រូវការ ? តម្រូវការមានប៉ុន្មានប្រភេទ ?

៣. អ្វីទៅហៅថាចំណូលចិត្ត និងតួនាទីរបស់វា ?

៤. ដូចម្តេចហៅថា ឧត្តមគតិ ? ចូរបង្ហាញពីតួនាទីឧត្តមគតិនៅក្នុងការរស់នៅ។

# អត្តចរិត

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់បានពីបញ្ញត្តិ និងលក្ខណៈនៃអត្តចរិត
- កំណត់ចំណុចសំខាន់ៗនៃខ្លឹមសារមេរៀន
- មានស្មារតីទទួលខុសត្រូវលើការសម្តែងចេញអត្តចរិតចំពោះមុខរបរវិជ្ជាជីវៈ និងក្នុងជីភាពប្រចាំថ្ងៃ។

## II- សេចក្តីផ្តើម

អត្តចរិត គឺជាផ្នែកមួយរបស់បុគ្គលិកលក្ខណៈ ។ ដូចនេះមនុស្សម្នាក់ៗចាំបាច់ត្រូវសិក្សាស្វែងយល់ពីអត្តចរិតរបស់បុគ្គល និងពីអត្តចរិតសង្គមជាមុនសិន។

## III- ខ្លឹមសារ

### ១- និយមន័យ

អត្តចរិត ជាសំណុំលក្ខណៈចិត្តរបស់បុគ្គល ដែលសម្តែងប្រាប់នូវឥរិយាបថរបស់បុគ្គលនោះ ចំពោះតថភាពបរានុម័ត ។ ឥរិយាបថនេះស្តែងឡើងដោយអំពើ និងអាកប្បកិរិយារបស់បុគ្គល ។

គេអាចនិយាយបានថា អត្តចរិតមនុស្សម្នាក់ៗ គឺជាបុគ្គលិកលក្ខណៈរបស់បុគ្គលខាងផ្នែក គុណធម៌ សីលធម៌ ទម្លាប់ និងឥរិយាបថ ដែលទាំងអស់នេះសម្តែងឡើងដោយអំពើ និងអាកប្បកិរិយារបស់បុគ្គលនោះ ក្នុងការងារ ក្នុងការសិក្សា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងក្នុងសង្គម។

ឧទាហរណ៍៖ សិស្ស"ក" ឧស្សាហ៍រៀនសូត្រមេរៀន ធ្វើកិច្ចការផ្ទិតផ្ទង់មានរបៀបរៀបរយ។ល។ សិស្ស"ខ" ជាមនុស្សរមទម្យ ចុះសម្រុងនឹងសង្គម ត្រូវបានមិត្តភក្តិរាប់អានដោយសុទ្ធចិត្ត ។ សិស្ស "គ" ជាអត្តទត្ថបុគ្គល គិតតែប្រយោជន៍ផ្ទាល់ខ្លួន គ្មានគិតប្រយោជន៍អ្នកដទៃ ឬប្រយោជន៍សង្គម។

លក្ខណៈឧស្សាហ៍រៀនសូត្រ ភាពរម្យទម និងចុះសម្រុង អត្តទត្ថបុគ្គល ទាំងនេះជាអត្តចរិតរបស់បុគ្គលម្នាក់ៗ ឬហៅម្យ៉ាងទៀតបានថា កិរិយាមាយាទ។ ដូចនេះមនុស្សម្នាក់ៗមានអត្តចរិតដោយឡែកៗពីគ្នា។ អត្តចិតកើតមានដោយផ្ទាល់នៅក្នុងខ្លួនមនុស្សម្នាក់ៗ ហើយជះឥទ្ធិពលដោយផ្ទាល់តាមរយៈអំពើរបស់មនុស្សនោះ។

### ២. លក្ខណៈអត្តចរិត

ជាទូទៅ អត្តចរិតមានលក្ខណៈពីរផ្សេងគ្នា គឺជាគុណសម្បត្តិ និងគុណវិបត្តិ។ តាមធម្មតាអត្តចរិត ត្រូវបានគេកំណត់ទៅលើសីលធម៌ដូចជា អត្តចរិតល្អគឺជាគុណសម្បត្តិ ។

ឧទាហរណ៍៖ ឧស្សាហ៍រៀនសូត្រ ចុះសម្រុង គឺជាគុណសម្បត្តិ... ហើយអត្តចរិតអាក្រក់ គឺជាគុណវិបត្តិរបស់មនុស្សដូចជា អត្តទត្ថបុគ្គល ភាពខ្ជិល ភាពខ្វះស្មារតីទទួលខុសត្រូវ អំពើកោងកាច។ល។ ភាពថ្លៃថ្នូរ ភាពចេះគួរសមគុណធម៌ សេចក្តីអង់អាចក្លាហាន ភាពស្និទ្ធស្នាល ភាពទទួលខុសត្រូវលើការងារ ស្នេហាមាតុភូមិ ភាពអំណត់លើការងារ...ទាំងអស់នេះជាគុណសម្បត្តិរបស់មនុស្ស។ ការប្រព្រឹត្តអំពើទុច្ចរិត ភាពខ្ជិលច្រអូស ភាពក្រអើតក្រទម ភាពវាយឫក ភាពចុះញ៉ម ភាពអសីលធម៌ ភាពមិនម្ចាស់ការទទួលខុសត្រូវលើការងារ ភាពគ្មានការចុះសម្រុង និងភាពគ្មានទំនាក់ទំនងល្អនៅក្នុងសហគមន៍... ទាំងអស់នេះជាគុណវិបត្តិរបស់មនុស្ស។ ជាទូទៅមនុស្សគ្រប់រូបតែងតែមានគុណសម្បត្តិផង និងគុណវិបត្តិផង។ ក្នុងជីវិតរស់នៅ អត្តចរិតបុគ្គល អាចពង្រីកបានដោយខ្លួនឯង តែក៏អាចផ្លាស់ប្តូរដែរ កាលណាលក្ខខណ្ឌសង្គមផ្លាស់ប្តូរ ។ ដូចនេះគេអាចផ្លាស់ប្តូរ អត្តចរិតមនុស្សបានតាមរយៈការអប់រំ ។

ឧទាហរណ៍៖ សិស្សម្នាក់ទៅសាលារៀន នៅសាលារៀនសិស្សនេះនាំយកទៅជាមួយនូវទម្លាប់អាក្រក់មួយគឺទម្លាប់លួច។ ទម្លាប់លួចនេះ សិស្សទទួលបានមកពីគ្រួសាររបស់គេ។ ប៉ុន្តែនៅសាលារៀនសិស្សបានទទួលឥទ្ធិពល

អប់រំពីគ្រូ។ បន្តិចម្តងៗសិស្សនោះក៏ភ្លេចចោលនូវទម្លាប់លួចនេះ ហើយក៏ក្លាយទៅជាអ្នកទៀងត្រង់ដូចគេឯង។

### ៣. ធម្មជាតិនៃអត្តចរិត

ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីអត្តចរិតរបស់មនុស្សម្នាក់ៗ គេគប្បីសិក្សាស្វែងយល់ពីចរិតគ្រួសារ ចរិតមជ្ឈដ្ឋានរស់នៅជុំវិញរបស់បុគ្គលនោះ និងចរិតសង្គមជាមុនសិន។

រួមសេចក្តីមក អត្តចរិតគួបផ្សំដោយឥរិយាបថ ដែលត្រូវបានបែងចែកជាបីក្រុម៖

- ឥរិយាបថចំពោះការងារ
- ឥរិយាបថចំពោះសង្គម និងបរិស្ថានជុំវិញ
- ឥរិយាបថចំពោះខ្លួនឯង

គេនិយាយថា ក្នុងអត្តចរិត ទំនោរជាធាតុដឹកនាំ ឬទំនោរមាននាទីដឹកនាំអត្តចរិតរបស់មនុស្ស ។

### ៤. ចំណុចសំខាន់ៗនៃអត្តចរិត

អត្តចរិតរបស់មនុស្ស គឺជាលក្ខណៈផ្លូវចិត្តរបស់មនុស្ស ដែលសម្តែងប្រាប់នូវឥរិយាបថ ឬឫកពាររបស់បុគ្គលចំពោះតថភាពបរានុម័ត។ គេអាចធ្វើចំណែកថ្នាក់ ដោយប្រៀបធៀបទៅនឹងការងារសង្គម និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ។

#### ៤.១. ការសម្តែងចេញនូវឥរិយាបថចំពោះការងារ

ឥរិយាបថចំពោះការងារ គឺជាការស្រឡាញ់ការងារ ការយកចិត្តទុកដាក់ និងការដក់ចិត្តធ្វើការងារដោយទទួលខុសត្រូវ ព្រមទាំងចេះដកស្រង់នូវបទពិសោធពីការងារ ដើម្បីពង្រីកគុណភាពផលិតកម្មរបស់ខ្លួន។ ដូច្នេះអ្នកដែលស្រឡាញ់ការងារ តែងតែធ្វើការប្រកបដោយស្មារតីទទួលខុសត្រូវ ចេះរៀបចំផែនការតាមបុរេវិនិច្ឆ័យ និងជានិច្ចកាលធ្វើស្វ័យសុក្រឹតការសំដៅលើកកម្ពស់គុណភាពការងាររបស់ខ្លួន។

#### ៤.២. ការសម្តែងចេញនូវឥរិយាបថចំពោះសង្គម និងបរិស្ថានជុំវិញ

មនុស្សមានឥរិយាបថចំពោះសង្គម និងបរិស្ថានជុំវិញ គឺជាប្រភេទមនុស្សដែលមានគំនិតស្នេហាមាតុភូមិពិតប្រាកដមានន័យថា គេមានគំនិតស្នេហាជាតិ ឬកម្រិតជាតិនិយមមោះមុត ហើយចេះផ្សារភ្ជាប់ជីវភាពរស់នៅរបស់ខ្លួនទៅនឹងជីវភាពរបស់មនុស្សជាទូទៅក្នុងសង្គម។ អ្វីទៅដែលហៅថាអ្នកស្នេហាមាតុភូមិពិតប្រាកដនោះ គឺជាជនតស៊ូដើម្បីមាតុភូមិខ្លួន ដើម្បីឱ្យមានឯករាជ្យបរិបូរណ៍ មានសន្តិភាពមានសេរីភាព មានលទ្ធិប្រជាធិបតេយ្យពិតប្រាកដរក្សាបាននូវបូរណភាពទឹកដីពេញលេញ ប្រកាន់នូវអព្យាក្រឹតភាព ហើយជានិច្ចកាលប្រឆាំងនឹងអំពើពុករលួយ ការរំលោភសិទ្ធិមនុស្ស ការបំបាត់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិការកេងប្រវ័ញ្ចញើសឈាមប្រជាពលរដ្ឋស្លូតត្រង់ ការបំផ្លាញសម្បត្តិជាតិ រួមមានសម្បត្តិវប្បធម៌ បេតិកភ័ណ្ឌជាតិ និងធម្មជាតិ រួមមានព្រៃឈើ មច្ឆាជាតិ និងសម្បត្តិក្នុងដី ការបំពុលបរិស្ថានជាដើម...។ល។ ម្យ៉ាងទៀត ការសម្តែងចេញនូវឥរិយាបថចំពោះសង្គម គឺជាការបង្ហាញនូវឥរិយាបថចំពោះសមូហភាព គឺការគោរពសមូហភាព និងសហគមន៍ ព្រមទាំងការបង្ហាញអត្តចរិតជាមនុស្សធម៌ ប្រកបដោយគុណធម៌មានតម្លាភាព និងសមធម៌ ដែលជាគុណសម្បត្តិរបស់មនុស្សជាតិទូទៅតាមរយៈ ការចេះគួរសម សម្បុរសធម៌ និងសេចក្តីសន្តោសត្រាប្រណី។

#### ៤.៣. ការសម្តែងចេញនូវឥរិយាបថផ្ទាល់ខ្លួន

ឥរិយាបថផ្ទាល់ខ្លួន គឺជាសភាពចរិតលក្ខណៈរបស់មនុស្ស ដែលយល់ដឹងដោយខ្លួនឯងនូវសកម្មភាពដែលខ្លួនបានប្រព្រឹត្តអំពើល្អ ឬអាក្រក់។ តាមរយៈនេះអត្តចរិតផ្ទាល់ខ្លួនបង្ហាញនូវអាកប្បកិរិយារមេទម្យពោលគឺការយល់ដឹងនូវអំពើណាដែលមិនចុះសម្រុងទៅនឹងសង្គម។ មនុស្សដែលស្គាល់ឥរិយាបថផ្ទាល់ខ្លួន តែងប្រកាន់យកនូវចរិតមួយចំនួនដូចជា ចេះវាយតម្លៃខ្លួនឯង(ស្វ័យវាយតម្លៃ) ដោយគតិយុត្តិធម៌ ចេះវិភាគដោយខ្លួនឯងនូវសកម្មភាពដែលខ្លួន

បានប្រព្រឹត្តចេះធ្វើស្ងៀមស្ងាត់ទៅមិនដល់ និងចេះកែលម្អដោយខ្លួនឯង ចេះជួយទុក្ខធុរៈអ្នកដទៃដោយមិនសម្លឹងលើគុណបំណាច់ ហើយចូលចិត្តយកមតិអ្នកដទៃមកពិចារណា ។ ការគោរពខ្លួនឯងក៏ជាអំពើមួយ បង្ហាញនូវឥរិយាបថផ្ទាល់ខ្លួន ដូចជាភាពមានទំនុកចិត្តលើសកម្មភាពផ្ទាល់ខ្លួន និងការរៀបចំអាកប្បកិរិយាសមរម្យចំពោះសហគមន៍ និងបរិស្ថានជុំវិញ។

## IV- សន្និដ្ឋាន

អត្តចរិតរបស់មនុស្សមានការអភិវឌ្ឍពេញមួយជីវិតមានន័យថា គ្រប់វ័យនៃជនគ្រប់រូបនៅក្នុងសង្គម។ ការបណ្ដុះស្មារតីអប់រំល្អគឺមានន័យថា អត្តចរិតរបស់មនុស្សមានសុជីវធម៌ខ្ពស់ជាកិត្យានុភាព និងការអភិវឌ្ឍសម្រាប់សង្គមទាំងមូល។ មជ្ឈដ្ឋានដែលជះឥទ្ធិពលខ្លាំងដល់ការអប់រំអត្តចរិតមនុស្សគឺ សង្គម បរិស្ថានសង្គម សាលារៀន និងគ្រួសារ។

### សំណួរ

១. ដូចម្ដេចហៅថា អត្តចរិត ?

២. តើអត្តចរិតសម្ដែងចេញនូវឥរិយាបថអ្វីខ្លះចំពោះសង្គម និងការងារ ?

៣. តើអត្តចរិតយ៉ាងដូចម្ដេចដែលសម្ដែងចេញនូវគុណសម្បត្តិ ?

៤. តើអត្តចរិតរបស់មនុស្សអាចកែប្រែបានឬទេ ? ចូរពន្យល់។

៥. តើអត្តចរិតរបស់មនុស្សអាចអប់រំបានដែរឬទេ ? ព្រោះអ្វី ?

# ឫកពា

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់ពីនិយមន័យ ឫកពាដោយប្រៀបធៀបទៅនឹងអត្តចរិត
- ប្រៀបធៀបទស្សនៈស្តីពីឫកពារបស់លោកអ៊ីប៉ូក្រាត និងលោកប៉ាវឡូវ
- ចូលរួមយ៉ាងសកម្មក្នុងការអប់រំសិស្សឱ្យមានឫកពាល្អ ក្នុងសង្គម។

## II- សេចក្តីផ្តើម

នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃកាលណាគេពិនិត្យសង្កេតមើលទឹកចិត្តរបស់អ្នករស់នៅជិតខាងគេអាចធ្វើចំណាត់ថ្នាក់មនុស្សទាំងអស់នោះទៅតាមប្រភេទផ្សេងៗគ្នាដោយឈរលើមូលដ្ឋាននៃលក្ខណៈសម្គាល់យ៉ាងសំខាន់ដែលស្តែងឱ្យឃើញជានិច្ចលើរាល់សកម្មភាពផ្លូវចិត្តរបស់អ្នកទាំងនោះ។

## III- ខ្លឹមសារ

### ១. និយមន័យ

ឫកពាគឺ ជាលក្ខណៈចិត្តដែលសម្តែងប្រាប់នូវលក្ខណៈដោយឡែកនៃអាកប្បកិរិយានិងសកម្មភាពរបស់បុគ្គល។

ឧទាហរណ៍៖ ក្នុងជីវភាពរស់នៅរាល់ថ្ងៃ គេអាចធ្វើការសង្កេតចិត្តគំនិតរបស់អ្នកនៅជុំវិញ ឬអ្នកជិតខាងដោយផ្អែកលើលក្ខណៈពិសេសៗដែលសម្តែងចេញតាមរយៈសកម្មភាពរបស់មនុស្សនោះ ។

ឆ្លងតាមការសង្កេតនេះ គេបានកត់សម្គាល់ឃើញថា មនុស្សខ្លះមានអត្តចរិតដូចគ្នា ប៉ុន្តែការសម្តែងចេញមកខាងក្រៅមានសភាពខុសគ្នា។ នេះបណ្តាលមកពីគេមានឫកពាខុសគ្នា ។

ឧទាហរណ៍៖ សិស្ស"ក" និង"ខ" មានអត្តចរិតស្រឡាញ់ពលកម្មដូចគ្នា។ ប៉ុន្តែសិស្ស"ក" បំពេញការងារដោយរហ័សរហួន រីឯសិស្ស"ខ"វិញធ្វើការងារអ៊ីយឺត តែស្អិតស្អាងទៀងទាត់។ ទីបញ្ចប់សិស្សទាំងពីរនេះអាចបំពេញការងារបានចប់សព្វគ្រប់ដូចគ្នា ។

ឧទាហរណ៍៖ ក្នុងល្បែងគេសង្កេតឃើញកុមារខ្លះមានភាពសកម្មខ្លាំង ខ្លះមានភាពនឹងនរ ខ្លះរ៉ូងរ៉ាង ខ្លះស្វាហាប់ ខ្លះទៀតទុយមុយកំសាក...ទាំងនេះមកពីឫកពាដែរ។

តាមឧទាហរណ៍ខាងលើនេះ យើងឃើញថា បុគ្គលនីមួយៗមានអាកប្បកិរិយាដោយឡែកពីគ្នា មានរបៀបធ្វើការដោយឡែកពីគ្នាដែរ។ លក្ខណៈ ឬចំណុចដោយឡែកពីគ្នាទាំងនេះជាឫកពាផ្ទាល់នៃបុគ្គលនីមួយៗ ហើយបុគ្គលម្នាក់ៗ ខុសប្លែកពីបុគ្គលដទៃទៀត។ ដូចនេះ លក្ខណៈដោយឡែកទាំងនេះដែលមាននៅក្នុងអាកប្បកិរិយា និងក្នុងសកម្មភាពបង្កើតបានជាឫកពានៃបុគ្គលម្នាក់ៗ។

ដើម្បីយល់ឱ្យបានច្បាស់លាស់អំពីឫកពារបស់មនុស្ស គេគប្បីសិក្សាស្វែងយល់ឱ្យបានហ្មត់ចត់ទៅលើកម្លាំង និងភាពរាងវៃនៃដំណើរការរបស់សរសៃប្រសាទ ព្រោះសរីរវិទ្យាស្តីពីសរសៃប្រសាទជួយឱ្យយើងអាចសិក្សាស្រាវជ្រាវ ពីឫកពាររបស់មនុស្សម្នាក់ៗបាន ។

### ២. ការពន្យល់អំពីឫកពា

តាំងពីបុរាណសម័យលោក អ៊ីប៉ូក្រាត(៤៦០-៣៥៦ មុនគ.ស)ដែលជាគ្រូពេទ្យដ៏ល្បីល្បាញនៃប្រទេសក្រិចសម័យបុរាណ បានធ្វើការបែងចែកមនុស្សជាតិជាបួនប្រភេទ ដោយពន្យល់ពីភាពខុសគ្នានៃឫកពា តាមវត្តមាននៃវត្ថុរាវបួនយ៉ាងខុសៗគ្នានៅក្នុងសព៌ាង្គកាយ។ វត្ថុរាវទាំងបួននោះគឺ **ឈាម អ៊ុយម័រអាបោធាតុ ឬ ធាតុទឹកក្នុងខ្លួន ទឹកប្រមាត់លឿង និងទឹកប្រមាត់ខ្មៅ** ។ លក្ខណៈទាំងនេះកំណត់ឫកពា៤ប្រភេទដូចតទៅ៖

- ប្រភេទទី១៖ ប្រភេទឈាមរាវ មានឫកពាចិត្តមុត ចំពោះអ្នកដែលមានឈាមច្រើន។ គឺជាប្រភេទឫកពាសកម្មភាព ឬក្តៅរ៉ក្លា។

- ប្រភេទទី២៖ អ៊ីយម័រអាបោធាតុ ឬ ធាតុទឹកក្នុងខ្លួន មានឫកពាចិត្តរឹងប៉ឹង ។ នេះជាប្រភេទមនុស្សមានឫកពានឹងនរមិនងាយច្រឡោត ។

- ប្រភេទទី៣៖ ទឹកប្រមាត់លឿងច្រើននៅក្នុងថ្លើម មានឫកពាកាច ចិត្តស្រាល ។ គឺជាប្រភេទឫកពាឆាប់ញោចឆាប់ច្រឡោត ឆេវឆាវ ។

- ប្រភេទទី៤៖ ទឹកប្រមាត់ខ្មៅច្រើនមានឫកពាព្រួយច្រើន។ គឺជាប្រភេទឫកពាកើតទុក្ខ ចូលចិត្តនៅម្នាក់ឯង ហើយកង្វល់ច្រើន ។

ក្រោយមកបាតុភូតនេះត្រូវបានលោក ប៉ាវឡូវ ពន្យល់ពីភាពខុសគ្នានៃឫកពាតាមប្រភេទនៃសកម្មភាពសរសៃប្រសាទ។ ក្នុងសកម្មភាពសរសៃប្រសាទមានលំនាំពីរគឺ **រំញោច និងការទប់។** លំនាំទាំងពីរនេះអាចបណ្តាលឱ្យសកម្មភាពសរសៃប្រសាទ "ខ្លាំង ឬខ្សោយ" "មានលំនឹង ឬគ្មានលំនឹង" "រហ័ស ឬមិនរហ័ស" ។ ឫកពាគឺជាការសម្តែងចេញរបស់សកម្មភាពសរសៃប្រសាទ។ ផ្អែកលើលក្ខណៈទាំងបីនេះហើយដែលលោក ប៉ាវឡូវ បានកំណត់ប្រភេទទាំងបួនរបស់ឫកពាដូចតទៅ៖

- ប្រភេទទី១៖ សកម្មភាពសរសៃប្រសាទខ្លាំង មានលំនឹង រហ័ស ប្រភេទឫកពាសកម្ម ចិត្តមុត ឬឈាមរាវ ។ មនុស្សដែលមានឫកពាប្រភេទនេះ ជាមនុស្សឆាប់យល់ដឹង ឆាប់មានសញ្ចេតនារីករាយ រាក់ទាក់ ក្តៅរ៉ក្លា គឺជាមនុស្សដែលឆាប់សម្របខ្លួនបានទៅនឹងមជ្ឈដ្ឋានថ្មី ។

ឧទាហរណ៍៖ សិស្សដែលមានឫកពាប្រភេទទី១ ជាសិស្សដែលមានទឹកមុខរីករាយ រហ័សរហួន ឆាប់សម្របខ្លួនបានទៅនឹងវិន័យសាលា ឆាប់ធ្វើឱ្យគ្រូស្រឡាញ់ មិត្តភក្តិឆាប់រាប់អាន ឆាប់យល់មេរៀន ចូលចិត្តមើលមេរៀនថ្មីជាងមេរៀនចាស់ រៀនសារឡើងវិញ ។ សិស្សរបៀបនេះមានតម្រូវការមួយចាំបាច់គឺ សកម្មភាពថ្មីៗចំពោះគេ ។

- ប្រភេទទី២៖ មានសកម្មភាពសរសៃប្រសាទខ្លាំង មានលំនឹង តែមិនរហ័ស ប្រភេទឫកពានឹងនរ ចិត្តរឹងប៉ឹង ។ មនុស្សឫកពាប្រភេទទី២នេះជាមនុស្សស្ងប់ស្ងៀម ប្រុងប្រយ័ត្ន ស្វិតស្វាញ មានលំនឹងមិនតក់ក្រហលមុននឹងធ្វើកិច្ចការអ្វីមួយ គេគិតពិចារណាថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយ ដូចសុភាសិតមួយពោលថា "មុននឹងនិយាយត្រូវបង្វិលអណ្តាតប្រាំពីរដងសិន"។ ប៉ុន្តែគេមានគុណវិបត្តិខ្លះដូចជា មានភាពយឺតយ៉ាវ មិនសូវក្តៅរ៉ក្លា លំបាកក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលនៃមជ្ឈដ្ឋានជុំវិញ ពិបាកនឹងសម្របខ្លួនចូលក្នុងសហគមន៍ថ្មី ។

ឧទាហរណ៍៖ សិស្សដែលមានឫកពាប្រភេទទី២នេះ ជាសិស្សព្យាយាម ស្ងប់ស្ងៀម។ គេពិបាកនឹងចុះចំណោមមិត្តភក្តិ។ គេហាក់ដូចជាខ្លាចគ្រូ ប៉ុន្តែនៅពេលណាដែលគេស្រឡាញ់គ្រូវិញ សញ្ចេតនានោះមិនងាយនឹងលុបបំបាត់ទៅវិញទេ។ ក្នុងការរៀនក៏ដូច្នេះដែរ ការប្តូរពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀតក៏មានការលំបាក ដូចជាបន្ទាប់ពីគេសិក្សាមុខវិជ្ជាគណិតវិទ្យា ហើយឱ្យប្តូរទៅសិក្សាអក្សរសិល្ប៍វិញ ក្នុងករណីនេះ សិស្សប្រភេទនេះប្តូរដោយពិបាក ។

- ប្រភេទទី៣៖ រំញោចលើសពីការទប់ សកម្មភាពសសៃប្រសាទខ្លាំង គ្មានលំនឹង ប្រភេទឫកពា ឆេវឆាវ ឆាប់ខឹង ឆាប់ញោច ឆាប់ច្រឡោត កាចហើយចិត្តស្រាល។ មនុស្សមានឫកពាប្រភេទនេះ ជាមនុស្សដែលឆាប់មានប្រតិកម្ម និងឆាប់មានសញ្ចេតនាស្រួចស្រាលនៅចំពោះមុខឧបសគ្គអ្វីមួយ ។ គេសម្តែងឱ្យឃើញថា គេខ្លាំងក្លា និងស្មោះត្រង់មិនលាក់លៀម ប៉ុន្តែគេមានគុណវិបត្តិខ្លះដូចជា ឆាប់ញោច ឆាប់ខឹង ឆាប់បាត់ស្មារតីម្ចាស់ការលើខ្លួនឯង។

ឧទាហរណ៍៖ សិស្សមានប្រភេទឫកពាទី៣ ជាសិស្សសកម្ម សិស្សនេះដើរមុខគេរហូត។ នៅពេលដែលគេទទួលបានកិច្ចការអ្វីមួយគេធ្វើភ្លាម គេពុះពារគ្រប់ឧបសគ្គភ្លាមៗ។ ផ្ទុយទៅវិញ បើគេបង្ខំសិស្សនេះជួនកាលត្រឡប់ទៅជាឈ្លោះប្រឆាំងទៅនឹងបញ្ហានេះទៅវិញ ។

ដើម្បីអប់រំសិស្សប្រភេទនេះ គ្រូត្រូវណែនាំសិស្សនោះឱ្យធ្វើការណាដែលទាមទារភាពស្វិតស្វាញ អំណត់ ស្មារតីម្ចាស់ការ ហើយនៅពេលណាដែលគេធ្វើខុស ត្រូវរិភាគកំហុសដោយស្ងាត់ស្ងៀម ដោយ និយាយលួងលោម ចៀសវាងមានទំនាក់ទំនងអាក្រក់ជាមួយសិស្ស ដែលនាំឱ្យការអប់រំប្រែជាគ្មានប្រយោជន៍ ។

- ប្រភេទទី៤៖ រំញោចខ្សោយ ការទប់ខ្សោយ មានសកម្មភាពសរសៃប្រសាទខ្សោយ ប្រភេទឫកពាខ្វល់ខ្វាយ និងព្រួយច្រើន។ មនុស្សប្រភេទឫកពាទី៤នេះ ជាមនុស្សព្រួយច្រើន គិតច្រើន ហើយមានអាកប្បកិរិយាស្លូតជានិច្ច។ ប៉ុន្តែគេពិបាកនឹងសម្របខ្លួនទៅនឹងមជ្ឈដ្ឋានថ្មី និងបរិស្ថានសង្គមថ្មី ។ គេឆាប់អស់សង្ឃឹមនៅចំពោះមុខភាពបរាជ័យ អ្វីមួយ ហើយខ្វះទំនុកចិត្តលើខ្លួនឯង។

ឧទាហរណ៍៖ សិស្សដែលមានឫកពាប្រភេទនេះ បង្ហាញនូវលក្ខណៈព្យាយាម។ ប៉ុន្តែគេស្ងៀមស្ងាត់នៅចំពោះមុខមនុស្សច្រើន គេមិនហ៊ានបញ្ចេញយោបល់ ឬមតិដោយស្មោះត្រង់អស់ពីចិត្តនោះទេ។ គេមានទឹកចិត្តព្រួយខ្វល់ច្រើន។ សិស្សប្រភេទនេះ តែងតែភ័យខ្លាចចំពោះបាតុភាពនានា គ្មានទំនុកចិត្តលើខ្លួនឯង ដូចជាពេលប្រឡង បើមុខវិជ្ជាទី១ធ្វើបានល្អ ទើបបានបន្តធ្វើមុខវិជ្ជាទី២ទៀត ផ្ទុយទៅវិញបើមុខវិជ្ជាទី១ធ្វើមិនបានល្អទេ គេនឹងងស់សង្ឃឹមហើយ ពេលខ្លះគេនឹងបោះបង់លែងធ្វើមុខវិជ្ជាដទៃទៀតក៏មាន ។

នៅក្នុងការសិក្សាអប់រំ ការយល់ដឹងពីឫកពារបស់សិស្សមានអត្ថន័យសំខាន់ណាស់។ ក៏ប៉ុន្តែការសិក្សាស្រាវជ្រាវ ពីឫកពាជាមូលដ្ឋានគ្រឹះរបស់គំរូសរសៃប្រសាទជាសកម្មភាពដ៏សំខាន់ និងមានភាពស្មុគស្មាញណាស់។ គំរូសកម្មភាពសរសៃប្រសាទ និងឫកពារបស់មនុស្សផ្លាស់ប្តូរប្រែប្រួលទៅតាមវ័យ តាមមជ្ឈដ្ឋានរស់នៅ និងបរិស្ថានសង្គម ព្រមទាំងអាស្រ័យទៅនឹងឥទ្ធិពលអប់រំរបស់សង្គមផង។ ដូច្នេះ គ្រូគប្បីសិក្សាស្វែងយល់ពីឫកពារបស់សិស្ស គឺមានប្រសិទ្ធភាពក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលរបស់គ្រូគ្រប់រូប ។

## IV. សន្និដ្ឋាន

ដូច្នេះវិទ្យាសាស្ត្រអប់រំពឹងផ្អែកលើគោលការណ៍ដ៏សំខាន់ក្នុងការបង្រៀន និងការអប់រំសិស្សនោះគឺ គោលការណ៍ដែលវិវរកមធ្យោបាយ ដើម្បីអប់រំឱ្យបានសម្រេចចំពោះសិស្សម្នាក់ៗ។ ចៀសវាងការអប់រំដោយប្រើហឹង្សាតាមបែបកម្រោល និងការទិតៀនចំៗ ។ ការអប់រំឫកពាសិស្សបានល្អ អាស្រ័យដោយការចេះលើកទឹកចិត្តសិស្សក្នុងការសិក្សា និងការប្រើសម្តីទន់ភ្លន់ផ្អែមល្ហែមចំពោះសិស្ស ពោលគឺការអប់រំទៅតាមប្រភេទនៃឫកពារបស់សិស្ស ទើបទទួលបានជោគជ័យ ។

## សំណួរ

១. ចូរឱ្យនិយមន័យ ឫកពា ?

២. តើលោកអ៊ីប៉ូក្រាតចែកឫកពាជាប៉ុន្មានប្រភេទ ? អ្វីខ្លះ ?ចូរបកស្រាយ។

៣. តើលោកប៉ាវឡូវ បានកំណត់ឫកពាជាប្រភេទអ្វីខ្លះ ? ចូរពន្យល់។

៤. តើឫកពារបស់មនុស្សអាចផ្លាស់ប្តូរបានឬទេ ? ព្រោះអ្វី ? ចូរលើកឧទាហរណ៍មកបញ្ជាក់ ?។

# សម្បទា

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង ៖

- ប្រាប់ពីបញ្ញត្តិ និងប្រភេទសម្បទា
- ប្រៀបធៀបទំនាក់ទំនងរវាងសម្បទា និងទំនោរ
- ចូលរួមក្នុងការបណ្តុះបណ្តាលសម្បទាដល់សិស្សឱ្យមានជំនាញពិតប្រាកដក្នុងការប្រកបរបរចិញ្ចឹមជីវិត។

## II- សេចក្តីផ្តើម

សម្បទារបស់មនុស្ស គឺជាលទ្ធផលនៃលក្ខខណ្ឌសង្គមប្រវត្តិ ។ សម្បទាកកើតឡើង និងរីកលូតលាស់ក្នុងសកម្មភាពទាំងឡាយ ដែលមានបំណងបំពេញតម្រូវការរបស់មនុស្ស ។

## III- ខ្លឹមសារ

### ១. និយមន័យ

សម្បទាជាលក្ខណៈចិត្តដ៏ស្មុគស្មាញរបស់បុគ្គល ហើយជាលក្ខខណ្ឌចាំបាច់នៃការសម្រេចភារកិច្ចបានល្អទៅតាមប្រភេទនៃសកម្មភាពរបស់បុគ្គល ។

គ្រប់សកម្មភាពដែលមនុស្សបំពេញបានល្អ អាស្រ័យដោយសម្បទាជាច្រើន។ សម្បទាអាចឱ្យបុគ្គលធ្វើអ្វីមួយដោយងាយ និងទទួលបានផលល្អ ។

ឧទាហរណ៍៖ សិស្ស "ក" អាចមានសម្បទាខាងគណិតវិទ្យា ប៉ុន្តែមិនមានសម្បទាខាងអក្សរសិល្ប៍ ផ្ទុយមកវិញ សិស្ស "ខ" មានសម្បទាខាងអក្សរសិល្ប៍ តែគេមិនមានសម្បទាខាងគណិតវិទ្យា ។

ការសម្រេចកិច្ចការបានល្អ លើរាល់សកម្មភាព គឺជាលទ្ធផលនៃបណ្តុំសម្បទាជាច្រើនបញ្ចូលគ្នា ។

ដូច្នេះសកម្មភាពរបស់គ្រូទាមទារឱ្យមានបណ្តុំយ៉ាងជិតស្និទ្ធ នៃសម្បទាខាងការអប់រំ សម្បទាខាងការគ្រប់គ្រង និង សម្បទាផ្សេងៗទៀត ។

### ២. ប្រភេទនៃសម្បទា

សម្បទាអាចត្រូវគេចែកចេញជាពីរប្រភេទ ៖

**ក. សម្បទាទូទៅ៖** សម្បទាខាងចំណេះដឹង សម្បទាខាងលំនឹក សម្បទាខាងលំនឹកសង្កេត សម្បទាខាងគំនិតច្នៃប្រឌិត ។ សុទ្ធតែសម្បទាទូទៅព្រោះវាសមស្របទៅនឹងវិស័យមួយនៃសកម្មភាពដែលមានលក្ខណៈទូលំទូលាយ។ សម្បទាទូទៅមានលក្ខណៈដោយឡែកចំពោះបុគ្គលម្នាក់ៗ ។ គ្មានសម្បទាណាដូចគ្នាបេះបិទឡើយ ព្រោះបុគ្គលពីររូបផ្សេងគ្នា ។ ឧទាហរណ៍ សូម្បីតែសិស្សពីរនាក់ ដែលមានសម្បទាផ្នែកគណិតវិទ្យា ក៏ពុំដូចគ្នាដែរ ។

**ខ. សម្បទាពិសេស៖** គឺជាសម្បទាតាមមុខវិជ្ជា ឬជំនាញនីមួយៗដែលអ្នកអប់រំ ឬត្រូវគេបណ្តុះបណ្តាលឱ្យសិស្សថែមទៀតដូចជា មុខវិជ្ជាឯកទេសខាងរូបវិទ្យា តូរ្យតន្ត្រី វិចិត្រករ...។

និយាយរួម ដើម្បីបំពេញភារកិច្ចទៅតាមសកម្មភាពបែបណាមួយ គេត្រូវមានសម្បទាទូទៅ និងសម្បទាពិសេស ។ មនុស្សគ្រប់រូបត្រូវមានការអភិវឌ្ឍលើរាល់សម្បទាផ្សេងៗរបស់ខ្លួន។ នេះគឺជាមូលហេតុ ដែលនាំឱ្យមនុស្សទទួលបានទិន្នផលខ្ពស់ក្នុងការងារ។ សម្បទារបស់មនុស្ស មានលក្ខណៈមិនដូចគ្នាទេ គឺអាស្រ័យទៅតាមកម្រិតវប្បធម៌ និងបទពិសោធក្នុងការងារ។ នេះជាគោលការណ៍មូលដ្ឋាននៃការអប់រំ និងការបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រព័ន្ធអប់រំថ្មី ក្នុងគោលបំណងឱ្យមនុស្សគ្រប់រូបមានការអភិវឌ្ឍទាំងចំណេះដឹង និងមានបំណិនរស់នៅក្នុងបរិស្ថានសង្គម គ្រួសារ និងសហគមន៍។

### ៣. សម្បទា និង លក្ខណៈធម្មជាតិ

មនុស្សកើតមក កាលនៅជាទារកមិនទាន់មានសម្បទាណាមួយពិតប្រាកដនៅឡើយទេ។ ប្រសិនបើមានលក្ខណៈពិសេសខាងផ្នែកកាយសម្បទា និងសរីរវិទ្យានោះវាគ្រាន់តែនិស្ស័យខាងផ្នែកណាមួយប៉ុណ្ណោះ ដែលជាលក្ខណៈធម្មជាតិបង្កើតឱ្យមនុស្សមានភាពខុសគ្នាពីកំណើតប៉ុណ្ណោះ។ តែលក្ខណៈធម្មជាតិពីកំណើតរបស់មនុស្សក៏មានអត្ថប្រយោជន៍យ៉ាងខ្លាំងក្លាណាស់ដែរ ចំពោះការអភិវឌ្ឍផ្នែកសម្បទារបស់មនុស្ស។

ឧទាហរណ៍៖ អ្នកខ្លះមានសម្បទាខាងតូរ្យតន្ត្រី គឺគេមានលក្ខណៈរបស់សរីរាង្គវិភាគនៃសោតវិញ្ញាណ។

រួមសេចក្ដីមក សម្បទា និងលក្ខណៈធម្មជាតិរបស់មនុស្សម្នាក់ៗ មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ព្រោះលក្ខណៈធម្មជាតិបានធ្វើឱ្យមានការអភិវឌ្ឍខាងសមត្ថភាពរបស់មនុស្ស ដែលជាផ្នែកមួយនៃលក្ខខណ្ឌដទៃទៀតក្នុងការបណ្ដុះបណ្ដាលសម្បទា ។

ឧទាហរណ៍៖ ប្រសិនបើសង្គមមានលក្ខខណ្ឌធម្មជាតិល្អ ដែលធ្វើឱ្យការអប់រំមានភាពងាយស្រួល នោះប្រាកដជាធ្វើឱ្យសម្បទាមានការអភិវឌ្ឍឡើងយ៉ាងឆាប់រហ័ស ។

### ៤. ទំនាក់ទំនងសម្បទា និងផ្នែកផ្សេងៗ

ការពង្រឹងឱ្យបានរឹងមាំនូវចំណេះដឹង ចំណេះធ្វើ និងបំណិនប្រសប់ គឺជាការជំរុញឱ្យមានការអភិវឌ្ឍខាងផ្នែកសម្បទា។

ឧទាហរណ៍៖ ចង់ឱ្យសិស្សយល់ដឹងខាងផ្នែកភាសានិយាយ ភាសាបរទេស គ្រឹត្យក្រមវិទ្យាសាស្ត្រ ត្រូវបណ្ដុះបណ្ដាលដល់គេនូវចំណេះដឹង ចំណេះធ្វើ និងបំណិនក្នុងការអនុវត្ត និងការស្រាវជ្រាវ ។

ទាំងអស់នេះគឺជាទិសដៅនៃការអប់រំ និងជាវិធីសាស្ត្រក្នុងការបង្រៀន ដែលជាមូលដ្ឋាននៃបទពិសោធសម្រាប់ឱ្យសម្បទារបស់សិស្ស មានការអភិវឌ្ឍឈានឡើងបន្តិចម្ដងៗ ទៅតាមកម្រិតយល់ដឹងរបស់គេ ដោយស៊ីជម្រៅទៅលើខ្លឹមសារនៃមេរៀន ដែលកាន់តែមានលក្ខណៈទំនើប និងវិទ្យាសាស្ត្រ។

បើសិនជាការអភិវឌ្ឍផ្នែកសម្បទាកាន់តែខ្លាំង នោះលំនាំនៃលក្ខខណ្ឌកាន់តែថយចុះបន្តិចម្ដងៗ។

ឧទាហរណ៍៖ សិស្សដែលមានសម្បទាខាងផ្នែកគណិតវិទ្យា មានលក្ខខណ្ឌងាយស្រួលច្រើន ដើម្បីក្ដាប់បាននូវចំណេះដឹង ចំណេះធ្វើ និងបំណិនខាងផ្នែកគណិតវិទ្យា។

### ៥. ទំនាក់ទំនងសម្បទា និងទំនោរ

សម្បទា និងទំនោរ ជាធម្មតាមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ទំនោរមានគោលដៅឆ្ពោះទៅរកសកម្មភាពមួយដ៏ប្រាកដប្រជា ឯសម្បទាវិញមានគោលដៅឆ្ពោះទៅរកសកម្មភាព ដោយប្រមូលផ្ដុំតាមធម្មតា ហើយធ្វើឱ្យសកម្មភាពនោះអភិវឌ្ឍឡើង។ បើយើងសង្កេតជាទូទៅយើងឃើញថា ដរាបណា កម្លាំងទាក់ទាញសិស្សទៅលើសកម្មភាពណាមួយពិតប្រាកដកាន់តែខ្លាំងទៅៗ នោះការចូលរួមរបស់សិស្ស ក៏កាន់តែមានសកម្មភាពខ្លាំងដែរ ។

ឧទាហរណ៍៖ ប្រសិនបើគេមានទំនោរខាងតន្ត្រីពេលនោះសកម្មភាពគេមានការចាប់អារម្មណ៍ខ្លាំង លើផ្នែកតូរ្យតន្ត្រី ដែលធ្វើឱ្យសម្បទាមានការអភិវឌ្ឍដែរ។

### ៦. សម្បទាត្រូវបានបណ្ដុះបណ្ដាល និងអភិវឌ្ឍនៅក្នុងសកម្មភាពអប់រំ

ក្នុងការបង្រៀន និងការអប់រំ គឺជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាព ដែលជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើឱ្យសម្បទាអ្នកអប់រំកាន់តែមានការអភិវឌ្ឍឡើង។ ដរាបណាអ្នកអប់រំធ្វើសកម្មភាពកាន់តែសំបូរបែប ពេលនោះការអភិវឌ្ឍសម្បទាក៏មានដំណើរការពេញលេញ ហើយល្អប្រសើរទៀតផង។ ក្នុងពេលបង្រៀនការដឹកនាំសកម្មភាព ការផ្ដល់ឱ្យសិស្សនូវឱកាសធ្វើសកម្មភាពដោយខ្លួនឯង និងការធ្វើសកម្មភាពរបស់សិស្សដោយសហការគ្នា គឺជាគោលដៅអភិវឌ្ឍផ្នែកសម្បទារបស់សិស្ស ។

លក្ខខណ្ឌជាច្រើនទៀត ដែលជាប្រភពនៃការអភិវឌ្ឍលើសម្បទារបស់សិស្ស។ ការបង្កើនឥតិយាបថចំពោះការងារ ទំនាក់ទំនងទៅនឹងសង្គម សហគមន៍ ការបង្កើនជំនឿទុកចិត្តដល់សិស្ស និងការវាយតម្លៃសិស្ស ក៏ជាកត្តាសំខាន់ណាស់ដែរ រួមទាំងលក្ខខណ្ឌនៃសាលារៀន ពិសេសការផ្សារភ្ជាប់សាលាទៅនឹងស្ថាប័ននានារបស់រដ្ឋ ជាមួយអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នឯកជនជាដើម។ ទាំងអស់នេះគឺជាបុព្វហេតុតែមួយគត់ ដើម្បីអប់រំកុលបុត្រកុលធីតារបស់យើងឱ្យក្លាយទៅជាពលរដ្ឋល្អ មានសមត្ថភាពគ្រប់គ្រាន់ក្នុងជីវិត និងមានគំនិតជឿនលឿន។

ម្យ៉ាងទៀត ភាពម្ចាស់ការក្នុងការងារនិងសេចក្តីព្យាយាមមានតួនាទីយ៉ាងសំខាន់នៅក្នុងលំនាំអភិវឌ្ឍសម្បទា។

ឧទាហរណ៍៖ សិស្សខ្ជិលមិនអាចក្លាយទៅជាសិស្សពូកែបានឡើយ។ តែក៏មិនអាចនិយាយបានជាទូទៅថា សិស្សឧស្សាហ៍សុទ្ធតែមានសមត្ថភាពអាចពន្យល់ ឬធ្វើអត្ថាធិប្បាយបានយ៉ាងល្អទៅលើបញ្ហាដ៏លំបាកនៃមេរៀន បានទាំងអស់នោះទេ។

ជាទូទៅសម្បទាត្រូវបានគេចែកចេញជាបីកម្រិតផ្សេងគ្នា៖

- កម្រិតធម្មតា ហៅ "សម្បទា"
- កម្រិតខ្ពស់ ហៅ "កោសល្យ"
- កម្រិតខ្ពស់បំផុត ឬសម្បទាវិសាមញ្ញ ឬភាពចម្លែក ហៅ "ទេពកោសល្យ" ។

## IV- សន្និដ្ឋាន

សាលារៀនត្រូវបង្កើតលក្ខខណ្ឌងាយស្រួល ដើម្បីឱ្យសម្បទាសិស្សមានការអភិវឌ្ឍឡើង ពិសេស គឺធ្វើយ៉ាងណាឱ្យសកម្មភាពអប់រំសិស្សកាន់តែសំបូរបែប។ ការបង្រៀន និងការអប់រំលើគ្រប់មុខវិជ្ជាសិក្សាសំដៅលើកកម្ពស់ដល់ដំណើរការអភិវឌ្ឍសម្បទារបស់សិស្ស។

### សំណួរ

១. ដូចម្តេចដែលហៅថា សម្បទា?

២. តើមានលក្ខខណ្ឌអ្វីខ្លះ ដែលនាំឱ្យសម្បទាមានការអភិវឌ្ឍ?

៣. តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលទៅលើសម្បទា?

៤. តើគ្រូបង្រៀនត្រូវធ្វើដូចម្តេច ដើម្បីបណ្តុះសម្បទាដល់សិស្ស?

៥. តើសម្បទាមានអត្ថប្រយោជន៍អ្វីខ្លះ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ?

# មេរៀនទី១៤　ការអប់រំ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ

## I- វត្ថុបំណង

ក្រោយពីសិក្សាមេរៀន គរុសិស្សនឹង៖

- ប្រាប់ពីឥទ្ធិពលលើការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស
- ពន្យល់ពីបំណិនក្នុងការបង្រៀន និងការអប់រំដើម្បីឱ្យបុគ្គលិកលក្ខណៈ
- មានស្មារតីទទួលខុសត្រូវក្នុងការបង្រៀន និងបណ្តុះបុគ្គលិកលក្ខណៈ ។

## II- សេចក្តីផ្តើម

មនុស្សគ្រប់រូប តែងឆ្លងកាត់តាមលំដាប់លំដោយនូវដំណាក់មួយក្នុងការអភិវឌ្ឍសង្គម និងផ្លូវចិត្តដែលជាមូលដ្ឋានកំណត់ឥរិយាបថ និងតម្លៃមនុស្សគ្រប់រូបបង្កើតឡើងសម្រាប់ភាពជោគជ័យ ឬបរាជ័យក្នុងទំនាក់ទំនងសង្គម និងផ្លូវចិត្តរបស់គេ។ ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ និងការសិក្សាពីឥទ្ធិពលសង្គមមកលើមនុស្សគ្រប់រូបមានតួនាទីដ៏សំខាន់ក្នុងភាពជោគជ័យរបស់មនុស្ស ។

## III- ខ្លឹមសារ

### ១. និយមន័យ

បុគ្គលិកលក្ខណៈ ជាលក្ខណៈចិត្តរបស់បុគ្គលម្នាក់ៗ ដែលវិវត្តន៍ប្រែប្រួលទៅតាមលក្ខខណ្ឌ និងឥទ្ធិពល នៃបរិស្ថាន ឬសង្គមដែលមនុស្សរស់នៅ ។ បុគ្គលិកលក្ខណៈត្រូវបានបង្កើតឡើងដោយគុណសម្បត្តិ និងសម្បទាដែលរួមបញ្ចូលគ្នាជាសំណុំមួយ ។ បុគ្គលិកលក្ខណៈតំណាងឱ្យវណ្ណៈមួយ តំណាងឱ្យសង្គមមួយ និងតំណាងឱ្យបុគ្គលម្នាក់ៗផងដែរ ។

ឧទាហរណ៍ ៖ ជនជាតិខ្មែរមានបុគ្គលិកលក្ខណៈមួយខុសពីបុគ្គលិកលក្ខណៈជនជាតិអាមេរិក ។

### ២. កត្តាដែលជះឥទ្ធិពលលើការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ

ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស ប្រព្រឹត្តទៅក្រោមឥទ្ធិពលនៃកត្តាផ្សេងៗដូចជា ៖

#### ក. កត្តាពីកំណើត និងកត្តាតំណពូជ

មនុស្សគឺជាភាវៈរស់ ។ ហេតុដូចនេះមនុស្សត្រូវទទួលឥទ្ធិពលពីកំណើត និងតំណពូជដែលជាពន្លករូបធាតុពីធម្មជាតិ ជាពិសេសរីសេសភាពកាយវិភាគ និងសរីរៈរបស់ខួរក្បាល ព្រមទាំងប្រព័ន្ធប្រសាទផង ។ និយាយពីតំណពូជគឺនិយាយពីការបញ្ជូនហ្សែន(Gen)ពីឪពុកម្តាយទៅឱ្យកូន ។ ការសិក្សាពីមនុស្សបានបង្ហាញថា កូនរបស់ឪពុកម្តាយណាមួយ និងទទួលបានលក្ខណៈជីវសាស្ត្រ ដែលផ្អែកទៅលើលក្ខណៈរបស់ឪពុកម្តាយពួកគេដូចជា ពណ៌ភ្នែក ប្រភេទឈាម ។ល។ កត្តាជាច្រើនទៀត ដែលអាចផ្តល់នូវសក្តានុពលសម្រាប់ការរីកលូតលាស់ ដែលនឹងកើតមានចំពោះបុគ្គលម្នាក់ៗតាមរយៈដំណើរពេញវ័យដូចជា កម្ពស់ ភាពរឹងមាំនៃឆ្អឹង ទម្រង់ខ្លួនប្រាណ ។

ឧទាហរណ៍៖ ដោយកត្តាពីកំណើត និងតំណពូជ បានជាគេច្រើននិយាយថា កូននេះមានរូបរាងដូចម្តាយរបស់គេបេះបិទ ឬមានចិត្តគំនិតដូចបងរបស់គេ ឬ ពូកែគណិតវិទ្យាដូចឪពុករបស់គេ។

ប៉ុន្តែ កត្តាពីកំណើត និងតំណពូជនេះមិនមែនជាកត្តាដែលមិនអាចប្រែប្រួល ហើយមិនមែនជាកត្តាសម្រេចការលូតលាស់នៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗទាំងស្រុងនោះទេ ។

ឧទាហរណ៍៖ លោកក្រមតាង៉ុយជាកូនកសិករ គាត់ជាអ្នកកវីនិពន្ធដ៏ល្បីល្បាញនៅកម្ពុជាយើង ។ សម្តេចព្រះសង្ឃរាជ ជួន ណាត ដែលត្រូវបានគេទទួលស្គាល់ទាំងក្នុង និងក្រៅប្រទេសថាជាអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរយើង ។

នៅក្នុងការងារទំនាក់ទំនងក្រោមឥទ្ធិពលនៃជីវិតរស់នៅ ដោយសារមជ្ឈដ្ឋានធម្មជាតិ មជ្ឈដ្ឋានសង្គម និង

មូលដ្ឋានសម្ភារៈ បច្ចេកវិទ្យាទំនើបក៏អាចកែប្រែកត្តាពីកំណើត និងតំណពូជផងដែរ។

### ខ. កត្តាម ជ្ឈដ្ឋាន

ពាក្យមជ្ឈដ្ឋានក្នុងន័យទូលាយគឺមានមជ្ឈដ្ឋានធម្មជាតិ( ទីក្រុង ជនបទ ប្រទេសកម្ពុជា ប្រទេសបារាំង...) និង មជ្ឈដ្ឋានសង្គម( សង្គមគ្រួសារ សាលារៀន សហគមន៍...)។ តែពាក្យថាមជ្ឈដ្ឋានសង្គម គឺសំដៅលើបរិស្ថានដែលមានន័យថា ឥទ្ធិពលសង្គមដែលជាកម្លាំងប្រព្រឹត្តមកលើមនុស្សពីមជ្ឈដ្ឋានខាងក្រៅ ។ ជានិច្ចកាល ការអភិវឌ្ឍរបស់មនុស្សកើតមានដោយការធ្វើអន្តរកម្មជាមួយបរិស្ថាននោះ ។ ការធ្វើអន្តរកម្មនេះហើយ ដែលផ្តល់បទពិសោធចំពោះបុគ្គលគ្រប់រូប។ បរិស្ថានជាកត្តាសម្រេចសក្តានុពលដែលបុគ្គលម្នាក់ៗទទួលបាន។ មជ្ឈដ្ឋានធម្មជាតិជះឥទ្ធិពលលើមនុស្សដោយសារបែបផែននៃស្ថានភាពរស់នៅ ។

ឧទាហរណ៍៖ អ្នកទីក្រុងមានរបៀបរស់នៅខុសគ្នាខ្លះពីអ្នកជនបទ ។

ចំពោះមនុស្ស មជ្ឈដ្ឋានសង្គមជាកត្តាចម្បង ប៉ុន្តែមនុស្សមានតួនាទីជាអ្នកគ្រប់គ្រងលើរាល់កិច្ចការជានិច្ច និងមានសមត្ថភាពអាចកែប្រែមជ្ឈដ្ឋានជុំវិញ និងសហគមន៍ ។ កត្តាមជ្ឈដ្ឋាននេះមិនមែនជាកត្តាកំណត់ទេ វាគ្រាន់តែជាកត្តាសំខាន់មួយសម្រាប់ការអភិវឌ្ឍបុគ្គលិកលក្ខណៈប៉ុណ្ណោះ ។

ឧទាហរណ៍៖ រឿងព្រេងឥណ្ឌាបាននិទានថា មានតុលាការម្នាក់បានកាត់ទោសមេចោរម្នាក់ ដោយឱ្យធ្វើការ ជាទម្ងន់អស់មួយជីវិត ហើយគាត់បានសន្និដ្ឋានទៀតថា កូនរបស់មេចោរនោះនឹងក្លាយទៅជាចោរទៀតហើយ ។ ក្រោយមក មានពេលមួយកូនតូចរបស់តុលាការនោះ ត្រូវបានពួកចោរលួចចាប់យកទៅ ហើយចិញ្ចឹមនៅក្នុងបនចោរ ។ លុះកូន នោះធំពេញវ័យ គេក៏ក្លាយទៅជាចោរជើងឆើតម្នាក់។

មជ្ឈដ្ឋានសង្គមជះឥទ្ធិពលលើមនុស្សតាមរបៀបពីរយ៉ាង ៖

**- តាមរបៀបឯកឯង៖** តាមធម្មជាតិមជ្ឈដ្ឋានសង្គមបានជះឥទ្ធិពលមកលើបុគ្គលម្នាក់ៗ ដោយគ្មានការចូលរួមពីមនសិការរបស់បុគ្គលនោះផងក៏មាន។

ឧទាហរណ៍៖ លោកប៉ិចថូវេន ជនជាតិអាល្លឺម៉ង់ គាត់ជាតន្ត្រីករល្បីល្បាញលើសកលលោក។ កាលដើមឡើយគាត់ជាកូនពាណិជ្ជករ តែគាត់ត្រូវបានជីតាយកមកចិញ្ចឹមតាំងពីកុមារភាព។ រាល់ពេលជីតារបស់គាត់លេងព្យ៉ាណូម្តងៗ គាត់តែងតែយកចៅរបស់គាត់ទៅដាក់នៅពីមុខព្យ៉ាណូ តាំងពីលោកប៉ិចថូវេនមានអាយុបាន៣ឆ្នាំម្លេះ ។ ទីបំផុតដោយទទួលការអប់រំហ្វឹកហាត់រួមទាំងភាពផ្សុំនឹងមជ្ឈដ្ឋាននេះផង បានធ្វើឱ្យលោកប៉ិចថូវេនអាចក្លាយជាតន្ត្រីករយ៉ាងជំនាញម្នាក់។ ផ្ទុយទៅវិញ ប្អូនគាត់ដែលរស់នៅជាមួយឪពុកម្តាយដែលជាពាណិជ្ជករ ក្លាយជាពាណិជ្ជករធម្មតាដូចឪពុកម្តាយ ។

ដូចនេះ ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស អាចធ្វើឱ្យមជ្ឈដ្ឋានធម្មជាតិ និងមជ្ឈដ្ឋានសង្គមផ្លាស់ប្តូរ។ គេអាចធ្វើឱ្យកត្តាតំណពូជនេះប្រែប្រួល និងជាពិសេសគឺធ្វើឱ្យលំនាំនៃបុគ្គលិកលក្ខណៈប្រែប្រួលទៅតាមមជ្ឈដ្ឋានសង្គមនោះដែរ ។

- **ការចូលរួមពីមនសិការ** គឺជាការចូលរួមមួយដ៏សំខាន់របស់មនុស្ស ដើម្បីឈានទៅសម្រេចបាននូវរាល់សកម្មភាពអ្វីមួយ ។ អ្នកមានចំណេះដឹង ហើយខ្វះមនសិការ នោះក៏ពុំអាចសម្រេចកិច្ចការអ្វីបានល្អនោះដែរ ។

### ៣. កត្តាអ ប់រំ

ការអប់រំ មានតួនាទីសំខាន់បំផុតក្នុងលំនាំអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស ព្រោះវាជាមធ្យោបាយសំខាន់ក្នុងការធ្វើឱ្យបុគ្គលិកលក្ខណៈរបស់កុមារ ជំទង់ និងមនុស្សពេញវ័យរីកលូតលាស់យ៉ាងពេញលេញ ។

សរុបមក ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់បុគ្គល ប្រព្រឹត្តទៅក្រោមឥទ្ធិពលដ៏ស្មុគស្មាញនៃកត្តាជាច្រើន ។

### ៤. ការអប់រំជាមូលដ្ឋាន គ្រឹះ សម្រាប់ ការអភិវឌ្ឍបុគ្គលិកលក្ខណៈ

#### ក. គេត្រូវស្គាល់ ពីមូលដ្ឋាន ចិត្តរបស់សកម្មភាពអប់រំ

#### ការអប់រំជាអ្វី ?

ការអប់រំ គឺជាសកម្មភាពរបស់សង្គម ដែលប្រព្រឹត្តទៅលើមនុស្សក្រោមរូបភាពផ្សេងៗ ក្នុងគោលបំណងមួយជាក់លាក់ និងក្នុងទិសដៅមួយច្បាស់លាស់។ ការអប់រំមានតួនាទីដឹកនាំ និងជះឥទ្ធិពលខ្លាំងក្លាទៅលើការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈព្រោះការអប់រំកំណត់ទិសដៅ និងមុខសញ្ញានៃការរីកលូតលាស់បុគ្គលិកលក្ខណៈ ដើម្បីឆ្លើយតបនឹងតម្រូវការរស់នៅក្នុងសង្គមនិងរៀបចំបុគ្គលិកលក្ខណៈឱ្យសមស្របទៅនឹងជីវភាពសង្គមក្នុងពេល អនាគត។

ហេតុនេះហើយបានជាអ្នកអប់រំត្រូវស្គាល់ និងយល់ឱ្យបានច្បាស់ពីមូលដ្ឋានចិត្តរបស់សកម្មភាពអប់រំ។ ចំពោះយុវវ័យជំនាន់ក្រោយនេះ ការអប់រំមានគោលដៅចាំបាច់នឹងរៀបចំយុវជនទាំងនោះឱ្យចេះរស់នៅ និងធ្វើការក្នុងឋានៈជាពលរដ្ឋល្អ។ នេះជាលំនាំនៃការអប់រំមួយយ៉ាងសំខាន់ ដែលទាមទារឱ្យមានគោលបំណង ខ្លឹមសារ វិធីសាស្ត្រ និងមានទិសដៅច្បាស់លាស់ក្នុងន័យធ្វើយ៉ាងណា ដើម្បីឱ្យបានសម្រេចនូវបុគ្គលិកលក្ខណៈរបស់មនុស្សគ្រប់រូបសមស្របតាមសំណូមពររបស់សង្គម ក្នុងដំណាក់ប្រវត្តិសាស្ត្រច្បាស់លាស់។

ឧទាហរណ៍៖ ដើម្បីឱ្យបុគ្គលិកលក្ខណៈជំទង់បានរីកលូតលាស់សមស្របទៅតាមតម្រូវការសង្គមប្រជាធិបតេយ្យ ក្នុងនាមជាអ្នកអប់រំត្រូវស្គាល់ឱ្យបានច្បាស់ពីចរិតលក្ខណៈសរីរៈ និងចរិតលក្ខណៈចិត្តរបស់ជំទង់ដូចជាគំនិតច្នៃប្រឌិត គំនិតអរូបី ចិត្តរំភើប ការស្រមៃ ឧត្តមគតិ ចំណង់ចំណូលចិត្ត ។

#### ខ. មធ្យោបាយ សំខាន់ ៗក្នុងការបណ្តុះ បណ្តាល បុគ្គលិកលក្ខណៈ

#### ខ.១. ការបង្រៀន និង រៀន

ការបង្រៀន និងរៀន ជាបញ្ហាគន្លឹះក្នុងគ្រប់សកម្មភាពអប់រំ ។ ដូចនេះសកម្មភាពនេះត្រូវតែមានកម្រិតខ្ពស់ និងមានគោលដៅច្បាស់លាស់ ។

ដើម្បីធានាគុណភាពក្នុងការបង្រៀន និង រៀន គ្រប់សកម្មភាពនេះ ត្រូវមានគោលដៅដូចតទៅ៖

- ផ្តល់ចំណេះដឹងដែលមានលក្ខណៈវិទ្យាសាស្ត្រ
- ប្រើប្រាស់វិធីសាស្ត្របង្រៀន ឱ្យសមស្របនឹងកម្រិតអាយុសិស្ស
- កម្មវិធីសិក្សាត្រូវបញ្ចូលបំណិនជីវិត
- ការបង្រៀនត្រូវបង្ហាញទិសដៅ និងមានការតម្រង់វិជ្ជាជីវៈ
- ត្រូវដឹកនាំសិស្សឱ្យចេះធ្វើសកម្មភាព( សិស្សមជ្ឈមណ្ឌល ) ចេះស្វ័យសិក្សា និងសហការក្នុងការសិក្សា ដោយផ្សារភ្ជាប់ការសិក្សាទៅនឹងការអនុវត្ត ។

#### ខ.២. សកម្មភាព សង្គម

បញ្ហាសំខាន់ក្នុងការអប់រំបុគ្គលិកលក្ខណៈ គឺជាការបំផុសឱ្យសម្តែងចេញជាសកម្មភាពផ្សេងៗក្នុងគោលបំណងឱ្យជំទង់យល់នូវតម្លៃនៃសង្គម ដោយបង្កលក្ខណៈឱ្យគេបានចូលរួមក្នុងសកម្មភាព ដូចជាពិធីបុណ្យជាតិ បុណ្យប្រពៃណី សកម្មភាពបរិស្ថាន សកម្មភាពអនាម័យ ទិវាប្រឆាំងនឹងជំងឺអេដស៍... ដោយធ្វើយ៉ាងណាឱ្យគេបានយល់ពីអត្ថន័យនៃសកម្មភាពទាំងនោះផង ។

ម្យ៉ាងទៀត យើងត្រូវមានគោលបំណងហ្វឹកហ្វឺនណែនាំសិស្ស ដោយបណ្តុះគេឱ្យមានសីលគុណធម៌ តម្លាភាព មានមនសិការជាតិ សក្តិសមជាពលរដ្ឋល្អក្នុងសង្គមប្រជាធិបតេយ្យ ។

#### គ. ការរៀបចំបុគ្គលិ កលក្ខណៈ សិស្ស គឺជាវិធីបណ្តុះ សីលគុណធម៌

ត្រូវយកចិត្តទុកដាក់ផ្តួចផ្តើមនូវបញ្ញត្តិអប់រំ"សីលគុណធម៌" ហើយធ្វើការតាមដានរាល់សកម្មភាពទាំងឡាយដែល

សិស្សអាចសម្តែងចេញជាអំពើ ឬសកម្មភាព ។

ឧទាហរណ៍៖ បង្រៀនពីសុជីវធម៌រស់នៅក្នុងសង្គម ដូចជាការចេះគួរសម ការប្រើពាក្យសម្តីទន់ភ្លន់ ការចេះគោរពគ្រូបាធ្យាចារ្យ លោកគ្រូ អ្នកគ្រូ ដោយសម្តែងនូវចសកម្មភាពទាំងឡាយ ដែលសក្តិសមជាយុវជនមានសុជីវធម៌។

ទាំងនេះ គឺជាសកម្មភាពរបស់សិស្សក្រោមការណែនាំរបស់គ្រូ។ តាមរយៈសកម្មភាពនេះហើយដែលគ្រូបណ្តុះដល់សិស្សនូវចំណេះដឹង និងទម្លាប់ល្អៗ ដែលនាំឱ្យសិស្សមានជំនឿជាក់លើសីលគុណធម៌ ព្រមទាំងធ្វើឱ្យសម្បទាសិស្សកើតមាន និងអភិវឌ្ឍឡើង។

បញ្ហាសំខាន់មួយទៀតក្នុងការបណ្តុះបណ្តាលសកម្មភាពជំទង់ គឺការផ្តល់ដល់ពួកគេនូវចំណេះដឹង ស្តីពីស្វ័យអប់រំ ស្វ័យហ្វឹកហ្វឺន ទម្លាប់ស្វ័យសិក្សា ការចេះវាយតម្លៃខ្លួនឯង និងមានស្មារតីម្ចាស់ការ។

សាលារៀនដែលជាគ្រឹះស្ថានអប់រំ ដោយមានការចូលរួមពីសហគមន៍ និងសង្គមទាំងមូលជាអ្នកផ្តល់នូវការអប់រំលើផ្នែកសីលគុណធម៌ដល់យុវជន។ សកម្មភាពគ្រួសារមានតួនាទីពិសេសផងដែរ ក្នុងការចូលរួមយ៉ាងសកម្មសម្រាប់ការអប់រំជំទង់ ព្រោះគ្រួសារបានជះឥទ្ធិពលយ៉ាងខ្លាំងក្លាដល់សញ្ចេតនារបស់ជំទង់។ ដូចនេះឪពុកម្តាយត្រូវជាគំរូល្អជានិច្ចដល់កូន ។ តាមចិត្តគរុកោសល្យ នេះជាតម្រូវការមួយដ៏សំខាន់បំផុតក្នុងការអប់រំបុគ្គលិកលក្ខណៈ។

ការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ គឺមានកត្តាជាច្រើនដែលចូលរួមដូចជា កត្តាពីកំណើត និងតំណពូជ កត្តាមជ្ឈដ្ឋាន ដែលរួមមានការអប់រំ និងកត្តាសកម្មភាពរបស់បុគ្គលផងដែរ។

## IV- សន្និដ្ឋាន

ដើម្បីធ្វើការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សឱ្យបានល្អ គ្រូបង្រៀនត្រូវសិក្សាស៊ីជម្រៅទៅលើខ្លឹមសារមេរៀនឱ្យបានល្អិតល្អន់ ពីព្រោះមនុស្សរស់នៅក្នុងសង្គម ទទួលឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញ ហេតុដូចនេះ ហើយមេរៀនការអប់រំ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្សពិតជាមានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍធនធានមនុស្សជូនជាតិ ។

### សំណួរ

១. តើមានកត្តាអ្វីដែលជះឥទ្ធិពលក្នុងការបង្កើត និងអភិវឌ្ឍបុគ្គលិកលក្ខណៈសិស្ស? ចូរវិភាគទំនាក់ទំនងរវាងគ្នា និងគ្នា ។

២. ហេតុអ្វីបានជាគេពោលថា ការអប់រំជាមធ្យោបាយសំខាន់សម្រាប់ការកកើត និងការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្ស?

៣. ហេតុអ្វីបានជាការរៀបចំសកម្មភាពអប់រំសិស្សបានល្អ គឺជាមធ្យោបាយប្រសើរសម្រាប់ការបណ្តុះបណ្តាលសីលគុណធម៌នៅក្នុងបុគ្គលិកលក្ខណៈរបស់សិស្ស?

# ផ្នែកទី៣

# ចិត្តវិទ្យាពាក់ព័ន្ធ

# មេរៀនទី៣៣ ចលករសិក្សា

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

– បកស្រាយពីបញ្ញត្តិចលករសិក្សា និងខ្លឹមសារសំខាន់ៗនៃមេរៀនបានក្បោះក្បាយ

– បង្ហាញពីសារៈសំខាន់នៃចលករសិក្សានៅក្នុងលំនាំបង្រៀន និងរៀនបានត្រឹមត្រូវ

– មានស្មារតីក្នុងការជំរុញសិស្សក្នុងចលករសិក្សាវិជ្ជមាន និងចៀសវាងចលករសិក្សាអវិជ្ជមាន និងរិះរកវិធីសាស្ត្រមកលើកទឹកចិត្តបានសមស្របទៅតាមតម្រូវការ។

## II- សេចក្តីផ្តើម

អ្នកសិក្សាដែលអាចទទួលការសិក្សាបានប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺនៅពេលណាដែលគេចង់រៀន ។ ដូចនេះបញ្ហាដែលសំខាន់ និងចាំបាច់គឺ គ្រូបង្រៀនត្រូវធ្វើដូចម្តេចឱ្យសិស្សចង់រៀន ឬសិស្សត្រូវទទួលបានការជំរុញទឹកចិត្ត ។

## III- ខ្លឹមសារ

### ១- និយមន័យ

ចលករ គឺជាកម្លាំងជំរុញដែលធ្វើឱ្យបុគ្គលចាប់ផ្តើមធ្វើសកម្មភាព ។

ប្រភេទកម្លាំងជំរុញទាំងនោះដូចជា ៖

- មនុស្សទទួលការជំរុញទឹកចិត្តដោយសារវត្ថុខុសគ្នា និងការយល់ដឹងមានកម្រិតប្លែកៗគ្នា

- ឋានានុក្រមតម្រូវការទាំង៥ក៏ជាប្រភេទតម្រូវការរបស់លោក Maslow

* តម្រូវការដើម្បីរស់ (Survival Needs)
* តម្រូវការផ្នែកសន្តិសុខ និងសុវត្ថិភាព (Safety and Security Needs)
* តម្រូវការផ្នែកសង្គម (Social Needs)
* តម្រូវការលើកសរសើរ និងការគោរពខ្លួនឯង (Esteem and Self-Respected)
* តម្រូវការធ្វើឱ្យខ្លួនឯងមានលក្ខណៈពិតប្រាកដ (Self-actualization)




ឋានានុក្រមតម្រូវការទាំង៥ក៏ជាប្រភេទតម្រូវការរបស់លោក Maslow

- តម្រូវការខាងក្រៅខ្លួនបុគ្គលអាចជាវត្ថុ ឬអ្នកផ្សេងៗ ប្រភេទតម្រូវការនេះ គឺជាប្រភពនៃចរិតសកម្មភាព ។ សកម្មភាពទាំងនោះធ្វើឱ្យតម្រូវការលេចឡើង និងរីកលូតលាស់ ។ ដើម្បីអប់រំតម្រូវការដល់បុគ្គលណាម្នាក់ អ្នកអប់រំត្រូវ

ចាត់តាំងសកម្មភាពឱ្យសំបូរបែប និងច្រើនរូបភាពស្របនឹងដំណាក់កាលវ័យរបស់បុគ្គល ។

- កាលណាបុគ្គលចាប់ផ្ដើមយល់អត្ថន័យពីតម្រូវការចំពោះអត្ថិភាព និងការលូតលាស់របស់បុគ្គលកាន់តែយល់ច្បាស់ និងស៊ីជម្រៅ នោះតម្រូវការនឹងក្លាយជាកម្លាំងជំរុញឱ្យបុគ្គលធ្វើសកម្មភាព ដើម្បីសម្រេចគោលបំណងនៃតម្រូវការនោះ ។

## ២- ប្រភេទចលករសិក្សា

### ២.១- ចលករសិក្សាអាចជាវិជ្ជមាន និងអវិជ្ជមាន

### ២.១.១- ចលករសិក្សាវិជ្ជមាន

**- ការលើកសរសើរ**

ការលើកសរសើរប្រកបដោយលទ្ធផលខ្ពស់ គឺការលើកសរសើរពីស្មារតី។ អ្នកត្រូវបានលើកសរសើរមានជំនឿជាក់ក្នុងការងារ និងទទួលបាននូវការយកចិត្តទុកដាក់ ការគោរពពីអ្នកនៅជុំវិញ ។ ប្រសិនបើអ្នកជាគ្រូបង្រៀនចេះចាត់តាំងការលើកសរសើរបានល្អនោះការលើកទឹកចិត្ត នឹងទទួលបានប្រសិទ្ធភាពខ្ពស់ ។

ជាក់ស្ដែង អ្នកអាចគួបផ្សំរវាងរូបភាពពីរគឺការលើកសរសើរ និងជូនរង្វាន់ដល់បុគ្គលដែលបានសម្រេចការងារយ៉ាងវិសេស ឬបុគ្គលដែលមានគំរូកម្រិតឆ្នើម ។ លើការចាត់តាំងការលើកសរសើរ អ្នកត្រូវដាក់សំណូមពរជាចំហ និងមានអត្ថន័យអប់រំជ្រាលជ្រៅទូលំទូលាយ។ ប្រសិនបើ សមិទ្ធផលការងារទាប ហើយត្រឡប់ជាមានកម្រិតលើកសរសើរខ្ពស់នោះ គឺធ្វើឱ្យមនុស្សដែលត្រូវបានលើកសរសើរមានការពេញចិត្តចំពោះខ្លួនដោយគិតថា ខ្លួនគ្រប់គ្រាន់ពេញលេញហើយ។ ប្រសិនជា សមិទ្ធផលការងារខ្ពស់ត្រឡប់ជាត្រូវលើកសរសើរកម្រិតទាបនោះ អាចបង្កឡើងនូវអាស្មិមានៈ ចិត្តស្រាល ឆាប់ខឹង មិនសប្បាយចិត្ត បង្កឡើងនូវការថយចុះចរិតសកម្មក្នុងការធ្វើសកម្មភាព។

ការលើកសរសើរគឺជាការទទួលយកសមិទ្ធផលសកម្មភាពក្នុងរយៈពេលកន្លងមកព្រមគ្នានឹងសេចក្ដីសោមនស្សរីករាយរបស់មនុស្សទាំងអស់ដែលនៅជុំវិញ និងជាការជំរុញឱ្យឈានទៅអនុវត្តភារកិច្ចបន្តដែលមានកម្រិតកាន់តែខ្ពស់ និងកាន់តែលំបាក ។ ហេតុនេះ នាយកសាលាត្រូវយកចិត្តទុកដាក់លើកសរសើរអ្នកខិតខំប្រឹងប្រែងពីកម្រិតទាបទៅកម្រិតខ្ពស់។

គម្លាតរយៈពេល ពីពេលដែលមានទង្វើគួរត្រូវបានលើកសរសើរ រហូតដល់ពេលលើកសរសើរកាន់តែខ្លីកាន់តែប្រកបដោយប្រសិទ្ធភាពខ្ពស់ « ប្រតិកម្មឆ្លើយតបយ៉ាងសកម្មចំពោះការប្រព្រឹត្តរបស់មនុស្សកាន់តែឆាប់ពេលណាលទ្ធផលកាន់តែខ្ពស់ពេលនោះ » ។

- រង្វាន់៖ វត្ថុលើកទឹកចិត្តដ៏សំខាន់ នៅក្នុងលំនាំគ្រប់គ្រង និងលំនាំបង្រៀន និងរៀន។

រង្វាន់មានច្រើនបែប៖

- ការបង្ហាញពីការយល់ព្រមទទួលយកលទ្ធផលរបស់ការងារ
    + ការជូនរង្វាន់ចំពោះការងារដែលធ្វើបានល្អ ( ថវិកា ឯកសារមានតម្លៃ សម្ភារសិក្សា សម្លៀកបំពាក់ )
    + ការផ្ដល់បុព្វសិទ្ធិពិសេសចំពោះអ្នកដែលបានទទួលពិន្ទុវាយតម្លៃខ្ពស់
    + ការលើកឈ្មោះដាក់ក្នុងតារាង ( បញ្ជី ) កិត្តិយស
    + ការលើកបង្ហាញពីការងារល្អនៅចំពោះមុខអង្គប្រជុំនៅក្នុងសាលាទាំងមូល ឬនៅចំពោះមុខសិស្សទាំងអស់នៅក្នុងថ្នាក់
    + ផ្ដល់ប័ណ្ណសរសើរ លិខិតសរសើរ ឬនិមិត្តសញ្ញាកិត្តិយស
    + ផ្ដល់មូលវិចារប្រកបដោយអត្ថន័យជ្រាលជ្រៅនៅក្នុងសៀវភៅទំនាក់ទំនងមាតាបិតាសិស្ស និងសៀវភៅសិក្ខាគារិក។

**- ការយល់ស្រប ឬការព្រមព្រៀងរបស់លោកនាយក នាយិកា ឬលោកគ្រូ អ្នកគ្រូ**

ការលើកទឹកចិត្តនេះពាក់ព័ន្ធនឹងការបង្ហាញឱ្យឃើញពីការចាប់អារម្មណ៍ ។ លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទាំងអស់ពេញចិត្តចំពោះលោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ដែលមានការចាប់អារម្មណ៍ចំពោះអ្វី ដែលគាត់ និងប្អូនៗបាន និងកំពុងធ្វើ។ ប្រការនេះមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍការគោរពខ្លួនឯងនិងការជឿជាក់លើខ្លួនឯង ។ នៅពេលបំពេញការងារអ្វីមួយ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សមានតម្រូវការអភិវឌ្ឍ ការគោរពខ្លួនឯង និងជំនឿជាក់លើខ្លួនឯងនៅក្នុងបំណិនផ្ទាល់ខ្លួន។ ការលើកទឹកចិត្តចំពោះលោកគ្រូ អ្នកគ្រូ និងប្អូនៗដើម្បីអភិវឌ្ឍចរិតលក្ខណៈគឺជាសមាសភាគគន្លឹះមួយនៃការបង្រៀនល្អ ដើម្បីឱ្យការសិក្សាបានប្រកបដោយលទ្ធផលខ្ពស់ ។ នៅពេលដែលលោកគ្រូ អ្នកគ្រូ ឬសិស្សធ្វើការងារអ្វីមួយ ហើយទទួលបាននូវការលើកទឹកចិត្តជាវិជ្ជមាន តាមរយៈការបង្ហាញចេញ នូវ ការយល់ស្របរបស់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូបង្រៀន នេះគឺជាការលើកទឹកចិត្តឱ្យលោកគ្រូ អ្នកគ្រូ និង ប្អូនៗធ្វើទង្វើនេះម្តងទៀតដែលយើងហៅថាការពង្រឹងការលុតលាស់ផ្លូវចិត្ត ។

លោកគ្រូពេញចិត្តនឹងការបង្រៀន សិស្សពេញចិត្តនឹងការសិក្សានៅពេលណាដែលៈ

+ មជ្ឈដ្ឋានជុំវិញគាំទ្រចំពោះការខិតខំប្រឹងប្រែង បំពេញភារកិច្ចបង្រៀន និងរៀន
+ លោកគ្រូ អ្នកគ្រូ និងសិស្សដឹងខ្លួនឯងថាមានសមត្ថភាព លទ្ធភាពគ្រប់គ្រាន់ក្នុងការពុះពាររាល់ឧបសគ្គផ្នែកបញ្ហាដោយមិនភ័យខ្លាចការរិះគន់នៅពេលមានកង្វះខាត
+ ការលំបាក និងការខិតខំប្រឹងប្រែងមានកម្រិតសមស្រប មានន័យថាភារកិច្ច ឬកិច្ចការដែលត្រូវបំពេញមិនពិបាកពេក ឬមិនងាយស្រួលពេក ។ លោកគ្រូ អ្នកគ្រូ និងសិស្សអាចសម្រេចជោគជ័យបានកម្រិតខ្ពស់នៅពេលខិតខំអនុវត្តការងារប្រកបដោយភាពសមហេតុផល
+ ការបង្រៀន និងរៀនមានអត្ថន័យ និងមានផលប្រយោជន៍
+ បទពិសោធ និងចំណេះដឹងដែលត្រូវបង្រៀនសិស្ស គឺត្រូវទាក់ទងទៅនឹងបទពិសោធរបស់លោកគ្រូ សិស្សដែលមានពីមុន។

**- ការបំផុសឱ្យមានការចង់ចេះចង់ដឹង**

ការបំផុសឱ្យមានការចង់ចេះចង់ដឹង ត្រូវចាប់ផ្តើមធ្វើកិច្ចការអ្វីមួយដោយបញ្ជាក់ច្បាស់ពីបញ្ហា ឬប្រធានបទដែលត្រូវដោះស្រាយ ដោយស្ទាបស្ទង់ឱ្យដឹងជាមុននូវចំណុចណាខ្លះដែលនៅពុំទាន់ចេះ ឬពុំទាន់ធ្វើបាន ។ ដើម្បីដាស់ឱ្យមានចម្ងល់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូបង្រៀនត្រូវមានផែនការត្រឹមត្រូវ និងធ្វើដូចម្តេចឱ្យមុខសញ្ញាមានការចាប់អារម្មណ៍ថា ការចាប់ផ្តើមនៃស្ថានភាពបង្រៀន និងរៀនគឺជាប្រការសំខាន់បំផុត។

លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ គួរចាប់ផ្តើមលើកឡើងថាលោកគ្រូ អ្នកគ្រូប្អូនៗបំពេញកិច្ចការនេះនឹងទទួលបានជោគជ័យក្នុងពេលនោះដែរ ។ លោកគ្រូ អ្នកគ្រូទាំងអស់និងប្អូនៗនឹងទទួលបាននូវអ្វីដែលថ្មីៗ ។ កត្តានេះធ្វើឱ្យសិស្សចងចាំទុកជាមេរៀនយូរអង្វែងសម្រាប់ខ្លួន។ ការទទួលជោគជ័យក្នុងការងារធ្វើឱ្យលោកគ្រូ អ្នកគ្រូ និងប្អូនៗកាន់តែមានចំណង់ក្នុងការបង្រៀន និងរៀនកាន់តែខ្លាំងឡើង និងមានបទពិសោធដែលបានមកពីការបំពេញភារកិច្ចដោយពេញចិត្ត ។ នៅក្នុងដំណើរការបង្រៀន និងរៀន លោកនាយក នាយិកា គ្រូបង្រៀនត្រូវផ្តល់លទ្ធភាពឱ្យបានច្រើនជូនមុខសញ្ញាមានន័យថា“ រក្សាទុកពេលវេលាសម្រាប់សិស្សធ្វើស្វ័យពង្រឹង” ។ ល្បិច ឬវិធីច្នៃប្រឌិតសមស្របជំរុញការ បង្រៀន និងរៀនឱ្យទៅដល់កម្រិតខ្ពស់។ ដូចនេះ កិច្ចការដែលលោកនាយក នាយិកាដាក់ជូនគ្រូបង្រៀន ឬគ្រូឱ្យសិស្សបំពេញមិនត្រូវឱ្យពិបាកពេកទេ( គឺជាកិច្ចការដែលពុំមាននរណាម្នាក់អាចទទួលជោគជ័យបាន និងអាចធ្វើឱ្យគេបោះបង់ ឬបាត់បង់ការចាប់អារម្មណ៍ )។

- **គំរូល្អ** ៖ លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ត្រូវប្រកាន់អាកប្បកិរិយាជាគំរូល្អចំពោះគ្រូ និងសិស្សទាំងអស់ ។ គំរូល្អអាចលើកទឹកចិត្តលោកគ្រូ អ្នកគ្រូ និងសិស្សឱ្យចាប់ផ្តើម និងបន្តការអនុវត្តភារកិច្ច និងតួនាទីបានល្អ

ប្រកបដោយការពេញចិត្ត គំរូល្អស្តែងចេញរបស់លោកនាយក នាយិកា និងលោកគ្រូ អ្នកគ្រូបង្រៀនត្រូវមាន លក្ខណៈស្របគ្នានឹងអាកប្បកិរិយាដែលមាន។

- **ព័ត៌មានត្រឡប់វិជ្ជមាន**

មុនប្រគល់កិច្ចការអ្វីមួយឱ្យសិស្សធ្វើ លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ត្រូវលើកបញ្ជាក់បង្ហាញពីលទ្ធផលវិជ្ជមាន ដែលមុខសញ្ញាទទួលបានពីការខិតខំប្រឹងប្រែងសម្រេចកិច្ចការកន្លងមក។ នៅពេលមុខសញ្ញាបំពេញការងារខុសឆ្គង លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូបង្រៀនដែលបំពេញតួនាទីភារកិច្ចប្រកបដោយជោគជ័យ តែងតែសង្កត់ធ្ងន់លើចំណុចវិជ្ជមាន(ជានិច្ចកាលត្រូវរកឱ្យឃើញចំណុចវិជ្ជមាន) នៃលទ្ធផលការងាររបស់មុខសញ្ញាជាជាងលើចំណុចអវិជ្ជមាន។

- **ការផ្តល់បុព្វសិទ្ធិពិសេស**

នេះគឺជាការលើកទឹកចិត្តដែលមានប្រសិទ្ធភាពបំផុត។ លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូត្រូវប្រកាសចំពោះមុខអង្គប្រជុំសាលា ឬចំពោះថ្នាក់រៀនពីការខិតខំប្រឹងប្រែងពីពិន្ទុទទួលបានពីការទទួលមុខតំណែង ការដំឡើងឋានៈ ឬតួនាទីថ្មីដែលជាកិត្តិយស...។ បុព្វសិទ្ធិធម្មតាមិនមានសារៈសំខាន់ស្មើនឹងការគោរព ការលើកសរសើរជាសាធារណៈនោះទេ។

- **កិច្ចសហការ និងការប្រឡងប្រណាំង**

ទង្វើពីរដែលជំរុញឱ្យលោកគ្រូ អ្នកគ្រូ ឬសិស្សធ្វើការងារមួយដែលមានសារៈសំខាន់ គឺកិច្ចសហការ និងការប្រឡងប្រណាំង។ ប្រសិនបើលោកនាយក នាយិកា ឬលោកគ្រូ អ្នកគ្រូចាត់តាំងសកម្មភាពប្រឡងប្រណាំងដោយ គួបផ្សំនឹងកិច្ចសហការដើម្បីពង្រឹងអាកប្បកិរិយាប្រកបដោយភាពរស់រវើក និងសប្បាយរីករាយនោះគឺជាការលើកទឹក ចិត្តប្រកបដោយអត្ថន័យវិជ្ជមាន។ ផ្ទុយមកវិញ អ្វីដែលជំរុញឱ្យបុគ្គលបំពេញការងារជាមួយអ្នកដទៃទៀតប្រកបដោយ កិច្ចសហការអ្វីនោះនឹងត្រូវបានកើតឡើងនៅក្នុងចិត្តបុគ្គលនោះហើយសង្គមរបស់គេនឹងអភិវឌ្ឍ។ នេះគឺជាលទ្ធផល ដែលភាគច្រើនគឺជាអ្នកសិក្សាមូលដ្ឋាន។

- **ការពេញចិត្តរបស់មាតាបិតាសិស្ស**

បើចង់ឱ្យលោកគ្រូ អ្នកគ្រូ និងសិស្សខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ចបានល្អ លោកនាយក នាយិកា គួរប្រើប្រាស់វិធានការដូចជា៖

+ លើកទឹកចិត្តមាតាបិតាសិស្សឱ្យចូលរួមគ្រប់សកម្មភាពរបស់ថ្នាក់រៀន និងសាលារៀន
+ ចាត់ទុកមាតាបិតាសិស្សជាជំនួយការរបស់លោកគ្រូ អ្នកគ្រូ
+ ផ្ញើរបាយការណ៍ ស្តីពីការរីកចម្រើនរបស់សិស្សជូនមាតាបិតាសិស្សឱ្យបានទៀងទាត់
+ អញ្ជើញលោកគ្រូ អ្នកគ្រូ និងមាតាបិតាសិស្សចូលរួមប្រជុំឱ្យបានទៀងទាត់ និងប្រើប្រាស់ការប្រជុំនេះដើម្បីលើកទឹកចិត្តលោកគ្រូ អ្នកគ្រូ និងសិស្សដែលបំពេញការងារបង្រៀន និងរៀនបានល្អ
+ ពេលខ្លះគួរសរសេរសេចក្តីសរសើរចំពោះមុខសញ្ញាណាដែលបានធ្វើកិច្ចការមួយគួរជាទីពេញចិត្ត និងផ្ញើជូនចំពោះមាតាបិតាសិស្ស។

- **ភាពថ្មី ភាពចម្លែក**

គឺអ្វីដែលដាស់លោកគ្រូ អ្នកគ្រូ ឬសិស្សឱ្យមានការចាប់អារម្មណ៍ ហើយខិតខំប្រឹងប្រែងឆ្លើយតបវិញឱ្យបាន។ ពេលខ្លះលោកនាយក នាយិកា ឬលោកគ្រូ អ្នកគ្រូលើកជាសំណួរ ឬបញ្ជាក់ប្រាប់ពីអ្វីមួយដែលលោកគ្រូបង្រៀន ឬសិស្សទើបតែរកឃើញថ្មីដើម្បីគាត់ឬប្អូនៗការពារទស្សនៈរបស់ខ្លួនដោយខិតខំបន្តត្រិះរិះឱ្យបានស៊ីជម្រៅទៅលើអ្វីនោះ។

- **ទឹកមុខ**

គឺការលើកទឹកចិត្តដ៏សំខាន់មួយ ។ លោកគ្រូ អ្នកគ្រូ ឬសិស្សសប្បាយចិត្តណាស់នៅពេលឃើញភាពញញឹមរបស់លោកនាយក នាយិកា ឬលោកគ្រូ អ្នកគ្រូបង្រៀន។ ការប្រើប្រាស់ទឹកមុខដាស់ការចាប់អារម្មណ៍ ក្នុងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការរៀនរបស់សិស្សនឹងបង្ហាញដល់លោកគ្រូ អ្នកគ្រូ និងសិស្សថា តើត្រូវធ្វើដូច ម្តេចដើម្បីអាចបង្កើនការចាប់អារម្មណ៍ និងអាចប្រើប្រាស់បាននូវអ្វីដែលថ្មីដោយផ្អែកលើចំណេះដឹងដែលមាន។

ទន្ទឹមនឹងនេះ ក៏នៅមានលទ្ធផលសម្រេចដែលលោកគ្រូ អ្នកគ្រូ និងសិស្សទទួលបានក្រោយពីការលើកទឹកចិត្ត គឺ ការប្រែប្រួលអាកប្បកិរិយា(ការលូតលាស់ផ្លូវចិត្តវិជ្ជមាន)។ ចំណុចខ្លះៗដែលលោកនាយក នាយិកា លោកគ្រូ អ្នកគ្រូត្រូវចងចាំក្នុងការអនុវត្តការលើកទឹកចិត្តមាន៖

- ការលើកទឹកចិត្ត គឺជាលំនាំមួយដែលស្មុគស្មាញ
- លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូមិនអាចលើកទឹកចិត្តមុខសញ្ញាទូទៅបានទាំងអស់នោះទេ
- ពេលខ្លះលទ្ធផលនៃការខិតខំប្រឹងប្រែងនឹងអាចទទួលបានតិចតួច ប៉ុន្តែមិនត្រូវបោះបង់ការងារនេះចោលទេ
- ទោះបីពេលខ្លះមានផលប៉ះពាល់ដែលធ្វើឱ្យគ្រូបង្រៀន និងសិស្សបំពេញការងារបានខ្លះៗ លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូមិនត្រូវអស់ទឹកចិត្តក្នុងការមិនបានទទួលជោគជ័យទាំងស្រុងនោះឡើយ។

### ២.១.២- ចលករសិក្សាអវិជ្ជមាន

ប្រសិនបើ ទង្វើ និងវត្ថុលើកទឹកចិត្តក្នុងរូបភាពដូចគ្នាតែមានគោលបំណងអវិជ្ជមាន នោះលទ្ធផលសម្រេចដែលអ្នកបានទទួលពីការលើកទឹកចិត្ត គឺការប្រែប្រួលអាកប្បកិរិយាអវិជ្ជមានដែលពុំមែនជាតម្រូវការរបស់សង្គមជាតិក្នុងការអភិវឌ្ឍធនធានមនុស្សឡើយ ។

ចលករសិក្សាអវិជ្ជមានផ្សេងទៀត មានការដាក់ទណ្ឌកម្ម ការភ័យខ្លាចចំពោះការមិនបានទទួលជោគជ័យ ការភ័យខ្លាចគេសើចចំអក ការមិនយល់ព្រមរបស់លោកគ្រូ អ្នកគ្រូ ការចំអកបញ្ឈឺចិត្ត ការទិតៀនក្នុងន័យអវិជ្ជមាន ការចំអក ដើម្បីសើចលេង ការបាត់បង់សិទ្ធិ ការប្រកួតប្រជែង កំហុស ការដាក់ទណ្ឌកម្មចំពោះរាងកាយ ។

អ្នកអប់រំដែលមានគំនិតជឿនលឿន តែងគិតថាក្នុងលំនាំសកម្មភាពអប់រំគួរតែចៀសវាងឱ្យបានឆ្ងាយពីចលករសិក្សាអវិជ្ជមាន ប្រសិនបើអាចធ្វើទៅបាន ។

## ២.២- ចលករសិក្សាខាងក្នុង និងចលករសិក្សាខាងក្រៅ

**២.២.១-** ចលករសិក្សាខាងក្នុងគឺជាចលករដែលនៅក្នុងសកម្មភាព។ សកម្មភាពនោះត្រូវបានស្តែងចេញឱ្យឃើញពីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលត្រូវបានជំរុញមកពីខាងក្នុងចិត្តមនុស្ស ។ នេះគឺជាការបំពេញចិត្តខ្លួនឯង ឬ « ស្វ័យពង្រឹង» ។

អ្វីៗដែលអ្នកបានគិត អ្វីដែលអ្នកបានបំពេញចិត្ត គឺជាចលករដែលមានថាមពលខ្លាំងបំផុត ៖

ឧទាហរណ៍៖ ចលករសិក្សាក្នុងមានផលប្រយោជន៍ផ្ទាល់ខ្លួន ការចង់ចេះចង់ដឹង ចំណេះដឹងថ្មី សេចក្តីរីករាយក្នុងការជួយមិត្តភក្តិបានសិក្សា និងបានទទួលនូវលទ្ធផលសិក្សាល្អប្រសើរ ជោគជ័យលើកិច្ចការ ឬការងារអ្វីមួយ ។

**២.២.២.** ចលករសិក្សាខាងក្រៅ គឺជាចលករដែលមកពីប្រភពខាងក្រៅ និងផ្តាច់ចេញពីសកម្មភាពពិតជាក់ស្តែងរបស់ប្រធាន ។

**ឧទាហរណ៍៖** ចលករសិក្សាខាងក្រៅមាន គំរូល្អរបស់លោកគ្រូ អ្នកគ្រូ រង្វាន់ ការយល់ព្រមរបស់លោកគ្រូ អ្នកគ្រូ ការលើកសរសើរ ការផ្តល់បុព្វសិទ្ធិពិសេស... ។

## ៣- វិធីសាស្ត្រជំរុញទឹកចិត្ត និងការពង្រឹងចលករសិក្សាវិជ្ជមាន

### ៣.១- វិធីសាស្ត្រជំរុញទឹកចិត្ត

- លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូបង្រៀន ត្រូវដឹងច្បាស់ពីពេលវេលាដ៏ល្អប្រសើរបំផុតសម្រាប់ ធ្វើការ

ជំរុញទឹកចិត្ត។ ការប្រើប្រាស់រូបភាពនៃការលើកទឹកចិត្ត ត្រូវផ្សារភ្ជាប់ជានិច្ចជាមួយនឹងវត្ថុបំណង ។ ប្រសិនបើអាចធ្វើទៅបានរាល់រូបភាពនៃការលើកទឹកចិត្តត្រូវស្តែងចេញជារូបភាពជាក់ស្តែង រូបតំណាង(គំរូ) ឬជានិមិត្តរូប។

ឧទាហរណ៍៖ អ្នកដែលមានសញ្ញាបត្រខ្ពស់ភាគច្រើនមានជីវភាពរស់នៅសមរម្យ។ ប្រយោគនេះ អាចដាស់ការចាប់អារម្មណ៍របស់លោកគ្រូ អ្នកគ្រូ និងប្អូនៗសិស្សមួយចំនួនឱ្យបន្តការសិក្សាទៅមុខទៀតឬទៅថ្នាក់ខ្ពស់បាន ។

- ត្រូវយកចិត្តទុកដាក់លើពាក្យសម្តី សំណួរ និងអាកប្បកិរិយាដែលជាគន្លឹះមូលដ្ឋានក្នុងការប្រើប្រាស់រូបភាពលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាព។

- ត្រូវរៀបចំសេចក្តីសង្ខេបគំនិតដើម្បីធ្វើការពិនិត្យឡើងវិញ និងធ្វើការផ្ទៀងផ្ទាត់រវាងលទ្ធផល និងវត្ថុបំណងនៃការលើកទឹកចិត្ត ឬរៀបចំជារឿងនិទានថ្មីមួយដែលមានឃ្លាប្រយោគល្បះប្រកបដោយអត្ថន័យចូលក្នុងសាច់រឿងតែមួយ។

មធ្យោបាយមួយចំនួន ដែលបង្ហាញឱ្យឃើញលទ្ធផលដែលមុខសញ្ញាទទួលបាន ពីកាជំរុញទឹកចិត្តរបស់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ៖

- ធ្វើការងារអ្វីមួយយ៉ាងសកម្ម
- ទទួលរង្វាន់ដោយមិនប្រកាន់រូបភាពណាមួយ
- បង្ហាញពីការខិតខំប្រឹងប្រែង
- ដាស់ស្មារតីចង់ចេះចង់ដឹង
- ចូលរួមក្នុងការប្រឡងប្រណាំង
- ស្រាវជ្រាវរកឃើញការងារ ឬកិច្ចការមួយ(ការងារជាក់បាំង)។

### ៣.២- វិធីសាស្ត្រក្នុងការពង្រឹងចលករសិក្សាវិជ្ជមាន

ដើម្បីពង្រឹងការលូតលាស់ផ្លូវចិត្តវិជ្ជមាន លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូត្រូវ ៖

- បង្កើនការប្រុងប្រយ័ត្នដល់សិស្ស
- អនុវត្តការត្រួតពិនិត្យ ឬការកែប្រែអាកប្បកិរិយាអវិជ្ជមានរបស់សិស្ស និងការលើកទឹកចិត្តក្នុងការកសាងអាកប្បកិរិយាវិជ្ជមានរបស់មុខសញ្ញា
- ពង្រឹងភាពចុះខ្សោយបន្តិចម្តងៗឱ្យមានភាពរឹងប៉ឹងឡើងវិញ និងសង្កត់ធ្ងន់ទៅលើស្វ័យពង្រឹង និងស្វ័យគ្រប់គ្រងបទពិសោធ ក្នុងការបង្រៀនរបស់លោកគ្រូ និងការសិក្សារបស់សិស្សដែលនឹងអាចអភិវឌ្ឍបាន
- ពង្រឹងការអភិវឌ្ឍគំនិតជឿនលឿន និងគំនិតផ្តើមប្រកបដោយភាពម្ចាស់ការ។

មធ្យោបាយវិជ្ជមានមួយចំនួន ដែលបង្ហាញឱ្យឃើញពីលទ្ធផល ដែលមុខសញ្ញាទទួលយកការពង្រឹងការលូតលាស់ផ្លូវចិត្តពីលោកនាយក នាយិកា ឬលោកគ្រូ អ្នកគ្រូ ៖

- មានបម្រុងប្រយ័ត្នស្តាប់ការណែនាំរបស់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ
- មានអាកប្បកិរិយាយកចិត្តទុកដាក់ក្នុងការបង្រៀន និងរៀន
- មានការកែប្រែអាកប្បកិរិយាកាន់តែប្រសើរឡើង
- ធ្វើការងារប្រកបដោយភាពម្ចាស់ការ។

## ៤- សមាសភាគ-របៀបអនុវត្ត-គោលការណ៍អនុវត្ត

### ៤.១- សមាសភាគនៃការលើកទឹកចិត្ត

- ការលើកទឹកចិត្តប្រព្រឹត្តដោយវាចារ ៖ ការផ្តល់យោបល់លើកសរសើរ ដើម្បីធ្វើការលើកទឹកចិត្ត ។ នេះគឺជាការផ្តល់យោបល់ផ្ទាល់ខ្លួនរបស់លោកគ្រូបង្រៀនដែលមានលក្ខណៈជាការវាយតម្លៃ ការគាំទ្រ និងជាព័ត៌មានត្រឡប់ស្តីពីលទ្ធផលការងារ

- ការលើកទឹកចិត្តតាមរយៈឥរិយាបថ៖ ឥរិយាបថ និងវាចាត្រូវផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ។ ឥរិយាបថមានការញញឹម ការងក់ក្បាល ការចង្អុលបង្ហាញ ដើម្បីជំរុញទឹកចិត្តលោកគ្រូ អ្នកគ្រូ និងសិស្សឱ្យចាប់ផ្តើម ឬបន្ត ឬខិតខំប្រឹងប្រែងធ្វើការអ្វីមួយឱ្យបានសម្រេចពេញលេញ

- ការលើកទឹកចិត្តចំពោះសកម្មភាព-ទង្វើ៖ ការពេញចិត្តចំពោះសកម្មភាព ឬទង្វើណាមួយដោយផ្អែកលើលទ្ធផលការងារដែលលោកគ្រូ អ្នកគ្រូបានទទួល

- ការលើកទឹកចិត្តប្រការដែលនៅជិតបំផុត៖ ការយកចិត្តទុកដាក់ ការបង្ហាញពីការចាប់អារម្មណ៍អ្វីៗដែលនៅជិតជាប់នឹងលោកគ្រូ-អ្នកគ្រូអ្វីៗ ដែលពាក់ព័ន្ធនឹងសិស្សដែលជាប្រការអាចជំរុញលទ្ធផលការងារបាន

- ការលើកទឹកចិត្តតាមរយៈការទំនាក់ទំនង៖ ការលើកទឹកចិត្តនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការលើកទឹកចិត្តដែលនៅជិតបំផុត។ ការទាក់ទងនេះអាចជាការទះតិចៗលើស្មាលោកគ្រូ-អ្នកគ្រូ ឬលើក្បាលប្អូនៗ

- ការលើកទឹកចិត្តតាមរយៈការបង្ហាញភស្តុតាង និមិត្តរូប៖ ជាសញ្ញាសម្គាល់ វត្ថុតាង ការសរសើរ ឬការផ្តល់យោបល់វិជ្ជមាន រង្វាន់ ភ័ព្វសំណាងក្នុងការចំណាយពេលវេលាលើសកម្មភាពដែលពេញចិត្ត។

### ៤.២- របៀបអនុវត្តការលើកទឹកចិត្ត

**ការលើកទឹកចិត្តអាចអនុវត្ត៖**

- **ចំពោះក្រុម អង្គភាព ឬថ្នាក់រៀនទាំងមូល៖** ជាឱកាសយូរៗម្តងដែល លោកនាយក នាយិកា សាលា ឬលោកគ្រូ អ្នកគ្រូអាចធ្វើការលើកទឹកចិត្តចំពោះអង្គភាព ក្រុម ថ្នាក់ទាំងមូល ឬបុគ្គលមួយចំនួន ។

- **ក្នុងលក្ខណៈអូសបន្លាយពេល៖** ការលើកទឹកចិត្តគួរធ្វើឱ្យបានឆាប់រហ័ស បើអាចធ្វើទៅបាន ។ ប៉ុន្តែលោកនាយក នាយិកា លោកគ្រូ អ្នកគ្រូត្រូវប្រើប្រាស់ចលករក្នុងលក្ខណៈអូសបន្លាយ តែនៅពេលណាដែលការអូសបន្លាយអាចបំពេញដោយការពន្យល់ណែនាំ ការប្រាប់បង្ហាញផ្លូវពីអ្វីដែលនឹងកើតមានឡើង។

- **តាមផ្នែក៖** ការលើកទឹកចិត្តលើផ្នែកណាដែលត្រឹមត្រូវ ឬអ្វីដែលធ្វើបានហើយ តែមិនទាន់ពេញលេញមានន័យថា លើកទឹកចិត្តលើផ្នែកដែលផ្តល់នូវគុណភាពវិជ្ជមាន ។ ការលើកទឹកចិត្តនេះសង្កត់ធ្ងន់លើវិធីដោះស្រាយវិជ្ជមាន ។ គោលការណ៍នៃការលើកទឹកចិត្ត គឺត្រូវចៀសវាងការលើកទឹកចិត្តអវិជ្ជមាន និងការរិះគន់។

- **ចំពោះបុគ្គល៖** ការលើកឈ្មោះបុគ្គលម្នាក់សក្តិសិទ្ធបំផុតជាងការឆ្លើយតប (ការលើកទឹកចិត្ត)ដោយលាក់មុខចំពោះបុគ្គលនោះ។ នេះបង្ហាញឱ្យឃើញថាលោកគ្រូស្គាល់បុគ្គលនោះច្បាស់ និងជាអ្នកវាយតម្លៃការងាររបស់គេ។

### ៤.៣- គោលការណ៍អនុវត្តក្នុងការលើកទឹកចិត្ត

ការលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ គឺចលករសិក្សាដែលអនុវត្តតាមគោលការណ៍៖

- ការលើកទឹកចិត្តប្រកបដោយភាពកក់ក្តៅ និងភាពរីករាយ
- ការចៀសវាងការលើកទឹកចិត្តអវិជ្ជមាន
- ការប្រើប្រាស់វិធីចលករខុសៗគ្នា
- ការលើកទឹកចិត្តប្រកបដោយអត្ថន័យជ្រាលជ្រៅចំពោះលោកគ្រូ-អ្នកគ្រូ និងចំពោះសិស្ស។

## IV- សន្និដ្ឋាន

សកម្មភាពរបស់មនុស្សកើតឡើងពីការលើកទឹកចិត្ត( ស្មារតី និងសម្ភារ) ។ ការលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាពចំណុះកត្តាជាច្រើនដូចជា សមត្ថភាពជ្រើសរើសមុខសញ្ញា រូបភាពលើកទឹកចិត្ត វិធីសាស្ត្រអនុវត្តការលើកទឹកចិត្តដោយផ្អែកលើគោលការណ៍ទាំងបួនខាងលើ និងឈរលើជំហរយុត្តិធម៌ និងស្មារតីអភិវឌ្ឍធនធានមនុស្ស។

### សំណួរ

1. ដូចម្តេចដែលហៅថាចលករសិក្សា?
2. តើគេចែកចលករការសិក្សាជាប៉ុន្មាន?អ្វីខ្លះ?
3. តើគេយកចលករសិក្សាទៅអនុវត្តយ៉ាងដូចម្តេច ទៅក្នុងការបង្រៀនរបស់ខ្លួន?

# មេរៀនទី៣៤ ចិត្តវិទ្យាអប់រំ

## I- វត្ថុបំណង

ក្រោយពីរៀនមេរៀននេះចប់គរុសិស្ស៖

- បកស្រាយពីនិយមន័យសីលធម៌ លំនាំនៃការអភិវឌ្ឍសីលធម៌បានត្រឹមត្រូវ
- មានបំណិនក្នុងការបណ្តុះបណ្តាលសីលធម៌ដល់សិស្សឱ្យប្រព្រឹត្តទៅប្រកបដោយមនសិការ
- មានស្មារតីទទួលខុសត្រូវលើការបង្រៀន និងអប់រំសីលធម៌ដល់សិស្ស ដើម្បីបំពេញតម្រូវការក្នុងជីវភាពប្រចាំថ្ងៃ។

## II- សេចក្តីផ្តើម

ការអប់រំតាមន័យទូលាយមួយ រួមមានទាំងការអប់រំ នៅសាលារៀន គ្រួសារ និងសង្គមសំដៅប្រព្រឹត្តទៅលើបុគ្គលិកលក្ខណៈរបស់សិស្សពោលគឺ បង្រៀនឱ្យប្អូនៗ រៀន ធ្វើមនុស្សល្អ ពលរដ្ឋល្អ។

## III- ខ្លឹមសារ

### ១- សីលធម៌ និង អំពើសីលធម៌

#### ១.១- និយមន័យសីលធម៌

សីលធម៌ គឺជាទ្រង់ទ្រាយមួយនៃមនសិការសង្គម បង្ហាញឱ្យឃើញឥរិយាបថវាយតម្លៃទំនាក់ទំនងរវាងផលប្រយោជន៍ខ្លួនជាមួយផលប្រយោជន៍របស់អ្នកដទៃ និងរបស់សង្គម ។ ឥរិយាបថវាយតម្លៃនេះ ស្ថិតនៅក្នុងផ្នែកសកម្មភាពសង្គមទាំងអស់(សេដ្ឋកិច្ច វប្បធម៌ អប់រំ សុខាភិបាល កីឡា ។ល។) ប៉ុន្តែការស្តែងឡើងឱ្យឃើញច្បាស់នៅក្នុងទំនាក់ទំនងរវាងមនុស្ស និងមនុស្ស( ទំនាក់ទំនងមហាជន គ្រួសារ មិត្តភក្តិ ប្តីប្រពន្ធ កូនចៅ ។ល។) មានពេលខ្លះផ្តុកទៅដោយទំនាក់ទំនងរវាងមនុស្ស និងវត្ថុ ពីព្រោះទំនាក់ទំនងរវាងមនុស្ស និងវត្ថុ បើពិនិត្យឱ្យសព្វគ្រប់ទៅ គឺពិតដូចជាទំនាក់ទំនងរវាងមនុស្ស និងមនុស្សដែរ ។

សីលធម៌ស្តែងឡើងឱ្យឃើញទស្សនៈអំពីកុសល សុភមង្គល កាតព្វកិច្ច ចិត្តបរិសុទ្ធ កិត្តិយស យុត្តិធម៌ និងស្មារតីស្វ័យគោរព ។ល។ ប្រភេទបញ្ញត្តិទាំងនេះ ស្ថិតនៅលើមូលដ្ឋានទស្សនវិជ្ជាមួយ និងស្តែងចេញជាក់ស្តែងជាប្រព័ន្ធនិយាមសីលធម៌ ។ ខ្លឹមសារទាំងអស់ដែលបានលើកឡើងខាងលើ បង្កើតបានជាមនសិការសីលធម៌របស់សង្គមមួយ និងឆ្លុះបញ្ចាំងអត្ថិភាពសង្គមមួយជាក់លាក់ ។

ដូចនេះប្រព័ន្ធទស្សនៈសីលធម៌ ឬមនសិការសីលធម៌ «ខឿនសីលធម៌» ផ្លាស់ប្តូរទៅតាមទ្រង់ទ្រាយសេដ្ឋកិច្ចសង្គម ទៅតាមរបបសង្គមនយោបាយ ។ តាមធម្មតាទោះបីទ្រង់ទ្រាយសេដ្ឋកិច្ច របបសង្គមនយោបាយផ្សេងគ្នាក៏ដោយ ក៏នៅមានបញ្ហាតិច ឬច្រើនដូចគ្នាដែរ ។ ហេតុនេះបញ្ហាសីលធម៌ គឺដូចគ្នាទាំងពាក្យទាំងខ្លឹមសារមូលដ្ឋាន ។ ប្រការនេះបង្កើតឡើងនូវភាពប្រែប្រួលក្នុងប្រព័ន្ធទស្សនៈសីលធម៌របស់របបសង្គមនយោបាយផ្សេងៗ ក៏នៅមានបញ្ហាមួយចំនួនដែលហៅថា «ចរិត ឬប្រភេទសីលធម៌ជាសកលរបស់មនុស្ស » ។ ឧទាហរណ៍ ៖ មេត្តាធម៌ ចិត្តបរិសុទ្ធ ស្មារតីស្វ័យគោរព សុភាពរាបសារ តាមធម្មតានេះជាបញ្ហាមួយក្នុងចំណោមបញ្ហាដែលកំពុងជជែកពិភាក្សាសីលធម៌ ។

#### ១.២- និយមន័យអំពើសីលធម៌

ប្រព័ន្ធទស្សនៈសីលធម៌ ឬមនសិការសីលធម៌របស់សង្គមមួយអាចមានអាទិភាព តែនៅក្រោមទម្រង់អំពើសីលធម៌រស់នៅ និងការធ្វើសកម្មភាពរបស់បុគ្គលិកលក្ខណៈ ក្នុងការអនុវត្តជាក់ស្តែងលើមនសិការសីលធម៌នេះ ។ ក្រៅពីនេះសីលធម៌មិនអាចមានអាទិភាព ក្រោមទម្រង់អាទិភាពធ្វើសកម្មភាពក្នុងខឿនវប្បធម៌សង្គម ពិសេសក្នុងមាគ៌ារស់នៅ ទំនៀមទម្លាប់ ប្រពៃណី ច្បាប់ ពីរបៀបប្រកាន់ឥរិយាបថ អ្នកអក្សរសាស្ត្រ សិល្បៈ ។ល។

ពេលនិយាយដល់អំពើសីលធម៌របស់មនុស្សជាក់ស្តែងដែលរស់នៅ ក្នុងខឿនវប្បធម៌សង្គមមួយជាក់លាក់ នោះគ្រ

ឡប់ជាលេចចេញបញ្ហា «លាយឡំ» នៅក្នុងអំពើសីលធម៌រស់នៅ ដោយធ្វើ សកម្មភាព ។ នៅចំណុចចាប់ផ្តើមជាកំណត់មួយក្នុងស្ថានភាពសង្គមជាក់ស្តែង អាទិភាពនៃខឿនសីលធម៌ផ្សេងៗ ខឿនសីលធម៌«ត្រូវតាមគន្លងច្បាប់» ឆ្លើយតបនឹងសង្គមនោះ ។ ពេលពិនិត្យលើសីលធម៌ យើងត្រូវធ្វើឱ្យអំពើសីលធម៌របស់ជំនាន់ក្រោយ បានសមស្របនឹង សីលធម៌របស់សង្គម ដោយបន្តអនុវត្តឱ្យបានល្អបរិសុទ្ធពីសីលធម៌ ដែលជាប្រពៃណីជាតិ និងចៀសវាងឱ្យបានឆ្ងាយ ពីសីលធម៌មិនសមស្រប ។

អំពើសីលធម៌គឺជាអ្វី ? អំពើសីលធម៌ គឺជាអំពើស្វ័យភ្ញាក់រឭក ដែលត្រូវបានជំរុញឱ្យចលករមួយមានអត្ថន័យផ្នែកសីលធម៌ ។ ក្នុងអំពើសីលធម៌ ដំបូងបង្អស់យើងត្រូវយកចិត្តទុកដាក់ដល់ចរិតស្វ័យភ្ញាក់រឭក ។ ការងារមួយដែលអាចផ្តល់លទ្ធផលសត្យានុម័ត ជាអំពើអកុសល ប្រសិនបើប្រធានគ្មានការភ្ញាក់រឭក គ្មានស្វ័យភ្ញាក់រឭកពីអំពើរបស់ខ្លួន និងគ្មានគោលបំណងលើលទ្ធផលសត្យានុម័តទេនោះ គេមិនអាចហៅថា ជាអំពើប្រព្រឹត្តមួយបានឡើយ ។ ចរិតស្វ័យភ្ញាក់រឭកស្តែងឡើងពីវិសេសភាពលើការយល់ដឹង ឥរិយាបថ ឆន្ទៈសីលធម៌ និយាយរួមគឺមានមនសិការសីលធម៌ ដែលធ្វើឱ្យអំពើប្រព្រឹត្តក្លាយទៅជាអំពើសីលធម៌ ។

អំពើមួយក្លាយទៅជា អំពើសីលធម៌ តែនៅពេលណាដែលចលកររបស់វាមានអត្ថន័យសកម្ម ឬ អសកម្មពីផ្នែកសីលធម៌តាមនិយាមរបស់សីលធម៌មួយជាក់លាក់ ។ ចលករសីលធម៌គឺជាលក្ខខណ្ឌដែលត្រូវមានមនសិការសីលធម៌ « លក្ខខណ្ឌគ្រប់គ្រាន់របស់អំពើសីលធម៌ » ។

ចលករសីលធម៌រីកលូតលាស់ឡើងពីតម្រូវការសីលធម៌ និងតម្រូវការផ្សេងៗទៀតរបស់មនុស្ស ។ តម្រូវការសីលធម៌ស្ថិតនៅក្នុងក្របខណ្ឌប្រព័ន្ធរួមនៃតម្រូវការរបស់បុគ្គលម្នាក់ ពោលគឺ មានភាពថ្លៃថ្នូរ ភាពខិនថយតាមលំដាប់ជាកំណត់ ។ ប៉ុន្តែក្នុងស្ថានភាពកំណត់ ដោយសារលក្ខខណ្ឌជាក់លាក់នៃស្ថានភាពជាក់ស្តែងតម្រូវការមួយចំនួន( ក្នុង នោះអាចមានតម្រូវការសីលធម៌ ) អាចលេចឡើងយ៉ាងជាក់ច្បាស់ ហើយក្លាយទៅជាកម្រងចលករ ។ ប្រការនេះ មាន ឥទ្ធិពលដល់ភាពថ្លៃថ្នូរ ភាពខិនថយ តាមលំដាប់រួមនៃតម្រូវការ ។ តាមធម្មតា ឆ្លងចូលដល់វ័យជំទង់ វ័យយុវជន ដែល ពាក់ព័ន្ធដល់ការបណ្តុះបណ្តាលលោកទស្សនៈរបស់វ័យនេះ តម្រូវការសីលធម៌គឺបង្កើតបានជាប្រព័ន្ធដោយឡែកមួយ ឬប្រព័ន្ធទស្សនៈសីលធម៌បុគ្គលមួយ។ប្រព័ន្ធទស្សនៈបុគ្គលចាក់ស្រេះចូលក្នុងប្រព័ន្ធតម្រូវការរួមរបស់បុគ្គលដែល ស្តែងឱ្យឃើញជាក់ស្តែង
និងបញ្ជាក់ប្រាប់ពីតម្លៃរបស់មនុស្សនោះ ។ អ្នកស្រាវជ្រាវចិត្តវិទ្យាអាចរកឃើញការកំណត់តម្លៃនេះ ដោយប្រព័ន្ធសំណួរតាមលំដាប់ថ្នាក់នៃមុខរបរ តាមលំដាប់ថ្នាក់នៃប្រភេទសកម្មភាពសង្គម មុខងារចរិត ពិសេសរបស់សង្គម លក្ខណៈសម្បត្តិសីលធម៌។ល។ តាមរយៈការងារនេះ យើងអាចដឹងពីទស្សនៈសីលធម៌ និង មនសិការសីលធម៌របស់មនុស្សម្នាក់ៗ ។

### ១.៣- ទំនាក់ទំនងរវាងតម្រូវការសីលធម៌ និងអំពើប្រព្រឹត្តសីលធម៌

ទស្សនៈរបស់យើងគឺ : តម្រូវការសីលធម៌ កំណត់អំពើសីលធម៌ (រួមជាមួយកត្តាផ្សេងៗ ) ប៉ុន្តែអំពើសីលធម៌ក៏ប្រព្រឹត្តឆ្លើយតបវិញនឹងតម្រូវការសីលធម៌ និងធ្វើឱ្យតម្រូវការនេះមានការផ្លាស់ប្តូរ ។

តម្រូវការសីលធម៌ស្ថិតនៅក្នុងប្រព័ន្ធតម្រូវការរបស់បុគ្គល ក្នុងលក្ខខណ្ឌមួយជាក់លាក់ និងត្រូវបានលេចឡើងបន្តិចម្តងៗ ដោយកំណត់ច្បាស់ពីកម្មវត្ថុដើម្បីបំពេញតម្រូវការនោះ ។ ពេលកម្មវត្ថុត្រូវបានកំណត់ច្បាស់ យើងនឹងមានចលករសីលធម៌ ។ ក្នុងលំនាំផ្លាស់ប្តូរសីលធម៌ទៅជាមួយផ្នែក គឺបុគ្គលិកលក្ខណៈស្តែងចេញ និងមួយផ្នែកផ្សេងទៀតពេលមានអំពើសីលធម៌ជាក់ស្តែងគឺ បង្កើតបានឥទ្ធិពលដែលធ្វើឱ្យកែប្រែតម្រូវការ និងធ្វើឱ្យបុគ្គលិកលក្ខណៈកាន់តែសុក្រឹតឡើង ។

ឧទាហរណ៍៖ តម្រូវការជួយមិត្តភក្តិ គឺជាតម្រូវការសីលធម៌ដែលបង្កប់ក្នុងបុគ្គលិកលក្ខណៈ ។ ពេលមិត្តណាម្នាក់ធ្លាក់ចូលក្នុងសភាពដែលតម្រូវការឱ្យជួយ តម្រូវការនេះស្តែងចេញភ្លាមមានន័យថា តម្រូវការថ្មីមានកម្មវត្ថុជាក់ស្តែង។ ពេលប្រធានចាប់ផ្តើមកំណត់លំនាំច្បាស់លាស់គឺតម្រូវការជួយមិត្តដោយប្រើអ្វី ដោយរបៀបណា ព្រោះអ្វី ដើម្បីអ្វី ។ល។ ពេលនោះគឺ

បណ្តុះជាបណ្តើរៗនូវចលករ។ នេះគឺជាចលករសីលធម៌ដែលត្រូវបណ្តុះក្នុងលំនាំដំបូងនៃអំពើសីលធម៌ និងកំណត់អំពើជាក់ច្បាស់ក្នុងលំនាំនោះ ។ ក្នុងពេលកំណត់ច្បាស់ «អ្វី» «របៀបណា» ។ល។ គឺលេចចេញកត្តាសត្យានុម័ត និងកត្តាអត្តនោម័តច្រើនណាស់ដែលចូលរួមចំណែកក្នុងនោះ ។ ឧទាហរណ៍៖ មិត្តតម្រូវឱ្យជួយដោយត្រូវខ្យល់ព្យុះធ្វើឱ្យរលើងផ្ទះ ។ យោលទៅតាមប្រធាន និងស្ថានភាពមនុស្សម្នាក់ៗអាចជួយជាកម្លាំង ដោយមានអ្នកជួយផ្នែកសម្ភារៈ អ្នកជួយលុយកាក់ ។ល។ ដូចនេះ គឺត្រូវដោះស្រាយអ្វីដើម្បីជួយមិត្ត ? ដោយរបៀបណា ? ។ មួយផ្នែកគឺ «មិត្តភាព» ។ សារៈសំខាន់នៅទីនេះ គឺតម្រូវការមិត្តភក្តិរបស់ប្រធានបានស្តែងឡើងយ៉ាងជ្រាលជ្រៅដោយទាមទារការលះបង់ច្រើន ឬតិចដោយផ្អែកលើមូលដ្ឋានណាមួយ។ល។ មួយផ្នែកទៀត វិសេសភាពស្ថានភាពជាក់ស្តែងរបស់សង្គម និងរបស់បុគ្គលនៅចំណុចផ្តើមគឺឆ្លុះបញ្ចាំងក្នុងចិត្តរបស់ប្រធាន និងធ្វើឱ្យផ្លាស់ប្តូរ «មិត្តភាព» (រួមមានតម្រូវការជួយមិត្ត)ផងដែរ។ ឧទាហរណ៍៖ ចង់ជួយមិត្តប៉ុន្តែដោយសារស្ថានភាពប្រាក់កាក់តិចតួច ប្រធានគ្រាន់តែមានចលករ តែនៅមានកម្រិតគឺលះបង់ប្រាក់សន្សំសំចៃមួយចំនួនដើម្បីជួយមិត្ត។ ប្រធានផ្សេងទៀតមានលុយជួយបានតែកម្លាំងប៉ុណ្ណោះ ។ល។ សញ្ចេតនាដូចនេះមិនអាចមិនជះឥទ្ធិពលដល់តម្រូវការជួយមិត្តរបស់ប្រធាននោះ ទេ ។ ករណីជាច្រើននៃស្ថានភាពនោះដែល «កម្រិត» គឺការបន្ថយតម្រូវការ ក្នុងករណីផ្សេងទៀត វាបង្កើនបន្ថែមនូវធាតុបង្ក «ការស្រឡាញ់ទៅឱ្យមិត្តដោយអាណិត ឬឈឺចាប់ឱ្យមកខ្លួនឯង» នេះជាមិត្តភាពរបស់ប្រធាន ។ល។

ទំនាក់ទំនងទៅវិញទៅមកនេះ កាន់តែស្តែងចេញច្បាស់លាស់ក្នុងលំនាំអនុវត្តអំពើសីលធម៌ ។ អំពើសីលធម៌ណាក៏ស្តែងចេញក្នុងស្ថានភាពសង្គមប្រវត្តិសាស្ត្រមួយ និងលក្ខខណ្ឌជាក់ស្តែងដែរ ។ ក្នុងលក្ខខណ្ឌនេះ ចលករសីលធម៌របស់ប្រធានស្តែងចេញរួមជាមួយមនសិការសីលធម៌( យល់ដឹង ឥរិយាបថ ឆន្ទៈ ) និងផ្សារភ្ជាប់ជាមួយលក្ខខណ្ឌនៃស្ថានភាពជាក់ស្តែង ក្នុងនោះអំពើត្រូវបានអនុវត្ត ។ លទ្ធផលគឺអំពើសីលធម៌ត្រូវបានអនុវត្តក្រោមទម្រង់គួបផ្សំមួយ( គឺមិនមែនបូកបញ្ចូលគ្នាទេ) មួយផ្នែកគឺ ចលករ និងមនសិការសីលធម៌សមស្របតាមវិសេសភាពនៃស្ថានភាព មួយផ្នែកទៀតគឺលក្ខខណ្ឌរបស់ស្ថានភាពដែលបាន «កែប្រែ» អំពើសីលធម៌ដោយសារប្រធាន ។ ដូចនេះ ឆ្លងកាត់ការអនុវត្តអំពើសីលធម៌ លក្ខខណ្ឌនៃស្ថានភាពសង្គម ប្រវត្តិសាស្ត្រជាក់ស្តែង ជះឥទ្ធិពលដល់ប្រធានព្រមទាំងកែប្រែប្រធាន។ វិភាគចំណង ទំនាក់ទំនងរវាងតម្រូវការសីលធម៌ និងអំពើសីលធម៌ផ្តល់នូវភស្តុតាងសមស្របនឹងការពិតគឺ៖

ក.ក្នុងការអប់រំសីលធម៌តម្រូវឱ្យមានការយល់ដឹងសីលធម៌ តើត្រូវមានឥរិយាបថដូចម្តេច គួរប្រព្រឹត្តអំពើដូចម្តេច ។ល។

ខ. ក្នុងការអប់រំសីលធម៌ ចាំបាច់ត្រូវចាត់តាំងសកម្មភាព អំពើប្រព្រឹត្តប្រកបដោយសីលធម៌ ។ កាលណាមានសកម្មភាពកើតឡើង អំពើសីលធម៌រួមជាមួយសីលធម៌ និងមនសិការសីលធម៌ក៏កើតឡើងដែរ ។

### ២- សំណុំបុគ្គលិកលក្ខណៈ គឺជាប្រធាននៃអំពើសីលធម៌

**២.១.** អំពើសីលធម៌ទទួលឥទ្ធិពលពីការកំណត់សីលធម៌ និងមនសិការសីលធម៌ ។ ការកំណត់អំពើសីលធម៌មួយជាក់ស្តែងគឺជាសំណុំបុគ្គលិកលក្ខណៈរួម ដែលមានចំណេះដឹង សញ្ចេតនាឆន្ទៈ ។ ចំណេះធ្វើ បំណិនប្រសប់ ទម្លាប់ត្រូវបានរៀបចំក្នុងប្រព័ន្ធគុណសម្បត្តិ និងសម្បទារួមរបស់មនុស្សម្នាក់ៗជាក់ស្តែង ។

សង្ខេបមក ប្រការនៃអំពើសីលធម៌ គឺជាសំណុំបុគ្គលិកលក្ខណៈជាក់ស្តែង ហើយការអប់រំសីលធម៌ត្រូវឆ្លងកាត់ការចាត់តាំង អំពើសីលធម៌ដើម្បីអប់រំសំណុំបុគ្គលិកលក្ខណៈរបស់មនុស្ស ។

**២.២.** កត្តាទាំងអស់របស់បុគ្គលិកលក្ខណៈពុំមែនសុទ្ធតែមានឥទ្ធិពលដូចគ្នាដល់គ្រប់អង្គធាតុបង្កទាំងអស់នៃអំពើសីលធម៌ទេ ។ ដំបូងបង្អស់ត្រូវគិតដល់លក្ខណៈត្រៀមប្រព្រឹត្តអំពើប្រកបដោយសីលធម៌ ។ ចំណេះដឹងណាដែលឆ្លងកាត់ឥរិយាបថ សញ្ចេតនា សកម្មភាពដោយប្រែក្លាយទៅជាជំនឿជឿជាក់លើផ្នែកសីលធម៌ ។ ជំនឿជឿជាក់ស្ថិតនៅក្នុងប្រព័ន្ធជាន់ថ្នាក់នៃចលករបុគ្គលិកលក្ខណៈ និងស្តែងឡើងជាទំនោរសីលធម៌របស់បុគ្គលិកលក្ខណៈ ដោយតម្រូវបែងចែកដោយឡែកទំនោរសីលធម៌បុគ្គលិកលក្ខណៈ និងទំនោរសីលធម៌របស់សកម្មភាពជាក់ស្តែងនីមួយៗ ។ ការអប់រំធាតុពិតគឺ

ប្រែទំនោរសីលធម៌បន្តិចម្តងៗរបស់សកម្មភាពជាទំនោរសីលធម៌របស់បុគ្គលិកលក្ខណៈ ។

ក្រៅពីទំនោរសីលធម៌របស់បុគ្គលិកលក្ខណៈ លក្ខណៈត្រៀមប្រព្រឹត្តអំពើប្រកបដោយសីលធម៌ទាមទារមានធាតុបង្កពីរទៀតគឺ គុណសម្បត្តិឆន្ទៈ និងរបៀបប្រព្រឹត្តអំពើ ។

គុណសម្បត្តិឆន្ទៈមានគោលបំណង ចរិតម៉ឺងម៉ាត់ ចរិតស្វិតស្វាញ ... ដែលចាំបាច់ដើម្បីប្រែលក្ខណៈពិសេសនៃទំនោរទៅជាអំពើប្រព្រឹត្ត ។ គ្រប់អំពើសីលធម៌សុទ្ធតែត្រូវភ្ជាក់រឭក ហើយភាគច្រើន ទង្វើសីលធម៌សុទ្ធតែជាអំពើប្រកបដោយឆន្ទៈ មានការតស៊ូចលករ រវាងផលប្រយោជន៍អ្នកដទៃ សមូហភាពសង្គម ។ល។

និយាមសីលធម៌សង្គមកំណត់កម្រិតប្រតិបត្តិ ។ ក្នុងប្រការនេះ ក្នុងការអនុវត្តពិតប្រាកដនៅមិនទាន់គ្រប់គ្រាន់ទេ ប៉ុន្តែត្រូវបានអនុវត្តឱ្យត្រូវរបៀបដោយសង្គមកំណត់ ក្រោមទម្រង់អំពើប្រកបដោយអរិយធម៌ ។

ធាតុបង្កមួយទៀតគឺ បំណិនប្រសប់ ទម្លាប់អំពើប្រកបដោយអរិយធម៌ ទើបជួយឱ្យលក្ខណៈត្រៀមប្រព្រឹត្តអំពើប្រកបដោយសីលធម៌ ស្តែងចេញបានគ្រប់គ្រាន់ និងបានពេញលេញ ។ចរិតត្រៀមធ្វើអំពើសីលធម៌ពាក់ព័ន្ធដល់ផ្នែកគុណសម្បត្តិ (ផ្នែកសីលធម៌ជាក់ស្តែង គឺឥរិយាបថ សញ្ចេតនា ឆន្ទៈ ។ល។ របស់បុគ្គលិកលក្ខណៈថែមទាំងពាក់ព័ន្ធដល់សម្បទាផ្នែកគរុកោសល្យ ជាក់ស្តែងគឺចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ (ទម្លាប់) ។

ប៉ុន្តែក្នុងរចនាសម្ពន្ធបុគ្គលិកលក្ខណៈ នៅមានធាតុបង្កសំខាន់មួយទៀត នៃបុគ្គលិកលក្ខណៈនោះ គឺមនសិការ ។ លើវិស័យសីលធម៌មនសិការស្ថិតក្រោមទម្រង់ «តម្រូវការស្វ័យអះអាង» «សតិសម្បជញ្ញៈ» ស្មារតីស្វ័យគោរព «កិត្តិយស» ។ល។

**២.៣.** តម្រូវការស្វ័យអះអាងគឺជាការចាំបាច់សម្រាប់អះអាងខ្លួនក្នុងឋានៈជាសមាជិកសង្គមម្នាក់ សមាជិកក្រុមម្នាក់ ។ល។ តម្រូវការចង់ឱ្យមនុស្សទាំងអស់ទទួលស្គាល់ខ្លួនដើម្បីឱ្យស្ងប់ចិត្ត នេះគឺជាតម្រូវការមួយនៃតម្រូវការមូលដ្ឋានរបស់មនុស្ស ហើយតម្រូវការនេះក្លាយទៅជាបុគ្គលិកលក្ខណៈ។ ការស្តែងឡើងជាមូលដ្ឋានរបស់តម្រូវការនេះ គឺចង់ឱ្យមនុស្សទាំងអស់គោរព យកចិត្តទុកដាក់ស្ញើចសរសើរ ។ល។ តម្រូវការនេះចាប់ផ្តើមកើតឡើងក្នុងអំឡុងអាយុ៣ឆ្នាំ និងដុះដាលខ្លាំងក្លាច្បាស់ប្រាកដចាប់ពីវ័យជំទង់។ ដូចគ្នានឹងតម្រូវការផ្សេងៗទៀតរបស់មនុស្សដែរតម្រូវការនេះកើតលូតលាស់ដោយសារសកម្មភាពមានទំនាក់ទំនងឆ្លាស់ និងប្រែប្រួលពេញមួយជីវិត ដោយផ្សារភ្ជាប់ទៅនឹងការប្រែប្រួលទីតាំងសង្គមរបស់បុគ្គល ។ ដោយមានការពាក់ព័ន្ធជិតស្និទ្ធជាមួយតម្រូវការអះអាង តម្រូវការនេះកើតឡើងជាស្វ័យវាយតម្លៃសកម្មភាពគុណសម្បត្តិ និងសមត្ថភាពខ្លួន ។ មុនដំបូងគឺការវាយតម្លៃរបស់សង្គម និងសមូហភាពចំពោះកុមារ ក្រោយមកបន្តិចម្តងៗក៏លេចចេញសម្បទាស្វ័យវាយតម្លៃរបស់កុមារផ្ទាល់ ។ ការងារវាយតម្លៃ និងស្វ័យវាយតម្លៃមាននាទីសំខាន់ក្នុងទំនោរសីលធម៌របស់មនុស្សម្នាក់ៗ ។

ប្រសិនជាការស្វ័យវាយតម្លៃសមស្របមានន័យថា ស្របតាមលក្ខណៈសត្យានុម័តលើមូលដ្ឋាននិយាមសីលធម៌ជឿនលឿន ត្រឹមត្រូវ នោះនឹងបង្កលក្ខណៈងាយស្រួលដល់ការលូតលាស់ចិត្ត និង សីលធម៌ ។ ផ្ទុយមកវិញ ស្វ័យវាយតម្លៃមិនសមស្របអាចស្តែងចេញតាមទិសពីរ ឬមួយទាបជាងសមត្ថភាពជាក់ស្តែងផ្ទាល់ខ្លួន ឬមួយខ្ពស់ជាង ។ ក្នុងករណីទាបជាង ប្រសិនបើមិនទាបខ្លាំងហួសហេតុ នោះគ្មានមហន្តរាយអ្វីទេ ប៉ុន្តែប្រសិនជាទាបហួសហេតុពេកពេលប្រៀបធៀបជាមួយសមត្ថភាពជាក់ស្តែង ពិតប្រាកដ នោះប្រធានសីលធម៌ធ្លាក់ចូលទៅក្នុងសភាពមន្ទិលសង្ស័យបាត់បង់ជំនឿជឿជាក់ខ្លួនឯងរហូតអាចមានទុទិដ្ឋិនិយម ហើយតម្រូវការស្វ័យអះអាងបណ្តាលឱ្យមហន្តរាយដល់កិត្តិយសងាយស្រួលធ្វើឱ្យបុគ្គលិកលក្ខណៈបាត់បង់ទៅវិញ មើលខ្លួនអន់ជាងអ្នកដទៃ ។ ផ្ទុយមកវិញ ប្រសិនបើស្វ័យវាយតម្លៃលម្អៀងទិសខ្ពស់ហួសនឹងធ្វើឱ្យសាមីខ្លួនធ្លាក់ចូលក្នុងជំងឺអួតអាង «លើកកម្ពស់ខ្លួន» មើលស្រាលសមូហភាព មើលស្រាលចិត្តនឹងផ្តល់ឱ្យបុគ្គលិកលក្ខណៈ «ឯកោ» ដាច់ឆ្ងាយពីគេឯង បដិបត្តិនឹងគេ ។ល។

**២.៤.** ទន្ទឹមនឹង «ស្វ័យវាយតម្លៃ» គឺបាតុភូត «សតិសម្បជញ្ញៈ» ។ សតិសម្បជញ្ញៈគឺការរួមផ្សំសីលធម៌នឹងមនសិការសីលធម៌ដែលបានក្លាយទៅជាចរិតធម្មជាតិរបស់បុគ្គលម្នាក់ៗ ។ សតិសម្បជញ្ញៈ គឺជាលទ្ធផលនៃការជ្រាបចូលក្នុង

ចិត្តគំនិត នៅលំនាំវាយតម្លៃសីលធម៌មួយរបស់គ្រួសារ ក្រុម របស់សង្គមជុំវិញ ។ល។ នៅពេលណាមួយនោះ វាបានក្លាយទៅជាសមត្ថភាពស្វ័យវាយតម្លៃសីលធម៌ ។ ការវាយតម្លៃរបស់សតិសម្បជញ្ញៈគឺផ្អែកលើនិយាមឧត្តមគតិ ដូចនេះពេលអំពើសីលធម៌ «សម្រេចបានតាមសំណូមពរ» នោះ «សតិសម្បជញ្ញៈធូរស្រាល» ពោលគឺរីករាយសាទរ ។ ប៉ុន្តែប្រសិនបើអំពើសីលធម៌ត្រូវបានវាយតម្លៃ ហើយមិនសម្រេចបានតាមសំណូមពរ មិនត្រឹមត្រូវ ខុសឆ្គង ។ល។ គឺសតិសម្បជញ្ញៈមានការលំបាកក្នុងចិត្តឥតស្រាក និងឈឺចាប់ ។ ការលំបាកក្នុងចិត្តឥតស្រាករបស់សតិសម្បជញ្ញៈថ្វីបើនៅខាងក្នុង ប៉ុន្តែអំណត់ណាស់ ខ្វល់ក្នុងចិត្ត «ស្តីឱ្យឥតឈប់» ។ ការអប់រំសីលធម៌ គឺត្រូវសំដៅឆ្ពោះទៅរកស្វ័យអប់រំ ស្វ័យត្រួតពិនិត្យស្វ័យវាយតម្លៃ សីលធម៌របស់ប្រធាន ។

សតិសម្បជញ្ញៈ ស្មារតីស្វ័យគោរព កិត្តិយសបុគ្គល ។ល។ ជាគុណសម្បត្តិដែលតម្រូវឱ្យអប់រំដល់មនុស្សម្នាក់ៗ ។

យើងសង្ខេបនេះតាមគម្រោងដូចតទៅ :




គម្រោងកត្តាចិត្តដែលប្រព្រឹត្តដោយផ្ទាល់លើអំពើសីលធម៌ (ប្រកាន់អាកប្បកិរិយា)

## ៣- វិធីធ្វើឱ្យសុក្រឹតដល់ការអប់រំសីលធម៌សិស្ស និងចលនាការសង្គម-ចិត្ត

**៣.១**. ការផ្ដត់ផ្គង់ចំណេះដឹងដល់សិស្ស (ចំណេះដឹងសីលធម៌ ឥរិយាបថ ភារកិច្ច កាតព្វកិច្ច ។ល។) មិនអាចមានតែមួយគត់នៅក្នុងការអប់រំសីលធម៌នោះទេ ។ ការងារនេះគឺគ្រាន់តែជាគន្លឹះអប់រំសីលធម៌មួយនៅសាលារៀនប៉ុណ្ណោះ ។ តាមរយៈម៉ោងសិក្សាសីលធម៌ ប្រសិនបើអនុវត្តបានលទ្ធផលសិស្សនឹងត្រូវផ្ទុកទៅដោយចំណេះដឹងទូទៅ ដែលមានប្រព័ន្ធសីលធម៌ ។ លទ្ធផលនេះស្តែងឡើងច្បាស់លាស់នៅលើមេរៀន លំហាត់ត្រួតពិនិត្យ វិញ្ញាសាប្រឡងលើមុខវិជ្ជាសីលធម៌ ។ ឥទ្ធិពលនៃទុនចំណេះដឹងនេះ គឺនៅត្រង់ជួយសីលធម៌របស់សិស្សឱ្យបានត្រឹមត្រូវ ហើយមើលឃើញ "អ្វីជាសីលធម៌ ហើយអ្វីជាអសីលធម៌" ច្រើនបែបច្រើនយ៉ាងនៅជុំវិញខ្លួន និងជួយប្អូនកំណត់ទិសក្នុងបាតុភូតទាំងនោះ ព្រមទាំងបង្កើតបន្ថែមចរិតស្វ័យភ្ញាក់រឭក ដែលជាសញ្ញាសម្គាល់មួយនៃអំពើសីលធម៌ ។

ប៉ុន្តែទោះបីបង្រៀនល្អដល់កម្រិតណាក៏ដោយ ក៏ម៉ោងសិក្សា និងមេរៀននៅក្នុងថ្នាក់រៀននៅតែមិនទាន់ធ្វើឱ្យចំណេះដឹងសីលធម៌ចាក់ឫសចូលជ្រៅក្នុងវិស័យចំណេះដឹង វិស័យបញ្ញារបស់ប្អូនៗបានដែរ (គឺមិនទាន់និយាយដល់ការប្រព្រឹត្តលើវិស័យផ្សេងៗទៀត ដូចជាការរំភើបឆន្ទៈជាដើម) ។ ប៉ុន្តែបើខ្វះ ប្រការនេះ នោះគឺមិនទាន់ដុះដាលនូវជំនឿជាក់សីលធម៌ ដែលមានប្រព័ន្ធរឹងមាំឥតប្រែប្រួលឡាស់ ។

**៣.២**. ដើម្បីប្រែក្លាយចំណេះដឹងទៅជាជំនឿជាក់សីលធម៌ គឺត្រូវប្រព្រឹត្តទៅលើវិស័យសញ្ចេតនាឆន្ទៈ ។ ក្នុងវិស័យនេះ រឿងនិទានមានលក្ខណៈរស់រវើកដែលអធិប្បាយក្នុងម៉ោងសីលធម៌ ការប្រព្រឹត្តសីលធម៌ ផ្នែកអក្សរសាស្ត្រ សិល្បៈ នៅក្នុងកម្មវិធីក្រៅម៉ោងសិក្សានៃមុខវិជ្ជាសីលធម៌ ... ក៏សំខាន់ណាស់ដែរ ។ របៀបប្រព្រឹត្តលើវិស័យសញ្ចេតនាចំណុចពិសេសនៃនិមិត្តរូបសិល្បៈរបស់រឿងនិទាន និង រួមចំណែកយ៉ាងសកម្មក្នុងការបណ្ដុះបណ្ដាលឥរិយាបថសញ្ចេតនា អំពើសីលធម៌ ព្រមទាំងប្រែក្លាយចំណេះដឹងទៅជាជំនឿជាក់ ។

ប៉ុន្តែសំខាន់ជាងនេះទៅទៀត គឺការប្រាស្រ័យទាក់ទងជាមួយមនុស្សពិត ការងារពិត ជាមួយប្រធានបទផ្ទាល់ពីទង្វើសីលធម៌របស់ប្អូនៗ ។

កម្លាំងបញ្ចុះបញ្ចូលដ៏ធំធេង « មនុស្សពិត ការងារពិត » គឺស្ថិតនៅត្រង់សមត្ថភាពបញ្ចូលជំនឿជាក់របស់មនុស្សម្នាក់ៗ របស់ក្រុម និងសង្គម ។ អំពើសីលធម៌នេះ អាចជាក្លាយជាក្បួនខ្នាតធ្វើឱ្យសិស្ស ធ្វើតាមក្នុងស្ថានភាពមួយ ដើម្បីប្រកាន់អាកប្បកិរិយាប្រហែលៗគ្នា ។

គេត្រូវបណ្តុះបណ្តាលព្រមគ្នានូវប្រការទាំងអស់នេះ ពោលគឺ ស្វ័យវាយតម្លៃសីលធម៌នៃសតិសម្បជញ្ញៈកិត្តិយស ។ល។

**៣.៣**. ក្នុងការអប់រំសីលធម៌ត្រូវយកចិត្តទុកដាក់ ដល់ឥទ្ធិពលចិត្តរបស់សង្គម ក្រុម និងគ្រួសារ ទំនាក់ទំនងមិត្តភក្តិក្នុងក្រុមមានតួនាទីដឹកនាំ ។ ក្រុម និងសង្គមរបស់ប្អូនគឺជំនួសមុខសង្គម និងជាផ្នែកមួយរបស់សង្គមដែលមានឥទ្ធិពលធំធេង ចំពោះការបណ្ដុះបណ្ដាលសីលធម៌របស់ប្អូន ។ បទពិសោធសីលធម៌របស់ក្រុម និងសង្គម គឺជាប្រភពបទពិសោធដោយពិតៗលើសីលធម៌ និងជានិយាមសីលធម៌របស់ក្រុម និងសង្គម ដែលជានិយាមសីលធម៌សង្គមចាំបាច់ចំពោះប្អូនៗ។ ការអប់រំសីលធម៌ជាមូលដ្ឋានដល់សិស្សគឺ«ការអប់រំនៅក្នុងក្រុមសង្គម ដោយក្រុមសង្គម និងដើម្បីក្រុមសង្គម » ។

ដើម្បីអប់រំសីលធម៌ក្នុងក្រុមសង្គមឱ្យបានសម្រេចបានលទ្ធផលល្អ ត្រូវយកចិត្តទុកដាក់លើចំណុចដូចតទៅ៖

- សកម្មភាពសង្គមក្រុម ដំបូងបង្អស់ត្រូវសំដៅទៅរកផលប្រយោជន៍របស់ក្រុម និងសង្គម ផលប្រយោជន៍របស់សមាជិកម្នាក់ៗ ។
- ខ្លឹមសារ និងទម្រង់សកម្មភាពត្រូវផ្ទុកទៅដោយទំនាក់ទំនងសង្គមជឿនលឿន សកម្ម ស្តែងចេញជាប្រព័ន្ធសំណូមពរសីលធម៌ ដែលសិស្សយល់បាន និងត្រូវបានអនុវត្តដោយមានការឯកភាពគ្នាក្នុងក្រុមសង្គម ។
- ខ្លឹមសារ និងទម្រង់សកម្មភាពរបស់ក្រុមរបស់សង្គម ត្រូវស្របជាមួយកម្រិតសម្បទា ចិត្តរបស់វ័យ និយាយរួម និងបង្កើតលក្ខខណ្ឌឱ្យបុគ្គលលូតលាស់ធ្វើយ៉ាងណាដើម្បីឱ្យមានភាពសុខដុមតុល្យភាពរវាងសកម្មភាពក្រុម

សង្គម និងការរស់នៅរបស់បុគ្គល ។

- ការចូលរួមជាមួយគ្នាត្រូវមានទំនាក់ទំនងជាប់ជាប្រចាំ ដើម្បីទទួលខុសត្រូវលើមូលដ្ឋានបុគ្គលម្នាក់ៗ ថ្វីបើគុណសម្បត្តិសម្បទារបស់ខ្លួនសុទ្ធតែមានទីតាំងមួយសមស្របក្នុងក្រុមសង្គម ។
- ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលមនសិការសីលធម៌ តាមរយៈទង្វើសីលធម៌របស់ក្រុម ។ ជាក់ស្តែងគឺ ត្រូវចាត់តាំងឱ្យល្អពីគន្លឹះ «ផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកក្នុងក្រុមសង្គម» មុនធ្វើសកម្មភាពនីមួយៗ និង «វាយតម្លៃទាញរកបទពិសោធ» ។ ក្រោយពេលធ្វើសកម្មភាពនីមួយៗក្នុងនោះ ត្រូវយកចិត្តទុកដាក់ កសាងមតិក្រុមសង្គមខ្លាំងក្លា និងមូលមតិជាឯកច្ឆន្ទចំពោះស្ថានភាពនីមួយៗ ។
- ត្រូវមានចលនាឈានឡើងរបស់ក្រុម សង្គម តាមរយៈទស្សនៈស្វ័យគ្រប់គ្រងខ្ពស់។ ធាតុពិតគឺត្រូវឱ្យ ប្អូនៗឆ្លងកាត់ជំនាន់បណ្តុះបណ្តាលក្រុមសង្គមមួយត្រឹមត្រូវ ស័ក្តិសមនឹងឈ្មោះរបស់ខ្លួនដែលត្រូវមាន ការផ្លាស់ប្តូរពីបែបបទ (ឬកពារអាការៈ) សម្រួលអនុវត្តដឹកនាំរបស់ «មេដឹកនាំ» ដើម្បីឆ្លើយតបទៅនឹងដំណាក់កាលប្រែប្រួលនីមួយៗរបស់សង្គម ។

**៣.៤.** ទម្រង់ខ្ពស់បំផុតនៃលំនាំអប់រំសីលធម៌គឺស្វ័យអប់រំ ។ ពេលនេះប្រធាន «ដណ្តើម» «ធ្វើម្ចាស់» បាន លើកគោលបំណង វិធី មធ្យោបាយ ដែលសង្គមក្រុមបានអប់រំខ្លួនប្រែក្លាយប្រការដែល «ដណ្តើម» បានទៅជា ឧបករណ៍ដោយឡែក និងប្រើប្រាស់ក្នុងការធ្វើឱ្យសីលធម៌ផ្ទាល់ខ្លួន ។ ពេលនេះប្រព័ន្ធទស្សនៈសីលធម៌ជឿនលឿន តម្រូវការសីលធម៌មួយស្តែងឱ្យឃើញតារាងកំណត់ទិសដៅ និងលក្ខណៈត្រៀមប្រព្រឹត្តអំពើសីលធម៌ និងចំណុច ទាំងអស់នោះដែលសុទ្ធតែត្រូវបានអនុវត្តក្នុងទង្វើសីលធម៌ ត្រូវបានធ្វើស្វ័យវាយតម្លៃត្រៀមប្រៀបធៀប ផ្ទុផ្តងដោយ សតិសម្បជញ្ញៈ ស្មារតីស្វ័យគោរព កិត្តិយស ។ល។

សង្ខេបមកយើងអាចប្រើប្រាស់គម្រោង ដូចតទៅ :

| |
|---|
| ទស្សនៈជឿជាក់ សីលធម៌ ទស្សនៈសីលធម៌ |

| |
|---|
| -សតិសម្បជញ្ញៈ<br>-ស្មារតីស្វ័យគោរព<br>- កិត្តិយស ។ល។ |

គម្រោងពីចលនាការទូទៅនៃលំនាំសីលធម៌

## IV- សន្និដ្ឋាន

នៅក្នុងសង្គមមានការរីកចម្រើនបានដរាបណាគ្រូបង្រៀន ចាំបាច់ត្រូវចូលរួមយ៉ាងសកម្មក្នុងការអប់រំសីលធម៌ ដើម្បីឱ្យសិស្សមានសុខភាពផ្លូវចិត្តមាំមួន មានការលូតលាស់បញ្ញាបានល្អ និងគំនិតច្នៃប្រឌិត មានសមត្ថភាពដោះ ស្រាយបញ្ហាប្រឈមបានត្រឹមត្រូវ និងបំណិនប្រាស្រ័យទាក់ទងប្រកបដោយសន្តិភាព ។

### សំណួរ

1. ដូចម្ដេចដែលហៅថា សីលធម៌ ?
2. តើគ្រូបង្រៀនត្រូវធ្វើដូចម្ដេច ដើម្បីលើកកម្ពស់សីលធម៌មនុស្ស ? ចូរលើកឧទាហរណ៍បញ្ជាក់ ។
3. តើការយល់ដឹងពីចិត្តវិទ្យាអប់រំ មានសារៈប្រយោជន៍យ៉ាងណា ចំពោះគ្រូ និងសិស្ស ?

# មេរៀនទី៣៥ ចិត្តវិទ្យាគ្រប់គ្រង

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

- រៀបរាប់នូវចំណេះដឹងពីមេរៀនចិត្តវិទ្យាគ្រប់គ្រង
- ប្រៀបធៀបចិត្តវិទ្យា និងសម្បទានៃការគ្រប់គ្រង
- ប្រែក្លាយទ្រឹស្តីទៅជាបទពិសោធ ជាវិទ្យាសាស្ត្រសម្រាប់ការងារគ្រប់គ្រង

## II- សេចក្តីផ្តើម

ដើម្បីបង្កើនផលិតផល ឱ្យបានល្អប្រសើរក្នុងការងារគ្រប់គ្រងរបស់ខ្លួនមនុស្សចាប់ផ្តើមមានគំនិតគិតរកមធ្យោបាយធ្វើយ៉ាងណាបង្កើនសកម្មភាពរបស់មនុស្សឱ្យខ្លាំងក្លា ទើបទិន្នផលកើនឡើង ។ ទន្ទឹមនឹងនោះ មនុស្សចាប់ផ្តើមជំរុញមនុស្ស តាមរយៈការលើកទឹកចិត្ត ជូនរង្វាន់ សរសើរផ្តល់ប័ណ្ណសរសើរ តំឡើងឋានៈ តំឡើងប្រាក់ខែចំពោះអ្នកមានស្នាដៃ ហើយដាក់ពិន័យចំពោះជនណាដែលខ្ជិល ។ បញ្ហាទាំងនេះទាក់ទងទៅនឹងទឹកចិត្ត ឬតម្រូវការរបស់មនុស្ស ។ ដូច្នេះមុខវិជ្ជាចិត្តវិទ្យា ឬចិត្តសាស្ត្រក៏ចាប់ផ្តើមមានសារៈសំខាន់ ហើយបានប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងការងារគ្រប់គ្រងប្រកបដោយគុណភាពខ្ពស់ ។

## III- ខ្លឹមសារ

### និយមន័យ

ចិត្តវិទ្យាគ្រប់គ្រងជាវិទ្យាសាស្ត្រមួយដែលសិក្សាពីបាតុភូតចិត្តសង្គម ពីបុគ្គលិកលក្ខណៈរបស់មនុស្ស និងការបណ្តុះបណ្តាលអប់រំ សតិអារម្មណ៍ ហើយយកវាទៅប្រើប្រាស់នៅក្នុងការងារគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ។

**ចិត្តវិទ្យាគ្រប់គ្រងត្រូវបានចែកចេញជាពីរជំពូក** :

- ជំពូកទីI ចិត្តវិទ្យា
- ជំពូកទីII ការគ្រប់គ្រង

### ជំពូកទី I

**១- ចិត្តវិទ្យាជាអ្វី?**

ក- ចិត្តវិទ្យាជាវិទ្យាសាស្ត្រមួយសិក្សាពីបាតុភូតចិត្ត និងគ្រឹត្យក្រមនៃការកកើតចិត្តរបស់មនុស្ស ។

ខ- ដូចម្តេចដែលហៅថា បាតុភូតចិត្ត?

បាតុភូតចិត្ត ជាបាតុភូតទាំងឡាយណាដែលកើតមាន និងប្រព្រឹត្តនៅក្នុងខួរក្បាលរបស់មនុស្ស ហើយស្តែងចេញមកក្រៅតាមរយៈ ៖

- ទឹកមុខ
- ស្នាមញញឹម
- ពាក្យសម្តី
- កាយវិការ
- អាកប្បកិរិយា
- សកម្មភាពរស់នៅប្រចាំថ្ងៃ

**គ- ដូចម្តេចដែលហៅថា ចិត្ត?**

ចិត្តជាធម្មជាតិដែលចេះត្រិះរិះនូវអារម្មណ៍ ហើយសន្សំនូវអារម្មណ៍ និងដឹងច្បាស់នូវអារម្មណ៍ ដែលធ្លាប់បាន

ទទួលកន្លងមកតាមរយៈឥន្ទ្រីយ៍ទាំង៥ ។

ឧទាហរណ៍ ៖ មុនពេលរៀនអក្សរ យើងមិនទាន់ចេះ ឬដឹងទេ ប៉ុន្តែក្រោយពីបានរៀនរួច យើងអាចអានរួច យើងមើលរួច ។

**ឃ- មុខងាររបស់ចិត្ត**

ចិត្តមានមុខងារជាអ្នកដឹង ៖

- ដឹងទិសលិច កើត ជើង ត្បូង ...
- ដឹងពីអ្វីដែលខ្លួនគួរធ្វើ ឬមិនគួរធ្វើ
- ដឹងពីអ្វីដែលខ្លួនធ្វើខុស ហើយពីអ្វីដែលខ្លួនធ្វើត្រូវ
- ដឹងពីរសផ្អែម ជូរ ប្រៃ ល្វីង ...
- ដឹងពីវត្ថុ រឹង ទន់ ស ខ្មៅ តូច ធំ ជាដើម ។ល។

* សរុបមកគឺយើងមានពុទ្ធិ មានចំណេះដឹង ចំណេះធ្វើគ្រប់យ៉ាងនេះឯង ។ អ្នកណាដឹងតិច គេថាមានចំណេះដឹងតិច អ្នកដឹងច្រើន គេថា មានចំណេះដឹងច្រើន ឬហៅថាមនុស្សមានចិត្ត មានបញ្ញាច្រើននេះឯង ។

## ២- បុគ្គលិកលក្ខណៈរបស់មនុស្ស

### ២.១- បុគ្គលិកលក្ខណៈ

**និយមន័យ៖** បុគ្គលិកលក្ខណៈជាលក្ខណៈចិត្ត ជារូបភាពចិត្តសង្គមរបស់បុគ្គលម្នាក់ៗនៃតថភាពបរានុម័ត ហើយវាផ្សំឡើងដោយធាតុពីរគឺ គុណធម៌ និង សម្បទា ។ បុគ្គលិកលក្ខណៈវាតំណាងឱ្យវណ្ណៈមួយ ក្រុមមួយ សង្គមមួយ ហើយវាក៏តំណាងឱ្យមនុស្សម្នាក់ៗផងដែរ ។

**ឧទាហរណ៍ទី១** ៖ ជនជាតិវៀតណាមមានបុគ្គលិកលក្ខណៈមួយដោយឡែកខុសពីជនជាតិកម្ពុជា

**ឧទាហរណ៍ទី២** ៖ ចិន្តា មានបុគ្គលិកលក្ខណៈមួយខុសពី កញ្ញាម្លិះ

### ២.២- កត្តាជះឥទ្ធិពលធ្វើឱ្យកកើតបុគ្គលិកលក្ខណៈមនុស្ស

មនុស្សកើតមកគ្មានបុគ្គលិកលក្ខណៈនោះទេ ប៉ុន្តែដោយសារពួកគេរស់នៅពាក់ព័ន្ធលើកត្តាទាំង៤ ដូច្នេះ បុគ្គលិកលក្ខណៈ ក៏កើតបណ្តើរៗទៅតាមដំណាក់កាល នៃវ័យរបស់ពួកគេ ។

**ក- កត្តាមជ្ឈដ្ឋាន** → ទីតាំង កន្លែងរស់នៅ ទីក្រុង ជនបទ ...
**ក- កត្តាមជ្ឈដ្ឋាន** → សង្គម : ខ្មែរ អាមេរិក ជប៉ុន ថៃ

ក.១. ទីតាំងខុសគ្នា កន្លែងរស់នៅខុសគ្នា ការលូតលាស់ខុសគ្នា ។

ក.២. សង្គមខុសគ្នា វប្បធម៌ខុសគ្នា ការជុះបុគ្គលិកលក្ខណៈខុសគ្នា ។

**ខ- កត្តាអប់រំ ៖** ក្មេងដែលបានទទួលការអប់រំ ខុសពីក្មេងដែលមិនបានទទួលការអប់រំ មានន័យថា សិស្សខ្លះបានរៀន រៀនសាលាល្អ រៀនច្រើន ហើយខ្លះទៀតមិនបានរៀន ឬរៀនបានតិច មានបុគ្គលិកលក្ខណៈខុសគ្នា ។

**គ- កត្តាតំណពូជ ៖** ជាតំណពូជមកពីឪពុកម្តាយដូនតា តាមរយៈការឱ្យហៀរនបន្តពីជំនាន់មួយទៅជំនាន់មួយទៀត ។ មានពូជខ្លះឆ្លាត ពូជខ្លះមិនឆ្លាត ដូចជាពូជផ្លែឈើអញ្ចឹងដែរ មានខ្លះផ្លែធំ មានខ្លះផ្លែតូចដូចគ្នានឹងមនុស្សដែរ។

**ឃ- កត្តាចរិតសកម្មផ្ទាល់របស់ក្មេងម្នាក់ៗ**

- មានក្មេងខ្លះឧស្សាហ៍ចង់ចេះចង់ដឹង មានការព្យាយាម
- មានក្មេងខ្លះខ្ជិលមិនចង់រៀនទេ គេចសាលា មិនមើលមេរៀនពេលមកដល់ផ្ទះវិញ ។

- កត្តាមជ្ឈដ្ឋាន
- កត្តាអប់រំ
- កត្តាតំណពូជ
- កត្តាចរិតសកម្មផ្ទាល់ខ្លួន

} កកើតជាបុគ្គលិកលក្ខណៈ

### ២.៣- រចនាសម្ព័ន្ធរបស់បុគ្គលិកលក្ខណៈ

បុគ្គលិកលក្ខណៈមានរចនាសម្ព័ន្ធដូចខាងក្រោម ៖

បុគ្គលិកលក្ខណៈ
- ក/ ទំនោរ →
  - ក១. តម្រូវការ
  - ក២. ចំណូលចិត្ត
  - ក៣. លោកទស្សនៈ
  - ក៤. ឧត្តមគតិ
- ខ/ អត្តចរិត
- គ/ ឫកពា
- ឃ/ សម្បទា

**ក- ទំនោរ ៖** អ្វីជាទំនោរ ?

ទំនោរជាលក្ខណៈចិត្តស្មុគស្មាញ ជាប្រព័ន្ធកម្លាំងចលករខាងក្នុង ដែលកំណត់ដល់ការជ្រើសរើសនូវឥរិយាបថ និងចរិតសកម្មរបស់បុគ្គលម្នាក់ៗ ។ ដោយសារទំនោរជាកម្លាំងចលករ វាជុញច្រានមនុស្សបង្កើតបានជានិន្នាការរៀងៗខ្លួនក្នុងសង្គម ។

**ក១- តម្រូវការ ៖** ជាបណ្តាសំណូមពរចាំបាច់របស់មនុស្សម្នាក់ៗ ដើម្បីរស់ និងដើម្បីធ្វើការងារ ។

**ឧទាហរណ៍ ៖** មនុស្សត្រូវការហូបចុក ស្លៀកពាក់ ប្រើប្រាស់ក្នុងការរស់នៅប្រចាំថ្ងៃ ។

**ក២- ចំណូលចិត្ត ៖** ជាឥរិយាបថរបស់បុគ្គល ចំពោះវត្ថុ ឬបាតុភូតទាំងឡាយក្នុងតថភាពបរានុម័ត ដែលមានការពេញចិត្ត និងធ្វើឱ្យជីវិតរបស់គេមានន័យ ឬអត្ថន័យ ។

**ឧទាហរណ៍ ៖** បុប្ផាចូលចិត្តរៀនអក្សរសាស្ត្រខ្មែរ ។

**ក៣- លោកទស្សនៈ ៖** ជាទស្សនៈរបស់បុគ្គលម្នាក់ៗ ដែលមានការយល់ដឹងអំពីធម្មជាតិ សង្គម មនុស្ស ។ លោកទស្សនៈជាទូទៅជាអ្នកកំណត់ឥរិយាបថរបស់បុគ្គល ហើយវាជាគ្រឹះនៃសីលធម៌របស់មនុស្សផងដែរ ។

**ឧទាហរណ៍ ៖** ស្រីរតន៍ ជាសិស្សដែលមានការយល់ដឹង ។ ដូចនេះ នាងជាក្មេងដែលមានសីលធម៌ ចេះគោរពឪពុកម្តាយ ចាស់ទុំក្នុងភូមិជាមួយគ្នា ។

**ក៤- ឧត្តមគតិ ៖** ជាភាពគំរូល្អឥតខ្ចោះ ដែលបុគ្គលម្នាក់ៗចង់បាន ឬមានការធ្វើតាម ដើម្បីសម្រេចនូវបំណងរបស់ពួកគេ ។

**ឧទាហរណ៍៖** លោកអាចារ្យ ហែម ចៀវ ជាវីរៈជនគំរូស្នេហាជាតិ ។

**ខ- អត្តចរិត**

អត្តចរិតជាលក្ខណៈចិត្ត ជាការសម្តែងប្រាប់នូវឥរិយាបថរបស់បុគ្គលម្នាក់ៗក្នុងតថភាពបរានុម័ត ។ ឥរិយាបថនេះត្រូវបានសម្តែងប្រាប់តាមរយៈអំពើ និងអាកប្បកិរិយារបស់បុគ្គលក្នុងការងារ ការរៀនសូត្រ ឬសកម្មភាពរស់នៅប្រចាំថ្ងៃ ។

**ឧទាហរណ៍ ៖** កញ្ញា ប៊ូព្រឹក ជាក្មេងឧស្សាហ៍ភ្ញាក់ពីព្រឹក ក្រោកឡើងបត់មុង កន្ទេល បោសសម្អាតផ្ទះ ស្រោចទឹកផ្កាជាស្រេចមុននឹងមកសាលារៀន ។

**គ- ឫកពា ៖** ជាលក្ខណៈចិត្ត ជាការសម្តែងប្រាប់នូវអាកប្បកិរិយាដោយឡែករបស់បុគ្គលម្នាក់ៗ ក្នុងតថភាពបរានុម័ត ។

**ឧទាហរណ៍ទី១ ៖** ផន ស៊ី និយាយញាប់ជាង រតនា ។

**ឧទាហរណ៍ទី២ ៖** សារី ធ្វើកិច្ចការរហ័ស រីឯនិមលធ្វើកិច្ចការមួយៗ ។

គេចែកឫកពាជា៤ តាមលោក អ៊ី ប៉ូក្រាត ក៏ដូចជា លោកប៉ាវ ឡូវ ដែរ ។ ការស្គាល់ឫកពារបស់មនុស្សមាន

សារៈប្រយោជន៍សម្រាប់យកមកប្រើក្នុងការគ្រប់គ្រង ។

**ឧទាហរណ៍**. ៖ផន ស៊ី ជាក្មេងនឹងធឹង យើងអាចប្រគល់ការងារឱ្យគេធ្វើបាន ។

**ឃ- សម្បទា ៖** សម្បទាជាលក្ខណៈចិត្តស្មុគស្មាញនៃបុគ្គលិកលក្ខណៈ វាជាសំណុំលទ្ធភាពចិត្តដែលអាចឱ្យបុគ្គលធ្វើអ្វីបានដោយងាយ ហើយទទួលបានលទ្ធផលល្អ ក្នុងវង្វង់សកម្មភាពមួយ ។

**ឧទាហរណ៍** ៖ បុប្ផាពូកែវាយកុំព្យូទ័រ ។

**ឃ១- ចំណាត់ថ្នាក់នៃសម្បទា**

គេចែកសម្បទាជាពីរ ៖

* **សម្បទាពិសេស** : ជាសម្បទាដែលឱ្យពីកំណើតរបស់បុគ្គលម្នាក់ៗ ។

**ឧទាហរណ៍** ៖ លោក ស៊ិន ស៊ីសាមុត មានសំឡេងពីរោះ គ្មានអ្នកណាមានសំឡេងពីរោះដូច ។

* **សម្បទាទូទៅ** ជាសម្បទាកើតឡើងដោយសារការរៀនឬបណ្តុះបណ្តាលក្នុងគ្រួសារ សាលារៀន និងសង្គម។

**ឧទាហរណ៍** ៖ ចិន្តា មានសមត្ថភាពវិភាគខាងទីផ្សារ ។

**ឃ២- កម្រិតនៃសម្បទា**

គេចែកសម្បទាជា៣កម្រិត

- **កម្រិតធម្មតា** : ហៅថា សម្បទា
- **កម្រិតខ្ពស់** : ហៅថា កោសល្យ(គឺជាសម្បទាកម្រិតខ្ពស់ដែលអាចឱ្យមនុស្សធ្វើអ្វីបានដោយងាយ ហើយទទួលបានលទ្ធផលល្អប្រសើរ) ។
- **កម្រិតខ្ពស់បំផុត**: ហៅថាទេពកោសល្យ (ជាសម្បទាកម្រិតខ្ពស់បំផុតវិសាមញ្ញ ចម្លែកដែលអាចឱ្យបុគ្គលធ្វើអ្វីបានដោយងាយ ហើយទទួលបានលទ្ធផលមានតម្លៃមិនអាចកាត់ថ្លៃបាន) ។

គេអាចរាប់ជនទេពកោសល្យបានជាច្រើននៅលើពិភពលោក ។ ឧទាហរណ៍៖ ព្រះបាទជ័យវរ្ម័នទី៧ ...។

ជនទេពកោសល្យជាបាតុភូតជន យើងត្រូវមានការបកស្រាយឱ្យបានច្បាស់លាស់ពីស្នាដៃរបស់ពួកគាត់ បើមិនដូច្នោះទេ ត្រូវធ្លាក់ទៅក្នុងទស្សនៈទេវកម្មនិយម ។ ឧ. ប្រាសាទអង្គរវត្តជាស្នាដៃរបស់មនុស្សជាអ្នកសាងសង់ ។

អ្នកមានសម្បទា មានន័យថា មានសមត្ថភាព ឬមានជំនាញក្នុងការបំពេញភារកិច្ចមួយបានល្អប្រសើរ ក្នុងសកម្មភាពបំពេញភារកិច្ចរបស់ខ្លួនប្រចាំថ្ងៃ ។

**៣- បណ្តាវិធីសាស្ត្រសម្រាប់ស្រាវជ្រាវពីបាតុភូតដើម្បីស្គាល់ចិត្តមនុស្ស**

៣.១- វិធីសាស្ត្រសង្កេត ៖ ជាវិធីសាស្ត្រមួយមើល ឬតាមដានដោយម៉ត់ចត់ទៅលើកម្មវត្ថុ ដែលកំពុងសិក្សាមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

**ឧទាហរណ៍** ៖ លោកគ្រូកំពុងសង្កេតសកម្មភាពសិក្សារបស់សិស្សឈ្មោះ ផល្លី ។

៣.២- វិធីសាស្ត្រសង្កេតដោយសរសេរ ៖ គឺជាវិធីសាស្ត្រប្រយោល មិនសិក្សាដោយផ្ទាល់ទៅលើកម្មវត្ថុនោះ ទេ ។ គឺសិក្សាពីស្នាដៃរបស់គេ របាយការណ៍ ឯកសារ ប្រវត្តិរូប សិលាចារឹក ស្លាកស្នាម ឬប្រព័ន្ធកម្រងសំណួរជាដើម ។

**ឧទាហរណ៍** ៖ ពេលលោកគ្រូកែកិច្ចការ ទើបដឹងថា ចំរើន ពូកែជាង ធីតា ។

៣.៣- វិធីសាស្ត្រសន្ទនា៖ ជាវិធីសាស្ត្រមួយឆ្លងកាត់តាមរយៈការនិយាយគ្នា ដែលជាបាតុភូតចិត្តមួយ ធ្វើឱ្យយើងដឹងពីចិត្តគំនិតមនុស្សនោះ ។

**៣.៤- វិធីសាស្ត្រពិសោធន៍៖** ជាវិធីសាស្ត្រមួយដ៏សំខាន់ ដើម្បីធ្វើការពិសោធទៅលើមនុស្ស ដើម្បីឱ្យបាតុភូតចិត្តរបស់គេស្តែងចេញមកក្រៅតាមរយៈសកម្មភាព ទើបយើងជាអ្នកសិក្សាអាចវាយតម្លៃចិត្តគំនិត បញ្ញា ស្មារតី គេបាន ។

**ឧទាហរណ៍** ៖ ចង់ដឹងសិស្សណាពូកែ មិនពូកែត្រូវដាក់កិច្ចការឱ្យធ្វើ ។ តាមរយៈកិច្ចការនេះ យើងនឹងរកឃើញសិស្សពូកែ ។

## ជំពូកទី II

### ១- ការគ្រប់គ្រង

**១.១- និយមន័យ៖** ការគ្រប់គ្រងគឺជាដំណើរការសម្រេចគោលដៅនៃអង្គការចាត់តាំងមួយដ៏មានប្រសិទ្ធភាពដែលស្តែងចេញនូវការចេះប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀតដូចជា ដី ព្រៃ រ៉ែ សមុទ្រ លុយ... ឱ្យមានប្រសិទ្ធភាព ឬអស់លទ្ធភាព ។

**១.២- អង្គការចាត់តាំង**

អង្គការចាត់តាំងជាការរៀបចំឡើងជាប្រព័ន្ធរបស់ក្រុមមនុស្ស សំដៅដើម្បីសម្រេចនូវគោលបំណងដ៏ជាក់លាក់មួយចំនួនរបស់ខ្លួន ។

**ឧទាហរណ៍** ៖ សាលារៀន មន្ទីរពេទ្យ ក្រុមហ៊ុន ក្រសួង រដ្ឋ សុទ្ធតែជាអង្គការចាត់តាំង ។

**១.៣- រចនាសម្ព័ន្ធនៃអង្គការចាត់តាំង**

ក្នុងអង្គការចាត់តាំងមានរចនាសម្ព័ន្ធ៣ ៖

- ផ្នែកនីមួយៗក្នុងអង្គការចាត់តាំង ត្រូវបានចាត់តាំងឡើងដោយមនុស្ស
- ផ្នែកនីមួយៗក្នុងអង្គការចាត់តាំង សុទ្ធតែបានបំពេញនូវសកម្មភាពមួយជាក់លាក់របស់ខ្លួន
- ផ្នែកនីមួយៗក្នុងអង្គការចាត់តាំង សុទ្ធតែបានបង្ហាញពី តួនាទី ឋានៈ សិទ្ធិ អំណាច ដែលមានការកំណត់សកម្មភាពច្បាស់លាស់ ។

+ បីផ្នែកនេះរួមបញ្ចូលគ្នា បង្កើតបានជាសមាសភាពប្រធាន អនុប្រធាន ជាប្រធានផ្នែក ជានាយកដ្ឋានផ្សេងៗ បង្កើតបានជាគោលនយោបាយ ជាច្បាប់ ជាសារាចរ ជាវិន័យផ្សេងៗ ដើម្បីប្រតិបត្តិក្នុងអង្គការចាត់តាំងនីមួយៗ ។

**១.៤- មុខងារនៃការគ្រប់គ្រង**

យើងបានដឹងហើយថា ការគ្រប់គ្រងគឺជាដំណើរការសម្រេចគោលដៅ របស់អង្គការចាត់តាំងមួយ ដែលក្នុងនោះមានការពាក់ព័ន្ធទៅដល់ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ទំនាក់ទំនងមនុស្សជាមួយនឹងការគ្រប់គ្រងធនធានដទៃទៀតដូចជា លុយ រ៉ែ ដី ព្រៃឈើ ។ល។ ដូចនេះការងារគ្រប់គ្រងជាការងារមួយស្មុគស្មាញ ដែលស្តែងចេញនូវមុខងារ៤សំខាន់គឺ ៖

ក- ផែនការ Planning

ខ- ចាត់តាំង Organizing

គ- ដឹកនាំ Leading

ឃ- ត្រួតពិនិត្យ Controlling

**ការអធិប្បាយ**

**ក- ផែនការ** ៖ ជាគម្រោង ឬជាយុទ្ធសាស្ត្រ ដែលគេបានរៀបចំឡើង ដើម្បីទុកយកវាទៅអនុវត្ត ឬ ធ្វើតាម ។

មុននឹងចេញផែនការ គេត្រូវសិក្សាស្រាវជ្រាវជាមុនសិន នូវរាល់បញ្ហាទាំងនោះ ដែលមានការពាក់ព័ន្ធ ដូចជា លុយ គោលនយោបាយ ស្តង់ដារ ទម្រង់បែបបទ ។

**ខ- ចាត់តាំង** ៖ ជាការចាត់ចែង ឬបែងចែកនូវរាល់សកម្មភាពទាំងឡាយ ដែលអនុវត្តក្នុងអង្គការចាត់តាំង តាម រយៈមនុស្សជាអ្នកដឹកនាំសកម្មភាពប្រតិបត្តិ ។

**គ- ដឹកនាំ** ៖ ជាអ្នកដឹកនាំធ្វើសកម្មភាពមានការជំរុញលើកទឹកចិត្ត ដាក់វិន័យ ពិន័យ ជូនរង្វាន់ ថែមប្រាក់ខែជាដើម ឬប្រជុំធ្វើសតិអារម្មណ៍ដល់កូនចៅ លៃយ៉ាងណាឱ្យពួកគេធ្វើសកម្មភាពខ្លាំងក្លា ដើម្បីសម្រេចផែនការក្នុង ការងារគ្រប់គ្រងរបស់ខ្លួន ។

**ឃ- ត្រួតពិនិត្យ** ៖ គឺជាមុខងារមួយដ៏សំខាន់បំផុតក្នុងការងារគ្រប់គ្រង បើគ្មានវាទេនោះ អ្នកគ្រប់គ្រង មិនដឹង ថា

ខ្លួនធ្វើខុស ឬធ្វើត្រូវ ធ្វើបានប៉ុន្មានភាគរយនៃផែនការហើយនោះទេ ។

ត្រួតពិនិត្យ គឺត្រូវត្រួតពិនិត្យនៅលើផ្នែក៤ ៖

- ត្រួតពិនិត្យ គុណភាព
- ត្រួតពិនិត្យ បរិមាណ
- ត្រួតពិនិត្យ ចំណាយចំណូល
- ត្រួតពិនិត្យ ពេលវេលា

១.៥- ក្នុងអង្គការចាត់តាំងគេចែកមនុស្សជាពីរផ្នែក ៖

- **ផ្នែកទី១** ៖ ជាកូនចៅ ជាបុគ្គលិកធម្មតា ឬជារាស្ត្រគ្មានតួនាទីដឹកនាំ ឬទទួលខុសត្រូវលើអ្នកដទៃឡើយ ។
- **ផ្នែកទី២** ៖ ជាមេ ជាថ្នាក់ដឹកនាំ ជាមន្ត្រីមានតួនាទី ធ្វើការងារខ្លួនឯងផង និងត្រួតត្រា ឬទទួលខុសត្រូវលើអ្នកដទៃ កូនចៅ ។

**មេដឹកនាំនេះ ចែកចេញជា៣កម្រិតទៀតគឺ ៖**

– **កម្រិតខ្ពស់បំផុត ( Top Managers )**

គឺជាក្បាលម៉ាស៊ីនបញ្ជា ទទួលខុសត្រូវលើរាល់កិច្ចការប្រតិបត្តិការទាំងអស់របស់អង្គការចាត់តាំងមួយ ឬក្រុមហ៊ុនមួយ ។

អ្នកគ្រប់គ្រងថ្នាក់ខ្ពស់ គឺជាអ្នកផ្តួចផ្តើមគំនិត បង្កើតផែនការ បង្កើតយុទ្ធសាស្ត្រ បង្កើតជារូបមន្តក្នុងដំណើរការប្រតិបត្តិក្នុងអង្គការចាត់តាំងរបស់ខ្លួន ។ គេក៏ត្រូវសម្តែងផងដែរនូវភាពជាអ្នកដឹកនាំ ជាអ្នកវាយតម្លៃ ធ្វើសេចក្តីព្រាងច្បាប់ផ្សេងៗ វិធីចាត់តាំង ត្រួតពិនិត្យ ជំរុញសកម្មភាពឱ្យសម្រេចបាននូវគោលការណ៍ដែលបានដាក់ចេញ ។

ជាទូទៅ អ្នកគ្រប់គ្រងថ្នាក់ខ្ពស់គេហៅថា ប្រធាន ឬអនុប្រធាន នាយក ឬនាយករង ឬថៅហ្វែ ។ល។ និង ។ល។

ឧទាហរណ៍ ៖ ប្រធានក្រុមហ៊ុន ប្រធានមន្ទីរ ប្រធានសភា នាយកសាលា នាយករដ្ឋមន្ត្រីជាដើម ។

– **កម្រិតកណ្តាល ( Middle Managers )**

គឺជាអ្នកដែលទទួលខុសត្រូវផ្ទាល់លើអ្នកគ្រប់គ្រងថ្នាក់ទាប ។ គឺជាអ្នកគ្រប់គ្រងតាមបណ្តាផ្នែក ( Department ) ជំនាញនីមួយៗដូចជា ផ្នែកម៉ាកាធីង ផ្នែកផលិតកម្ម ផ្នែកគ្រប់គ្រងបុគ្គលិក ផ្នែកហិរញ្ញវត្ថុជាដើម ។ សំខាន់ជាងនេះទៅទៀត អ្នកគ្រប់គ្រងថ្នាក់កណ្តាលជាអ្នកទទួលខុសត្រូវលើការអនុវត្តផែនការ និងគោលនយោបាយតាមផ្នែករបស់អង្គភាព ឬអង្គការចាត់តាំងមួយ ដើម្បីប្រមូលផ្តុំជាគោលដៅរួមសំដៅសម្រេចផែនការរួម ។

**ឧទាហរណ៍៖**១. ក្រុមហ៊ុនមួយមានប្រធានផ្នែកមួយ ដែលជាអ្នកទទួលបន្ទុកគ្រប់គ្រងបុគ្គលិករបស់ក្រុមហ៊ុន។

២. អង្គការមួយមានសុទ្ធតែប្រធានផ្នែកមួយៗរបស់វា ដើម្បីទទួលបន្ទុកបន្ទាប់ពីប្រធានធំរបស់អង្គការនោះ ។

– **កម្រិតទាប ( Lowest Managers )**

គឺជាអ្នកដែលដឹកនាំផ្ទាល់ ធ្វើសកម្មភាពជាមួយកម្មករ ឬប្រជារាស្ត្រប្រចាំថ្ងៃ ដើម្បីប្រតិបត្តិតាមផែនការដែលបានដាក់ចុះ ។

ដូចនេះ អ្នកគ្រប់គ្រងថ្នាក់ទាបក៏ត្រូវពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទាល់ លើការកែតម្រូវ ឬដោះស្រាយបញ្ហាទាក់ទងក្នុងផលិតកម្ម ឬសេវាកម្មដែរ ។

**ឧទាហរណ៍៖** ១. ប្រធានក្រុម ប្រធានផ្នែកតូចៗក្នុងផលិតកម្មផ្ទាល់ ។

២. បើអង្គការចាត់តាំងជារដ្ឋវិញមានដូចជា មេក្រុម មេភូមិ មេស្រុកជាដើម ។

រូបបំព្រួញមេដឹកនាំទាំងបីកម្រិត



ការចាត់តាំងកម្រិតថ្នាក់ដឹកនាំ

## ២- ជំនាញរបស់អ្នកគ្រប់គ្រង (សម្បទាអ្នកគ្រប់គ្រង)

- ជំនាញប្រើបច្ចេកទេស
- ជំនាញប្រើមនុស្ស
- ជំនាញប្រើបញ្ញា

### ២.១- ជំនាញប្រើបច្ចេកទេស (សម្បទារបស់អ្នកគ្រប់គ្រង)

ដើម្បីបំពេញតួនាទីភារកិច្ចការងារគ្រប់គ្រងរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ឬទទួលបានជោគជ័យនោះ មេដឹកនាំ ឬអ្នកគ្រប់គ្រងចាំបាច់ត្រូវមានជំនាញបច្ចេកទេសច្បាស់លាស់ ដែលឆ្លងកាត់ការរៀននៅសាលា ឬវិទ្យាស្ថានណាមួយពិតប្រាកដ មានសញ្ញាប័ត្រត្រឹមត្រូវ បើពុំដូច្នោះទេ ពុំអាចដឹងពីការងារជំនាញនេះឡើយ ពេលធ្វើជាមេគេគឺគ្មានដឹងអ្វីទាំងអស់ នាំឱ្យការងារគ្រប់គ្រងបរាជ័យ ។

### ២.២- ជំនាញប្រើមនុស្ស (សម្បទាប្រើមនុស្ស)

ជំនាញនេះ ជាជំនាញពិបាក ហើយវាមានសារសំខាន់ និងចាំបាច់ណាស់សម្រាប់មេដឹកនាំ ឬអ្នកគ្រប់គ្រងក្នុងការងារគ្រប់គ្រងរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។ យើងបានដឹងហើយថា ការគ្រប់គ្រងគឺជា ដំណើរការសម្រេចគោលដៅនៃអង្គការចាត់តាំងមួយដ៏មានប្រសិទ្ធភាព ដែលក្នុងនោះមានការស្តែងចេញនូវការចេះប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀតដូចជា ប្រាក់កាស សម្ភារៈដីធ្លី ជាដើម ឱ្យអស់លទ្ធភាព ។ ការប្រើប្រាស់មនុស្សក្នុងការងារគ្រប់គ្រងត្រូវមានជំនាញពិតប្រាកដ ដែលបានរៀនសូត្រ ឬ ទទួលបានបទពិសោធន៍ពីវគ្គបំប៉នផ្សេងៗ តាមសាលា តាមមហាវិទ្យាល័យនានា ផ្នែកចិត្តសាស្ត្រ ឬចិត្តវិទ្យា ហើយយកវាមកប្រើក្នុងការងារគ្រប់គ្រង ទើបទទួលបានលទ្ធផលខ្ពស់ ។

ចិត្តវិទ្យាមានវិធីសាស្ត្រមើលចិត្ត ឬមើលបាតុភូតចិត្តរបស់មនុស្ស ដែលស្តែងចេញតាមរយៈ កាយវិការ អំពើ អាកប្បកិរិយា របស់ពួកគេ ទើបអាចស្គាល់ពី បុគ្គលិកលក្ខណៈ ស្គាល់ពីទំនោរ អត្តចរិក ឬកពា សម្បទា មានន័យថា ស្គាល់ពីតម្រូវការ ចំណូលចិត្ត ទស្សនៈ ឧត្តមគតិ ឆន្ទៈ សញ្ចេតនា របស់ពួកគេយ៉ាងច្បាស់ ។

#### ក- ដើម្បីប្រើមនុស្សបានត្រូវស្គាល់ចិត្ត ស្គាល់តម្រូវការ

**ឧទាហរណ៍ ៖** - ចង់ឱ្យកម្មករធ្វើការងារសកម្មថៅកែត្រូវចេះលើកទឹកចិត្ត ចេះសរសើរ ផ្តល់ប្រាក់លើកទឹកចិត្តចំពោះអ្នកដែលសកម្មក្នុងការងារ ។

- មន្ត្រីរាជការ អ្នកមានស្នាដៃ ឬមានសមត្ថភាពត្រូវដំឡើងឋានៈ ជូនមេដាយ តំឡើងប្រាក់

បៀវត្ស ។

- ក្រុមហ៊ុនទូរស័ព្ទដៃ គេស្គាល់ពីតម្រូវការរបស់មនុស្ស ដូចនេះគេចេះប្រើចិត្តសាស្ត្រ គឺលក់កាតថ្ងៃពិសេសថែមមួយរយភាគរយ ឬថែមពីររយភាគរយដោយសារតែថែមនេះធ្វើឱ្យមនុស្សជ្រួលចិត្តទិញកាតបញ្ចូលកាន់តែច្រើន នេះមានន័យថា ក្រុមហ៊ុនបានប្រើចិត្តសាស្ត្រ គេរឹតតែទទួលលុយបានកាន់តែច្រើន ។

ខ- ត្រូវសិក្សាពីវិធីសាស្ត្រ ឬត្រូវមានវិធីសាស្ត្រ ៖ សង្កេត អង្កេត សន្ទនា ពិសោធ បញ្ចុះបញ្ចូល ការផ្តល់យោបល់ជាដើម ។

គ- ត្រូវសិក្សាពីបុគ្គលិកលក្ខណៈរបស់មនុស្សនៅជំពូកទីទើបយកវាមកអនុវត្ត ឬប្រើប្រាស់ឱ្យមាន ប្រសិទ្ធភាព ក្នុងការងារគ្រប់គ្រងនូវ**ជំពូកទីII** ឱ្យមានប្រសិទ្ធភាព និងទទួលបានគុណភាពខ្ពស់ ។

ឃ- ត្រូវស្គាល់រចនាសម្ព័ន្ធចិត្ត-សង្គម មាន២ប្រភេទ ៖

ឃ.១. *រចនាសម្ព័ន្ធផ្លូវការ* ៖ គឺជារចនាសម្ព័ន្ធមានការចាត់តាំងតាមឋានានុក្រមរបស់អង្គការចាត់តាំងមួយ គឺការតែងតាំងថ្នាក់ដឹកនាំតាមផ្លូវការ ។

ឃ.២. *រចនាសម្ព័ន្ធមិនផ្លូវការ* ៖ ជារចនាសម្ព័ន្ធមួយគ្មានការតែងតាំងទេ ប៉ុន្តែវាមិនអាចខ្វះបានរាល់ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ក្នុងអង្គភាពទំនាក់ទំនងនេះ គេហៅថា រចនាសម្ព័ន្ធមិនផ្លូវការ ។

**ចំណាំ៖**

កាលណារចនាសម្ព័ន្ធទាំងពីរនេះមិនឯកភាពគ្នា នាំឱ្យទិន្នផលនៃការគ្រប់គ្រងថយចុះ ។

**ឧទាហរណ៍** ៖ បុគ្គលិកនៅក្នុងអង្គភាពឈ្លោះគ្នា មិនពេញចិត្តគ្នា គឺគេមិនធ្វើការនាំឱ្យសមិទ្ធិផលថយចុះ ។

**ង. ត្រូវស្គាល់ ឬយល់ដឹងពីបាតុភូតចិត្ត-សង្គមសកល មានចរិតមហាជនជះឥទ្ធិពលលើផ្នត់គំនិតមនុស្ស**

ង.១- **ការជះឥទ្ធិពលរបស់ប្រពៃណីទំនៀមទម្លាប់** ៖ ប្រពៃណីយ៉ាងណាចិត្តយ៉ាងនោះ ព្រោះប្រពៃណីជាវប្បធម៌ ជាមជ្ឈដ្ឋាន ដែលជាប្រភពកកើតបុគ្គលិកលក្ខណៈរបស់មនុស្ស ឬជាប្រភពនៃចិត្តមនុស្ស (មើលជំពូកI កត្តាទាំង៤ដែលជះឥទ្ធិពលដល់បុគ្គលិកលក្ខណៈ)

**ឧទាហរណ៍** ៖ ខ្មែរមានទំនៀមទម្លាប់ប្រពៃណីផ្សេងពីអាមេរិក ដូច្នេះចិត្តគំនិត តម្រូវការ សញ្ចេតនា ឬបុគ្គលិកលក្ខណៈមិនដូចជនជាតិអាមេរិកនោះទេ ។

ង.២- **ការជះឥទ្ធិពលរបស់សាសនា** ៖ សាសនាជាប្រភពជំនឿ ដែលនាំឱ្យមនុស្សធ្វើតាមប្រតិបត្តិតាមក្នុងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ បើជនណាម្នាក់មិនធ្វើតាម មានន័យថា ជននោះមិន ជឿសាសនានោះទេ ។

ដូច្នេះ ការស្គាល់សាសនា ចរិតរបស់សាសនា មានន័យថា ស្គាល់ចិត្តមនុស្ស ស្គាល់តម្រូវការសញ្ចេតនារបស់មនុស្ស ឬស្គាល់ផ្នត់គំនិតគេច្បាស់ ងាយស្រួលក្នុងការងារគ្រប់គ្រង ។

**ឧទាហរណ៍** ៖ -គេជឿសាសនាព្រះពុទ្ធ ជឿបុណ្យ ជឿបាប ជឿធ្វើល្អបានល្អ ។ ដូច្នេះ គ្រាន់តែជីកស្រះធ្វើផ្លូវល្មមៗ ឱ្យតែព្រះសង្ឃចេញមុខធ្វើ ប្រជាជននឹងចូលរួមទាំងកម្លាំង និងថវិកាភ្លាមរហូតកិច្ចការបានសម្រេច ។

- រាល់រដូវភ្ជុំបិណ្ឌប្រជាជនខ្មែរតែងតែរៀបចំប្រដាប់ប្រដាប្រើប្រាស់ ឬចង្ហាន់ទៅវត្តដើម្បីប្រគេនចង្ហាន់ព្រះសង្ឃក្នុងគោលបំណងឧទ្ទិសមគ្គផលជូនមាតាបិតាឬបុព្វការីដែលបានចែកឋានទៅកាន់លោកខាងមុខគ្រប់ៗគ្នា (នេះជាផ្នត់គំនិតខ្មែរដែលកាន់ព្រះពុទ្ធសាសនា) ។

ង.៣- **ការប្រព្រឹត្តរបស់មតិសង្គម៖** មតិសង្គម សំដៅមតិភាគច្រើនក្នុងសង្គមមានឥទ្ធិពលទៅលើផ្លូវ

ចិត្តបុគ្គលណាស់ ។ កាលណាមតិភាគច្រើនគេសម្រេចធ្វើអ្វីមួយ នាំចិត្តបុគ្គល ឬបុគ្គលម្នាក់ឯងមិនហ៊ានជំទាស់ ឬធ្វើឡើយ ហើយបើនៅតែចចេសធ្វើគឺត្រូវសង្គម ឬមតិសង្គមគម្រាម ឬបញ្ឈប់ភ្លាម ។

### ង.៤- ការឆ្លងរាលដាលចិត្ត

ជាទម្រង់សកលបំផុត ដែលស្តែងចេញតាមរយៈសព្វេតនារបស់បុគ្គលម្នាក់ៗ ក្នុងសង្គម ឬក្នុងការរស់នៅប្រចាំថ្ងៃនៅលើកត្តាពីរ ៖

#### ១- កត្តាសម្ភារៈ

ជាសព្វេតនា ឬការគិតរបស់មនុស្ស ប្រែប្រួល ឬរាលដាលឆ្លង ដោយសារតែសម្ភារៈ (លុយ មាស ប្រាក់ ...) ។

ឧទាហរណ៍ ៖ ពេលបានទទួលប្រាក់ខែច្រើន នាំឱ្យគ្រូមានទឹកចិត្តបង្រៀន ។

#### ២- កត្តាស្មារតី ឬសោភ័ណ

ជាសព្វេតនា ឬតម្រូវការទៅលើផ្នែកស្មារតី ដែលនាំឱ្យសព្វេតនារបស់បុគ្គលម្នាក់ៗមានការប្រែប្រួល ឬរាលដាលឆ្លង ដូចជា ៖

- កិត្តិយស ការសរសើរ ការលើកទឹកចិត្ត ការគោរពស្រឡាញ់ ការជូនមេដាយ ធ្វើឱ្យមានជំនឿមានយុត្តិធម៌ ជាដើម ។

**ឧទាហរណ៍** ៖ ការជូនមេដាយកិត្តិយសចំពោះអ្នកមានស្នាដៃ ធ្វើឱ្យបុគ្គលនោះ មានកម្លាំងបំពេញកិច្ចការកាន់តែបានល្អប្រសើរ ។

**ឧទាហរណ៍** ៖ ក្នុងផ្ទះត្រូវរង្វាន់ នាំឱ្យអ្នកផ្ទះសប្បាយចិត្ត ។

**២.៣- ជំនាញប្រើបញ្ញា ៖** ជាសមត្ថភាព ឬជាសម្បទាដែលមានកម្រិតខ្ពស់របស់អ្នកគ្រប់គ្រង ឬមេដឹកនាំ ដើម្បីមានជំនាញនេះ លុះណាតែមេដឹកនាំបានរៀនសូត្រច្រើន ជាពិសេសច្បាប់ ដូចជាច្បាប់សេដ្ឋកិច្ច ពាណិជ្ជកម្ម ច្បាប់ភូមិបាល ច្បាប់ព្រហ្មទណ្ឌ ... ជាដើម ហើយឆ្លងកាត់ការងារច្រើន បទពិសោធច្រើន ទើបមានសមត្ថភាព ដើម្បីដោះស្រាយបញ្ហាបាន ព្រោះថាការងារគ្រប់គ្រងមនុស្សជាប្រភពនៃបញ្ហា បើគ្មានបញ្ញា បើមិនចេះច្បាប់ បើគ្មានជំនាញ មិនអាចដោះស្រាយបញ្ហាបាននោះទេ ។

ការចេះច្បាប់ ចេះនយោបាយ ស្គាល់ពីសង្គមច្បាស់ ស្គាល់ពីតម្រូវការមនុស្ស ស្គាល់ពីចិត្តមនុស្ស ស្គាល់ពីចរិតអន់ថយ ឬធ្វើឱ្យសង្គមរីកចម្រើន ទើបអាចធានាដល់ជំនាញប្រើបញ្ញា ។ នេះមានន័យ មានជំនាញ ហើយត្រូវស្គាល់ចិត្តមនុស្ស ឬចេះចិត្តសាស្ត្រ ទើបអាចដោះស្រាយបញ្ហាបាននូវក្នុងការងារគ្រប់គ្រងរបស់ខ្លួន ។ មនុស្សមានជំនាញខាងប្រើបញ្ញាមានន័យថា គេមានសម្បទាខ្ពស់ផ្នែកបញ្ញាអាចរៀបចំផែនការ ឬសម្រេចចិត្តធ្វើអ្វីៗក្នុងការងារគ្រប់គ្រងរបស់ខ្លួននឹងប្រព្រឹត្តទៅបានល្អ និងមានជោគជ័យជាប្រាកដ ។

## ៣- ចរិតលក្ខណៈ និងភាពជាអ្នកដឹកនាំ

### ៣.១- លក្ខណៈទូទៅ

- សង្គមត្រូវការមេដឹកនាំជាចាំបាច់ មិនថាសម័យណានោះទេ គឺពុំអាចខ្វះបាន ។ ចំណែកគ្រួសារ ស្ថាប័នក្រុមហ៊ុន ក្រសួង រដ្ឋ សុទ្ធតែជាអង្គការចាត់តាំងចាំបាច់បំផុតមានអ្នកដឹកនាំ ។ គ្មានមេដឹកនាំដូច ជាចែវទូកកណ្តាលទន្លេរកត្រើយមិនឃើញវិលវល់ ព្រោះមិនដឹងជាត្រូវទៅណា ។

### ៣.២- ភាពជាអ្នកដឹកនាំ

- ភាពជាអ្នកដឹកនាំ : អ្នកដឹកនាំត្រូវមានសមត្ថភាពលើជំនាញ ៖

+ ជំនាញប្រើបច្ចេកទេស

+ ជំនាញប្រើមនុស្ស

+ ជំនាញប្រើបញ្ញា

- អ្នកដឹកនាំដែលមានជំនាញច្បាស់លាស់ អាចដឹកនាំក្រុមមនុស្ស អង្គភាព ឬស្ថាប័នឱ្យមានការរីកចម្រើនបាន ដោយសារតែសមត្ថភាពដឹកនាំ ចេះធ្វើផែនការ ចេះចាត់ចែង ចេះជំរុញ ចេះលើកទឹកចិត្ត ជូនរង្វាន់ ដាក់ពិន័យចំពោះជនអសកម្មក្នុងស្ថាប័នរបស់ខ្លួន ។ តាមរយៈការប្រើប្រាស់ចិត្តសាស្ត្រអនុវត្តនៅក្នុងអង្គការចាត់តាំងរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ពេលនោះទិន្នផលក៏កើនឡើង ។

### ៣.៣- អ្នកដឹកនាំចែកចេញជាពីរផ្នែក

- អ្នកដឹកនាំធម្មតា ឬមិនផ្លូវការ ជាអ្នកដឹកនាំក្នុងក្រុមតូចៗ ឬក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

**ឧទាហរណ៍** ៖ + ឪពុក ម្ដាយ

+ អាណាព្យាបាល

+ ព្រឹទ្ធាចារ្យ

- អ្នកដឹកនាំផ្លូវការ ជាអ្នកដឹកនាំដែលមានការជ្រើសតាំងពីអង្គភាព ឬពីអង្គការចាត់តាំងទៅតាមផ្លូវច្បាប់ ។

**ឧទាហរណ៍** ៖ + នាយកសាលា

+ មេឃុំ

+ រដ្ឋមន្ត្រី

+ សមាជិកសភា

+ ប្រធានអង្គការ

+ ប្រធានក្រុមហ៊ុន

### ៣.៤- អ្នកដឹកនាំផ្លូវការចែកចេញជាបី ៖

- អ្នកដឹកនាំផ្តាច់ការ : តាំងខ្លួនជាធំ មិនស្ដាប់យោបល់ថ្នាក់ក្រោម
- អ្នកដឹកនាំធូរលុង : ជាអ្នកដឹកនាំមិនមានការយល់ដឹង
- អ្នកដឹកនាំប្រជាធិបតេយ្យ : គោរពថ្នាក់ក្រោម

### ៣.៥- លក្ខណៈសម្បត្តិនៃអ្នកដឹកនាំ

### ៣.៥១- អ្នកដឹកនាំល្អ

- មានសេចក្ដីក្លាហាន
- មានយុត្តិធម៌-មានតម្លាភាព
- មានការព្យាយាម ម៉ឺងម៉ាត់
- មានចំណេះ មានជំនាញ
- ស្មោះត្រង់ មានអធ្យាស្រ័យល្អនឹងកូនចៅ
- មានសីលធម៌ល្អ
- ជាមនុស្សនឹងនរ
- ចេះចាត់ចែង ចេះបែងចែកត្រឹមត្រូវ
- គ្មានចរិតបៀតបៀន មិនក្រេវក្រោធ
- សុភាពរាបសា រួសរាយរាក់ទាក់
- មានបទពិសោធន៍ មានចំណេះដឹងខ្ពស់
- មិនត្រចៀកស មានភាពឯករាជ្យលើការវិនិច្ឆ័យការងារក៏ដូចជាដឹកនាំកូនចៅ

- មានសុខភាពមាំមួន
- មានការទទួលខុសត្រូវលើការងារខ្លួន

### ៣.៥២- មេដឹកនាំមិនល្អ

- ច្រណែន
- បក្សពួកនិយម
- ពុករលួយ
- គ្មានភាពយុត្តិធម៌
- មិនស្មោះត្រង់
- ខ្វះសមត្ថភាព ពូកែអួត
- ប្រើតែអំណាច
- គ្មានការទទួលខុសត្រូវ ពូកែនិយាយ
- មិននឹងនរ
- ខ្ជិលច្រអូស
- ក្រអឺតក្រទម
- ទន់ជ្រាយ
- មានសីលធម៌រស់នៅមិនល្អ

### ៣.៥៣- កិត្យានុភាពរបស់អ្នកដឹកនាំ

កិត្យានុភាពរបស់អ្នកដឹកនាំចែកចេញជាពីរ ៖

#### ៣.៥៣.១- កិត្យានុភាពរបស់អ្នកដឹកនាំត្រឹមត្រូវ មានសមត្ថភាព

អ្នកដឹកនាំត្រឹមត្រូវមានសមត្ថភាពធ្វើឱ្យអង្គភាពខ្លួន ស្ថាប័នខ្លួន រដ្ឋរបស់ខ្លួនមានការរីកចម្រើនអ្នកនៅក្រោមឱវាទមានសេចក្តីសុខ មានការរីកចម្រើន បានទទួលផលប្រយោជន៍សក្តិសមទៅនឹងការងារ ការរស់នៅប្រចាំថ្ងៃ ។ ធ្វើឱ្យអ្នកនៅក្រោមបង្គាប់មានជំនឿ គោរព និងស្រឡាញ់កោតខ្លាចស្ងាដៃ ការដឹកនាំរបស់គាត់ ។

#### ៣.៥៣.២- អ្នកដឹកនាំមិនត្រឹមត្រូវ ខ្វះសមត្ថភាព

អ្នកដឹកនាំមិនត្រឹមត្រូវពូកែអួត ភូតភរ បំភ្លៃការពិត បក្សពួក ពុករលួយ ប្រើអំណាចឃោរឃៅគិតតែប្រយោជន៍បក្សពួកខ្លួន គ្មានការទទួលខុសត្រូវចំពោះការងារគ្រប់គ្រងរបស់ខ្លួន ។ អ្នកក្រោមបង្គាប់ស្អប់តែមិនហ៊ាននិយាយបន់ឱ្យតែធ្លាក់ ឬចុះចេញពីតំណែង ។

## IV- សន្និដ្ឋាន

– ការងារគ្រប់គ្រង មេដឹកនាំមិនចេះចិត្តសាស្ត្រ និងមេដឹកនាំចេះចិត្តសាស្ត្រ ហើយយកចិត្តសាស្ត្រទៅប្រើក្នុងការងារគ្រប់គ្រងរបស់ខ្លួនឃើញថា មានផលចម្រើន និងជោគជ័យខុសគ្នាឆ្ងាយណាស់ ។

– ក្នុងអង្គការចាត់តាំងនីមួយៗ ដោយហេតុថាមានមេដឹកនាំ ឬអ្នកគ្រប់គ្រងខុសគ្នា ដូចនេះរបៀបដឹកនាំ ចាត់ចែង ត្រួតពិនិត្យ ការរៀបចំផែនការ សុទ្ធតែខុសៗគ្នា ហើយលទ្ធផលទៀតសោតក៏ខុសគ្នាដែរ ។ ដូចនេះអ្នកគ្រប់គ្រងទាមទារឱ្យមានសមត្ថភាព ឬសម្បទាទៅលើការងារគ្រប់គ្រង បានន័យថា គេមានសមត្ថភាព ឬ ជំនាញសំខាន់ទាំងបី ដែលយើងបានរៀបរាប់មកខាងលើរួចស្រេចហើយ មានដូចជា ៖

+ ជំនាញបច្ចេកទេស
+ ជំនាញប្រើមនុស្ស
+ ជំនាញប្រើគំនិតបញ្ញា

ម្យ៉ាងវិញទៀត មេដឹកនាំ ឬអ្នកគ្រប់គ្រងត្រូវប្រកាន់យក ឬគប្បីមានបុគ្គលិកលក្ខណៈមួយចំនួនក្នុងភាពជា អ្នកដឹកនាំដូចជា ៖

- ម៉ឺងម៉ាត់
- ក្លាហាន
- មានយុត្តិធម៌ មានតម្លាភាព
- ស្មោះត្រង់
- មានចំណេះ មានបទពិសោធន៍
- មានការទទួលខុសត្រូវខ្ពស់
- ទន់ភ្លន់ សុភាពរាបសា
- មានអធ្យាស្រ័យ មេត្តា
- មិនច្រឡោត មិនក្រោធផ្ដេសផ្ដាស់
- ព្យាយាម អំណត់ ខន្តី
- ស្ដាប់ហេតុផល ស្ដាប់មតិថ្នាក់ក្រោម
- គ្មានចរិតផ្ដាច់ការ ឬបក្សពួកនិយម
- ឧស្សាហ៍ ព្យាយាម
- មានជំនាញ ឬសម្បទាជាអ្នកគ្រប់គ្រង
- ប៉ិនប្រសប់ក្នុងការប្រើចិត្តសាស្ត្រក្នុងការងារគ្រប់គ្រងរបស់ខ្លួន ។

សរុបមក មេដឹកនាំ ឬអ្នកគ្រប់គ្រងត្រូវមានមានលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើ គឺពិតជាជោគជ័យនៅក្នុងការងារគ្រប់គ្រង ។

## សំណួរ

1. ហេតុអ្វីបានជាអ្នកដឹកនាំ ត្រូវយល់ដឹងពីបុគ្គលិកលក្ខណៈរបស់មនុស្ស ?
2. តើការគ្រប់គ្រងជាអ្វី ?
3. ហេតុដូចម្តេចបានជាអ្នកគ្រប់គ្រងចាំបាច់ត្រូវមានការយល់ដឹងពីបាតុភូតចិត្ត សង្គមសកលមានចរិតមហាជន? ចូរបកស្រាយ ។
4. តើអ្នកគ្រប់គ្រងត្រូវមានជំនាញអ្វីខ្លះ ?
5. ដូចម្តេចដែលហៅថា ចិត្ត ? ចូរឱ្យឧទាហរណ៍ ។
6. តើអ្នកដឹកនាំចាំបាច់ត្រូវមានលក្ខណៈសម្បត្តិដូចម្តេច ?
7. ដូចម្តេចដែលហៅថាអង្គការចាត់តាំង ? តើអង្គការចាត់តាំងមានរចនាសម្ព័ន្ធប៉ុន្មាន ? អ្វីខ្លះ ?
8. តើអ្នកគ្រប់គ្រងចេះចិត្តសាស្ត្រ និងអ្នកគ្រប់គ្រងមិនចេះចិត្តសាស្ត្រ មានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច?

# មេរៀនទី៣៦ ការកត់សម្គាល់បញ្ហាសុខភាពផ្លូវចិត្តជំទង់

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

- ពិពណ៌នាពីមូលដ្ឋានអំពីសុខភាពផ្លូវចិត្តរបស់សិស្សក្នុងវ័យពីកុមារភាព ដល់វ័យជំទង់
- ប្រៀបធៀបពីសញ្ញាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តរបស់សិស្ស
- មានស្មារតីចូលរួមដោះស្រាយសញ្ញាប្រឈមនឹងគ្រោះថ្នាក់ និងវិធានការមួយចំនួនក្នុងការបង្ការការធ្វើអត្តឃាតនៅក្នុងសាលារៀន

## II- សេចក្តីផ្តើម

កិច្ចការបង្រៀន និងអប់រំជំទង់ ជាការងារដែលទាមទារនូវ ការយកចិត្តទុកដាក់ និងភាពអត់ធ្មត់ខ្ពស់។ សុខភាពផ្លូវចិត្តរបស់សិស្សល្អ នាំឱ្យសិស្សមានអារម្មណ៍ល្អក្នុងការចូលរួមសកម្មភាពរៀន និងប្រាស្រ័យទាក់ទងជាមួយមជ្ឈដ្ឋានខាងក្រៅ។ ការសិក្សាស្រាវជ្រាវជាច្រើនដែលផ្តោតលើកត្តាលើកកម្ពស់ដល់លទ្ធផលសិក្សារបស់សិស្សបានថា កត្តាសុខភាពផ្លូវចិត្តរបស់សិស្សមានការពាក់ព័ន្ធទៅនឹងលទ្ធផលនៃការសិក្សារបស់ពួកគេ។

ក្នុងតួនាទីបង្រៀន គ្រូអាចចូលរួមចំណែកក្នុងការកំណត់រកសញ្ញាសម្គាល់ ទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្ស សំដៅធ្វើឱ្យប្រសើរឡើងដល់ការចូលរួមសកម្មភាពរៀន និងលទ្ធផលសិក្សារបស់ជំទង់។ ការចូលរួមចំណែកនេះ អាចធ្វើទៅបានតាមរយៈការស្វែងយល់បន្ថែមអំពីកត្តាពាក់ព័ន្ធនឹងបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្ស ដែលទាក់ទងនឹងការសិក្សា បញ្ហាអាកប្បកិរិយារបស់សិស្សនៅក្នុងថ្នាក់ ការកំណត់រកសញ្ញាណដែលប្រឈមនឹងគ្រោះថ្នាក់ពាក់ព័ន្ធនឹងការធ្វើអត្តឃាត ការផ្តល់ការជួយគាំទ្រដំបូងតាមដែលអាចធ្វើបាន និងធ្វើការបញ្ជូនទៅអ្នកដែលមានជំនាញខាងសុខភាពផ្លូវចិត្ត ដើម្បីផ្តល់ការជួយគាំទ្រតាមបែបចិត្តសាស្ត្រដ៏សមស្របទៅតាមប្រភេទ និងកម្រិតនៃ បញ្ហារបស់ពួកគេ។

ក្នុងការអភិវឌ្ឍជាក់លាក់ដែលឆ្លងពីដំណាក់កាលកុមារភាព ដល់ជំទង់ ជំរុញឱ្យមានការប្រែប្រួលជាច្រើនកើតឡើង ដោយរាប់ទាំងផ្នែកបុគ្គលិកលក្ខណៈ សរីរសាស្ត្រ និងចិត្តសាស្ត្រ។ ការវិវត្តទាំងនេះ ក៏មានការរួមចំណែក និង ជះឥទ្ធិពលក្នុងកម្រិតណាមួយ ដល់បញ្ហាផ្លូវចិត្តរបស់ជំទង់ផងដែរ។ អាការៈខុសពីធម្មតាខ្លះទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្តរបស់ជំទង់អាចងាយឃើញ ប៉ុន្តែពេលខ្លះអាចត្រូវការសង្កេតក្នុងរយៈពេលមួយ រួមផ្សំនឹងការសាកសួរព័ត៌មានបន្ថែមពីពួកគាត់ផ្ទាល់ ឬអាចពីមិត្តភក្តិ ឬអ្នកដែលនៅជាមួយគាត់ច្រើនជាងគេ។

បើទោះបីជាមេរៀននេះ ចូលរួមចំណែកដល់គ្រូបង្រៀន ក្នុងការកំណត់ដឹងអំពីសញ្ញាសម្គាល់មួយចំនួនទាក់ទងនឹងបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្ស ក្នុងកម្រិតសិក្សាជាក់លាក់នេះក៏ដោយ ក៏អ្វីដែលយើងទាំងអស់គ្នាចាំបាច់ត្រូវមានការប្រុងប្រយ័ត្ននោះគឺ ការដាក់ឈ្មោះ ឬដាក់ងារ ឱ្យសិស្សដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តនោះ ដែលជាមូលហេតុនាំឱ្យមានការវាយតម្លៃជាអវិជ្ជមាន ឬរហូតដល់ការរើសអើង ។ ឈរលើមូលដ្ឋានលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គ្រូក៏ចាំបាច់ត្រូវគោរពនូវគោលការណ៍រក្សាការសម្ងាត់ និងឯកជនភាពរបស់សិស្ស និងជជែកជាមួយអាណាព្យាបាលរបស់សិស្ស ដើម្បីរកជំនួយបន្ថែមដើម្បីគាំទ្របញ្ហាសុខភាពផ្លូវចិត្តរបស់សិស្ស។ ការអាចកំណត់ដឹងពីបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្ស ក្នុងដំណាក់កាលដំបូងៗ អាចមានការងាយស្រួលក្នុងការផ្តល់ការជួយគាំទ្របឋម និងការផ្តល់អន្តរាគមន៍តាមបែបចិត្តសាស្ត្រប្រកបដោយប្រសិទ្ធភាព ។ ខ្លឹមសារក្នុងផ្នែកបន្ទាប់នៃមេរៀននេះ នឹងលើកយកសញ្ញាសម្គាល់មួយចំនួន ជាពិសេសផ្តោតជាក់លាក់ទៅលើកត្តាប្រឈមទៅនឹងការធ្វើអត្តឃាតរបស់ជំទង់ ដើម្បីជាជំនួយដល់គ្រូបង្រៀន ធ្វើជាមូលដ្ឋានក្នុងការស្វែងយល់ពីបញ្ហាពាក់ព័ន្ធនឹងផ្លូវចិត្ត ជាមួយនឹងការសិក្សារបស់សិស្ស និងផ្តល់ការជួយគាំទ្រតាមដែលអាចធ្វើទៅបានដោយមានការចូលរួមចំណែក និងសហការពីអាណាព្យាបាលរបស់

ជំទង់ ។

## III- ខ្លឹមសារ

បញ្ហាសុខភាពផ្លូវចិត្តរបស់កុមារ ក្នុងវ័យសិក្សានេះ ស្ដែងចេញជារូបភាពផ្សេងៗគ្នា ទៅតាមមូលហេតុ ប្រភេទ និងកម្រិតនៃបញ្ហា ។ បញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តខ្លះរបស់កុមារកើតឡើងដោយសារ ការវិវត្តមិនប្រក្រតីនៃកោសិកាប្រសាទ ក្នុងដំណាក់កាលដំបូងនៃជីវិត ដែលប៉ះពាល់ដល់កម្រិតបញ្ញារបស់កុមារ និងសមត្ថភាពក្នុងការសិក្សា ។ បញ្ហាពាក់ព័ន្ធមួយចំនួនទៀតបង្កឡើង ដោយសាររបៀបនៃការចិញ្ចឹមបីបាច់ និងអប់រំរបស់អាណាព្យាបាល ដែលជាមូលហេតុមួយនាំឱ្យកុមាររៀនពីរបៀបដាក់លាក់ណាមួយ ក្នុងការបញ្ចេញអាកប្បកិរិយា ឆ្លើយតបទៅនឹងមជ្ឈដ្ឋានខាងក្រៅ (ជាមួយមិត្តរួមថ្នាក់ គ្រូបង្រៀន ឬអ្នកដទៃទៀត)។ ការសំដែងអាកប្បកិរិយាក្នុងស្ថានភាពជាក់លាក់ណាមួយ ជាសភាវៈគតិដែលកុមារចាំបាច់ត្រូវធ្វើ ដើម្បីបន្សុំ និងសម្របខ្លួនឱ្យរស់ក្នុងស្ថានភាពនោះ។

បញ្ហាសុខភាពផ្លូវចិត្តជាក់លាក់ ដែលច្រើនកើតក្នុងវ័យកុមារមានដូចជា ការយឺតយ៉ាវបញ្ញា វិបល្លាសក្នុងការសិក្សា ជំងឺអូទីហ្សឹម វិបល្លាសទាក់ទងនឹងអាកប្បកិរិយានិងបម្រុងប្រយ័ត្ន បញ្ហាទាក់ទងនឹងការថប់បារម្ភ ការធ្លាក់ទឹកចិត្ត និងក៏មានបញ្ហាវិបល្លាសមួយចំនួនផ្សេងទៀតផងដែរ ។ សញ្ញាសម្គាល់ និងរោគសញ្ញាដែលមានរៀបរាប់ដូចខាងក្រោមនេះ មានមួយចំនួនប៉ុណ្ណោះ និង មិនមែនជាមូលដ្ឋានសម្រាប់គ្រូបង្រៀន ដើម្បីកំណត់រោគវិនិច្ឆ័យលើបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្សនោះទេ ។ ការធ្វើរោគវិនិច្ឆ័យដើម្បីកំណត់ថាកុមារ ឬបុគ្គលណាម្នាក់មានបញ្ហា ឬជំងឺផ្លូវចិត្តណាមួយ ជាទូទៅត្រូវបានធ្វើឡើងដោយ អ្នកចិត្តសាស្ត្រឯកទេស ឬ វេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា ។

### ១- ការយឺតយ៉ាវបញ្ញា

#### ក- និយមន័យ

ការយឺតយ៉ាវបញ្ញា សំដៅដល់កម្រិតបញ្ញារបស់កុមារ ដែលមានកម្រិតទាបជាងកម្រិតធម្មតារបស់កុមារទូទៅ (ពិន្ទុបញ្ញារបស់កុមារទាបជាងពិន្ទុ ៧០/១០០) ។បញ្ហាក្នុងការលូតលាស់បញ្ញាយឺតយ៉ាវនេះ ចាប់ផ្ដើមកើតឡើងចំពោះកុមារនៅមុនអាយុ១៨ឆ្នាំ ហើយប៉ះពាល់ដល់មុខងារប្រព័ន្ធប្រសាទកណ្ដាលរបស់កុមារ ។ ការយឺតយ៉ាវបញ្ញាត្រូវបានគេបែងចេញជា៤កម្រិតគឺ កម្រិតស្រាល កម្រិតមធ្យម កម្រិតធ្ងន់ និងកម្រិតធ្ងន់ធ្ងរខ្លាំង។ កុមារដែលមានការយឺតយ៉ាវបញ្ញាក្នុងកម្រិតធ្ងន់ ឬធ្ងន់ធ្ងរខ្លាំង អាចមានបញ្ហាពិបាកក្នុងការទំនាក់ទំនងដោយវាចាជាមួយអ្នកដទៃ ហើយដែលភាគច្រើនអាចត្រូវបានគេកំណត់ដឹងចាប់តាំងពីពេលកើត ។ ចំណែកឯការយឺតយ៉ាវបញ្ញាក្នុងកម្រិតស្រាល អាចលេចចេញក្នុងវ័យកុមារភាព។

#### ខ- មូលហេតុនៃការយឺតយ៉ាវបញ្ញា

មិនមានមូលហេតុជាក់លាក់ណាមួយ ត្រូវបានរកឃើញថាជាប្រភពដែលបណ្ដាលឱ្យកើតមានបញ្ហាដែលពាក់ព័ន្ធទៅនឹងបញ្ញារបស់កុមារ មួយនេះណាស់ ។ កត្តាជីវសាស្ត្រ (តំណរពូជ ឬការលូតលាស់មិនប្រក្រតីនៃអំប្រ៊ីយ៉ុង) និងកត្តាចិត្តសង្គម (ក្នុងពេលមានផ្ទៃពោះ ឬពេលសម្រាល ឬការប្រើប្រាស់ថ្នាំក្នុងពេលទារក ឬកុមារភាព ឬកង្វះអាហារូបត្ថម្ភជាដើម) ត្រូវបានគេដាក់បន្ទុក ថាអាចជាមូលហេតុចម្បងៗដែលនាំឱ្យកុមារ មានការយឺតយ៉ាវបញ្ញា។

#### គ- លក្ខណៈសម្គាល់

ការសម្គាល់កុមារ ដែលមានការយឺតយ៉ាវបញ្ញាអាចផ្ដោតទៅលើ ផ្នែកដែលពាក់ព័ន្ធមួយចំនួន ដូចជា កម្រិតបញ្ញារបស់កុមារទាបជាងកុមារធម្មតា (ទាបជាង៧០/១០០ពិន្ទុបញ្ញា) កង្វះខាតនូវសមត្ថភាព ឬជំនាញមួយចំនួន បើប្រៀបធៀបជាមួយនឹងកុមារផ្សេងទៀតដែលមានអាយុស្របាលៗគ្នាដូចជា ការប្រាស្រ័យទាក់ទង ការធ្វើសកម្មភាពក្នុងទម្លាប់ប្រចាំថ្ងៃ ការថែទាំអនាម័យខ្លួនប្រាណ ការយល់ដឹងពីសុវត្ថិភាព និងការចូលរួមក្នុងសកម្មភាពកម្សាន្តដែលជាចំណូលចិត្ត។ ការសម្គាល់ក្នុងលក្ខណៈជាក់លាក់មួយចំនួនទៀតមានដូចជា៖

- ការរីកលូតលាស់យឺតយ៉ាវទៅតាមដំណាក់កាល

- ការសិក្សាខ្សោយ
- លំនឹក ឬការចងចាំខ្សោយ
- មានការពិបាកក្នុងការផ្ទង់ស្មារតី
- ខ្វះខាតចលករសិក្សា
- មានការពិបាកក្នុងការធ្វើទូទៅនីយកម្ម
- មានការពិបាកទំនាក់ទំនងជាមួយកុមារដទៃ
- អាចមានការបង្ហាញនូវអាកប្បកិរិយាផ្លូវភេទមិនសមរម្យ

## ២- វិបល្លាសការសិក្សា

### ក- និយមន័យ

វិបល្លាសក្នុងការសិក្សារបស់កុមារ សំដៅដល់ភាពខុសគ្នា ដែលគួរឱ្យកត់សម្គាល់រវាង លទ្ធផលនៃការសិក្សារៀនសូត្ររបស់កុមារ ធៀបទៅនឹងការរំពឹងទុកមួយ ដោយផ្អែកទៅលើកម្រិតអាយុ កម្រិតបញ្ញា និងកម្រិតនៃការសិក្សារបស់គាត់។ វិបល្លាសការសិក្សាត្រូវបានរកឃើញថាជាមូលហេតុចម្បងមួយ ដែលនាំឱ្យមានការធ្លាក់ចុះនៃលទ្ធផលសិក្សារបស់កុមារ ចំណែកឯកុមារជាច្រើន អាចទៅដល់ការបោះបង់ការសិក្សាក៏មាន ។ វិបល្លាសនេះមានបីប្រភេទផ្សេងគ្នាគឺ វិបល្លាសការអាន វិបល្លាសការគណនាលេខ និងវិបល្លាសការសរសេរ។

### ខ- មូលហេតុនៃវិបល្លាសការសិក្សា

មូលហេតុចម្បងៗពីរផ្សេងគ្នា ត្រូវបានគេរកឃើញថា ជាប្រភពដែលនាំឱ្យមានវិបល្លាសការសិក្សា ។ កត្តាប្រព័ន្ធប្រសាទ ជាកត្តាមួយដែលបង្កឡើងដោយតំណពូជ ដែលនាំឱ្យមានការលូតលាស់ប្រព័ន្ធកោសិការខួរក្បាលមិន ប្រក្រតី ។ ការលូតលាស់មិនប្រក្រតីនៃកោសិកាខួរក្បាលនេះ កើតឡើងយ៉ាងជាក់លាក់ទៅលើផ្នែកដែលទទួលបន្ទុកភាសា និងគំហើញ ជាពិសេសទៅលើកុមារដែលមានវិបល្លាសការអាន ។ កត្តាមជ្ឈដ្ឋានខាងក្រៅ ជាកត្តាទីពីរដែលនាំឱ្យមានវិបល្លាសការសិក្សាដែរ ដែលសំដៅដល់គុណភាពនៃការអប់រំ (ខ្សោយ) ដល់កុមារ ឬអាចជាការរស់នៅក្នុងស្ថានភាពជីវភាពគ្រួសារលំបាកខ្លាំង ឬការរស់នៅក្នុងស្ថានភាពគ្រួសារដែលមានអំពើហិង្សា ដែលប៉ះទង្គិចដល់ការវិវត្តបញ្ញា ផ្លូវចិត្ត និងផ្លូវកាយរបស់កុមារ។

### គ- លក្ខណៈសម្គាល់

- **វិបល្លាសការអាន** ៖ អានយឺត មិនអាចចងចាំបាននូវអ្វីដែលទើបនឹងអានរួច អានឃ្លាមិនបានពេញលេញ អានច្រឡំពាក្យ អានចោះៗ ។
- **វិបល្លាសការគណនាលេខ** ៖ ពិបាកក្នុងការចងចាំពាក្យ ឬអានពាក្យ ក្នុងគណិតវិទ្យា ឬនិមិត្តសញ្ញា ពិបាកចងចាំលំដាប់លំដោយ ឬជំហានក្នុងគណិតវិទ្យា ឬធ្វើប្រមាណវិធី ។
- **វិបល្លាសការសរសេរ** ៖ នឹកឃើញពីឃ្លាត្រូវសរសេរប៉ុន្តែសរសេរមិនចេញ រឹងដៃមិនអាចចាប់ផ្តើមសរសេរបាន ។

## ៣- វិបល្លាសបម្រុងប្រយ័ត្ន និងរពឹសជ្រុល

### ក- និយមន័យ

វិបល្លាសបម្រុងប្រយ័ត្ន និងរពឹសជ្រុលនេះពាក់ព័ន្ធនឹងបញ្ហាអាកប្បកិរិយារបស់កុមារ ដែលសំដែងចេញតាមរយៈការចុះថយនូវបម្រុងប្រយ័ត្ន ទៅលើរំញោចផ្សេងៗដែលនៅជុំវិញខ្លួន ។ ការចុះថយនូវបម្រុងប្រយ័ត្ននេះ អាចមានមកជាមួយនូវអាកប្បកិរិយារពឹសជ្រុលផងដែរ ដែលលក្ខណៈទាំងពីរនេះអាចងាយសង្កេតឃើញដោយធៀបទៅនឹង កុមារផ្សេងទៀតដែលមានអាយុស្របាលៗគ្នា ។ កុមារមានបញ្ហានេះ ងាយរំខានចិត្ត និងរំខានដល់បម្រុងប្រយ័ត្ន ដោយសាររំញោចខាងក្រៅ ដែលនាំឱ្យពួកគេពិបាកក្នុងការផ្តោតអារម្មណ៍ ទៅលើកិច្ចការងារណាមួយឱ្យបានជាប់លាប់ និងចប់ចុងចប់ដើម។ វិបល្លាសនេះអាចកើតឡើងទៅលើកុមារា ច្រើនជាង៣ដងនៃកុមារី។

### ខ- មូលហេតុនៃវិបល្លាសបម្រុងប្រយ័ត្ន និងរពឹសជ្រុល

មានកត្តាពីរយ៉ាង ដែលអ្នកស្រាវជ្រាវខាងផ្នែកចិត្តសាស្ត្រកុមារបានរកឃើញថាពាក់ព័ន្ធនឹងវិបល្លាសបម្រុងប្រយ័ត្ន និងរពឹសជ្រុល។ កត្តាទីមួយគឺ ទាក់ទងនឹងជីវសាស្ត្រ ដែលប្រសិនបើក្នុងគ្រួសារណាដែលមានសមាជិកណាម្នាក់ ធ្លាប់មានបញ្ហានេះ ក្នុងជំនាន់របស់ឪពុកម្ដាយ ឬជីដូនជីតា នោះវិបល្លាសបម្រុងប្រយ័ត្នអាចមានចំពោះជំនាន់កូន ឬជំនាន់ចៅ ។ កត្តាធំមួយទៀតគឺទាក់ទងនឹងកត្តាចិត្តសាស្ត្រ ។ កត្តាចិត្តសាស្ត្រនេះពាក់ព័ន្ធជាមួយនឹង របៀបក្នុងការចិញ្ចឹមបីបាច់របស់ឪពុកម្ដាយ ឬអាណាព្យាបាល។ ការចូលរួមចំណែកក្នុងការជួយគាំទ្រ និងបង្ហាញនូវភាពអត់ធ្មត់ចំពោះបញ្ហាអាកប្បកិរិយាក្នុងវិបល្លាសនេះ អាចជួយធ្វើឱ្យប្រសើរឡើងដល់ស្ថានភាពផ្លូវចិត្តរបស់កុមារ ជាពិសេសទៅលើការឱ្យតម្លៃខ្លួនរបស់កុមារ ។ មូលហេតុសំខាន់មួយ ក្នុងការធ្លាក់ចុះលទ្ធផលសិក្សារបស់កុមារ គឺទៅលើបញ្ហាបម្រុងប្រយ័ត្ននេះ។

### គ- លក្ខណៈសម្គាល់

- នៅមិនស្ងៀម និយាយច្រើន រំខានអ្នកដទៃ
- រត់ចុះឡើង ឬធ្វើសកម្មភាពដែលអាចបង្កគ្រោះថ្នាក់ដល់ខ្លួន ឬអ្នកដទៃ
- ពិបាកក្នុងការផ្ចង់អារម្មណ៍ ឬប្រមូលអារម្មណ៍លើកិច្ចការដែលគ្រូដាក់ឱ្យ
- ធ្វើអ្វីតាមតែសន្ទុះចិត្ត និងឆាប់ផ្លាស់ប្ដូរកម្មវត្ថុ
- ពិបាករៀបចំរបស់របរតាមលំដាប់លំដោយ ឬមិនមានសណ្ដាប់ធ្នាប់

## ៤- ការថប់បារម្ភ

### ក- និយមន័យ

ទម្រង់នៃការថប់បារម្ភក្នុងវ័យជំទង់មានច្រើនប្រភេទ ។ បញ្ហាថប់បារម្ភខ្លះអាចបន្តវត្តមានរហូតដល់វ័យបន្ទាប់ៗទៀត។ ប្រភេទដែលមានការចាប់អារម្មណ៍ច្រើន ក្នុងបញ្ហាថប់បារម្ភរបស់កុមារនេះមានដូចជា ការថប់បារម្ភពីការបែកចេញ ការថប់បារម្ភទូទៅ ការខ្លាចជាក់លាក់ និងការបាក់ស្បាត។ ការថប់បារម្ភពីការបែកចេញ ជាការកើនឡើងនៃអារម្មណ៍ភ័យខ្លាចក្រែងត្រូវបែកចេញពី ឪពុកម្ដាយ ឬអាណាព្យាបាល ។ ស្ថានភាពនៃការថប់បារម្ភនេះនាំឱ្យកុមារមានការពិបាកនឹងនៅសាលារៀន ឬនៅទីកន្លែងណាដែលមិនមានវត្តមានរបស់ឪពុកម្ដាយ ឬអាណាព្យាបាលរបស់ពួកគេ។

មិនខុសពីមនុស្សធំប៉ុន្មាននោះទេ ចំពោះការថប់បារម្ភទូទៅរបស់ជំទង់សំដៅដល់ ការព្រួយបារម្ភខ្លាំងអំពីបញ្ហា ឬការគំរាមកំហែងណាមួយដែលអាចកើតឡើងចំពោះគាត់នៅពេលណាមួយខាងមុខ។ ការកើនឡើងនៃអារម្មណ៍ភ័យខ្លាចរបស់កុមារ ឬជំទង់ក្នុងស្ថានភាពនេះ ច្រើនហួសពីកុមារ ឬជំទង់ដទៃទៀតដែលមានអាយុស្របាលៗគ្នា ។ ការខ្លាចជាក់លាក់ គឺជាការកើនឡើងនៃអារម្មណ៍ភ័យខ្លាចក្នុងរយៈពេលមួយយូរ ហើយមិនសមហេតុផល ដែលបង្កឡើងដោយកម្មវត្ថុ ឬស្ថានភាពជាក់លាក់ណាមួយ ។ ឧទាហរណ៍៖ កុមារាអាយុប្រហែល១២ឆ្នាំម្នាក់ ភ្ញាក់ភ័យឡើងញ័រខ្លួនសឹងមិនអាចកំរើកខ្លួនរួច នៅពេលមានសត្វជីងចក់មួយតូចធ្លាក់នៅលើតុរបស់គាត់។

ការបាក់ស្បាតជាលក្ខខណ្ឌចិត្តសាស្ត្រមួយ កើតឡើងបន្ទាប់ពីបុគ្គលម្នាក់ទទួលរងនូវព្រឹត្តិការណ៍ណាមួយដែលនាំឱ្យមានការប៉ះទង្គិចផ្លូវចិត្ត ។ ព្រឹត្តិការណ៍ទាំងឡាយណាដែលមានចរិតគំរាមកំហែងដល់អាយុជីវិត បូរណភាពរាងកាយ និងសុវត្ថិភាព បើទោះបីជាដោយផ្ទាល់ ឬដោយគ្រាន់តែឃើញក៏ដោយ ដែលមានដូចជា ការទទួលរងនូវការរំលោភបំពានរាងកាយ ការទទួលរងការវាយដំជាញឹកញាប់ពីគ្រួសារដែលប្រើអំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ ការដែលត្រូវចាប់បង្ខាំងទុក ឬចាប់ជំរិត មរណៈភាពរបស់មនុស្សជាទីស្រឡាញ់ និងការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិជាដើម ។

### ខ- មូលហេតុនៃការថប់បារម្ភ

មានមូលហេតុជាច្រើនបានទាញចេញពីសេចក្ដីសន្និដ្ឋាន និងពីលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់អ្នកឯក-

ទេសខាងផ្លូវចិត្តកុមារ និងជំទង់ដែលមានស្ថានភាពថប់បារម្ភ ដូចបានរៀបរាប់មួយចំនួនខាងលើនេះ ។ មូលហេតុទាំងនេះរាប់បញ្ចូលទាំងផ្នែកហេរ្យណេទិច បទពិសោធន៍ដែលជួបប្រទះពីកុមារភាព និងរបៀបក្នុងការចិញ្ចឹមកូន ។ ការទទួលព័ត៌មានជារូបភាព ឬសំឡេងពីមជ្ឈដ្ឋានខាងក្រៅ ដែលរាប់ពីបណ្តាញព័ត៌មាន និងបណ្តាញសង្គម ក៏ជាផ្នែកមួយដែលនាំឱ្យមានការជះឥទ្ធិពលដល់ភាពភ័យខ្លាច និងទូទៅនីយកម្មនៃអារម្មណ៍នេះចំពោះកុមារ និងជំទង់ផង ដែរ ។

### គ- លក្ខណៈសម្គាល់

សញ្ញាសម្គាល់ភាគច្រើនរបស់ជំទង់ អាចខុសប្លែកពីអ្វីដែលកើតមានចំពោះមនុស្សពេញវ័យ ។ ទាំងកុមារ និងជំទង់ភាគច្រើនសំដែងនូវអាកប្បកិរិយាគេចវេសពីស្ថានភាព ដែលនាំឱ្យពួកគេមានការថប់បារម្ភ ឬជៀសវាងនូវរាល់សកម្មភាពទាំងឡាយណា ដែលតម្រូវឱ្យមានការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ទាំងក្នុងសាលារៀន ឬក្នុងសហគមន៍ ។ លក្ខណៈសម្គាល់មួយចំនួនទៅលើស្ថានភាពនៃបញ្ហាថប់បារម្ភរបស់កុមារ និងជំទង់មានដូចខាងក្រោម៖

- **ការថប់បារម្ភពីការបែកចេញ** ៖ មានអារម្មណ៍មិនស្រណុកក្នុងចិត្តពេលនៅឆ្ងាយពីផ្ទះ ឬពីឪពុកម្តាយ តែងសួរពីវត្តមានរបស់ឪពុកម្តាយ បំផ្លើសពីស្ថានភាពរបស់ឪពុកម្តាយថាមានជំងឺឈឺធ្ងន់ ឬអាចមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬចាំបាច់ត្រូវការមើលថែទាំ
- **ការថប់បារម្ភទូទៅ** ៖ តែងមានការព្រួយបារម្ភជ្រុលពីសុវត្ថិភាព ឬក្រែងមានការគំរាមណាមួយ ពិបាកគេងដោយសារការព្រួយបារម្ភ ឆាប់ខឹងមួម៉ៅ ឬពិបាកផ្ទង់អារម្មណ៍
- **ការខ្លាចជាក់លាក់** ៖ កើនឡើងនូវអារម្មណ៍ភ័យខ្លាចខ្លាំងចំពោះកម្មវត្ថុ (ជាពិសេសសត្វ) ឬស្ថានភាព (ឧ. បន្ទប់បិទជិត ឬទីខ្ពស់) ណាមួយជាក់លាក់ គេចវេសពីកម្មវត្ថុ ឬស្ថានភាពដែលនាំឱ្យមានការភ័យខ្លាច
- **ការបាក់ស្បាត** ៖ នឹកឃើញដោយឯងៗពីព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តដែលបានជួបប្រទះ ព្យាយាមគេចចេញ ឬមិនចង់ទាក់ទងជាមួយអ្វីដែលនាំឱ្យនឹកឃើញដល់ការប៉ះទង្គិចផ្លូវចិត្ត ថយចុះការគេង បម្រុងប្រយ័ត្ន យល់សប្តិអាក្រក់ ឆាប់ខឹង

## ៥- ការធ្លាក់ទឹកចិត្ត

ការធ្វើអត្តឃាតក្នុងវ័យជំទង់ ឬយុវវ័យដែលមានចំណុចចាប់ផ្តើមពីការធ្លាក់ទឹកចិត្ត ត្រូវបានអង្គការសុខភាពពិភពលោក ចាត់ចូលជាមូលហេតុធំមួយ ក្នុងចំណោមមូលហេតុ៥ នៃអត្រាមរណៈរបស់មនុស្ស នៅលើពិភពលោក។ ក្តីបារម្ភ ចំពោះបញ្ហានេះ បានធ្វើឱ្យមានការបង្កើតឡើងនូវកិច្ចអន្តរាគមន៍ផ្សេងៗ រួមទាំងផ្នែកចិត្តសាស្ត្រ ដើម្បីធ្វើការបង្ការ និងដោះស្រាយ។ អាយុកាលដែលអាចឈានដល់ការធ្វើអត្តឃាតរបស់ជំទង់ ភាគច្រើនចាប់ពីអាយុ១៤ឆ្នាំឡើង ។ ក្នុងបរិបទខ្លះ ករណីនៃការធ្វើអត្តឃាត ក៏ត្រូវបានគោរយការណ៍ថាមានអាយុតិចជាងនេះក៏មាន។

### ក- និយមន័យ

ការធ្លាក់ទឹកចិត្ត ជាស្ថានភាពនៃផ្លូវអារម្មណ៍មួយ ដែលបុគ្គលម្នាក់មានការធ្លាក់ចុះនូវអារម្មណ៍រីករាយ ចិត្តរំភើប កម្លាំងចិត្ត និងសកម្មភាពកំសាន្តដែលធ្លាប់មាន។ ស្ថានភាពទាំងនេះប៉ះពាល់ដល់ការចូលរួមក្នុងសកម្មភាពសិក្សា គ្រួសារ ឬសហគមន៍។

### ខ- មូលហេតុនៃការធ្លាក់ទឹកចិត្ត

ការធ្លាក់ទឹកចិត្តរបស់កុមារ ឬ ជំទង់ភាគច្រើនត្រូវបានគេផ្តោតសំខាន់ទៅលើបទពិសោធន៍ដែលពួកគេ បានឆ្លងកាត់ដំបូងៗក្នុងជីវិត ការប្រាស្រ័យទាក់ទងរបស់ឪពុកម្តាយ ការមិនត្រូវបានយកចិត្តទុកដាក់ពីឪពុកម្តាយ អំពើ ហិង្សាក្នុងគ្រួសារ ឬកង្វះការគាំទ្រផ្នែកសង្គម ។ កុមារមួយចំនួនតូចត្រូវបានរកឃើញថាមានអាការៈធ្លាក់ទឹកចិត្ត សូម្បី តែចាប់តាំងប៉ុន្មានឆ្នាំដំបូងៗនៃជីវិត មុនពេលកើតមានស្ថានភាពដែលបានរៀបរាប់មុននេះក៏មាន ។ លទ្ធផល មិនល្អទទួលបានពីការសិក្សា ការប្រែប្រួលក្នុងការប្រាស្រ័យទាក់ទងរវាងភេទដូចគ្នារបស់ជំទង់ ការទទួលរង ការរំលោភបំពាន ក៏អាចជាកត្តារួមផ្សំនៃការធ្លាក់ទឹកចិត្តរបស់ពួកគេផងដែរ។

### គ- លក្ខណៈសម្គាល់

- ពិបាកផ្លង់អារម្មណ៍
- ចំពោះកុមារតូច អាចបដិសេធការទៅសាលារៀន
- នៅដាច់តែឯង មិនសូវចូលរួមជាមួយអ្នកដទៃ
- មានអារម្មណ៍មិនល្អចំពោះខ្លួនឯង យល់ថាជីវិតគ្មានតម្លៃ
- តូចចិត្ត ឬអស់សង្ឃឹម
- ការធ្វើទុក្ខទោសដល់ខ្លួន ឬឈានដល់ការប៉ុនប៉ងធ្វើអត្តឃាត
- ឆាប់ខឹងឆេវឆាវ
- ជំទង់ខ្លះអាចឈានដល់ការប្រើសារធាតុញៀន ឬសេពសុរា
- អាចមានសញ្ញាពាក់ព័ន្ធបញ្ហាចិត្តកាយវិបល្លាស ដូចជា ឈឺក្បាល ឈឺក្រពះ ។ល។

**សញ្ញាប្រឈមនាំទៅដល់ការធ្វើអត្តឃាតរបស់ជំទង់**

- ធ្លាប់មានប្រវត្តិប៉ុនប៉ងធ្វើអត្តឃាត
- លក្ខណៈសម្គាល់អំពីការធ្លាក់ទឹកចិត្តកើនឡើង
- ការផ្លាស់ប្តូរអាកប្បកិរិយាប្លែកៗ ពិសេសទាក់ទងនឹងការធ្វើទុក្ខទោសដល់ខ្លួន
- ការនិយាយអារម្មណ៍អស់សង្ឃឹមញឹកញាប់
- ការនិយាយរឿងពាក់ព័ន្ធនឹងការធ្វើអត្តឃាត (វិធី ពេលវេលា ទីកន្លែង)
- លែងចូលរួមសកម្មភាពដែលធ្លាប់ចូលចិត្ត ឬសកម្មភាពក្នុងសាលា ឬជាមួយមិត្តភក្តិ
- មានចេតនាទុកបណ្តាំផ្ញើ ឬស្នើឱ្យមានការជួយធ្វើអ្វីមួយជាចុងក្រោយ
- ការគេងថយចុះខ្លាំង
- មាន ឬកើនឡើងការប្រើសារធាតុញៀន រួមទាំងគ្រឿងស្រវឹង

កត្តាចូលរួមក្នុងការបង្ការទប់ស្កាត់ការប៉ុនប៉ងធ្វើអត្តឃាតរបស់ជំទង់

√. កំណត់រកជំទង់ដែលអាចមានការប្រឈមទៅនឹងការធ្វើអត្តឃាត

√. លើកកម្ពស់ការយល់ដឹងអំពីសញ្ញាណនៃការធ្លាក់ទឹកចិត្ត ក្នុងចំណោមគ្រូបង្រៀន និងបុគ្គលិកសិក្សា

√. ផ្តល់ព័ត៌មានដល់ឪពុកម្តាយ ឬអាណាព្យាបាលអំពីកម្រិតនៃការប្រឈមទៅនឹងការធ្វើអត្តឃាត

√. រក្សាទម្លាប់ប្រើវិធីសាស្ត្រជាវិជ្ជមានទាំងឡាយណា ដែលលើកកម្ពស់ទឹកចិត្តសញ្ចេតនា និងការឱ្យតម្លៃខ្លួនរបស់សិស្ស ។

√. កាត់បន្ថយឱ្យនៅកម្រិតតិចបំផុតតាមដែលអាចធ្វើបាន នូវរបៀបដែលអាចដាក់សំពាធជាវិជ្ជមានទាំងឡាយណាដែលជ្រុលហួស ឬខ្លាំងពេក ចំពោះសិស្ស ។

√. លើកកម្ពស់ឱ្យមានការសម្តែងពីអារម្មណ៍ជាមួយគ្រូ ឪពុកម្តាយ មិត្តភក្តិជិតស្និទ្ធ ឬជាមួយអ្នកដែលទុកចិត្តបំផុត ។

√. លើកកម្ពស់ការប្រាស្រ័យទាក់ទងល្អរវាងគ្រូ និងសិស្ស សិស្ស និងសិស្ស

√. បង្ការ ឬកាត់បន្ថយអំពើហិង្សានៅក្នុងសាលា ឬអំពើទុក្ខទោសដល់សិស្ស ។

√. បញ្ជូនទៅកាន់អ្នកឯកទេសផ្លូវចិត្ត ក្រោយពេលដឹងពីសញ្ញាណនៃការធ្លាក់ទឹកចិត្ត ឬសញ្ញាប្រឈមនាំទៅដល់ការធ្វើអត្តឃាត ។

## IV- សន្និដ្ឋាន

ការចូលរួមសកម្មភាពក្នុងការសិក្សា និងលទ្ធផលក្នុងការសិក្សា មានការជាប់ពាក់ព័ន្ធជាមួយនឹងសុខភាពផ្លូវចិត្តរបស់សិស្ស។ បញ្ហាផ្លូវចិត្តរបស់សិស្ស ក្នុងវ័យសិក្សាមានច្រើនប្រភេទ និងមានកម្រិតខុសៗគ្នា។ ចំណែកឯកត្តាដែលបង្កឱ្យមានបញ្ហាផ្លូវចិត្តទាំងនេះ អាចមានជាប់ពាក់ព័ន្ធជាមួយនឹង កត្តាជីវសាស្ត្រ កត្តាចិញ្ចឹមបីបាច់របស់ឪពុកម្តាយ ឬអាណាព្យាបាល កត្តាមជ្ឈដ្ឋានជុំវិញ កត្តាសង្គម និងកត្តាចិត្តសាស្ត្រ។

### សំណួរ

1. តើវិបល្លាសការសិក្សាត្រូវបានគេចែកចេញជាប៉ុន្មានប្រភេទ ?ហើយមានមូលហេតុអ្វីខ្លះដែលនាំឱ្យមានវិបល្លាសនេះកើតឡើង។
2. តើមានសញ្ញាណអ្វីខ្លះដែលអ្នកអាចសម្គាល់បានថា សិស្សរបស់អ្នកមានអាការៈពាក់ព័ន្ធនឹងការធ្លាក់ទឹកចិត្ត ?
3. ក្នុងចំណោមបញ្ហាផ្លូវចិត្តពាក់ព័ន្ធមួយចំនួនរបស់កុមារ ឬជំទង់ដែលមានរៀបរាប់ខាងដើម តើស្ថានភាពនៃបញ្ហាណាមួយដែលអាចមានការប្រឈមខ្លាំងជាងគេ និងត្រូវការជួយគាំទ្រពីអ្នកជាងគេ ?
4. ក្នុងនាមជាគ្រូបង្រៀនម្នាក់  តើអ្នកនឹងធ្វើបែបណាដើម្បីចូលរួម  ក្នុងការបង្ការទប់ស្កាត់ការប្រឈមទៅនឹងការធ្វើអត្ត ឃាតរបស់សិស្ស ?

# មេរៀនទី៣៧ របៀបប្រាស្រ័យទាក់ទងរវាងគ្រូ និងសិស្ស

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

- រៀបរាប់បានពីលក្ខណៈខុសៗគ្នានៃបញ្ហារបស់កុមារ និងជំទង់
- ពន្យល់បានពីប្រាស្រ័យទាក់ទងជាវិជ្ជមានជាមួយកុមារ និងជំទង់ដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត
- ស្មារតីព្យាយាមក្នុងការិះរកមធ្យោបាយក្នុងការអប់រំផ្លូវចិត្តសិស្ស ឱ្យចេះរស់នៅដោយសន្តិភាព

## II- សេចក្តីផ្តើម

ដោយធម្មជាតិនៃប្រភេទ និងកម្រិតបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្សខុសៗគ្នាពីម្នាក់ទៅម្នាក់ នោះរបៀបផ្សេងៗគ្នាមួយចំនួន ក៏ចាំបាច់យកមកប្រើដែរ ជាពិសេសក្នុងបរិបទបណ្តុះបណ្តាលអប់រំ ។ ក្នុងវ័យសិក្សាសិស្សក្នុងកម្រិតសិក្សាជាក់លាក់មួយចំនួន ចំណាយពេលវេលាច្រើននៅជាមួយ ថ្នាក់រៀន ឬគ្រូបង្រៀន ជាជាងជាមួយឪពុកម្តាយ ឬសមាជិកគ្រួសារឯទៀតៗ ដែលនៅឯផ្ទះ ។ ដូចនេះ បន្ថែមពីលើកិច្ចការងារទទួលខុសត្រូវក្នុងការបង្រៀន របៀបដែលគ្រូបង្រៀន ប្រើការប្រាស្រ័យទាក់ទងជាមួយសិស្ស ពិតជាមានចំណងទាក់ទងជាវិជ្ជមាន ជាមួយនឹងលទ្ធផលនៃការសិក្សារបស់សិស្សផងដែរ ។

ចំពោះសិស្សដែលអាចមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត ក្នុងវ័យសិក្សា ក៏រឹតតែតម្រូវឱ្យគ្រូបង្រៀនមានឥរិយាបថ អាកប្បកិរិយាជាវិជ្ជមាន និងមិនវិនិច្ឆ័យក្នុងសកម្មភាពរៀន និងបង្រៀនផងដែរ។ គ្រូបង្រៀនអាចក្លាយទៅជាប្រភពធនធានផ្លូវចិត្តមួយយ៉ាងល្អ នៅពេលដែលសិស្សមានអារម្មណ៍ថា មានភាពកក់ក្តៅ បានទទួលការស្រឡាញ់ ការការពារ មានសុវត្ថិភាព និងមិនត្រូវបានរិះគន់ ឬមិនត្រូវបានវិនិច្ឆ័យក្នុងន័យអវិជ្ជមាន នៅរាល់ពេលដែលសិស្សមានការប្រាស្រ័យទាក់ទងជាមួយគ្រូបង្រៀន។ ជាងនេះទៅទៀត ឥរិយាបថ និងទង្វើប្រកបដោយក្រម សីលធម៌វិជ្ជាជីវៈនេះ អាចជួយបណ្តុះនូវមនសិការល្អ និងសេចក្តីស្រឡាញ់ និងបង្រៀនពីការប្រាស្រ័យទាក់ទងល្អ ជាមួយអ្នកដទៃនៅពេលដែលពួកគេចម្រើនវ័យនៅថ្ងៃអនាគត ដែលសិស្សមួយចំនួនមិនធ្លាប់ដែលជួបប្រទះនូវបទពិសោធន៍ទាំងនេះ ជាមួយអ្នកឯទៀត ក្នុងជីវិតដំបូងៗរបស់ពួកគេ ។ ឧទាហរណ៍៖ ការបង្ហាញនូវភាពអត់ធ្មត់ក្នុងការប្រាស្រ័យទាក់ទងជាមួយសិស្សដែលមានបញ្ហាអាកប្បកិរិយាអាចបង្រៀនឱ្យសិស្សរៀនពីរបៀបអត់ធ្មត់ដូចគ្នានេះ ជាមួយអ្នកដទៃទៀតនៅពេលអនាគត។

បើទោះបីជា គុណវឌ្ឍន៍របស់គ្រូបង្រៀនមានការផ្សារភ្ជាប់ជាមួយនឹងរបៀបក្នុងការប្រាស្រ័យទាក់ទងជាមួយសិស្ស ដែលមានបញ្ហាពាក់ព័ន្ធនឹងបញ្ហាសុខភាពផ្លូវចិត្តក៏ដោយ ក៏ទន្ទឹមនឹងការផ្តល់ការយកចិត្តទុកដាក់យ៉ាងល្អប្រកបដោយវិជ្ជាជីវៈនេះ មិនមែនត្រឹមតែធ្វើឡើងសម្រាប់តែសិស្ស ក្នុងការទទួលខុសត្រូវរបស់ខ្លួនប៉ុណ្ណោះនោះទេ គ្រូបង្រៀនក៏ចាំបាច់ត្រូវការ ការយកចិត្តទុកដាក់យ៉ាងល្អ ជាមួយនឹងខ្លួនឯងផងដែរ។ ផ្នែកដែលពាក់ព័ន្ធនេះ នឹងមាននិយាយលម្អិតក្នុងមេរៀន ការថែទាំសុខភាពផ្លូវចិត្តរបស់គ្រូបង្រៀន។

នៅក្នុងផ្នែកបន្ទាប់នៃមេរៀននេះ និងមានការរៀបរាប់អំពីការប្រាស្រ័យទាក់ទងដ៏ល្អ និងប្រកបដោយប្រសិទ្ធភាព ប្រើដោយគ្រូបង្រៀន ជាមួយនឹងសិស្សរបស់ខ្លួន ជាពិសេសចំពោះសិស្សដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត។

## III- ខ្លឹមសារ

ដោយផ្អែកលើប្រភេទ និងកម្រិតផ្សេងៗគ្នា នៃបញ្ហាសុខភាពផ្លូវចិត្តរបស់សិស្ស ការឆ្លើយតបដ៏ត្រឹមត្រូវតាម រូបភាពនៃការប្រាស្រ័យទាក់ទង គឺជាការប្រព្រឹត្តដ៏ចាំបាច់។ កម្រិតនៃការបើកចំហរឱ្យដឹងអំពីបញ្ហាផ្លូវចិត្តរបស់សិស្ស ក៏អាស្រ័យយ៉ាងសំខាន់ទៅលើ កម្រិតនៃភាពទុកចិត្តរបស់ពួកគេ ចំពោះយើងដែលជាគ្រូបន្ទុក ឬគ្រូបង្រៀនផងដែរ។ ការប្រាស្រ័យទាក់ទងល្អ ជាពិសេសក្នុងស្ថានភាពដែលសិស្សត្រូវការ ការយកចិត្តទុកដាក់ជាក់លាក់ ជាចលករមួយ ដ៏មានប្រសិទ្ធភាពក្នុងការបង្កើន កម្រិតនៃភាពទុកចិត្តឱ្យកាន់តែខ្លាំងឡើង ។ របៀបប្រាស្រ័យទាក់ទងមួយចំនួនក្នុង ស្ថានភាពដែលសិស្ស មានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត មានរៀបរាប់ដោយសង្ខេប និងជាមូលដ្ឋានជំនួយដល់គ្រូ ដើម្បីឆ្លើយតបក្នុងដំណាក់កាលបឋម។ ផ្នែកទីមួយ ផ្តោតទៅលើការឆ្លើយតបចំពោះសិស្សដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តទូទៅ និងផ្នែកបន្ទាប់នឹងរៀបរាប់អំពី ការឆ្លើយតបចំពោះសិស្ស ដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តជាក់លាក់ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្រូបង្រៀនក៏ចាំបាច់លើកទឹកចិត្ត ឱ្យមានការចូលរួមឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធ នឹងសុខភាពផ្លូវចិត្តរបស់សិស្ស ពីបុគ្គលិកសិក្សាដទៃទៀត ក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន និងជាពិសេស ការចូលរួមរបស់ឪពុកម្តាយ ឬអាណាព្យាបាលផងដែរ។

### ១- ចំពោះសិស្សដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តទូទៅ

ការឆ្លើយតបក្នុងផ្នែកនេះ ត្រូវបានកំណត់ដោយការអនុវត្តដែលត្រឹមត្រូវរបស់គ្រូបង្រៀន ចំពោះសិស្សដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តជាទូទៅ និងការអនុវត្តដែលចាំបាច់គួរជៀសវាង ក្នុងការឆ្លើយតបចំពោះសិស្សរបស់ខ្លួន ដែលមានបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត។

#### ក- ការអនុវត្តត្រឹមត្រូវ

- ប្រើការប្រាស្រ័យទាក់ទងដោយមានការយល់ចិត្ត ដូចជាស្តាប់ដោយយកចិត្តទុកដាក់ មិនមានឥរិយាបថវិនិច្ឆ័យ និងបង្ហាញនូវភាពស្មោះត្រង់ក្នុងទំនាក់ទំនង
- ធ្វើការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវចិត្ត និងសារៈសំខាន់នៃការរក្សាការសម្ងាត់
- បង្កលក្ខណៈងាយស្រួលដល់សិស្ស ដើម្បីអាចរកឱកាសជជែកអំពីបញ្ហាពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត
- លើកទឹកចិត្តឱ្យមាន ការបញ្ចេញអារម្មណ៍ និងរៀនពីរបៀបក្នុងការបញ្ចេញអារម្មណ៍តាមបែបវិជ្ជមាន
- ផ្តល់ព័ត៌មានពីការវិវត្តន៍នៃបញ្ហាពាក់ព័ន្ធនឹងផ្លូវចិត្តរបស់សិស្ស ទៅកាន់អាណាព្យាបាលនិងធ្វើការបញ្ជូនទៅកាន់អ្នកឯកទេសខាងផ្លូវចិត្ត ក្នុងករណីចាំបាច់
- គោរពគោលការណ៍សិទ្ធិជាមូលដ្ឋានរបស់កុមារ និងរក្សាការសម្ងាត់
- រៀនពីរបៀបក្នុងការថួយថែទាំសុខភាពផ្ទាល់ខ្លួន

#### ខ- ការអនុវត្តដែលគួរជៀសវាង

- ស្តីបន្ទោសចំពោះអាកប្បកិរិយាមិនធម្មតាណាមួយរបស់សិស្ស
- ដាក់ទណ្ឌកម្ម ឬធ្វើឱ្យសិស្សកាន់តែមានអារម្មណ៍អាម៉ាស់ ក្នុងចំណោមសិស្សដទៃទៀត ឬក្នុងចំណោមបុគ្គលិកសិក្សារបស់ខ្លួន
- កេងប្រវ័ញ្ច ឬទាញយកផលប្រយោជន៍ ពីបញ្ហាពាក់ព័ន្ធនឹងផ្លូវចិត្តរបស់សិស្ស
- ដាក់ឱ្យសិស្សដែលមានបញ្ហាពាក់ព័ន្ធនឹងផ្លូវចិត្តឱ្យនៅដោយឡែក ឬមានភាពលំអៀងជាអវិជ្ជមានក្នុងការបំពេញតួនាទីបង្រៀនរបស់ខ្លួនចំពោះពួកគេ
- ព្យាយាមស្វែងយល់មូលហេតុផ្សេងៗ នៅពីក្រោយបញ្ហាពាក់ព័ន្ធនឹងផ្លូវចិត្ត ក្នុងខណៈពេលដែលសិស្សមិនមានសុវត្ថិភាព និងទំនុកចិត្តក្នុងការផ្តល់ព័ត៌មាន

## ២- ចំពោះក្មេងដែលមានបញ្ហាសុខភាពពាក់ព័ន្ធនឹងផ្លូវចិត្តជាក់លាក់

### ២.១- ការប៉ុនប៉ងធ្វើអត្តឃាត

ការកើនឡើងនៃការព្រួយបារម្ភរបស់ពិភពលោកក្នុងទស្សវត្សចុងក្រោយនេះ គឺទៅលើអត្រាដ៏ខ្ពស់នៃការធ្វើអត្តឃាតរបស់ជំទង់ ក្នុងវ័យសិក្សា។ ការធ្វើអត្តឃាតក្នុងវ័យមុនឈានចូលដល់មជ្ឈឹមវ័យនេះ ត្រូវបានចាត់ចូលជាការបារម្ភយ៉ាងខ្លាំងមួយ ក្នុងវិស័យសុខាភិបាល ជាពិសេសផ្នែកសុខភាពផ្លូវចិត្ត។ បើទោះបីបញ្ហានេះ ជាបញ្ហាប្រឈមដ៏ស្មុគស្រាញក៏ដោយ ក៏វាជាប្រការដែលចាំបាច់ផងដែរ ដែលគ្រប់គ្នាត្រូវមានការចូលរួមចំណែកដោះស្រាយ ឬធ្វើឱ្យប្រសើរឡើង។ ការធ្វើអត្តឃាត គឺជាបញ្ហាដែលភាគច្រើន អាចដឹងតាមរយៈការយកចិត្តទុកដាក់សង្កេតអំពី ការផ្លាស់ប្តូរអាកប្បកិរិយាដែលប្រែប្រួលគួរឱ្យកត់សម្គាល់ ដើម្បីធ្វើការបង្ការ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ក្នុងករណីកម្រិតនៃបញ្ហាផ្លូវចិត្តរបស់សិស្សមានសភាពធ្ងន់ធ្ងរពេក ដែលការបង្ការ ហាក់ដូចជារឿងដែលមិនអាចឆ្លើយតបបានគ្រប់គ្រាន់ សម្រាប់បញ្ចៀសការធ្វើអត្តឃាត ចំពោះសិស្សមួយចំនួន។

#### ក- សញ្ញាណសម្គាល់បញ្ហាមួយចំនួន ដែលអាចនឹងឈានទៅដល់ការប៉ុនប៉ងធ្វើអត្តឃាត

- ការថយចុះនូវចំណាប់អារម្មណ៍ចំពោះសកម្មភាពដែលធ្លាប់ធ្វើជាប្រចាំ
- ការធ្លាក់ចុះពិន្ទុសិក្សា គួរឱ្យចាប់អារម្មណ៍
- មានបញ្ហាចរិយា ឬបញ្ហាទំនាក់ទំនងជាមួយមិត្តរួមថ្នាក់ ឬរួមសាលា
- អវត្តមានពីថ្នាក់រៀន ដោយមិនមានមូលហេតុច្បាស់លាស់
- កើនឡើងនូវការប្រើថ្នាំជក់ ឬគ្រឿងស្រវឹង

#### ខ- របៀបដែលគ្រូបង្រៀនត្រូវធ្វើក្នុងករណីសិស្សមានបញ្ហាពាក់ព័ន្ធនឹងការប៉ុនប៉ងធ្វើអត្តឃាត

របៀបសាមញ្ញៗ ប៉ុន្តែចាំបាច់មួយចំនួន ដែលគ្រូបង្រៀនអាចធ្វើបាន ក្នុងស្ថានភាពដែលសិស្សមានការប៉ុនប៉ងធ្វើអត្តឃាត មានដូចខាងក្រោម ៖

- បង្ហាញនូវការស្តាប់ដោយយកចិត្តទុកដាក់ និងឥរិយាបថមិនវិនិច្ឆ័យ
- ធ្វើឱ្យប្រាកដថា សិស្សមិនមានអ្វីដែលនឹងបង្កឱ្យមានគ្រោះថ្នាក់ក្នុងស្ថានភាពនៅជាមួយគ្នានោះ
- ជៀសវាងការរំលឹកដល់ស្ថានភាពដែលរឹតតែនាំឱ្យមានអារម្មណ៍ធ្លាក់ទឹកចិត្ត ឬអស់សង្ឃឹមថែមទៀត
- ព្យាយាមប្រើការនិយាយ និងប្រាស្រ័យទាក់ទងតែផ្នែកដែលវិជ្ជមានល្អៗ និងជាការលើកទឹកចិត្ត
- ជៀសវាងទុកឱ្យនៅតែឯង
- ផ្តល់ព័ត៌មានទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាល
- នាំទៅកាន់អ្នកឯកទេសផ្លូវចិត្ត
- ផ្តល់ព័ត៌មានដែលពាក់ព័ន្ធ ទៅដល់អ្នកឯកទេសផ្លូវចិត្ត បើចាំបាច់
- ចូលរួមធ្វើការតាមដានការវិវត្ត ជាមួយឪពុកម្តាយ ឬអាណាព្យាបាល ដើម្បីធ្វើឱ្យប្រាកដថា សិស្សនោះបានទទួលសេវាដ៏ចាំបាច់ និងត្រឹមត្រូវ។

### ២.២- កំហឹង

កំហឹងជាអារម្មណ៍ដែលមានពីធម្មជាតិមួយរបស់មនុស្សគ្រប់រូប មិនថាក្មេង ឬចាស់ ប្រុស ឬស្រីនោះទេ។ កំហឹងជាអ្វីដែលមនុស្សគ្រប់គ្នាមិនអាចលុបបំបាត់បានទេ ប៉ុន្តែយើងអាចរៀនពីរបៀបក្នុងការគ្រប់គ្រងវា និងពីរបៀបក្នុងការបញ្ចេញវា តាមរបៀបវិជ្ជមាន។ របៀបក្នុងការបញ្ចេញកំហឹងជាច្រើន គឺជារបៀបដែលរៀនពីអ្នកដទៃ ឬមជ្ឈដ្ឋាននៅជុំវិញខ្លួនយើង។ កុមាររឹងរឹតតែងាយរៀនពីរបៀប និងយកគ្រាប់តាមមនុស្សធំ ឬអ្នកដែលនៅជិតគាត់បំផុតក្នុងការបញ្ចេញកំហឹង ជាពិសេស កុមារដែលរស់នៅក្នុងគ្រួសារដែលប្រើអំពើហិង្សា។ ដោយសារតែ របៀបនៃការបញ្ចេញកំហឹង គឺជាអាកប្បកិរិយាដែលរៀន និងធ្វើត្រាប់តាមអ្នកដទៃ អាកប្បកិរិយានេះ ក៏អាចធ្វើការកែប្រែ និងផ្លាស់ប្តូរបានដែរ

តាមរយៈការរៀនពីរបៀបក្នុងការគ្រប់គ្រង និងបញ្ចេញកំហឹងតាមរបៀបវិជ្ជមាន។ មានមូលហេតុជាក់លាក់មួយចំនួន ដែលនាំទៅដល់ការផ្ទុះឡើងនៃកំហឹង ក្នុងចំណោមសិស្សក្នុងវ័យសិក្សា។ មូលហេតុមួយចំនួនជាមូលហេតុដែល ងាយនឹងប៉ាន់ប្រមាណដល់ កម្រិតនៃការផ្ទុះកំហឹង ក្នុងចំណោមសិស្សរបស់អ្នក ប៉ុន្តែក៏មានមូលហេតុមួយចំនួនផ្សេងទៀត ដែលអ្នកនឹងស្មានមិនដល់ថា អាចនឹងនាំទៅដល់ការផ្ទុះកំហឹង។ មូលហេតុទាំងនេះមានដូចខាងក្រោម៖

### ក- មូលហេតុដែលនាំឱ្យមានកំហឹងកើតឡើងក្នុងថ្នាក់រៀន

- ការដណ្តើមសម្ភារៈសិក្សា ឬទីតាំងកន្លែងអង្គុយ
- ការដើរប៉ះគ្នាដោយអចេតនា ការរុញច្រានគ្នា ឬការលេងដោយប្រើកម្លាំងកាយ
- ការប្រកែកគ្នា ការមិនយល់ស្របគ្នាលើប្រធានបទណាមួយ ឬការចំអកចំអន់គ្នាលេង
- ការបដិសេធមិនរាប់រក ដោយសារជាសិស្សថ្មីក្នុងថ្នាក់ ឬដោយសារមិនមែនជាក្រុមរបស់ខ្លួន

### ខ- របៀបដែលគ្រូបង្រៀនត្រូវធ្វើក្នុងករណីសិស្សមានបញ្ហាពាក់ព័ន្ធនឹងអំពើហិង្សា

- រក្សាភាពអត់ធ្មត់ និងគ្រប់គ្រងស្ថានភាពបង្ការកុំឱ្យកំហឹងក្លាយទៅជាអំពើហិង្សា
- ដើរតួជាអ្នកសម្រុះសម្រួល ដោយឱ្យភាគីទាំងសងខាងស្ថិតនៅឱ្យឆ្ងាយពីសិស្សដទៃទៀត ឬពីកន្លែងដែលអាចបង្កគ្រោះថ្នាក់ ដើម្បីរក្សាសុវត្ថិភាព
- ប្រសិនបើអាចធ្វើបាន ផ្តល់របស់បន្តិចបន្តួចដែលសិស្សចូលចិត្ត ដើម្បីបង្វែរ និងកាត់បន្ថយកំហឹង
- ជៀសវាងការគំរាមកំហែងដល់ភាគីណាមួយ ដែលរឹតតែធ្វើឱ្យពួកគេមានអារម្មណ៍កាន់តែតានតឹង ឬភ័យខ្លាច
- ជៀសវាងការនិយាយ ឬបញ្ចេញអាកប្បកិរិយា ដែលនាំកំហឹងកាន់តែកើនឡើង
- ផ្តល់ឱកាសឱ្យភាគីទាំងសងខាងបានបញ្ចេញនូវអារម្មណ៍ដែលនៅពីក្រោយកំហឹង តាមរយៈការប្រើពាក្យសម្តី ជាជាងការប្រើកម្លាំងបាយ។ ឧទាហរណ៍ៈ ខ្ញុំមិនចូលចិត្តឱ្យអ្នកធ្វើបែបនេះដាក់ខ្ញុំទេ...
- ប្រើបច្ចេកទេសសាមញ្ញជាមូលដ្ឋានដូចជា ឱ្យសិស្សរាប់ពី០ដល់១០ ឬច្រើនជាងនេះ ប្រសិនបើ កំហឹងមានលក្ខណៈខ្លាំងក្លា ឬឱ្យសិស្សដកដង្ហើមឱ្យបានវែងៗ ចំនួន៣ ទៅ៤ដងមុនពេលនិយាយម្តងៗ ។
- បញ្ចៀសភាគីទាំងសងខាង ឱ្យចេញឆ្ងាយពីគ្នាក្នុងរយៈពេលណាមួយ ប្រសិនបើស្ថានភាពនៃកំហឹងមិនថមថយ
- ធ្វើការសង្កេត និងបញ្ជូនសិស្សដែលឆាប់មានអារម្មណ៍ឆេវឆាវ ឬសំដែងនូវអាកប្បកិរិយាបំពារបំពានទៅជួបអ្នកចិត្តសាស្ត្រដែលនៅជិតបំផុត។

### គ- វិធីសាស្ត្រមួយចំនួន ក្នុងការបង្ការ ការកើនឡើងនៃកំហឹងក្នុងថ្នាក់រៀន

មានវិធីសាស្ត្រមួយចំនួន ដែលអនុវត្តក្នុងថ្នាក់រៀន ជាការរួមចំណែកកាត់បន្ថយនូវការកើនឡើង និងឈានទៅដល់ការផ្ទុះកំហឹង។ វិធីសាស្ត្រទាំងនេះមានដូចជា៖

- បង្កើតនូវបរិយាកាសសិក្សាដែលផ្តល់នូវផាសុខភាពផ្លូវអារម្មណ៍ដល់សិស្ស ដូចជាការរៀបចំឱ្យមាននូវវិន័យរបស់ថ្នាក់រៀន ដែលមានលក្ខណៈច្បាស់លាស់ សាមញ្ញងាយយល់ និងស្មើភាពចំពោះសិស្ស គ្រប់រូប
- លើកទឹកចិត្តឱ្យសិស្សរៀនពីរបៀបសំដែងអារម្មណ៍ តាមរយៈការពាក្យសំដី ជាជាងការសម្តែងអារម្មណ៍តាមរយៈសកម្មភាពរាងកាយ ឬការប្រើកម្លាំងបាយ
- លើកទឹកចិត្តឱ្យសិស្សចេញឆ្ងាយពីស្ថានភាពនៃនាំឱ្យកាន់តែផ្ទុះកំហឹងមួយរយៈពេលខ្លី ឬអាចទៅទីកន្លែង ណាមួយក្នុងបរិវេណថ្នាក់រៀន ឬសាលាដែលធ្វើឱ្យមានអារម្មណ៍ប្រសើរឡើងវិញ
- លើកទឹកចិត្តឱ្យសិស្សរៀនពីរបៀបក្នុងការគិតឱ្យបានល្អិតល្អន់ មុននឹងបញ្ចេញកំហឹងរបស់ខ្លួន

- បង្រៀនពីរបៀបសាមញ្ញៗក្នុងការដោះស្រាយបញ្ហា
- ធ្វើជាគំរូដល់សិស្ស ក្នុងការសំដែងអារម្មណ៍ ឬបញ្ចេញកំហឹងរបស់ខ្លួន។

## IV- សន្និដ្ឋាន

គ្រូបង្រៀន ជាអ្នកដែលនៅជិតបំផុតជាមួយសិស្សបន្ទាប់ពីឪពុកម្ដាយ ឬអាណាព្យាបាល និងសមាជិកមួយចំនួន ក្នុងគ្រួសារដែលសិស្សរស់នៅជាមួយ។ ការប្រាស្រ័យទាក់ទងល្អរបស់គ្រូទៅកាន់សិស្ស ក្នុងស្ថានភាពជាក់លាក់ជាពិសេសចំពោះសិស្សដែលមានបញ្ហាជាប់ពាក់ព័ន្ធជាមួយនឹងសុខភាពផ្លូវចិត្ត បានចូលរួមចំណែកក្នុងការកាត់បន្ថយស្ថានភាពនៃបញ្ហានោះបានមួយកម្រិត។ បញ្ហាជាក់លាក់ខ្លះដូចជា ការប៉ុនប៉ងធ្វើអត្តឃាត និងការបញ្ចេញនូវអាកប្បកិរិយាហិង្សាក្នុងថ្នាក់រៀន ក៏អាចត្រូវបានបង្ការ ឬកាត់បន្ថយ នៅពេលដែលគ្រូបង្រៀនដឹង និងអនុវត្តរបៀបដ៏ត្រឹមត្រូវ និងវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពជាមួយសិស្ស។ ទោះបីជាយ៉ាងណាក៏ដោយ ការឆ្លើយតបដ៏ត្រឹមត្រូវក្នុងដំណាក់កាលបឋម អាចនឹងមិនគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាដែលសិស្សអាចមាន ជាពិសេសក្នុងករណីដែលបញ្ហាដែលកើតឡើង ហួសពីសមត្ថភាព និងជំនាញដែលគ្រូបង្រៀនអាចធ្វើបាន ។ ក្នុងករណីនេះ ការស្វែងរក អន្តរាគមន៍បន្ថែមពីអ្នកដែលមានជំនាញ និងឯកទេសជាក់លាក់ខាងផ្នែកផ្លូវចិត្ត ដោយមានការសហការណ៍ពីឪពុក ម្ដាយ ឬអាណាព្យាបាល ដើម្បីធ្វើការបញ្ជូន ពិតជាចាំបាច់។

### សំណួរ

1. តើអ្វីខ្លះដែលគ្រូបង្រៀនត្រូវធ្វើ និងជៀសវាងមិនត្រូវធ្វើនៅពេលមានសិស្ស ដែលមានបញ្ហាពាក់ព័ន្ធនឹង សុខភាពផ្លូវចិត្តទូទៅ?
2. សិស្សដែលអាចមានបញ្ហាពាក់ព័ន្ធនឹងការប៉ុនប៉ងធ្វើអត្តឃាត អាចសម្គាល់បានដោយរបៀបណាខ្លះ?
3. កំហឹងជាអារម្មណ៍ពីធម្មជាតិមួយរបស់មនុស្ស ។ ដើម្បីកាត់បន្ថយបញ្ហាដែលអាចកើតឡើងដោយសារការផ្ទុះកំហឹង តើក្នុងនាមជាគ្រូបង្រៀនម្នាក់ អ្នកនឹងប្រើវិធីសាស្ត្របែបណាដែរ?

# មេរៀនទី៣៨ ការថែទាំសុខភាពផ្លូវចិត្តគ្រូ

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ គរុសិស្សនឹង ៖

- ពណ៌នាបានអំពីអត្ថប្រយោជន៍ក្នុងការថែទាំសុខភាពផ្លូវចិត្តរបស់ខ្លួន និងសញ្ញាណ ការតានតឹង ផ្លូវចិត្ត ការថប់បារម្ភ និងការធ្លាក់ទឹកចិត្ត
- បង្ហាញបានពីការប្រើបច្ចេកទេសជាមូលដ្ឋានមួយចំនួនក្នុងការថែទាំ និងធ្វើឱ្យសុខភាពផ្លូវចិត្តប្រសើរឡើង
- មានទំនួលខុសត្រូវក្នុងការប្រើប្រាស់វិធីជួយសុខភាពផ្លូវចិត្ត ឱ្យបានរឹងមាំក្នុងការបំពេញភារកិច្ចប្រកបដោយជោគជ័យ ។

## II- សេចក្តីផ្តើម

ភារកិច្ចបណ្តុះបណ្តាលធនធានមនុស្សសម្រាប់សង្គមជាតិ ជាកិច្ចការងារដែលចាំបាច់ត្រូវការ ការខិតខំប្រឹងប្រែងឆន្ទៈវិជ្ជាជីវៈ និងភាពអត់ធ្មត់។ លក្ខណៈសម្បត្តិទាំងនេះ តម្រូវឱ្យគ្រូបង្រៀនដែលជាអ្នកបណ្តុះបណ្តាលថ្នាលធនធានមនុស្សជំនាន់ក្រោយនេះ ត្រូវតែជាបុគ្គលដែលមានបុគ្គលិកលក្ខណៈល្អ រឹងប៉ឹង មាំមួន សុខភាពល្អ និងអាចបំពេញមុខងារបានយ៉ាងល្អទៅតាមកិច្ចការងារទទួលខុសត្រូវប្រកបដោយវិជ្ជាជីវៈ។ សុខភាពមនុស្សម្នាក់ល្អប្រសើរទៅបានត្រូវដើរទន្ទឹមគ្នាទាំងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត។ ការបរិភោគបន្លែ ត្រី សាច់ និងផ្លែឈើជាប្រចាំថ្ងៃ គឺក្នុងគោលបំណងធ្វើឱ្យសុខភាពរាងកាយរឹងមាំល្អមិនមានជំងឺមកយាយី។ មិនខុសពីសុខភាពផ្លូវកាយនោះទេសុខភាពផ្លូវចិត្ត ក៏ចាំបាច់ត្រូវការអាហារដ៏ត្រឹមត្រូវដើម្បីធ្វើឱ្យសុខភាពផ្លូវចិត្តនៅល្អប្រសើរកាត់បន្ថយភាពមិនប្រក្រតីដែលអាចកើតឡើងផងដែរ។ អាហារដ៏ល្អសម្រាប់សុខភាពផ្លូវចិត្ត គឺរាល់បច្ចេកទេស វិធីសាស្ត្រ ឬការអនុវត្តដែលមាន លក្ខណៈវិជ្ជមានទាំងឡាយណាដែលធ្វើឱ្យផ្លូវចិត្តមានសភាពស្ងប់ស្ងាត់ល្អ ផ្តោតទៅលើបទពិសោធន៍ លំនឹក ឬឫបារម្មណ៍ដែលមានលក្ខណៈវិជ្ជមាន និងសាមញ្ញៗ នោះភាពរឹងមាំនៃសុខភាពផ្លូវកាយ ក៏នឹងកើតមានឡើងផងដែរ។ ការសិក្សាស្រាវជ្រាវជាច្រើនក៏បានបង្ហាញអំពីទំនាក់ទំនងជាវិជ្ជមានរវាងសុខភាពផ្លូវចិត្ត និងលទ្ធផលនៃការបំពេញកិច្ចការងារផងដែរ ។ នោះមានន័យថា បើបុគ្គលិកមានសុខភាពផ្លូវចិត្តល្អ នោះលទ្ធផលនៃការបំពេញកិច្ចការក៏ល្អផងដែរ។

បញ្ហាផ្លូវចិត្តដែលនឹងរៀបរាប់ក្នុងផ្នែកខ្លឹមសារបន្ទាប់នេះ គ្រាន់តែជាបញ្ហាផ្លូវចិត្តមួយចំនួនប៉ុណ្ណោះ ដែលត្រូវបានគេសង្កេតឃើញភាគច្រើន តែងកើតមានក្នុងការបំពេញការងារ រាប់ទាំងការងារក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន។ ប៉ុន្តែដោយសារ បញ្ហាសុខភាពផ្លូវចិត្តមានលក្ខណៈទូលំទូលាយ និងច្រើនប្រភេទ និង ច្រើនកម្រិតជាងនេះ ដូចនេះវិសាលភាពនៃខ្លឹមសារក្នុងអត្ថបទនេះ នឹងមិនគ្របដណ្តប់ច្រើនជាងនេះនោះទេ។ ខ្លឹមសារដែលនឹងរៀបរាប់នេះមានដូចជា សញ្ញាណសម្គាល់មួយចំនួនដែលអាចកំណត់ដឹងពីភាពមិនប្រក្រតីនៃសុខភាពផ្លូវចិត្ត និងបច្ចេកទេសជាមូលដ្ឋានមួយចំនួន ដែលណែនាំដោយអ្នកចិត្តសាស្ត្រ ដើម្បីយកទៅអនុវត្ត និងថែរក្សាសុខភាពផ្លូវចិត្តឱ្យបានល្អប្រសើរ។ ក៏ប៉ុន្តែសូមចងចាំថា ដើម្បីឱ្យកាន់តែមានភាពស្ទាត់ជំនាញ និងឃើញពីប្រសិទ្ធភាពនៃបច្ចេកទេសដែលមានណែនាំនៅចុងបញ្ចប់នៃផ្នែកនេះ ការអនុវត្តជាប្រចាំ និងទៀងទាត់ ក្នុងរយៈពេលមួយ ពិតជាត្រូវការជាចាំបាច់ ដោយខានមិនបាន។

## III- ខ្លឹមសារ

### និយមន័យ

ការថែទាំសុខភាពផ្លូវចិត្ត គឺជាការអនុវត្តរាល់សកម្មភាព និងបច្ចេកទេសទាំងឡាយណាដែលមានចរិតជាវិជ្ជមានសំដៅថែរក្សាលើកកម្ពស់សុខភាពផ្លូវចិត្តរបស់ខ្លួន ។ សកម្មភាព និងបច្ចេកទេសទាំងនេះ អាចជាអ្វីដែលកើត

ចេញពីទម្លាប់ជាប្រចាំរបស់បុគ្គល ឬពីការរៀនពីមជ្ឈដ្ឋានខាងក្រៅដោយរាប់ទាំងអ្នកដែលមានឯកទេសវិជ្ជាជីវៈខាងផ្នែកសុខភាពផ្លូវចិត្តផងដែរ ។

បញ្ហាសុខភាពផ្លូវចិត្ត ដែលតែងសង្កេតឃើញកើតឡើងជាញឹកញាប់ក្នុងការងារមានដូចជា ការតានតឹងផ្លូវចិត្ត ការនឿយណាយចិត្តកាយ ការថប់បារម្ភ និងការធ្លាក់ទឹកចិត្ត។ ក្នុងផ្នែកខ្លឹមសារនេះ នឹងផ្តោតទៅលើពីរផ្នែកធំៗគឺ មួយផ្នែករៀបរាប់អំពីបញ្ហាផ្លូវចិត្តដែលពាក់ព័ន្ធ សញ្ញាសម្គាល់ទូទៅដែលប្រាប់ថាអ្នកចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមលើសុខភាពផ្លូវចិត្ត និងសញ្ញាសម្គាល់ជាក់លាក់ចំពោះបញ្ហាសុខភាពផ្លូវចិត្តជាក់លាក់មួយចំនួនដូចជា ការតានតឹងចិត្ត និងការនឿយណាយចិត្ត ការថប់បារម្ភ និងការធ្លាក់ទឹកចិត្ត។

### ១- បញ្ហាសុខភាពផ្លូវចិត្ត

នៅពេលដែលជួបប្រទះនូវបញ្ហាផ្សេងៗក្នុងជីវិតប្រចាំថ្ងៃ ទាំងបញ្ហាដែលកើតមានឡើងនៅក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន ទាំងក្នុងនាមជាសមាជិកមួយក្នុងគ្រួសារ ឬក្នុងនាមជាសមាជិកម្នាក់របស់សហគមន៍ ឬសង្គម ការប្រែប្រួលនៃសុខភាពផ្លូវចិត្ត នឹងកើតមានឡើងដោយជៀសមិនផុតក្នុងរយៈពេលមួយ ។ ក្រោយរយៈពេលមួយ ការប្រែប្រួលនៃសុខភាពផ្លូវចិត្តនេះអាចនឹងត្រឡប់មកសភាពប្រក្រតីវិញ សម្រាប់មនុស្សខ្លះ ប៉ុន្តែសម្រាប់មនុស្សមួយចំនួនទៀតអាចត្រូវការពេលវេលាយូរជាងនេះ ឬអាចត្រូវការ ការផ្តល់ ការជួយគាំទ្រផ្នែកផ្លូវចិត្ត ដើម្បីឱ្យការប្រែប្រួលនៃសុខភាពផ្លូវចិត្តអាចវិលត្រឡប់មករកសភាពធម្មតាវិញ។ ឧទាហរណ៍ៈ អ្នកគ្រូសុភី មានអារម្មណ៍ស្រងូតស្រងាត់ប្រហែលជាបី ទៅបួនថ្ងៃហើយ ពេលខ្លះគាត់មិនសូវញ៉ាំអាហារនោះទេ ក្រោយពេលដែលទទួលដំណឹងថាឪពុករបស់គាត់នៅឯស្រុកធ្លាក់ខ្លួនឈឺជាទម្ងន់។ បន្ទាប់ពីឪពុករបស់គាត់បានចេញពីមន្ទីរពេទ្យ អារម្មណ៍របស់គាត់ក៏ចាប់ផ្តើមប្រសើរឡើងវិញ និងអាចបំពេញកិច្ចការងាររបស់គាត់ជាបណ្តើរៗវិញដែរ។

ក្នុងរយៈពេលដែលការប្រែប្រួលនៃសុខភាពផ្លូវចិត្ត មិនអាចត្រឡប់មករកសភាពធម្មតាវិញបាន ការលេចចេញនូវសញ្ញាសម្គាល់ ឬនិយាយក្នុងវាក្យស័ព្ទបច្ចេកទេសថា ជាធាតុសញ្ញាផ្លូវចិត្ត អាចមានការកត់សម្គាល់ដូចខាងក្រោម៖

#### ក- សញ្ញាសម្គាល់ជាទូទៅដែលប្រាប់ថាអ្នកចាំបាច់ត្រូវយកចិត្តទុកដាក់លើសុខភាពផ្លូវចិត្ត

- ការថយចុះនូវ ការគេង ឬពិបាកក្នុងការគេង
- ការថយចុះនូវ ការផ្ចង់ស្មារតី និងបម្រុងប្រយ័ត្ន ក្នុងកិច្ចការបង្រៀន
- ការថយចុះនូវ ចំណង់ចំណូលចិត្ត ឬសកម្មភាពដែលធ្លាប់កម្សាន្ត
- ការថយចុះនូវ ការបំពេញមុខងារប្រចាំថ្ងៃ រាប់ទាំងសកម្មភាពក្រៅពីកិច្ចការងារបង្រៀន
- ការប្រែប្រួលនូវ អារម្មណ៍ ការគិត និងអាកប្បកិរិយា ខុសពីសភាពប្រក្រតី
- ការប្រែប្រួល ជាអវិជ្ជមាន នូវទំនាក់ទំនងជាមួយមិត្តភក្តិ មិត្តរួមអាជីព
- ការកើនឡើងនូវ ការព្រួយបារម្ភ ឬការភ័យខ្លាចដោយឥតមូលហេតុជាក់លាក់
- ការកើនឡើងនូវ អារម្មណ៍ខឹង មួម៉ៅ ឬហួតដល់មិនអាចគ្រប់គ្រងអារម្មណ៍បានចំពោះសិស្ស
- ការកើនឡើងនូវ ការប្រើថ្នាំជក់ ឬគ្រឿងស្រវឹង ឬថ្នាំផ្សេងៗដែលមិនមែនថ្នាំព្យាបាល

#### ខ- សញ្ញាសម្គាល់ជាក់លាក់ទៅលើបញ្ហាសុខភាពផ្លូវចិត្តជាក់លាក់

សញ្ញាសម្គាល់ជាក់លាក់ដែលមានរៀបរាប់នៅទីនេះ ផ្តោតទៅលើសញ្ញាសម្គាល់ ឬអាការៈរំខាន ខាងផ្លូវចិត្តដែលបង្កឡើងដោយបញ្ហាផ្លូវចិត្តជាក់លាក់មួយចំនួនដែលមានដូចជា ការតានតឹងផ្លូវចិត្ត ការថប់បារម្ភ និងការធ្លាក់ទឹកចិត្ត ។

### ខ.១- ការតានតឹងផ្លូវចិត្ត

ការតានតឹងផ្លូវចិត្ត សំដៅដល់រាល់ស្ថានភាព ឬបញ្ហាទាំងឡាយណាដែលយើងជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ ដែលមានប្រភពមកពីការងារ ពីគ្រួសារ ឬសង្គម ហើយធ្វើឱ្យមានការពិបាក ក្នុងការប្រឈមមុខដោះស្រាយ។ វាហាក់ដូចជាហួសពីសមត្ថភាព ឬពីធនធានផ្លូវចិត្តដែលមាន ដើម្បីយកទៅ ដោះស្រាយ។ រោគសញ្ញាជាក់លាក់មួយចំនួន ពាក់ព័ន្ធនឹងការតានតឹងផ្លូវចិត្ត ដែលតែងសង្កេតឃើញកើតឡើង មានដូចជា៖

- នឿយហត់អស់កម្លាំង
- នៅមិនសុខរសាប់រសល់
- មានសភាពតឹងតែងក្នុងចិត្ត
- ស្មុគស្មាញក្នុងចិត្ត
- ឆាប់ភ្លេច
- ឆាប់ខឹង ឆេវឆាវ មួម៉ៅ
- ថយចុះទំនុកចិត្ត
- ថយចុះការផ្ចង់អារម្មណ៍ក្នុងការងារ
- ថយចុះចំណាប់អារម្មណ៍ចំពោះសកម្មភាពដែលធ្លាប់រីករាយ
- ថយចុះចំណង់ផ្លូវភេទ
- អាចវិវត្តទៅជាការនឿយណាយកាយចិត្ត

### ខ.២- ការថប់បារម្ភ

ការថប់បារម្ភរមែងកើតឡើងចំពោះមនុស្សគ្រប់រូប ។ វាជាស្ថានភាពនៃអារម្មណ៍ច្របូកច្របល់ ច្រាស់ច្រាល នៅមិនស្រណុកក្នុងចិត្ត និងអាចមានលាយឡំជាមួយនឹងអារម្មណ៍ភ័យខ្លាច ឬភ័យស្លុតផងដែរ។ ការថប់បារម្ភភាគច្រើនសំដៅដល់ការព្រួយបារម្ភបញ្ហាផ្សេងៗ ដែលទាក់ទងទៅនឹងអនាគតកាល បើទោះបីជាពេលខ្លះវាជាការព្រួយបារម្ភដែលមានលក្ខណៈមិនជាក់លាក់ក៏ដោយ។ ការកត់សម្គាល់សញ្ញាណនៃការថប់បារម្ភ មានដូចខាងក្រោមនេះ ៖

- មានអារម្មណ៍ដូចជាថប់ៗដង្ហើម ឬពិបាកដកដង្ហើម
- ចលនាបេះដូងដើរញាប់ អាចលាយឡំជាមួយអាការៈបែកញើសដៃ ជើង
- អាការៈច្រាស់ច្រាលនៅមិនស្រណុកក្នុងចិត្ត
- ចលនាដង្ហើមដូចជាខ្លីៗ ឬផុតៗ
- មានអារម្មណ៍តឹងណែនក្នុងទ្រូង
- គិតច្រើន ឬព្រួយចិត្តច្រើនពីបញ្ហាផ្សេងៗ រហូតដល់ពិបាកក្នុងការគ្រប់គ្រងខ្លួនឯង
- ការគេងថយចុះ ឬមានការពិបាកក្នុងការគេង
- ឆាប់មានអារម្មណ៍ខឹង មួម៉ៅ
- ឆាប់ភ័យ ស្លុត ឬខ្លាច មិនសមហេតុផល ឬមិនមានមូលហេតុច្បាស់លាស់

### ខ.៣- ការធ្លាក់ទឹកចិត្ត

ការធ្លាក់ទឹកចិត្តសំដៅដល់អារម្មណ៍ប្រែប្រួលទៅរកសភាពក្រៀមក្រំចិត្ត បាត់ចំណូលចិត្ត ឬ សកម្មភាពដែលធ្លាប់ធ្វើ ឬធ្លាប់រីករាយពីមុន។ ការធ្លាក់ទឹកចិត្តក៏ប៉ះពាល់ និងរំខានដល់អារម្មណ៍ ការគិត និងអាកប្បកិរិយា ក្នុងជីវភាពប្រចាំថ្ងៃផងដែរ ។ ការធ្លាក់ទឹកចិត្តក្នុងរយៈពេលមួយយូរ អាចជាប្រភពដែលនាំទៅដល់ការធ្វើអត្តឃាត ។

សញ្ញាសម្គាល់មួយចំនួននៃអាការៈអ្នកដែលមានការធ្លាក់ទឹកចិត្តមានដូចជា៖

- ឆាប់មានអារម្មណ៍អស់កម្លាំង និងហត់នឿយ
- មានអាការៈរំខានផ្នែករាងកាយមិនច្បាស់លាស់
- មានអារម្មណ៍ឆាប់ខឹង ឆាប់អាក់អន់ស្រពន់ចិត្ត
- មានការព្រួយចិត្ត ព្រួយបារម្ភជ្រុល និងក្រៀមក្រំចិត្ត
- យល់ថាខ្លួនហាក់ដូចជាបានធ្វើអ្វីខុស ឬមានវិប្បដិសារី
- បាត់ចំណង់ចំណូលចិត្ត ឬការចាប់អារម្មណ៍ក្នុងសកម្មភាពប្រចាំថ្ងៃ
- ថយចុះការផ្ទង់អារម្មណ៍ គួរឱ្យកត់សម្គាល់
- ថយចុះការគេង និងញ៉ាំ
- មានអារម្មណ៍ឯកោ ឬផ្តាច់ខ្លួន ផ្តាច់ទំនាក់ទំនងចេញពីគេឯង
- មានអារម្មណ៍ហាក់ដូចជាជីវិតគ្មានតម្លៃ
- មានអារម្មណ៍អស់សង្ឃឹមក្នុងជីវិត
- មានគំនិត ឬធ្លាប់ប៉ុនប៉ង បញ្ចប់ជីវិតខ្លួន

## ២- បច្ចេកទេស និងវិធីសាស្ត្រក្នុងការថែទាំសុខភាពផ្លូវចិត្ត

### ក- ចំណុចគន្លឹះ និងវិធីសាស្ត្រសាមញ្ញៗទូទៅមួយចំនួន ក្នុងការថែទាំសុខភាពផ្លូវចិត្ត

បញ្ហាសុខភាពផ្លូវចិត្ត ក្នុងកម្រិតដំបូងៗភាគច្រើនអាចវិវត្តទៅរកភាពប្រសើរឡើងវិញដោយខ្លួនឯង ក្នុងរយៈពេលមួយ ។ ការអនុវត្តនូវទម្លាប់ ឬវិធីសាស្ត្រដែលមានលក្ខណៈវិជ្ជមាន សម្រាប់ធ្វើ ឱ្យសុខភាពផ្លូវចិត្តបានល្អប្រសើរឡើងវិញ គឺជាអាកប្បកិរិយាដ៏ប្រពៃ និងរឹតតែជួយជំរុញឱ្យដំណើរវិវត្តន៍ទៅរកភាពប្រសើរឡើងដូចប្រក្រតីវិញ កាន់តែលឿន។ វិធីសាស្ត្រសាមញ្ញមួយចំនួន ដែលគ្រូបង្រៀនអាចធ្វើបាន មានដូចខាងក្រោមនេះ៖

- ធ្វើលំហាត់ប្រាណឱ្យបានទៀតទាត់
- ចំណាយពេលសម្រាកលំហែកាយឱ្យបានច្រើន
- ថ្លឹងថ្លែងតុល្យភាពរវាង ការងារ គ្រួសារ និងឯកជនភាព
- ចំណាយពេលនៅជាមួយគ្រួសារ ឬមិត្តភក្តិដែលទុកចិត្ត
- ទទួលទានដំណេក និងអាហារដែលមានជីវជាតិ ឱ្យបានគ្រប់គ្រាន់
- ធ្វើសកម្មភាពដែលនាំឱ្យមានភាពសប្បាយរីករាយ
- ដាក់អាទិភាពការងារ និងរក្សាដែនកំណត់ការងារ គ្រួសារ និងពេលវេលាផ្ទាល់ខ្លួន
- ស្វែងរកប្រភពគាំទ្រពីខាងក្រៅ អាចជាមិត្តភក្តិជិតស្និទ្ធ មិត្តរួមអាជីព ឬអ្នកដែលជាទីទុកចិត្ត ឬជាទីគោរព ដើម្បីជជែកពីបញ្ហាដែលមានក្នុងចិត្ត
- អនុវត្តវិធីសាស្ត្រលៃលកដោះស្រាយបញ្ហាដែលមានលក្ខណៈវិជ្ជមាន ដូចជាអនុវត្តលំហាត់ដកដង្ហើម លំហាត់សម្រាកចិត្ត-កាយ លំហាត់នឹកស្រម៉ៃក្នុងចិត្ត និងការធ្វើសមាធិជាដើម។

ឧទាហរណ៍៖ អង្គុយ និងប្រើអារម្មណ៍ស្ងប់តាំងចិត្តទៅលើអ្វីមួយ ដូចជា ការកំសាន្តនៅព្រៃភ្នំ និងសមុទ្រ ។

### ខ- បច្ចេកទេសជាក់លាក់មួយចំនួន ដើម្បីកាត់បន្ថយបញ្ហាពាក់ព័ន្ធនឹងផ្លូវចិត្តក្នុងកិច្ចការបង្រៀន និងសម្រាប់ថែទាំសុខភាពផ្លូវចិត្ត

មានបច្ចេកទេសតាមបែបចិត្តសាស្ត្រជាច្រើន ដែលបានរកឃើញថាមានប្រសិទ្ធភាព និងត្រូវបានណែនាំឱ្យប្រើប្រាស់ដោយអ្នកឯកទេសខាងផ្លូវចិត្ត ។ គោលបំណងសំខាន់មួយនៃការណែនាំឱ្យប្រើប្រាស់បច្ចេកទេសទាំងនោះ

គឺដើម្បីជួយធ្វើឱ្យអ្នកអនុវត្តកាត់បន្ថយនូវការរំខានផ្លូវចិត្ត ជួយធ្វើ ឱ្យសភាពផ្លូវចិត្តបានសម្រាក និងស្ងប់ល្អដែលជាមូលហេតុនាំឱ្យមានលក្ខណៈប្រសើរឡើងខាងសុខភាពផ្លូវចិត្ត ។ សុខភាពផ្លូវចិត្តប្រសើរឡើង ក៏ជា មូលហេតុដ៏ចំបងមួយដែលចូលរួមចំណែកធ្វើឱ្យសុខភាពផ្លូវកាយកាន់តែរឹងមាំល្អ ភាពស៊ាំក្នុងរាងកាយកាន់តែប្រសើរ នោះប្រសិទ្ធភាពកិច្ចការងារបង្រៀន ក៏កាន់តែខ្ពស់។ ដោយសារអ្វីដែលនឹងណែនាំខាងក្រោមនេះជាបច្ចេកទេស នោះអ្នកអនុវត្តតម្រូវឱ្យចំណាយពេលវេលា និងការអត់ធ្មត់ក្នុងរយៈពេលមួយ ដើម្បីនឹងអាចឃើញលទ្ធផល ដែលជាផ្លែផ្កាចេញពីការអនុវត្តបច្ចេកទេសថែទាំសុខភាពផ្លូវចិត្ត និងកាត់បន្ថយ ក៏ដូចជាបង្ការបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តផងដែរ ។ បច្ចេកទេសដែលនឹងណែនាំនៅផ្នែកបន្ទាប់នេះ នឹងលើកយកមកចំនួនបីប៉ុណ្ណោះគឺ លំហាត់ដកដង្ហើម ការធ្វើសមាធិដាក់ចិត្តឱ្យមូល កន្លែងសុវត្ថិភាពក្នុងចិត្ត ។

### ខ.១ លំហាត់ដកដង្ហើម

មានរបៀបជាច្រើនត្រូវបានអនុវត្តក្នុងបច្ចេកទេសដកដង្ហើម ។ លំហាត់ដកដង្ហើមដែលណែនាំនៅទីនេះ ជាលំហាត់ដកដង្ហើមសាមញ្ញធម្មតា និងងាយស្រួលអនុវត្ត ប៉ុន្តែមានប្រសិទ្ធភាពល្អ។ ការអនុវត្តលំហាត់ដកដង្ហើមនេះ អាចធ្វើក្នុងឥរិយាបថ អង្គុយនៅលើកៅអី ឬដេកនៅលើផ្ទៃរាបស្មើក៏បាន ដោយការបិទភ្នែក ឬបើកភ្នែកក៏បាន ប៉ុន្តែការបិទភ្នែក ជួយឱ្យការកត់សម្គាល់លើចលនាដង្ហើមបានងាយស្រួលជាង ។ ការអនុវត្តជាជំហានៗ ក្នុងការធ្វើលំហាត់ដកដង្ហើមសាមញ្ញនេះ មានដូចខាងក្រោមនេះ៖



1. *ដកដង្ហើមតាមធម្មតាឱ្យបាន៣ ទៅ ៤ដងសិន តាមសម្រួល មិនបង្ខំ*
2. *បន្ទាប់មក ចាប់ផ្តើមផ្តោតលើចលនាចេញ ចូលនៃខ្យល់ដង្ហើមតាមច្រមុះ*
3. *នៅពេលដកដង្ហើមចូល សម្គាល់ថាមានខ្យល់ដង្ហើមចូលតាមច្រមុះ*
4. *នៅពេលដកដង្ហើមចេញ សម្គាល់ថាមានខ្យល់ដង្ហើមចេញតាមច្រមុះ*
5. *បន្តអនុវត្តបែបនេះ ក្នុងលក្ខណៈតាមសម្រួល មិនបង្ខំ។ ប្រសិនបើមានការគិត ឬអារម្មណ៍ ឬរូបភាពក្នុងចិត្តដែលមានលក្ខណៈរំខានណាមួយកើតឡើង គ្រាន់តែសម្គាល់វា ហើយចាប់ផ្តើមបង្វែរការកត់សម្គាល់មករកចលនាចេញចូលនៃខ្យល់ដង្ហើមតាមច្រមុះវិញ*
6. *បន្ទាប់ពីអនុវត្តបាន ២ ទៅ ៣នាទី អ្នកអាចផ្លាស់ប្តូរចលនាដង្ហើម ដោយធ្វើការដកដង្ហើម ចូល ឬ ចេញឱ្យបានយូរជាងមុនបន្តិច និងបន្តកត់សម្គាល់ទៅលើខ្យល់ដង្ហើមចេញ ចូលតាមច្រមុះដូចមុនដដែល។*

### ខ.២ ការធ្វើសមាធិដាក់ចិត្តឱ្យមូល

ក៏មិនខុសពីបច្ចេកទេសដកដង្ហើមដែរ បច្ចេកទេសក្នុងការធ្វើសមាធិមានច្រើនប្រភេទ និងច្រើនរបៀប។ អ្វីដែលដកស្រង់យកមកណែនាំនៅទីនេះ គឺប្រភេទសមាធិមួយដែលមានឈ្មោះថា ការធ្វើ សមាធិដាក់ចិត្តឱ្យមូល។ ការធ្វើសមាធិប្រភេទនេះ ផ្តោតការកត់សម្គាល់ទៅលើកម្មវត្ថុមួយជាក់លាក់ ។ ការរៀបចំឥរិយាបថសម្រាប់អនុវត្តបច្ចេកទេសនេះ គឺក្នុងឥរិយាបថអង្គុយពែនភ្នែន ដោយបិទភ្នែក ឬបើកភ្នែកក៏បាន ។ ការអនុវត្តជាជំហានៗ ក្នុងការធ្វើសមាធិដាក់ចិត្តឱ្យមូល មានដូចខាងក្រោមនេះ៖

1. *អង្គុយនៅទីកន្លែងណាមួយដោយផ្ទាល់ ឬទ្រាប់ពូក ដោយខ្នងដាក់ឱ្យត្រង់*
2. *ជើងទាំងពីរអាចដាក់ខ្វែងគ្នា (ពែនភ្នែន) ហើយដៃទាំងពីរដាក់ពីលើគ្នា នៅចន្លោះជើង*
3. *ជ្រើសរើសយកវត្ថុ ឬរូបភាពអ្វីមួយ ឬរបស់អ្វីមួយក្នុងចិត្ត ដែលមានន័យល្អសម្រាប់អ្នក*
4. *បន្ទាប់មក ផ្តោត...រកត់សម្គាល់ទៅលើ៖*
   - *ផ្នែកនីមួយៗ ឬផ្នែកតូចៗនៃវត្ថុនោះ*
   - *ទម្រង់ ពណ៌*



- *ទំហំ កម្រាស់ ទម្ងន់*
- *ប្រភេទវត្ថុធាតុដើមដែលយកមកធ្វើ*

5. *គ្រាន់តែផ្តោតការកត់សម្គាល់ ប្រៀបដូចជាអ្នកកំពុងធ្វើការសង្កេតផ្ទាល់ ដោយមិនធ្វើការវិនិច្ឆ័យ ទៅលើកម្មវត្ថុនោះឡើយ។*

### ខ.៣ កន្លែងសុវត្ថិភាពក្នុងចិត្ត

លំហាត់ កន្លែងសុវត្ថិភាពក្នុងចិត្ត គឺជាប្រភេទមួយនៃបច្ចេកទេសនឹកស្រម៉ៃក្នុងចិត្ត។ ការអនុវត្តបច្ចេកទេសនេះអាចធ្វើទៅបានក្នុងឥរិយាបថអង្គុយ ឬដេកក៏បាន។ អ្នកអនុវត្តតម្រូវឱ្យនឹករកទីកន្លែងណាមួយដែលធ្លាប់បានទៅដល់ ហើយធ្វើឱ្យមានអារម្មណ៍ស្ងប់ស្ងាត់ល្អ និងមានសុវត្ថិភាព ដោយមិនមានអ្នករំខាន។ ប្រសិនបើមិនមានកន្លែងណាមួយនោះទេ អ្នកអនុវត្តអាចបង្កើតទីកន្លែងនោះនៅក្នុងចិត្ត ក្នុងពេលអនុវត្តនេះតែម្តង ដែលជាទីកន្លែងធ្វើឱ្យមានអារម្មណ៍ស្ងប់ស្ងាត់ល្អ និងមានសុវត្ថិភាព (ឧទាហរណ៍ អាចជាព្រៃភ្នំ ឬមាត់សមុទ្រ ឬជាកន្លែងផ្សេងៗទៀត)។ ការអនុវត្តបច្ចេកទេសប្រភេទ ងាយធ្វើឱ្យមានអារម្មណ៍ស្ងប់ល្អ ប្រសិនបើអនុវត្តដោយបិទភ្នែក ។ ការអនុវត្តជាជំហានៗនៃបច្ចេកទេស កន្លែងសុវត្ថិភាពក្នុងចិត្ត មានដូចខាងក្រោមនេះ៖

1. *នឹកទៅដល់ទីកន្លែងដែលធ្លាប់ទៅដល់នោះ ឬជាកន្លែងដែលបង្កើតនៅក្នុងចិត្ត (ជាកន្លែងដែលធ្វើឱ្យមានអារម្មណ៍ស្ងប់ល្អ មានសុវត្ថិភាព និងមិនមានអ្នករំខាន)*
2. *បន្ទាប់មកចាប់ផ្តើមនឹកស្រម៉ៃដល់អ្វីៗ ដែលអាចឃើញនៅជុំវិញទីនោះ (នៅខាងមុខ ខាងឆ្វេង ខាងស្តាំ និងខាងក្រោយ)*



3. *បន្ទាប់មក កត់សម្គាល់ទៅលើពណ៌ផ្សេងៗដែលមាននៅទីនោះ ទៅលើរូបរាង និងទម្រង់ផ្សេងៗដែលមាន*
4. *បន្ទាប់មកទៀត កត់សម្គាល់ទៅលើ សំឡេងដែលអាចឮនៅទីនោះ (អាចជាសំឡេងខ្យល់បក់ សំឡេងសត្វយំ ឬសំឡេងទឹកធ្លាក់...) និងសម្គាល់ថាសំឡេងនោះ នៅជិត ឬឆ្ងាយប៉ុណ្ណា*
5. *បន្ទាប់មក កត់សម្គាល់ទៅលើ ក្លិនល្អៗអ្វីដែលអាចស្រង់បាន (អាចជាក្លិនផ្កា ឬក្លិនរុក្ខជាតិ...)*
6. *បន្ទាប់មកទៀត កត់សម្គាល់ទៅលើ អាកាសធាតុដែលប៉ះលើរាងកាយរបស់អ្នក (អាចត្រជាក់ក្តៅ ឬល្មម)*
7. *និងចុងក្រោយ កត់សម្គាល់ទៅលើអារម្មណ៍ល្អដែលមានក្នុងចិត្ត រួចហើយដកដង្ហើមតាមសម្រួល យឺតៗ មួយៗ អត់បង្ខំ និងបើកភ្នែកបន្តិចម្តងៗ។*

**តើត្រូវអនុវត្តបច្ចេកទេសទាំងនេះញឹកញាប់ប៉ុណ្ណា ?**

១ទៅ២ដងក្នុងមួយថ្ងៃ ឬអាចច្រើនជាងនេះ នៅពេលដែលភាពថ្មឹកកាន់តែកើនឡើង ។ ក្នុងពេល អនុវត្តម្តងៗ អាចចាប់ផ្តើមចំណាយពេលពី៣នាទី ទៅ៥នាទី ឬអាចកាន់តែយូរជាងនេះ ប្រសិនបើអាចធ្វើបាន ។ ប្រសិទ្ធភាពកាន់តែមាន នៅពេលដែលការអនុវត្តកាន់តែទៀងទាត់ ក្រោយរយៈពេលមួយ ។

## IV- សន្និដ្ឋាន

ក្នុងភារកិច្ចជាអ្នកបណ្តុះបណ្តាលធនធានមនុស្ស ដែលជាទំពាំងស្នងឬស្សីរបស់ជំនាន់ក្រោយ ទាមទារនូវ ការខិតខំប្រឹងប្រែង ភាពអត់ធ្មត់ និងសុខុមាលភាពល្អដោយរាប់ទាំងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្ត។ គុណភាព និងប្រសិទ្ធភាពក្នុងការបំពេញភារកិច្ចដ៏ធំមួយនេះ អាចឡើងខ្ពស់ ឬថយចុះ ក៏អាស្រ័យទៅលើកម្រិតនៃសុខភាពផ្លូវចិត្ត ផងដែរ។ ការថែទាំសុខភាពផ្លូវចិត្ត និងបង្ការក៏ដូចជាកាត់បន្ថយបញ្ហាដែលអាចមានពាក់ព័ន្ធនឹងផ្លូវចិត្ត ជាកត្តារួមចំណែកមួយយ៉ាងសំខាន់ ។ មានសញ្ញាណសម្គាល់មួយចំនួន ដែលកើតចេញពីការប្រែប្រួលនៃ សុខភាពផ្លូវចិត្តរបស់គ្រូបង្រៀន ក្រោយពេលមានប្រតិកម្មតបតទៅនឹងស្ថានភាពនៃការតានតឹងផ្លូវចិត្ត ការថប់បារម្ភ ឬការធ្លាក់ទឹកចិត្តដែលអាចកើតមានឡើងក្នុងការងារជាគ្រូបង្រៀន។

សមត្ថភាពផ្លូវចិត្តរបស់មនុស្សភាគច្រើន អាចធ្វើឱ្យការផ្លាស់ប្តូរមិនប្រក្រតីនៃសភាពផ្លូវចិត្តនេះ ត្រឡប់មកសភាពធម្មតាវិញ ក្រោយរយៈពេលដ៏សមស្របមួយ។ ការអនុវត្ត ឬប្រណិប័តន៍វិធីសាស្ត្រសាមញ្ញៗ និងបច្ចេកទេសតាមបែបចិត្តសាស្ត្រមួយចំនួន អាចរឹតតែជួយធ្វើឱ្យដំណើរវិវត្តន៍ទៅរកភាពប្រក្រតីនៃសភាពផ្លូវចិត្តកាន់តែលឿន។ ទោះបីជាយ៉ាងណាក៏ដោយ បុគ្គលខ្លះអាចត្រូវការអ្នកឯកទេស ក្នុងផ្នែកចិត្តសាស្ត្រដែលអាចជា អ្នកចិត្តសាស្ត្រ អ្នកព្យាបាលតាមបែបចិត្តសាស្ត្រ ឬវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា ជួយបន្ថែមទៀត នៅពេលដែលការជួយខ្លួនឯងតាមរយៈការអនុវត្តវិធីសាស្ត្រសាមញ្ញៗ ឬការអនុវត្តបច្ចេកទេសតាមបែបចិត្តសាស្ត្រ ដោយខ្លួនឯងហើយមានប្រសិទ្ធភាពតិចតួច ។

### សំណួរ

1. តើអ្វីខ្លះអាចជាហេតុការណ៍ដែលនាំឱ្យមានការតានតឹងផ្លូវចិត្ត ក្នុងភារកិច្ចជាគ្រូបង្រៀន?
2. តើការធ្លាក់ទឹកចិត្ត ក្នុងរយៈពេលមួយយូរ និងប្រសិនបើមិនមានការជួយតាមបែបចិត្តសាស្ត្រនោះទេ អាចនឹងមានគ្រោះថ្នាក់អ្វីខ្លះកើតឡើង?
3. តើការអនុវត្តបច្ចេកទេសតាមបែបចិត្តសាស្ត្រ ក្នុងការជួយថែទាំសុខភាពផ្លូវចិត្ត ត្រូវការពេលវេលា រយៈពេលប៉ុណ្ណាដែរ? ហើយអ្វីដែលចាំបាច់បំផុតដើម្បីធ្វើឱ្យការអនុវត្តបច្ចេកទេសទាំងនោះមានប្រសិទ្ធភាព?

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មហាវិទ្យាល័យអប់រំផ្តល់ការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បណ្ឌិតដូចខាងក្រោម៖

- វិញ្ញាបនបត្រអប់រំកុមារតូច
- វិញ្ញាបនបត្រអប់រំបឋមសិក្សា

- បរិញ្ញាបត្រអប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រអប់រំ ឯកទេសអប់រំពេញមួយជីវិត
- បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសកម្មវិធីសិក្សានិងការបង្រៀនកម្រិតកុមារតូច

- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអប់រំពេញមួយជីវិត

- បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍការអប់រំ
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍធនធានមនុស្ស និងអប់រំពេញមួយជីវិត

**មហាវិទ្យាល័យអប់រំក៏មានផ្តល់សេវាប្រឹក្សាយោបល់ និងស្រាវជ្រាវអប់រំផងដែរ។**

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនខាងក្រោម

www.facebook.com/rupp.edu.kh

www.rupp.edu.kh/fed/

Facebook Page
Faculty of Education